

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពី ពុទ្ធសាសនបណ្ឌិត្យ


ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន ៖

ទីប្រឹក្សា : **ហៀន ចណ្ឌារត្ន**

នាយកការផ្សាយ : **ឈន អៀម**

និពន្ធនាយក : **យី ធន់**

និពន្ធនាយករង : **ឱម ខែម**

គណៈកម្មការនិពន្ធ

សម្ដេចព្រះធម្មលិខិត **លាស់ ឡាយ**, ព្រះពុទ្ធឃោសាចារ្យ **ហេង លាងហោ**

លោក **ម៉ែន ប្រាង**, លោក **អាំ ធន**

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

នៃក្រសួងធម្មការ និងសាសនា . ភ្នំពេញ

## ごあいさつ

この本は、世界宗教者平和会議日本委員会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました。

この本が、日本の宗教者とカンボジアの人々との友情のきずなとなり、カンボジアの宗教と文化の発展に貢献できれば幸いです。

## ACKNOWLEDGEMENT

The Kampuja Surya Magazine is specially printed as a cooperative project of the Japanese Committee of the World Conference on Religion and Peace (WCRP) and Japan Sotoshu Relief Committee (JSRC).

We pray that this magazine would contribute to the Friendship with Cambodian people and their religious and cultural preservation.

## និវេទនកថា

ទស្សនាវដ្ដីកម្ពុជសុរិយានេះ ត្រូវបានបោះពុម្ពឡើងជាពិសេស ទុកដូចជាគម្រោងការងារ របស់គណៈកម្មាធិការជប៉ុននៃក្រុមប្រឹក្សាពិភពលោកស្ដីពីសាសនានិងសន្តិភាព (WCRP) ហើយនិងគណៈកម្មាធិការជំនួយសូតូស៊ូជប៉ុន (JSRC) ។

យើងខ្ញុំអធិដ្ឋាន សូមឱ្យទស្សនាវដ្ដីនេះ បានជាវិភាគមានរក្សាមិត្តភាពជាមួយប្រជាជនកម្ពុជា និងថែរក្សាសម្បត្តិសាសនានិងវប្បធម៌របស់ប្រជាជនកម្ពុជា ។

# មាតិកាអត្ថបទ

## I. អក្សរសាស្ត្រពុទ្ធសាសនា ៖


- អំពីប្រវត្តិព្រះពុទ្ធឃោសៈ ( ឈេន អៀម ) ១
- អហឹង្សា និងដំណោះស្រាយជម្លោះ ( ហេង មណីចិន្តា ) ២៩
- មាឃបូជា ( ម៉ែន ប្រាង ) ៤៦


## II. អក្សរសាស្ត្រទូទៅ ៖


- សុភាសិតច្បាប់ស្រី សុត្តន្តប្រីជា ឥន្ទ ៥៤
- វាក្យស័ព្ទសំស្ក្រឹតដំបូងក្នុងភាសាខ្មែរបុរាណ (បណ្ឌិត ឡុង សៀម) ៦៥
- ព្រះពុទ្ធសាសនា និងការអប់រំសីលធម៌ខ្មែរ ( ព្រឹទ្ធាចារ្យ ឆេង ផុន ) ៩១
- ឥទ្ធិពលរបស់សត្វមកលើជីវភាពខ្មែរ ( មៀច ប៉ុណ្ណ ) ១០២
- ខ្លាច « ខ្លាមិនខ្លាច ខ្លាចអាចម៍ខ្លា » ( វណ្ណ ស៊ុនហេង ) ១១៥
- ពាក្យទំនៀមខ្មែរបុរាណ ( មៀច ប៉ុណ្ណ ) ១១៧
- សេចក្តីជូនដំណឹងអំពីលទ្ធផលនៃចម្លើយកំណាព្យប្រស្នា ១១៩
- ចម្លើយកំណាព្យប្រស្នា ( តឹក ប៊ុនឈឿង ) ១២៣
- * កំណាព្យប្រស្នា ( វណ្ណ ស៊ុនហេង ) ១២៦


## III. កំណត់ និង ប្រវត្តិការណ៍ ៖


- ការបែងចែកគម្ពីរព្រះត្រៃបិដ ( ត ) ១២៧
- បេសកកម្មលោក យី ធន់ នៅទីក្រុងឡាហ័រ ( ប៉ាគីស្ថាន ) ១៣១
- គណៈប្រតិភូអង្គការជំនួយ ស្វូត្ស៊ូ ជប៉ុន នៅសៀមរាប ១៣៧
- ពិធីសម្ពោធបើកបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ១៤៣

# អំពីប្រវត្តិព្រះពុទ្ធឃោសៈ

រៀបរៀងដោយ **ឈន អៀម**

ព្រះពុទ្ធឃោសៈ គឺជាអដ្ឋកថាចារ្យ ដ៏ល្បីល្បាញបំផុត នៃលទ្ធិពុទ្ធសាសនាថេរវាទ ។ លោកកើតនៅក្នុងប្រទេសឥណ្ឌា និងត្រូវបានចិញ្ចឹមបីបាច់តាមប្រពៃណីព្រាហ្មណ៍ ។ លោកបានចេះដឹងអក្សរសាស្ត្រឥណ្ឌាយ៉ាងច្បាស់លាស់ ហើយចេះយ៉ាងស្ទាត់ជំនាញនូវប្រព័ន្ធវេយ្យាករណ៍នៃភាសាបាណិនិ ។ មុនពេលលោកចូលកាន់ពុទ្ធសាសនា, លោកគឺជាអ្នកប្រតិបត្តិតាមប្រព័ន្ធបតញ្ជលី ។ លោកមិនគ្រាន់តែចេះយោគៈប៉ុណ្ណោះទេ, ប៉ុន្តែ លោកចេះទាំងប្រព័ន្ធសំខ្យាផងដែរ ។ លោកបានសិក្សាយ៉ាងល្អិតល្អន់អក្សរសាស្ត្រអភិធម្ម ។ លោកបានបង្កើតចំណេះដឹងយ៉ាងសម្បូរផ្តល់ឱ្យអក្សរសាស្ត្រពុទ្ធនិយម ដោយបានទាញយកសម្ភារៈខ្លឹមសារថ្មីៗពីប្រភពដទៃទៀត ។ លោកបានសិក្សាយ៉ាងស្ទាត់ជំនាញនូវអក្សរសាស្ត្រនៃប្រទេសសីឡង់ (ស្រីលង្កា) ហើយជាអ្នកប្រាជ្ញម្នាក់ដ៏មានកេរ្តិ៍ឈ្មោះល្បីល្បាញបំផុតនៃវត្តមហាវិហារ នៅអនុរាធបុរៈ ។ លោកបានសិក្សាលទ្ធិពុទ្ធសាសនាយ៉ាងជ្រៅជ្រះ ហើយជាអ្នកគាំទ្រដ៏ចម្បងម្នាក់នៃលទ្ធិពុទ្ធសាសនា ។ លោកក៏បានចេះដឹងលទ្ធិពុទ្ធ-សាសនាមហាយានដែរ ដែលលោកទុកជាវេទល្លវាទ ឬវេទុល្លវាទ ហើយលោកក៏បានចេះចាំទស្សនវិជ្ជាដ៏ចម្បងរបស់ពុទ្ធសាសនាមហាយាន ដែលលោកទុកជាលទ្ធិនៃមហាសុញ្ញតាវាទ (The great void) ។ នៅក្នុងអដ្ឋកថារបស់លោក ព្រះពុទ្ធឃោសៈ បានបញ្ចូលយ៉ាងច្រើន និងយ៉ាងសំខាន់នូវរឿងនិទាន, រឿងល្បើក, រឿងប្រជាប្រិយ និងប្រពៃណី, ប្រវត្តិសាស្ត្រ និងជីវប្រវត្តិ, ក្រៅពីពាក្យបកស្រាយផ្ទាល់មាត់ និងការពិភាក្សាខាងទស្សនវិជ្ជា ។ អដ្ឋកថារបស់លោកត្រូវបានគេចាត់ទុកជាឃ្លាំងដ៏ធំមួយ ដែលអ្នកប្រវត្តិសាស្ត្រនៃសង្គមវិជ្ជាឥណ្ឌាបុរាណ អាចទាញយក

ខ្លឹមសារមិនចេះអស់ មិនចេះហើយ ។

លោកស្រី រិស ដាវីដ (Mrs. Rhys Davids), មានប្រសាសន៍ថា ព្រះពុទ្ធឃោសៈ ហាក់ប្រដូចបាននឹងពួកទស្សនវិទូអឺរ៉ុប មុនលោកហ៊្យូម (Hume) និងលោកហាតឡេ (Hartley), បើនិយាយទាក់ទងនឹងបញ្ហាញាណតំណាង (Representative cognition) ឬបញ្ហាភ្ជាប់មតិមួយទៅមតិមួយទៀត តាមការរំលឹកឃើញ (The association of ideas) ។ ដរាបណាពុទ្ធសាសនា នៅតែជាជំនឿប្រចាំជីវិតក្នុងចំណោមមនុស្សជាតិ, ដរាបនោះ ព្រះពុទ្ធឃោសៈ នឹងនៅតែត្រូវបានគេរំលឹកគុណដោយសេចក្ដីគោរព និងកតញ្ញូតាធមិជាដរាប ។ លោកបានធ្វើអ្វីៗទាំងអស់សម្រាប់*ព្រះត្រៃបិដកជាភាសាបាលី* ដូចជាអ្វីៗទាំងអស់ ដែលលោកសាយនៈ (Sāyana) បានធ្វើ សម្រាប់*អក្សរសាស្ត្រវេទ* ឬ លោកសិលង្កាធ្វើសម្រាប់*អាគមសាសនាជេន* (the Jain Āgama) ដូច្នោះ ។ ស្នាដៃរបស់លោកគឺជាកិច្ចការមួយដ៏មានផលប្រយោជន៍ណាស់ ។ លោកមានព្រះជន្មវែងដើម្បីបានឃើញការងាររបស់លោកទទួលរង្វាន់ និងដើម្បីបានទទួលក្រេបនូវកិត្តិស័ព្ទដ៏ទូលំទូលាយ ដែលលោកស័ក្តិសមទទួលបំផុត ។

យោងតាមប្រពៃណី ជំនឿ របស់ភូមា, គេបាននិយាយថាព្រះពុទ្ធឃោសៈបានកើតនៅក្នុងប្រទេសឥណ្ឌាភាគខាងជើង ក្នុងសតវត្សទី ៥ នៃគ្រិស្តសករាជ ។ នៅមិនឆ្ងាយប៉ុន្មានពីដើមពោធិ៍ដ៏ធំមួយដើមនៅគយា មានភូមិមួយឈ្មោះឃោសៈ ឬឃោសគាម, ពីព្រោះ ភូមិនេះត្រូវបានពួកគង្វាលគោដ៏មានគ្នាយ៉ាងច្រើនរស់នៅយ៉ាងតឹកកង ។ ពេលនោះ មានស្ដេចមួយអង្គសោយរាជ្យ ទ្រង់មានព្រាហ្មណ៍បុរោហិតម្នាក់ឈ្មោះ កេសី ។ ភរិយា របស់ព្រាហ្មណ៍កេសី ឈ្មោះនាង កេសនី ។ ព្រះពុទ្ធឃោសៈ គឺជាបុត្ររបស់លោកទាំងពីរនោះ ។ ឈ្មោះរបស់លោកគឺឃោសៈ ។ នៅពេលនោះ គេពិបាកយល់ដឹង ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធណាស់

ពីព្រោះពាក្យប្រៀនប្រដៅនោះត្រូវបានគេសរសេរជាភាសាសីហឡៈ ។ គេនិយាយថា កាលនោះឃោសះ ទើបតែមានអាយុប្រាំពីរឆ្នាំ, លោកបានចេះចាំយ៉ាងស្ទាត់វេទទាំងបី ។ ព្រាហ្មណ៍កេសី ជាអ្នកបង្រៀនចំណេះនៅក្នុងគម្ពីរវេទ ។ ថ្ងៃមួយលោកបានទៅគាល់ព្រះរាជា ជាមួយនឹងកូនរបស់លោក, ហើយនៅពេលកំពុងបង្រៀនព្រះរាជា, លោកបានប្រទះវគ្គមួយ ដែលនៅក្នុងនេះ មានបង្កប់ចំណុចអាថ៌កំបាំងមួយចំនួន ។ លោកពុំអាចបកស្រាយសេចក្ដីនៃអត្ថបទនោះបាន ហើយក៏សុំព្រះរាជានុញ្ញាតត្រឡប់មកផ្ទះវិញ ។ ឃោសះបានជួយឪពុកគាត់ឱ្យរកឃើញអត្ថន័យកំបាំងរបស់ចំណុចទាំងឡាយនោះ ហើយព្រាហ្មណ៍កេសី មានសេចក្ដីត្រេកអរយ៉ាងខ្លាំង ។

ឃោសះ បានទូលសុំព្រះមហាថេរមួយអង្គ ឱ្យលោកសូធ្យវេទទាំងបី (ត្រៃវេទ) ។ ឃោសះបានស្ដាប់ហើយ បានជាប់ស្នេហ៍ចំពោះការសូធ្យវេទរបស់ព្រះមហាថេរ ហើយក៏ចង់ដឹងពីជំនឿប្រតិបត្តិរបស់លោក ។ ពេលនោះ ព្រះមហា-ថេរ ក៏ចាប់សូធ្យខ្លឹមសារនៃព្រះអភិធម្ម, ដោយយោងជាពិសេសដល់កុសលា ធម្មា, អកុសលា ធម្មា, អព្យាកតា ធម្មា ។ ព្រះមហាថេរក៏បានពន្យល់ផងដែរ នូវបញ្ហាពិបាកខ្លះៗ នៃទស្សនវិជ្ជាពុទ្ធសាសនា ។ ក្នុងពេលកំពុងស្ដាប់សេចក្ដីបកស្រាយបំភ្លឺព្រះធម៌របស់ព្រះពុទ្ធ, ឃោសះមានសេចក្ដីរីករាយយ៉ាងធំធេង ហើយបន្ទាប់មកក៏បានជម្រាបឪពុកម្ដាយ អំពីបំណងរបស់ខ្លួន ដើម្បីបោះបង់ជីវភាពជាគ្រហស្ថ ។ ឃោសះបាននិយាយថា ៖ « ខ្ញុំនឹងសុំផ្នួសពីព្រះមហាថេរ រៀនសូធ្យធម៌របស់ព្រះពុទ្ធ, ហើយបន្ទាប់មក ខ្ញុំនឹងត្រឡប់មកផ្ទះវិញ, ហើយសឹក » ។ ឃោសះត្រូវបានបំបួស ហើយទទួលតចបញ្ចកកម្មដ្ឋាន[១] ។ លោកក៏ចាប់ផ្ដើមពិចារណាលើធម៌នេះ ហើយបាន

(១) កម្មដ្ឋាន ដែលកំណត់យកអាការៈក្នុងរូបកាយ ត្រឹមតែប្រាំ គឺ សក់, រោម, ក្រចក, ធ្មេញ, ស្បែក មកពិចារណាឱ្យឃើញច្បាស់ថាជាបដិកូល គួរខ្ពើម ... ។

ក្លាយជាអ្នកតាំងនៅស៊ប់ក្នុងព្រះត្រៃសរណគមន៍ ។ ក្រោយមក លោកបានប្រតិបត្តិកាន់សីលដប់ ដោយមានជំនឿរឹងមាំក្នុងព្រះធម៌របស់ព្រះដ៏មានព្រះភាគ ។

យោងតាមគម្ពីរសទ្ធម្មសង្គហៈ, គេនិយាយថា គឺព្រះរេវតត្ថេរទេ ដែលបានបំបួសឃោសៈ ក្រោយលោកបានប្តូរជំនឿងាកមកជឿក្នុងពុទ្ធសាសនា ។ ឃោសៈបានត្រាច់រង្គាត់ពាសពេញជម្ពូទ្វីប ហើយបានផ្ចាញ់មនុស្សគ្រប់គ្នា ដោយបានឆ្លើយដោះស្រាយសំណួរទាំងឡាយ ដែលគេបានចោទសួរចំពោះលោក ។ បន្ទាប់មក លោកបានចូលទៅកាន់វត្តមួយ ដែលជាទីស្នាក់អាស្រ័យនៅរបស់ភិក្ខុសង្ឃជាច្រើន ; ក្នុងចំណោមនេះ ព្រះរេវតត្ថេរ គឺជាប្រមុខគេ ។ ថ្ងៃមួយ ឃោសៈកំពុងសូធ្យមន្ត្រ ហើយព្រះថេរៈបានស្តាប់ឮការសូធ្យរបស់គាត់ រួចមានពុទ្ធដីកាថា : " អ្នកណាគេ កំពុងស្រែកដូចពពៃ ? ឃោសៈបានឆ្លើយតបថា : " នែភិក្ខុ, តើលោកយល់អត្ថន័យបង្កប់នៅក្នុងសម្រែកពពៃនេះឬទេ ?" ព្រះថេរៈមានពុទ្ធដីកាថា : " ចំរើនពរ, អាត្មាដឹង" ។ ភ្លាមនោះ ឃោសៈក៏បានសួរបញ្ហាដ៏អាថ៌កំបាំងទាំងឡាយទាក់ទងនឹងវេទទាំងបី, ឥតិហាសៈ, ‑ ល ‑ ។ ព្រះថេរៈបានឆ្លើយបកស្រាយបញ្ហាទាំងនោះយ៉ាងត្រឹមត្រូវ ។ ព្រះថេរៈបានចោទសំណួរមួយចំពោះឃោសៈវិញ ដែលលោកបានស្រង់ចេញមកពីចិត្តយមកៈ នៅក្នុងគម្ពីរយមកៈ ។ ឃោសៈមិនអាចឆ្លើយសំនួរនោះបានហើយក៏សុំបួសក្នុងសំណាក់ព្រះរេវតត្ថេរ ។ ព្រះថេរៈបានបំបួសឃោសៈជាសាមណេរ ហើយទទួលយកលោកជាសិស្ស ។ ម្តងនោះ, សាមណេរឃោសៈ បានមានគំនិតមួយកើតឡើង អំពីឧត្តមភាពនៃចំណេះរបស់លោក បើប្រៀបផ្ទឹមទៅនឹងចំណេះដឹងរបស់ឧបជ្ឈាយ៍លោក ។ ព្រះឧបជ្ឈាយ៍ទតយល់គំនិតរបស់សាមណេរឃោសៈ ហើយមានពុទ្ធដីកាទៅកាន់សាមណេរនោះថា : " បើលោកគិតដូចនេះ, លោកឯងមិនសមសក្តិជាសិស្សរបស់ខ្ញុំទេ " ។ ឃោសៈ ក៏បានសុំឱ្យព្រះថេរៈខមាទោស ។ ព្រះឧបជ្ឈាយ៍បានឆ្លើយតបថា : " ខ្ញុំព្រះករុណា នឹងអត់ទោស

ឱ្យលោក ប្រសិនបើលោកព្រមនិមន្តទៅកាន់ប្រទេសសីឡុង់, ហើយបកប្រែព្រះធម៌របស់ព្រះសម្ពុទ្ធពីភាសាសីហាឡ្ស:ទៅជាភាសាមាគធី " ។ ឃោសៈ ទទួលព្រមនិមន្តទៅកាន់ប្រទេសសីឡុង់, ក្រោយពេលលោកបានជម្រះជំនឿខុសឆ្គងរបស់ព្រាហ្មណ៍ប្រុសជាឪពុកលោករួចហើយ ។ លោកបាននិមន្តទៅជួបព្រាហ្មណ៍ជាឪពុកលោកដែលបានដេញដោលសួរថា តើលោកចង់ក្លាយខ្លួនទៅជាគ្រហស្ថឥឡូវនេះ ឬយ៉ាងណា ? ឃោសៈបិតនៅស្ងៀម ហើយកំពុងសាកល្បងរកមធ្យោបាយធ្វើឱ្យឪពុករបស់លោកព្រមលះបង់ជំនឿខុសរបស់គាត់ ។ លោកបានសំរេចជោគជ័យក្នុងកិច្ចការនេះ ហើយឪពុករបស់លោកបានបោះបង់ជំនឿខុសរបស់គាត់ ហើយបានក្លាយទៅជាអ្នកដើរតាមព្រះពុទ្ធវិញ ។

ក្រោយពេលបានធ្វើឱ្យឪពុកលោក តាំងនៅស៊ប់ក្នុងសោតាបត្តិផលរួចហើយ, ឃោសៈ បានត្រឡប់មកជួបព្រះឧបជ្ឈាយ៍វិញ ។ គ្រាន់តែបានទទួលការអនុញ្ញាតពីឧបជ្ឈាយ៍ភ្លាម លោកបានចុះសំពៅនិមន្តទៅកាន់ប្រទេសសីឡុង់ ។ នៅតាមផ្លូវ លោកបានជួបព្រះថេរៈពុទ្ធទត្តៈ ដែលកាលនោះលោកកំពុងត្រឡប់ពីលង្កា (សីឡុង់) ទៅកាន់ជម្ពូទ្វីបវិញ ។ នៅតាមផ្លូវទៅកាន់ប្រទេសសីឡុង់ មុនពេលលោកបានជួបព្រះថេរៈពុទ្ធទត្តៈ, ឃោសៈបាននិមន្តមកដល់នាគបដ្ដនៈ ។ ថ្ងៃមួយ, នាយកនៃសង្ឃនៅទីនោះ មិនអាចពន្យល់ឱ្យបានច្បាស់នូវអត្ថន័យនៃចំណុចអាថិកំបាំងមួយ ។ ឃោសៈបានចេះដឹងទាំងអស់អំពីចំណុចនោះ ។ ព្រះសង្ឃនាយកកោតសរសើរយ៉ាងខ្លាំង ហើយក្រោយបានសាកសួរពតិមានសព្វគ្រប់ហើយ ក៏សុំឱ្យលោកបង្រៀនបិដកទាំងបីដល់ពួកភិក្ខុ ។ ឃោសៈបានប្រកែក ហើយបានទូលព្រះសង្ឃ-នាយកអំពីគោលបំណងនៃការនិមន្តមកកាន់កោះលង្កា ។ ភ្លាមនោះ ព្រះសង្ឃនាយកបានសុំឱ្យឃោសៈសរសេរអត្ថបទមួយ ស្ដីពីអត្ថន័យនៃគាថា ដែលព្រះពុទ្ធទ្រង់បានសំដែងទាក់ទងនឹងបិដកទាំងបី ។ ឃោសៈបានយល់ព្រម ហើយគេនិយាយថា

គ្រាន់តែលោកឆ្លើយទទួលថាព្រមភ្លាម, លោកក៏ចាប់សរសេរ រួចបញ្ចប់គម្ពីរវិសុទ្ធិ-មគ្គក្នុងថ្ងៃរសៀលនោះ ។ ក្រោយពេលបានសរសេរវិសុទ្ធិមគ្គរួចហើយ លោកក៏សឹងលក់ទៅ ។ សក្កៈ, ស្ដេចនៃទេវៈ គឺព្រះឥន្ទបានលួចយកគម្ពីរនោះ ។ ឃោសៈក៏សរសេរគម្ពីរនេះម្ដងទៀតក្រោមពន្លឺចង្កៀង ។ សក្កៈក៏មកលួចយកគម្ពីរនោះជាលើកទីពីរ ។ ឃោសៈរកមិនឃើញគម្ពីរនោះទៀត ក៏សរសេរជាលើកទីបី ហើយក៏សឹងលក់ទៅ ដោយបានចងអត្ថបទសរសេរដៃនោះជាប់ទៅនឹងស្បង់ ដែលលោកស្លៀក ។ ពេលនោះ, សក្កៈបានទុកគម្ពីរទាំងពីរដែលលោកបានលួចនោះ នៅខាងលើព្រះកេសរបស់លោកដែលកំពុងសឹង ។ ឃោសៈមានព្រះទ័យសោមនស្សណាស់ នៅពេលតើនឡើង ដោយបានឃើញគម្ពីររបស់លោកវិញ រួចក៏បង្ហាញគម្ពីរទាំងបីច្បាប់ចំពោះព្រះសង្ឃនាយក ។ ពេលនោះ គម្ពីរទាំងបីត្រូវបានគេយកមកសូធ្យ ។ គេឃើញថាគម្ពីរទាំងបី គឺជាអត្ថបទចម្លងដូចគ្នាបេះបិទ ពីមួយទៅមួយក្នុងគ្រប់សេចក្ដីលំអិត ។ ព្រះសង្ឃនាយកគាប់ព្រះទ័យខ្លាំងណាស់ ហើយក៏បានផ្ដល់ការអនុញ្ញាតដល់ព្រះឃោសៈ ឱ្យប្រែព្រះពុទ្ធឱវាទពីភាសាសីហឡៈ ទៅជាភាសាមាគធី ។ លោកបានសរសើរអំពីគុណសម្បត្តិរបស់ព្រះឃោសៈ ហើយចាប់ពីពេលនោះមក ព្រះឃោសៈបានក្លាយជាអ្នកមានកិត្តិស័ព្ទល្បីល្បាញថាជាព្រះពុទ្ធឃោសៈនៅក្នុងចំណោមអ្នកស្រុកនៃប្រទេសសីឡង់ ។

ក្នុងអំឡុងពេលឋិតនៅក្នុងប្រទេសសីឡង់ ព្រះពុទ្ធឃោសៈបានគង់នៅក្នុងជាន់ខាងក្រោមនៃអគារប្រាំពីរជាន់ ជាទីដែលលោកបំពេញកិច្ចការបកប្រែប្រចាំថ្ងៃ នូវពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។ លោក ស្ពេន ហារឌី (Spence Hardy) បានរៀបរាប់ថា, ព្រះពុទ្ធឃោសៈគង់នៅក្នុងគន្ធាគារវិហារដាច់ពីគេឯង, លោកជាប់រវល់តែនឹងការបកប្រែឱ្យស្របតាមក្បួនវេយ្យាករណ៍នៃភាសាមាគធី ដែលជាឫសគល់នៃភាសាទាំងអស់ (មូលភាសា), នូវអដ្ឋកថា ជាភាសាសីហឡៈទាំងមូល ទៅជា

ភាសាបាលី ។ ក្នុងពេលលោកគង់នៅក្នុងប្រទេសសីឡង់ លោកតែងចេញទៅក្រៅដើម្បីបិណ្ឌបាតរៀងរាល់ព្រឹក ហើយរើសយកស្លឹកត្នោតដែលជ្រុះ សម្រាប់សរសេរលើស្លឹកត្នោតនោះ ។ នេះគឺជាការកត់សំគាល់របស់អ្នកលក់ទឹកត្នោតម្នាក់ ( a toddy seller) ដែលបានឃើញលោកសរសេរជាក់ស្តែង លើស្លឹកត្នោតនោះ ។ ថ្ងៃមួយ អ្នកលក់ទឹកត្នោតបានយកអាហារពេញមួយថូ ហើយប្រគេនអាហារនោះចំពោះព្រះពុទ្ធឃោសៈ, ប៉ុន្តែព្រះពុទ្ធឃោសៈបានសុំឱ្យគាត់ឡើងទៅជាន់លើ ហើយប្រគេនអាហារនោះចំពោះព្រះមហាថេរៈដែលគង់នៅទីនោះវិញ ។ អ្នកលក់ទឹកត្នោតបានធ្វើតាម ហើយបានជួបនឹងព្រះថេរៈដែលគង់ក្នុងបន្ទប់ខាងលើ ដោយលោកមានពុទ្ធដីកាថា : " ព្រះពុទ្ធឃោសៈ ទើបស័ក្តិសមទទួលអាហារនេះជាងអាត្មាភាពទាំងឡាយនេះ ។ ជារៀងរាល់ថ្ងៃ លោកតែងបកប្រែព្រះធម៌របស់ព្រះពុទ្ធ ពីភាសាសីហឡៈទៅជាភាសាមាគធី ។ ចូរអ្នកប្រគេនអាហារនេះ ទៅលោកវិញ " ។ អ្នកលក់ទឹកត្នោតក៏បានធ្វើតាមយ៉ាងនោះ ។ កិច្ចការបកប្រែរបស់ព្រះពុទ្ធឃោសៈត្រូវបានបញ្ចប់ តាមដែលគេនិយាយថាតែក្នុងរយៈពេលបីខែប៉ុណ្ណោះ ។ ព្រះសង្ឃ-នាយក បានពោលសរសើរព្រះពុទ្ធឃោសៈយ៉ាងច្រើន ហើយក៏បានដុតចោលស្នាដៃទាំងអស់សរសេរជាភាសាសីហឡៈ ដោយព្រះថេរៈមហិន្ទៈ ។ ព្រះពុទ្ធឃោសៈបានសុំសេចក្តីអនុញ្ញាតពីព្រះសង្ឃនាយក និមន្តត្រឡប់ទៅស្រុកវិញ និងបានទៅជួបឪពុកម្តាយលោក ។ នៅពេលលោកត្រៀមខ្លួនហៀបតែនឹងចេញដំណើរ, ស្រាប់តែមានភិក្ខុជាតិសីហឡៈខ្លះបាននិយាយអាក្រក់ពីលោក ដោយពោលពាក្យថា លោកឥតចេះភាសាសំស្ក្រឹតទេ ។ នៅក្នុងកណ្តាលទីជំនុំសង្ឃ, ព្រះពុទ្ធឃោសៈបានឡើងលើវេទិកា និយាយយ៉ាងស្ទាត់ជំនាញ ដើម្បីបង្ហាញពីចំណេះខាងសំស្ក្រឹតរបស់លោក ។ តាំងពីពេលនោះមក ភិក្ខុទាំងឡាយក៏អស់សេចក្តីសង្ស័យចំពោះចំណេះដឹងខាងភាសាសំស្ក្រឹតរបស់លោក ។

ថ្ងៃមួយ មានស្ត្រីបំរើពីរនាក់របស់ព្រាហ្មណ៍ពីរនាក់ បានឈ្លោះទាស់ទែងគ្នា វាយតប់គ្នាទៅវិញទៅមក ។ ព្រះពុទ្ធឃោសៈតែមួយអង្គគត់បានឃើញស្ត្រីទាំងពីរនាក់ឈ្លោះគ្នា ។ រឿងក្តីបានឡើងទៅដល់តុលាការ ហើយព្រះរាជា ជាអ្នកត្រូវកាត់សេចក្តី ដោយទ្រង់ជឿទាំងស្រុងលើភស្តុតាងសរសេររបស់ព្រះពុទ្ធឃោសៈ ។ ព្រះរាជាទ្រង់មានបន្ទូលពោលសរសើរលោក ដោយកត់សម្គាល់ថា លោកជាមនុស្សម្នាក់មានបញ្ញាវាងវៃណាស់ ។ នៅពេលត្រឡប់ពីប្រទេសសីឡុងវិញ ព្រះពុទ្ធឃោសៈបាននិមន្តទៅរកព្រះឧបជ្ឈាយ៍លោកក្នុងជម្ពូទ្វីប ហើយទូលពុទ្ធដីកាដល់ឧបជ្ឈាយ៍ថា លោកបានសរសេរព្រះ*បរិយត្តិ*ចប់សព្វគ្រប់ហើយ ។ បន្ទាប់មក ព្រះពុទ្ធឃោសៈបាននិមន្តទៅផ្ទះឪពុក-ម្តាយលោក ដែលបានប្រគេនចង្ហាន់ដ៏មានឱជារស់បំផុតដល់លោក ។

ប្រភពខ្លះនិយាយថា ក្រោយពេលបានបញ្ចប់ការងាររបស់លោកនៅក្នុងប្រទេសសីឡុងហើយ ព្រះពុទ្ធឃោសៈបាននិមន្តទៅប្រទេសភូមា ដើម្បីផ្សព្វផ្សាយព្រះពុទ្ធសាសនា នៅទីនោះ ។ ជនជាតិភូមាចាត់ទុកឱកាសនោះជាការបើកសករាជថ្មីនៅក្នុងសាសនារបស់ពួកគេ គឺនៅពេលដែលព្រះមហាអដ្ឋកថាចារ្យបាននិមន្តមកដល់ប្រទេសរបស់ពួកគេ អំពីប្រទេសសីឡុង ។ គេបាននិយាយថា លោកបាននាំយកពីប្រទេសសីឡុង មកប្រទេសភូមា នូវគម្ពីរវេយ្យាករណ៍បាលីរបស់កច្ចាយនៈមួយច្បាប់, ដែលលោកបានប្រែជាភាសាភូមា, និងបានសរសេរអត្ថាធិប្បាយលើវេយ្យាករណ៍បាលីនោះទៀតផង ។ កិច្ចការនេះ មិនត្រូវបាននិយាយយោងដល់ដោយព្រះមោគ្គល្លានត្ថេរ ឬដោយអ្នកវេយ្យាករណ៍ប្រាក្រឹតទាំងឡាយទេ, ដោយលោកហេមចន្ទ្រៈ និងអ្នកដទៃទៀតទេ, ហើយនេះប្រហែលជាការទទួលស្គាល់ក្នុងចំណោមស្នាដៃទាំងឡាយដែលគេសន្មតដោយភ័ន្តច្រឡំថាជារបស់ព្រះពុទ្ធឃោសៈ ។ សៀវភៅឧបមាកថា មួយក្បាល សរសេរជាភាសាភូមា ក៏ត្រូវបានគេចាត់ទុកជា

ស្នាដៃរបស់លោកដែរ ។ *ក្រមមនុ* របស់ភូមា ( The Burmese code of Manu ) ក៏ត្រូវបានគេនិយាយថា បានបញ្ចូលមកក្នុងប្រទេសភូមា អំពីប្រទេសសិឡុង ដោយព្រះពុទ្ធឃោសៈដែរ ។ ទោះបីជាកាលប្បវត្តិទាំងឡាយរបស់ប្រទេសសិឡុង និងសិលាចារឹករបស់ភូមា ក្នុងសតវត្សទី៥ នៃគ្រិស្តសករាជ មិនបាននិយាយដល់ចំណុចនេះក្តី, ក៏ស្នាដៃផ្ទាល់របស់ព្រះពុទ្ធឃោសៈ ដូចជា គម្ពីរអត្ថសាលិនី និងវិសុទ្ធិមគ្គ ត្រូវបានជនជាតិភូមាស្គាល់ច្បាស់លាស់ណាស់ ហើយគេមានជំនឿយ៉ាងជ្រាលជ្រៅក្នុងគម្ពីរទាំងនោះ តាំងតែពីព្រេងនាយមក ។ សូម្បីតែឥឡូវនេះ ក៏ព្រះពុទ្ធឃោសៈត្រូវបានជនជាតិភូមាគោរពបូជាយ៉ាងខ្ពង់ខ្ពស់ ទុកដូចជាលោកកំពុងបានគង់ព្រះជន្មរស់នៅក្នុងចំណោមពួកគេដូច្នោះ ។

ព្រះធម្មកិត្តិ - ជាភិក្ខុជាតិសីហឡៈមួយអង្គ - នៅពេលនិយាយរៀបរាប់ដល់រាជរបស់ព្រះបាទមហានាម ដែលជាស្តេចនៃប្រទេសសិឡុង ក្នុងបណ្តាឆ្នាំទាំងឡាយ នាដើមសតវត្សទី៥ នៃគ្រិស្តសករាជ ក៏បាននិទានអំពីជីវិត និងស្នាដៃរបស់ព្រះពុទ្ធឃោសៈដែរ ។ នៅក្នុងការនិទាននេះ, ព្រះពុទ្ធឃោសៈ ត្រូវបានព្រះធម្មកិត្តិត្អែរពិពណ៌នាថា លោកជាយុវព្រាហ្មណ៍ កើតនៅទីជិតខាងនៃដើមមហាពោធិ៍ក្នុងរដ្ឋមគធៈ ។ យុវព្រាហ្មណ៍នេះ ចេះចាំវេទទាំងបី ហើយមានសម្បទាធំធេងក្នុងការរៀនឆាប់ចេះចាំ ។ យុវព្រាហ្មណ៍ គឺជាមនុស្សមិនចេះនឿយហត់នឹងការសួរដេញដោលពីជំនឿប្រាជ្ញា ហើយក្លាយទៅជាអ្នកគោចរដេញដោលជំនឿប្រាជ្ញាម្នាក់ក្នុងជម្ពូទ្វីប ។ យុវព្រាហ្មណ៍នេះ មានទម្លាប់ទស្សធ្យនៅពេលយប់នូវទ្រឹស្តីនៃទស្សនវិជ្ជា *បតញ្ជលី* ។ ក្រោយមក, គេបានមកទាក់ទងជាមួយព្រះមហាថេរព្រះនាមរេវតៈ ដែលបានដឹកនាំគេឱ្យជឿពុទ្ធសាសនា ។ ពុទ្ធឃោសៈជាមនុស្សជ្រាលជ្រៅណាស់ក្នុងសំដីវោហារ បីដូចជាព្រះពុទ្ធអង្គផ្ទាល់ ។ ពេលលោកគង់នៅក្នុងជម្ពូទ្វីប លោកបានតែងសៀវភៅ *ញាណោទយៈ* និងបានសរសេរគម្ពីរ *អត្ថសាលិនី*, អដ្ឋកថា នៃ*គម្ពីរ*

ធម្មសង្គណី ។ លោកជាមនុស្សមានចំណង់មុតមាំក្នុងការបកប្រែអដ្ឋកថា ទៅជាភាសាមាគធី ឬភាសាមគធៈ ។ នៅពេលដែលសមត្ថភាពរបស់លោកត្រូវបានគេសាកល្បងដោយការផ្ដល់ឱ្យគាថាពីរ លោកជាអ្នកទទួលជោគជ័យក្នុងការសាកល្បងនោះ ហើយក្រោយមក លោកបានតែងគម្ពីរ វិសុទ្ធិមគ្គ ។ លោកបានសរសេរអដ្ឋកថាបរិត្ត, ដែលមានន័យថា ឬមួយជាអដ្ឋកថាលើបរិត្ត, ឬមួយ, ប្រហែលជាដូច្នេះមែន ជាអដ្ឋកថាសង្ខេបខ្លីលើបិដក ។

នាម *រេវតៈ* មិនឃើញមាននិយាយដល់នៅក្នុងសេចក្ដីយោងណាមួយដោយផ្ទាល់នៅក្នុងសំនេរទាំងឡាយរបស់ព្រះពុទ្ធឃោសៈទេ ។ តាមសេចក្ដីយោងទាំងនេះ វាជាការច្បាស់ណាស់ថា ព្រះពុទ្ធឃោសៈបានគង់នៅ *កាញ្ចិបុរៈ* និងកន្លែងដទៃទៀត នៅក្នុងប្រទេសឥណ្ឌាភាគខាងត្បូង មុនលោកបាននិមន្តទៅប្រទេសសីឡង់ ។ និគមវចនៈ ( ពោលគឺសេចក្ដីសន្និដ្ឋាន ឬសេចក្ដីពន្យល់នៅទីបញ្ចប់ ឬនៅដើមសៀវភៅ អំពីសម័យកាលនៃការនិពន្ធ, អំពីអ្នកនិពន្ធ ជាដើម ) មិនបានបង្ហាញថា ពោធ-គយា ជាទីកន្លែងកំណើតរបស់ព្រះពុទ្ធឃោសៈទេ ។ នៅក្នុងគម្ពីរ *វិសុទ្ធិមគ្គ,* បាដលិបុត្ត ត្រូវបានលោកនិយាយយោងដល់ពីរដង, ប៉ុន្តែ ការស្គាល់របស់ព្រះពុទ្ធឃោសៈ អំពីបាដលិបុត្តនេះ មិនច្បាស់លាស់សោះឡើយ ។

យោងតាមការរៀបរាប់របស់ព្រះធម្មកិត្តិ, គម្ពីរអត្ថសាលិនី ត្រូវបានតែងនិពន្ធមុនគម្ពីរវិសុទ្ធិមគ្គ, ចំណែកឯគាថាផ្ដើមរបស់គម្ពីរ អត្ថសាលិនី សន្មតថា មានមុនយ៉ាងច្បាស់នៃអត្ថបទគម្ពីរវិសុទ្ធិមគ្គ ។ និគមវចនៈ របស់ព្រះពុទ្ធឃោសៈ ចំពោះគម្ពីរវិសុទ្ធិមគ្គ បញ្ជាក់យ៉ាងទូលំទូលាយ នូវសេចក្ដីរៀបរាប់ពីការចូលរួមរបស់ព្រះពុទ្ធឃោសៈ ជាមួយព្រះសង្ឃបាល, ដ៏ជាព្រះថេរៈដឹកនាំនៃមហាវិហារនាកាលនោះ ។ គម្ពីរចូលវង្ស បញ្ជាក់យ៉ាងច្បាស់ណាស់អំពីការស្នាក់នៅរបស់ព្រះពុទ្ធឃោសៈ នៅក្នុងប្រទេសសីឡង់ នៅសម័យកាលនៃព្រះរាជាមហានាម ( ៤០៩ - ៤២១ គ.ស.)

ប៉ុន្តែ ពុំមានភស្តុតាងអក្សរចារឹកណាមួយ ដើម្បីកំណត់ពីសម័យកាលជាមួយគ្នានេះទេ (Synchronism) ។

ចំពោះករណីព្រះថេរៈពុទ្ធទត្តវិញ មានសេចក្តីយោងដល់ថា លោកទាំងពីរមានឋានៈស្មើគ្នា, ហើយព្រះពុទ្ធទត្តបានស្នើសុំដោយអំណរសាទរឱ្យព្រះពុទ្ធឃោសៈសរសេរគម្ពីរមួយស្តីពី វិន័យ ។ ប្រសិនបើសេចក្តីយោងដ៏សាមញ្ញនេះ ត្រូវបានគេប្រកាន់យកជាមូលដ្ឋានរឹងមាំដើម្បីបញ្ជាក់ពីសហសម័យ នៃព្រះអដ្ឋកថាចារ្យបាលីទាំងពីរអង្គ, នោះព្រះពុទ្ធទត្តនឹងត្រូវបានគេចាត់ទុកជាសហកាលិករៀមច្បង (ពោលគឺ អ្នករស់នៅស្រករគ្នា ប៉ុន្តែមានវ័យច្រើនជាង) ។ គេពុំមានភ័ស្តុតាងផ្ទាល់ផ្សេងទៀតណាមួយ ដែលភ្ជាប់ទំនាក់ទំនងព្រះថេរៈទាំងពីរដោយកាលប្បវត្តិ នៅឡើយ ។ ប៉ុន្តែ ព្រះពុទ្ធទត្តៈ និងព្រះពុទ្ធឃោសៈ គឺប្រាកដជាត្រូវបានចាត់ ទុកជា *សហកាលិក* (គឺអ្នករស់នៅក្នុងសម័យកាលជាមួយគ្នា) ។ ព្រះពុទ្ធទត្ត : ជាអ្នក ស្រុក *ឧរគបុរៈ* (ឧរ៉ៃយូរ) នៅជិត *ត្រីនិណូប៉ូលី* (Trichinopoly) បច្ចុប្បន្ន ។ ដោយព្រះឱស្ឋលោកផ្ទាល់ លោកតែងមានពុទ្ធដីកាដោយស្នេហាជាតិខ្ពស់ អំពីព្រះរាជាណាចក្រ *ចោឡៈ* ហើយតែងភ្ជាប់សកម្មភាពអក្សរសាស្ត្ររបស់លោកជាមួយ នឹងរាជ្យរបស់ *អច្ចុតវិក្កន្តៈ* ឬ *អច្ចុតវិក្កមៈ* នៃ សន្តតិវង្ស *កលភៈ* ឬ *កលម្ពៈ* (កទម្ពៈ) ។

សេចក្តីរៀបរាប់របស់ព្រះធម្មកិត្តិ ស្តីពីភាពស្ទាត់ជំនាញរបស់ព្រះពុទ្ធឃោសៈ ក្នុងគម្ពីរវេទ និងមែកធាងផ្សេងទៀតនៃលទ្ធិព្រាហ្មណ៍ គឺជាសេចក្តីរៀបរាប់ដ៏ត្រឹមត្រូវ ។ ព្រះពុទ្ធឃោសៈបាននិយាយពីវេទទាំងបួន, ជាអាទិ៍, *ឥរុព្វេទ (ឫគ្វេទ), យជុព្វេទ (យជុវេទ), សាមវេទ* និង *អត្ថព្វណវេទ* នៅក្នុងគម្ពីរ *សុមង្គលវិលាសនី* របស់លោក ។ លោកបានបង្ហាញនូវការយល់ដឹងរបស់លោកអំពីការធ្វើពលិការតាមគម្ពីរវេទ យ៉ាងលំអិតផងដែរ ។ យោងតាមពុទ្ធដីកាលោក, *យិដ្ឋៈ* ត្រូវបានគេហៅថា *មហាយាគៈ* (ពលិការដ៏ធំ) ហើយ ហុតៈ គឺជាការទទួល

ឱ្យស្នាក់អាស្រ័យ ផ្ដល់ជូនដល់មនុស្សទាំងឡាយ ចូលរួមក្នុងពិធីពលិការ ។ លោកបាននិយាយដល់ *អគ្គហោមៈ* ដែលជាឈ្មោះចេញមកពីហេតុដែលថា *អគ្គិ-ហោមៈ* ត្រូវបានប្រព្រឹត្តទៅដោយការដុតវត្ថុពលិក្នុងភ្លើង ឆេះឡើងដោយអុស ។ *ទព្វិហោមៈ* គឺជាប្រភេទមួយបែបនៃអគ្គិហោមៈ ហើយត្រូវបានគេហៅយ៉ាងនេះ ពីព្រោះពលិការនេះ ត្រូវបានធ្វើឡើងដោយការដាក់សំបក (គ្រាប់ស្រូវ, គ្រាប់ធញ្ញ-ជាតិឯទៀត ... ) ទៅក្នុងភ្លើងដោយស្លាបព្រាឈើ ។ *មុខហោមៈ* គឺជាការធ្វើពលិការមួយបែបទៀត ដែលនៅក្នុងការធ្វើពិធីនេះ គេបានព្រោះគ្រាប់ស្ពៃខ្មៅទៅក្នុងភ្លើង ចេញពីមាត់អ្នកធ្វើពិធីបូជា ។ *លោហិតហោមៈ* ក៏ត្រូវបានគេពិពណ៌នាថា ជាពលិការមួយបែបដែរ ។ ប្រពៃណីបាននិយាយពីភាពស្និទ្ធស្នាលរបស់ព្រះពុទ្ធឃោសៈ ជាមួយប្រព័ន្ធ*បតញ្ជលិ* (បតញ្ជលិមតៈ) ដែលសំដៅដល់ទ្រឹស្ដីសំខ្យា-យោគៈ ។ ទស្សនៈនេះ ត្រូវបានពោលរៀបរាប់ដោយសារការជជែករបស់លោក អំពីឋានៈនៃ *អវិជ្ជា* នៅក្នុងលទ្ធិពុទ្ធសាសនា ដោយប្រៀបធៀបជាមួយនឹង *បកតិ* (ប្រក្រឹតិ) នៃ *បកតិវាទ* មានន័យថា ទស្សនវិជ្ជា សំខ្យា ។ ស័ព្ទ *សមុនៈ*, នៅក្នុងអដ្ឋកថាទាំងឡាយរបស់លោក, តែងរំលឹកយើងឱ្យដឹងពីការជំពាក់គុណរបស់លោកចំពោះ គម្ពីរ *យោគសូត្រ* របស់បតញ្ជលិ និងអដ្ឋកថារបស់ វ្យាសៈ លើគម្ពីរនោះ ។

ការចេះដឹងបន្តិចបន្តួចរបស់ព្រះពុទ្ធឃោសៈ ជាមួយប្រព័ន្ធ *ន្យាយៈ* គឺជាភស្តុតាងជាក់ស្ដែង ចេញមកពីការបកន័យគ្នា ដែលលោកបានកត់សម្គាល់រវាងស័ព្ទ *ហេតុ* ដូចដែលគេធ្លាប់ប្រើនៅក្នុងពុទ្ធសាសនាថេរវាទ ហើយនិងស័ព្ទដដែល ដូចដែលគេធ្លាប់យល់ជាទូទៅក្នុងន័យសម្មតិកម្មដ៏ចម្បងក្នុងវិចារណកម្ម ស៊ីឡូហ្ស៊ីស (Syllogistic reasoning)[១] ។

វចនាបថ សរសេរជាពាក្យរាយរបស់ព្រះពុទ្ធឃោសៈ នៅក្នុងប្រការជា

ច្រើន គឺដូច រចនាបថ សរសេរជាពាក្យរាយរបស់ បតញ្ជលី ។ ពេលខ្លះ លោកបានដក ស្រង់ជាភាសាបាលី នូវវេយ្យាករណសូត្ររបស់ បាណិនិ ។ បាណិនិ មិនមានការយល់ ទាស់ចំពោះ *អាបត្តិ* ក្នុងន័យនៃ *ប្រាប្តិ* ទេ ។ ក្នុងន័យនេះឯង អាបត្តិ ត្រូវបានស្វែង រកដើម្បីពន្យល់នៅក្នុងគម្ពីរ សាមន្តបាសាទិកា ។ ការពិពណ៌នាខាងកាយវិភាគសាស្ត្រ របស់ព្រះពុទ្ធឃោសៈ អំពីផ្នែកទាំងសាមសិបពីរ នៃសរីរាង្គមនុស្ស ដូចលោកបាន រៀបរាប់នៅក្នុងគម្ពីរវិសុទ្ធិមគ្គ បង្ហាញឱ្យឃើញនូវការចេះដឹងតិចតួចរបស់លោក ចំពោះចំណេះដឹងខាងវេជ្ជសាស្ត្រ ។ ចំណេះដឹងរបស់ព្រះពុទ្ធឃោសៈ អំពីគម្ពីរ ឧបនិស័ទ មិនឃើញមាននិយាយក្នុងកន្លែងណាមួយនៅក្នុងអត្ថបទសរសេររបស់ លោកទេ ។ យុទ្ធកថាជាភាសាសំស្ក្រឹតដ៏ធំពីរ គឺរឿង *រាមាយនៈ* និងរឿង *មហាភារតៈ* មិនឃើញលោកនិយាយដល់នៅក្នុងទីណាមួយ នៃស្នាដៃរបស់លោក ឡើយ ។ សេចក្តីយោងរបស់លោកដល់រឿង *មហាភារតយុទ្ធ* និងរឿង *សីតា-ហរណៈ* នៅក្នុងគម្ពីរ *សុមង្គលវិលាសនី* ត្រូវបានឃើញមាននៅក្នុងការភ្ជាប់នឹង ការពន្យល់ពាក្យ *អក្ខានំ* ។

---

(១) ការពិចារណាតាមបែបស៊ីឡូហ្ស៊ីស ។ ស៊ីឡូហ្ស៊ីស, នៅក្នុងតក្កវិទ្យា, គឺជាទម្រង់នៃ ការពិចារណា ឬទឡ្ហីកម្មមួយបែប ដែលផ្គុំផ្សំដោយសេចក្តីអះអាងបី, នៅក្នុងបណ្តាសេចក្តី អះអាងទាំងបីនេះ, សេចក្តីអះអាងពីរមុនគេ មានឈ្មោះថា សម្មតិកម្មចម្បង និងបន្ទាប់បន្សំ, ហើយសេចក្តីអះអាងចុងក្រោយ គេហៅថា សេចក្តីសន្និដ្ឋាន ។ សេចក្តីសន្និដ្ឋាន ត្រូវតែ ចេញមកពីសម្មតិកម្ម ជាចាំបាច់ ។

ឧ. មនុស្សទាំងអស់គ្នាត្រូវតែស្លាប់ (ចម្បង)
អ្នកឯងជាមនុស្សម្នាក់ (បន្ទាប់បន្សំ)
ដូច្នេះអ្នកឯងក៏ត្រូវស្លាប់ (សន្និដ្ឋាន) ។

ចំពោះមុខការរបស់លោក នៅក្នុងប្រទេសឥណ្ឌាភាគខាងត្បូងវិញ, ព្រះពុទ្ធឃោសៈ ក្នុងអំឡុងកាលនៅទីនោះ បានរៀនចេះស្ទាត់គ្រប់គ្រាន់ក្នុងគម្ពីរបិដកទាំងបី ។ ការប្តូរសាសនារបស់លោក ហើយនឹងការបួសជាភិក្ខុពុទ្ធសាសនិក បានជួយលោកយ៉ាងសំខាន់ ឱ្យលោកសរសេរអត្ថបទមួយ ដែលមានឈ្មោះថា : *ញាណោទ័យ* ឬ " ការដុះដាលឡើងនៃវិជ្ជា " (The Awakening of knowledge) មុនពេលលោកនិមន្តទៅប្រទេសសីឡង់ ។ លោកបានភ្ជាប់អត្ថបទនេះ ជាអត្ថបទបន្ថែមទៅលើគម្ពីរ*ធម្មសង្គណី*, ដែលជាគម្ពីរដំបូងរបស់*អភិធម្មបិដក* ។ លោកបានសរសេរ*អត្ថធម្មសាលិនី* ដែលជាអដ្ឋកថាដ៏សង្ខេបលើ*ធម្មសងណី* ។ គ្រូរបស់លោកគឺព្រះរេវតៈ ពេលនោះបានទូន្មាន និងណែនាំឱ្យលោកព្រមនិមន្តទៅ ប្រទេសសីឡង់ ។ សកម្មភាពរបស់លោក មុនពេលបំពេញ បេសកកម្មរបស់លោកទៅកាន់ប្រទេសសីឡង់ គឺត្រូវបានកំហិតនៅតែក្នុងប្រទេសចោឡៈ ឬ ទមិឡៈ ក្នុងតំបន់ដេក្កង់ តែប៉ុណ្ណោះ ។ លោកបានស្នាក់អាស្រ័យនៅ *កាញ្ចិបុរៈ* និងកន្លែងដទៃទៀត ជាមួយ*ព្រះជោតិបាល*, ហើយតាមសំណូមពររបស់ថេរៈអង្គនេះ លោកបានសរសេរ *សារត្ថប្បកាសិនី* និង *មនោរថបូរណី* ។ លោកបាននិមន្តទៅទស្សនា *មយូរសុត្តបដ្ដនៈ* ឬ *មយូររូបបដ្ដនៈ* (ប្រហែលជាភ្ជាប់ជាមួយមយវេរាម) ឋិតនៅដែនទន្លេកណ្តាលមួយនៃ*កាវេរី* ។ នៅទីនេះ ព្រះពុទ្ធមិត្តត្ថេរបានសុំព្រះពុទ្ធឃោសៈឱ្យសរសេរ*បបញ្ចសូទនី* ។ ស្នាព្រះហស្តរបស់ព្រះពុទ្ធឃោសៈរំលឹកឱ្យយើងនឹកឃើញជនជាតិអន្ធកៈ (អន្ទ្រៈ) និង ទមិឡៈ (ទ្រាវិឌៈ) ដែលត្រូវបានគេចាត់ទុកថាមិនមែនជាប្រជាជន អរ្យ៉ន ។ នៅក្នុង*វិភង្គៈ-អដ្ឋកថា* របស់លោក, ព្រះពុទ្ធឃោសៈបានយោងដល់ភាសាមិនមែនអរ្យ៉ន ដប់ប្រាំបី (មិលក្ខភាសា) មានជាអាទិ៍ ដូចជា ឱឌ្ឋៈ, កិរាតៈ, អន្ទ្រកៈ, យោណកៈ និង ទមិឡភាសា ។ នៅក្នុង*សាមន្តបាសាទិកា*, ភាសាមិនមែនអរ្យ៉នទាំងឡាយ ត្រូវបានតំណាងជាគំរូដោយអន្ធកភាសា និងទមិឡភាសា ។

ក្រោយពេលបានបង្ហើយគម្ពីរ *ញាណោទ័យ* និងបញ្ចប់បេសកកម្ម របស់លោកនៅប្រទេសឥណ្ឌាភាគខាងត្បូង, ព្រះពុទ្ធឃោសៈបាននិមន្តទៅប្រទេស សីឡង់ ដែលលោកបានធ្លាប់ស្គាល់ថា *សីហឡៈ* ឬ *តម្ពបណ្ណិ* ។ ភាសាសីហឡៈ ត្រូវបានគេរាប់នៅក្នុងអដ្ឋកថា *សុត្តនិបាត* ក្នុងបណ្តាភាសាមិនមែនអរ្យ៉ន *(មិលក្ខភាសា- បរិយាបណ្ណា)* ។

សេចក្តីរៀបរាប់របស់ព្រះធម្មកិត្តិ ចង្អុលប្រាប់ថា ព្រះពុទ្ធឃោសៈ បានចាកចេញទៅប្រទេសសីឡង់ ក្រោយពេលបានទទួលសេចក្តីណែនាំពីឧបជ្ឈាយ៍ របស់លោក គឺ ព្រះថេរៈរេវតៈ ។ យើងបានដឹងពីអវសានកថានៅក្នុងគម្ពីរ *មនោរថ-បូរណី* របស់លោកថា លោកបានស្នាក់អាស្រ័យជាមួយព្រះជោតិបាល មិនមែននៅតែកាញ្ចិបុរៈ និងកន្លែងទាំងឡាយផ្សេងៗទៀត នៅក្នុងចោឡៈ ឬ ទ្រាវិឌប្រទេស ប៉ុណ្ណោះទេ, ប៉ុន្តែ នៅមហាវិហារ ក្នុងកោះតម្ពបណ្ណិ ផងដែរ ។ សេចក្តីថ្លែងរបស់ព្រះពុទ្ធឃោសៈនេះ ប្រសិនបើនេះជាការណ៍ពិតមែន, អាចមានន័យថា ព្រះជោតិ-បាល មិនមែនសព្វព្រះទ័យតែអង្វរឱ្យព្រះពុទ្ធឃោសៈ ព្រមនិមន្តទៅប្រទេសសីឡង់ នោះប៉ុណ្ណោះទេ, ប៉ុន្តែខ្លួនលោកផ្ទាល់ បាននាំព្រះពុទ្ធឃោសៈទៅកាន់ទីនោះ ។ ព្រះសង្ឃបាលត្ថេរ កាលនោះគឺជាប្រមុខនៃមហាវិហារ ។ គឺប្រហែលជាការពន្លើស ដែលនិយាយថា ព្រះពុទ្ធឃោសៈមិនត្រូវបានគេអនុញ្ញាតឱ្យប្រែអដ្ឋកថាទាំងឡាយ ដែលជា*សីហឡៈភាសា,* មុនពេលសមត្ថភាពរបស់លោកត្រូវបានសាកល្បង, ពោលគឺ មុនពេលលោកបានទទួលជោគជ័យក្នុងការសរសេរគម្ពីរវិសុទ្ធិមគ្គ ។ ការសាកល្បងដំបូង អំពីពហុសុតភាព និងសមត្ថភាពខាងបញ្ញារបស់លោក អាចត្រូវបានគេចាត់ទុកជាការងារធម្មតា ។ វាអាចជាថា គេបានឱ្យលោកពន្យល់គាថាពីរបទ ដកស្រង់ចេញពី*សំយុត្តនិកាយ,* ប៉ុន្តែ ពុំមានន័យថាការបង្កើតគម្ពីរដ៏ចម្បង ដូចជាគម្ពីរវិសុទ្ធិមគ្គ គឺជាលទ្ធផលភ្លាមៗនោះទេ ។

ភ័ស្តុតាងផ្ទៃក្នុងនៃស្នាដៃ បញ្ជាក់ថាលោកបានសរសេរគម្ពីរនោះកើតចេញបាន ក្រោយពេលលោកមានឱកាសដ៏ទូលំទូលាយមួយ សម្រាប់ឱ្យលោកសិក្សាអដ្ឋកថាទាំងឡាយជាភាសា*ស៊ីហឡ:* និងឱ្យលោកស្គាល់ជិតស្និទ្ធជាមួយទស្សនៈត្រឹមត្រូវរបស់គ្រូទាំងឡាយ ដែលភ្ជាប់ខ្លួនទៅនឹងមហាវិហារ ។ បណ្ណាល័យរបស់មហាវិហារប្រហែលជាត្រូវបានគេស្គាល់ថា *គន្ថាករ* ឬក៏ប្រហែលជា *គន្ថាគារ* ។

ស្នាព្រះហស្តទាំងបួន ដែលលោកបានសរសេរភ្លាមៗ បន្ទាប់ពីគម្ពីរវិសុទ្ធិ-មគ្គរបស់លោក គឺអដ្ឋកថាទាំងឡាយលើ *និកាយ* បួនដំបូង ដែលត្រូវបានចេញបន្តបន្ទាប់មកទៀត ដោយអដ្ឋកថាទាំងឡាយរបស់លោកលើគម្ពីរទាំងប្រាំពីរ នៃព្រះអភិធម្ម ។ *គម្ពីរវិសុទ្ធិមគ្គ* ត្រូវបានសរសេរឡើងតាមសំណូមពររបស់ព្រះសង្ឃ-បាលត្ថេរ ។ ក្នុងបណ្តាអដ្ឋកថាលើ*និកាយ* ទាំងបួន, គម្ពីរ*សុមង្គលវិលាសិនី* គឺលោកបានសរសេរឡើងតាមសំណូមពររបស់ព្រះទាឋនាគត្ថេរ នៃសុមង្គលវិហារ, គម្ពីរ *បបញ្ចសូទនី* តាមសេចក្តីស្នើសុំរបស់ព្រះពុទ្ធមិត្តត្ថេរ នៃមយូរសុត្តបដ្ដនៈ ហើយគម្ពីរ *សារត្ថប្បកាសិនី* និង *មនោរថបូរណី* តាមសេចក្តីស្នើរបស់ព្រះជោតិ-បាលត្ថេរ ។ អដ្ឋកថាព្រះអភិធម្ម ត្រូវបានគេនិយាយថា លោកបានសរសេរឡើងតាមសំណូមពររបស់ភិក្ខុពុទ្ធឃោសៈ ដែលឥឡូវនេះ គេបញ្ជាក់ថាជាចុល្លពុទ្ធ-ឃោសៈ នៃ *គន្ធវង្ស* ហើយដែលគេសន្មតថា ជាអ្នកនិពន្ធគម្ពីរ *បរមត្ថជោតិកា*, ជាអដ្ឋកថាបន្តលើគម្ពីរទាំងបួន នៃខុទ្ទកនិកាយ ។ បេសកកម្មអក្សរសាស្ត្ររបស់ព្រះពុទ្ធឃោសៈ នៅក្នុងប្រទេសសីឡង់ បានបញ្ចប់ជាមួយនឹងការសរសេរអដ្ឋកថាព្រះអភិធម្ម ចប់ដែរ ។

ការសិក្សាដោយរិះគន់លើសៀវភៅ *ពុទ្ធឃោសុប្បត្តិ* មិនបានជួយយើងច្រើនក្នុងការបំភ្លឺពីប្រវត្តិរបស់ព្រះពុទ្ធឃោសៈទេ ។ អ្នកនិពន្ធសៀវភៅនេះ មានចំណេះច្បាស់លាស់តិចតួច ។ គេគ្រាន់តែបានប្រមូលរឿងព្រេងទាំងឡាយ និទាន

រៀបរាប់ជុំវិញព្រះពុទ្ធឃោសៈ ។ តាមទស្សនៈប្រវត្តិសាស្ត្រ រឿងព្រេងទាំងនោះមិនមានតម្លៃអ្វីជាធំដុំទេ ។ ការនិយាយរៀបរាប់នៅក្នុងសៀវភៅ *ពុទ្ធឃោសុប្បត្តិ* អំពីកំណើត, ជីវភាពពីដំបូង, ការប្តូរជំនឿសាសនា, . ល . របស់ព្រះពុទ្ធឃោសៈ បញ្ជាក់ឱ្យឃើញភាពប្រហាក់ប្រហែលគ្នាដ៏ច្បាស់ក្រឡែត ជាមួយនឹងកំណើត, ជីវភាព, ការប្តូរជំនឿ សាសនា . ល . របស់មិលិន្ទៈ និងមោគ្គលិបុត្តតិស្សត្ថេរ ។ នៅក្នុងការសាកសួរ ដែលបានកើតមានរវាងព្រះពុទ្ធឃោសៈ និងព្រះពុទ្ធទត្តត្ថេរ, គេនិយាយថា ព្រះពុទ្ធទត្តត្ថេរ បានប្រាប់ព្រះពុទ្ធឃោសៈ ថាដូច្នេះ : " ខ្ញុំព្រះករុណានិមន្តទៅមុនលោក ទៅកាន់ប្រទេសសីឡង់ ដើម្បីប្រមូលចងក្រងពុទ្ធវចនៈ, ខ្ញុំព្រះករុណា ចាស់ហើយ, មិនមានពេលវែងដើម្បីរស់រានយូរ ហើយដោយហេតុនេះនឹងមិនអាចបញ្ចប់ការងារបានទេ ។ លោកចូរបន្តការងារ ឱ្យចប់ចុង-ដើមគួរជាទីពេញចិត្តផងចុះ " ។

នៅក្នុងជំពូកទីប្រាំមួយ នៃគម្ពីរឃោសុប្បត្តិ (១), យើងឃើញថា ព្រះ

---

(១) ជាស្នាដៃខ្លី សរសេរជាភាសាបាលី ចំនួន ៣០ ទំព័រ ត្រូវបានគេស្គាល់ផងដែរថា មហាពុទ្ធ-ឃោសស្ស និទានវត្ថុ ។ ស្នាដៃនេះត្រូវបានព្រះមង្គលត្ថេរ សរសេរឡើងជាពាក្យរាយ ចែកជាប្រាំបីជំពូក ។

គឺជាជីវប្បវត្តិរបស់ព្រះពុទ្ធឃោសៈ ។ ស្នាដៃនេះមិនមានតម្លៃពេកទេ ពីព្រោះអ្នកនិពន្ធជាប់ចិត្តតែរៀបរាប់ពីរឿងព្រេងជុំវិញព្រះអដ្ឋកថាចារ្យ ជាជាងហេតុការណ៍ពិតជាក់ស្តែងរបស់លោក ។

គេស្គាល់ពីអ្នកនិពន្ធតិចតួចណាស់ ក្រៅតែពីឈ្មោះរបស់លោកចេញ ។ គម្ពីរនេះប្រហែលជាបានសរសេរក្នុងសតវត្សទី ១៦, ពីព្រោះគេឃើញមាននិយាយយោងដល់នៅក្នុងគម្ពីរ ជិនកាលមាលី សរសេរក្នុងឆ្នាំ ១៥១៧ គ.ស ។

ពុទ្ធឃោសៈ បានធ្វើឱ្យអក្សរគម្ពីរពុទ្ធសាសនាទៅជាភាសាមាគធី, ហើយនៅក្នុងជំពូកទីប្រាំពីរ មានសរសេរថា នៅពេលបីខែក្រោយមក, កាលបើលោកបានបញ្ចប់ការងាររបស់លោកហើយ, ស្នាព្រះហស្តរបស់ព្រះមហិន្ទត្ថេរ ក៏ត្រូវបានគេគរ ហើយដុតចោល ។ អ្នកនិពន្ធបានធ្វើកំហុសមួយនៅក្នុងជំពូកទីប្រាំមួយ គឺកំហុសដែលធ្វើឱ្យគេយល់ថា ព្រះពុទ្ធឃោសៈបានបកប្រែគម្ពីរពីសីហឡៈទៅជាភាសាបាលី ។ តាមពិត ព្រះពុទ្ធឃោសៈបានបកប្រែតែអដ្ឋកថាទាំងឡាយជាភាសាសីហឡៈ ទៅជាភាសាមាគធី, ហើយមិនបានបកប្រែអត្ថបទគម្ពីរទាំងឡាយផ្ទាល់ទេ ។ បើសិនជាលោកបានបកប្រែអត្ថបទគម្ពីរដូច្នោះមែន, នោះប្រហែលជាពុំមានឱកាសណា ដើម្បីដុតចោលស្នាព្រះហស្តរបស់ព្រះមហិន្ទត្ថេរទេ ។ នៅក្នុងគម្ពីរ *ចូឡវង្ស* មាននិយាយយ៉ាងច្បាស់លាស់ថា នៅក្នុងជម្ពូទ្វីប មានតែអត្ថបទគម្ពីរជាភាសាបាលីប៉ុណ្ណោះ, ហើយព្រះពុទ្ធឃោសៈ ត្រូវបានបញ្ជូនទៅប្រទេសសីឡង់ ដើម្បីឱ្យបកប្រែអដ្ឋកថាជាភាសាសីហឡៈ ទៅជាភាសាបាលី ។

ព្រះពុទ្ធឃោសៈ និងព្រះនាគសេន ទាំងពីរអង្គនេះ បានបង្ហាញឱ្យឃើញនូវសញ្ញាដ៏អស្ចារ្យខាងបញ្ញា ក្នុងយុវវ័យរបស់លោក ។ ទាំងពីរអង្គអាចរៀនចេះចាំគម្ពីរវេទទាំងឡាយក្នុងរយៈពេលដ៏ខ្លីបំផុត ។ ទាំងពីរអង្គបានចូលកាន់ព្រះពុទ្ធសាសនាតាំងពីវ័យក្មេងខ្ចី ។ ក្រោយពេលបានចូលកាន់ពុទ្ធសាសនាហើយ, ព្រឹត្តិការណ៍ទាក់ទងនឹងជីវភាពរបស់ព្រះថេរៈទាំងពីរអង្គដ៏ល្បីល្បាញនេះ មានលក្ខណៈប្រហាក់ប្រហែលគ្នា ។ ក្រោយពេលបានបួសរួច, ព្រះនាគសេនបានគិតថា គ្រូរបស់លោកប្រហែលជាមនុស្សល្ងង់ ពីព្រោះលោកគ្រូបានបង្រៀន *អភិធម្ម* ដល់លោកជាដំបូង ដោយមិនគិតដល់ពាក្យប្រៀនប្រដៅដទៃទៀតរបស់ព្រះពុទ្ធ ។ គ្រូរបស់លោកបានយល់នូវអ្វី ដែលកំពុងប្រព្រឹត្តទៅនៅក្នុងសតិអារម្មណ៍របស់ព្រះនាគសេន ហើយលោកក៏ស្តីប្រដៅព្រះនាគសេន ។ ព្រះនាគសេន បានសុំខមាទោស ។ ព្រះពុទ្ធ-

ឃោសៈ ក៏បានគិតដូច្នោះដែរថា : " អាត្មាអញ ឬ ឧបជ្ឈាយ៍របស់អាត្មាអញ ដែលបានយល់ជ្រាលជ្រៅព្រះពុទ្ធវចនៈ ? " គ្រូរបស់ព្រះពុទ្ធឃោសៈ បានដឹងរឿងនេះហើយ ក៏ស្តីប្រដៅព្រះពុទ្ធឃោសៈ ។ ចំពោះកំហុសនេះ ព្រះពុទ្ធឃោសៈ ក៏បានសុំខមាទោស ។

ការរៀបរាប់អំពីការប្តូរជំនឿរបស់ព្រះពុទ្ធឃោសៈ ក៏ស៊ីគ្នានឹងការប្តូរជំនឿរបស់ព្រះមោគ្គលិបុត្តតិស្សៈ ដូចដែលបានកត់ត្រានៅក្នុងគម្ពីរ*មហាវង្ស* ដែរ ។ អាសនៈ (កៅអី) របស់តិស្សៈ (គឺមោគ្គលិបុត្តតិស្សៈ) ត្រូវបានគេផ្តល់ទៅឱ្យព្រះថេរៈអង្គណាមួយគង់, ដែលលោកធ្លាប់តែនិមន្តជារៀងរាល់ថ្ងៃទៅកាន់ផ្ទះនៃឪពុករបស់លោក ។ តិស្សៈ បានច្រឡោតខឹងដោយឃើញព្រះថេរៈគង់លើអាសនៈផ្ទាល់របស់ខ្លួន ។ តិស្សៈ បានសួរឱ្យព្រះថេរៈពន្យល់ចំណុចអាថិកំបាំងមួយចំនួននៅក្នុងគម្ពីរវេទ, ព្រះថេរៈក៏បានពន្យល់ចំណុចទាំងនោះរួចសព្វគ្រប់ ។ តិស្សៈ ត្រូវបានព្រះថេរៈសួរសំណួរមួយតបវិញ នៅក្នុង *ចិត្តយមកៈ* ដែលធ្វើឱ្យតិស្សៈវិលក្បុង ។ តិស្សៈ បានសួរព្រះថេរៈអំពី មន្ត្រៈ ជាអ្វី ។ នៅពេលដែលតិស្សៈ បានដឹងថាគឺជា ពុទ្ធមន្ត្រៈ, តិស្សៈ បានសុំឱ្យព្រះថេរៈចែករំលែកពុទ្ធមន្ត្រៈនោះ ដល់គាត់ផង ។ ព្រះថេរៈមានពុទ្ធដីកាថា, " អាត្មាចែករំលែកពុទ្ធមន្ត្រៈ ទៅឱ្យតែអ្នកណាដែលស្លៀកដណ្តប់សំពត់របស់យើង" ។

យោងតាមគម្ពីរពុទ្ធឃោសុប្បត្តិ, ពុទ្ធឃោសៈច្រឡោតខឹង, នៅពេលគាត់បានឃើញសមណព្រាហ្មណ៍មួយអង្គគង់លើអាសនៈ (កៅអី) របស់គាត់ នៅក្នុងផ្ទះរបស់ឪពុកគាត់, គឺព្រាហ្មណ៍កេសី ។ នៅពេលដែលព្រះថេរៈបានឆាន់ចង្ហាន់រួចរាល់ហើយ, គាត់បានសួរលោកថា " តើលោកចេះវេទទាំងឡាយឬទេ ឬ តើលោកចេះដឹងខ្លះៗអំពីមន្ត្រៈផ្សេងៗឬទេ ? " ព្រះថេរៈ បានឆ្លើយតបថា " អាត្មាចេះមិនត្រឹមតែវេទទាំងឡាយទេ, ប៉ុន្តែ ចេះមន្ត្រៈមួយផ្សេងទៀត" ។ ហើយបន្ទាប់មក

ព្រះថេរះក៏បានសូធ្យវេទទាំងបី ។ ពុទ្ធឃោសះ បានសុំឱ្យព្រះថេរះសូធ្យមន្ត្រះរបស់លោក ។ ព្រះថេរះ បានសូធ្យផ្នែកខ្លះៗនៃ *អភិធម្មបិដក* ។ នៅពេលដែលពុទ្ធ-ឃោសះ ដឹងអំពីព្រះថេរះថា នោះគឺជា *ពុទ្ធមន្ត្រះ*, ពុទ្ធឃោសះ ក៏មានចំណង់ចង់ចេះពុទ្ធមន្ត្រះនោះ ។ ពេលនោះ, គាត់បានកោរក្បាល ដោយមានការអនុញ្ញាតពីឪពុកម្ដាយរបស់គាត់ផង បានសុំផ្នួស ហើយបានក្លាយទៅជាបព្វជិតមួយរូប ។

ព្រះពុទ្ធឃោសះ, ក្រោយពេលបានបង្ហើយករណីយកិច្ចទាំងអស់របស់លោកក្នុងប្រទេសសីឡង់រួចហើយ, ក៏បានត្រឡប់មកកាន់ជម្ពូទ្វីបវិញ ដើម្បីមកគោរពព្រះមហាពោធិព្រឹក្ស ។ នៅរយៈពេលចុងក្រោយ នៃជីវិតរបស់លោក, ព្រះពុទ្ធឃោសះ បានចំណាយពេលប្រតិបត្តិតាមក្រឹត្យវិន័យយ៉ាងតឹងរ៉ឹង ក្រោយពេលបានដកខ្លួនចេញពីសកម្មភាពអក្សរសាស្ត្ររបស់លោក ។ លោកចំណាយពេលសេសសល់នៃជីវិតរបស់លោក នៅពុទ្ធគយា ជាកន្លែងដែលលោកទទួលអនិច្ចធម្ម ។ លោកបានសុគតដោយស្ងប់ស្ងៀម ហើយបានទៅបដិសន្ធិឡើងវិញក្នុងឋានសួគ៌ ។

ពេលវេលាពិតប្រាកដនៃការសុគតរបស់លោក ត្រូវបានលោកដឹង ហើយលោកបានត្រិះរិះដូច្នេះថា : " មរណភាពមានបីប្រភេទគឺ *សមុច្ឆេទះ*, *ខណិកះ* និង *សម្មតិ* ។ ក្នុងបណ្ដាមរណភាពទាំងបីនេះ, មរណភាពទីមួយ គឺជា មរណភាពរបស់បុគ្គលដែលគ្មានសៅហ្មង ( វិមលបុគ្គល ), មរណភាពទីពីរ គឺជាការឈប់មួយខណៈនៃផលិតកម្ម - គំនិត ( ខណិកក្ស័យ ) ហើយមរណភាពចុងក្រោយគឺជាមរណភាពធម្មតារបស់សព្វសត្វ ។ ក្នុងបណ្ដាមរណភាពទាំងបីនេះ, តើអាត្មាអញ ត្រូវស្លាប់ដោយមរណភាពធម្មតាឬ ?" សូម្បីតែនៅខណៈចុងក្រោយ នៃជីវិតរបស់លោកហើយក៏ដោយ, ក៏ព្រះពុទ្ធឃោសះ នៅតែមានទម្លាប់ពិចារណាបែបទស្សនវិជ្ជាដែរ ។ ដោយចងចាំជាប់ក្នុងព្រះទ័យនូវសិក្ខាបទទាំងឡាយដែលត្រូវប្រតិបត្តិតាម, លោកបានរលត់សង្ខារ ហើយបានយោនយកកំណើតជាថ្មីនៅក្នុង

តុសិតសួគ៌ ។ អដ្ឋកថាទាំងឡាយរបស់លោក ត្រូវបានជាត់សំឡេងនៅនឹងកន្លែងដែលលោកបានបញ្ចប់ដង្ហើមចុងក្រោយរបស់លោក ។ ប៉ុន្តែ មានពាក្យនិយាយតៗគ្នាមកថា អ្នកស្រុកនៅប្រទេសកម្ពុជា តែងគិតថា ព្រះពុទ្ធឃោសៈបានសុគតនៅក្នុងប្រទេសរបស់គេ ក្នុងវត្តដ៏ធំមួយ ហៅថា *ពុទ្ធឃោសវិហារ* ។ ក្រោយពេលបូជាសពលោករួចហើយ, ពួកព្រាហ្មណ៍ និងមនុស្សដទៃទៀត បានរើសអដ្ឋិធាតុរបស់លោក, បញ្ចុះអដ្ឋិធាតុទាំងនោះ នៅក្នុងទីដ៏ពិសិដ្ឋជិតដើមពោធិព្រឹក្ស ហើយសង់ស្តូបលើអដ្ឋិធាតុទាំងឡាយនោះផង ។

## បុព្វាធិការី និង ឧត្តរាធិការី

( Predecessors and successors )

ព្រះពុទ្ធឃោសៈ បានមានពុទ្ធដីកាអំពីពួកបោរាណៈ ឬ បោរាណថេរ ដោយបាននិយាយយោងដល់ព្រះថេរៈទាំងឡាយដែលរៀនព្រះធម៌អំពីគ្រូទាំងឡាយរបស់លោក ហើយរក្សាទស្សនៈទាំងឡាយរបស់គ្រូលោក ។ លោកទាំងឡាយនោះ មិននាំយកមកពិនិត្យ នូវទស្សនៈរឹងត្អឹងឯណានិមួយរបស់ខ្លួនផ្ទាល់នោះទេ ។ យោងតាមគម្ពីរគន្ធវង្ស, លោកទាំងឡាយនោះ គឺជាថេរៈដែលបានចូលរួមក្នុងដំណើរប្រព្រឹត្តទៅនៃសង្គាយនាពុទ្ធសាសនាទាំងបីលើកជាដំបូង ហើយលោកទាំងនោះគឺជាអដ្ឋកថាចារ្យដែលបានគេស្គាល់ដំបូងគេ ដោយពិតប្រាកដ ។

បោរាណាចារិយៈ គឺជាឈ្មោះមួយទៀតរបស់ អដ្ឋកថាចារិយៈ ( អដ្ឋកថាចារ្យ ) ។ យើងមិនយល់ព្រមជាមួយលោកស្រី រីស ដាវិដ (Mrs Rhys Davids) ដែលថា ពួកបោរាណៈតំណាងនិកាយនៃគំនិតទស្សនវិជ្ជាដ៏ជាប់លាប់ (មិនផ្លាស់ប្តូរ) ។ ក្នុងនាមនៃពួកបោរាណៈ, មានភាសិតជាប្រពៃណីខ្លះ ដែលមានចរិតជារឿងព្រេង ឬជាទ្រឹស្តី ត្រូវបានព្រះពុទ្ធឃោសៈលើកយកមកជាទីសំអាង ។ ភាសិតតែមួយគត់ដែលស័ក្តិសមនឹងកន្លែងរបស់ខ្លួននៅក្នុងអត្ថបទគម្ពីរចុងក្រោយ ដូចជា គម្ពីរ*បរិវារៈ*,

គឺជាភាសិតមួយទាក់ទងនឹងខ្សែបន្ទាត់នៃវិន័យ ដែលអាចារ្យទាំងឡាយបានស្រង់យកមកពីព្រះមហិន្ទត្ថេរ និងសហធម្មិកទាំងអស់របស់លោក ។ សេចក្ដីសន្និដ្ឋាននេះអាចត្រូវបានគេចាត់ទុកជាគំរូដើមរបស់អាចារ្យទាំងឡាយ នៅក្នុងគម្ពីរ*ទីបវង្ស* ។ យោងតាមពួកបោរាណៈ ឬពួកអ្នកបុរាណ ( The Ancients ), ព្រះថេរៈទាំងឡាយដែលមាននាមថា មហិន្ទៈ, ឥដ្ឋិយៈ, ឧត្តិយៈ, សម្ពលៈ, និងភទ្ទសាល បាននិមន្តពីប្រទេសឥណ្ឌា ទៅកាន់ប្រទេសសីឡង់ ហើយបានបង្រៀន*វិន័យ*, និកាយទាំងប្រាំរបស់ *សុត្តបិដក* ( សុតន្តបិដក ), ហើយនិងគម្ពីរទាំងប្រាំពីរនៃ*អភិធម្មបិដក*។ ព្រះពុទ្ធឃោសៈ បានអាងលើប្រភពរបស់ពួកអ្នកបុរាណ នៅពេលលោកពន្យល់ទ្រឹស្ដី*បដិច្ចសមុប្បាទ* ។ លក្ខណៈពិសេសមួយ អំពីសេចក្ដីស្រង់របស់ពួកបោរាណៈ គឺថា សេចក្ដីស្រង់នោះទាំងអស់ សរសេរក្នុងទម្រង់ជាពាក្យកាព្យ, គំរូដើមនៃសេចក្ដីស្រង់មាននៅក្នុងគាថា ដែលឧទ្ទិសចំពោះព្រះថេរៈ ព្រះថេរីសម័យបុរាណ ។ ពួកបោរាណៈ បាននិយាយថា :" សីលធមិ គឺជាគ្រឿងអលង្ការរបស់ស្នូម, វាតុបតែងលំអគេ, ដោយមានសីលធមិជាអលង្ការ, ស្នូមប្រែក្លាយទៅជាមនុស្សធំដុំ " ។ ការសិក្សាដ៏ម៉ត់ចត់ អំពីអដ្ឋកថារបស់ព្រះពុទ្ធឃោសៈ នឹងជួយយើងឱ្យចាប់អារម្មណ៍ អំពីសេចក្ដីស្រង់របស់ពួកបោរាណៈ ។

ពួក *ភាណកៈ* ធ្លាប់តែរក្សា និងផ្សព្វផ្សាយអត្ថបទគម្ពីរ តាមទម្លាប់ផ្ទាល់មាត់ ។ អត្ថបទផ្ទាល់មាត់ទាំងឡាយ ត្រូវបានបន្តពីអាចារ្យមួយទៅអាចារ្យមួយ ( អាចារិយបរម្បរាយៈ ), រហូតដល់អត្ថបទទាំងនោះត្រូវបានសរសេរកត់ត្រាជាអក្សរនៅក្នុងប្រទេសសីឡង់ ក្នុងអំឡុងរាជ្យព្រះបាទវដ្ដគាមណី, ហើយនៅក្នុងប្រទេសឥណ្ឌា ក្នុងអំឡុងរាជ្យព្រះបាទកណិស្កៈ ។ នៅក្នុងសេចក្ដីផ្ដើមនៃគម្ពីរ*សុមង្គលវិលាសិនី*, ព្រះពុទ្ធឃោសៈបានភ្ជាប់ប្រភពដើមនៃក្រុមផ្សេងៗ (the different Schools) របស់ពួកភាណកៈ ទៅនឹងកិច្ចការសង្គាយនាពុទ្ធសាសនា

លើកទីមួយ, ដោយប្រការដូច្នេះថា ៖ គ្រាន់តែអត្ថបទវិន័យត្រូវបានព្រះឧបាលី សូធ្យចប់ភ្លាម, ព្រះមហាកស្សបៈជាប្រធាននៃសង្គាយនាទីមួយនោះបានប្រគល់ឱ្យលោក ( ព្រះឧបាលី ) នូវកិច្ចការថែរក្សា *អត្ថបទវិន័យ* ដោយការសូធ្យក្នុងចំណោមសហធម្មិកទាំងឡាយរបស់លោក ។ ការសូធ្យគម្ពីរ *ទីឃនិកាយ* ត្រូវបានបន្ទុកបណ្ដាក់តាមរបៀបដូចគ្នា ទៅឱ្យព្រះអានន្ទ និងសហធម្មិករបស់លោក, ចំណែកឯការសូធ្យគម្ពីរ *មជ្ឈិមនិកាយ* ត្រូវបានប្រគល់ទៅឱ្យក្រុមរបស់ព្រះសារិបុត្ត ។ ការសូធ្យគម្ពីរ *អង្គុត្តរនិកាយ* ត្រូវបានប្រគល់ទៅឱ្យសហធម្មិករបស់ព្រះអនុរុទ្ធ, ចំណែកឯការសូធ្យគម្ពីរ *សំយុត្តៈ* ត្រូវបានរក្សាទុកក្រោមការគ្រប់គ្រងរបស់ ព្រះមហាកស្សបៈផ្ទាល់ ។

អដ្ឋកថាដំបូងៗ ដែលលោកស្រី រីស ដាវិដ ( Mrs Rhys Davids ) បានស្រង់ចុះក្នុងបញ្ជី មានចំនួនប្រាំមួយ ៖ គឺ (១) អដ្ឋកថារបស់ពួកអ្នកតាំងលំនៅក្នុងឧត្តរវិហារ នៅអនុរាធបុរៈ, (២) *មូលអដ្ឋកថា* ឬ *មហាអដ្ឋកថា* ឬ ហៅយ៉ាងសាមញ្ញថា អដ្ឋកថារបស់ពួកអ្នកតាំងលំនៅក្នុងមហាវិហារ នៅអនុរាធបុរៈ ដែរ, (៣) *អន្ធ-អដ្ឋកថា*, បន្សល់ទុកមកនៅកាញ្ចិបុរៈ ក្នុងប្រទេសឥណ្ឌាភាគខាងត្បូង, (៤) *មហាបច្ចរី* ឬ ក្បូនធំ, មានឈ្មោះហៅដូច្នេះ ពីព្រោះអដ្ឋកថានោះត្រូវបានតាក់តែងឡើងនៅលើក្បូនត្រង់កន្លែងណាមួយក្នុងប្រទេសសីឡង់, (៥) *កុរុណ្ឌអដ្ឋកថា*, ត្រូវបានគេហៅដូច្នេះ ពីព្រោះ អដ្ឋកថានោះ ត្រូវបាននិពន្ធចងក្រងឡើងនៅ កុរុណ្ឌវេឡុ-វិហារ ក្នុងប្រទេសសីឡង់, (៦) *សង្ខេប-អដ្ឋកថា* ឬ អត្ថាធិប្បាយសង្ខេប ដែលត្រូវបានគេចាត់ចូលជាមួយនឹងអន្ធ-អដ្ឋកថា, ប្រហែលជានៅភាគខាងត្បូងនៃប្រទេសឥណ្ឌា ។ *មហាបច្ចរី, មហាកុរុណ្ឌិយៈ* និង *អន្ធ-អដ្ឋកថា* ត្រូវបានគេស្រង់ឈ្មោះ និងលើកយកមកពិភាក្សានៅក្នុងគម្ពីរសាមន្តបាសាទិកា, ជាអត្ថាធិប្បាយអំពីវិន័យ ។ គេអាចសន្មតដោយសមហេតុ-ផលថា អដ្ឋកថាទាំងឡាយ

នោះ ទាក់ទងជាសំខាន់ជាមួយការបកស្រាយសិក្ខាបទនៃ វិន័យ ។ *គម្ពីរវិសុទ្ធិមគ្គ* និយាយយោងដល់អដ្ឋកថាវិន័យពីដំបូងជាភាសាសីហឡ្ទះ ។ ប៉ុន្តែ ដោយផ្អែកតែលើហេតុការណ៍នេះប៉ុណ្ណោះ គេមិនអាចសន្និដ្ឋានបានថា អដ្ឋកថា *មហាកុរុណ្ឌិយៈ* និងមហាបច្ចរី, ដែលដកស្រង់ និងពិភាក្សាជាភាសាសីហឡ្ទះ, នៅពេលនោះមានអត្ថិភាពហើយនោះទេ ។ *អាគម-អដ្ឋកថា* ដែលព្រះពុទ្ធឃោសៈបានពឹងផ្អែក, ពេលលោកធ្វើអត្ថាធិប្បាយលើ *និកាយ* បួនដំបូង, និង*បោរាណអដ្ឋកថា*, ដែលផ្អែកនៅលើអដ្ឋកថានេះ, លោកបានធ្វើអត្ថាធិប្បាយទាំងឡាយលើគម្ពីរព្រះអភិធម្ម, គឺគម្ពីរ*ជាតក*, *ពុទ្ធវង្ស*, *ចរិយាបិដក* និង *អបទាន* ។ អដ្ឋកថាទាំងពីរនេះ (អាគមៈ-អដ្ឋកថា និង បោរាណៈ-អដ្ឋកថា ) គឺជាចំណែករបស់*មហាអដ្ឋកថា* ។ ក្នុងឋានៈជាសមាជិក មួយអង្គ នៃមហាវិហារ, ព្រះពុទ្ធឃោសៈ បានអនុវត្តតាមយ៉ាងម៉ត់ចត់នូវប្រពៃណី ធ្វើអត្ថាធិប្បាយរបស់មហាវិហារ ហើយទាត់ចោល ឬ យកចេញនូវទស្សនៈទាំងឡាយរបស់គ្រូ ( អាចារ្យ ) នៃនិកាយអភយគិរី ។ *ទីឃៈ-អដ្ឋកថា*, *មជ្ឈិម-អដ្ឋកថា*, *សំយុត្តៈ-អដ្ឋកថា*, និង*អង្គុត្តរៈ-អដ្ឋកថា* គឺជាផ្អែកសំខាន់បួនរបស់*អាគមៈ-អដ្ឋកថា* ។ *ជាតក-អដ្ឋកថា* ត្រូវបានគេបញ្ចូលទៅក្នុង*បោរាណៈ-អដ្ឋកថា* ។ ការកត់សម្គាល់ដដែលនេះ ក៏អនុវត្តដោយប្រសិទ្ធភាពស្មើគ្នាចំពោះអដ្ឋកថារបស់ព្រះពុទ្ធឃោសៈ លើគម្ពីរព្រះអភិធម្ម វៀរលែងតែគម្ពីរអត្ថសាលិនីចេញ ។ វាអាចជារឿងពិតដែលថា *បោរាណៈ-អដ្ឋកថា* គឺជាឈ្មោះមួយទៀត សម្រាប់ហៅ *មហា-អដ្ឋកថា*, និយាយជារួម ។ វាអាចកើតមានថា *អដ្ឋកថា* ជាភាសាសីហឡ្ទះ ដំបូងគេ មិនមានអត្ថាធិប្បាយលើគម្ពីរទាំងអស់របស់ *ខុទ្ទក-និកាយ* ទេ ។

ទស្សនៈទាំងឡាយដែលព្រះពុទ្ធឃោសៈ បានដកស្រង់ដាក់ក្នុងស្នាព្រះហស្តរបស់លោក ក្នុងនាមព្រះនាគសេន គឺតាមពិតទៅជាទស្សនៈមាននៅក្នុងមិលិន្ទ-

បញ្ហា ។ ការជជែកដេញដោលរវាងព្រះនាគសេន និងស្តេចមិលិន្ទៈ មាននិយាយរៀបរាប់នៅក្នុង *មិលិន្ទបញ្ហា* ។ គេនិយាយថា ការជជែកដេញដោលនេះ បានកើតមានឡើងប្រាំសតវត្ស ក្រោយពេលព្រះពុទ្ធបរិនិព្វាន ពោលគឺក្នុងសតវត្សទីមួយនៃគ្រឹស្ត-សករាជ ។ ការជជែកដេញដោលនេះ សន្មតថាកើតមានមុនយ៉ាងច្បាស់នៃវាទប្បដិ-វាទ (Controversies) នៅក្នុង*គម្ពីរកថាវត្ថុ* ។ កាលបរិច្ឆេទ នៃគម្ពីរកថាវត្ថុនេះ ត្រូវបានគេកំណត់ថានៅឆ្នាំទី ១៨ នៃរាជ្យព្រះបាទអសោក និង ២៣៦ ឆ្នាំ មុនគ្រឹស្ត-សករាជ ។

មហាកច្ចានៈ គឺជាអ្នកនិពន្ធដ៏មានល្បីឈ្មោះ នៃស្នាដៃពីរគឺ*នេត្តិ* និង *បេដកោបទេស* ស្តីពីវិធីសាស្ត្រពន្យល់ ឬ បកប្រែគម្ពីរ ដែលត្រូវបានគេធ្វើឱ្យរីកចំរើនក្នុងពុទ្ធសាសនាថេរវាទ, ស្រករគ្នានឹង *តន្ត្រយុត្តិ* នៅក្នុង *អត្ថសាស្ត្រ* របស់លោក កោដិល្យៈ, *សុស្រុត-សំហិតា* និង ស្នាដៃរបស់ព្រាហ្មណ៍ដទៃទៀត ។ មហាកច្ចានៈ មាននាមដូចគ្នានឹងព្រះថេរៈមហាកច្ចានៈ ដែរ ។ ក្នុងបណ្តាស្នាដៃទាំងពីរ, *បេដកោបទេស* ត្រូវបានដកស្រង់ដោយមានឈ្មោះត្រឹម *បេដកៈ* នៅក្នុងគម្ពីរ *សាមន្តបាសាទិកា* ។ ព្រះធម្មបាល បានសរសេរអត្ថាធិប្បាយលើស្នាដៃទាំងនោះ ។ ទំនាក់ទំនងខាងប្រវត្តិសាស្ត្រ រវាងស្នាដៃទាំងពីរ ហើយនិង *មិលិន្ទៈ* ឋិតក្នុងអន្ធការភាព ពោលគឺពុំច្បាស់ ។ ព្រះពុទ្ធឃោសៈ មិនបានដកស្រង់ប្រភពសំអាងពីស្នាដៃទាំងពីរក្នុងនាមរបស់មហាកច្ចានៈ ទេ ។ ស្នាដៃទាំងពីរនេះ មានតម្លៃក្នុងទំនាក់ទំនងចំពោះគម្ពីរថេរវាទ ដូចគ្នានឹង *និរុត្តៈ* របស់ *យាស្កៈ* មានតម្លៃចំពោះគម្ពីរវេទ, ហើយវិធីសាស្ត្ររបស់ស្នាដៃទាំងពីរ ហាក់ដូចជាបានរីកចំរើន ជាសំខាន់ លើខ្សែបន្ទាត់របស់គម្ពីរ និទ្ទេស ឬ វិភង្គៈ ដែលព្រះថេរៈមហាកច្ចានៈ បានសាកល្បងរួចមកហើយ ។

សេចក្តីត្រូវការឱ្យមានការបកស្រាយដ៏ត្រឹមត្រូវនូវព្រះពុទ្ធវចនៈ ត្រូវបាន

គេចាប់អារម្មណ៍តាំងពីដំបូងទីម្លេះ សូម្បីនៅពេលព្រះបរមគ្រូកំពុងមានព្រះជន្ម នៅឡើយ ។ នៅពេលនោះ គេបានលើកយកសំណួរដ៏ចម្រូងចម្រាសសុំឱ្យព្រះបរមគ្រូផ្ទាល់ដោះស្រាយ ។ គឺនៅពេលនោះហើយដែលយើងបានជួបនឹងដំណាក់កាលដំបូងនៃដើមកំណើតធ្វើអត្ថាធិប្បាយក្នុងពុទ្ធសាសនា ។ ភស្តុតាងដែលមានទាំងអស់ចង្អុលប្រាប់ហេតុការណ៍ថា : ក្នុងរង្វង់ពេលប៉ុន្មានឆ្នាំ នៃការត្រាស់ដឹងរបស់ព្រះពុទ្ធ, ទីតាំងពុទ្ធសាសនា ត្រូវបានស្ថាបនាឡើងនៅក្នុងកន្លែងផ្សេងៗ មានទីតាំងជាប់ទីក្រុង និងបុរីជាច្រើន ។ នៅកន្លែងនិមួយៗ ក៏កើតមានសហគមន៍ភិក្ខុសង្ឃ ឋិតក្រោមការដឹងនាំ និងក្រោមការណែនាំរបស់សាវ័កដ៏មានកិត្តិស័ព្ទមួយអង្គ របស់ព្រះពុទ្ធ ។ ដោយអនុវត្តតាមក្រឹត្យវិន័យជាតាបស ឬ ជាអាចារ្យ ( គ្រូ ) គោចរ, បព្វជិតទាំងឡាយមានទម្លាប់គង់ក្នុងរដូវភ្លៀង នៅក្នុងឱទ្យានកំសាន្តរបស់ព្រះរាជា ឬក្នុងវិហារ ។ ការសាកសួរសុខទុក្ខជាមិត្តភាព និងការទៅមករកគ្នាម្តងម្កាលតាមបែបអ្នកចេះដឹងសហសម័យ គេមិនបានដឹងច្បាស់ទេ ។ ក្នុងចំណោមអ្នកដឹកនាំភិក្ខុសង្ឃផ្សេងៗ, មានភិក្ខុសង្ឃខ្លះ មានឋានៈខ្ពង់ខ្ពស់ខាងទ្រឹស្តី, ខ្លះខាងវិន័យ, ខ្លះខាងការអធិប្បាយធ្វើវិភាគ, ខ្លះខាងការប្រព្រឹត្តតបកម្ម, ខ្លះខាងសំដែងធម៌, ខ្លះខាងទស្សនវិជ្ជា, ខ្លះខាងកំណាព្យ . ល . ។ ក្នុងចំណោមសាវ័កជិតស្និទ្ធរបស់ព្រះពុទ្ធ, មានមនុស្សខ្លះ មកពីត្រកូលព្រាហ្មណ៍ ហើយចេះស្ទាត់ជំនាញគម្ពីរវេទ និងអក្សរសាស្ត្រវេទទាំងមូល ។

គ្រូគោចរ នៅសម័យកាលនោះ តែងត្រាច់ចរនៅក្នុងប្រទេស, ចូលរួមគ្រប់ទីកន្លែងដែលគេឈប់សម្រាក ក្នុងការជជែកសាកសួរដេញដោល ស្តីពីកិច្ចការនានា ទាក់ទងនឹងសាសនា, ទស្សនវិជ្ជា, សីលធម៌, ចរិយាធម៌ និង បែបបទគ្រប់គ្រងប្រទេស ។ កាលណាមានទស្សនវិទូដ៏សំខាន់ណាមួយ និយាយផ្តេសផ្តាស បន្តុះបង្អាប់ព្រះពុទ្ធ, ព្រះធម៌ និង ព្រះសង្ឃ, កាលណាមានទស្សនវិទូបែបនេះណាមួយ

បកស្រាយខុសនូវទស្សនៈរបស់ព្រះពុទ្ធ, កាលណាមានការជជែកដេញដោលដ៏ក្តៅគគុកណាមួយបានផ្ទុះឡើងនៅក្នុងចំណោមភាតរភាពសហសម័យ ឬកាលណាមានភិក្ខុណាមួយប្រព្រឹត្តអនាចារ, ព្រះពុទ្ធ ឬក៏សាវ័ករបស់ព្រះអង្គតែងដាស់តឿនឱ្យភិក្ខុទាំងឡាយទៅជួយការពារផលប្រយោជន៍របស់គេទាំងឡាយនោះ ។

សំណួរ និងចម្លើយដ៏ពេញលេញនៃស័ព្ទសំខាន់ៗ និងអត្ថបទដកស្រង់ពីគម្ពីរ ត្រូវបានគេសន្មតថាជាស្នាដៃរបស់ព្រះសារិបុត្ត ហើយត្រូវបានគេស្គាល់ជាទូទៅថា *សង្គីតិសុត្តន្ត* ។ អត្ថបទជាភាសាសំស្ក្រឹតពុទ្ធសាសនា នៃគម្ពីរសង្គីតិសុត្តន្តនេះមានបកប្រែជាភាសាទីបេត៍ និងភាសាចិន ក្រោមឈ្មោះថា*សង្គីតិបរិយាយសូត្រ* ។ វិធីប្រមូលផ្តុំប្រធានបទផ្សេងៗ ដាក់ក្រោមចំណងជើងលេខរៀង និងវិធីពន្យល់ដោយមធ្យោបាយរៀបរាប់យ៉ាងសាមញ្ញ ដែលព្រះសារិបុត្តបានអនុវត្ត, ផ្តល់លក្ខណៈសំគាល់គម្ពីរពីរ ក្នុងបណ្តាចង្កោមគម្ពីរចាស់ជាងគេ គឺ*សំយុត្តៈ* និង*អង្គុត្តរៈ* ហើយនិងគម្ពីរខ្លះនៃ *អភិធម្មបិដកៈ*, ជាពិសេសគឺ *បុគ្គលប្បញ្ញត្តិ* ។ ព្រះសារិបុត្តមិនបានបញ្ចប់បញ្ជីទេ ។ នៅមានសាវ័កល្បីឈ្មោះ និងមានចំណេះជ្រៅជ្រះផ្សេងទៀត របស់ព្រះពុទ្ធ ។ ក្នុងចំណោមសាវ័កទាំងនោះ មានសាវ័កខ្លះជាស្ត្រីភេទ, ដែលបានជួយតាមលទ្ធភាពរបស់ខ្លួន ធ្វើឱ្យមានដំណើររីកចំរើនខាងការធ្វើអត្ថាធិប្បាយ ។ ចូរយើងលើកយកជាឧទាហរណ៍ ករណី ព្រះថេរៈមហាកច្ចានៈ ដែលមិនសូវគាប់ព្រះទ័យនឹងការរៀបរាប់ជាស្វ័យប្រវត្តិ, ហើយបានបង្កើតស័ព្ទបច្ចេកទេស ដូចជាព្រះសារិបុត្តបានធ្វើដូច្នោះទេ ។ លោកដាក់កំហិតដល់ខ្លួនលោក ត្រឹមតែការបកស្រាយអត្ថន័យបង្កប់ខាងក្នុង និងខ្លឹមសារទស្សនវិជ្ជាដ៏ពិត នៃគោលការណ៍ដំបូងរបស់ព្រះពុទ្ធ ។ លោកត្រូវបានគេចាត់ទុកជាបុគ្គលដ៏មានឥទ្ធិពលចម្បងមួយរូបលើ*បដិសម្ភិទា* ឬវិធីសាស្ត្រនៃប្រព័ន្ធវិភាគរបស់ព្រះពុទ្ធ ។ នៅក្នុងមជ្ឈិមនិកាយ, យើងបានឃើញសេចក្តីរៀបរាប់ ដ៏វែងរបស់លោក លើការកត់សម្គាល់ពិសេស ឬលើភាពផ្សេងគ្នា

នៃស័ព្ទអរូបីបច្ចុប្បន្ន ។ ភាគដំបូងនៃសេចក្តីពន្យល់របស់ព្រះមហាកោដ្ឋិតៈ អាច និយាយបានថា ជាគ្រឹះប្រវត្តិសាស្រ្តនៃលក្ខណាហារ ក្នុង*នេត្តិប្បករណៈ*, នៃអត្ថបទខ្លះៗ របស់*មិលិន្ទបញ្ហា* និងសេចក្តីរៀបរាប់ខ្លះៗ ក្នុងអដ្ឋាធិប្បាយរបស់ព្រះពុទ្ធ-ឃោសៈ ។ ព្រះមោគ្គល្លាន, ព្រះអានន្ទ, ព្រះធម្មទិន្នា និងព្រះខេមា បានធ្វើវិភាគមានប្រហាក់ប្រហែលគ្នា ។

អត្ថបទគម្ពីរទាំងឡាយមានសេចក្តីបកស្រាយពន្យល់ជាពាក្យវាយ ឬមានអដ្ឋាធិប្បាយមួយពាក្យម្តងៗ ។ គេបានចាត់ថ្នាក់អត្ថបទគម្ពីរទាំងនោះថា *វេយ្យា-ករណៈ* ។ គម្ពីរព្រះអភិធម្មទាំងឡាយ វៀរលែងតែគម្ពីរ *កថាវត្ថុ* តែមួយចេញ ក៏ត្រូវបានគេចាត់ចូលក្នុងនិយមន័យនៃ *វេយ្យាករណៈ* ដែរ ។ *កថាវត្ថុ* ដែលជាគម្ពីរវាទប្បដិវាទពុទ្ធសាសនាមួយ (Buddhist controversies) ទាក់ទងទៅនឹងសម័យកាលព្រះបាទអសោក បានដើរតាមខ្សែបន្ទាត់រីកចំរើនមួយផ្ទាល់ដោយឡែករបស់ខ្លួន ។ តាមរយៈវាទប្បដិវាទ, គេអាចមើលឃើញដោយជាប់ចិត្ត នូវវិធីបកស្រាយប្រកបដោយស្មារតីរិះគន់ លើចំណុចអាថ៌កំបាំង ហើយមានសារសំខាន់ផ្សេងៗរបស់លទ្ធិពុទ្ធសាសនា ។ វិធីសាស្រ្តប្រែផ្ចិតគម្ពីរសរសេរទុកក្នុងគម្ពីរ *នេត្តិ* និង *បិដកោបទេស* អាចត្រូវបានគេចាត់ទុកជាជំហានមួយវែងឆ្ងាយ ពីដំណាក់កាលនៃគម្ពីរនិទ្ទេសៈ ឬវិភង្គៈ, ដូចគ្នានឹងការជជែកដេញដោលនៅក្នុងមិលិន្ទៈ អាចត្រូវបានគេចាត់ទុកជាជំហានមួយវែងឆ្ងាយពីបដិវាទកម្មទាំងឡាយនៅក្នុង *កថាវត្ថុ* ។ ខ្សែបន្ទាត់ពីរនេះនៃដំណើរធ្វើអដ្ឋាធិប្បាយពីមុន ត្រូវបានគេរកឃើញនៅទីបំផុតក្នុងអដ្ឋកថា ។

ព្រះពុទ្ធទត្ត, ព្រះចុល្លពុទ្ធឃោសៈ, ព្រះពុទ្ធឃោសៈទី III, ព្រះធម្មបាល, ព្រះឧបសេន និងព្រះមហានាម គឺជាអ្នកបន្តវេនអំពីព្រះពុទ្ធឃោសៈ ដ៏គួរឱ្យកត់សំគាល់ ។

*( នៅមានត )*

# អហឹង្សា និងដំណោះស្រាយជម្លោះ

រៀបរៀងដោយ ឥន្ទបញ្ញោភិក្ខុ ហេង មណីចិន្តា

ជាការប្រសើរណាស់ ដែលយើងទាំងអស់គ្នានាំគ្នាធ្វើសិក្ខាសាលាអំពីប្រធានបទដ៏ធំមួយ ដែលមានតម្លៃគួរពិចារណា គួរពិភាក្សា និងគួរស្វែងយល់ និងជាប្រធានបទដែលទាក់ទងផ្ទាល់ទៅនឹងជីវិតរបស់មនុស្សគ្រប់រូប សង្គមគ្រប់សង្គម ជាពិសេស មនុស្សខ្មែរ សង្គមខ្មែរ ដែលកំពុងធ្លាក់ចូលទៅក្នុងបរិបទនៃប្រធានបទនេះ ។

អាចក្តីគិតថា បើយើងទំពារប្រធានបទនេះបាន វាមិនត្រឹមតែមានប្រយោជន៍សំរាប់ខ្មែរទេ គឺនឹងជាប្រយោជន៍ដល់និរន្តរភាពរបស់ពិភពលោកទាំងមូល ជាពិតប្រាកដផង ។

តាមពិត ប្រធានបទនេះ អាចថាជាបុរាណវត្ថុដែលមានចំណាស់ជាងគេទាំងអស់តែមួយគត់ ដែលសល់មកដល់ពួកយើង នាស.វ. ទី២០ នេះ ចាប់តាំងពីមានកំណើតមនុស្ស និងសង្គមមនុស្ស លើផែនដីនេះមកម្ល៉េះ ហើយវានឹងក្លាយទៅជាប្រធានបទមួយដ៏មានសារសំខាន់បំផុត សំរាប់ថ្ងៃអវសាន ឬថ្ងៃគង់វង្សរបស់មនុស្ស និងចក្រវាឡទាំងមូល នាអនាគត ។ ដូច្នេះ សូមឱ្យយើងយកចិត្តទុកដាក់ឱ្យមែនទែន ក្នុងកិច្ចសិក្ខាសាលានេះ ។

ប្រហែលជា ២៦០០ ឆ្នាំមុន មានអគ្គបុរសម្នាក់បានធ្វើការសិក្សា ស្រាវជ្រាវលើប្រធានបទនេះ យ៉ាងខ្លាំងក្លាជាទីបំផុត ដោយហ៊ានយកជីវិតជាដើមផាន់អស់រយៈពេល ៦ ឆ្នាំគត់ និងបានយកមកដាក់ឱ្យគេសាកល្បងពិសោធមើល ថាពិតជាបានការមែន អស់រយៈពេល ៤៥ ឆ្នាំទៀត ទើបលោកអស់ចិត្ត ហើយក៏លាចាកលោកនេះទៅ ដោយបន្សល់ទុកនូវឯកសារនៃការស្រាវជ្រាវនោះរហូតដល់សព្វថ្ងៃ

ដែលជាមរតកលោកមួយ ដែលមិនអាចរកបាននៅក្នុងការស្រាវជ្រាវរបស់អ្នកណាទៀតឡើយ ។ *អគ្គបុរសនោះឈ្មោះ សិទ្ធត្ថៈ ឬព្រះសម្មាសម្ពុទ្ធរបស់យើងនេះឯង* ។

ជាការអះអាងទៅលើការពោលខាងលើនេះ អាចក្តីសូមលើកយកនូវពាក្យដែលព្រះអង្គ និងសាវ័ករបស់ព្រះអង្គ បានពោលទុកក្នុងគម្ពីរព្រះត្រៃបិដកខ្លះៗដូចខាងក្រោមនេះ :

**យេ ច ធម្មា ហេតុប្បភវា តេសំ ហេតុំ តថាគតោ**
**តេសញ្ច យោ និរោធោ ច ឯវំ វាទី មហាសមណោ**

ព្រះមហាសមណៈ តែងបង្រៀនតែអំពីធម៌ណាដែលកើតពីហេតុ និងវិធីសំរាប់រំលត់នូវហេតុនោះ តែប៉ុណ្ណោះ ។

**ទុក្ខមេវ ហិ សម្ភោតិ ទុក្ខំ តិដ្ឋតិ វេតិ ច នាញ្ញត្រ**
**ទុក្ខា សម្ភោតិ នាញ្ញត្រ ទុក្ខា និរុជ្ឈតិ**

មានតែទុក្ខទេដែលកើត មានតែទុក្ខទេដែលលូតលាស់តាំងនៅ
ក្រៅពីទុក្ខគ្មានអ្វីទេដែលកើត ក្រៅពីទុក្ខគ្មានអ្វីរលត់ទេ ។

**យោ ច ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គតោ**
**ចត្តារិ អរិយសច្ចានិ សម្មប្បញ្ញាយ បស្សតិ**
**ទុក្ខំ ទុក្ខសមុប្បាទំ ទុក្ខស្ស ច អតិក្កមំ**
**អរិយញ្ចដ្ឋង្គិកំ មគ្គំ ទុក្ខូបសមគាមិនំ ។**

អ្នកដែលបានយកព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃជាទីពឹង រមែងបានឃើញដោយបញ្ញាត្រូវ នូវសច្ចៈដ៏ប្រសើរបំផុត ៤ ប្រការ គឺអ្វីជាសេចក្តីទុក្ខ ហេតុដែលនាំឱ្យកើតសេចក្តីទុក្ខនោះ ការរំលត់នូវសេចក្តីទុក្ខ និងវិធីដ៏ល្អ ៨ ប្រការ សំរាប់នាំទៅរកការរំលត់ទុក្ខនោះ ។

ពាក្យថា ធមិ នៅក្នុងកថាទី ១ លោកថាស្មើនឹងពាក្យ ទុក្ខ ក្នុងកថាខាងក្រោមៗ ។

ពាក្យថា ទុក្ខៈ នេះ ក្នុងវចនានុក្រមបាលី-អង់គ្លេស មានសេចក្ដីប្រែថា suffering ( សេចក្ដីទុក្ខ ), misery ( ទុរគតភាព ), woe ( ភាពកំសត់ ), pain ( ការឈឺចាប់ ), ill ( ជំងឺ ), sorrow ( ការសោកសៅ ), trouble ( រញ៉េរញ៉ៃ ), discomfort ( អផាសុកភាព ), unsatisfactoriness ( ការមិនពេញចិត្ត ), problematic situation ( ស្ថានភាពដែលមានបញ្ហា ), stress ( ការតានតឹង ), conflict ( ទំនាស់ ) .....

ដូច្នេះ យើងអាចនិយាយថាព្រះសម្មាសម្ពុទ្ធ លោកបានស្រាវជ្រាវ និងប្រៀនប្រដៅតែអំពីរឿងទំនាស់ និងវិធីសំរាប់រំលត់នូវទំនាស់តែប៉ុណ្ណោះ ដែលត្រូវចំនឹងប្រធានបទដែលយើងកំពុងនាំគ្នាពិភាក្សា និងស្វែងយល់ ។

*តើព្រះពុទ្ធ លោកនិយាយពីរឿងទំនាស់ និងវិធីដោះស្រាយទំនាស់ដូចម្ដេចខ្លះ ?*

## ប្រភេទទំនាស់

*ទំនាស់ ឬជម្លោះ មាន ៣ ប្រភេទ*

១- ទំនាស់ខ្លួនឯង : គឺការសង្ស័យ ការសោកស្ដាយ វិប្បដិសារី ការកើតទុក្ខ ការខឹងនឹងខ្លួនឯង ការមិនអាចសំរេចចិត្តបាននៅក្នុងចិត្តរបស់ខ្លួន លើវិថីជីវិតរបស់ខ្លួន ដូចជា របស់ហ្នឹងគួរយក ឬមិនគួរ ; ផ្លូវហ្នឹងត្រូវដើរ ឬត្រូវជៀសវាង ; សង្គមហ្នឹងគួររស់នៅ ឬមិនគួររស់នៅ ; របស់ហ្នឹងត្រូវ ឬខុស ។ ល ។ គឺវាប្រទាំងប្រទើស ច្របូកច្របល់នៅក្នុងចិត្ត ។ លទ្ធផលនៃទំនាស់នេះ ធ្វើឱ្យសុខភាពចិត្តចុះខ្សោយ ឆាប់ខឹង ខឹងច្រើនវង្វេង ភ្លេចមុខភ្លេចក្រោយ យល់ខុស

ជាត្រូវ យល់ត្រូវជាខុស និងធ្វើឱ្យសុខភាពរាងកាយទ្រុឌទ្រោម ដូចជាឆាប់ចាស់ មានជំងឺក្រពះ ជំងឺបេះដូង ចុកដៃ ជើង បរិភោគមិនបាន និងអាចស្ទុះទៅរកអ្នកដទៃ ឬឈានទៅរកមរណភាពមុនកាលកំណត់ក៏មាន ។

២- ទំនាស់សង្គម ៖ គឺការទាស់ជាមួយមនុស្សម្នាក់ទៀត ឬជាមួយក្រុម បក្ស សង្គម ប្រទេស ដែលខ្លួនរស់នៅជាមួយ ឬដទៃក្រៅពីរបស់ខ្លួន ។ លទ្ធផលនៃទំនាស់នេះ គឺទៅជាខឹងគ្នា មើលមុខគ្នាមិនចំ បៀតបៀនគ្នា សម្លាប់គ្នា និងកើតជាសង្គ្រាមក៏បាន ; ទៅជាលួច បំផ្លាញ ស៊ីសំណូក សូកប៉ាន់ ធ្វើឱ្យវិនាសដល់ទ្រព្យសម្បត្តិគ្នា ; ទៅជារំលោភលើសិទ្ធិក្រុមគ្រួសារគ្នា ដូចជា មើលងាយ រំលោភ ចាប់លួចកូនចៅ ភរិយាស្វាមីគ្នាជាដើម ; ទៅជាកុហក បោកបញ្ឆោត ជេរប្រទេចគ្នាដោយសម្ដីអសុរោះ មិនជាការគួរឱ្យស្ដាប់ ; ចាក់ចុច អុជអាលធ្វើឱ្យបែកបាក់សាមគ្គីគ្នាជាដើម ; និងក្លាយខ្លួនទៅជាមនុស្សចូលសង្គមគេមិនចុះ យកគ្រឿងញៀនធ្វើជាត្រីមុខ ដើម្បីបំភ្លេចទុក្ខ ដែលជាការកឱ្យកើតនូវអាជ្ញាកម្មផ្សេងៗទៀត មិនចេះចប់ ។

៣- ទំនាស់ធម្មជាតិ ៖ គឺការរំលោភទៅលើធម្មជាតិ ប្រឆាំងនឹងច្បាប់ធម្មជាតិ កេងប្រវ័ញ្ចធម្មជាតិ ហួសពីធម្មជាតិអាចអត់ទ្រាំបាន ដូចជាការកាប់ព្រៃឈើអស់ ការបូមទឹកពីក្រោមផែនដីអស់ ការបូមយកប្រេងកាតមកប្រើដោយមិនគិត ។ ល ។ លទ្ធផលនៃការទំនាស់ជាមួយធម្មជាតិ គឺការដែលធម្មជាតិដាក់ទណ្ឌកម្មមកវិញ ដូចជា ការកើតឡើងនៃ Ozone layer, Green House effect ទឹកជំនន់, ការរាំងស្ងួត, ជំងឺប្លែកៗ ជាដើម ។

## ហេតុដែលនាំឱ្យកើតជាទំនាស់

១- ទាស់គ្នាព្រោះរឿងវត្ថុ, រឿងសំឡេង, រឿងរសជាតិ, និងវេទនារម្មណ៍

ខាងផ្លូវកាយ ។ ក្នុងភាសាបាលី លោកហៅថាទំនាស់ព្រោះរឿងកាមវត្ថុ ដណ្ដើមគ្នារឿងអាមិស មិនបានដូចចិត្តក៏ទាស់ ; បានមកហើយបាត់ទៅវិញក៏ទាស់ ( កាម-តណ្ហា ) ។

២. ទាស់គ្នាព្រោះរឿងឋានៈ វណ្ណៈ កម្រិតនៃការរស់នៅ ( ភវតណ្ហា ) ។

៣. ទាស់គ្នាព្រោះខ្លាចវិនាស ( វិភវតណ្ហា ) ។

៤. ទាស់គ្នាព្រោះរឿងច្បាប់ រឿងវិន័យ របៀប ធម្មនុញ ( សីល-វិបត្តិ ) ។

៥. ទាស់គ្នាព្រោះរឿងចរិយាមារយាទ សុជីវធម៌ ទំនៀមទម្លាប់ បែបនៃការប្រព្រឹត្ត ( អាចារវិបត្តិ ) ។

៦. ទាស់គ្នាព្រោះរឿងទ្រឹស្ដី មនោគមវិជ្ជា ឧត្ដមគតិ ជំនឿ សាសនា វប្បធម៌ ( ទិដ្ឋិវិបត្តិ ) ។

៧. ទាស់គ្នាព្រោះរឿងអាជីវកម្ម រឿងមុខរបរ រឿងចិញ្ចឹមជីវិត រឿងសេដ្ឋកិច្ច រឿងការងារ ( អាជីវវិបត្តិ ) ។

៨. ទាស់គ្នាព្រោះរឿងបានលាភ ឬបាត់លាភ ( លាភ អលាភ ) ។

៩. ទាស់គ្នាព្រោះរឿងបានយស ឬបាត់យស ( យស អយស) ។

១០. ទាស់គ្នាព្រោះរឿងបានទទួលការសរសើរ ឬបង្អាប់បន្ទោស ( បសំ-សា និន្ទា ) ។

១១. ទាស់គ្នាព្រោះរឿងបានសុខ ឬបានទុក្ខ ( សុខ ទុក្ខ ) ។

១២. ទាស់គ្នាព្រោះអត់ការធ្វើ ទំនេរពេក ឬការងារច្រើនពេក នាំឱ្យច្របូកច្របល់ ( កម្ម ) ។

១៣. រឿងហូប ស្លៀកពាក់ កន្លែងនៅ ថ្នាំព្យាបាល ( បច្ច័យ ៤ ) ។

## ភាវៈគ្មានទំនាស់ គ្មានជម្លោះ សុខ ការរួមរស់នៅជាមួយគ្នា

ជម្លោះគឺជារឿងធម្មតាប្រចាំសង្គមមនុស្ស (សាមញ្ញលក្ខណៈ : សព្វេ សង្ខារា ទុក្ខា = អ្វី១ទាំងអស់ សុទ្ធតែជាទុក្ខ ) ។ ពាក្យថា សង្គម ភាសាបាលី អានថា សង្គមៈ មកពីពាក្យថា សង្គាម ដែលភាសាសំស្រ្កឹតហៅថា សង្គ្រាម ។ ដូច្នេះ គ្មានអ្វីដែលសង្ស័យទេ ដែលថាហេតុអ្វីទើបមនុស្សចេះតែមានទំនាស់ ឬឈ្លោះគ្នានោះ ។ តែប្រការដែលសំខាន់ គឺថា មនុស្សត្រូវរស់នៅជាមួយគ្នា រស់នៅក្នុងសង្គម ( ក្នុងភាសាបាលី សង្គមៈ ប្រែទៀតថា សមាគម ការសេពគប់គ្នា ការរស់នៅជាមួយគ្នា ) ដោយមិនអាចជៀសវាងបាន ។ យើងមិនអាចមិនមានជម្លោះ ( ទុក្ខ ) បានទេ ក្នុងឋានៈយើងជាបុថុជ្ជន តែយើងអាចដោះស្រាយនូវជម្លោះនោះបាន រំងាប់នូវជម្លោះនោះបាន និងទប់កុំឱ្យរាលដាលធំបាន រហូតដល់ក្លាយទៅជាសង្គ្រាមប្រហារគ្នា ។ វាដូចគ្នានឹងការដែលយើងមិនអាចមិនស្លាប់បានទេ តែយើងអាចរកថ្នាំមកព្យាបាល មកពន្យារអាយុរបស់យើងឱ្យនៅវែង តាមដែលអាចវែងបានដែរ ។

**នត្ថិ សន្តិ បរំសុខំ** ពុំមានសេចក្ដីសុខឯណា ស្មើដោយការមានសន្តិភាពឡើយ ។ គោលបំណងនៃជីវិតមនុស្ស និងសង្គម គឺ *សន្តិភាព* ការមិនមានជម្លោះ ការមិនមានទំនាស់ សេចក្ដីស្ងប់សុខ ។ សន្តិភាព ( និព្វាន ) ជាពាក្យផ្ទុយនឹងពាក្យជម្លោះ ពាក្យទំនាស់ ( ទុក្ខៈ ) ជារបស់ដែលនរណាក៏ចង់បាន ចង់កើតមាននៅក្នុងជីវិតខ្លួន និងសង្គមខ្លួនដែរ ។ *តែដើម្បីទៅដល់ភាវៈដែលជាសន្តិនេះ តើយើងត្រូវទៅ ត្រូវដើរ តាមផ្លូវណា វិធីណា របៀបណា ទើបបានដល់សន្តិភាព និងបានទទួលសន្តិភាពនោះ ដោយពិត១ ?*

## វិធីដើម្បីបំបាត់ជម្លោះ និងទំនាស់

នៅក្នុងបរិបទដែលយើងកំពុងតែសន្ទនានេះ យើងបានព្យាយាមបំបាត់

ជម្លោះទាំងឡាយ ដោយពាក្យ*អហឹង្សា* ។ គំនិតនៃការប្រើពាក្យអហឹង្សា នៅក្នុងការដោះស្រាយជម្លោះ ដែលគេស្គាល់ជាទូទៅ គឺគំនិតរបស់មហាត្មៈគន្ធី រដ្ឋបុរសរបស់ឥណ្ឌា ក្នុងសម័យទាមទារឯករាជ្យអំពីអង់គ្លេស ។ ចលនានេះ បានក្លាយទៅជាលទ្ធិមួយ ដែលគេកំពុងតែពេញនិយម ថាជាមធ្យោបាយមួយដែលល្អ សំរាប់ដោះស្រាយជម្លោះនានា ទាំងក្នុងឋានៈជាបុគ្គល និងសង្គម ។ តែប្រវត្តិនៃពាក្យនេះ ប្រើតាំងពីសម័យពុទ្ធកាលមកម៉្លេះ ។

អាចក្តីគិតថា ល្អណាស់ តែវាដូចជាងាយៗពេក បើយើងប្រើពាក្យនេះ ដោយពុំបានគិតគូរឱ្យហ្មត់ចត់ និងស្គាល់វាឱ្យបានច្បាស់លាស់ទេនោះ ។ នៅក្នុងប្រព័ន្ធនៃការដោះស្រាយបញ្ហា យ៉ាងហោចណាស់ ក៏យើងត្រូវគិតដល់រឿង ៥ យ៉ាងដែរ គឺ *អ្នកឈ្លោះ រឿងដែលឈ្លោះ អ្នកដោះជម្លោះ របៀបដោះស្រាយជម្លោះ និងលទ្ធផលនៃដំណោះស្រាយនោះ* ។ លុះត្រាតែរបស់ទាំង ៥ នេះ មិនហឹង្សាទើបសន្តិភាព ឬការជានាគ្នាហ្នឹង វាមានន័យគ្រប់គ្រាន់ និងមានស្ថិរភាព បើពុំនោះទេ វាគ្រាន់តែជាការដាក់កញ្ចក់ឱ្យត្រីក្រឹមក្នុងដប រួតបង្ហាញរាងតែប៉ុណ្ណោះ ។

• *អ្នកឈ្លោះ :*

១) មានទស្សនៈ មានជំនឿ មានការយល់ឃើញ វប្បធម៌ ក្នុងរឿងជម្លោះយ៉ាងណា ហើយទស្សនៈ ជំនឿ ការយល់ឃើញ វប្បធម៌ នោះខុសគ្នាដូចម្តេច ( សទ្ធា ) ។

២) មានការប្រព្រឹត្ត មានសីលធម៌ មានសីលប៉ុណ្ណា ខុសគ្នាកម្រិតណា : ជាអ្នកដែលនិយមការប្រើតែហឹង្សា មានវាយតប់ សម្លាប់ ( បាណាតិបាតា ), លួចកេងប្រវញ្ច ( អទិន្នាទានា ), ងប់ងល់នឹងរឿងកាមគុណ ( កាមេសុមិច្ឆាចារា ), កុហក និយាយមិនទៀងត្រង់ មិនមានសច្ចៈជាប្រចាំ ( មុសាវាទា ) និងជាអ្នកមិន

មានសតិគ្រប់គ្រាន់ព្រោះអំណាច គ្រឿងស្រវឹង ឬទេ ? ( សីល ) ។

៣) មានការលះបង់ដើម្បីសន្តិភាព និងការរស់នៅជាមួយគ្នាប៉ុណ្ណា មានទំនោរទោរទន់ដាក់គ្នាកម្រិតណា មិនឃើញតែប្រយោជន៍ខ្លួនត្រឹមណា ( ចាគៈ ) ។

៤) ការសិក្សារៀនសូត្រ កម្រិតវប្បធម៌ អាយុ សតិបញ្ញា ការចេះដឹងយ៉ាងណា ខុសគ្នាដូចម្តេច ( បញ្ញា ) ។

បើទាំង ៤ នេះ ប្រហាក់ប្រហែលគ្នា ឬអាចធ្វើសម្បទានឱ្យមានភាពប្រហាក់ប្រហែលគ្នាបាន អ្នកឈ្លោះគ្នានោះ អាចនឹងឈានទៅរកការត្រូវគ្នាវិញដោយវិធីអហឹង្សាបាន ។

• *រឿងដែលឈ្លោះ :*

ទាស់គ្នារឿងអី ធំ ឬតូច សំខាន់ ឬមិនសូវសំខាន់ ស្លាប់ ឬរស់ រឿងពិត ឬមិនពិត រឿងហិង្សា ឬអហឹង្សា មានហេតុផលច្បាស់លាស់ឬទេ ។ ( សូមមើលហេតុដែលនាំឱ្យទាស់ខាងលើ ) ។

• *អ្នកដោះ :*

តើអ្នកឈ្លោះដោះស្រាយទំនាស់ដោយខ្លួនឯង ឬពឹងពាក់ឱ្យមានអ្នកមកជួយដោះស្រាយឱ្យ ?

**យម្ហិ សច្ចញ្ច ធម្មោ ច អហឹសា សញ្ញមោ ទមោ**
**ស វេ វន្តមលោ ធីរោ សោ ថេរោតិ បវុច្ចតិ ។**

អ្នកណាមានសច្ចៈ មានធម៌ *មិនហឹង្សា* ជាអ្នកសង្រួម មានការត្រួតត្រាចិត្តខ្លួនបាន ឆ្លាត និងមិនមានមន្ទិលនៅក្នុងខ្លួន អ្នកនោះទើបហៅថាជាថេរៈបាន ។

ថេរៈ ក្នុងទីនេះ សូមសំគាល់ថាជាអ្នកដែលដោះស្រាយបញ្ហាទំនាស់នោះ ។

## លក្ខណៈ ១០ យ៉ាងរបស់អ្នកដោះស្រាយបញ្ហា

*១) ថេរោ រត្តញ្ញូ* ៖ ជាមនុស្សពេញវ័យ មានចំណាស់ មានការពិសោធន៍ច្រើន,

*២) សីលវា* ៖ ជាអ្នកមានសីល គោរពច្បាប់ វិន័យ,

*៣) ពហុស្សុតោ* ៖ ជាពហុស្សូត ជាអ្នកចេះដឹងទូលំទូលាយ មានការសិក្សាខ្ពស់ច្រើន,

*៤) ស្វាគតបាដិមោក្ខោ* ៖ ចេះច្បាប់ ជានីតិបណ្ឌិត អាចយល់កិច្ចរាក់ជ្រៅក្នុងច្បាប់ទាំងឡាយបាន,

*៥) អធិករណសមុប្បាទវូបសមកុសលោ* ៖ ឆ្លៀវឆ្លាត មានចំណេះដឹងមានបច្ចេកទេសក្នុងការរំងាប់អធិករណ៍ ដោះស្រាយជម្លោះដែលកើតឡើងឱ្យស្ងប់ស្ងាត់ទៅវិញបាន,

*៦) ធម្មកាមោ* ៖ ជាអ្នកស្រឡាញ់ធម៌ ស្រឡាញ់ការចេះដឹង ស្រឡាញ់ការពិត ចេះស្តាប់ ចេះនិយាយ ធ្វើឱ្យមានបរិយាកាសមិត្តភាព រីករាយបានគ្រប់ៗគ្នា ធ្វើឱ្យគេចង់ពិភាក្សា ប្រឹក្សាជាមួយ,

*៧) សន្តុដ្ឋោ* ៖ ជាអ្នកសន្តោស មិនសម្លឹងឃើញតែផលប្រយោជន៍ផ្ទាល់ខ្លួនជាធំ,

*៨) បាសាទិកោ* ៖ មានអាកប្បកិរិយាគួរឱ្យជ្រះថ្លា មានបុគ្គលិកលក្ខណៈល្អគួរឱ្យរាប់អាន,

*៩) ឈានលាភី* ៖ ជាអ្នកមិនមានសេចក្តីទុក្ខក្នុងចិត្ត មិនមានវិបត្តិផ្លូវចិត្ត ចិត្តមានសមាធិល្អ,

*១០) អនាសវចេតោវិមុត្តិបញ្ញាវិមុត្តិ* ៖ មានចិត្តបរិសុទ្ធ ផុតពីអគតិធម៌ គឺមិនលំអៀងព្រោះស្រឡាញ់ ព្រោះខ្លាច ព្រោះស្អប់ និងព្រោះមិនដឹង,

អ្នកដោះស្រាយជម្លោះ គប្បីសម្លឹងមើលខ្លួនឯងលើចំណុចខាងលើ មុននឹងដោះជម្លោះគេ ហើយអ្នកដែលពឹងឱ្យគេដោះឱ្យ ក៏គប្បីសម្លឹងមើលដែរ តើអ្នកនោះមានកត្តាទាំងនេះឬទេ ?

## អ្នកដោះគប្បីមានសប្បុរិសធម៌ ៧ យ៉ាងនៅក្នុងខ្លួន

១) តើរឿងនេះ កិច្ចការនេះ មានដំណើរយ៉ាងដូចម្ដេច មានប្រវត្តិមកដូចម្ដេច និងព្រោះតែពីហេតុអ្វី ? ត្រូវសិក្សា ស្រាវជ្រាវឱ្យឃើញ *កុំចេះតែជឿគេងាយៗពេក* ( ធម្មញ្ញុតា )។

២) តើរឿងនេះ កិច្ចការនេះ ចេញជាលទ្ធផលយ៉ាងណាខ្លះ ហើយតទៅអនាគត វានឹងទៅជាយ៉ាងណា មានគោលបំណងយ៉ាងណា ។ ត្រូវសិក្សា វិភាគ និងទស្សន៍ទាយឱ្យបានច្បាស់លាស់ និងមានហេតុផល កុំតាមព្រេងសំណាង ( អត្ថញ្ញុតា ) ។

៣) ត្រូវដឹងពីខ្លួនឱ្យបានច្បាស់លាស់ តាំងពីសុខភាព សមត្ថភាព និងគុណធម៌ ថាតើប្រកបកិច្ចការហ្នឹង ដោះស្រាយកិច្ចការហ្នឹង បានដោយជោគជ័យ និងសុវត្ថិភាពឬទេ ជៀសវាងទៅទាំងកម្រោល ៨ ជ្រុង ទទឹងទិស ដែលជាហេតុនាំឱ្យអន្តរាយដល់ខ្លួនទទេ ( អត្តញ្ញុតា ) ។

៤) ពេលវេលាកំណត់នូវអ្វីៗទាំងអស់ ។ *ផ្លែឈើមុននឹងទុំ វាត្រូវឆ្លងកាត់ការថែទាំ, ចេញត្រួយ, ចេញផ្កា, ក្ដិប, ចាស់, ស្រគាល ហើយទីបំផុតក៏នឹងទុំ* ។ ដូច្នេះ ត្រូវសិក្សាពីកាលវេលាឱ្យបានល្អ តើកាលណាគួរធ្វើអ្វី និយាយអ្វី គិតអ្វី គួរធ្វើប៉ុណ្ណា ។ល។ ( កាលញ្ញុតា ) ។

៥) ធ្វើអ្វី និយាយអ្វី គិតអ្វីក៏ដោយ ត្រូវឱ្យមានប្រមាណ គឺ ល្មម ។ ដំណោះស្រាយដែលស្ថិតនៅក្នុងពាក្យ *ល្មម* ជាដំណោះស្រាយដែលអស្ចារ្យជាទី

បំផុត ។ បើមិនចេះល្មមទេ នឹងមានតែសេចក្ដីក្ដៅក្រហល់ក្រហាយ នៅក្នុងដួងចិត្តជាពុំខាន ។ ដាំចង្ក្រានឱ្យប្រមាណឆ្នាំង ! ( បមាណញ្ញុតា ) ។

៦) *នៅជាមួយអ្នកណា ត្រូវស្គាល់អ្នកនោះឱ្យច្បាស់* ។ បើមិនស្គាល់ច្បាស់ទេ នឹងមានការផ្សងព្រេងយ៉ាងគ្រោះថ្នាក់ជាទីបំផុត ។ បើស្គាល់គេច្បាស់អាចនឹងទាញយកនូវផលប្រយោជន៍បានយ៉ាងច្រើនពីការស្គាល់នោះ និងមិនព្រួយពីរឿងអ្វីគ្រោះថ្នាក់ផង ។ ដឹងពីគេឱ្យច្បាស់ តើគេជាជនប្រភេទណា ចូលចិត្តអ្វី ហើយយកមកគិតថាតើយើងគួរធ្វើចំពោះគេយ៉ាងដូចម្ដេច ( បុគ្គលញ្ញុតា ) ។

៧) *នៅកន្លែងណា គប្បីស្គាល់កន្លែងនោះឱ្យច្បាស់* ដូចពោលប៉ោអាវយើងអញ្ចឹង ! ដីហ្នឹងយ៉ាងដូចម្ដេច ព្រៃហ្នឹងយ៉ាងណា មនុស្សពួកហ្នឹងយ៉ាងដូចម្ដេច បរិស្ថានសង្គមដូចម្ដេច ( បរិសញ្ញុតា ) ។

## របៀបដោះស្រាយទំនាស់

១) ដោះដោយនាំគូវិវាទ វត្ថុវិវាទ ច្បាប់វិវាទ និងអ្នកដោះស្រាយវិវាទ ឱ្យបានព្រមគ្នា,

២) ដោះដោយការដាក់ទោសដល់អ្នកដែលបង្កវិវាទ តាមការដែលគេទទួលថាខុស,

៣) ដោះដោយការយកមតិភាគច្រើន,

៤) ដោះដោយឱ្យអ្នកខុស សូមទោសដល់អ្នកត្រូវ,

៥) ដោះដោយឱ្យអ្នកសងខាងយល់គ្នា បំភ្លេចរឿងចាស់ចោល ដោយមិនបាច់កាត់ក្ដី,

៦) ដោះឱ្យចំសាច់រឿងជម្លោះ និងព្យាយាមដោះនៅត្រង់ហេតុរបស់ជម្លោះ,

៧) ធ្វើឱ្យទស្សនៈ ច្បាប់ ការសម្បទាន និងសតិបញ្ញា ការយល់ដឹង បានខិតចូលជិតគ្នា ឬអាចស៊ីគ្នាបាន ដោយមិនខាតផលប្រយោជន៍រៀងៗខ្លួន,

៨) មានលក្ខណៈវិទ្យាសាស្ត្រ មានលំដាប់នៃការដោះស្រាយបញ្ហា :

- សិក្សា ពិនិត្យជម្លោះឱ្យបានច្បាស់ ត្រឹមត្រូវ,
- ស្តាប់សេចក្តីត្រូវការក្នុងការដោះស្រាយជម្លោះរាល់ភាគី,
- វិភាគរកការពិតរបស់ជម្លោះ និងសេចក្តីត្រូវការពិតក្នុងការមិនមានជម្លោះ,
- សិក្សាពីវិធីសំរាប់ដោះស្រាយជម្លោះ និងតបស្នងទៅនឹងសេចក្តីត្រូវការនៃភាគីទាំងសងខាង ដោយត្រឹមត្រូវតាមធម៌ និងច្បាប់,
- អនុវត្តទៅតាមផែនការដែលបានគ្រោងទុក,
- វាយតម្លៃទៅលើការដោះស្រាយបញ្ហា តើតបស្នងទៅនឹងគោលដៅនៃដំណោះស្រាយឬទេ,

៩) ប្រើការចរចា ជាជាងការបង្គាប់បញ្ជា ។

## លទ្ធផលនៃដំណោះស្រាយជម្លោះ

ការដោះស្រាយជម្លោះដោយវិធីអហិង្សា មិនមែនបានន័យថា លទ្ធផលដែលបានមកនោះ មានភាពអហិង្សានោះទេ ព្រោះអហិង្សា មិនមែនត្រឹមតែមានន័យថា ការមិនប្រើកម្លាំងដើម្បីដោះស្រាយបញ្ហានោះទេ តែមានន័យថា ការមិនបៀតបៀន ការមិនធ្វើឱ្យខាតប្រយោជន៍ទៅលើអ្នកម្ខាងទៀត ។ ដូច្នេះ បើលទ្ធ-ផលនោះវាបៀតបៀនទៅលើអ្នកម្ខាងទៀត ដោយមិនត្រឹមត្រូវដោយធម៌ ក៏យើងមិនទាន់អាចចាត់ថា មានភាពអហិង្សាគ្រប់គ្រាន់នៅក្នុងដំណោះស្រាយរបស់យើងបានទេ ។

លទ្ធផលនៃដំណោះស្រាយជម្លោះ គួរមាននិរន្តរភាព មិនមែនបានតែមួយភ្លែត ហើយត្រូវនាំគ្នាដោះទៀតនោះទេ ។

## តើអហឹង្សាគ្រប់គ្រាន់ឬទេ សំរាប់ដំណោះស្រាយជម្លោះ

យើងកុំភ្លេចថា ពាក្យសង្គម មានន័យថា សង្គ្រាម ការច្របូកច្របល់ រួចបាត់ទៅហើយ ហើយក៏មិនអាចធ្វើឱ្យមនុស្សគ្រប់គ្នាប្រើអហឹង្សា នៅក្នុងសង្គមទាំងអស់គ្នាបានដែរ ។ នេះជាការពិតដែលយើងប៉ានទទួល ។ *រឿងដែលអាចធ្វើបាន គឺការដែលយើងធ្វើយ៉ាងណាកាត់បន្ថយការប្រើហឹង្សា នៅក្នុងដំណោះស្រាយបញ្ហាជម្លោះនានា ឱ្យបានច្រើនជាទីបំផុត* ។

ពុទ្ធសាសនាបានស្នើនូវវិធីសំរាប់កាត់បន្ថយការប្រើហឹង្សា ក្នុងដំណោះស្រាយជម្លោះខ្លះៗ ដូចតទៅ :

១) ការបង្កើននូវភាពស្មើគ្នា និងភាពគ្រប់គ្រាន់ខាងផ្នែកសេដ្ឋកិច្ច ប្រកបដោយនិរន្តរភាពរវាងបុគ្គល សង្គម និងធម្មជាតិ ( កាយភាវនា ) ។

២) ការបង្កើនសក្តានុពលក្នុងការគោរពច្បាប់ និងសមភាព នៅក្រោមអំណាចនៃច្បាប់ វិន័យរបស់សង្គម ដែលយើងរស់នៅ ព្រមទាំងមានច្បាប់គ្រប់គ្រាន់ ច្បាប់ដែលអាចអនុវត្តបាន : លើការរស់នៅប្រចាំថ្ងៃ ច្បាប់លើការដាក់ទោសចំពោះអ្នកដែលធ្វើខុស ដោយយុត្តិធម៌ ; ច្បាប់លើការប្រកបអាជីវកម្ម ការងារ មុខរបរ មុខងារ ការទទួលខុសត្រូវ សេវាកម្ម ; និងច្បាប់លើការប្រើប្រាស់វត្ថុទាំងឡាយ ( សីលភាវនា ) ។

៣) ការធ្វើសង្គមឧបនីយកម្ម ( socialization ) នៃវប្បធម៌អហឹង្សារបស់សាសនា ជំនឿទាំងអស់ទៅលើដួងចិត្ត តាំងតែពីក្មេងៗ ដោយការធ្វើសមាធិ ។ វប្បធម៌អហឹង្សា គួរប្រកបដោយ មេត្តា ករុណា មុទិតា ឧបេក្ខា ជឿបុណ្យ ជឿបាប

( ចិត្តភាវនា ) ។

៤) ការបង្កើនសមភាព លើវិស័យសិក្សា ការអប់រំ ការអភិវឌ្ឍន៍សតិ-បញ្ញា និងជាការសិក្សាដែលឆ្ពោះទៅរកការរួចចាកផុតពីសេចក្ដីទុក្ខ ទំនាស់ និងឆ្ពោះទៅរកសន្តិភាព ទាំងផ្នែកផ្លូវកាយ និងចិត្តវិញ្ញាណ ។ ( បញ្ញាភាវនា ) ។

## យោបល់

ការដោះស្រាយជម្លោះដោយអំពើហឹង្សា និងសង្គ្រាម នឹងនៅតែមានទៅទៀតរហូតដល់ទីបញ្ចប់នៃពិភពលោកនេះ តែសេចក្ដីព្យាយាមនៃការប្រើអហឹង្សា-ធម៌ ដើម្បីទៅជំនួសហឹង្សាធម៌ ក៏ត្រូវតែបន្តទៅទៀត ដោយមិនលះបង់ដែរ ព្រោះវាជាថ្នាំដែលអាចបន្តអាយុឱ្យយើនយូរទៅមុខបាន ។ ក្នុងសម័យពុទ្ធកាល ជួនកាលព្រះអង្គបានទទួលជោគជ័យ ក្នុងការដោះស្រាយជម្លោះ ដូចជាករណីប្រទេសកបិល-ពស្តុ និងប្រទេសទេវទហៈ ឈ្លោះគ្នាពីរឿងបែងចែកទឹកជាដើម ។ ព្រះអង្គបានបង្វែរការធ្វើសង្គ្រាមដណ្ដើមទឹក មកជាការចរចាគ្នា សម្រុះសម្រួលគ្នា ដើម្បីចែកទឹកគ្នាវិញ ។

នៅកន្លែងខ្លះ ព្រះអង្គមិនអាចដោះស្រាយបានភ្លាមទេ តែទ្រង់ទុកពេលវេលានៃទំនាស់ឱ្យរសាយដោយខ្លួនឯងខ្លះ និងមានការគាបសង្កត់ពីមជ្ឈដ្ឋានខាងក្រៅខ្លះ ជារបៀបពហិការ ( sanction ) ទើបអាចដោះស្រាយបាន ដូចជាករណីដែលភិក្ខុបរិស័ទព្រះអង្គឈ្លោះគ្នា រហូតដល់ព្រះអង្គចេញទៅគង់ក្នុងព្រៃស្ងាត់តែមួយអង្គឯង ជាដើម ។

នៅក្នុងករណីមួយទៀត ព្រះអង្គមិនអាចដោះស្រាយបានទាល់តែសោះ គឺបានត្រឹមតែពន្យារពេលកុំឱ្យឆាប់កើតឡើងតែប៉ុណ្ណោះ គឺក្នុងករណីដែលព្រះបាទវិឌូឌភៈ លើកទ័ពទៅវាយនគរកបិលពស្តុ ដើម្បីសងសឹកលើការប្រកាន់ពូជ វណ្ណៈ

របស់ស្តេចនគរកបិលពស្តុ ។ ព្រះអង្គបានទៅណែនាំ និងដោះស្រាយបានតែ ២ ដង ប៉ុណ្ណោះ លុះដល់លើកទី ៣ សង្គ្រាមក៏កើតឡើងទាល់តែបាន ។

នៅក្នុងព្រះសូត្រឈ្មោះ ចក្កវត្តិសូត្រ បាននិយាយអំពីដំណោះស្រាយជម្លោះដ៏ធំមួយ ដែលគួរឱ្យយកចិត្តទុកដាក់ ជាពិសេស បង្ហាញអំពីគុណតម្លៃរបស់អហិង្សាធម៌ គឺសីល ៥ ។ តែទោះជាយ៉ាងណាក្តី ទំរាំនឹងគេនឹកឃើញ ហើយចាប់ផ្តើមចរចាយកនូវអហិង្សាធម៌នោះមកប្រើ ក៏ទាល់តែគេមានការតក់ស្លុតយ៉ាងខ្លាំងចំពោះអំពើហិង្សា ដែលគេបានប្រើនៅក្នុងសង្គ្រាមដ៏ឃោរឃៅមួយ ដែលបានបំផ្លាញជីវិតមនុស្សសឹងតែអស់រលីង ។ អ្នកដែលនៅសល់ខ្លះនោះ ភាគច្រើនជាស្ត្រីកុមារ និងមនុស្សចាស់ ។ គេបានចាប់ផ្តើមសម្រុលគ្នា ធ្វើកិច្ចសន្យាថានឹងមិនសម្លាប់គ្នា មិនលួចគ្នា មិនខុសប្រពៃណីគ្នា មិនកុហកគ្នា និងមិនផឹកទឹកស្រវឹងតទៅទៀត ។ លទ្ធផលនៃវិថីជីវិតបែបអហិង្សានេះ បានធ្វើឱ្យអាយុកាល ( life expectancy ) របស់គេ កើនពី ១០ ឆ្នាំ រហូតដល់ទៅម៉ឺនឆ្នាំ និងមានវិបុលភាពគ្រប់ប្រការទាំងអស់ ។

ចំណុចដែលគួរឱ្យចាប់អារម្មណ៍នៅក្នុងព្រះសូត្រនេះមួយទៀត ហាក់ដូចជាបានដើរតួយ៉ាងសំខាន់នៅក្នុងដំណោះស្រាយជម្លោះ និងចាត់តាំងវប្បធម៌អហិង្សាឡើង ( ព្រោះពេលនោះ សល់ភាគច្រើនជាស្ត្រីភេទ ) ។ តើជាការអាចទៅរួចទេ ដែលស្ត្រីភេទទាំងឡាយ ក្រោកឡើងដើរតួជាអ្នកដោះស្រាយជម្លោះ នាបច្ចុប្បន្នរបស់យើង ( បុគ្គលក្នុងសង្គម ក្នុងប្រទេស អន្តរជាតិ ) និងបង្កើតវប្បធម៌សីល ៥ ពោលគឺអហិង្សា ឱ្យកើតមានឡើងនៅពាសពេញស្រទាប់ជីវិតទាំងឡាយ ។ ព្រះពុទ្ធអង្គទ្រង់សម្តែងឡើងថា ទ្រង់បានស្រាវជ្រាវរាវរកមើលអស់ហើយ ថាពុំមានអ្វីដែលមានឥទ្ធិពលលើបុរសទាំងឡាយ ជាងសំឡេងរបស់ស្ត្រីភេទឡើយ ។

អ្វីដែលបានពោលមកហើយនេះ គឺគ្រាន់តែជាគំនិតខ្លះៗ និងដ៏សង្ខេបក្នុង

ចំណោមគំនិតដ៏ច្រើន សំរាប់ដំណោះស្រាយជម្លោះតាមបែបពុទ្ធនិយម ឬ អហិង្សា ។ យើងត្រូវការកិច្ចស្រាវជ្រាវដ៏វែងឆ្ងាយទៀត ដើម្បីនឹងអាចទទួលបាននូវវិធីដ៏មានប្រសិទ្ធភាពមួយក្នុងការអនុវត្តអហិង្សា សំរាប់ជម្លោះទាំងឡាយ ។ ការផ្តល់យោបល់ ការកែលំអ ការរិះគន់លើអត្ថបទនេះ ដើម្បីឱ្យរឹតតែល្អ ជាការស្វាគមន៍ ដ៏កក់ក្តៅបំផុតពីអ្នករៀបរៀង ។

***

## ពុទ្ធភាសិតដែលទាក់ទងទៅនឹងដំណោះស្រាយជម្លោះ

**ន តេន អរិយោ ហោតិ យេន បាណានិ ហឹសតិ**
**អហឹសា សព្វបាណានំ អរិយោតិ បវុច្ចតិ ។**

បើនៅតែមានហឹង្សានៅឡើយទេ គេមិនហៅថាជាជនមានអារ្យធម៌ទេ លុះត្រាតែមានអហឹង្សាធម៌ ទើបគេហៅថាអារ្យជន ។

**មាវោច ផរុសំ កញ្ចិ វុត្តា បដិវទេយ្យុំ តំ**
**ទុក្ខា ហិ សារម្ភកថា បដិទណ្ឌា ផុសេយ្យុំ តំ ។**

កុំពោលពាក្យអាក្រក់ដាក់នរណាឡើយ ព្រោះពេលដែលគេត្រូវអ្នកបៀតបៀន គេនឹងឆ្លើយតបអ្នកវិញ ការនិយាយអាក្រក់ដាក់គ្នា ជាការនាំឱ្យកើតទុក្ខ ( ទំនាស់ ) ហើយអាចរាលដាលដល់ការប្រទូសរ៉ាយគ្នាផង ។

សចេ នេរេសិ អត្តានំ កំសោ ឧបហតោ យថា
ឯស បត្តោសិ និព្វានំ សារម្ភោ តេ ន វិជ្ជតិ ។

បើអ្នកធ្វើសំឡេងខ្លួនឱ្យស្ងប់បាន ដូចជាគងដែលបែកហើយនោះ អ្នកឈ្មោះថាបានចូលទៅកាន់និព្វាន ហើយអ្នកក៏មិនបាច់ឈ្លោះប្រកែកជាមួយនរណាទៀតដែរ ។

ជយំ វេរំ បសវតិ ទុក្ខំ សេតិ បរាជិតោ
ឧបសន្តោ សុខំ សេតិ ហិត្វា ជយបរាជយំ ។

អ្នកឈ្នះរមែងបង្កពៀរឡើង អ្នកចាញ់រមែងកើតទុក្ខ រីអ្នកដែលលះនូវការឈ្នះ និងចាញ់បាន ហើយមានចិត្តស្ងប់រំងាប់ នឹងនៅជាសុខ ។

ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ
អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ ។

តាំងតែពីណាមក ក្នុងលោកនេះ ពៀរមិនដែលរំងាប់ដោយការចងពៀរទេ មានតែរំងាប់ដោយការមិនចងពៀរតែប៉ុណ្ណោះ ព្រោះនេះជាច្បាប់ធម្មជាតិ ។

បរេ ច ន វិជានន្តិ មយមេត្ថ យមាមសេ
យេ ច តត្ថ វិជានន្តិ តតោ សម្មន្តិ មេធគា ។

ជនទូទៅតែងនឹកមិនឃើញថាខ្លួនកំពុងវិនាស ព្រោះរឿងវិវាទឈ្លោះគ្នាទេ តែអ្នកដែលដឹងការពិតវិញ គេរមែងមិនឈ្លោះគ្នាទេ ។

# មាឃបូជា

មាឃបូជា ជាពិធីបុណ្យមួយរបស់ពុទ្ធមាមកជន (១) ទាំងបព្វជិត ទាំងគ្រហស្ថ ។ ពិធីនេះ ត្រូវគេប្រារព្ធធ្វើឡើង នៅថ្ងៃពេញបូរមី ខែមាឃ ដើម្បីឧទ្ទិសដល់ព្រឹត្តិការណ៍ដ៏សំខាន់ជាប្រវត្តិសាស្ត្ររបស់ពុទ្ធសាសនា ដែលបានកើតមានឡើងក្នុងសម័យពុទ្ធកាល ។

## I- ព្រឹត្តិការណ៍ទី ១

សម័យមួយ ព្រះសម្ពុទ្ធទ្រង់គង់នៅក្នុងវត្តវេឡុវន កលន្ទកនិវាបស្ថាន នាក្រុងរាជគ្រឹះ ។ នៅល្ងាចថ្ងៃពេញបូរមី ខែមាឃ ព្រះសម្ពុទ្ធទ្រង់បើកសាវកសន្និបាតមួយ ហៅថា ចតុរង្គសន្និបាត គឺជាសន្និបាតប្រកបដោយអង្គ ៤ គឺ :

- សន្និបាតនេះ ធ្វើឡើងនៅថ្ងៃពេញបូរមីនៃខែមាឃ នេះជាអង្គទី១ ។
- សន្និបាតនេះ មានភិក្ខុសង្ឃជាសមាជិកចូលរួម ចំនួន ១២៥០ អង្គ ហើយភិក្ខុសង្ឃទាំងអស់នេះ គ្មានអ្នកណានិមន្តឡើយ ស្រាប់តែមកជួបជុំគ្នាតែម្តង, នេះជាអង្គទី ២ ។
- ភិក្ខុទាំង ១២៥០ អង្គ សុទ្ធតែជាព្រះអរហន្តខីណាស្រព, នេះជាអង្គទី ៣ ។
- ព្រះអរហន្តខីណាស្រពទាំង ១២៥០ សុទ្ធសឹងជាឯហិភិក្ខុ, នេះជាអង្គទី ៤ ។

នៅក្នុងសាវកសន្និបាតនេះ ព្រះសម្ពុទ្ធទ្រង់ប្រកាសនូវឱវាទបាដិមោក្ខ ដែលមានបទថា :

(១) ពុទ្ធមាមកជន = ជនអ្នករាប់អានពុទ្ធសាសនា - កាន់ពុទ្ធសាសនា ។

. **សព្វបាបស្ស អករណំ** ការមិនធ្វើនូវបាបទាំងពួង

. **កុសលស្សូបសម្បទា** ការបំពេញនូវកុសល

. **សចិត្តបរិយោទបនំ** ការជម្រះចិត្តឱ្យបរិសុទ្ធ ។

ពុទ្ធឱវាទទាំងបីនេះ ជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធគ្រប់ព្រះអង្គ ។ ជាមួយនេះ ព្រះសម្ពុទ្ធទ្រង់ធ្វើវិសុទ្ធិឧបោសថ ។

## II. ព្រឹត្តិការណ៍ទី ២

ក្នុងបុព្វណ្ហសម័យ ព្រះមានព្រះភាគទ្រង់យាងទៅគង់នៅក្នុងបាវាល-ចេតិយ នៃក្រុងវេសាលី ។ គ្រានោះ ក្រុងមារមានចិត្តបាប បានចូលទៅគាល់ព្រះមានព្រះភាគ ក្រាបទូលថា « បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិ-និព្វានរបស់ព្រះមានព្រះភាគហើយ ព្រោះព្រះអង្គបានសន្យាពីពេលមុនថា កាលណាពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ជាសាវ័ក សាវិកា របស់ព្រះអង្គ នៅមិនទាន់ឈ្លាសវាងវៃ ក្លៀវក្លា ពហុស្សូត ទ្រង់ធម៌ ប្រតិបត្តិធម៌ ដ៏សមគួរដល់ធម៌ ប្រព្រឹត្តតាមធម៌ និងមិនទាន់រៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សំដែងបញ្ញត្ត តាំងទុក បើក ចែក ធ្វើឱ្យងាយបាន ហើយនិងមិនទាន់បានសង្កត់សង្កិនបរប្បវាទដែលកើតឡើងហើយ ឱ្យជាកិច្ចដែលខ្លួនបានសង្កត់សង្កិនដោយល្អតាមពាក្យដែលសមហេតុ ហើយសំដែងធម៌ប្រកបដោយបាដិហារ្យ, ព្រហ្មចារ្យ ( សាសនា ) របស់តថាគតនេះ នៅមិនទាន់ខ្ជាប់ខ្ជួន មិនទាន់ចម្រើន មិនទាន់ផ្សាយទៅសព្វទិស គេមិនទាន់ដឹងច្រើនគ្នា មិនទាន់ពេញបរិបូណ៌, ពួកទេវតា និងមនុស្ស មិនទាន់ចេះសំដែងបានដោយប្រពៃ ដរាបណា, តថាគតមិនទាន់បរិនិព្វាន ដរាបនោះ » ឥឡូវ អ្វីៗទាំងនេះ មានសព្វគ្រប់ហើយ ដូច្នេះ កាលនេះជាកាលគួរនឹងបរិនិព្វានរបស់ព្រះមានព្រះភាគហើយ ។

កាលបើក្រុងមារក្រាបទូលយ៉ាងនេះហើយ ព្រះមានព្រះភាគ ក៏បានត្រាស់ថា ម្នាលមារមានចិត្តបាប អ្នកចូរមានសេចក្ដីខ្វល់ខ្វាយតិចចុះ ការបរិនិព្វានរបស់តថាគត មិនយូរប៉ុន្មានទេ គឺកន្លង ៣ ខែ អំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់មានសតិសម្បជញ្ញៈ ទ្រង់ដាក់អាយុសង្ខារ ឰដ៏បាវាលចេតិយ ។ លុះព្រះមានព្រះភាគ ទ្រង់ដាក់អាយុសង្ខារហើយ ផែនដីក៏កក្រើកយ៉ាងខ្លាំង គួរឱ្យភ្លូកភ្លឹក ព្រឺព្រួចរោម ឯផ្គរក៏លាន់ឮឡើង ។

ព្រះអានន្ទដែលកំពុងគង់នៅក្រោមដើមឈើជិតទីនោះ មានសេចក្ដីត្រិះរិះថា អើហ្ន៎ ការកក្រើកផែនដីនេះខ្លាំងណាស់ តើមានហេតុ មានបច្ច័យ ដូចម្ដេចហ្ន៎ ! ហើយក៏ចូលទៅគាល់ក្រាបទូលសួរចំពោះព្រះដ៏មានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ ហេតុបច្ច័យដែលនាំឱ្យកក្រើកផែនដីនេះ មាន ៨ យ៉ាងគឺ :

១. មហាប្រឹថពីនេះ ប្រតិស្ឋាននៅលើទឹក ឯទឹកប្រតិស្ឋាននៅលើខ្យល់ ខ្យល់ប្រតិស្ឋាននៅលើអាកាស ។ សម័យដែលមានខ្យល់ធំបក់ ខ្យល់ធំដែលបក់នោះរមែងធ្វើទឹកឱ្យកក្រើក ឯទឹកដែលកក្រើកមកហើយ ក៏ធ្វើផែនដីឱ្យកក្រើក រំពើក រំភើប ញាប់ញ័រ ។

២. សមណៈក្ដី ព្រាហ្មណ៍ក្ដី ដែលមានឫទ្ធិ ដល់នូវការស្ទាត់ជំនាញក្នុងចិត្ត ឬទេវតាដែលមានឫទ្ធិធំ មានអានុភាពធំ កាលបុគ្គលនោះបានចម្រើនបឋវីសញ្ញាឱ្យមានកំលាំងតិច ចម្រើនអាបោសញ្ញាឱ្យមានកំលាំងច្រើន បុគ្គលនោះ រមែងធ្វើផែនដីនេះឱ្យកក្រើក រំពើក រំភើប ញាប់ញ័របាន ។

៣. កាលដែលព្រះពោធិសត្វ ច្យុតចាកពួកទេវតាដែលស្ថិតនៅក្នុងស្ថានតុសិត មានសតិ និងសម្បជញ្ញៈ យាងចុះកាន់ព្រះមាតុឧទរ ក្នុងកាលនោះ ផែនដីនេះតែងកក្រើក រំពើក រំភើប ញាប់ញ័រ ។

៤. កាលដែលព្រះពោធិសត្វមានសតិ និងសម្បជញ្ញៈ ទ្រង់ប្រសូតចាក ព្រះមាតុឧទរ កាលនោះ ផែនដីនេះតែងកក្រើក រំពើក រំភើប ញាប់ញ័រ ។

៥. កាលដែលតថាគត ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ កាល នោះផែនដីនេះតែងកក្រើក រំពើក រំភើប ញាប់ញ័រ ។

៦. កាលដែលតថាគត មានសតិ និងសម្បជញ្ញៈដាក់ចុះនូវអាយុសង្ខារ កាលនោះ ផែនដីនេះតែងកក្រើក រំពើក រំភើប ញាប់ញ័រ ។

៧. កាលដែលតថាគត បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ [១] កាល នោះ ផែនដីនេះតែងកក្រើក រំពើក រំភើប ញាប់ញ័រ ។

## III. ពិធីមាឃបូជា

ពិធីមាឃបូជា មានលក្ខណៈប្លែកពីពិធីបុណ្យនានា ព្រោះពិធីបុណ្យនេះ ជាពិធីបុណ្យរបស់ពុទ្ធសាសនិក ទាំងបព្វជិត ទាំងគ្រហស្ថ ធ្វើរួមគ្នា ដោយមានគោល បំណងដូចគ្នា ។

តាមទំនៀមទម្លាប់របស់ពុទ្ធសាសនិកកម្ពុជា កាលណាដល់ល្ងាចថ្ងៃ ១៥ កើត ខែមាឃហើយ គេតែងតែមកជួបជុំគ្នានៅតាមវត្តអារាម ក្នុងមូលដ្ឋានរបស់ខ្លួន ដោយឥតមានអ្នកណាអញ្ជើញឡើយ ។ កាលណាជួបជុំគ្នាហើយ គេនាំគ្នាកាន់ទៀន ធូប ផ្កា ភ្ញី ដែលជាសក្ការបូជា ដង្ហែប្រទក្សិណព្រះវិហារបីជុំ រួចបង្អោនចូលទៅបូជា ចំពោះព្រះពុទ្ធបដិមា ។

- ជាដំបូង ពួកបព្វជិតបានចាប់ផ្ដើមនមស្សការ ចំពោះព្រះរតនត្រ័យ ។
- បន្ទាប់មក ពួកគ្រហស្ថ ក៏ចាប់ផ្ដើមនមស្សការ ចំពោះព្រះរតនត្រ័យ ។

តមក លោកអាចារ្យម្នាក់បានឡើងប្រកាសមាឃបូជា ដោយអាន

(១) អនុបាទិសេសនិព្វានធាតុ គឺការរំលត់ខន្ធចូលកាន់បរិនិព្វាន ។

សេចក្ដីប្រកាស មួយឃ្លាម្ដងៗ ដើម្បីឱ្យអ្នកទាំងអស់គ្នាថាតាម ។ ឯពាក្យពេចន៍នៃសេចក្ដីប្រកាសនោះ មានការប្លែកគ្នាខ្លះដោយអន្លើ ប៉ុន្តែ ខ្លឹមសារជាមូលដ្ឋានដូចគ្នា ។ ក្នុងទីនេះ សូមលើកយកសេចក្ដីប្រកាសមាឃបូជាមួយជាគម្រូ ដូចខាងក្រោម :

**នមោ តស្ស ភគវតោ**

**អរហតោ សម្មាសម្ពុទ្ធស្ស** ( បីដង ) ។

សូមនមស្សការ ចំពោះព្រះភគវន្តមុនី អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះដោយគោរព ។

**សម្មាសម្ពុទ្ធោ វត សោ ភគវា យោ សព្វទុក្ខស្ស បហានាយ ធម្មំ ទេសេតិ តំ សម្មាសម្ពុទ្ធំ អានេរន នមស្សាម** ។

ព្រះភគវន្តមុនីអង្គណា ទ្រង់សំដែងនូវធម៌ ដើម្បីកំចាត់បង់នូវសេចក្ដីទុក្ខទាំងពួង ព្រះភគវន្តមុនីអង្គនោះ ជាព្រះសម្មាសម្ពុទ្ធពិតមែន យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធអង្គនោះ ដោយគោរព ។

**និយ្យានិកោ វត សោ ធម្មោ យោ សព្វទុក្ខស្ស បហានាយ ស្វាក្ខាតោ តេន ភគវតា តំ ធម្មំ អានេរន នមស្សាម** ។

ព្រះធម៌ណា ដែលព្រះភគវន្តមុនីអង្គនោះ ទ្រង់ត្រាស់សំដែងហើយដោយប្រពៃ ដើម្បីកំចាត់បង់នូវសេចក្ដីទុក្ខទាំងពួង ព្រះធម៌នោះ ជាធម៌ស្រោចស្រង់សត្វពិតមែន យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំនូវព្រះធម៌នោះ ដោយគោរព ។

**សុប្បដិបន្នោ វតស្ស ភគវតោ សោ សាវកសង្ឃោ យោ សព្វទុក្ខស្ស បហានាយ បដិបន្នោ តំ សង្ឃំ អានេរន នមស្សាម** ។

ព្រះអរិយសង្ឃណា លោកប្រតិបត្តិ ដើម្បីកំចាត់បង់នូវសេចក្ដីទុក្ខទាំង

ពួង ព្រះអរិយសង្ឃនោះ ជាសង្ឃសាវ័ក នៃព្រះភគវន្តមុនីអង្គនោះ លោកប្រតិបត្តិ ដោយប្រពៃពិតមែន យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំ នូវព្រះអរិយសង្ឃនោះ ដោយគោរព ។

ថ្ងៃនេះ ជាតិថីពេញបូរមី នៃខែមាឃ មានព្រះចន្ទពេញវង់ ត្រូវនឹងថ្ងៃដែលព្រះសាក្យមុនី សម្មាសម្ពុទ្ធ ជាបរមគ្រូ ទ្រង់ប្រជុំសាវកសន្និបាត សំដែងឱវាទ-បា្បតិមោក្ខ និងទ្រង់ដាក់អាយុសង្ខារ ។ ឯសាវកសន្និបាតនេះ ហៅថា ចតុរង្គសន្និ-បាត ព្រោះជាសន្និបាតប្រកបដោយអង្គ ៤ គឺ :

- ថ្ងៃពេញបូរមី ខែមាឃ, នេះជាអង្គទី ១ ។
- ភិក្ខុ ១២៥០ អង្គ ឥតមានអ្នកណានិមន្ត ស្រាប់តែមកជួបជុំគ្នាក្នុងវត្តវេឡុវ័ន, នេះជាអង្គទី ២ ។
- ភិក្ខុ ១២៥០ អង្គនោះ សុទ្ធតែជាព្រះអរហន្តខីណាស្រពទាំងអស់, នេះជាអង្គទី ៣ ។
- ព្រះអរហន្តខីណាស្រព ១២៥០ អង្គនោះ សុទ្ធសឹងជាឯហិភិក្ខុ (១), នេះជាអង្គទី ៤ ។

តិថីនេះ ជាឧបលក្ខិតសម័យមួយ (២) ដ៏ឧត្តុង្គឧត្តមក្នុងព្រះពុទ្ធសាសនា គឺជាថ្ងៃសម្រាប់ពុទ្ធមាមកជន ទាំងបព្វជិត ទាំងគ្រហស្ថ នាំគ្នាធ្វើសក្ការបូជា ចំពោះព្រះសម្មាសម្ពុទ្ធព្រះអង្គនោះ ព្រមទាំងព្រះធម៌ ជាព្រះបរមពុទ្ធោវាទ និងព្រះអរិយសង្ឃជាសាវ័ករបស់ព្រះអង្គ ។

ឥឡូវនេះ យើងខ្ញុំទាំងអស់គ្នា ជាពុទ្ធសាសនិកជន បានមកជួបជុំគ្នា រៀប

---

(១) កុលបុត្រ ដែលព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ឯហិភិក្ខុ តែប៉ុណ្ណោះ ក៏ឧប្បត្តិទៅជាភិក្ខុភ្លាមមួយរំពេច ហៅថា ឯហិភិក្ខុ ។ (២) ឧបលក្ខិតសម័យ សម័យដែលគួរចងចាំ ឬកត់សម្គាល់ទុក ។

ចំសក្ការបូជា មានទៀន ធូប និងផ្កាភ្ញីជាដើម ក្នុងទីនេះ ដែលមានព្រះពុទ្ធរូបសួងព្រះអង្គ គង់ជាប្រធាន ហាក់ដូចជា ព្រះបរមសាស្តាអង្គនោះ ទ្រង់ស្តេចមកគង់ ក្នុងទីចំពោះមុខនៃយើងទាំងអស់គ្នា យើងខ្ញុំព្រះអង្គ សូមថ្វាយសក្ការបូជាទាំងនេះ ចំពោះព្រះសម្មាសម្ពុទ្ធអង្គនោះ ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ ដោយគោរព ។

បពិត្រព្រះសាក្យមុនីបរមគ្រូ ព្រះអង្គជាបូជារហបុគ្គល [(១)] របស់ទេវតា និងមនុស្ស ឥតមានបុគ្គលណាមួយ ត្រឹមស្មើនឹងព្រះអង្គឡើយ ទោះបីព្រះអង្គ ទ្រង់ចូលបរិនិព្វាន បាត់ព្រះរូបព្រះកាយអស់កាលយូរអង្វែងទៅហើយក៏ពិតមែន ប៉ុន្តែទ្រង់បានប្រតិស្ឋានព្រះវិសុទ្ធោវាទ គឺព្រះធម៌វិន័យ ដ៏វិសុទ្ធិវិសេស ទុកជាតំណាងព្រះអង្គ ទាំងព្រះគុណរបស់ព្រះអង្គ ក៏នៅមានប្រាកដ ទាំងព្រះបរមសារីរិកធាតុ និងព្រះពុទ្ធរូបសួងព្រះអង្គ ក៏នៅមានប្រាកដដែរ ។ សូមព្រះដ៏មានបុណ្យ ជាបរមសាស្តា ទ្រង់ព្រះមេត្តាប្រោស ទទួលនូវសក្ការបូជា របស់យើងខ្ញុំព្រះអង្គ ដែលបានរៀបចំថ្វាយនៅទីនេះ ដើម្បីជាផលានិសង្ស ឱ្យយើងខ្ញុំព្រះអង្គ បានប្រកបដោយឥដ្ឋមនុញ្ញ-ផល វិបុលសុខ និងសេចក្តីចំរើនដ៏ទូលំទូលាយ អស់កាលជាយូរអង្វែងទៅហោង ។

លុះលោកអាចារ្យ ប្រកាសមាឃបូជាហើយ បព្វជិត ឬគ្រហស្ថ មួយចំនួន នាំគ្នាសូធ្យគាថា ប្រារព្ធមាឃបូជា ដូចខាងក្រោម ៖

**មាឃនក្ខត្តយុត្តាយ បុណ្ណាយ បុណ្ណមាយ យោ**
**អរហំ សម្មាសម្ពុទ្ធោ ភគវា គោតមវ្ហយោ**
**សុទ្ធានន្ទនយោ ញាណោ សត្ថា លោកេ អនុត្តរោ**
**វិហរន្តោ រាជគហេ មគធានំ គិរិព្វជេ**
**វិហារេ វេឡុវនេ ច កលន្ទកនិវាបិយេ**
**សឌ្ឍស្ស សន្និបាតម្ហិ ឧត្តមេ ចតុរង្គិកេ**

(១) បូជារហបុគ្គល បុគ្គលដែលគេគួរបូជា ។

អត្ថារតេលសេហិ ភិក្ខុ- សរតេហិ បរិចារិតោ
គីហិ គាថាហិ សច្ចិម្ប៊ សព្វំ ពុទ្ធាន សាសនំ
សមោសារេសិ ឱវាទំ បាតិមោក្ខំ អនុត្តរំ
កមេចម្ភកសម្ពុទ្ធំ សខីណាសវសាវកំ
ចិរកាលមតិកម្បិ បសារេន អនុស្សរំ
អយម្បិ បរិសា សព្វា បសន្នា ធម្មគារវិនី
សម្បត្តា គាធិសំ គាសំ សុនក្ខត្តំ សុមង្គលំ
ធិបធូបាធិសក្ការេ អភិសជ្ជ យថាពលំ
តេហិ បូជេ កវេហដ្ឋ- កុដ្ឋា ឥធ សមាគតា
អភិវន្ទតិ បូជេតិ ភគវន្តំ សសាវកំ
ភាវេន សម្ពទិ ភូតំ អតិការម្មណុត្តនា
ឱសារេត្វ បាតិមោក្ខំ ចសុទ្ធក្ខមុបោសថេ
ឥតោ ជេន សុបុញ្ញេន សោត្ថិ ហោតុ សធាច នោ
សាសនំ សត្ថុ អម្ហាកំ ចិរំ ធិប្បតុ គាធិនោ ។

ក្រោយពីការសូធ្យគាថាប្រារព្ធមាឃបូជាហើយ គេនាំគ្នាសូធ្យធម៌បទជាច្រើនទៀត ដែលទាក់ទងដល់ការដាក់អាយុសង្ខារ និងព្រះធម៌វិន័យរបស់ព្រះសម្ពុទ្ធ ។ ជាមួយនេះ គេនិមន្តធម្មកថិកឱ្យសំដែងធម្មទេសនា ស្តីពីរឿងពុទ្ធប្បវត្តិ ។

ក្នុងបុរាណកាល ពិធីមាឃបូជានេះ បានប្រព្រឹត្តទៅពេញមួយរាត្រី ហើយនៅពេលព្រឹកឡើង ថ្ងៃ ១ រោច ខែមាឃ មានពិធីដាក់បាត្រព្រះសង្ឃ ជាកិច្ចបញ្ចប់ពិធីផង ។

រៀបរៀងដោយ **ម៉ែន ប្រាជ**

ពិនិត្យសម្រួលដោយ **ឱម ខែម**

# សុភាសិតច្បាប់ស្រី
# របស់ ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ

ជីវប្រវត្តិ ៖

ឧកញ៉ាសុត្តន្តប្រីជាឥន្ទ កំណើតកើតនៅស្រុកទន្លេធំ គឺភូមិរកាកោង ខេត្តមុខកំពូល មាតាឈ្មោះ យាយមុំ បិតាឈ្មោះ បញ្ញង់កែ ។ លោកកើតថ្ងៃចន្ទ ខែអាសាឍ ឆ្នាំវក ព.ស.កន្លងទៅបាន២៤០៣ វស្សា គឺថ្ងៃ ២២ សូយេត ឆ្នាំ១៨៥៩ ។ កាលអាយុ ១០ ឆ្នាំ នៅវត្តសិក្សាអក្សរខ្មែរ ។ អាយុ ១៥ ឆ្នាំ ចេញរៀនប្រែព្រះបរិយត្តិ បួសជាសាមណេរនៅវត្តព្រែកពោធិ បួសបានមួយវស្សា សិក្ខចាកភេទសាមណេរ រួចទៅរៀននឹងលោកព្រះអាចារ្យ ពេជ ស្រុកព្រះត្រពាំង ។ អាយុ ១៨ ឆ្នាំ នៅរៀននឹងលោកគ្រូព្រះពុទ្ធឃោសាចារ្យ ប្រាក់ វត្តឧណ្ណាលោម ក្រុងភ្នំពេញ ។ អាយុ ១៩ ឆ្នាំ ទៅរៀននឹងលោកគ្រូព្រះអាចារ្យ សុខ វត្តកែវ ស្រុកបាត់ដំបង ។ អាយុ ២០ ឆ្នាំ បានបួសជាភិក្ខុនៅវត្តកែវ មួយវស្សា ទើបលាព្រះឧបជ្ឈាយាចារ្យ ទៅរៀននៅស្រុកបាងកក ក្រុងស្យាម រៀនបាន ៧ វស្សា ក៏វិលមកស្រុកខ្មែរវិញ ក្នុងអំណាចលោកព្រះយ៉ាកថាថន " ញ៉ូញ " នៅវត្តកណ្តាល ស្រុកបាត់ដំបង បួសបាន ១០ វស្សា លាសិក្ខាបទសិក្ខមក មានបុត្រ ភរិយា នៅភូមិជ្វាធំ [១] លោក កថាថន " ឈុំ " ចិញ្ចឹមជាទីហ្លួងវិជិតរោហារ បានតែង បានប្រែបាលីជាសំរាយ មានឈ្មោះសែសិបប្អូនឈ្មោះ ជាសៀវភៅខ្លះ ចារស្លឹករឹតខ្លះ ។ លុះអាយុបាន ៥៥ ឆ្នាំ រាជការក្រុងភ្នំពេញ ឱ្យយកមកតាំងទីជាឧកញ៉ាសុត្តន្តប្រីជា ប្រោសឱ្យជួយតែងសព្វវចនា-ធិប្បាយខ្មែរ នៅទីសាលាបាលី ក្នុងរវាងអាយុ ៥៥ ឆ្នាំ ដល់អាយុ ៦៥ ឆ្នាំ បានលារាជការ វិលមកនៅស្រុកបាត់ដំបងដើមវិញ ។ លុះនៅថ្ងៃ ១០ កើត ខែអស្សុជ ឆ្នាំជូត

(១) ឯកសារដើមសរសេរថា " ឈ្វាធំ "

ឆស័ក មានរោគក្អក បណ្ដាកូនចៅរាល់គ្នា នាំគ្នាប្រតិបត្តិប្រកបថ្នាំ រកគ្រូរក្សាពុំចេះធូរឡើយ លុះដល់ថ្ងៃអាទិត្យ ១២ កើត ខែកត្តិក ឆ្នាំជូត ឆស័ក ក៏ទទួលអនិច្ចកម្ម នៅវេលាម៉ោង ៨ ព្រឹក គឺថ្ងៃ ៨ ណោវ៉ែម ឆ្នាំ ១៩២៤ ។

ស្នាដៃសំខាន់ៗ របស់ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ មានដូចខាងក្រោមនេះ ៖

- ធម៌ដែលគ្រហស្ថត្រូវប្រព្រឹត្ត,
- ប្រស្នារឿង ស្ត្រីល្អ ទឹកផ្អែម ត្រីដែលមានរសពិសាជាងត្រីឯទៀត,
- ទោសកើតអំពីជក់អាភៀន និង កញ្ឆា,
- ប្រស្នារឿង ពាលគួរអោយខ្លាច,
- រឿង យុវនាតចាញ់បោកចៅពាល,
- រឿង ចៅពាលក្លែងភេទជាសង្ឃធ្វើគ្រូមើលសុភ្ន,
- រឿង ពាលសង្រ្គមហួសប្រមាណ,
- រឿង តាថេន និងសិស្ស ៣ នាក់,
- កាព្យនិរាសអង្គរ,・
- គតិលោក,
- រឿង អំបែងបែក ( ជាសាស្ត្រស្លឹករឹត ),
- បឋមសម្ពោធិ ( ជាក្រាំង ),
- លោកនីតិបករណ៍ ( ពាក្យកាព្យ ),
- សុភាសិតច្បាប់ស្រី,
- ក្បួនមេកាព្យ,
- និងស្នាដៃជាច្រើនទៀត រួមទាំងអស់មាន ៤៤ មុខ ។

នៅក្នុងពេលនេះ យើងនឹងចុះផ្សាយសុភាសិតច្បាប់ស្រី របស់អ្នកកវី

សុត្តន្តប្រីជា ឥន្ទ ដែលជាចិន្តកវីឯក មានកិត្តិសព្ទល្បីល្បាញ នៅក្នុងសតវត្សទី ២០ នេះ និងជាអ្នកប្រាជ្ញអក្សរសាស្ត្រខ្មែរ មានទេពកោសល្យពូកែខាងតែងកាព្យឃ្លោងដ៏ពិរោះចាប់ចិត្ត សម្បូរទាំងខាងសំនួនវោហារ ទាំងរឿងរ៉ាវផ្សេងៗ ដែលប្រកបដោយគតិបណ្ឌិតខ្ពស់ ។

អត្ថបទសុភាសិតច្បាប់ស្រីនេះ ត្រូវបានចុះផ្សាយលើកទី ១ នៅក្នុងទស្សនាវដ្ដីកម្ពុជសុរិយា នៅក្នុងឆ្នាំ ១៩៣៤ ម្តងរួចហើយ ។ ការដែលយើងចុះផ្សាយម្តងទៀតនេះ គឺចង់ឱ្យបងប្អូនរួមជាតិ បានស្គាល់ស្នាដៃនៃចិន្តកវីឯកនេះផង និងជាកិច្ចរក្សាកេរបស់លោកកុំឱ្យបាត់បង់ផង ។ ម្យ៉ាងទៀត សុភាសិតនេះ ជាពាក្យកាព្យដ៏វិចិត្រល្អិតល្អណាស់ គួររក្សាទុកជាគំរូ ឬជាបែប ជាច្បាប់សម្រាប់សិក្ខាកាម-ជន អ្នកស្រឡាញ់អក្សរសាស្ត្រ យកជាគំរូ ជាមេរៀនសំរាប់ការតែងនិពន្ធរបស់ខ្លួន។ រីឯខ្លឹមសារនៃច្បាប់នេះវិញ ក៏មានអត្ថន័យជ្រាលជ្រៅ មានសារប្រយោជន៍ក្រៃលែង សម្រាប់បុរស ស្ត្រី យុវជន យុវនារីខ្មែរគ្រប់គ្រាប់ និងឆ្លុះបញ្ចាំងឱ្យឃើញសីលធម៌ខ្មែរ សម័យមុនៗ ។

ទស្សនាវដ្ដីកម្ពុជសុរិយា សូមឧទ្ទិសកុសលដែលកើតពីការផ្សាយកំណាព្យនេះ ជូនចំពោះវិញ្ញាណក្ខន្ធរបស់អ្នកឧកញ៉ា សុត្តន្តប្រីជាឥន្ទ សូមបានសោយសុខក្នុងសុគតិភព ជារៀងរហូតតទៅ ។

## សុភាសិតច្បាប់ស្រី [១]

(១) ជុលិហត្ថ [២] នមស្សការដាក់លើកេស ពាងប្រទីបកោសុមប្រទុមទេស [៣]

---

(១) សុភាសិតច្បាប់ស្រីនេះ លោកឧកញ៉ាសុត្តន្តប្រីជា ឥន្ទ បានតែងកាលលោកមានឋានន្តរ-សក្តិ ថ្នាក់ទី " ហ្លួងវិចិត្រវោហារ " ។ (២) ជុលិ «ក្រពុំម្រាម» ហត្ថ «ដៃ» ។ ជុលិ គឺអញ្ជលិ អញ្ជលិ ក្លាយមកពីអញ្ជលី ។ (៣) កោសុមប្រទុម=ផ្កាឈូក ។ ទេស=គ្រឿងទេស, គ្រឿងក្រអូប ។

ចិត្តវិសេសអារ័ក្តបាទព្រះសាស្តា ។

សឹងជាមោលីលោកទាំងត្រៃចក្រ ដូចកល់ហាក់ប្រទីបស្វាងទូទិសា
កន្លងបាត់ស្វាត់ទៅក្នុងអនា កាន់មហានិព្វានឋានសម្រាន្តរម្យ ។
មួយជនកជននីបង្កើតកេស ទាំងទិព្វទេពសព្វនិវេសន៍ស្ថានសួគិសម
សូមចំរើនវុឌ្ឍីសិរីរម្យ ចូរជួយឃុំកំចាត់កាត់អន្តរាយ ។
ខ្ញុំបាទហ្លួងវិចិត្រវោហារថែង ប្រែសុន្ទរពាក្យតែងកាព្យភិប្រាយ
ទុកទូន្មានសត្រីស្រីទាំងឡាយ តាមបរិយាយតម្រាប់ច្បាប់នារី ។
កំពុងពេញពាលរូបតរុណរ័ក[១] ចំរើនស័ក្តិកបលក្ខណ៍ជាសត្រី
គួរប្រព្រឹត្តតាមយ៉ាងព្រហ្មចារី រក្សាកាយកុំបីឱ្យហ្មងសៅ ។
សេចក្តីជួ[២] គួរជំរុះពីរូបចេញ សេចក្តីល្អគួរបំពេញឱ្យមាននៅ
តាំងចរិតប្រព្រឹត្តឱ្យត្រង់ត្រូវ នឹងតវង្សពង្សផៅជាមង្គល ។
សត្រីណាកើតក្នុងព្រះវង្សខ្ពស់ បំរុងយសថ្នមកាយហ្មាយ[៣] យកផល
ពោងសួនចិត្តកុំចេីកទៅតាមកល ទើបមិនពាល់ពាក្យតិះអ្នកដទៃ ។
ខ្លួនតរុណពេញចំទង់វង្សនារី ដូចមណីសូរ្យកាន្តមានដម្លៃ
មែនបើបែកប្រេកប្រេះកាលណានៃ ក៏ថយថ្លៃចុះថោករកលក់ក្រ ។
ឯគូទាបកុំទៅប្រឹងឱ្យខ្ពស់ប្រាណ មើលសន្តានតាមសណ្តាប់អ្នកល្អ
នឹងស្លៀកពាក់សំពត់អាវព័ណខ្មៅស តែងកាយក៏មើលកាយឱ្យហ្មត់ហ្មង ។
ការតែងតួសុភាពរៀបតាប់កល នរណាយល់គង់សរសើរថាន្លនល្អង
ចេះតែងប្រាណត្រូវប្រមាណមិនមានឆ្គង ចុះទំនងមយុររម្យ[៤] សមសណ្ឋាន ។

---

(១) តរុណា = ក្មេង, កំឡោះ ក្រមុំ ។ រ័ក = ស្រឡាញ់ (ពាក្យថៃ) ។

(២) ជួ = អាក្រក់ (ពាក្យថៃ) ។ (៣) ហ្មាយ = បំណង, ប៉ងប្រាថ្នា, សំគាល់ (ពាក្យថៃ) ។

(៤) មយុរ = ក្ងោក ។ រម្យ = គួររីករាយ ។

មែនរូបល្អសសមឧត្តមស័ក្តិ    តែមិនចេះទុកដាក់ឱ្យសមប្រាណ
គង់មិនស្ទុះកាយស្ទើតឆើតទៅបាន    ខុសសណ្ឋានឥន្ទ្រីយ៍នីវីវណ្ណ ។
ប្រការមួយទោះដើរដំណើរនាដ (១)    សន្សឹមយាសយាងបាទចរដោយជាន់
កុំបង់បោយផ្ទារហ័ត្ថក្រពាត់ព័ន្ធ    កុំបើកផន (២) បន្ថយថ្នក់ក្រោមផ្ចិត ។
កុំដើរក្រោយកាយយោគងោកឱ្នកខ្នក់    កុំសិតសក់កណ្តាលផ្លាមិនស្និទ្ធ
ឃើញភ្ញៀវមកកុំលលេងតាមចិត្ត    មកស្ពានស្និតសីមតិតប្រឹក្សាគ្នា ។
ឱ្យកំណត់កត់ចាំពាក្យណាគាប់    កុំបីត្រាប់ពាក្យពុតពោរពាលា
កុំនិយាយឡោះឡេះកេះកៀវគ្នា    កុំនាំពារក្រៅក្នុងចេញចូលស្ពាន ។
ទីភូមិណាស្រីជួមិនគួរចរ    ទៅអបអររាប់រក៏ជាសន្តាន
(១៥) ទីភូមិណាប្រុសជុំកុំលលាន    ផ្ទុះមានរកចាស់គេជូនទៅ ។
ចូររវាំងការណ៍កេរ្តិ៍កុំចេរចរ    តាមផ្ទះពួកនិករសាច់ញាតិផៅ
កុំឡើងផ្ទះញាតិមិត្រឥតគេហៅ    តែត្រាច់ទៅញយៗ គង់ថយស័ក្តិ ។
នឹងអង្គុយឱ្យស្រគត់ស្រគំកាយ    កាលនិយាយកុំលាយសើចរលាក់
កើតជាស្ត្រីក្តីខ្លាសមានច្រើនថ្នាក់    ចូរស្ងួនស័ក្តិរក្សាការណ៍ក្តីហ្មង ។
នយៈនេត្រកុំសង្កេតឱ្យកីន (៣) ណាស់    មើលតែច្បាស់យល់ជាក់ដាក់វិញបោង
បើផ្លេកទៅយល់អស់កំឡោះផង    កុំមៀងហ្មងផ្អងផ្អៀងសំឡឹងគន់ ។
ឯនេត្រានាំអាត្មាឱ្យមួហ្មង    ដូចទំនងណែនាំឱ្យសម្ព័ន្ធ
ពិតមិនពិតគេក៏ដិតចិត្តចៅលន់    ពាលជនប្រមាទ (៤) មារយាទបាន ។
(២០) តែបើស្ត្រីស្រីនឹងប្រុសតែងប្រតិព័ទ្ធ    មិនដែលណានឹងអត់ក្តីរមស្មាន
មែនបើស្ន័គ្រៗ ទុកតែក្នុងប្រាណ    កុំស្ន័គ្រស្មានចេញក្រៅឱ្យគេយល់ ។

---

(១) នាដ = ដំណើររាំ, ដំណើរល្អគួរមើល ។ (២) ផន មើលថា ផន់ ប្រែថា ដោះ ។
(៣) កីន គឺ កើន ; លើសប្រក្រតី ។ (៤) គប្បីសរសេរ "ប្រមាថ" ទើបត្រូវ ។

ដូចសាខាព្រឹក្សាត្រូវខ្យល់បោក រំជួយយោគក៏តែមែកមិនងេកគល់
ចូរតាំងចិត្តសណ្ឋិតកុំគិតខ្វល់ ទំនងកល់ចាមរីរក្សាកាយ ។
ខ្លួនន្ធួននាងដូចយ៉ាងផ្កាប្រទុម ទើបក្រពុំផុសជ្រែកវែកជលសាយ
ទ្រង់សុគន្ធកេសរក្លិនខ្ចរខ្ចាយ មិនដែលណាយភមរីគ្លី [១] លំអង ។
គ្រាន់បានក្រេបរសជាតិរេណុ [២] ផ្កា ផ្អែតកាលណាក៏លាលាកចេញផ្លុង
មិននៅផ្គង់បំរុងរសទៀតលង ដូចទំនងចិត្តប្រុសមិនខុសគ្នា ។
បើប្រុសណាប្រាថ្នាមករួមរ័ក ឱ្យស្គាល់ជាក់ជើងប្រុសនោះយ៉ាងណា
វិស័យប្រុសច្រើនប្រាជ្ញប្រែសត្យា ដែលថាស្រឡាញ់ចៅតើម្ដេចមិញ ។
(២៩) ចូរពិនិត្យគិតរំពឹងឱ្យដឹងណែ កុំធ្វើតែចិត្តរហ័សក្រែងផ្កាសរិញ
យោគទៅមុខទុកឱ្យបែងបទចេញ ឃើញចំណេញពេញចិត្តស្ងួមចេញមុខ ។
ត្រចៀកឮកុំលុះលលើតាម សង្កត់កាមសង្កិនស្ដាប់ស័ព្ទទំនុក
ល្មមនឹងគេចឬនឹងកែបំបែរមុខ ឬជាល្មមដាក់ទុកតួ [៣] យ៉ាងណា ។
គោងគ្រឹកក្រង [៤] ហ្មងមើលឱ្យប្រាកដ កុំរវាលជឿខ្យល់មាត់ប្រុសចរចា
ឧបាយប្រើមេអណ្ដើកមានប្រាជ្ញា នាំសារាការប្រឡោមលោមបំព្រាង ។
មេអណ្ដើកកុំទៅជឿជាបន្ទាត់ អណ្ដាតបត់ថ្លត [៥] ភរលច្រើនយ៉ាង
សរសើរតែពីមានបុណ្យកូនខុនណាង មករួតរវាងឱ្យតែលុះចុះចិន្ដា ។
តែគឺមោះមិនចំពោះដូចនិយាយ នឹងបែរកាយបៀតកើយទៅត្រង់ណា
ដូចគេភរប្រាប់លាភស្រុកលង្កា មិនគួរយាត្រាតាមពាក្យគេប្រាប់ ។
(៣០) ផ្លូវឆ្ងាយភ្នែកប្រៀបដូចភ្នែកងងឹត នឹងសង្កេតពិតមិនពិតតាមស្ទួរស័ព្ទ
គេនឹងនាំទៅស្លាប់ក៏ស្លាប់ឆាប់ នឹងជឿស្ដាប់មនុស្សនេះក៏ក្រសល់ ។

---

(១) គ្លី ក្រែង ឈ្លី ទេដឹង ! ។ (២) រេណុង = លំអង ។ (៣) តួ គឺ ខ្លួន ។
(៤) គិតពិនិត្យ ។ (៥) និយាយប្រមូលផ្សំពីនេះពីនោះ ។

មេអណ្តើកដូចខ្មោចបិសាចខូច
យកអាសាប្រាថ្នាស៊ីកំណល់
ឯក្តីជួតួឯកក៏ដឹងគ្រប់
ពិគ្រោះស្តាប់អាការឱ្យមាំមួន
មែនការរកស្វាមីនេះក្រណាស់
បើស្ត្រីណារួមត្រេកផ្តេកផ្តិតកាយ
ធម្មជាតិប្រុសខូចពូជពាលពិត
សារពើកិច្ចការមិនចង់គយ
(៣៩) ពុំមានគិតជួញប្រែស្រែចំការ
នាំភឿនផ្វង(២) ចូលរោងសុរាបាយ
កាលបើអស់ធនធានគ្មានអ្វីកែ
ទៅបញ្ចាំឱ្យគេអន្តរធាន
លុះអស់ខ្លួនកើតក្លាយត្រាច់ប្រចុប
លុះកម្មផលអកុសលឱ្យគេទាន់
ឱ្យចុះក្តីវាយខ្នងចងហាលថ្ងៃ
ខ្លួនប្រពន្ធឯណាក៏ធន់បាន
បែបយ៉ាងនេះមានច្រើនហើយអនង្គ(៤)
កុំឃើញតែរូបល្អស្រឡាញ់ឯង
(៤០) ប្រុសខ្លះនោះតែងអង្គដើរចង់ស្រី
ឃើញកល្យាប្រាថ្នារ័ក្សរួមស្ថាន

តែគេបន់តិចតួចក៏ភ្លាមដល់
មិនដឹងកល់តែជឿក៏អស់ខ្លួន ។
ការនឹងគប់សេពមិត្តគិតឱ្យធ្ងន
កុំរាលព្រមយ៉មខ្លួនចុះងាយៗ ។
វាច្រើនផ្តាសតែកញ្ឆាសុរាបាយ
គង់អន្តរាយអ័បចុន(១) ធនធានក្រោយ ។
វាច្រើនតែប្រព្រឹត្តទុច្ចទោសឱ្យ
បានមួយរយបង់មួយពាន់មិនគ្រាន់ចាយ ។
ចេះតែតែងអាត្មាដើរកែក្រាយ
ជក់អាភៀនញៀនកាយទាល់អស់ប្រាណ ។
ក៏លើកយកភូមិស្រែនូវភូមិស្ថាន
ចិត្តមិនមានអាណិតកូនប្រពន្ធ ។
ដើរលេងយប់គប់ភឿនគិតលួចប្លន់
គេក៏ព័ន្ធចាប់ទៅជូននគរបាន(៣) ។
កើតចង្រៃនៅគុកទុក្ខរំខាន
គង់ចុះសានក្រមទ័ណ្ឌព័ន្ធកឯង ។
ចូរខំប្រុងគំនិតគិតឱ្យវែង
ដល់ក្រោយលិចគិតលែងឯណាបាន ។
ចងការខ្ចីប្រាក់គេមកតែងប្រាណ
ទើបអួតប្រាណថាខ្លួនអ្នកមានធំ ។

---

(១) អ័បចុន = ទាល់ ក្រខ្សត់ (ពាក្យថៃ) ។ (២) ផ្វង = ពួក បន (ពាក្យថៃ) ។
(៣) នគរបាល អានខ្យល់ថៃថា នគរបាន ។ (៤) អនង្គ អានខ្យល់ថៃថា អណុង ។

យកប្រាក់ស្ទកមេអណ្ដើកអណ្ដាតជា
ឯងមិនដឹងក៏ស្មានថាមានធំ
លុះដល់ថ្ងៃម្ចាស់ប្រាក់គេមកដល់
ឯងប្រពន្ធក៏ព័ន្ធជាមួយគ្នា
មានប្រុសខ្លះខ្ជីខ្ជាខ្ជិលរកស៊ី
ស្អាងតែអង្គឱ្យតែប្រពន្ធផ្គាប់
ប្រុសខ្លះនោះលុះល្បែងបៀរប៉ោថ្វ
សំពត់អាវផ្ដិលថាសតុតោកពាន
(៤៩) តែកងចារ៉ុំសេមាដែលកូនពាក់
កូនប្រពន្ធក៏ធន់ទៅតាមកម្ម
ហែអនង្គនារីរូបចំណាប់
ប្រុសឥឡូវច្រើនជួជាតិណ៉ាំចៅ
វិស័យប្រុសទុច្ចរិតចិត្តអ្នកលេង
ទោះមានប្រាក់ចាក់គរជាកោដិលាន
មានប្ដីខុសតុះគំនិតចិត្តស្ទើរបែក
ស្ត្រីទ្រទ្រាំតាមកម្មចាំចិត្តចៅ
តែចិត្តមនុស្សនេះមានះទៅរកខុស
ឃើញតែប្រុសក៏ព្រើលទៅផ្ដេសផ្ដាស
(៥០) ជាសត្រីល្អកាលពេញក្រមុំ
តែចាស់ចុះគិតលែងស្វែងរកថ្មី
ល្អអាប្រុក់ក៏តែគ្រានៅក្មេងគ្រាន់

ឱ្យមកស្ដីពណ៌នារឿងមនោរម្យ
ក៏ជឿចុះចិត្តពុំមានសង្កា ។
ទារប្ដឹងផ្ដល់ទាល់លុះចុះអាជ្ញា
នឹងគេចរាងណារួចកំនួចជាប់ ។
ចង់បានតែនារីគេមានស្រាប់
លុះអស់ទ្រព្យគេចត្រឡប់មិនរាប់អាន ។
ចិត្តម៉ៅមួលួចលេងឥតស្រាកស្រាន្ត
យកទៅទុយ (១) តាមរានរោងចំណាំ ។
លួចស្រាយដាក់ហោប៉ៅទៅបញ្ចាំ
មុខក្រជាំទ្រាំបំរើការគេទៅ ។
អញ្ជើញស្ដាប់បរិយាយយើងប្រដៅ
កុំចើកទៅរួមរ័កឱ្យធ្លាក់ប្រាណ ។
នាំឱ្យវង្វេងវរវំខាន
គង់អន្តរធានគ្មានសល់ដល់កូនចៅ ។
អង្គុយជួតតែទឹកភ្នែកអន់ក្ដួលក្ដៅ
នឹងបែរទៅកែខ្លួនក៏ជួនចាស់ ។
ម្ដេចមិនមើលទាបខ្ពស់ឱ្យជាក់ច្បាស់
ដល់ក្រក្រោយគិតក្រឡាស់សែនក្រក្រី ។
ចំរើនសមស័ក្ដិយសព្រោះស្វាមី
ក៏សាបសូន្យរាសីដូចត្បូងឆា ។
ចុះមានប្ដីពីរបីជាន់ក៏អន់ថ្លា

(១) ទុយ ថប់តែ " ទុក " ទេដឹង !

នឹងត្រឡប់ក្មេងវិញបានកាលណា ផុតប្រាជ្ញានឹងគិតកែមានតែទុក្ខ ។
បើស្រីណាកបកេរ្តិ៍ភរិយាគាប់ ទោះខាតទ្រព្យខានធនចុនសព្វមុខ
គង់មានគេសង្គ្រោះជួយដោះទុក្ខ ចំរើនសុខរាសីសួស្តីជា ។
ប្រៀបដូចមាសនព្វគុណកបរស្មី មានដីឡៀតតបីនឹងពណ៌នា
ថាបើត្តូជូចិត្តផតភរិយា នឹងដុសខាត់យ៉ាងណាមិនថ្លាបាន ។
ប្រៀបដូចមាសក្រឡៃស្មីរអាប់ នឹងប្រដាប់កាយក៏មិនថ្កើងថ្កាន
អ្នកត្រូវការតែងអង្គមិនចង់បាន លក់ដូរគ្មានដីឡៃថ្លៃថយថោក ។
(៥៥) ហេតុនេះនួនចូរស្ងួនរក្សាប្រាណ កុំឱ្យមានមន្ទិលមួហ្មងមក
គួរមិនគួរគួរគិតឱ្យត្រូវច្រក កុំកាន់យកជាគាប់ប្រកបកាយ ។
ចូរនៅក្នុងឱវាទញាតិវង្ស រក្សាទ្រង់តាមវង្សខ្សែស្រឡាយ
គួរភិសេកឯកឈ្មោះឮសុសសាយ កុំស្ទុះទៅតាមព្រះពាយពីពាក្យប្រុស ។
ឯខ្យល់មាត់បុរសនេះខ្លាំងក្លា លោកតែងថាអណ្តាតនេះដឹងរស
ចូររវាំងកំឡាំងខ្យល់បុរស កុំឱ្យចូលជ្រាបរស់សពាង្គកាយ ។
បើគេស្នើគ្រឱ្យស្ងួមដល់ម៉ែឪ កុំរត់ទៅដោយកាមតាមងាយៗ
ដល់គេស្អប់ឯងត្រឡប់ជាមេម៉ាយ ឯកាកាយខ្មាសគេគីនពេកពន់ ។
ខាងម៉ែឪក៏ក្រោធពិរោធខ្លាំង ចង់វាយជេរដោយកំឡាំងទោសោលន់
ព្រោះកាច់មុខលោកខ្មាស់អស់(១) មហាជន មិនគិតគន់ស្រឡាញ់ប្រាណទើបបានទុក្ខ ។
(៦០) បើប្រទះម៉ែឪចិត្តខ្លាំងក្រៃ ក៏លក់ថ្លៃឱ្យចៅប្តីបរាមុខ
បើប្រុសក្រកុំរកឡើយក្តីសុខ ខ្លួនធ្វើល្មក់(២) ពោងលក់ខ្លួននាងឯង ។
នឹងបន្ទោសម៉ែឪឯណាបាន ព្រោះសន្តានគិតខុសលុះដោយល្បែង
ស្រឡាញ់ប្រុសចុះចោលម៉ែឪឯង មិនគិតក្រែងគុណលោកប៉ុនទាំងភ្នំ ។

(១) ខ្មាស់ សរសេរតាមច្បាប់ដើម សព្វថ្ងៃសរសេរ" ខ្មាស" ។ (២ ) ល្មក់ ក្លាយមកពី លោមក ។

លោកចិញ្ចឹមមកប៉ងនឹងឱ្យមាន គូបូរាណវេណីនឹងស៊ីនំ
លុះកូនស្រីទូរយសខុស(១) អារម្មណ៍ ទើបក្រេវមក្រំក្រោធកូនស្ងួនឲ្យគំនិត ។
បើកូនជាក៏មានមុខសង៉ា(២) ញាតិវង្សពង្សាក៏ថ្លាចិត្ត
ទោះព្រៀងលានទៅនាស្ថានឆ្ងាយជិត ក៏មានចិត្តសរសើរនួនអនង្គ ។
ហៃនារីអោមយង់ចូរប្រុងប្រាណ កុំលលានតាមចិត្តដែលគិតចង់
គិតទុកមុខម្តាយឪពុកត្រកូលវង្ស រក្សាអង្គឱ្យគង់គេរ្តិ៍ម៉ែឪ ។
(៦៥) កាលទុំជោរគួរជំរុះជ្រុះចាកទង កុំជ្រុះឆ្ងាយឱ្យរំលងពីដើមទៅ
កុំដណ្តើមជ្រុះមុនឱ្យហ្មងសៅ យល់មិនត្រូវច្បាប់នារីពីបូរាណ ។
កុំគិតឡើយត្រង់គូគង់បានទេ ឧស្សាហ៍តែធ្វើការរកធនធាន
សន្សំទ្រព្យសម្បត្តិឱ្យកើតមាន ទើបនឹងបានពឹងពំនាក់នៃអាត្មា ។
ទៅខ្សត់អ្វីប្តីល្អនឹងតវង្ស គង់អ្នកល្អស្មើពង្សមកប្រាថ្នា
ម៉ែឪរៀបទុកដាក់តាមធម្មតា មានសង្ហារាសីល្បីកេរ្តិ៍ឈ្មោះ ។
មួយការស្រីគប្បីរៀនឱ្យចេះ ជាចំណេះគ្រឿងរកចិញ្ចឹមពោះ
ញាតិសន្តានឆ្ងាយជិតតាំងចិត្តស្មោះ កុំកឈ្លោះឱ្យមោះជាសត្រូវ ។
អធ្យាស្រ័យអ្នកក្រៅហៅថាញាតិ ពឹងផ្ញើមាត្រក្រែងមានធុរៈក្តៅ
ខ្ញុំកំដរយកស្តូរលប្រើហៅ ខឹងដេរទៅហៅមកយកតែការ ។
(៧០) រៀងចំអាបបង្អែមសៃមសមហាត់ ឱ្យចេះចាត់តាមរៀងគ្រឿងអាហារ
ចូលជំនុំមានរវល់មង្គលការ កាន់តែងារអ្វីៗ គប្បីផ្គង់ ។
ចុះជំនុំឱ្យច្រឡំគេអ្នកល្អ ចៀម(៣) ខ្លួនក្រកុំដំឡើងតំកើងអង្គ
គេឱ្យអ្វីប្រមាណយកឱ្យសមទ្រង់ កុំលោភលង់បង់លាភភាពនឹងអាប់ ។

---

(១) បុរាណសរសេរ ទូរយស សព្វថ្ងៃគេប្រើ ទុរយស ។ (២) សង៉ា = ល្អ រុងរឿង គូនឹងសង្ហា (ពាក្យថៃ) ។ (៣) ចៀម - ប្រុង (ពាក្យថៃ) ។

ចូល[១] ធ្វើអ្វីគប្បីដណ្ដឹងសួរ ការមិនគួរខ្លួនក្រមុំកុំអាលចាប់
គេបង្គាប់សូមធ្វើតាមបង្គាប់ ចាប់ឱ្យជាប់តាមការអាសាគេ ។
បើចូលថាសូរមមួយនឹងអ្នកល្អ ល្អកសម្លអន្លក់នៅមុខមេ
កុំលលោមលោល្អកទៅមុខគេ ប្រមាណពេលមស្រួលទទួលទាន ។
អ្វីឆ្ងាញ់នៅឆ្ងាយកាយមិនដល់ កុំរវល់ល្អកឱ្យគេថាបាន
ឆ្ងាញ់មិនឆ្ងាញ់នៅមុខខ្លួនប៉ុន្មាន ទទួលទានគ្មាននិន្ទាជាសួស្ដី ។
(៧៩) ជានារីពោងរៀនកិច្ចដាក់ទុក ការស៊ីចុកដេកដើរធ្វើអ្វីៗ
មើលប្រមាណតាមស្ថានខ្លួនជាស្រី ជាតិសត្រីស្រីក្រមុំធំឥរិយា ។
មែនបើធ្វើការអ្វីខំឱ្យស្រេច កុំភ្លាំងភ្លេចគេចចោលទៅឯណា
រវាំងពេកកិច្ចការនៃអាត្មា កុំខ្ជីខ្ជាគប់ភឿនលឿនពឿនទៅ ។
បើនឿយណាស់ប្រះដេកទៅជាវិញ កុំចូលចេញឥតការយល់មិនត្រូវ
អ្វីនោឡោកើតឡើងកុំផ្អើលទៅ ស្ដាប់ឱ្យជាក់រាក់ជ្រៅសូមសួរគ្នា ។
រវាំងមើលទីស្ថានរបស់ទ្រព្យ គន់ឱ្យសព្វនេះនោះនៅត្រង់ណា
ឃើញខាតចុះគួរឱ្យបំពេញវ៉ា របស់ណាគួរចំណាយឱ្យចាយចេញ ។
មានមួយស្លឹងប្រឹងប្រចុបឱ្យគ្រប់បាទ កុំឱ្យខាតដោយការមិនគួរទិញ
បើស៊ីតិចធ្វើតិចគិតឱ្យពេញ កុំចាយចេញលើសកំណត់ខ្សត់នឹងដល់ ។
(៨០) មិនគួរទិញកុំទៅទិញបុលគេមក មើលលៃលកល្មមតែមួយគ្រាល្វល់[២]
បើម៉ែឪចាស់ជរារោគាដល់ ខំខ្វល់ខ្វាយប្រតិបត្តិលោកទាំងទ្វី ។
ព្រោះជនកជននីទីរាប់អាន បង្កើតប្រាណបានធំដឹងសេចក្ដី
ថ្នមបបក់បញ្ចុកបាយចំណី ប៉ងនឹងពឹងកូនស្រីជាត្រីមុខ ។

( នៅមានត )

(១) ចង់ បានសេចក្ដីល្អជាង ចូល ។ (២) រវល់ ផ្លាស់ រ ជា ល រួចផ្សំនឹង វ ជា ល្វ ។

# វាក្យសព្ទសំស្ក្រឹតជំបូង ក្នុងភាសាខ្មែរបុរាណ និង ឋាននាមខ្មែរមានប្រភពពីភាសាសំស្ក្រឹត

## L ’ influence du sanscrit dans l’ancien khmer et les toponymes khmers d’origine sanscrit

បណ្ឌិត **ឡុង សៀម** (១)

ការសិក្សាវចនស័ព្ទភាសាខ្មែរបុរាណ មិនអាចប្រព្រឹត្តទៅបានទេ ប្រសិនបើគ្មានការសិក្សាលើពាក្យដែលខ្ចីមកពីភាសាសំស្ក្រឹត ។ នៅក្នុងភាសាខ្មែរបុរាណក៏ដូចជាក្នុងភាសាដទៃទៀត នៅក្នុងតំបន់អាស៊ីដែលមានអរិយធម៌បុរាណដែរ ពាក្យកម្ចីពីភាសាសំស្ក្រឹត មានចំនួនច្រើនជាអតិបរមា ។

នៅក្នុងសៀវភៅឈ្មោះ « ភាសានៅឥណ្ឌូចិន » ( ប៉ារីស ឆ្នាំ១៩៤៨ ), លោក ហ្សក សឺដេស បានកត់សំគាល់ថា ភាសានៃអរិយធម៌បុរាណនៅប្រទេសអាស៊ីអាគ្នេយ៍ គឺមាន :

- ភាសាចាមបុរាណ «ភាសានៅចំប៉ា» ចាប់ពី ស.វ.ទី ៧,
- ភាសាមនបុរាណ « ភាសានៃរាជាណាចក្រកម្ពុជា ទ្វារវតី » ចាប់ពី ស.វ.ទី ៧,

---

(១) បណ្ឌិត ឡុង សៀម ជាសហការីបណ្ឌិតសភាវិទ្យាសាស្ត្រ សហព័ន្ធរុស្ស៊ី ( វិជ្ជាស្ថានបូព៌ាវិទ្យា ) សាស្ត្រាចារ្យសិលាចារឹក និងអក្សរសាស្ត្រ សាកលវិទ្យាល័យ ភ្នំពេញ

- ភាសាម៉ាឡាយូបុរាណ « ភាសានៅស៊ូម៉ាត្រា » ចាប់ពី ស.វ.ទី ៧
- ភាសាបាឡាវ៉ា ( ជ្វា ) បុរាណ « ភាសានៅបាឡាវ៉ា » ចាប់ពី ស.វ.ទី ៨
- ភាសាភូមាបុរាណ « ភាសានៅភូមា » ចាប់ពី ស.វ.ទី ១១
- ភាសាថៃបុរាណ « ភាសានៅថៃ » ចាប់ពី ស.វ.ទី ១៣
- រីឯភាសាខ្មែរបុរាណ ដែលជាភាសានៃកម្ពុជទេសវិញ មានកាលបរិច្ឆេទចាប់ពី ស.វ.ទី ៦ មក ។

តាមឯកសារប្រវត្តិសាស្ត្រ នៅសតវត្សទី ១ នៃ គ.ស រាជាណាចក្រនគរភ្នំ ឬហ្វូណន (ឈ្មោះប្រទេសកម្ពុជា ពីបុរាណ) គឺជារាជាណាចក្រមួយ ក្នុងចំណោមរាជាណាចក្រ ដែលបានទទួលឥទ្ធិពលពីឥណ្ឌា នៅអាស៊ីអាគ្នេយ៍ ។ អ្នកដែលបានបង្កបង្កើតរាណាចក្រនេះ គឺព្រាហ្មណ៍ម្នាក់ដែលមានប្រភពមកពីប្រទេសឥណ្ឌា ដែលមានឈ្មោះជាសំស្ក្រឹតថា កោណ្ឌិញ្ញ ។ នៅក្នុងសៀវភៅឈ្មោះ « ប្រវត្តិសាស្ត្រនៃប្រទេសដែលទទួលឥទ្ធិពលឥណ្ឌា នៅឥណ្ឌូចិន និងឥណ្ឌូណេស៊ី » ប៉ារីស ឆ្នាំ ១៩៦៤, លោក ហ្សក សឺដែស បានសរសេរថា អាពាហ៍ពិពាហ៍រវាងព្រាហ្មណ៍កោណ្ឌិញ្ញ និងមហាក្សត្រីខ្មែរដែលមានព្រះនាម សោមា ( = ព្រះច័ន្ទ ) គឺជាការផ្ដើមនៃរាជវង្សមហាក្សត្រខ្មែរ ដែលដឹកនាំប្រទេសកម្ពុជា ក្នុងសម័យមុនអង្គរ និងអង្គរ ។ ម្យ៉ាងទៀត សម្ពន្ធភាពតាមអាពាហ៍ពិពាហ៍រវាងព្រាហ្មណ៍មកពីឥណ្ឌា និងមហាក្សត្រីខ្មែរ អាចបកស្រាយបានថា ជានិមិត្តរូបនៃការលេចឡើងដោយសន្តិភាពនៃឥទ្ធិពលភាសាសំស្ក្រឹត នៅក្នុងភាសាខ្មែរ ។ ប្រជាជនដែលជាម្ចាស់ស្រុក ហើយដែលរស់នៅក្នុងក្របខ័ណ្ឌវប្បធម៌អូស្ត្រូអាស៊ី បានទទួលឥទ្ធិពលវប្បធម៌ឥណ្ឌាមករួមផ្សំនឹងវប្បធម៌ដើមរបស់ខ្លួន បង្កើតបានជាវប្បធម៌មួយបែបថ្មី ប្រកបដោយការរីកចំរើន ។

ប៉ុន្តែ កាលបរិច្ឆេទពិតប្រាកដនៃការហូរចូលនូវភាសាសំស្ក្រឹតមកក្នុងប្រទេសកម្ពុជា នៅមិនទាន់កំណត់បានច្បាស់លាស់នៅឡើយ ។ សិលាចារឹកទី១ ជាភាសាសំស្ក្រឹត នៅ វ៉ូកាញ ត្រូវគេសន្មតថាជាសិលាចារឹកនៃសម័យនគរភ្នំ នៅសតវត្សទី ៣ ដោយសំអាងទៅលើការវិភាគអក្ខរក្រមដែលគេប្រើក្នុងការសរសេរ ។ សិលាចារឹកនេះ អាចចាត់ទុកថាជាប្រភពមួយដ៏សំខាន់ក្នុងប្រវត្តិសាស្ត្រ នៃនគរភ្នំ ដែលក្នុងនគរនេះ ភាសាសំស្ក្រឹតត្រូវបានគេប្រើជាភាសាផ្លូវការ ក្នុងរាជខុទ្ទកាល័យ ។

សិលាចារឹកដទៃទៀតជាភាសាសំស្ក្រឹត ដែលមានកាលបរិច្ឆេទប្រហែលជាក្នុងសតវត្សទី ៦ ( សិលាចារឹក K ៤០ នៅតាកែវ វត្តបាទី, K៩២៤ នៅឡុងសៀងកួសាំងស៊ិន, K ៩៧៥ នៅស៊ីទេព ថៃឡង់, K. ៣៦៥ នៅបាសាក់ ប្រទេសឡាវខាងត្បូង ) ក៏ត្រូវបានគេរកឃើញក្នុងតំបន់ឆ្ងាយៗនានាក្នុងប្រទេសកម្ពុជា នាបុរាណកាលដែរ ។ បើវិនិច្ឆ័យទៅតាមរបាយសិលាចារឹកតាមភូមិសាស្ត្រ គេអាចធ្វើការសន្និដ្ឋានបានថា ភាសាសំស្ក្រឹតត្រូវបានប្រជាជនកម្ពុជាមួយចំនួនធំប្រើប្រាស់ ហើយអ្នកទាំងនោះ ប្រហែលជាអ្នកគោរពបូជាសាសនាយ៉ាងមុតមាំ មានជាអាទិ៍ ពុទ្ធសាសនា មហាយាន និងនិកាយផ្សេងៗ របស់ព្រហ្មញ្ញសាសនា ។

ព្រមជាមួយគ្នានោះ មានសិលាចារឹកជាភាសាខ្មែរដែរ ដូចជាសិលាចារឹក K. ២៨ នៅតាកែវ K. ១៣៧ នៅខេត្តក្រចេះ K. ៤២៦ នៅខេត្តកណ្ដាល ។ បើវិនិច្ឆ័យទៅតាមភាពបុរាណនៃអក្ខរក្រមដែលគេប្រើ គឺមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងអក្ខរក្រម ដែលប្រើក្នុងសិលាចារឹក ដែលរៀបរាប់ខាងលើ ។ ដូចនេះហើយ សិលាចារឹកទាំងនេះ អាចចាត់ទុកបានផងដែរថា ជាសិលាចារឹកនៅសតវត្សទី៦ ។ ដោយមូលហេតុនេះ ភាសាខ្មែរបុរាណ បើគិតតាមប្រភពសំនេរត្រូវកំណត់កាលបរិច្ឆេទក្នុងសតវត្សទី៦ គឺមិនមែនក្នុងសតវត្សទី៧ ទេ ។

ក្នុងមូលន័យនៃការសិក្សាប្រវត្តិភាសាខ្មែរ សម័យកាលនោះគឺ ទី១ វាឆ្លើយគ្នានឹងការចាប់ផ្តើមនៃការខ្ចីវចនស័ព្ទពីភាសាសំស្ក្រឹតមកក្នុងភាសាខ្មែរ ( ភាសាសរសេរ ) និងទី២ វាឆ្លើយគ្នាទៅនឹងការលេចឡើងនៃអត្ថបទជាលាយល័ក្សណ៍អក្សរជាភាសាខ្មែរ ដោយប្រើអក្ខរក្រមដែលគេប្រើសំរាប់ចារឹកអត្ថបទជាភាសាសំស្ក្រឹត ក្នុងប្រទេសកម្ពុជា ។

បើវិនិច្ឆ័យតាមអក្សរចារឹក ភាសាខ្មែរបុរបណ យកតួអក្សរព្យញ្ជនៈនៃអក្ខរក្រមសំស្ក្រឹតមកធ្វើការកែទំរង់ លើកលែងតែព្យញ្ជនៈ ៹ និង s ដើម្បីបង្កើតអក្ខរក្រមរបស់ខ្លួនផ្ទាល់ ។

ហេតុនេះហើយ យើងអាចសន្និដ្ឋានបានថា ការប្រើអក្ខរក្រមតែមួយសំរាប់ពាងភាសាទាំងពីរ បណ្តាលឱ្យភាសាខ្មែរខ្ចីវចនស័ព្ទជាច្រើនពីភាសាសំស្ក្រឹតដែលជាភាសាមួយប្រកបដោយកិត្យានុភាព និងជាភាសាសំរាប់ប្រើក្នុងសាសនា ។

អត្ថបទទី ១ ជាភាសាខ្មែរ និងមានកាលបរិច្ឆេទត្រឹមត្រូវ ត្រូវគេរកឃើញនៅអង្គរបុរី គឺនៅឆ្នាំ ៦១១ នៃ គ.ស ។ ក្នុងនោះ គេប្រទះឃើញមានពាក្យសំស្ក្រឹតជាច្រើន ។ នៅក្នុងអត្ថបទនេះ ទន្ទឹមគ្នានឹងពាក្យកម្ចីធម្មតា គេសង្កេតឃើញមានប្រើពាក្យសំស្ក្រឹតសំរាប់ពាងឈ្មោះអ្នកចំរៀង និងអ្នករបាំផងដែរ ។

ឈ្មោះសំស្ក្រឹតថ្មីៗទាំងនេះ ខុសប្លែកពីឈ្មោះមនុស្ស ដែលមានកំណើតជាភាសាខ្មែរ គឺថា ឈ្មោះមនុស្សទាំងនេះជាពាក្យច្រើនព្យាង្គ និងជាពាក្យដែលមានសូរសៀងពិសេស និងសំដែងន័យច្បាស់លាស់ផង ។ ឧទាហរណ៍ : វស្សន្តមាលិកា «ផ្កាម្លិះនាវស្សន្តរដូវ» គន្ធារី «មានគុណសម្បត្តិល្អ» ចារុមតី «ម្ហូបចំណីសំរាប់ពិចារណា» អរុណមតិ «ធម្មិពេលព្រលឹម» គន្ធិនី «មានក្លិនឈ្ងុយឈ្ងប់» ។ ម្យ៉ាងទៀតពាក្យដែលមានដើមកំណើតពីសំស្ក្រឹត ហើយមានបំលែងពេញលេញជាភាសាខ្មែរបុរាណ នៅសតវត្សទី៧ គេមិនសូវជួបប្រទះទេ ។ ប៉ុន្តែពាក្យមួយចំនួន ដូចជា :

ក្លិង្គ « ជនជាតិឥណ្ឌា » ត្រូវនឹងភាសាសំស្ក្រឹតថា **Kalinga** ( K.១ ), «ស្មើ» <សំស្ក្រឹត : « សម **sama** », ផ្លែ K. ៩០, ផល < សំស្ក្រឹត « ផលះ **phala** », ព្រះ K.៦០០ « អាទិទេព » < សំស្ក្រឹត : « វរះ **vara** » អាចចាត់ទុកថាជាពាក្យដែលមានបំលែងជាភាសាខ្មែរបុរាណ នាសម័យនោះ ។

ក្នុងការស្រាវជ្រាវ និងរៀបចំបោះពុម្ពវចនានុក្រមខ្មែរបុរាណ នៅក្នុងសិលាចារឹកបុរាណជាភាសាខ្មែរ យើងរកឃើញពាក្យ ពហុព្យាង្គមួយចំនួនធំ ដែលគេអាចចាត់ទុកបានថាជាពាក្យកម្ចីពីភាសាសំស្ក្រឹត ។

ការសិក្សាពាក្យដែលលើកមកជាឧទាហរណ៍ខាងលើ អាចឱ្យយើងសន្និដ្ឋានបានថា ពាក្យសំស្ក្រឹតដែលមានពីរ ឬ បីព្យាង្គ បានទទួលបំលែងឱ្យទៅជាពាក្យខ្មែរ ដែលមានមួយព្យាង្គប្រកបដោយក្រុមព្យញ្ជនៈនៅខាងដើម ហើយនៅពេលនោះយើងបានសង្កេតឃើញយ៉ាងជាក់ស្តែង នូវនិន្នាការឯកព្យាង្គក្នុងការវិវឌ្ឍន៍សូរស័ព្ទភាសាខ្មែរ ។

ជាទូទៅ ពាក្យខ្មែរសុទ្ធ ឬ ពាក្យកម្ចី ដែលបំលែងមកជាពាក្យខ្មែរ មិនអាចមានលើសពីពីរព្យាង្គឡើយ ហើយនៅចុងពាក្យមិនអាចមានព្យញ្ជនៈលើសពីមួយទេ ។ រីឯព្យញ្ជនៈចុងពាក្យនេះ អាចជាព្យញ្ជនៈច្រមុះ ប៉ុន្តែមិនអាចជាព្យញ្ជនៈបិទអាស្ពីរេ ឬ បិទសូន័រឡើយ ។

ដំណើរបំលែងពាក្យពីសំស្ក្រឹតទៅជាពាក្យខ្មែរបុរាណ ប្រព្រឹត្តទៅយឺតណាស់ គឺប្រើរយៈពេលអស់យ៉ាងច្រើនសតវត្ស ។

ហេតុដូច្នេះហើយ នៅប្រទេសកម្ពុជា ភាសាសំស្ក្រឹត ត្រូវគេចាប់ផ្តើមប្រើប្រាស់មុនពេលដែលកើតមានសិលាចារឹកជាភាសាខ្មែរ ។

ឥទ្ធិពលនៃភាសាសំស្ក្រឹត មកលើរចនាសម្ព័ន្ធវចនស័ព្ទខ្មែរបុរាណ ត្រូវកំណត់ដោយកត្តាក្រៅភាសាវិទ្យា មួយចំនួនដូចតទៅ :

- នៅសម័យអង្គរ មានការប្រែប្រួលជាខ្លាំងក្នុងវិស័យសេដ្ឋកិច្ច និងវប្បធម៌ រីឯភាសាខ្មែរបុរាណមានលក្ខណៈអភិវឌ្ឍបិទជិត គ្មានវិធីគ្រប់គ្រាន់សំរាប់បង្កើតពាក្យថ្មីៗ តាមបញ្ញត្តិអរូបី និងបច្ចេកស័ព្ទទេ ។

- ពាក្យថ្មីៗ ត្រូវបង្កើតឡើងភាគច្រើនដោយវិធីផ្ចត់ដើម និងវិធីផ្ចត់ដែក ហើយច្រើនជាពាក្យដែលតាងបញ្ញត្តិរូបី ។

- វចនស័ព្ទខ្មែរសុទ្ធ ច្រើនតែជាពាក្យពហុន័យ និងសទិសស័ព្ទ ។ ប៉ុន្តែប្រព័ន្ធវចនស័ព្ទតែងតែរីកចំរើនឥតឈប់ឈរ ។ នៅសម័យអង្គរ ក្នុងរង្វង់មហាក្សត្រ និងសាសនា គេចូលចិត្តប្រើភាសាសំស្ក្រឹត គេនិយមថា ភាសាសំស្ក្រឹតជាភាសាដែលមានកិត្យានុភាព ដោយហេតុថា អត្ថបទភាគច្រើនជារាជក្រឹត្យ ដែលនិពន្ធឡើងដោយបព្វជិត ដែលមានឋានន្តរសក្តិខ្ពង់ខ្ពស់ ក្នុងនោះគេសង្កេតឃើញមានពាក្យខ្មែរ និងពាក្យសំស្ក្រឹតនៅលាយឡំគ្នា ។

- ឥទ្ធិពលទៅវិញទៅមក រវាងពាក្យខ្មែរ និងពាក្យសំស្ក្រឹត ធ្វើឱ្យបាតុភូតវេវចនស័ព្ទបានរីកដុះដាល ។ម្យ៉ាងទៀត ពាក្យកម្ចីពីភាសាសំស្ក្រឹត មាននិន្នាការបន្ថយការប្រើប្រាស់ពាក្យខ្មែរសុទ្ធ ដូចជាពាក្យខ្មែរសំរាប់ប្រាស្រ័យទាក់ទងធម្មតាហើយនិងពាក្យសំរាប់តាងបញ្ញត្តិមនុស្ស ស្រី ម្តាយ ឪពុក គោ និងលេខសំរាប់តាងចំនួន ត្រូវជំនួសជាបណ្តើរៗដោយពាក្យសំស្ក្រឹត ។

- ក្នុងសម័យកាលនៃអរិយធម៌អង្គរ ភាសាខ្មែរបានខ្ចីពាក្យសំស្ក្រឹតជាច្រើនមកប្រើប្រាស់ ដូចជាពាក្យក្នុងវិស័យសាសនា នយោបាយ រដ្ឋបាល ច្បាប់ប្រក្រតិទិន និងពាក្យបច្ចេកទេសផ្សេងៗទៀត ព្រមទាំងឈ្មោះទីកន្លែង « ឋាន-នាម» ឈ្មោះមនុស្ស « នរនាម » ឈ្មោះអាទិទេព « ទេវនាម » ។

ដោយវិនិច្ឆ័យទៅតាមអក្សរចារឹកជាភាសាខ្មែរ និង សំស្ក្រឹត ពេលនោះជនជាតិខ្មែរបានស្គាល់អភិប្រាយដ៏ល្បីៗ នានាជាភាសាសំស្ក្រឹត អំពីច្បាប់ នយោបាយ

និងរចនាសម្ព័ន្ធរដ្ឋបាលក្នុងរដ្ឋ មានជាអាទិ៍ៈ ធម្មសាស្ត្រ ( អភិប្រាយអំពីច្បាប់ ) នីតិ-សាស្ត្រ ( អភិប្រាយអំពីនីតិសាស្ត្រ ) អត្ថសាស្ត្រ ( អភិប្រាយអំពីនយោបាយ ) រាជ-ធម៌ ( អភិប្រាយអំពីរាជវង្ស ) ។ ល ។ ចំណែកក្នុងវិស័យនរនាម និងឋាននាម ក៏ទទួលឥទ្ធិពលភាសាសំស្ក្រឹតយ៉ាងខ្លាំងដែរ ។ តាមអត្ថបទចារឹកជាភាសាខ្មែរបុរាណ យើងអាចនិយាយបានថា ជាការបន្តប្រពៃណីសរសេរបញ្ជីឈ្មោះអ្នកដែលទទួលខុសត្រូវក្នុងការកសាងប្រាសាទសំរាប់បូជាព្រះឥស្វរ ព្រះវិស្ណុ និងព្រះពុទ្ធ ។ បញ្ជីអសា-ធារណនាមសំខាន់ៗ ត្រូវគេរក្សាទុកនៅឡើយ ។ ឈ្មោះទាំងនេះ គេអាចជួបប្រទះក្នុងអត្ថបទភាសាខ្មែរបុរាណ នៅក្នុងសម័យផ្សេងៗគ្នា និងចារឹកនៅទីកន្លែងផ្សេងគ្នា ។ គ្រួសាររបស់អ្នកធ្វើសក្ការបូជា បំរើព្រះអាទិទេព ពីមួយជំនាន់ ទៅមួយជំនាន់ បានរក្សាឈ្មោះត្រកូលរបស់ខ្លួនជាសំស្ក្រឹត K. ៧៨២ ។ មនុស្សដែលស្ថិតក្នុងស្រទាប់ក្រោម មានឈ្មោះជាពាក្យដែលមានកំណើតខ្មែរ និងសំស្ក្រឹត ។ រីឯមនុស្សស្ថិតនៅស្រទាប់លើ ភាគច្រើនមានឈ្មោះជាសំស្ក្រឹត ឈ្មោះមន្ត្រីជាន់ខ្ពស់ ទោះជាមន្ត្រី គ្រហស្ថ ឬ បណ្ឌិតក៏ដោយ សុទ្ធតែជាភាសាសំស្ក្រឹតទាំងអស់ ។

ព្រះរាជាទាំងអស់នៅសម័យមុនអង្គរ និងអង្គរ មានព្រះនាមជាពាក្យដែលមានដើមកំណើតពីភាសាសំស្ក្រឹត ។

ឧទាហរណ៍ ៈ

- ភវវរ្ម័ន :K១៤៩ « ជនដែលព្រះឥស្វរការពារ »
- ឥសានវរ្ម័ន K.២២ « ជនដែលព្រះឥសានការពារ »
- ជ័យវរ្ម័ន K.៤៥៣ « ប្រកបដោយជ័យជំនះ »
- ឥន្ទ្រវរ្ម័ន K.១៤ « ជនដែលព្រះឥន្ទ្រការពារ »
- សុរិយាវរ្ម័ន K.៣១ « ជនដែលព្រះអាទិត្យការពារ »

នៅក្នុងអក្សរចារឹកជាភាសាខ្មែរ គេក៏អាចរកឃើញផងដែរ នូវឋាននាម

ប្រហែល ១.៥០០ ។

ក៏ដូចជានរនាមដែរ ឋាននាមក្នុងភាសាខ្មែរបុរាណ ត្រូវបង្កើតឡើង ដោយពាក្យខ្មែរផង និងសំស្ក្រឹតផង ។ ឋាននាមដែលជាពាក្យដើមកំណើតខ្មែរ ជាធម្មតា ច្រើនតាងឈ្មោះ ភ្នំ ព្រៃ បឹង ត្រពាំង ដី ខ្ពង់រាប ភូមិ តំបន់ ស្រែ ។ ឋាននាមជាភាសាសំស្ក្រឹត តាងឈ្មោះប្រទេស តំបន់ ទីក្រុង ប្រាសាទ និងគ្រឹះស្ថានសាសនានានា ។ ឈ្មោះសំស្ក្រឹតខាងលើ ច្រើនជាពាក្យដែលមានឫស ជាផ្នែកមួយនៃទេវ-នាម ។ ពាក្យទេវនាម គឺយើងសំដៅយកឈ្មោះអាទិទេព ប្រុស ឬស្រី នៃព្រហ្មញ្ញ-សាសនា និងពុទ្ធសាសនា ដែលប្រជាជនគោរពបូជា ។

ទេវនាមទាំងនេះ បានបង្ហាញអំពីអត្ថិភាពនៃសំយោគនិយម រវាងសាសនា និងអាណាចក្រនៅកម្ពុជា សម័យបុរាណ ។ ទេវនាម គឺជានាមអមតៈ ដែលយកពីឈ្មោះអាទិទេព សំរាប់តាងរូបលក្ខណៈរបស់ព្រះរាជា និងមន្ត្រីជាន់ខ្ពស់ ។

ឈ្មោះរាជធានីបុរាណនៅសម័យមុនអង្គរ និងសម័យអង្គរ ដែលមានដើមកំណើតពីភាសាសំស្ក្រឹត ។

ឧទាហរណ៍ ៖

- វ្យាធបុរៈ «ទីក្រុងរាជាដែលជាព្រានប្រមាញ់ដ៏រី » (បាភ្នំ)
- សំភុបុរៈ « ទីក្រុងព្រះឝិវៈ » (សំបូរ)
- ឥសានបុរៈ «ទីក្រុងព្រះឥសាន» K. ៣១៤ (សម្បូរព្រៃគុក)
- ហរិហរាល័យបុរៈ «ទីក្រុងព្រះវិស្ណុ និងព្រះឥស្វរ» K. ២៣៥ (លលៃ)
- កម្ពុបុរៈ « ទីក្រុងតាបសកម្ពុ » K. ២៨៣
- យសោធរបុរៈ « ទីក្រុងដ៏ស្រស់ប្រិមប្រិយ៍ » K. ៧០

ឈ្មោះទាំងពីរខាងក្រោយនេះ គឺជាឈ្មោះបុរាណនៃអង្គរធំ ។

ឥទ្ធិពលរបស់ភាសាសំស្ក្រឹត ទៅលើរចនាសម្ព័ន្ធវចនស័ព្ទខ្មែរ បានឡើងដល់កំរិតកំពូលនៅសតវត្សទី XII ដូចដែលគេឃើញច្បាស់ក្នុងឧទាហរណ៍លើអត្ថបទចារឹក K. ៤៧០ ។ រហូតដល់សម័យកាលនេះ ក្នុងភាសាសរសេរពាក្យកម្ចីរក្សាទំរង់ដើមរបស់ខ្លួន ។ ការបំលែងប្រព្រឹត្តទៅមិនបានរហ័ស គឺបណ្តាលមកពីភាសាទាំងពីរ មានចំណាត់ថ្នាក់បែបរចនាសម្ព័ន្ធមិនដូចគ្នា ប៉ុន្តែការខ្ចីពាក្យពីសំស្ក្រឹតនៅតែមានបន្តទៅទៀត ។

នៅក្នុងអត្ថបទសិលាចារឹកជាភាសាខ្មែរ នៅសតវត្សទី XIII - XIV គឺនៅសម័យចុងក្រោយនៃអត្ថិភាពអាណាចក្រអង្គរ ចំនួនពាក្យសំស្ក្រឹតត្រូវគេរកឃើញប្រហាក់ប្រហែលនឹងចំនួនពាក្យខ្មែរ ។ ពាក្យទាំងនេះមួយចំនួនធំ នៅតែរក្សារចនាសម្ព័ន្ធអក្ខរាវិរុទ្ធទៅតាមភាសាដើមរបស់ខ្លួន ។

ឧទាហរណ៍ : អត្ថបទសិលាចារឹកនៅប្រាសាទបាយ័ន K. ៤៧០ ដែលមានកាលបរិច្ឆេទឆ្នាំ ១៣២៧ គឺជាអត្ថបទដែលថ្លែងអំពីរាជក្រឹត្យ ហើយក្នុងនោះមានពាក្យចំនួន ២៤០ ។ ក្នុងចំនួននេះ ១១០ ពាក្យ ជាពាក្យដែលខ្ចីពីភាសាសំស្ក្រឹត ។

ក្នុងសិលាចារឹក កំពង់ស្វាយ K. ១១៧ និងបារាយណ៍ K. ១៤៤ នៅសត-វត្សទី XIII - XIV ពាក្យកម្ចីពីភាសាសំស្ក្រឹត និងបាលី ដែលប្រើក្នុងពុទ្ធសាសនាថេរវាទមានចំនួនលើសពាក្យខ្មែរយ៉ាងច្រើន ។ ហេតុនេះ ក្នុងការអានអត្ថបទសិលាចារឹកទាំងនេះ ជួនកាលអាចនាំឱ្យគេមានទស្សនៈថា ភាសាដែលគេសរសេរអត្ថបទនេះ ជាភាសាដែលកើតពីសំយោគ រវាងភាសាខ្មែរនិងភាសាសំស្ក្រឹត ដែលក្នុងនោះវចនស័ព្ទ ជាវចនស័ព្ទសំស្ក្រឹត រីឯសម្ព័ន្ធល្បះ ចេញពីភាសាខ្មែរ ។ ភាសាខ្មែរដែលគេប្រើសំរាប់ចារអត្ថបទទាំងនេះ អាចប្រៀបធៀបទៅនឹងភាសា « កាវី » ដែលគេប្រើសំរាប់ចារអត្ថបទនៅកោះជ្វា គឺជាភាសាដែលកើតឡើងពីការរួមផ្សំរវាងភាសាសំស្ក្រឹត និងភាសាជ្វាបុរាណ ។ ប្រហែលជាសម័យនោះកើតមានសហា

ភិប្រាយនៃភាសាខ្មែរ និងសំស្ក្រឹតនៅក្នុងកិរិតភាសារអក្សរសាស្ត្រ ។

## ឋាននាមខ្មែរមានប្រភពពីភាសាសំស្ក្រឹត

ក្នុងអត្ថបទសិលាចារឹកពីសតវត្សទី ៤ ដល់ទី ១៤ គេសង្កេតឃើញមានឋាននាមក្នុងភាសាខ្មែរ ចំនួនប្រមាណ ៤០០ ជាពាក្យខ្ចីពីភាសាសំស្ក្រឹត ។ បើយើងប្រៀបធៀបទៅនឹងចំនួនឋាននាមទាំងអស់ដែលមាននៅក្នុងសិលាចារឹកខ្មែរ គឺឋាននាមជាពាក្យសំស្ក្រឹតមានប្រហែលជាងមួយភាគបី ។ តាមការសិក្សាស្រាវជ្រាវ គេពិនិត្យឃើញថា ឋាននាមជាពាក្យសំស្ក្រឹតទាំងនេះ មានលក្ខណៈខុសប្លែកពីឋាននាមជាពាក្យខ្មែរ ព្រោះថា ឋាននាមទាំងនោះមានប្រភពផ្សេងគ្នា ។ ឋាននាមជាពាក្យសំស្ក្រឹតមានប្រភពពីមជ្ឈដ្ឋានអ្នកប្រាជ្ញដែលជាគ្រហស្ថ ឬ អ្នកសាសនាក្នុងរាជវាំងដែលចេះភាសាសំស្ក្រឹតយ៉ាងជ្រៅជ្រះ ហើយឋាននាមជាពាក្យខ្មែរ មានកំណើតពីស្រទាប់ប្រជារាស្ត្រធម្មតា ។ នៅក្នុងសម័យកាលនោះ ភាសាសំស្ក្រឹតមានតួនាទីយ៉ាងសំខាន់នៅក្នុងកិច្ចការរដ្ឋបាល ដែលត្រូវគេចាត់ទុកថាជាភាសាផ្លូវការ ។ ភាសានេះត្រូវបានគេយកទៅប្រើប្រាស់ក្នុងការកត់ត្រាព្រះរាជបញ្ញត្តិ, ព្រះរាជក្រឹត្យក្នុងការបែងចែកដែនដី មណ្ឌលរដ្ឋបាល ( ខេត្ត រាជធានី ក្រុង ស្រុក ... ) វត្តអារាម និងប្រាសាទ អាងទឹក ( បារាយណ៍ ) ភ្នំ ផ្លូវទឹក និងសំណង់ផ្សេងៗទៀត នៅក្នុងប្រទេស ដែលនៅក្នុងនោះ គេពិនិត្យឃើញឋាននាមភាគច្រើនជាភាសាសំស្ក្រឹត ។ តើបន្សំ នៃឋាននាមជាពាក្យសំស្ក្រឹតក្នុងភាសាខ្មែរ ប្រព្រឹត្តទៅយ៉ាងដូចម្តេច ?

យើងកត់សំគាល់ឃើញថា បន្សំនៃឋាននាមសំស្ក្រឹតក្នុងភាសាខ្មែរ ធ្វើឡើងដោយការប្រើប្រាស់ឋាននាមទាំងនោះក្នុងអត្ថបទសិលាចារឹកជាភាសាខ្មែរ ដោយបំពេញបច្ចេកស័ព្ទនៃមណ្ឌលរដ្ឋបាល និងបច្ចេកស័ព្ទឋាននាមផ្សេងៗទៀត ដែលជាពាក្យខ្មែរ ឬ មានប្រភពមកពីពាក្យសំស្ក្រឹត ។ បច្ចេកស័ព្ទ នៃឋាននាមដែលមាន

ប្រភពពីសំស្រ្កឹតនេះ ជាពាក្យសំស្រ្កឹតដែលត្រូវបានធ្វើសមានកម្មនៅក្នុងភាសាខ្មែររួចទៅហើយ ។ បច្ចេកស័ព្ទនេះ គឺជាបច្ចេកស័ព្ទ ដែលត្រូវបានគេសិក្សាយ៉ាងហ្មត់ចត់ ក្នុងប្រធានបទ ស្តីអំពី « បច្ចេកស័ព្ទឋាននាម » ដូចជាមានពាក្យប្រមាណ (**pramāna** ) វិសយ ( **visaya** ) ភូមិ ( **bhumi** ) ... ។ ម្យ៉ាងទៀត ឋាននាមជាពាក្យសំស្រ្កឹតមួយចំនួនធំ បានបង្កើតឡើងដោយភ្ជាប់នូវស័ព្ទខាងចុងដទៃៗទៀត ( éléments déterminatifs ) ដែលសំគាល់នូវទីកន្លែង ។ ធាតុទាំងនេះមានដូចជា :

**pura / puri** បុរះ / បុរិ មានន័យថា បុរី ឬក្រុងដែលមានកំពែងការពារ ។ ពាក្យនេះត្រូវបានគេប្រើនៅក្នុងឋាននាមសំស្រ្កឹតមួយចំនួន ដូចខាងក្រោម :

**sruk vanapura** K ៩៥៧ : ឈ្មោះស្រុក វនបុរះ ( វនបុរះ - « បុរីរុក្ខជាតិ, ស្រុក - « ស្រុក » ) ;

**viṣaya virapura** : ឈ្មោះខេត្ត វិរបុរះ ( វិរះបុរះ - « បុរីអង់អាច, បុរីវីរជន» ) ;

**pramāṇa çreṣṭhapura** K. ៩៤៤ : ដែនដីឈ្មោះស្រេស្ឋបុរះ ( ស្រេ ឞ្ឋ បុរះ - « បុរីដែលមានសោភណភាពល្អប្រណីត » ) ;

**kamrateṅ jagat liṅgapura** : ប្រាសាទ ឈ្មោះលិង្គបុរះ ( លិង្គបុរះ - « បុរីដែលមានលិង្គ, ដែលមានការគោរពបូជាលិង្គ » ) ;

**rudrapura** K. 9 : ទីក្រុងឈ្មោះ រុទ្របុរះ ( រុទ្របុរះ - « បុរីរបស់អាទិទេពឈ្មោះ រុទ្រះ » ) ;

**grāma** គ្រាមះ មានន័យថាជាភូមិ, ជាលំនៅឋាន, ជាកន្លែងដែលមានមនុស្សរស់នៅ ។ ឧទាហរណ៍ :

**sruk devigrāma** K. 258 : ស្រុកឈ្មោះ ទេវិគ្រាមះ ( ទេវិគ្រាម

« ជាភូមិរបស់ទេពអប្សរ » ) ;

**sruk daçagrāma** K. 258 : ស្រុកឈ្មោះ ទសគ្រាមៈ ( ទសៈគ្រាមៈ « ភូមិ ១០ » ) ;

**pramāna çatagrāma** K. 207 : ដែនដីឈ្មោះ សតគ្រាមៈ ( សតគ្រាមៈ - « ភូមិចំនួន ១០០ » ) ;

**kamrateṅ jagat çri narendragrāma** K. 276 : ប្រាសាទឈ្មោះស្រិ នរេន្ទ្រគ្រាមៈ (ស្រ្តិ នរេន្ទ្រគ្រាមៈ - « ភូមិរបស់អាទិទេព ស្រិនរេន្ទ្រៈ) ;

**pada** បទៈ មានន័យថាជាលំនៅឋាន ។ ឧទាហរណ៍ :

**janapada** K. 235 : តំបន់មួយ ឈ្មោះជនបទ : ( ជនបទៈ - « លំនៅឋានរបស់មនុស្ស» ) ;

**sruk viṣnupada** K. 292 : ស្រុកឈ្មោះ វិស្ណុបទៈ ( វិស្ណុបទៈ - « លំនៅឋានរបស់ព្រះវិស្ណុ » ) ;

**sruk rudrapada** K. 352 : ស្រុកឈ្មោះ រុទ្រ្របទៈ ( រុទ្រ្របទៈ « លំនៅឋានរបស់ទេវ រុទ្រ្រៈ » ) ;

**çivapada** K. 580 : ប្រាសាទឈ្មោះ សិវបទៈ ( តិ វបទៈ - « លំ-នៅឋានរបស់ព្រះសិវៈ » ) ;

**pattana / pattaṇa** បត្តនៈ មានន័យថា ទីក្រុង ។ ឧទាហរណ៍ :

**sruk vīrendrapattana** K. 713 : ស្រុកឈ្មោះ វីរេន្ទ្របត្តនៈ ( វីរេន្ទ្របត្តនៈ - « ក្រុងរបស់ទេវៈឈ្មោះ វីរេន្ទ្រៈ » ) ;

**ai çivapattana** K.163 : នៅឯទីក្រុង សិវបត្តនៈ (តិ វបត្តនៈ « ក្រុងរបស់ព្រះតិ វៈ » ) ;

**alaya** អលយៈ មានន័យថា ទីជំរក ឬលំនៅឋាន ។ ឧទាហរណ៍ :

**sruk maheçvarālaya** K. 467 : ស្រុកឈ្មោះមហេស្វរាលយះ ( មហេឝ្វ រាលយះ - « លំនៅឋានរបស់ទេវៈ ឈ្មោះ មហេស្វរះ » ) ;

**sruk bhadrālaya** K. 262 : ស្រុកឈ្មោះភទ្រាលយះ ( ភទ្រាលយះ « ជំរកប្រកបដោយសោភណភាពល្អត្រកាល » ) ;

**sruk vishvālaya** K 91 : ស្រុកឈ្មោះ វិសះវាលយះ (វិឞ :វាលយះ « លំនៅឋានរបស់ទេវៈ វិឞះ » ) ;

**nivãsa** និវាសះ មានន័យថា " លំនៅឋាន ឬជំរក " ។ ឧទាហរណ៍ :

**sruk vrddhanivãsa** : ស្រុកឈ្មោះវ្ទទ្ធនិវាសះ ( វ្ទទ្ធនិវាសះ - « លំនៅរបស់ព្រះសង្ឃ ដែលមានឋានះជាភាសាបារាំងថា : **venerable** » ) ;

**sruk arinivãsa** : ស្រុកឈ្មោះ អរិនិវាសះ ( អរិនិវាសះ -« ជំរករបស់សត្រូវ » ) ;

**kamraten jagat çri bhadreçvarannivãsa** K. 91 : ប្រាសាទឈ្មោះឝ្រី ភទ្រេឝ្វ រន្និវាសះ ( = «លំនៅឋានរបស់អាទិទេពឝ្រី ភទ្រេឝ្វ រះ» ) ;

**kṣetra** ក្សេត្រះ មានន័យថា ទីលានចំការ ។ ឧទាហរណ៍ :

**sruk jayakṣetra** K. 832 : ស្រុកឈ្មោះជយក្សេត្រះ (= « ទីលានប្រកបដោយជ័យជំនះ » ) ;

**surk jitakṣetra** K. 913 : ស្រុកឈ្មោះជិតក្សេត្រះ (= « ទីលានដែលគេច្បាំងយកបាន » ) ;

**deça** ទេសះ ( ទេឝ ) មានន័យថា " ប្រទេស ឬតំបន់ " ។ ឧទា.

**sruk muladeça** K. 187 : ស្រុកឈ្មោះ មុលទេឝះ (= « តំបន់ដ៏សំខាន់ » ) ;

**madhyamadeça** K 873 : « តំបន់កណ្ដាល » ;

**camnat madhyamadeça** K 873 : ភូមិឈ្មោះមធ្យមទេតះ ។

ចំណែកឯពាក្យ កម្វុជទេតះ **kamvujadeça** ជាឋាននាមមួយដែរ នៅក្នុងសិលាចារឹកជាភាសាខ្មែរ ។ ឈ្មោះនេះ ជាឈ្មោះប្រទេសកម្ពុជាពីបុរាណក្នុងសម័យអង្គរ ដែលបានចារនៅលើសិលាចារឹកវត្តសំរោង ( samroṅ ) K 956 (នៅក្នុងស្រុកបាភ្នំ) និងនៅក្នុងសិលាចារឹកស្តុកកក់ធំ stuk kak thom K 935 (ក្នុងខេត្តប្រាជីនបុរិ ប្រទេសថៃ) ។ ក៏ប៉ុន្តែ ក្នុងគ្រប់សិលាចារឹកជាភាសាសំស្ក្រឹតនៅសម័យមុនអង្គរ និងសម័យអង្គរ ប្រទេសកម្ពុជាបុរាណ មានឈ្មោះថា កម្វុទេតះ kamvudeça និងកម្វុជះ kamvuja ។ ពាក្យ « កម្វុជះ » ត្រូវបានគេប្រើប្រហែល ៤០ ដង ក្នុងសិលាចារឹកសំស្ក្រឹត ។ ចំណែកពាក្យ « កម្វុទេតះ » គេប្រើម្តងក្នុងសិលាចារឹកនៅកូរ៉ាត់ K 400 ( ប្រទេសថៃ ) ដែលមានចុះកាលបរិច្ឆេទ ឆ្នាំ ៨៦៨ និងលើកក្រោយបំផុត ក្នុងសិលាចារឹកអង្គរវត្ត (ខេត្ត សៀមរាប) K 300 នៅសតវត្សទី ១៤ ។

គេអាចសន្និដ្ឋានបានថា ឈ្មោះទាំងបីរបស់ប្រទេសកម្ពុជា នាបុរាណកាល គឺកម្វុជះ កម្វុទេតះ និងកម្វុជទេតះ មានប្រភពពីភាសាសំស្ក្រឹត ហើយមានលក្ខណៈពិសេសមួយ គឺវត្តមាននៃពាក្យ « កម្វុ » ( kamvu ) ។ តាមវចនានុក្រមសំស្ក្រឹតខ្មែរ ទំនាក់ទំនងសំនួរ រវាងព្យញ្ជនៈ « វ » (v) និង« ព » (b) មានញឹកញាប់ណាស់ ហើយវាមានន័យថា « គេតនភ័ណ្ឌ » របស់ព្រះវិស្ណុ ។ តាមសិលាចារឹកកម្ពុជាជាភាសាសំស្ក្រឹត ពាក្យ កម្វុ - កម្ពុ ត្រូវបានទទួលស្គាល់ជានរនាម ហើយតាមរយៈសិលាចារឹកបក្សីចាំក្រុង ( ខេត្តសៀមរាប ) K 286 នៅឆ្នាំ ៩៤៧ ដែលលោក G. Cœdès ចាត់ទុកថាជាព្រះនាមរបស់មហាឫសីមួយអង្គ ដែលជាស្ថាបនិករាជាណាចក្រខ្មែរដំបូងគេ ។ មហាឫសីអង្គនេះ បានរៀបអភិសេកជាមួយនឹងម្ចាស់ក្សត្រីខ្មែរមួយព្រះអង្គ ព្រះនាម មេរ៉ា ( Merā ) ហើយព្រះអង្គបានផ្តល់កំណើត

មេរ៉ាដល់រាជវង្សានុវង្សក្សត្រខ្មែរ គឺរាជវង្ស « សុរិយៈ » ឬសុរិយវង្ស ។

G. Cœdès បានចាត់ទុកថាឈ្មោះជនជាតិខ្មែរ អាចកើតចេញពីអក្សរកាត់នៃពាក្យសំគាល់គូភរិយា (kamvu និង merā) ហើយលោកបានបញ្ជាក់ពីបញ្ហានេះជាលើទីមួយក្នុងសិលាចារឹក K227 ។ លើសពីនេះទៀត ពាក្យ «កម្ពុ»ក៏ត្រូវបានគេប្រើក្នុងការបង្កើតឋាននាម និងទេវនាមសំខាន់ៗ ដែរ ដែលមានជាអាទិ៍ដូចជាៈ

**kamvujarājalakṣmi** កម្ពុជរាជលក្ស្មី K.272 ៖ ជាព្រះរាជនាមរបស់ព្រះមហាក្សត្រីខ្មែរមួយព្រះអង្គ ដែលជាមហេសីរបស់ព្រះបាទភវវរ្ម័នទី១ ។

**kamvupurī** កម្ពុបុរិ K 283 ( = « ក្រុងរបស់មហាឫសីកម្ពុ » ) ជាឈ្មោះរាជធានីអង្គរបុរាណ ។

**hari kamvujendra** ហរិ កម្ពុជេន្ទ្រៈ K.549 ៖ ជាឈ្មោះរបស់អាទិទេពមួយអង្គ ។ ពាក្យ « **kamvujendra** » ត្រូវបានបង្កើតឡើងដោយការផ្សំពាក្យ « **kamvu** និង **indra** » ។ ពាក្យនេះ គឺជានាមឈ្មោះរបស់អាទិទេពដែលការពារកម្ពុជទេស ។ រូបបដិមាឈររំណាងអាទិទេពអង្គនេះ មាននៅភ្នំដា ក្នុងខេត្តតាកែវ ។ « ហរិហរៈ» ជានាមឈ្មោះអាទិទេពមួយអង្គ គឺព្រះវិស្ណុ ។

តាមការកត់ត្រា នាមឈ្មោះរបស់មហាឫសីកម្ពុ ក្លាយជាឯកតានៃអសាធារណនាមមួយ ហើយឈ្មោះទាំងបីនៃប្រទេសខ្មែរបុរាណ អាចកំណត់អត្ថន័យដូចតទៅ ៖

កម្ពុទេសៈ **Kamvudeça** គឺជាប្រទេសមួយដែលបង្កើតឡើងដោយមហាឫសី « កម្ពុ » ឬ ជាប្រទេសកម្ពុទេសៈ ។

កម្ពុជៈ **Kamvuja** គឺជាតំណវង្សនៃមហាឫសី « កម្ពុ » ឬ ជាប្រទេសកម្ពុជ ។

កម្ពុទេសៈ **kamvudeça** គឺជាប្រទេសតំណវង្សមហាឫសី « កម្ពុ »

ឬក៏ជាប្រទេសកម្ពុជទេសៈ ។

ក្រោមឥទ្ធិពលនៃព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ នាមឈ្មោះកម្ពុជទេសៈ ហាក់ដូចជាមានខ្លឹមសារនយោបាយសំខាន់ណាស់ ។ សិលាចារឹកស្តុកកក់ធំ និងសិលាចារឹកវត្តសំរោង ដែលត្រូវបានចាត់ទុកជាអត្ថបទអំពីវង្សាវតារក្សត្រខ្មែរសម័យអង្គរ បានប្រើពាក្យកម្ពុទេសៈ ជាពាក្យផ្លូវការសំរាប់សំគាល់ចក្រភពអង្គរ នៅក្នុងពិធីទេវ.រាជ ដើម្បីអភិសេកព្រះបាទជ័យវរ្ម័នទី II ( ៨០២ - ៨៥០ ) ជាស្តេចចក្រភព ( ចក្រវាទិន ) ។ ពិធីនេះបានប្រព្រឹត្តទៅនៅ Ṛdval ( ជាភ្នំបច្ចុប្បន្ន ) និងនៅភ្នំមហេន្ទ្រ.បរ័ត ( ភ្នំគូលែន ) ។ នៅសតវត្សទី ១៤ គឺនៅចុងសម័យចក្រភពអង្គរ ក្នុងសិលាចារឹកវត្តខ្វាន់ ( កំពង់ធំ ) K. 177 នាមឈ្មោះកម្ពុជទេសៈ ត្រូវបានជំនួសដោយពាក្យ « កម្ពុជរាស្ត្រ » ដែលមានន័យថា « រាជាណាចក្រកម្ពុជ » ។

គិរិ / បវ៌្វត **giri / parvvata** មានន័យថា « ភ្នំ, កូនភ្នំ » ។ ឧទាហរណ៍

**sruk bhadragiri** ( = « ភ្នំដ៏ល្អ » K. 235 D : ជាឈ្មោះស្រុកមួយគឺស្រុកភទ្រគិរិ ។

**candanagiri** K 235 D : « ភ្នំឈ្មោះចន្ទនគិរិ », ( ចន្ទនគិរិ = « ភ្នំឈើខ្លឹមចន្ទន៍ » ) ;

**malayaparvvata** K. 136 : ភ្នំឈ្មោះ មលយៈ ( មលយបវ៌្វតៈ « ភ្នំមលយៈ » ) ;

**kamrateṅ jagat dviradaparvvata** K 136 : ប្រាសាទឈ្មោះទ្វិរទបវ៌្វតៈ ( ទ្វិរទបវ៌្វតៈ - « ភ្នំដំរី » ) ;

**taṭāka** តដាកៈ មានន័យថា អាងទឹកដ៏ធំមួយដែលកើតឡើងដោយការជីក ។ ឧទាហរណ៍ :

**laksmindratatāka** K 702 : «អាងទឹកឈ្មោះ លក្ស្មិន្ទ្រតដាកៈ»

( លក្ស្មីន្ទ្រៈ - « ស្វាមីរបស់ព្រះនាងលក្ស្មី គឺព្រះវិស្ណុ » ) ;

**yaçodharatatāka** K. 70 : អាងទឹកដ៏ធំមួយឈ្មោះ « យេធេ ា-ធរតដាកៈ» ( យសោធរតដាកៈ ) ដែលជីកឡើងក្នុងរជ្ជកាលព្រះបាទយសោវរ្ម័នទី I មានបណ្ដោយ ៧ គ.ម ទទឹង ១.៨០០ ម ។

**ãçrama** អាគ្រ- មៈ មានន័យថា ព្រះវិហារ ឬអាស្រម ។ ឧទាហរណ៍ :

**sruk çri bhadreçvarãçrãma** K 852 : ស្រុកឈ្មោះ « ស្រិភទ្រេស្វរាស្រមៈ » ( = វិហាររបស់ទេវៈគ្រិ ភទ្រេឝ្វ រៈ ),

**sruk harãçrama** K. 175 N : ស្រុកឈ្មោះ « ហរាគ្រមៈ » ( = វិហាររបស់ទេវៈ ហរៈ ) ។

តាមឧទាហរណ៍ដែលបានបង្ហាញខាងលើ យើងឃើញថា ស្ទើរគ្រប់នាម-ស័ព្ទបញ្ជាក់ពីទីកន្លែង ( **pura; grãma; pada; pattna; alaya; nivãsa; kṣetra; giri; purvvata; ãçrama** ) បានត្រូវគេយកមកប្រើក្នុងការបង្កើតឋាននាមសំរាប់សំគាល់ទីកន្លែងដ៏ពិសិដ្ឋៗ ( ប្រាសាទនានា ) ទីលំនៅឋានធំ ឬតូច (ដែនដី, ខេត្ត, ស្រុក) ។ ជារឿយៗ នាមឈ្មោះប្រាសាទ និងនាមឈ្មោះស្រុក ត្រូវបានសំគាល់ដោយឋាននាមតែមួយ ។ ឧទាហរណ៍ : **kamraten jagat çri bhadreçvarãçrama** K.258 ជាឈ្មោះប្រាសាទ ហើយនៅក្នុងសិលាចារឹក K.852 ពាក្យដដែលនេះជាឈ្មោះស្រុក ។ **kamraten jagat jayaksetra** K.205 ជាឈ្មោះប្រាសាទ ហើយនៅក្នុងសិលាចារឹក K.832 ជាឈ្មោះស្រុក ។ ចំពោះបញ្ហានេះ យើងយល់ឃើញថា ឈ្មោះរបស់ប្រាសាទ អាចត្រូវបានប្រើជាបន្តបន្ទាប់ សំរាប់សំគាល់ឈ្មោះស្រុក ហើយបញ្ច្រាសមកវិញ ឈ្មោះស្រុកអាចប្រើសំគាល់ឈ្មោះប្រាសាទ ។

ម្យ៉ាងទៀត នៅដំបន់នៃទីតាំងវត្ថុឋាននាមខ្មែរ បើឋាននាមត្រូវបានប្រើ

សំគាល់វត្ថុពីរ វត្ថុមានទំហំតូច អាចស្ថិតនៅក្នុងវត្ថុដែលមានបរិមាត្រធំ ។

ក្នុងចំណោមឋាននាមសំស្ក្រឹត ដែលមាននៅក្នុងសិលាចារឹក មានឋាននាម ១៨០ ដែលត្រូវបានបង្កើតជាមួយពាក្យ « បុរ » ( **pura** ) ជាបច្ឆិមបទ ។ តាមចំនួននេះ ពាក្យ « បុរ » ( **pura** ) អាចចាត់ទុកថាជាធាតុសំខាន់មួយក្នុងការបង្កើតឋាននាមសំស្ក្រឹតនៅកម្ពុជទេស ។ គ្រប់រាជធានីជាបន្តបន្ទាប់របស់ប្រទេសកម្ពុជា នៅសម័យអង្គរ និងសម័យមុនអង្គរ សុទ្ធសឹងតែត្រូវផ្សំនឹងវត្តមាននៃពាក្យ « **pura** » ។ ឧទាហរណ៍ **vyādhapura** K. 276 ( ក្រុងនៃព្រានប្រមាញ់, ទីស្ថានដែលតាំងនៅក្រុងបាភ្នំ ), **bhavapura** K 939 ( ក្រុងនៃទេវៈភវៈ ជារាជធានីព្រះបាទភវវរ្ម័ន ដែលតាំងនៅត្រើយខាងកើត នៃបឹងទន្លេសាប ) **sambhupura** K. 293 ( ក្រុងទេវៈសម្ភុ ដែលតាំងនៅត្រើយទន្លេមេគង្គខាងលើ, ក្រុងក្រចេះ ) **içānapura** K 314 ( ក្រុងរបស់ទេវៈឥសានៈ ជារាជធានីរបស់ព្រះបាទ ឥសានវរ្ម័នតាំងនៅខាងជើង ( ក្រុងកំពង់ធំ ), **indrapura** K.235 ( ក្រុងរបស់ទេវៈឥន្ទ្រៈ ដែលតាំងនៅត្បូងឃ្មុំ ) **amarendrapura** K.235 អមរិន្ទ្របុរៈ ( ក្រុងអមតៈនៃទេវៈឥន្ទ្រៈ តាំងនៅក្បែរក្រុងសៀមរាប ) **yaçodha rapura** យសោធរបុរៈ K 70 ក្រុងស្អាត និងមានជ័យជំនះ, ជារាជធានីនៃកម្ពុជទេស ពីសតវត្សទី IX ដល់ទី XIV ឈ្មោះក្រុងអង្គរបុរាណ ) ។

ការខុសប្លែកគ្នាយ៉ាងច្រើនរវាងឋាននាមជាពាក្យខ្មែរ និងឋាននាមជាពាក្យសំស្ក្រឹត គឺស្ថិតនៅត្រង់ឋាននាមជាពាក្យខ្មែរ ត្រូវបានបង្កើតឡើងតាមការបង្ហាញឯង១ និងតាមការប្រើប្រាស់វាក្យស័ព្ទរុក្ខវិទ្យា និងសត្តវិទ្យា ។ ចំណែកឯឋាននាមជាពាក្យសំស្ក្រឹតវិញ ត្រូវបានបង្កើតឡើងតាមបំរាស់ទេវនាមរបស់ពួកទេវៈ, ព្រាហ្មណ៍និងពាក្យសិរីតសំរាំងចេញពីនាមស័ព្ទ និងគុណស័ព្ទ ដែលប្រើប្រាស់ក្នុងការសុំពរជ័យ និងការបួងសួង ។ ដោយយកទេវនាម ជាលក្ខណៈវិនិច្ឆ័យក្នុងចំណាត់

ថ្នាក់យើងអាចចាត់ថ្នាក់ឋាននាមសំស្ក្រឹតតាមរបៀប ដូចតទៅ :

- ឋាននាមបំរើឱ្យទេវនាម សិវៈ ( **çiva** ) និងអ្វីៗ ដែលទាក់ទងដល់ទេវៈអង្គនេះ ។ ឧទាហរណ៍ :

**k.j. çivalinga** K 697 : លិង្គរបស់ព្រះឝិវ, ជានិមិត្តរូបនៃការគោរពទេវរាជា ជាពាក្យបញ្ជាក់ពីអំណាចស្តេចចក្រភព (ស្តេចចក្រវាតិន cakravartin ) ដែលជាតំណាងទេវៈ ឝិ វ លើផែនដី ។

ប្រាសាទ ឝិ វលិង្គ : ជាឈ្មោះប្រាសាទដែលទាក់ទងទៅទេវនាម ឝិ វ នេះដែរ ។

ប្រាសាទ ឝិ វបាទ K 344 ( **çivapāda** ) : ជាឈ្មោះប្រាសាទមួយទៀត ដែលទាក់ទងទៅនឹងទេវនាម ឝិ វ ដែរ ។ ឝិវបាទ មានន័យថាព្រះបាទរបស់ព្រះឝិ វ ។

**k.j. çivapura** K .195 ( បុរីរបស់ព្រះឝិ វ ) គឺជាឈ្មោះប្រាសាទ ឝិ វបុរៈ ( **çivapura** ) ។

**sr. çivagartbha** K. 809 ( កំណើតព្រះឝិវ ) គឺជាឈ្មោះស្រុកឝិវគរភៈ ( çivagarbha ) ។

**sr. çivagupta** K. 212 ( ការគាំទ្ររបស់ព្រះឝិវ ) គឺជាឈ្មោះស្រុកសិវគុប្តៈ ( ឝិ វគុប្ត ) ( **çivagupta** ) ។

- ឋាននាម បង្ហាញដោយទេវនាមព្រះវិស្ណុ ( **vishnu** ) មានដូចជា :

**sr. viṣnupura** K 67 ( បុរីរបស់ព្រះវិស្ណុ ) ជាឈ្មោះស្រុកមួយ គឺស្រុក វិស្ណុបុរៈ ( **visnupura** ) ។

viṣnugrāma វិស្ណុគ្រាម K 521 ( ដែនដីរបស់ព្រះវិស្ណុ ) ។

ឋាននាមមួយចំនួនធំ បង្ហាញដោយទេវនាម សិវៈ និងវិស្ណុ ត្រូវបានបញ្ជាក់

យ៉ាងច្បាស់នៅក្នុងសិលាចារឹក ។ ព្រឹត្តិការណ៍នេះបានបញ្ជាក់ឱ្យដឹងថា សិវ ( គិ វ ) និយម និងវិស្ណុនិយម ជះឥទ្ធិពលយ៉ាងខ្លាំងក្នុងស្រទាប់ប្រជាជន ។ ម្យ៉ាងទៀត ដើម្បីជៀសវាងការខុសឆ្គងផ្នែកសទិសសូរក្នុងភាសា ដែលបង្កឡើងដោយឋាននាមដដែលៗ ដែលបានបង្កើតរួចមកហើយ រាជបណ្ឌិតបានសំអាងលើការឱ្យឈ្មោះផ្សេងៗ របស់គីវ និងនាមនានាទៀត នៃអវតាររបស់ព្រះវិស្ណុ សំរាប់បង្កើតឋាននាមថ្មីៗ ទៀត ។ តាមរយៈសៀវភៅ Kamaleswar Bhattacharya ក្រោមចំណងជើង « ព្រាហ្មណ៍សាសនា នៅកម្ពុជាបុរាណ » ( Paris, 1961 ) បានឱ្យដឹងថា នៅក្នុង នាមឈ្មោះរបស់ព្រះសិវៈជាង ៣០ មាននាមមួយចំនួន បានយកមកប្រើសំរាប់ សំគាល់ឋាននាម ។ ឧទាហរណ៍ ៖

**rudra** ៖ ស្រុក រុទ្រៈ ក្នុងស្រុក រុទ្រៈ K 467

**içãna** ៖ នៅរាជធានីឥសានបុរៈ K 314

**içvara** នៅ ( ប្រាសាទ ) ឥស្វបុរៈ K 91

**hara** នៅ ( ស្រុក ) ហរាគ្រ មៈ K 175

**virendra** នៅ ( ស្រុក ) វិរេន្ទ្របុរៈ K 467

**çarvva** ៖ នៅ ( ប្រាសាទ ) សវ្វ៌ / គ វ្វ៌ស្រមៈ K ៤៤

**bhava** នៅ ( រាជធានី ) ភវបុរៈ K 939

**çri bhadreçvara** ស្រីភទ្រិគ្វ រៈ នៅ (ស្រុក) គ្រិ ភទ្រេគ្វ រាគ្រ ម K. ៨៥២

**amogha** នៅ ( ដែនដី ) អមោឃបុរៈ K 221

**svayambhu** ស្វយម្ភុ ៖ នៅ ( ស្រុក ) ស្វយម្ភុបុរៈ K 580

តាមរយៈឋាននាមដែលបានវិភាគរួចមកហើយ ទេវនាម çiva ៖ គីវ និងនាមឈ្មោះដទៃទៀតរបស់អាទិទេពអង្គនេះ ត្រូវបានប្រើក្នុងប្រភេទនានា នៃ

ឋាននាមក្នុងប្រទេស ដែលសុទ្ធតែសន្ធវាក្យស័ព្ទសរិតសំរាំងតាំងពីពាក្យបោរាណក្នុងភាសាសំស្ក្រឹត ។ ឧទាហរណ៍ :

**çiva** ឝិវ « ទន្សើល្អ, បរមសុខ » **bhava** ភវះ « វឌ្ឍនភាព ; សម្បូររុងរឿង » , **amogha** អមោឃះ « ដុះដាល » **bhadra** ភទ្រះ « សោភ័ណ » **hara** ហរះ « បំផ្លាញ ( អ្វីដែលអាក្រក់ ) » ។ ឋាននាមទាំងនេះត្រូវ បានចាត់ទុកថា ជាពាក្យមានន័យជានិមិត្តរូប ។

តាមរយៈសិលាចារឹកទាំងឡាយ នាមខ្លះរបស់អវតារនៃព្រះវិស្ណុ បានចាត់ទុកជាធាតុនៃឋាននាម ដូចតទៅ :

**kṛsnaguha** K.133 «ល្អាងក្ឫស្ន» K.J. Narāyana K260 S « ប្រាសាទ នរាយនៈ », **sr. vikramapura** ស្រុកវិក្រមបុរះ K.467 « រាជធានីវិក្រមះ » ជាឈ្មោះស្រុក វិក្រមបុរះ ;

**rāmakṣetra** រាមក្សេត្រ : K 257 « ចំការរបស់ព្រះរាមា, ជាឈ្មោះតំបន់មួយ » ។

ឈ្មោះមួយ ក្នុងចំណោមរាជធានីនៃកម្ពុជទេស ( **kambujadeça** ) បានត្រូវគេសំគាល់ឃើញតាមការបង្កើតសន្ធវាក្យស័ព្ទ : ហរិហរាលយះ K 293 ដែលមានន័យថា : គឺជាលំនៅឋាននៃព្រះហរិ ( ព្រះវិស្ណុ ) និងព្រះហរះ ( ឝិវ ) ។ ឋាននាមនេះ អាចឱ្យបកស្រាយថាជាពាក្យតឹកតាង ដែលឆ្លុះបញ្ចាំងពីការលាយចូលគ្នានៃសាសនាវិស្ណុនិយម និងឝិវនិយម ដែលកើតមានឡើងនៅដើមសម័យអង្គរ ។

អាស្រ័យដោយការបន្សុីសាសនានេះហើយ បានជាព្រះបាទជ័យវរ្ម័នទី II អាចដឹកនាំនយោបាយសម្របសម្រួល និងសន្តិភាពកម្ម រវាងក្សត្របុរីខ្មែរដែលបានបែកខ្ញែកគ្នា ជាពិសេស ការបង្រួបបង្រួមចេនឡាទឹកលិច និងចេនឡាដីគោក ។ តាមការសិក្សាឋាននាម យើងសង្កេតឃើញថា ការគោរពបូជាទេវៈ brahma

(ព្រហ្ម) ដែលជាទេវៈសំខាន់មួយដែរ នៅក្នុងសាសនាព្រាហ្មណ៍ ដូចជា មិនសូវមាន ប្រជាប្រិយភាពដូចទេវៈតី វ និងព្រះវិស្ណុទេ ។ ក្នុងនោះ ឋាននាមដែលទាក់ទងនឹងទេវ នាម " ព្រហ្ម " (**brahma**) ដែលគេប្រទះឃើញនៅក្នុងសិលាចារឹកខ្លះដែរ ដូចជាៈ

**sruk vrahmapura** K.235 ស្រុកវ្រហ្មបុរៈ, ( **vrahmapura** រាជធានីរបស់ព្រះព្រហ្ម ) ។

**sruk vrahmagarbha :** ស្រុកព្រហ្មគរភៈ K.352 : ស្រុកវ្រហ្មគភិ, ស្រែវ្រហ្មគភិ, ( **vrahmagarbha** កំណើតព្រះព្រហ្ម ) ។

**vrahmapada** វ្រហ្មបទ K. 235 ឈ្មោះដំបន់មួយ **vrahma pada** លំនៅឋានរបស់ព្រះព្រហ្ម ។

ក្រៅពីនាមឈ្មោះសំខាន់ៗរបស់ទេវៈ ក្នុងទ្រឹស្តីទេវៈទាំងបី ក្នុងព្រហ្មញ្ញ-សាសនា នាមឈ្មោះរបស់ទេវៈបន្ទាប់បន្សំនៃសាសនានេះ ក៏ត្រូវបានគេចាត់ទុកជាធាតុសំខាន់ក្នុងការបង្កើតឋាននាមសំស្ក្រឹតដែរ ។ ឧទាហរណ៍ :

**nagara indrapura :** នគរឥន្ទ្របុរៈ K 235 ឈ្មោះរាជធានីមួយនៃកម្ពុជទេស ( **Kambujadeça** ) ; **indra** ឥន្ទ្រៈ ជាទេវៈខាងព្យុះ ។

**sruk indraparass :** ស្រុកឥន្ទ្រៈបរស្ស K. 292 ឈ្មោះស្រុកមួយដែលមានន័យថា ជាលំនៅរបស់ព្រះឥន្ទ្រ ។

**sruk somalaya** K. 918 ស្រុកសោមលយៈ **soma** គោរម្យ-ងាររបស់ទេវៈព្រះច័ន្ទ ។

**candrapura** K. 117 : (ទីតាំង) ចន្ទ្របុរៈ, **candra** ទេវព្រះច័ន្ទ ។

**k. j. çri suryyaparvvata** K 31 : ប្រាសាទត្រី សុរយ្យបវ៌ត, **suryya** " ទេវៈព្រះអាទិត្យ " ។

**sruk kāmadhenu** K.467 : ស្រុកកាមធេនុ, **kāma** " ទេវៈកាម, "

**dhenu** មេគោដ៏ពិសិដ្ឋ ។

**sruk anaṅgapura** K 292 ៖ ស្រុកអនង្គបុរៈ, **Anaṅga** គោរម្យងារនៃទេវកាមៈ ។

**sruk varuna** K 262 S ៖ ស្រុក វរុណៈ ; **varuṇa** ទេវៈពិរុណ ឬភ្លៀង ។

**sruk vagindra** K 380 E ៖ ស្រុកវគិន្ទ្រ, **vagindra** ទេវៈវាគ្មិន ។

ក្នុងភាសាខ្មែរ សន្ធវាក្យស័ព្ទ ចន្ទ្រៈ ( **candra** ) សុរ្យយៈ ( **suryya**) កាមៈ ( **kāma** ) ត្រូវបានគេស្គាល់យូរណាស់មកហើយថា ជានាមស័ព្ទធម្មតា ដែលមានន័យថា ព្រះច័ន្ទ ព្រះអាទិត្យ និងកាមិន្ទ្រីយ៍ ។

នៅយុគសម័យកម្ពុជទេស ពុទ្ធសាសនាត្រូវបានគេគោរពទទឹមគ្នានឹងព្រហ្មញ្ញសាសនា ក៏ប៉ុន្តែ នាមឈ្មោះដែលបង្កើតជាមួយក្រុមពុទ្ធនាម និងពោធិសត្វនាម គ្មាននៅក្នុងសិលាចារឹកទេ ។ ហេតុនេះ ក្នុងព្រះពុទ្ធសាសនា ព្រះពុទ្ធ និងព្រះពោធិសត្វ ពុំត្រូវបានចាត់ទុកជាទេវៈទេ ។ ដូច្នេះ ក្នុងការបង្កើតឋាននាមសំស្រ្កឹតសំគាល់ទីតាំងរស់នៅតាមសន្ធវាក្យស័ព្ទ គឺជាពាក្យមានប្រភពចេញមកពីទេវកថាព្រោះខ្មែរបុរាណ ត្រូវការពាក្យទាំងនោះយកមកការពារប្រឆាំងនឹងសត្រូវខាងក្រៅ និងគ្រោះធម្មជាតិ ព្រមទាំងជំងឺឆ្លងគ្រប់បែបយ៉ាង ។ ក្នុងន័យនេះហើយបានជា ក្រៅពីសន្ធវាក្យស័ព្ទសំស្រ្កឹតដ៏ល្អវិចិត្រ ដូចជាវាក្យស័ព្ទដែលប្រើប្រាស់ក្នុងការប្រសិទ្ធិពរការបួងសួង ក្នុងបែបបទនៃពិធីបួងសួង ត្រូវបានចាត់ទុកជាធាតុដែលត្រូវបានគេប្រើក្នុងការបង្កើតឋាននាម ។ ឋាននាមទាំងនោះ សម្បូរដោយពាក្យសំណូមពរ ដូចតទៅ ៖

- ឋាននាមសំគាល់ដោយពាក្យសុំពរ ដោយបានបង្ហាញពីបំណងប្រាថ្នាសុភមង្គល និងសុខភាពល្អ ។ ឧទាហរណ៍ ៖

**sruk sukhalaya** K.393 : ស្រុក សុខលយៈ, ( **sukha** - " សុខ " "សុខភាព" ។

**sruk maṅgalpura** K. 205 : ស្រុកមង្គលបុរៈ, **maṅgal** " មង្គល " ។

- ឋាននាមសំគាល់ដោយពាក្យសំណូមពរ ដោយបានបង្ហាញពីបំណង ប្រាថ្នាចង់បានសន្តិភាព និងសន្តិសុខរស់នៅបានវែងឆ្ងាយ ( អាយុវែង ) ។ ឧទាហរណ៍

**pram praçāntagrāma** K.187 : ដែនដីប្រសាន្តគ្រាមៈ **pra-çān ta** " សន្តិភាព " ។

**sruk amaralaya** អមរលយៈ K. 598 : ស្រុក **amaralaya** ; **amara** - " អមតៈ" ។

**abhayapura** អភយបុរៈ K.357 : ប្រាសាទ **abhaya pura**; **abhaya**" និរភ័យ" ។

- ឋាននាមសំគាល់ដោយពាក្យសំណូមពរ ដោយបានបង្ហាញពីបំណង ប្រាថ្នាចង់បានវឌ្ឍនភាព ភាពសម្បូរសប្បាយ ។ ឧទាហរណ៍ :

**sruk bhogapura** ភោគបុរៈ K. 843 : ស្រុក **bhogapura**; **bhoga**" ភោគ" ។

**sruk dhanavaha** ស្រុកធនវហៈ K 467 : ស្រុក **dhanaveaha dhana**"' ធនធាន " veha" រថ " ។

**srukphalapriya** : ស្រុក ផលប្រិយៈ; **phala** " ផល ; ការប្រមូលផល ", **priya** " ប្រិយ " ;

**srukvassantapura** K221 : ស្រុកវស្សន្តបុរៈ **vassanta** វស្សន្ត

**sruk bhrttipura** K. 292 : ស្រុក bhrttipura; **bhrtti**

" អ្នកចិញ្ចឹម" ។

- ឋាននាមសំគាល់ដោយពាក្យសំណូមពរ ដោយបង្ហាញពីបំណងប្រាថ្នាចង់បានជ័យជំនះ ជោគជ័យ ។ ឧទាហរណ៍ :

**sruk lambhapura** K.292 : ស្រុក **lambhapura** ; **lambha** " ជោគជ័យ " ។

**sruk siddhipura** K. 702 : ស្រុកសិទ្ធិបុរៈ, **siddhi** " ជោគជ័យ " ។

**sruk vijayapura** ស្រុកវិជ័យបុរៈ, **vijaya** " វិជ័យ " ។

**sruk vikranta** K. 697 : ស្រុកវិក្រន្ត, **vikranta** " អ្នកដើរ, " ជ័យជំនះ" ។

- ឋាននាមសំគាល់ដោយពាក្យសំណូមពរ ដោយបង្ហាញពីបំណងប្រាថ្នាចង់បាននូវសោភណភាព, ភាពក្សេមក្សាន្ត ។ ឧទាហរណ៍ :

**sruk raṅgapura** K. 476 ស្រុករង្គបុរៈ, **raṅga** " រង្គ, វិចិត្រ " ។

**bhadrapura** K. 56 ប្រាសាទភទ្របុរៈ, **bhadra** " សោភ័ណ " ។

**sruk jyotigrāma** K. 219 ស្រុកជ្យោតិគ្រាម, **jyoti** " ពន្លឺ " ។

**çreṣṭhanivāsa** K 467 : ភូមិស្រេស្ឋនិវាសៈ, **çrestha** " សោភ័ណ " ។

- ឋាននាមសំគាល់ដោយពាក្យសំណូមពរ ដោយបង្ហាញពីបំណងប្រាថ្នាចង់បាននូវសុភមង្គល និងមានជីវភាពប្រកបដោយសីលធម៌ល្អ ឬមានបញ្ញា បរិបូណ៌ ។ ឧទាហរណ៍ :

**sruk moksalaya** K. 58 : ស្រុកមោក្សល័យ **moksa** «មោក្ស» ( អរិដ្ឋា ) ។

**sruk dharmapura** K 697 : ស្រុកធម្មបុរៈ, dharma- "ធម៌, " សីលធម៌សាសនា" ។

**sruk vidyāvāsa** K.617 : ស្រុកវិទ្យាវាសៈ, **vidya**" វិទ្យា, ពុទ្ធិ," **avāsa**" លំនៅ " ។

**vidyāçrama** K 262 : ប្រាសាទវិទ្យាស្រមៈ

**sruk kaivalyapura** K.868 : ស្រុក កៃវល្យបុរៈ, **kaivalya-** " ការសរសើរ, ជានិរន្តរ៍ " ។

តាមរយៈឋាននាមដែលបានវិភាគរួចមកហើយនេះ យើងអាចកត់សំគាល់បានថា ឋាននាមខ្លះត្រូវបានបង្កើតឡើងតាមសន្ធវាក្យស័ព្ទ និងពាក្យសុំពរជ័យ ដែលជានាមសំគាល់ទីកន្លែងរស់នៅ ហើយត្រូវភ្ជាប់ដោយពាក្យ « ស្រុក » ដែលជាពាក្យបញ្ជាក់ពីទីប្រជុំជនរដ្ឋបាល ដែលសំគាល់ថា ជាស្រុកដែលអ្នកនិយាយភាសានេះស្គាល់ច្បាស់ ។ ការភ្ជាប់ពាក្យនេះ នៅមុខឋាននាមសំស្ក្រឹតបង្កើតបានជាពាក្យសមាសមួយ ដោយផ្គុំពាក្យខ្មែរជាមួយពាក្យសំស្ក្រឹត ។ លំនាំនេះ អាចចាត់ទុកថាជារបៀបមួយក្នុងចំណោមរបៀបល្អៗបំផុត ក្នុងការយកលំនាំតាមពាក្យសំស្ក្រឹតក្នុងការបង្កើតឋាននាមខ្មែរ ។ ចំនួនឈ្មោះស្រុកប្រហែល ១១០ ដែលសំគាល់ដោយពាក្យសំស្ក្រឹត ត្រូវបានបញ្ជាក់ក្នុងសិលាចារឹក ហើយមានតែពាក្យមួយចំនួនទេ ដែលត្រូវបានបញ្ជាក់នៅក្នុងការសិក្សានេះ ។

ជាមួយឋាននាមសំស្ក្រឹត បង្កើតបានតែមួយផ្នែកនៃសទ្ទានុក្រមសំស្ក្រឹតដែលខ្មែរយើងពីបុរាណបានប្រើប្រាស់ ។ ក៏ប៉ុន្តែ ពាក្យទាំងនេះអាចបង្កើតទម្ងន់លើកម្មីភាសា និងឥទ្ធិពលនៃរចនាសម្ព័ន្ធសាសនារបស់បុព្វបុរសខ្មែរយើង ក្នុងលំនាំបង្កើតឋាននាមនៅកម្ពុជា ។

***

# ព្រះពុទ្ធសាសនា និង ការអប់រំសីលធម៌ខ្មែរ

ដោយព្រឹទ្ធាចារ្យ **ឆេង ផុន**

ដើម្បីអបអរសាទររំឭកខួបគម្រប់ ៧៥ ឆ្នាំ នៃពុទ្ធសាសនបណ្ឌិត្យ និងខួបគម្រប់ ៧០ ឆ្នាំ នៃកំណើតរបស់ទស្សនាវដ្ដី កម្ពុជសុរិយា, នៅក្នុងឆ្នាំ ១៩៩៦ នេះ ពុទ្ធសាសនបណ្ឌិត្យ នៃក្រសួងធម្មការ និងសាសនា បានរៀបចំកម្មវិធីសកម្មភាពជាពិសេសមួយ គឺការធ្វើសន្និសីទ - ការបង្ហាញស្នាដៃស្រាវជ្រាវ - ការប្រជុំ ពិភាក្សា អំពីប្រធានបទដែលទាក់ទងដល់ព្រះពុទ្ធសាសនា និងវប្បធម៌ អក្សរសាស្ត្រជាតិ ។ កម្មវិធីនេះ នឹងប្រព្រឹត្តទៅជារៀងរាល់ខែ ចាប់តាំងពីខែ កុម្ភៈ ឆ្នាំ ១៩៩៦ នេះតទៅ ។

កាលពីថ្ងៃ អង្គារ ទី ២៧ កុម្ភៈ កន្លងទៅនេះ នៅទីស្នាក់ការបណ្ដោះអាសន្ន នាវត្តឧណ្ណាលោម ពុទ្ធសាសានបណ្ឌិត្យ មានកិត្តិយសបានអញ្ជើញលោកព្រឹទ្ធាចារ្យ ឆេង ផុន មកធ្វើការបកស្រាយប្រធានបទមួយ ស្ដីពីពុទ្ធសាសនា និងការអប់រំសីលធម៌ខ្មែរ ដើម្បីជាកិច្ចចាប់ផ្ដើម នៃសកម្មភាពដ៏ពិសេសនេះ ។

ខាងក្រោមនេះ គឺជាសេចក្ដីដកស្រង់ប្រសាសន៍របស់លោកព្រឹទ្ធាចារ្យ ឆេង ផុន ដែលយើងបានកត់ត្រា ក្នុងឱកាសដែលលោកធ្វើការបកស្រាយអំពីពុទ្ធសាសានា និងការអប់រំសីលធម៌ខ្មែរ នៅចំពោះអង្គប្រជុំនៃព្រះសង្ឃ និងភ្ញៀវជាតិ អន្តរជាតិ ជាច្រើនរូប ដែលបានអញ្ជើញមកពីក្រសួង មន្ទីរ និងអង្គការអន្តរជាតិនានា នៅភ្នំពេញ ។

- សូមថ្វាយបង្គំ សម្ដេចព្រះមហាឃោសនន្ទ ជាទីសក្ការៈ,
- សូមថ្វាយបង្គំ ព្រះសង្ឃគ្រប់ព្រះអង្គ,
- សូមគោរព ជូនជី និងមិត្តទាំងអស់,

សព្វថ្ងៃនេះ ខ្ញុំជាសិស្សខាងវិបស្សនា ខ្ញុំបានបង្កើតមជ្ឈមណ្ឌលវិបស្សនាមួយ ។ ប៉ុន្តែ បទពិសោធន៍របស់ខ្ញុំនៅស្ទើរ ឯចំណេះចេះដឹងក៏មានកំរិត ។ ក្នុង

ឱកាសធ្វើការសន្ទនា អំពីការអប់រំតាមបែបពុទ្ធសាសនានេះ ខ្ញុំពុំបានកំណត់ក្នុងចិត្តខ្លួនឯងថា ការងារនេះបានច្បាស់លាស់ បានត្រឹមត្រូវនោះទេ ព្រោះស្ថិតនៅក្នុងការស្រាវជ្រាវនៅឡើយ ។ ខ្ញុំព្រះករុណា ខ្ញុំ សូមពឹងលើសម្ដេច ពឹងលើព្រះអង្គ ពឹងលើអ្នកចេះដឹងទាំងអស់ ដែលនៅសល់បន្តិចបន្តួច ជួយពិភាក្សារិះរកផ្លូវត្រូវ ។ កន្លងមកនេះ ខ្ញុំព្រះករុណា ធ្លាប់បានធ្វើការនៅផ្នែកសិល្បៈវប្បធម៌ អស់រយៈពេលជាង ៤០ ឆ្នាំ ខ្ញុំចេះតែមានការព្រួយបារម្ភច្រើន អំពីវប្បធម៌ជាតិ ហើយក៏បានគិតគូរយ៉ាងជ្រៅទៅក្នុងវប្បធម៌ជាតិ ។ លុះគិតពិចារណាទៅ ក៏បានឃើញមានតម្លៃមួយ ដែលជាតម្លៃខាងស្មារតី ឬក៏តម្លៃខាងផ្លូវចិត្តរបស់ខ្មែរ នោះគឺតម្លៃខាងសិល្បៈ ខាងសោភណភាព ខាងសម្រស់ ខាងគំនិតច្នៃប្រឌិត ។ តម្លៃម្យ៉ាង ដែលគេហៅថា តម្លៃខាងផ្លូវចិត្តនោះ គឺបានរកឃើញនៅក្នុងវិបស្សនា នៅក្នុងសមាធិ ។ ការពិត យើងចង់ដឹងតម្លៃខាងផ្លូវចិត្តនោះ វាធំប៉ុនណា វាមានប្រយោជន៍ប៉ុនណា ចំពោះជីវិតមនុស្ស ។ តួយ៉ាងដូចជានៅក្នុងប្រាសាទបាយ័ន ឃើញមានគំនិតគិតពីនាមច្រើន ។ នាមនោះវារូប ។ សិល្បករបង្កើតរូបឡើង ក៏យកនាមទៅដាក់ក្នុងរូបនោះទៅ ដើម្បីឱ្យគេមើលរូបទៅឃើញនាម ។ នេះជាឧបករណ៍មួយបង្ហាញថា ហេតុដូចម្ដេចបានជានៅសម័យអង្គរ ការអប់រំរបស់គេ គេគិតរហូតដល់កំរិតនេះ ? រួចបែរមកយើងសព្វថ្ងៃ ហេតុដូចម្ដេចបានជាបោះបង់ការអប់រំ នាមហើយនិងរូប រូបហើយនិងនាម តើមានរបៀបទាក់ទងគ្នាតាមបែបយ៉ាងណា ? តុល្យភាពរវាងកាយនិងចិត្ត ចិត្តនិងកាយ សម្ភារៈនិងស្មារតី ស្មារតីនិងសម្ភារៈ នោះតើយ៉ាងណា ? យើងសព្វថ្ងៃបាត់តុល្យភាពអស់ហើយ ។ សម័យឥឡូវនេះ ដោយការលូតលាស់ខាងសម្ភារៈវាខ្លាំងពេកទៅ ក៏លេចឡើងនូវការប្រដេញប្រណាំងទៅរកសមត្ថភាព ដោយការប្រដេញប្រណាំងទៅលើលោកិយ បញ្ហាវាខ្ពស់ពេកទៅ សេចក្ដីត្រូវការមានមិនចេះចប់ ទោះសម្ភារៈលូតលាស់យ៉ាងណា ក៏មិនអាចបំពេញសេចក្ដីត្រូវការបាន ។ យើងមិនអាច

បញ្ចប់បាន យើងមិនអាចគ្រប់គ្រាន់ទៅកើត ដូច្នេះ ទំនាស់ ជម្លោះវាក៏កើតឡើងដែរ ។ ដោយមើលឃើញយ៉ាងនេះ យើងចង់ជួយខ្មែរ ចង់ជួយប្រទេសជាតិយើង ចង់ជួយមនុស្សជាតិ ។ នឹងអាចធ្វើទៅបាន ទាល់តែទាំងអស់គ្នាដើរផ្លូវកណ្ដាល ។ មានជនជាតិអង់គ្លេសម្នាក់ ធ្លាប់បានធ្វើវិបស្សនាជាច្រើនឆ្នាំ ។ គាត់ធ្លាប់បានទៅធ្វើវិបស្សនានៅប្រទេសឥណ្ឌា ភូមា ស្រីលង្កា ។ គេបានជួបខ្ញុំព្រះករុណា នៅអាស្រម ។ គាត់មានប្រសាសន៍ថា ឥឡូវនេះ ផ្លូវមួយដែលគេនិយមហៅថា ផ្លូវអូខេនោះ គឺផ្លូវមជ្ឈិមបដិបទា ផ្លូវកណ្ដាល ដែលមនុស្សលោកទាំងអស់ព្រមទទួលយកបាន ពោលគឺ មិនល្អពេក មិនអាក្រក់ពេក ។ ពេលនេះ ខ្ញុំព្រះករុណា ចេះតែគិតមិនយល់ថា ហេតុដូចម្ដេចបានជាខ្មែរយើងចេះតែឆ្វេងពេក ស្ដាំពេក មានទស្សនៈហួសហេតុនិយម (extrémisme) ដូច្នេះ ។ តើគេយកទស្សនៈនេះពីណាមក ? ហេតុអ្វីបានជាផ្លូវកណ្ដាល ផ្លូវមជ្ឈិមបដិបទា ដែលជាផ្លូវព្រមទទួលបានទាំងអស់គ្នា ផ្លូវដែលដើរបានសុខទាំងអស់គ្នា បែរជាគេមិនព្រមដើរទៅវិញ ? ហេតុអ្វីបានជាមានតែផ្លូវតឹងហួស ផ្លូវធូរហួសអញ្ចឹង ? ខ្ញុំព្រះករុណា ចេះតែគិត ពិចារណា ... រួចហើយក៏គិតទៅដល់សម័យអង្គរ ដែលគេសាងប្រាសាទបាយ័ន មានកំពូល ៥៤ សុទ្ធតែមានមុខបួនទាំងអស់ ។ មនុស្សណាក៏មានមុខពីក្រោយដែរ ។ មនុស្សដែលមានមុខពីក្រោយ មានប្រាជ្ញាពីក្រោយនោះ ជាមនុស្សដែលគេចផុតពីទោសទាំងឡាយរបស់ជីវិត ។ ប្រហែលជាពីជំនាន់នោះ ដើរទៅណាមកណា មនុស្សសុទ្ធតែមានមុខបួនដូចៗគ្នាអញ្ចឹងហើយមើលទៅ ។ ខ្ញុំព្រះករុណា ចេះតែគិតយ៉ាងដូច្នេះ ព្រោះកំពូលកណ្ដាល តំណាងឱ្យអំណាចកណ្ដាល ។ កំពូលរាងកាយ ៥៤ ឯទៀត ជាអំណាចរាយរងទាំងអស់ ។ ទ្វារទាំងប្រាំ គឺទល់ដែនយើងទាំងប្រាំច្រក ។ សូម្បីតែនៅទល់ដែន បើគិតពីអំណាចកណ្ដាលរហូតដល់ទល់ដែន រហូតទៅដល់ចុងកាត់មាត់ញក ត្រូវតែមានព្រហ្មវិហារធម៌ទាំងអស់ ។ បើអញ្ចឹង ប្រហែលជាព្រះមហាក្សត្រក៏មានព្រហ្ម-

វិហារធម៌ វាស្ត្រក៏មានព្រហ្មវិហារធម៌ អ្នកមានក៏មានព្រហ្មវិហារធម៌ អ្នកក្រក៏មានព្រហ្មវិហារធម៌ អ្នកល្ងង់ក៏មានព្រហ្មវិហារធម៌ អ្នកចេះក៏មានព្រហ្មវិហារធម៌ ។ បើមនុស្សទាំងអស់ សុទ្ធតែមានព្រហ្មវិហារធម៌ នៅក្នុងសង្គមមួយទាំងមូល តើសង្គមនោះវាល្អប៉ុនណា ? ។ គេឃើញមុខគ្នា សុទ្ធតែញញឹមដោយព្រហ្មវិហារធម៌ទាំងអស់ មើលមុខគ្នាដោយព្រហ្មវិហារធម៌ទាំងអស់ ។ មើលមុខគ្នាឃើញតែករុណាទាំងអស់ មិនឃើញគំនុំ មិនឃើញជាសត្រូវ មិនឃើញជាខ្មាំង ដូច្នេះ នាំឱ្យគ្មានការភ័យព្រួយពីរឿងមនុស្សសម្លាប់មនុស្សទេ ។ ខ្ញុំព្រះករុណា ចេះតែគិតដល់សម័យរុងរឿង តើគេរុងរឿងអ្វីខ្លះ ? ។ សូមមេត្តាពិចារណា ដោយខ្ញុំព្រះករុណា ជាប់ចិត្តនឹងវប្បធម៌របស់ខ្លួន ក៏ខំរកនឹកថា តើនៅសម័យរុងរឿងគេខ្លាំងខាងអី ? គេរុងរឿងអី ? គេរុងរឿងខាងសម្ភារៈ ? គេរុងរឿងខាងស្មារតី ? គេរុងរឿងខាងផ្លូវចិត្ត ? ឬក៏គេរុងរឿងទាំងកាយ ទាំងចិត្ត ទាំងស្មារតី ? ។ ខ្ញុំព្រះករុណា ចេះតែគិតពិចារណា រិះរកពីការកើតឡើង ការវិវឌ្ឍន៍ រីកចំរើន ពីការធ្លាក់ទឹងស្រុតចុះ ដល់ក៏រិតមួយដែលលែងកែខៃបាន លែងគ្រប់គ្រងបាន ។ តើយើងត្រូវរិះរកវិធីណា មធ្យោបាយណា ដើម្បីកែប្រែគំនិតនោះមកវិញ ? ។ ខ្ញុំព្រះករុណា មិនតូកែខាងធម៌អាថ៌ ខាងសាសនា គម្ពីរបាលីនោះទេ ខ្ញុំព្រះករុណា ចេះតែគិតតាមរយៈវប្បធម៌ទេ ។ ខ្ញុំព្រះករុណា គិតត្រិះរិះស្រាវជ្រាវដឹងច្បាស់ អំពីក្រឹត្យក្រុមកើតឡើង អំពីហេតុនិងបច្ច័យដែលស្ថិតស្ថេរ ហេតុនិងបច្ច័យដែលស្រុតចុះ ។ ទាំងអស់នេះ សុទ្ធតែមានហេតុនិងបច្ច័យរបស់វា (Condition nécessaire et suffisante) លក្ខខ័ណ្ឌចាំបាច់ និងគ្រប់គ្រាន់សំរាប់លូត សំរាប់កើត សំរាប់រីក សំរាប់ស្ថិតស្ថេរ ។ បើខុសលក្ខខ័ណ្ឌ (Condition) វានឹងសាបសូន្យវិញ ។ មនុស្សម្នាក់ៗ បុគ្គលម្នាក់ៗ ក៏ដូចជាប្រទេសជាតិទាំងមូលដែរ ខាងផ្លូវចិត្ត មិនទាំងដឹងខ្លួនឯងថាកើតអ្វីទៅ ? រីកអ្វី មានអ្វី ចង់បានអ្វីនោះផង ។ នេះជាបញ្ហាមួយ ដែលខ្ញុំព្រះករុណា សរសេរក្នុងទស្សនាវដ្តី

អំពីទស្សនៈលើជីវិត មាន ១០ ។ ទស្សនៈលើជីវិត ១០ ឥទ្ធិពលទៅលើចិត្តនិងគំនិត មាន ១៥ ។ ទាំង ២៥ នេះ មានឥទ្ធិពលមកលើសិល្បៈគ្រប់ប្រភេទទាំងអស់ ។ សូម្បីតែល្ខោន ក៏មានដល់ទៅ ១៦ ទម្រង់ ។ ទាំងអស់នេះបង្ហាញថា សារៈវាកើតមុនកំណើតទាំងអស់ (l'essence précéde la naissance) ។ ខ្មែរពីដើមមានទម្លាប់មួយដែលសុំឱ្យព្រះអង្គមេត្តាជួយពិចារណា ។ កាលណាសារៈកើតមុន ទើបវាច្បាស់លាស់ គឺឧបមាដូចជានាឡិកា កើតមកសំរាប់មើលម៉ោង មិនមែនសំរាប់ដងទឹកផឹកទេ ។ មីក្រូកើតមកសំរាប់និយាយ ។ បើអញ្ចឹងសារៈរបស់មីក្រូ វាកើតមុនមីក្រូទៅហើយ សារៈនេះវាកើតមុននាឡិកាទៅហើយ គេមិនអាចយកនាឡិកាទៅដងទឹកផឹកបានទេ ។ រីឯប្រាសាទទាំង ១០៨០ សុទ្ធតែសារៈកើតមុនកំណើតទាំងអស់ ។ គ្មានរឿងផ្សងព្រេង គ្មានរឿងចៃដន្យ គ្មានរឿងនឹកស្មានៗ ធ្វើស្មានៗទេ ។ និយាយរួមគឺគ្មានស្មានទេ ។ ដល់មកឥឡូវ វាផ្សងព្រេងនិយម ចៃដន្យនិយមពេក ។ នឹកឃើញថា នឹកឃើញធ្វើ នឹកឃើញសំរេច ។ ខ្ញុំព្រះករុណា មើលឃើញថា ខុសកាន់តែជ្រៅទៅៗ ។ ប្រៀបធៀបទៅនឹងប្រាសាទ ទាំង ១០៨០ មិនឃើញមានប្រាសាទណាមួយខុសខ្នាត ខុសក្បួន នោះឡើយ ។ រហូតដល់ឥឡូវនេះ ទោះបីថា បច្ចេកទេសល្អលាស់ប៉ុនណា ធរណីមាត្ររីកចំរើនដល់ណាក៏ដោយ ក៏យកទៅគណនាឃើញថា អត់ខុសទាល់តែសោះ ។ សព្វថ្ងៃ ខ្ញុំព្រះករុណា យល់ឃើញថា ទាល់តែបង្រៀនខ្មែរឱ្យចេះទ្រឹស្ដី ហេតុ - ផល ឡើងវិញ នោះគឺហេតុផលតាមបែបព្រះពុទ្ធ (Causalité bouddhique) ហេតុផលបដិច្ចសមុប្បាទ (Causalité dialectique) ឱ្យខ្មែរដឹង សូម្បីតែការកើត និងការស្លាប់ ក៏ត្រូវឱ្យដឹងហេតុផលផងដែរ ។ ហើយយ៉ាងហោចណាស់ ឱ្យដឹងត្រឹមតែសារៈកើតមុនកំណើតប៉ុណ្ណឹងក៏បានដែរ ។ ដូច្នេះ យើងក៏មើលឃើញថា ទ្រឹស្ដីព្រះពុទ្ធសាសនាជួយយើងសន្ធឹកណាស់ ។ ទីពីរ ខ្ញុំព្រះករុណា យល់ថា ខ្មែរជាអ្នកឱ្យកំណើតទៅគេ មិនមែនជាអ្នកទៅយោនយកកំណើតពីគេ

ទេ ។ សូមព្រះអង្គ សូមអ្នកស្រាវជ្រាវទាំងអស់ មេត្តាពិចារណាមើល តើព្រះពុទ្ធសាសនាជាអ្នកឱ្យកំណើតគេ ឬក៏ទៅយោនយកកំណើតពីគេ ។ ចំណុចត្រង់នេះហើយ ដែលយើងត្រូវពិចារណាឡើងវិញ ។ ព្រះពុទ្ធសាសនាដឹកជីវិត ឬក៏ជីវិតដឹកព្រះពុទ្ធសាសនា ? ។ កាលពីថ្ងៃមុននោះ នៅអន្លង់វិល ខ្ញុំព្រះករុណា បានប្រើពាក្យមួយថា ព្រះធម៌ជាជីវិត ឬជីវិតជាព្រះធម៌ ។ មិនអាចព្រះធម៌នៅផ្សេង ជីវិតនៅផ្សេងបានទេ ។ ធ្វើយ៉ាងដូចម្ដេចឱ្យព្រះធម៌កើតនៅត្រឹមជីវិតប្រចាំថ្ងៃរបស់យើង ទើបព្រះធម៌មានប្រយោជន៍ ។ ចុះបើព្រះធម៌នៅដោយឡែកពីជីវិត ជីវិតនៅដោយឡែកពីព្រះធម៌ តើវានឹងទៅជាយ៉ាងណា ? វត្តនៅដោយឡែកពីសង្គម សង្គមនៅដោយឡែកពីវត្ត តើនឹងទៅជាយ៉ាងណា ? ថ្ងៃមុន ខ្ញុំព្រះករុណា ជំរាបសម្ដេចនាយកថា ខ្មែរយើងពីដើមមានសាលាស្រុកពីរ គឺសាលាស្រុកខាងលោកិយ មានប៉ូលិស មានគុក មានច្រវាក់ មានខ្នោះ មានឃ្នាង, និងសាលាស្រុកមួយទៀត គេហៅថា សាលាស្រុកខាងស្មារតី គ្មានគុក គ្មានច្រវាក់ គ្មានខ្នោះ គ្មានឃ្នាងទេ មានតែការអប់រំ ។ ឧទាហរណ៍ តាមប្រពៃណីពីបុរាណ បើមានចោរ នោះព្រះសង្ឃអញ្ជើញចោរទៅវត្តលោកគ្រូចៅអធិការ និយាយនឹងចោរថា « អាត្មាសុំបិណ្ឌបាតរឿងលួច រឿងប្លន់ កាប់សម្លាប់ ផឹកស៊ី អាវ៉ាសែ ចាប់ពីថ្ងៃនេះ សូមញ្ញើមឈប់ប្រព្រឹត្តទៀត » ។ បើចោរព្រមប្រគេនលោក នូវការប្រព្រឹត្តខុសឆ្គងខាងលើទាំងប៉ុន្មាននេះ ចោរនោះចេញពីវត្តមក ក្លាយជាមនុស្សត្រឹមត្រូវ ។

ចំណែកយើងឥឡូវនេះ យើងខ្វះចៅហ្វាយស្រុកបែបនេះ ។ ដូច្នេះរឿងយោនយកកំណើត រឿងឱ្យកំណើតទៅគេ សូមពិចារណាមើល តើសព្វថ្ងៃនេះយើងរៀបចំខ្លួនសម្រាប់ទៅណា ? និយាយអំពីការអប់រំ ដូចដែលមានចែងនៅក្នុងប្រធានបទនោះ យើងត្រូវពិភាក្សាគ្នាអំពីព្រះពុទ្ធសាសនាទាក់ទងទៅនឹងការអប់រំ ។ ចំណែកខ្ញុំព្រះករុណា ទាក់ទងទៅនឹងវប្បធម៌ ។ ពាក្យថា វប្បៈ វឌ្ឍនៈ កាយវប្បៈ កាយវឌ្ឍនៈ

ចិត្តវប្បៈ ចិត្តវឌ្ឍនៈ បញ្ញាវប្បៈ បញ្ញាវឌ្ឍនៈ ... វឌ្ឍនៈវាទាក់ទងទៅនឹងការអប់រំវប្បៈ គឺជាការល្អណាស់, វប្បៈ គឺជាការអប់រំ ។ ខ្ញុំគិតពិចារណាចង់ឱ្យប្រជាពលរដ្ឋខ្មែរ ចង់ឱ្យកូនខ្មែរ រៀបចំខ្លួនយ៉ាងណាឱ្យទៅជាមនុស្សដែលឱ្យកំណើតទៅអ្នកដទៃ សូមកុំរៀបចំខ្លួនជាអ្នកចាំតែយោនយកកំណើតពីអ្នកដទៃឡើយ ។ អំពីរឿងព្រះពុទ្ធសាសនា សូមព្រះអង្គដែលជ្រួតជ្រាបជ្រៅជ្រះក្នុងរឿងនេះ មេត្តាជួយគិតមើលថា ចង់អប់រំខ្មែរ ចង់កសាងខ្មែរ ឬក៏ចង់យកព្រះពុទ្ធសាសនានេះមកជួយខ្មែរ ឬជួយវិស័យអប់រំនេះ តើត្រូវធ្វើយ៉ាងណា ? ។ នេះក៏សុទ្ធតែជាការសិក្សា ដែលយើងត្រូវជួយកែច្នៃតទៅថ្ងៃមុខ ។

កាលពីសម័យអង្គរ កម្មវិធីសិក្សារបស់ព្រះបាទជ័យវរ័ន្មទី៧ កម្មវិធីសិក្សានៅឧត្តមសិក្សាព្រះខ័ន ដែលមានព្រះនាងឥន្ទ្រទេវី ជ័យរាជទេវី ជាបងប្អូនបង្កើតជាសកលវិទ្យាធិការិនី សូមព្រះអង្គជួយស្រាវជ្រាវមើលក្នុងសិលាចារឹកផង តើមានអ្វីខ្លះ ។ ខ្ញុំ និងលោក យី ធន់ បាននាំគ្នាស្រាវជ្រាវអំពីភាពរុងរឿងក្នុងសិលាចារឹក និងកម្មវិធីអប់រំក្នុងសម័យអង្គរ តើគេចាត់ចែងរៀបចំយ៉ាងណា ? ។ ទិសរបស់គេមានបី : ទី១ គឺច្បាំងឈ្នះខ្លួនឯង, ទី២ ច្បាំងឈ្នះធម្មជាតិ, ទី៣ ច្បាំងឈ្នះអ្នកដទៃ ។ ម្សិលមិញ ខ្ញុំបានជំរាបសម្តេចនាយកផងដែរថា : យើងខ្ជិលខ្លា និងការច្បាំងឈ្នះខ្លួនឯង យើងខ្ជិលខ្លានិងការយកចិត្តទុកដាក់នឹងខ្លួនឯង យើងចង់ឈ្នះអ្នកដទៃខ្លាំងជាងចង់ឈ្នះខ្លួនឯង ឬមួយក៏ចង់ឈ្នះធម្មជាតិខ្លាំងពេក ដោយមិនគិតអំពីជ័យជំនះលើខ្លួនឯង ។ អ្វីៗទាំងអស់ ស្រេចទៅលើមនុស្ស ។ មនុស្សខ្លាំង មនុស្សឈ្នះ ។ ដូចតេជោមាស និងតេជោយ៉តបានផ្តាំថា : មនុស្សខ្លាំង មនុស្សឈ្នះ គឺមនុស្សស្គាល់ចំណុចខ្សោយខ្លួនឯង ជំនះចំណុចខ្សោយខ្លួនឯងបាន ស្គាល់ចំណុចខ្សោយរបស់ខ្មាំង វាយខ្មាំងតាមចំណុចខ្សោយរបស់ខ្មាំង ។ ខ្ញុំព្រះករុណា ចេះតែយកសំដីនេះមកគិត យល់ថា នៅពេលបច្ចុប្បន្ននេះ សំដីនេះ មានតម្លៃណាស់ ។ ជ័យ

ជំនះដែលពុំវិលត្រឡប់ទៅបរាជ័យ គឺជ័យជំនះលើខ្លួនឯង ។ ចង់ឈ្នះលើអ្នកដទៃ បើគេខ្លាំងដែរ ប្រាកដជាបរាជ័យហើយ ។ ម្សិលមិញ ខ្ញុំព្រះករុណាបានជួបជាមួយអ្នកនិពន្ធ ( អ្នកកាសែត ) ប្អូនដប់ម្ភៃនាក់ នៅក្នុងកាសែត ឃើញថា និយាយបីម៉ាត់ ជេរពីរម៉ាត់ ។ ខ្ញុំបានឱ្យយោបល់ថា ៖ អ្ហូនអើយ ! យើងចាប់ខ្សោយពីរឿងជេរគេនេះតែម្តង ។ កាលដែលខ្មែរខ្លាំង ខ្មែរជេរខ្លួនឯងច្រើនជាងជេរគេ ។ កត្តាខាងក្រៅមិនសំខាន់ទេ គឺកត្តាខាងក្នុងទេដែលសំខាន់ជាង ។ ការពោលមកទាំងប៉ុន្មាននេះគ្រាន់តែចង់ប្រគេនព្រះអង្គជ្រាបប៉ុណ្ណោះ ។ ហើយសូមអភ័យទោស ដោយឥតបានត្រៀម និងចងក្រងឱ្យទៅជាប្រព័ន្ធមានទំនាក់ទំនងគ្នារវាងអត្ថន័យ និងអត្ថរូប ។ នេះគ្រាន់តែជាគំនិត ដើម្បីផ្សារភ្ជាប់មជ្ឈមណ្ឌលវិបស្សនា ជាមួយនឹងពុទ្ធសាសនបណ្ឌិត្យ ដែលជាមិត្តភ័ក្តិធ្លាប់ជួយគ្នាទៅវិញទៅមក ។ បំណងធំរបស់យើង គឺចង់ផ្សារភ្ជាប់ទៅនឹងរឿងអប់រំ និងជួយបណ្តុះបណ្តាលគំនិតល្អ សីលធម៌ល្អ ។ មានគេសួរខ្ញុំថា កន្លែងពាងធ្វើអ្វីខ្លះ ? ខ្ញុំឆ្លើយថា នេះជាកន្លែងធម៌ស សាលាស ។ ស្អីទៅសាលាសនោះ ? សាលាស ទាល់តែមានធម៌ស ។ ស្អីទៅជាធម៌ស ? គឺធម៌ទេវតាឬក៏ថាធម៌គ្រប់គ្រងលោកឱ្យបានល្អ ត្រឹមប៉ុណ្ណឹងសិនចុះ មិនហ៊ានវាតទៅដល់ព្រះនិព្វានទេ ព្រោះពិបាកទៅណាស់ ។ ពេលនេះ យើងគ្រាន់តែរៀបរយយ៉ាងណាឱ្យមនុស្សលោករស់បានស្រួលសិនទៅ ។ បំណងគឺមានតែប៉ុណ្ណឹងទេ ។ យើងចង់បន្ទាបបន្ថិតសាសនាមករកជីវិត មករកប្រយោជន៍នៅក្នុងជីវិត ។ ខ្ញុំបានឯកភាពគ្នាជាមួយប្អូន យី ធន់ ថា ៖ ប្រសិនបើព្រះពុទ្ធសាសនាគ្មានប្រយោជន៍ដល់ជីវិតទេ វានឹងរលត់បាត់ទៅហើយ ។ ខ្ញុំព្រះករុណាចេះតែពិចារណាថា ៖ យ៉ាងម៉េចបានជាវត្តមួយៗ ឃើញសុទ្ធតែចាស់ៗ ទៅ ។ ម្យ៉ាងវិញទៀត អ្នកដែលចូលទៅរៀនសមាធិរៀនវិបស្សនា ម៉េចក៏ឃើញសុទ្ធតែយាយៗ និងតាៗ ? តើធម៌ព្រះពុទ្ធហ្នឹងសំរាប់តែមនុស្សជិតស្លាប់ទេវិញឬអី ? សុទ្ធតែជាធម៌ងាប់អញ្ចឹងឬអី ? តើមានធម៌សំរាប់

យុវជនឬទេ ? មានធម៌សំរាប់រៀនពូកែឬទេ ? មានធម៌សំរាប់រកស៊ីពូកែឬទេ ? មានធម៌សំរាប់ធ្វើនយោបាយពូកែឬទេ ? មានធម៌សំរាប់ធ្វើប៉ូលិសពូកែឬទេ ? មានធម៌សំរាប់ធ្វើយោធាពូកែឬទេ ? ម៉េចក៏អត់ ? ហើយបើមាន ម៉េចក៏អត់មនុស្សមករៀន ? តើមកពីអ្នកណា ? មកពីវត្ត ? មកពីលោកសង្ឃ ? មកពីអ្នកបង្រៀនឬក៏មកពីគេមិនមក ? ។ គ្រាន់តែប៉ុណ្ណឹងយើងអាចពិចារណាបានហើយថា ម៉េចបានជាអញ្ចឹង ? ខ្ញុំព្រះករុណាបានរៀបចំឱ្យយុវជនធ្វើសមាធិ ធ្វើវិបស្សនា តែកំពុងព្រួយបារម្ភពីសេចក្តីត្រូវការជាចាំបាច់ខ្លះៗ ដូចជាប្រាក់ និងអាហារភោជនសំរាប់ឧបត្ថម្ភដល់អ្នកមកធ្វើសមាធិ ។ ឥឡូវ លុយបានមកហើយ ។ បើមានលុយ ក៏ដូចជាមានបាយដែរ ។ ឥឡូវ សិស្សក៏មានហើយដែរ ហើយត្រូវរកគ្រូសំរាប់បង្រៀនបង្ហាត់ធ្វើសមាធិនេះ ។

ថ្ងៃមុន មានយុវជនជប៉ុន ៣០០ នាក់ មកអង្គុយធ្វើសមាធិ យើងនាំយុវជនឱ្យមកអង្គុយធ្វើសមាធិ រៀនធម៌ ស្តាប់ធម៌ ។ ឥឡូវនេះ យើងបានទាក់ទងយុវជនជប៉ុនមកធ្វើសមាធិ ។ យុវជនជប៉ុន គេមានស្មារតីជឿនលឿនណាស់ ធ្វើភ្លាមដឹងភ្លាម ព្រោះការអប់រំខាងបញ្ញារបស់គេឈានទៅដល់កំរិតមួយ ដែលអាចឱ្យគេធ្វើភ្លាមដឹងភ្លាម ។ គេធ្វើតែ ១៥ នាទី ចេញមកវិញ ខ្ញុំសួរថា តើបានផលយ៉ាងម៉េច ? គេឆ្លើយថា : តា ! តាឯងបាននាំខ្ញុំទៅដល់ឋានមួយដែលគ្មានសម្ពាធ គឺល្អណាស់ ។ នេះគ្រាន់តែជាការសាកល្បងបែបនេះមួយឆ្នាំមកហើយ ។ គឺជាការសាកល្បងអប់រំខាងផ្លូវចិត្តតាមវិធីព្រះពុទ្ធ ។ តើការអប់រំខាងផ្លូវចិត្តនេះ វាជួយដល់ក្មេងប៉ុនណា ? ជួយដល់អ្នករកស៊ីប៉ុនណា ? ។ តែយើងគ្រាន់តែពិចារណាថា : បើចង់ឱ្យព្រះពុទ្ធសាសនាកាន់តែមានប្រយោជន៍ឡើង ( se rendre utile ) ជាជំហានដំបូង យើងគួរធ្វើឱ្យសាសនាមានប្រយោជន៍សិន ។ ហើយបន្ទាប់មក ទើបធ្វើឱ្យទៅជាចាំបាច់ ( se rendre nécessaire ) គឺថា បើអត់ធម៌ គឺរស់មិន

បានតែម្ដង ។ តើយើងត្រូវធ្វើយ៉ាងម៉េច ? នេះជាបញ្ហាចោទ ។ ឥឡូវ គេបញ្ចូលទៅក្នុងកម្មវិធីអប់រំហើយ ។ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ បានយល់ស្របហើយ ។ លោកប្រធានចង់បញ្ចូលសមាធិទៅក្នុងកម្មវិធីសិក្សាថែមទៀត ។ ចង់និយាយថា មើលខ្លួនឯងខាងក្នុង អប់រំខាងក្នុង ។ ពីព្រោះអសីលធម៌មានពីរ : អសីលធម៌ខាងក្រៅ និងអសីលធម៌ខាងក្នុង ។ មូលហេតុនៃការសម្លាប់ និងអត្តឃាតមកពីច្បាំងចាញ់អសីលធម៌ខាងក្រៅ និងអសីលធម៌ខាងក្នុង ។ បើចាញ់ទាំងពីរហ្នឹងបានសេចក្ដីថា ឬសម្លាប់ខ្លួនឯង ឬសម្លាប់គេ ហើយមូលហេតុដែលសម្លាប់គ្នាទៅវិញទៅមក ប្លន់ លួច កាប់ សម្លាប់ គឺមកតែពីរឿងអសីលធម៌ហ្នឹងឯង ។ គេចាញ់ គឺចាញ់អសីលធម៌ខាងក្រៅ និងចាញ់អសីលធម៌ខាងក្នុង ។ ដូចខ្ញុំបាននិយាយពីខាងដើមមកហើយថា : អ្នកនិពន្ធ ប្អូនដប់នាក់ សរសេរជេរគេពាសវាល ពាសកាលដោយអះអាងថា : មកពីអ្នកនេះគេធ្វើបាបអញ្ចេះ-មកពីអ្នកធំ-មកពីរដ្ឋអំណាច... ។ ខ្ញុំប្រាប់ទៅវិញថា ប្អូនឯងយល់ច្រឡំពេញទីហើយ ។ ម៉េចក៏ទុកទោសទាំងឡាយឆ្លើយដាក់អ្នកដទៃវិញ ? ហើយខ្លួនឯងម៉េចក៏រួចខ្លួន ? សួរថា : បើយើងមិនទទួល តើអ្នកណាជាអ្នកបង្ខំឱ្យយើងទទួលបាន ? ។ ឧបមាថា ខ្ញុំមិនខឹង តើអ្នកណាចេះមកធ្វើម៉េចឱ្យខ្ញុំខឹងបាន ? ដូច្នេះ ការអប់រំហ្នឹង វាជួយទៅដល់សង្គម គឺជួយមនុស្សឱ្យបន្ថយកំហឹង បន្ថយការប្រមាថ នេះចាត់ទុកថា វាសមៀមណាស់ទៅហើយ ។ ក្នុងអង្គប្រជុំថ្ងៃមុន លោកយាយវីណេប៉ាន់ សួរខ្ញុំថា ឥឡូវ តាឯងយល់យ៉ាងម៉េចអំពីការបញ្ចូលធម៌ព្រះពុទ្ធទៅក្នុងកម្មវិធីសិក្សារបស់សាលា ដូចយ៉ាងសីលប្រាំ ជាដើម ។ ឯព្រះតេជព្រះគុណ ហេង មណីចិន្ដា ក៏បានបំផុសរឿងសីល ៥ ទៅក្នុងអប់រំដែរ ។ ខ្ញុំ ព្រះករុណាឱ្យយោបល់ថា : ធ្វើឱ្យមែនទែនណ៎ា ? ប្រយ័ត្នបង្កឱ្យមានរឿងប្រមាថព្រះណ៎ា ? តែធ្វើមិនស្រួល វាក្លាយទៅជារឿងលេងសើច ។ ប្រយ័ត្ន ! ខ្មែរលេងអាក្រក់ណាស់ ។ រឿងនេះត្រូវគិតឱ្យមែនទែន កុំគិតតែពីរឿងសប្បាយ រឿងស្រួល

ហើយក៏នាំគ្នាបញ្ចូលភ្លាមទៅ ដោយមិនបានពិចារណាអំពីផលវិបាក និងមិនបានត្រៀមលក្ខណៈជាមុន ។ បើសព្វថ្ងៃនេះ គ្រូរវល់តែរកស៊ី គ្រូកំពុងតែលំបាក តើធម៌ហ្នឹងវាចូលទៅដល់ក្មេងយ៉ាងម៉េចទៅ ? តើគេចាប់ពីអ្វីទៅអ្វី ពីណាទៅដល់ណា បើអ្វីៗ ហាក់បីដូចគ្មានបានត្រៀមទុកសោះយ៉ាងនេះ ? ។ គំនិតវាល្អមែនហើយ ប៉ុន្តែ វិធី តើទៅតាមវិធីណា ? ។ រួចបើម៉ែឪ មិនទាន់ចេះធម៌ផង ធ្វើម៉េច ? ។ វិធីដែលព្រះអង្គហេង មណីចិន្តា ធ្វើ ដូចជាម្យ៉ាងដែរ ។ ព្រះអង្គហៅក្មេងៗ មករៀនភាសាអង់គ្លេស ព្រោះនិន្នាការបច្ចុប្បន្ននេះ ក្មេងៗចង់រៀនអង់គ្លេសណាស់ ។ លោកមានពុទ្ធដីកាថា : អាត្មាអាចបង្រៀនភាសាអង់គ្លេសបាន ដោយមិនទាំងយកឈ្នួលទៀតផង ប៉ុន្តែ ជាថ្នូរ សុំឱ្យក្មេងៗទាំងនោះរៀនធម៌ ។

សព្វថ្ងៃនេះ ក្រោយពីមានការព្រមព្រៀងពីសិស្សក្មេងៗនោះមក មានអ្នកស្ម័គ្រចិត្តរៀនធម៌ ដូរនឹងភាសាអង់គ្លេសចំនួនដល់ទៅជាង១.០០០ នាក់ទៅហើយ ។ គេទាំងអស់គ្នាចេះសូត្រធម៌ឥតមានទើសទាក់ឡើយ ។ លុះក្មេងៗទាំង នេះរៀនធម៌ចេះសូត្រធម៌ ដល់ត្រឡប់ទៅផ្ទះវិញឃើញថាមានការដូរចរិតខ្លះៗ គឺគេមានសីលធម៌ល្អជាមួយឪពុកម្ដាយ ។ ឃើញដូច្នោះ ម៉ែឪស្រឡាញ់កូន ស្រឡាញ់ទាំងព្រះសង្ឃដែលបានបង្ហាត់បង្រៀនកូន ស្រឡាញ់ទាំងវត្ត ដែលជាទីផ្សព្វផ្សាយព្រះធម៌ ។ នេះជាវិធីមួយបែប សំរាប់បញ្ចូលធម៌ទៅក្នុងសាលា ។ គួរគប្បីពិចារណាថា យើងមិនមែនចេះតែបញ្ចូល, ចេះតែបញ្ជានោះទេ ។ ធ្វើបែបនេះ ប្រហែលជាគ្មានប្រយោជន៍អ្វីទេ ។ នេះហើយជារឿងដែលយើងទាំងអស់គ្នាត្រូវ ពិចារណា ។

* ខ្ញុំសូមស្នើការពិចារណាត្រឹមនេះសិន ដើម្បីទុកជូនអង្គប្រជុំលើកសំណួរ ។

*សូមអរគុណ,*

# ឥទ្ធិពលរបស់សត្វ មកលើ ជីវភាពមនុស្សខ្មែរ

តាំងពីយូរលង់មកហើយ មនុស្ស និងសត្វតែងតែរស់នៅដោយផ្សារភ្ជាប់ជាមួយនឹងធម្មជាតិ ។ ម្ល៉ោះហើយ ទំនាក់ទំនងរវាងភាគីទាំងបីនេះ តែងតែជះឥទ្ធិពលដល់គ្នាទៅវិញទៅមក ។

រហូតមកដល់សព្វថ្ងៃនេះ វត្តមានសត្វនៅទីកន្លែងណា សម្រែកសត្វរាត្រី-ចរ មានប្រផ្នូលយ៉ាងណានោះ ក៏នៅតែមានមនុស្សខ្មែរជឿ និងយកចិត្តទុកដាក់ជាពិ-សេសនៅឡើយ ។ បន្ទាប់ទៅនេះ ខ្ញុំសូមលើកយកបាតុភូតមួយចំនួនមកបង្ហាញជូនដើម្បីជ្រាប និងទុកជាការយល់ដឹងខ្លះៗ អំពីជំនឿរបស់ខ្មែរពីបុរាណ ។

*១ / សម្រែកខ្លែងស្រាក* : ខ្មែរយើងធ្លាប់ជឿថា ខ្លែងស្រាក មៀមលលកខ្មោច សុទ្ធសឹងជាអ្នកបំរើ ឬជាអ្នកនាំសាររបស់ខ្មោច ព្រាយ បិសាច ។ សម្រែកសត្វទាំងនេះនៅពេលយប់ ច្រើនតែធ្វើឱ្យមនុស្សម្នាក្មេងចាស់ ភ័យ ខ្លាចញ័ររន្ធត់ ។ គេធ្លាប់ចំណាំថា បើកាលណាខ្លែងស្រាកទំយំនៅលើដំបូលផ្ទះណា ឬក៏ទំនៅលើមែកឈើជិតផ្ទះណា មនុស្សក្នុងផ្ទះនោះនឹងឈឺធ្ងន់ ឬស្លាប់ផងក៏សឹងមាន ។

*២ / សំឡេងសត្វឳឡុយំ* : ចាស់ៗ ធ្លាប់និយាយថា មានសត្វឳឡុពីរប្រ-ភេទគឺ : ឳឡុគោ និងឳឡុស្លឹក ។

ឳឡុស្លឹក ជាធម្មតាមានមាឌតូច ឯសម្រែករបស់វាក៏ពុំបណ្ដាលឱ្យមានគ្រោះមហន្តរាយអ្វីដែរ ។ តែចំពោះឳឡុគោវិញ វាមានមាឌធំជាងឆ្មាត ជាងកេងកងទៅទៀត ។ វាយំឮសូរ ( ម៉ ! !... ) ដូចសំឡេងគោយំអញ្ចឹង ។ វាកម្រនឹងយំណាស់ ។ ពេលយប់ វាច្រើនតែយំនៅលើដើមឈើធំដែលដុះលើកំពូលភ្នំ ។ ដូច

នេះហើយ សម្រែករបស់វាលាន់ឮទៅឆ្ងាយបង្គួរដែរ ។ កាលណាឮសម្រែករបស់វានៅពេលយប់ស្ងាត់ អ្នកផងតែងតែមានអារម្មណ៍ភ័យរន្ធត់ ព្រោះតាមឮចាស់ៗនិយាយតៗគ្នាមកថា បើសត្វឪឡុគោនេះយំបែរមុខឆ្ពោះទៅទិសណា ស្រុកភូមិនៅទីនោះច្បាស់ជាជួបគ្រោះវិបត្តិភ័យអន្តរាយ ដូចជា ជំងឺអំបល់ ស្លាប់រង្គះរង្គាល ដូចយ៉ាងជំងឺអុតធំ ជំងឺអាសន្នរោគ ទុរ្ភិក្សអត់ឃ្លានជាដើម ។

៣ / *ឈ្លូសចូលភូមិ* : ឈ្លូសជាសត្វព្រៃ ផ្លាងបំផុត ។ តាមចរិតធម្មជាតិរបស់វា វាខ្លាចមនុស្ស ខ្លាចស្រុកភូមិណាស់ ហើយមិនងាយនឹងហ៊ានដើរមកកាន់ទីជិតៗលំនៅរបស់មនុស្សឡើយ ។ ប៉ុន្តែ ដោយចៃដន្យ ប្រសិនបើវារត់ចូលមកក្នុងភូមិ ទោះរត់កាត់ទទឹងភូមិ ឬបណ្តោយភូមិក្តី ទោះរត់ឆ្លងផុតរួចខ្លួនក្តី ទោះត្រូវអ្នកស្រុកវាយសម្លាប់បានក្តី ចាស់បុរាណតែងតែទស្សន៍ទាយថា ស្រុកភូមិនោះនឹងកើតមានវិបត្តិ ចលាចល ភ័យភិត ឬមានហេតុឧបទ្រពចង្រៃបែបណាមួយកើតឡើងជាមិនខាន ដូចជាឈ្លោះទាស់ទែង បែកបាក់សាមគ្គីគ្នា មានភិតភ័យ ត្រូវឃ្លាតចាកចោលស្រុក ភូមិ ឬមានកើតហេតុចង្រៃផ្សេងៗទៀត ។

៤ / *ព្រូត ឃ្មុំចូលផ្ទះ* : ព្រូត ឃ្មុំ ជាបាណកសត្វ ក្រេបលំអងផ្កាធ្វើទឹកដែលមានរសជាតិផ្អែមស្អិត ដូចស្ករ ។ ក្រៅពីផ្តល់ផ្លិត ទឹកឱ្យមនុស្ស វាក៏មានចរិតអវិជ្ជមានខ្លះៗ ដែរ ។ ចាស់ៗ ខ្មែរមានជំនឿថា បើឃ្មុំចូលផ្ទះ នឹងនាំមកនូវលាភសក្ការះដល់ម្ចាស់ផ្ទះ, តែកុំបុករុកវា ។ ចំពោះសត្វព្រូតវិញ វាមិនមែនចូលមកនៅដោយកសាងជាផ្លិត ជាក្បាលទឹកដូចឃ្មុំទេ គឺវាគ្រាន់តែហើរចូលផ្ទះមួយរយៈខ្លីហើយក៏ហើរឆ្លងផុតទៅ ។ បើវាចូលផ្ទះណា ហើយមានទិចមនុស្ស សត្វក្នុងផ្ទះនោះ តាមទំនាយចាស់ៗ ពីបុរាណថា នឹងមានឧបទ្រព្យចង្រៃ វិនាសទ្រព្យសម្បត្តិក្នុងផ្ទះនោះជាប្រាកដ មានកូនចៅក្នុងផ្ទះឈឺ ឬងាប់គោ ក្របីជាដើម ។

៥ / *ក្រៀលយំ* : ក្រៀលជាសត្វស្លាបរកស៊ីតាមបឹងបួរ ថ្លុកត្រពាំង ។ វា

មានសម្បុរខ្មៅ មាឌធំ ហើយខ្ពស់ ។ គេអាចយកស្លាបវាមកធ្វើជាផ្លិតយ៉ាងធំ ។ បណ្ដាជនខ្មែរធ្លាប់ពោលត១គ្នាមកថា ៖ កាលណាគេឃើញសត្វក្រៀលមួយគូ ឬច្រើន ហើរយ៉ាងខ្ពស់ជារង្វង់មូល ហើយយំឮសូរ ( ក្រុល ១ ... ) បន្លឺសូរយ៉ាងគ្រលួចនោះ គេនាំគ្នាសន្មតថា នៅក្នុងស្រុកភូមិនាតំបន់នោះ នឹងមានក្រមុំកម្លោះពង្រត់គ្នា ។

*៦ / សសេះយំ* = ( ប្រយាបតឿន ) សត្វសសេះ ជាបក្សីរស់នៅក្នុងព្រៃ ឬក៏នៅជិត១ លំនៅឋានរបស់មនុស្សផងដែរ ។ វាមានដុះរោមក្រញាំងនៅលើក្បាលដូចជាកំប៉ោយ ។ វាមានសម្បុរលឿងស្រអាប់ ។ វាស្វះស្វែងរកអាហារដោយចោះឈើពុក ដើម្បីចឹកស្រមោច ឬសត្វល្អិតផ្សេង១ស៊ីជាអាហារ ។ វាចឹកយ៉ាងញាប់ទៅលើឈើពុក ឮសូរ ( ត្រុល ១ ... ) អ្នកស្រុកអ្នកភូមិនៅតំបន់ស្រុកគីរីវង្សតែងតែនាំគ្នាចំណាំត១គ្នាមកថា ៖ កាលណាគេឮវាយំ កិក ! កិក ! កិក ! បែបញាប់រន្ថើននោះ គេយល់ថា នេះជាប្រផ្នូលល្អ ទំនាយទាយថា នឹងមានលាភអ្វីម្យ៉ាងមិនខាន ។ ជនណាដែលនៅជិតកន្លែងវាយំ ( តឿន ) ឮកិក១ ! នេះ តែងតែបន្លឺសំឡេងតបទៅវិញយ៉ាងខ្លាំង១ ថា ៖ « ប្រយាប ! មានលាភ ! » ។ គេថារបៀបនេះទាល់តែសសេះលែងយំទើបគេឈប់ថា ។ លុះវាយំកិក១ ! របៀបនេះអស់ចិត្តហើយ វាក៏ហើរទៅកាន់ទីផ្សេងបាត់ទៅ ។ យំរបៀបនេះ គេនិយមហៅថា « ប្រយាបតឿន »

*៧ / ក្អែកបួល* ៖ ក្អែកជាបក្សីសំបុរខ្មៅរលើប ។ សត្វនេះ រស់នៅមិនឆ្ងាយពីស្រុកភូមិទេ ព្រោះវាចូលចិត្តឆាប ឆក់ ពងមាន់ កូនមាន់ ឬត្រី សាច់ ដែលអ្នកស្រុក អ្នកភូមិហាលនៅតាមស្នូរក្បែរផ្ទះ ។ សត្វនេះមានចរិតផ្អើល ខ្លាច ភ័យសស្លើតសស្លក់ ។ សត្វនេះថ្វីបើវាផ្អើលខ្លាចមនុស្ស តែវារស់នៅមិនដាច់ឆ្ងាយពីមនុស្សទេ ។ ដូច្នេះហើយបានជាធ្លាប់មានរឿងដំណាលផ្សេង១និយាយដល់រឿង

ក្អែក ដូចជារឿងល្បើកលោកឡាហ្មុនតែន ដំណាលអំពី « ក្អែក និងកញ្ជ្រោង ... » ចំរៀងខ្មែរបុរាណ មានចំណងជើងថា « បង្គងក្អែក » ដែលមានអត្ថន័យកំសត់ស្រងេះស្រងោច សឹងជាចំរៀងបកស្រាយអំពីទុក្ខចំបែងនៃការនិរាសបែកបាក់គ្នា ។ តាមជំនឿតៗគ្នាមក កាលណាគេឮក្អែកប៉ូល អក់វ៉ូវៗ ! ឡូវៗ ! ក្រវ៉ាកៗ ! គេតែងតែជឿថា បងប្អូនគ្រួសារដែលឃ្លាតទៅឆ្ងាយនោះ និងវិល ត្រឡប់មកវិញ ។ ម្យ៉ាងទៀត បើវាបន្លឺសូរថា អក់វ៉ូវ ! អក់វ៉ូវ ! អក់វ៉ូវ ! ញាប់រន្ថើនដដែលៗ ច្រើនដងនោះ គេជឿថាមានមនុស្សជាភ្ញៀវ ឬជាសាច់ញាតិមកដល់ភ្លាមៗ ឥឡូវនេះហើយ ។ ប៉ុន្តែ គួរឱ្យស្ដាយពន់ពេកណាស់ បច្ចុប្បន្ននេះ ក្មេងៗសាក្រោយមួយចំនួនពុំស្គាល់ក្អែកទាល់តែសោះ ព្រោះតាំងពីស្រុកយើងកើតមានសង្គ្រាម ក្អែកនៅស្រុកខ្មែរទាំងប៉ុន្មាន ត្រូវគេចខ្លួនហើរទៅបាត់អស់ ដើម្បីទៅរស់នៅទីតំបន់ណា ដែលមានសេចក្ដីសុខស្ងប់ ។

*៨ / កុកទំផ្ទះ* : នៅស្រុកខ្មែរយើងមានពូជកុកជាច្រើនប្រភេទ ដូចជាកុកគ្រោង កុកក្រសា កុកននាល កុកស កុកសាប់ ។ល។ ប៉ុន្តែ នៅទីនេះគេច្រើនសំដៅទៅលើកុកតែពីរប្រភេទទេ គឺកុកស និងកុកសាប់ ។ គេតែងតែកត់សម្គាល់ថា កាលណាកុកណាមួយ នៃប្រភេទកុកទាំងពីរ ទំលើដំបូលផ្ទះ ចាស់ៗប្រាប់តៗ គ្នាមកថា « ចង្រៃ » ខ្លាំងណាស់ ។ គេតែងចងក្រងជាពាក្យទំនៀមថា : «... ចង្រៃដូចកុកទំផ្ទះ ដូចរន្ទះបាញ់ភូមិ ... » បានន័យថា អព្ភូតហេតុទាំងពីរយ៉ាងនេះ ចង្រៃដូចគ្នា ។ ដូច្នេះ កាលណាមានហេតុបែបនេះកើតឡើង ខ្មែរៗដែលមានជំនឿ គេតែងតែនិមន្តព្រះសង្ឃមកចំរើនព្រះបរិត្តបណ្ដេញឧបទ្រពចង្រៃ ឬក៏អញ្ជើញគ្រូមកបង្កក់ ប្រោះព្រំ កំចាត់នូវឧបទ្ទវហេតុនេះ ដើម្បីឱ្យម្ចាស់ផ្ទះរស់នៅក្នុងសុភមង្គលឡើងវិញ ។

*៩ / ពស់ ឬថ្លាន់ចូលផ្ទះ* : សត្វលូនទាំងពីរបែបនេះ ជាធម្មតាមិនសូវ

ចូលចិត្តនឹងមនុស្សម្នា ឬមិនដែលរស់នៅក្នុងផ្ទះមនុស្សទេ លើកលែងតែពស់សង់សឿ ដែលវាចូលមកលំនៅស្ថានមនុស្សម្តងម្កាល ដើម្បីចាប់កណ្តុរស៊ីជាអាហារ ។ ពស់ដែលគេធ្លាប់ឃើញចូលផ្ទះ ដោយចៃដន្យនោះ គឺពស់ព្រៃ និងពស់ផ្ទាន់ ។ ពស់ទាំងពីរប្រភេទនេះ មានចរិតស្លូតបូត មិនសាហាវដូចពស់អសិរពិសផ្សេងៗទៀតឡើយ ។ បើកាលណាវាចូលមកនៅលើផ្ទះ ក្រោមផ្ទះនោះ ចាស់ពីបុរាណកំណត់ថាវាមកឱ្យសុខសប្បាយទេ មិនបង្កនូវភ័យអន្តរាយបែបណាមួយឡើយ ។ កាលណាឃើញវាចូលមក គេត្រូវចាប់វាថ្នមៗ ហើយបបោសអង្អែលលាបប្រេង លាបម្សៅរួចដុតធូប និយាយដូចនេះថា : « ឯងចូលមកផ្ទះយើងនេះ សូមឯងនាំយកមកនូវលាភជ័យ សេចក្តីសុខ សេចក្តីចំរើន សុភមង្គលដល់យើង យើងលែងឯងឱ្យមានសេរីភាព ចូរឯងទៅរស់នៅក្នុងព្រៃឱ្យបានសេចក្តីសុខចុះ » ។

*១០ / អំពិលអំពែកចូលផ្ទះ* : អំពិលអំពែកជាសត្វដង្កូវម្យ៉ាង មានជាតិហ្វូសហ្វ័រភ្លឺភ្លិបភ្លែតៗ នៅត្រង់ពោះរបស់វា ។ នៅពេលយប់ ជាពិសេសនៅរដូវវស្សាដែលមានភ្លៀងធ្លាក់ជោគជាំ អំពិលអំពែកកើតកូនកើតចៅជាច្រើន ។ លុះពេលព្រលប់មកដល់ វាហើរព្រោងព្រាតបញ្ចេញពន្លឺភ្លិបភ្លែតៗ ពាសពេញព្រៃ ឬពាសពេញភូមិ ។ សត្វអំពិលអំពែកចូលចិត្តហើរលេងសប្បាយតាមវាលស្មៅ នៅទីធ្លាក្បែរផ្ទះក្នុងភូមិ ។ ប្រការដែលគួរឱ្យកត់សំគាល់ គឺវាកម្រនឹងហើរចូលមកក្នុងផ្ទះណាស់ ។ ប៉ុន្តែ ជាចៃដន្យបើវាហើរចូលក្នុងផ្ទះ ទោះបីលើ ឬក្រោមផ្ទះក្តី ចាស់បុរាណទាយថា វានាំយកលាភសក្ការៈមកឱ្យម្ចាស់ផ្ទះនោះ ។ ជួនកាលអំពិលអំពែកនៅហើរវិវក់ឆ្វេលចុះឆ្វេលឡើងក្នុងផ្ទះអស់ពេលយ៉ាងយូរ ។ ជួនកាលវាចូលមកតែមួយភ្លែតក៏ចេញទៅវិញ ។ យោលទៅតាមបាតុភូតបែបនេះ ទំនាយក៏ទាយទៅតាមនោះដែរ គឺថា : បើវាចូលមកហើរចុះ ហើរឡើងអស់រយៈពេលយូរ គេជឿថា នឹងមានលាភធំណាស់ ។ តែបើចូលមកតែមួយភ្លែត ហើរចេញបាត់ទៅវិញ ទំនាយទាយថា មាន

លាភដែរ តែបានបន្តិចបន្តួចប៉ុណ្ណោះ ។ អ្នកភូមិខ្លះៗ នៃខេត្តកំពង់ធំ កាលបើឃើញអំពិលអំពែកហើរចូលផ្ទះ គេហាមកូនហាមចៅមិនឱ្យចាប់វាលេងឡើយ ព្រោះគេជឿថា បើកាលណាវាងាប់ដោយក្មេងចាប់ដៃធ្ងន់ពេកនោះ នឹងនាំឱ្យមានគ្រោះមហន្តរាយវិញ ។ គេបង្គាប់កូនចៅឱ្យសូត្រជាបទស្មើៗ ថា ៖ « អំពិលអំពែកអើយ កុំទៅផ្ទះគេ គេចាប់គេចង មកផ្ទះបង បងឱ្យកងពាក់ បាក់មួយទៅ បងឱ្យមួយទៀត ..... » យ៉ាងនេះជាដើម ។

*១១ / តុកកែយំ* ៖ តុកកែជាសត្វមួយប្រភេទ ដែលរស់នៅតាមដើមឈើ ឬក្នុងលំនៅឋានរបស់មនុស្ស ត្រាច់ចរតាមសសរ តាមផ្ទាន ផ្ដោង ដើម្បីស្វែងរកចាប់ចំណីស៊ីជាអាហារ ។ វាក៏ពងហើយភ្ញាស់កូនបន្តពូជពង្សនៅទីនោះផងដែរ ។ ចាស់ៗ ធ្លាប់ប្រាប់តៗ គ្នាមកថា បើតុកកែណាយំតិចជាង ៧ ម៉ាត់ នោះពុំល្អឡើយ ព្រោះវាបកស្រាយនូវឋាមពលខ្សោយ (រាសីដាក់, វាសនាតិច) ដែលចាស់ៗ ប្រាប់ឱ្យដេញវាចេញពីផ្ទះ ។ បើតុកកែណាដែលយំចាប់ពីប្រាំពីរម៉ាត់ រហូតទៅដល់ ១៥ ឬ១៨ ម៉ាត់នោះ លោកទាយថា ល្អពន់ពេកណាស់ គួរលៃថែរក្សាវាឱ្យនៅជាប្រចាំនៅក្នុងផ្ទះ ព្រោះតាមរយៈចំនួនម៉ាត់ដែលវាយំបានច្រើនយ៉ាងនេះ វាជាការបកស្រាយនូវឋាមពលខ្លាំងក្លា ( រាសីខ្ពស់ ជោគជតាល្អវិសេស ) ។

*១២ / អំពីព្រាបចូល ឬព្រាបចេញ* ៖ ព្រាបជាសត្វព្រៃ មានចរិតស្លូតបូត ហើយគេងាយនឹងផ្សាំងវាណាស់ ។ ក្នុងករណីទូទៅ វាហាក់សំដែងការស្និទ្ធស្នាលជាមួយមនុស្ស, រូបរាងវាល្អល្អះគួរឱ្យស្រឡាញ់ណាស់ ។ សំឡេងយំរបស់វាឮស្ងួរដូចសំឡេងថ្ងូររបស់អ្នកជំងឺ សមដូចពាក្យទំនៀមលោកពោលថា ៖ « ថ្ងូរដូចព្រាប » ម្យ៉ាងទៀត មានពាក្យអ្នកស្រុកធ្លាប់ចំអន់គ្នាលេងថា ៖ « ព្រាបណាពូកែថ្ងូរ ព្រាបនោះពិតជាធាត់ » ។ ចាស់ៗ ធ្លាប់ចំណាំថា ៖ បើកាលណាគេឃើញសត្វព្រាបហើរទាំងហ្វូងមកអាស្រ័យនៅលើផ្ទះណា នោះជាសញ្ញាប្រាប់ឱ្យដឹងថា គ្រួសារនោះ

នឹងមានជោគជតារាសីល្អ គួរថែរក្សាការពារព្រាបនោះឱ្យវារស់នៅជារៀងរហូតតទៅ វាពិតជាបានល្អ ត្រជាក់ត្រជុំមិនខាន ។ ផ្ទុយទៅវិញ បើកំពុងតែរស់នៅលើផ្ទះណាមួយសុខៗ ស្រាប់តែវានាំគ្នាហើរចេញពីផ្ទះលែងនៅតទៅទៀត នោះជាសញ្ញាប្រាប់ឱ្យដឹងថា រាសីម្ចាស់ផ្ទះនឹងធ្លាក់ចុះ នឹងមានហេតុភេទមិនល្អតទៅថ្ងៃមុខ ។

១៣ / *វត្តមានសត្វចាបដូនតា* ៖ សត្វបក្សីដែលមានមាឌតូចជាងចាបធម្មតានេះ ជាសត្វមានចរិតរពិសពន់ពេកណាស់ ។ បើវាទំនៅលើមែកឈើណានោះ វាមិនដែលនៅស្ងៀមបានមួយភ្លែតឡើយ វាលោតចុះលោតឡើង ហើយយំឮសូរចាច់ ៗ ! ។ ជាធម្មតា វាចូលចិត្តរស់នៅលើដើមឈើជិតៗផ្ទះមនុស្ស ហើយហាក់ចុះ ហាក់ឡើង យំចាច់ ៗ ឥតឈប់ឈរ ។ សត្វនេះ មានវត្តមានតាមពេលតាមកាល ( Oiseau passager ) ពោលគឺមិនមែនរស់នៅជាអចិន្ត្រៃយ៍ដូចរស់សត្វបក្សាបក្សីផ្សេងឯទៀតឡើយ ។ ខ្មែរយើងធ្លាប់ជឿតៗគ្នាតាំងពីយូរមកហើយថា ៖ សត្វចាបដូនតានេះ ជាតំណាងព្រលឹងដូនតាខ្មែរទាំងអស់ មានទីស្នាក់អាស្រ័យនៅជាអចិន្ត្រៃយ៍នៅឯព្រៃហេមពាន្តឯណោះ ។ តែកាលណាចូលដល់ជិតពាក់កណ្តាលខែភទ្របទហើយនោះ សត្វចាបដូនតាបានធ្វើដំណើរពីព្រៃហេមពាន្តមកដល់ប្រទេសខ្មែរ ។ ត្រង់នេះស្របនឹងជំនឿខ្មែរថា ៖ នៅវស្សានរដូវ ពេលដែលមេឃមានពពកខ្មៅមីរដេរដាស មានភ្លៀងធ្លាក់ជោគជាំទាំងយប់ទាំងថ្ងៃឥតស្រាក មានផ្គរលាន់ឮសូរគគ្រឹមពួដ៏អាកាសនោះ ស្តេចយមបាលបានបើកលែងព្រលឹងខ្មោចដូនតាដែលមានទោសជាប់នៅឯស្ថាននរកនោះ ឱ្យមករកកូនចៅដើម្បីបានទទួលអាហារភោជន ដែលកូនចៅតែងនាំគ្នាទៅធ្វើបុណ្យបញ្ជូនកុសលនៅតាមវត្តអារាមនានា ។ តាមចំណាំ សត្វចាបដូនតាមកកាន់ស្រុកខ្មែរយើងក្នុងកាលវេលាមួយទៀងទាត់ណាស់ គឺចូលដល់ជិតពាក់កណ្តាលខែភទ្របទមកដល់ លុះចប់រដូវភ្ជុំបិណ្ឌ ហើយក៏ស្រាប់តែទៅបាត់អស់គួរឱ្យកត់សំគាល់ពន់ពេកណាស់ ។ ចាស់ៗ ធ្លាប់និទានថា លុះ

ផុតរដូវភ្ជុំបិណ្ឌហើយ សត្វចាបដូនតាដែលជាតំណាងព្រលឹងដូនតា បានលាយើងជាកូនចៅ វិលត្រឡប់ទៅលំនៅឋានឯព្រៃហេមពាន្តវិញ ។ លុះដល់ខែភទ្របទ រដូវភ្ជុំបិណ្ឌឆ្នាំក្រោយ ទើបមកម្តងទៀត ។

*១៤ / ឆ្មា ឆ្កែ ចូលផ្ទះ* : សត្វទាំងពីរប្រភេទនេះ សុទ្ធសឹងតែជាសត្វស្រុក ។ ជួនកាលពួកវាមានម្ចាស់គ្រប់គ្រងថែរក្សា ។ ជួនកាលវាក៏ត្រាច់ចរ ម្តងទៅត្រង់នេះ ម្តងទៅត្រង់នោះ ឥតទីដៅច្បាស់លាស់ឡើយ ។ មានជួនកាលទៀតពួកវាដែលរស់នៅក្រោមដំបូលផ្ទះណាមួយ ហើយដោយមានហេតុបច្ច័យជាអាថិកំបាំងក្តី ដោយត្រូវម្ចាស់វាយធ្វើបាបបង្អត់អាហារក្តី វាក៏សំរេចចិត្តចេញពីផ្ទះនោះដើម្បីធ្វើការផ្សងព្រេងទៅរកទីថ្មីទៀត ។ ចំពោះសត្វអស់នេះ ចាស់ៗធ្លាប់មានពាក្យស្លោកខ្លះៗដែរ ដូចជាពោលថា : « ពុតសិស្សគ្រូបី ពុតស្រីប្តីលែង ពុតគោជ្រលែង ពុតឆ្កែបង់ម្ចាស់ (១) » ។ ឯពាក្យស្លោកមួយឃ្លាទៀតនោះ ពាក់ព័ន្ធដល់សត្វឆ្មា « ឆ្មាសម្បុរបី ស្រីគ្រប់ល័ក្ខណ៍ » ពាក្យស្លោកខាងក្រោមនេះ មានអត្ថន័យល្អ ។ ចាស់ៗ តែងតែមានជំនឿតៗ គ្នាមកថា : កាលណាឆ្មា ឬឆ្កែចូលមកនៅក្នុងផ្ទះយើងនោះ ចាត់ទុកជាប្រផ្នូលល្អណាស់ ។ គេសន្មតថា ប្រហែលជាអានុភាពជាអាថិកំបាំងអ្វី បណ្តាលចិត្តឱ្យសត្វទាំងនេះចូលមកនៅផ្ទះយើង ក្នុងន័យនាំយកទ្រព្យសម្បត្តិលាភជ័យល្អមកឱ្យយើង ។ អាចគិតថា ប្រហែលជាផ្ទះនោះ ជាទីត្រជាក់ត្រជុំ

---

(១) មនុស្ស ឬសត្វទាំងបួនជំពូកនេះ ចាស់ៗ លោកចាត់ថា ចង្រៃណាស់ មិនគួរឱ្យសេពគប់ឡើយ ។

* គោជ្រលែង : គោគេចវេះដើរចោលហ្វូង ឬមិនចង់ចូលផ្ទះដូចសត្វដទៃទៀត ។

* ពុតសិស្សគ្រូបី : រៀនហើយរត់រកគ្រូថ្មីទៀត ញយៗ មានន័យថាចិត្តសាវា ។

* ពុតឆ្កែបង់ម្ចាស់ : គឺឆ្កែរត់ចោលម្ចាស់ឥតហេតុផល ។

សុខក្សេមក្សាន្តហើយបានជាសត្វទាំងនេះមកសុំជ្រកកោននៅជាមួយ ដើម្បីសុំសេចក្ដីសុខ ។ ដូច្នេះ កាលបើមានហេតុភេទបែបនេះ ទោះបីយើងមានឆ្កែឆ្មាក្នុងផ្ទះយើងស្រាប់ហើយក្ដី គួរកុំធុញទ្រាន់ទើសទាល់ គួរទទួលវាឱ្យនៅផងចុះ កាលបើឃើញវាចូលមកនៅដោយមានអាកប្បកិរិយាស្លូតបូត ឱនលំទោន សុភាពរាបសារ ។ តទៅថ្ងៃមុខ អ្នកច្បាស់ជាបានជួបវាសនាល្អជាមិនខាន ។ ធម្មតាសត្វឆ្កែ ឬឆ្មាក៏តែងតែមានពីរសណ្ឋានជាដរាប គឺខ្លះល្អ ខ្លះទៀតអាក្រក់ ។ ឆ្មាសូម្បីវាមានសម្បុរបីក៏ដោយ ក៏មានអាក្រក់ដែរ ។ ប៉ុន្តែ ជួនកាលខ្លះ ពួកវាមិនមានចរិតអាក្រក់មកពីកំណើតនោះទេ ប៉ុន្តែវាចំណុះទៅនឹងការអប់រំបង្ហាត់បង្រៀនរបស់ម្ចាស់វា ។ ចាស់ៗ ធ្លាប់ពោលថា ឆ្មាវាបន់ឱ្យតែម្ចាស់មាននឹងបានដេកពូក ។ ឯសត្វឆ្កែបន់ឱ្យតែម្ចាស់ងាប់ នឹងបានស៊ីចំណីពោរពាសក្នុងពេលគេធ្វើបុណ្យឱ្យខ្មោចម្ចាស់វា ។

*១៥ / ឆ្កែលូនៅពេលយប់ស្ងាត់* ៖ តាមធម្មតា ឆ្កែវាតែងព្រុះមនុស្សចម្លែក ព្រុះដេញសត្វឆ្កែផងគ្នាដែលវាពុំធ្លាប់ឃើញ ។ ប៉ុន្តែ គេកម្រឮវាលូ ណាស់ លើកលែងតែស្ថិតក្នុងករណី ដែលត្រូវម្ចាស់វាយកទៅប្រោសចោល ( បំបរបង់ ) រកផ្លូវវិលមកផ្ទះវិញមិនឃើញប៉ុណ្ណោះ ហើយឆ្កែប្រភេទនេះលូតែពេលថ្ងៃទេ ។ ប៉ុន្តែ ប្រសិនបើនៅពេលយប់ស្ងាត់ គេឮវាលូយ៉ាងវែង បន្លឺសូរគ្រលួចបែបលន្លង់លន្លោច ឮសូរគួរឱ្យព្រឺក្បាល គឺលូបញ្ចេញសំឡេងបែបនេះហើយដែល ចាស់ៗខ្មែរយើងកំណត់ថា ៖ ជាប្រផ្នូលមិនល្អសំរាប់ស្រុកភូមិទៅថ្ងៃមុខ ។ ចាស់តែងតែជឿថា ស្រុកទេសយើងមានចម្បាំងរាំងជល់ ទុរ្ភិក្សអត់ឃ្លាន ឬមានជំងឺរាតត្បាត ។

*១៦ / គោក្រយៅក្រឡាច់* ៖ ជាទូទៅ គោជាសត្វមានផលប្រយោជន៍ចំពោះមនុស្ស ដោយផ្ដល់នូវកំលាំងអូសទាញ ផ្ដល់សាច់ជាអាហារ ផ្ដល់ទឹកដោះ និងផ្ដល់កូនសំរាប់បន្តពូជពង្ស ។ ខ្មែរយើងចំណាំដឹងថា គោទាំងអស់ពុំមានលក្ខណៈដូចៗ

គ្នាទាំងអស់ទេ ។ ពួកខ្លះមានលក្ខណៈល្អ ដែលគេជឿថា បើវាមិនចំរុងចំរើន យ៉ាងហោចណាស់ក៏វាមិនឱ្យទោសដល់ម្ចាស់ដែរ ។ ឯមួយពួកទៀត វាមានលក្ខណៈខុសប្លែកពីប្រក្រតី ។ គេមើលដឹងលក្ខណៈល្អ អាក្រក់នេះដោយសារក្រយៅរបស់វា ។ ក្រយៅដែលអាក្រក់នោះ គឺក្រយៅក្រឡាច់ ក្រយៅឈ្វាកក្រោល ក្រយៅរំភាយខ្ចាត់ ក្រយៅធាក់លាញ ។ ល ។ គោណាដែលមានក្រយៅមានភិនភាគដូចពោលមកនេះ គេចាត់ទុកជាសត្វចង្រៃ គេរិះរកគ្រប់វិធីដើម្បីលក់ ឬដូរចេញឱ្យផុតពីផ្ទះ ។ បើកាលណានៅតែរឹងរូសប្រើប្រាស់ ឬចិញ្ចឹមគោប្រភេទនេះ គេជឿថា នឹងមានហេតុអន្តរាយ វិនាសទ្រព្យសម្បត្តិ ឬមនុស្សក្នុងគ្រួសារឈឺថ្កាត់ ស្លាប់ព្រាត់ប្រាសក៏សឹងមាន ។ អំពីលក្ខណៈចង្រៃបែបនេះ ខ្មែរយើងធ្លាប់មានពាក្យស្លោកពោលថា : « *អំ-ពិលឯត្បូង អណ្តូងឯលិច គោក្រយៅក្រឡាច់ ប្រពន្ធដោះញ* » ។ មានន័យថា បើមានដើមអំពិលនៅពីខាងត្បូងផ្ទះ បើមានអណ្តូងនៅខាងលិចផ្ទះ បើមានគោក្រយៅក្រឡាច់ បើមានប្រពន្ធដោះញ នោះបុរាណាចារ្យលោកចំណាំថា ចង្រៃពន់ពេកណាស់ ។

*១៧ / ត្រដេវរ៉ិចចាល់* : ត្រដេវរ៉ិចជាបក្សីដែលរកស៊ីដោយមិនសូវបង្ហាញខ្លួនឱ្យមនុស្សម្នាឃើញងាយៗ នោះឡើយ ។ វាយំឮសូរ តេៗ រ៉ិច ! ៗ . . . យំផងហើរផង ហាក់ដូចជាភិតភ័យណាស់ ។ ចំពោះសត្វត្រដេវរ៉ិចនេះ ចាស់ៗខ្មែរធ្លាប់និយាយជាពាក្យទំនឹមទំនៀមថា : «ដេកយកជើងទ្រមេឃ ដូចសត្វត្រដេវរ៉ិច» មានន័យថា ជាមនុស្សប្រយ័ត្នប្រយែង មានការភ័យបារម្ភច្រើន ។ តែចំពោះចាស់បុរាណគាត់ធ្លាប់ចំណាំតៗ គ្នាមកថា បើនៅពេលយប់ស្ងាត់ មានសត្វត្រដេវរ៉ិចចាល់ទាំងហ្វូងឮសូរ តេៗ រ៉ិច ៗ . . . ទ្រហឹងអឺងអាប់ នោះច្បាស់ជាមានពពួកចោរមកលួចឬប្លន់នៅភូមិណាមួយក្នុងតំបន់នោះហើយ គេត្រូវតែនាំគ្នាប្រុងប្រយ័ត្នឡើង ។

*១៨ / សត្វជើងបី* : តាមធម្មតា សត្វពាហនៈជាចតុប្បាទ ដូចជាគោក្របី

សេះ ដំរី ជ្រូក ឆ្កែ ឆ្មាជាដើម តែងតែមានជើងបួនជាដរាប ។ ដូច្នេះ បើគេនាំគ្នាកំណត់ថា សត្វជើងបីនោះ តើគេសំគាល់ត្រង់លក្ខណៈបែបយ៉ាងណាទៅវិញ? ។ គេសំគាល់ថា សត្វជើងបី ចំពោះតែសត្វដែលជើងទាំងបួនរបស់វាមានសម្បុរមិនដូចគ្នា ។ ឧទាហរណ៍ ជើងបីសម្បុរខ្មៅ ជើងមួយសម្បុរស ឬផ្ទុយមកវិញ ជើងបីសម្បុ-រសជើងមួយសម្បុរខ្មៅ នេះគេចាត់ថា សត្វនោះមានជើងបីហើយ ។ បើសត្វដែលគេចិញ្ចឹមណា ដែលមានលក្ខណៈដូចពោលខាងលើនេះ គេមិនចិញ្ចឹមទេ គេចាត់ទុកថាជាសត្វចង្រៃនាំមកនូវទុក្ខទោស ឧបទ្រពចង្រៃដល់ម្ចាស់ជាមិនខាន ។

*១៩ / កូនក្របីឈ្មៀច* ៖ តាមពូជរបស់វា ក្របីមានពីរពណ៌ គឺសម្បុរខ្មៅនិងសម្បុរឈ្មៀច ( ពណ៌កុលាប ) ។ តាមការសង្កេត គេឃើញមានក្របីឈ្មៀចតិចបំផុត ។ កសិករខ្មែរមិននិយមចិញ្ចឹមក្របីឈ្មៀចទេ គេថាវាចាញ់កំដៅថ្ងៃជាងក្របីខ្មៅ ។ ចំពោះអ្នកដែលចិញ្ចឹមក្របីខ្មៅទាំងហ្វូង១ ឱ្យដេករួមគ្នានៅក្នុងក្រោលតែមួយនោះ បើកាលណាហើយមានបាតុភូតចម្លែកមួយ គឺឃើញមេក្របីខ្មៅណាមួយកើតកូនមកជាក្របីឈ្មៀច នោះគេជឿថាជាបុព្វនិមិត្តប្រាប់ឱ្យដឹងអំពីការស្លាប់រង្គាល នៃហ្វូងក្របីដោយសារជំងឺអំបល់ ។

*២០ / មនុស្សមានគភ៌មិនអាចជិះដំរីបាន* ៖ ដូចសត្វពាហនៈដទៃទៀតដែរ វាតែងតែមានការពាក់ព័ន្ធទៅនឹងជីវភាពមនុស្សដែលយើងសូមលើកយកមកពណ៌នាដូចតទៅ ៖ ហ្មដំរីទាំងឡាយតែងតែមានការប្រយ័ត្នប្រយែង មិនអនុញ្ញាតឱ្យមនុស្សមានគភ៌ ( ផើម ) ជិះលើខ្នងដំរីឡើយ ។ បើគេនៅតែបំពារបំពានទៅលើតំណមនេះ ដំរីនឹងរលាស់ជម្រុះមនុស្សផើមនោះឱ្យធ្លាក់ពីលើខ្នងវា ។

*២១ / ហាមសាសងស្នេហានៅលើខ្នងដំរី* ៖ ដោយឡែកពីតំណមមិនឱ្យមនុស្សផើមជិះលើខ្នង ការសាសងតាមផ្លូវស្នេហាប្រឡូកប្រឡែងគ្នានៅលើខ្នងដំរីក៏ជាប្រការមួយពុំអាចអនុញ្ញាតបានដែរ ។ យើងរាល់គ្នាដែលធ្លាប់ដឹងអំពីប្រពៃណី

នេះ រួមទាំងហ្មដីរផង នៅពុំទាន់បានស្រាវជ្រាវរកឃើញអំពីមូលហេតុច្បាស់លាស់នៅឡើយ ។ រហូតមកទល់ពេលនេះ យើងគ្រាន់តែដឹងតាមរយៈចាស់ៗ និយាយថា ៖ បើកាលណាគេនៅតែបំពារបំពានទៅលើតំណាមនេះ ដីរនឹងស្រុត ( ស្លាប់ ) ដោយពុំអាចព្យាបាលឱ្យជាបានឡើយ ។

*២២ / ដីរចូលរួមចំណែកក្នុងការនាំមកនូវភាពត្រជាក់ត្រជំ និងព្យាបាលក្មេងអារ៉ុះ* ៖ ក្មេងអារ៉ុះជាប្រភេទក្មេងដែលពិបាកចិញ្ចឹម ព្រោះវាមានជំងឺរ៉ាំរ៉ៃជាប្រចាំ គឺជំងឺចំរុះច្រើនមុខ ឈឺនេះផង ឈឺនោះផង ពិបាកព្យាបាលជាទីបំផុត ។ ហេតុគួរឱ្យចម្លែក នៅត្រង់វាស្គមរីងរៃ ឈឺឥតមានថ្ងៃស្រាកស្រាន្ត តែវាមិនស្លាប់ ។ ចាស់បុរាណធ្លាប់ព្យាបាលក្មេងអារ៉ុះនេះតាមវិធីប្លែកៗជាច្រើន មានដាក់វាឱ្យអង្គុយក្នុងឈ្នាង ហើយយកទៅធ្វើពិធីឧបកិច្ចនៅត្រង់ផ្លូវបំបែកជាបួន ដាក់វានៅចំផ្លូវព្រះសង្ឃនិមន្តបិណ្ឌបាត ដើម្បីឱ្យព្រះសង្ឃទស្សន៍ ឬក៏យកទៅប្រគេនលោកធុតុង្គឱ្យលោកព្យាបាល ឬក៏ឧបកិច្ចធ្វើជាឱ្យទៅលោកអាចារ្យចិញ្ចឹមជានិមិត្តរូប រួចទៅលោះយកមកវិញ ។ ល ។ និង ។ ល ។ តែនៅពេលនោះ យើងសូមលើកយកវិធីមួយមកពណ៌នានោះគឺ ការព្យាបាលដោយមានអន្តរាគមន៍ពីដីរ ។ តាំងពីបុរមបុរាណវៀងដរាបមក ខ្មែរយើងតែងតែចាត់ទុកដីរថាជាសត្វត្រជាក់ត្រជំ ជាសត្វនាំមកនូវសុភមង្គល ជាសត្វតំណាងឱ្យទឹក និងភាពសំបូររុងរឿង ។ ជំនឿនេះបានចាក់ឫសយ៉ាងជ្រៅទៅក្នុងអារម្មណ៍ខ្មែរ រហូតដល់នាំគ្នាជឿតៗមកថា បើកាលណាយល់សប្តឃើញដីរនោះ ច្បាស់ជាមានភ្លៀងជាពុំខាន ។ ខ្មែរខ្លះជឿថា ដីរនាំមកនូវជោគវាសនាល្អ ធ្វើអ្វីៗតែងតែកើតចំរើនផលកាក់កបជានិច្ច ។ ដូច្នេះហើយបានជាស្រីៗ នៅស្រុកស្រែខ្លះដែលចង់ចិញ្ចឹមនាងឱ្យបានផលចំរើន គេតែងទៅនិយាយអង្វរហ្មដីរឱ្យជួយគេឱ្យបានស្ទាបបបូរមាត់ក្រោមរបស់ដីរ ។ ជួនកាលគេយកស្បែកដីរ (ដែលងាប់ ) មកធ្វើជាជ្រញ់ហាន់ស្លឹកមនឱ្យដង្កូវនាងស៊ី ដើម្បីឱ្យបានលទ្ធផលល្អក្នុងការ

ចិញ្ចឹម ។ ខ្មែរភាគច្រើន ពិសេសគ្រួសារអ្នកមាន ច្រើនតែយកភ្លុកដំរីទាំងគូរមកដាក់តាំងលើតុកិត្តិយស ឬលើខ្នងទូ ទុកជាគ្រឿងលំអផ្ទះផង និងទុកជាទ្រព្យត្រជាក់នៅក្នុងផ្ទះផង ។

ចំពោះក្មេងអារ៉ឺះ គេយកវាទៅដាក់ពីក្រោមពោះដំរី ឬដាក់ពីក្រោមមាត់ដំរី យកប្រមោយវាឱ្យស្ទាប់ក្បាលក្មេងនោះ ឬក៏ឱ្យវាព្រួសទឹកដាក់ខ្លួនប្រាណក្មេងនោះ ក្នុងក្តីសង្ឃឹមថាធ្វើយ៉ាងនេះ ក្មេងនឹងបានជាសះស្បើយពីជំងឺរ៉ាំរ៉ៃរបស់វា ហើយវានឹងមានសុខភាពល្អ មានកម្លាំងពលំ មានប្រាជ្ញាស្មារតីល្អឡើងវិញ ។

សូមជំរាបអស់លោកអ្នកអានថា អ្វីដែលខ្ញុំបានសរសេររៀបរាប់អំពីជំនឿផ្សេងៗ ដូចពោលខាងលើនេះ គឺជាជំនឿ ជាការចំណាំ ជាប្រផ្នូលរបស់ខ្មែរនៅក្នុងស្រុកគិរីវង្ស ខេត្តតាកែវ ។ ខ្ញុំបានសាកសួរចាស់ព្រឹទ្ធាចារ្យក្នុងភូមិជាច្រើននៃឃុំតាអូរ ឃុំព្រៃអំពក ឃុំព្រៃរំដេង ឃុំព្រះបាទជាន់ជុំ អំពីការកំណត់ចំណាំផ្សេងៗ រួមជាមួយនឹងបទពិសោធន៍ ការសង្កេតផ្ទាល់ខ្លួនខ្លះៗ ។ ចំពោះជំនឿផ្សេងៗទៀត ដូចជាអំពិលអំពែកចូលផ្ទះ ក្រៀលហើរខ្ពស់យំលើអាកាស ប្រហែលជាមានប្រជាជននៅខេត្តកំពង់ធំខ្លះជឿដូចនៅខេត្តតាកែវដែរ ។ ជំនឿបុរមបុរាណ មិនមែនមានដូចគ្នាសុទ្ធសាធដូចគេចាក់ពុម្ពនោះទេ ប៉ុន្តែ វាអាចខុសប្លែកគ្នាទៅតាមតំបន់ទៅតាមស្រុកខេត្ត ។ ដូច្នេះ ប្រសិនបើអស់លោកអ្នកអាននៅតំបន់ផ្សេង ចេះដឹងអ្វីអំពីជំនឿប្រពៃណីខុសប្លែកពីនេះ សូមមេត្តាសរសេរផ្ញើទៅពុទ្ធសាសនបណ្ឌិត្យដើម្បីស្រាវជ្រាវពិនិត្យផ្ទៀងផ្ទាត់ និងចងក្រងរក្សាទុកជាឯកសារឱ្យបានច្រើនសំរាប់ឱ្យកូនចៅយើងជំនាន់ក្រោយៗ សិក្សាស្រាវជ្រាវជាបន្ត ។

ដោយ **មៀច ប៉ុណ្ណ**

# ខ្លាច

## « ខ្លាមិនខ្លាច បែរខ្លាចអាចម៍ខ្លា »

ខ្លាមិនខ្លាចទេ ទៅខ្លាចឯឃ្លេ ឮគេបន្ទាច
នេះចំជាខ្លៅ ហៅមិនអង់អាច ព្រោះខ្លាមិនខ្លាច
បែរខ្លាចអាចម៍ខ្លា ។

ខ្លាចអ្វីកំហុស ខ្លាចតែធ្វើខុស ហើយខំដោះសារ
នោះទើបពោងខ្លាច ពុំអាចកត់ត្រា ខុសដោយចេតនា
កុំស្មេហាឡើយ ។

ខ្លាចអ្វីខ្លួនស្លាប់ ព្រោះធម្មជាតិច្បាប់ លំដាប់មកហើយ
ខ្លាចតែជាតិស្លាប់ អាប់ឱនខ្សត់ខ្សោយ ខ្លួនរស់ឈ្មោះឱ្យ
អសោចីទីតេះ ។

ខ្លាចអ្វីបណ្ឌិត ខ្លាចតែគំនិត យើងពុំចង់ចេះ
ខ្លាចមួយគេប្រើ ដើររកស្វែងសេះ បើស្វែងចំណេះ
គង់ចេះមិនខាន ។

ខ្លាចអ្វីលាមក ក្លិនស្អុយគគ្រុក ប្រឡាក់អង្គប្រាណ
លាមកប្រឡាក់ ចាក់ទឹកលាងបាន ចេះត្រូវគិតល្អាន
ខ្លាចស្អុយកេរ្តិ៍ឈ្មោះ ។

ខ្លាចអ្វីសមុទ្រ គេអាចឆ្លងផុត ឥតបីមានមោះ
ខ្លាចតែមនុស្សល្ងង់ កំពុងធ្លាក់ជ្រោះ ពុំព្រមរំដោះ
ពីគ្រោះអវិជ្ជា ។

*ខ្លាចអ្វីពាក្យពិត ទិតៀនពីមិត្ត គិតជួយដល់គ្នា*
*ខ្លាចតែពាក្យក្លែង បង្វែងមាយា បីដូចផ្លែល្វា*
*ល្អឈ្មោះតែក្រៅ ។*

**ខណ្ឌ ស៊ិនហេខ**

***

ពុំមានអ្វីដែលមានឥទ្ធិពលលើបុរសទាំងឡាយ
ជាងសំឡេងរបស់ស្ត្រីភេទឡើយ

ធម្មបទ

# ពាក្យទំនៀមខ្មែរបុរាណ

( បទពាក្យប្រាំពីរ )

១. ចូរកូនចៅខ្មែរពិចារណា នូវពាក្យវាចាចាស់ព្រេងព្រឹទ្ធ
ទូន្មានណែនាំឱ្យរិះគិត ដុះដាលគំនិតពិតថ្មីថ្មើង ។

២. ដីរិសាផុងព្រយុងឈើ សត្វមានភ្លីភ្លើដើរជាន់ភ្លើង
រាជសីហ៍ខ្លបខ្លាចមនុស្សស្រុកយើង ស៊ីភ្លើងទើបចេញអស់អសារ ។

៣. បបួលដីរីឱ្យទៅផង ក្រែងមនុស្សយកខ្នងសង់គេហា
ក្រមមយំសោកបោកអាត្មា ដោយសារយកពិសពុំទាន់គេ ។

៤. សណ្ដាយសប្បាយសើចស្រួលណាស់ រយះមាត់ឡើងគ្រហ៊ោ - ហ៊ោ
ខ្មាសអស់មច្ឆាបឹងទន្លេ ព្រោះតែឃើញគេយាសយំយែក ។

៥. សម្លូត្រជាក់យកដៃលូក ដល់ក្ដៅគគុកលូកនឹងវែក
ក្ដៅណាស់ស៊ីរាក់ពន់អនេក ត្រជាក់ក្រែពេកវែងស៊ីជ្រៅ ។

៦. ឈើពុកកុំដាក់គូទអង្គុយ ត្រីស្អុយលាយឡំត្រីឆ្អាបនៅ
ក្នុងទ្រុងជាមួយយូរៗទៅ ត្រីឆ្អាបអាស្រូវស្អុយដូចគ្នា ។

៧. ទូកចេញទៅបាត់កំពង់នៅ ទទួលខុសត្រូវតាមវេរា
គេស៊ីពងអស់ឆ្អែតអាត្មា ឯងរងសោកាសំបុកមាន់ ។

៨. ពេលជំងឺរិតវែងភិតភ័យ ថាយកដីរីទៅបែបន់
ដល់ពេលជំងឺបានស្រាកស្រន់ បែរយកពងមាន់ទៅថ្វាត់ថ្វាយ ។

៩. ប្រយ័ត្នត្រីរស់រត់រួចបាត់ ហើយខំដេញស្កាត់សត្វទន្សាយ
រួចអស់ទាំងពីរក្ដៅក្រហាយ ទន្សាយក៏រួចត្រីក៏បាត់ ។

១០. ចង់សួរអន្ទង់រកផ្ទាំងវែង កុំខ្វល់ខ្វាយខ្វែងក្រែងប្រយ័ត្ន

ខ្លាចឆ្នាំងខ្លីពេកពុំអាចកាត់ ទៅជាកំណាត់សត្វអន្ទង់ ។

១១. ឃ្លោកលិចអំបែងបែរអណ្ដែត ពួកប្រេតឡើងស្ថានសួគ៌ខ្ពស់ខ្ពង់
ត្រីស៊ីស្រមោចទឹកលិចលង់ លុះទឹករោចរងរីងរាំងខះ ។

១២. ស្រមោចស៊ីវិញរិលរីងស្ងួន ស៊ីសងដូចកង់ត្រោចធ្មង់ផ្លាស់
អន្ទោលចងពៀរវាសនាផ្លាស់ ក្រឡាស់ក្រឡាប់កម្មវេរា ។

១៣. ផ្លែខ្នុរបន្លាជ្រាំងច្រូងច្រាង ខុសពីរូបរាងនៃផ្លែល្វា
មួយអាក្រក់ក្រៅ-ក្នុងសោភា រីឯផ្លែល្វាជាតែក្រៅ ។

១៤. ផ្លូវណាវៀចវាងកុំបោះបង់ រីផ្លូវណាត្រង់កុំត្រាច់ទៅ
ផ្អកផ្អើលតាមគ្នាខ្លាចផ្លែព្នៅ ត្រឡាចវារទៅល្ពៅវារមក ។

១៥. កន្លែងទំនាបថ្លុកខ្ទង់ដី ក្របីដេកដឹកកន្លែងជ្រក
ត្រង់ដែនដីដុះជាដំបូក កណ្ដៀរកៀរបូករីងរឹតខ្ពស់ ។

១៦. នេះពាក្យទំនីមទំនៀមខ្មែរ តែងទុកជាកេរពុំមានមោះ
ឱ្យកូនចៅក្រោយចេះរៀនរស់ ឱ្យមានកិត្តិយសឈ្មោះនាមល្បី ។

១៧. ពាក្យប្រៀនប្រដៅប្រៀបប្រដូច កុំមានល្បិចខូចនាំអប្រិយ
ដើរតាមគន្លងប្រពៃណី ចាស់ស្ដីឱ្យស្ដាប់ច្បាប់ឱវាទ ។

រៀបរៀងដោយ

**មៀច ប៉ុណ្ណ**

# សេចក្ដីជូនដំណឹង

## អំពីលទ្ធផលនៃចម្លើយ " កំណាព្យប្រស្នា "

គណៈកម្មការនិពន្ធទស្សនាវដ្ដីកម្ពុជសុរិយា មានកិត្តិយស សូមប្រគេនដំណឹង ចំពោះព្រះតេជព្រះគុណ និងជូនដំណឹងចំពោះ អស់លោក អ្នកនាងកញ្ញា ព្រមទាំងមិត្តអ្នកអានជាទីគោរពថា ក្នុងចំណោមចម្លើយយ៉ាងច្រើន ដែលគណៈ-កម្មការនិពន្ធបានទទួលនោះ មានចម្លើយចំនួន ២៧ ច្បាប់ ដែលត្រូវនឹងខ្លឹមសារសំណួរ ។ ចម្លើយទាំង ២៧ នោះ មានសម្ផស្សកាព្យប្រហាក់ប្រហែលគ្នា ដែលគណៈកម្មការ សម្រេចធ្វើការបែងចែកជាពីរថ្នាក់ គឺថ្នាក់ ក មានចំនួន ១២ ចម្លើយ និងថ្នាក់ ខ មានចំនួន ១៥ ចម្លើយ ។ ជ័យលាភី ថ្នាក់ ក ត្រូវបានរង្វាន់ចំនួន ១០.០០០ (ដប់ពាន់) រៀល រីឯថ្នាក់ ខ ត្រូវបានរង្វាន់ចំនួន ៥.០០០ (ប្រាំពាន់) រៀល ។

• ជ័យលាភី ថ្នាក់ ក ទាំង ១២ រូប មានរាយនាមដូចខាងក្រោម ៖

១. លោក តឹក ប៊ុនឈឿង និស្សិតមហាវិទ្យាល័យវេជ្ជសាស្ត្រ ឱសថ-សាស្ត្រ និងទន្តសាស្ត្រ ។

២. ភិក្ខុ ស៊ុំ វាសនា សមណសិស្សពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត វត្តសំពៅមាស, ភ្នំពេញ ។

៣. ភិក្ខុ ឡាក់ សុភ័ក្ត្រ ធម្មចរោ កុដិលេខ ១១ វត្តឧណ្ណាលោម, ភ្នំពេញ ។

៤. ភិក្ខុ អោម សុផុន សមណសិស្សពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ឆ្នាំទី៣ " ខ " គង់នៅវត្តបទុមវតី, ភ្នំពេញ ។

៥. ភិក្ខុ ព្រហ្ម សុជាតិ វត្តអង្គរយាប ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។

៦. ភិក្ខុ ខឹម ម៉ី ញាណុត្តរោ វត្តមហារាជដ្ឋាន ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល ។

៧. ភិក្ខុ សេង សុមុនី បទុមវង្សា សមណសិស្សពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត គង់នៅកុដិលេខ ១១ វត្តឧណ្ណាលោម, ភ្នំពេញ ។

៨. លោក ប៊ូ ចេន និស្សិតមហាវិទ្យាល័យគរុកោសល្យ ស្នាក់នៅវត្តសំរោងអណ្តែត ភ្នំពេញថ្មី, ខ័ណ្ឌឫស្សីកែវ, រាជធានីភ្នំពេញ ។

៩. ភិក្ខុ អាង ជាតិឡោម ឋានរក្ខិតោ សមណសិស្សពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត កុដិលេខ ៣ វត្តឧណ្ណាលោម, ក្រុងភ្នំពេញ ។

១០. ភិក្ខុ ខឹម រតនា សមណសិស្សពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត កុដិលេខ ១១ វត្តឧណ្ណាលោម, ភ្នំពេញ ។

១១. លោក ជា សុភឿន គរុនិស្សិត មហាវិទ្យាល័យគរុកោសល្យ ស្នាក់នៅកុដិលេខ ១១ វត្តឧណ្ណាលោម, ភ្នំពេញ ។

១២. ភិក្ខុ រិន ចន្ទ កោសលប្បញ្ញោ សមណសិស្សពុទ្ធិកបឋមសិក្សា វត្តមហាមន្ត្រី កុដិលេខ ៥ ។

• ជ័យលាភី ថ្នាក់ ១ ទាំង ១៥ រូប មានរាយនាមដូចខាងក្រោម ៖

១. ភិក្ខុ សាង សុមែន រតនសុវណ្ណោ កុដិលេខ ១១ វត្តឧណ្ណាលោម ។

២. លោក ហេង ដេត និស្សិតមហាវិទ្យាល័យអក្សរសាស្ត្រ មនុស្សសាស្ត្រ ស្នាក់នៅកុដិលេខ ២៧ វត្តបទុមវតី, ភ្នំពេញ ។

៣. ភិក្ខុ សេង ចិន្ត្រា ឧប្បលត្ថេរ គង់នៅវត្តស្លា ឃុំកំពង់ឫស្សី ស្រុកពារាំង ខេត្តព្រៃវែង ។

៤. លោក ខៀវ រិទ្ធី និស្សិតមហាវិទ្យាល័យប្រវត្តិវិទ្យា ។

៥. លោក សេង គៀន គ្រូបង្រៀននៅភូមិព្រៃមាស ឃុំកំពង់ឫស្សី ស្រុកពារាំង ខេត្តព្រៃវែង ។

៦. លោក ឈឹម ផាន់ណា និស្សិតថ្នាក់អាជីវកម្មធុនតូច នៅមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ស្នាក់នៅវត្តឧណ្ណាលោម ។

៧. លោក សុង សៀង ស្នាក់នៅវត្តបទុមវតី, ក្រុងភ្នំពេញ ។

៨. ភិក្ខុ សុខ កយ សមណសិស្សពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត វត្តឧណ្ណាលោម, ភ្នំពេញ ។

៩. ភិក្ខុ នេត ដារា សមណសិស្សបឋមសិក្សា វត្តច្រេស ឃុំស្រង៉ែ ស្រុកទ្រាំង ខេត្តតាកែវ ។

១០. ភិក្ខុ ប៉ិច សុផាត សមណសិស្ស ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ភ្នំពេញ ។

១១. ភិក្ខុ វង្ស សឿន ញាណសារោ សមណសិស្សពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រឹត, ភ្នំពេញ ។

១២. ភិក្ខុ សេង រដ្ឋា សមណសិស្សសាលាពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត គង់នៅកុដិលេខ ២៧ វត្តបទុមវតី, ភ្នំពេញ ។

១៣. អ្នកគ្រូ ឡាន់ សាម៉ុន សាស្ត្រាចារ្យអនុវិទ្យាល័យព្រៃទប់ ឃុំធ្លក ស្រុកទ្រាំង ខេត្តតាកែវ ។

១៤. ភិក្ខុ ទន់ សុតាត ធម្មរតោ នៅវត្ត គុហានគរ ឃុំពង្រ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

១៥. សាមណេរ ទួត សាម៉ុន នៅវត្ត គុហានគរ ឃុំពង្រ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

ជ័យលាភីទាំងពីរប្រភេទខាងលើ អាចនិមន្ត និងអញ្ជើញទៅទទួលយករង្វាន់ ពីបណ្ណាធិការដ្ឋាន នៃទស្សនាវដ្ដីកម្ពុជសុរិយា នៅពុទ្ធសាសនបណ្ឌិត្យ វត្តឧណ្ណាលោម ចាប់តាំងពីថ្ងៃផ្សាយដំណឹងនេះទៅ នៅរៀងរាល់ម៉ោងធ្វើការ ។

គណៈកម្មការនិពន្ធ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯឧត្ដម វណ្ណ ស៊ុនហេង អ្នកតំណាងរាស្ត្រមណ្ឌលព្រៃវែង ដែលបានជួយឧបត្ថម្ភដល់ទំព័រសំណួរ-ចម្លើយប្រស្នា របស់ទស្សនាវដ្ដីកម្ពុជសុរិយានេះ ។

# ចម្លើយកំណាព្យប្រស្នា

ចុះក្នុងទស្សនាវដ្ដីកម្ពុជសុរិយា លេខ ៣ / ១៩៩៥

គណៈកម្មការនិពន្ធ មានកិត្តិយស នឹងចុះផ្សាយអត្ថបទរបស់និស្សិត តឹក ប៊ុនឈៀង ដែលបានទទួលចំណាត់ថ្នាក់ " ក " ជាជំនួសចម្លើយរបស់ម្ចាស់សំណួរ ដែលមានសេចក្ដីដកស្រង់ ដូចខាងក្រោម ៖

*ចម្លើយកំណាព្យប្រស្នា កម្ពុជសុរិយា លេខ ៣ ឆ្នាំ ១៩៩៥*

មនុស្សយើងទាំងប្រុសស្រី រស់ពេញដីលើលោកា
តែងប្រើច្រើនភាសា ទុកចរចាគ្រាន់ទាក់ទង ។
មានបារាំងអង់គ្លេស មានម៉ាឡេមានអាល្លឺម៉ង់
អារ៉ាប់ចាមហូឡង់ មានជប៉ុនចិនកូរេ ។
សរុបលើលោកា ច្រើនក្រៃណាមិនអស់ទេ
ទោះបីប្រឹងសរសេរ អស់ច្រើនខែក៏មិនចប់ ។
ច្រើនរយពាន់ភាសា រៀនយ៉ាណាក៏មិនសព្វ
ចេះបានដល់ត្រឹមដប់ នេះប្រសប់ហើយពូកែ ។
ប្រស្នាបានចោទសួរ ជាសំណួរពីរម៉ាត់តែ
មិនចេះស្ដាប់បានដែរ មិនបាច់ប្រែអាចយល់បាន ។
ប្រស្នានេះបន្លឺ មាញរម្មណ៍គ្រប់សន្ដាន
គេប្រើគ្រប់ទីស្ថាន តើនេះបានន័យជាអ្វី ?
ភាសាតែពីរម៉ាត់ នេះរសាត់ពេញផែនដី
ទាំងក្មេងចាស់ប្រុសស្រី ស្ដាប់សំដីករីខ្ញុំ ។
ម្ចាស់ឈ្មោះ វណ្ណ ស៊ុនហេង សួរជាល្បែងល្បងអប់រំ
កម្ពុជសុរិយាផ្សំ មកផ្ដើមផ្ដុំជាអត្ថបទ ។

អ្វីទៅជាភាសា ន័យយ៉ាងណាជាប្រាកដ
គេហៅថាសន្ទត មានបែបបទតាមជាតិសាសន៍ ។
និយាយនិងសរសេរ មានសំនេរប្លែកៗណាស់
សន្ទតគ្រាន់ប្រើប្រាស់ សំនេរខ្លះស្រដៀងដែរ ។
ឯនិយាយនោះសោត ទោះបីក្រោធឬថ្នមថៃ
បញ្ចេញសំឡេងតែ យើងជាខ្មែរស្តាប់មិនបាន ។
ចិនយួនចាមប្លែកគ្នា ទោះឥណ្ឌាក៏ប្រែបាន
ប្លែកគ្នាទាំងប៉ុន្មាន គង់ដឹងបានសន្តានចិត្ត ។
ពាក្យពីរម៉ាត់និយាយ មានអត្ថន័យប្រាកដពិត
អ្នកចេះក៏មិនគិត ទោះអ្នកល្ងិតក៏នឹងយល់ ។
នោះគឺជាការ " សើច " ជាសំណើចគ្មានអំពល់
ពីចិត្តឥតខ្វាយខ្វល់ មិនរវល់នឹងទុក្ខា ។
សំណើចសើចក្អាកក្អាយ យ៉ាងសប្បាយគ្រប់អាត្មា
ទោះជាតិសាសន៍ណាៗ ចេញភាសាសើចដូចគ្នា ។
ឯពាក្យមួយផ្សេងទៀត សូមញោមញាតិស្តាប់គ្រប់គ្នា
សំដែងកម្មវេរា ទុក្ខវេទនាជាប្រចាំ ។
នោះហើយហៅថា " យំ " គ្រប់និគមអាចចំណាំ ។
ទួញយំសោកផ្តែផ្តាំ អាចចងចាំក្នុងជីវិត ។
ទោះសើចឬក៏យំ តូចឬធំឆ្ងាយឬជិត
ក៏តង់តែគំនិត យល់យ៉ាងពិតគ្រប់ៗគ្នា ។
ទោះអង់គ្លេសចិនចាម ទោះវៀតណាមបារាំងជ្វា
អេស្ប៉ាញឡាវភូមា ស្រីលង្កាសៀមស៊ុីរី ។

ហូឡង់ខ្មែរកូរ៉េ ស៊ីសម៉ាឡេទាំងហុងគ្រី
ប៉ូឡូញប៊ុលការី អារ៉ាប៊ីអ៊ីស្រាអែល ។
ជាតិសាសន៍មានច្រើនណាស់ មានសល់ខ្លះកេរដំណែល
ចេះឃុំចេះសើចដែល ដឹងប្រហែលចេះគ្រប់គ្នា ។
ខ្ញុំរៀបរាប់ប៉ុណ្ណេះ តាមខ្ញុំចេះតាមប្រាជ្ញា
ខ្ញុំរៀនសូត្រសិក្សា ឆ្លើយប្រស្នាចាយ៉ាងនេះ ។
" ឃុំ " " សើច " ជាចម្លើយ ដែលត្រូវឆ្លើយជាពិសេស
រៀនរៀបរៀងរើរេះ ចែងជូនធ្មេះចេះតាមក្បួន ។
ពេលនេះកវីខ្ញុំ សូមបង្គំបន្ទាបខ្លួន
សូមបានពរទាំងបួន សូមជួបជួនគ្រប់អាត្មា ។
សូមឱ្យសន្តិភាព លើវាលរាបក្នុងលោកា
ជៀសផុតសង្គ្រាមណា មានមេត្តាបានសុះសាយ ។
សូមឱ្យសាសនាពុទ្ធ បានរួចផុតពីអន្តរាយ
នៅជាងពីរពាន់ឆ្នាយ បានយូរឆ្ងាយដល់ប្រាំពាន់ ។
លោកអ្នកនិងរូបខ្ញុំ ជួបសុខុមផុតទោសទណ្ឌ
ដល់សាសនាគ្រប់គ្រាន់ ព្រះមានបុណ្យប្រោសទេសនា ។
សូមបានស្តាប់ព្រះធម៌ ថ្លៃបវរក្នុងលោកា
សូមសម្រេចធម៌អាថ៌ រួចទុក្ខាផុតអវិចី ។
បានផុតអបាយបួន បានរួចខ្លួនផុតចង្រៃ
បានសុខរៀងរាល់ថ្ងៃ ផុតទុក្ខភ័យនិព្វានហោង ។

**គីក ប៊ុនឈឿន**

# កំណាព្យប្រស្នា

## បទព្រហ្មគីតិ

* ព្រហ្មគីតិគិតស្រដី ពីពួកត្រីនៅក្នុងទឹក មានច្រើនជាពន្លឹក
ទឹកសាបប្រែរាប់ពុំអស់ ។

* គាល់រាំងឆ្មោសណ្តាយ កែសក្លាំងឆ្មាយលេញរៀលរ៉ស់ អណ្តែងក្រឹមក្រាញ់ក្រុស
ឆ្លាំងកញ្ចុះកញ្ចោក់ស្លា ។

* ធម្មជាតិកើតទឹកមក ទីជម្រកនៃមច្ឆា អត់ទឹកត្រីមរណា
សូន្យសង្ខារពុំរស់ឡើយ ។

* បើទឹកនោះត្រជាក់ ត្រីពីងពាក់កាន់ច្រើនហើយ ទឹកក្តៅមិនមានស្បើយ
ពុំនៅឡើយត្រីប្រាសប្រាណ ។

* ត្រីមួយឫទ្ធិក្លាខ្លាំង អាចតតាំងកំដៅបាន ទោះទឹកពុះប៉ុន្មាន
វារស់បានមិនស្លាប់អី ។

* ប្រស្នាការកំសាន្ត សួរសន្តានទាំងប្រុសស្រី ត្រីនោះមានឈ្មោះអ្វី
ខ្លួនវែងខ្លីធំប៉ុណ្ណា ?

* ម្តេចខ្លាំងអាចស្មាញស្ទុះ ទឹកក្តៅពុះហែលហានក្លា ខុសពីសព្វមច្ឆា
សូមដោះសាប្រាប់ខ្ញុំផង ។

២៤ - ០៤ - ១៩៩៦

**ចណ្ណ ស៊ុនហេង**

# ការបែងចែកគម្ពីរព្រះត្រៃបិដក

(ត)

ឆ) នៅក្នុងខេត្ត បាត់ដំបង វត្តចំនួន ៦៥ បានទទួល ១ ចប់ ក្នុងមួយវត្ត ត្រូវជា ៦៥ ចប់ (សេចក្ដីសំរេចលេខ ១៩៦ / ៩៥ ចុះថ្ងៃទី ២៨ ខែកញ្ញា ១៩៩៥) ដូចខាងក្រោម :

១. វត្ត ស្លាកែត (មេគណ)
២. វត្ត ខ្វេង (អនុគណ)
៣. វត្ត ពោធិវាល (អនុគណ)
៤. វត្ត បាណន់លើ (អនុគណ)
៥. វត្ត កែវ (អនុគណ)
៦. វត្ត វេឡុវនេរាម (អនុគណ)
៧. វត្ត បវេល (អនុគណ)
៨. វត្ត ជ្រោយម្ទេស (អនុគណ)
៩. វត្ត បឹងអំពិល (អនុគណ)
១០. វត្ត អន្លង់វិល
១១. វត្ត ទួលតាឯក
១២. វត្ត ពិភិទ្ធារាម
១៣. វត្ត សំរោងក្នុង
១៤. វត្ត សុរិយា
១៥. វត្ត បាយដំរាំ
១៦. វត្ត រូងជ្រៃ
១៧. វត្ត ឈើទាល
១៨. វត្ត អណ្ដើក
១៩. វត្ត ខ្នាតរមាស
២០. វត្ត កណ្ដាល " ស្វាយប៉ោ "
២១. វត្ត គោកឃ្មុំ
២២. វត្ត សោមនស្ស
២៣. វត្ត ភ្នំសំពៅ
២៤. វត្ត កំផែង
២៥. វត្ត កណ្ដាល " សង្កែ "
២៦. វត្ត ព្រៃស្វាយ
២៧. វត្ត ពោធិក្នុង
២៨. វត្ត ស្នោ
២៩. វត្ត គោកក្ដួច
៣០. វត្ត ស្ទឹង
៣១. វត្ត ខ្សាច់ពោយ
៣២. វត្ត សង្កែវារ
៣៣. វត្ត រកា
៣៤. វត្ត ល្វា

៣៥. វត្ត រឿងរង្សី
៣៦. វត្ត បឹងរាំង
៣៧. វត្ត អូរតាតី
៣៨. វត្ត ស្វាយជ្រំ
៣៩. វត្ត បុប្ផាវតី
៤០. វត្ត ព្រៃតូច
៤១. វត្ត ជ្រោយស្ដៅ
៤២. វត្ត កំពង់សីមា
៤៣. វត្ត ដីរស
៤៤. វត្ត កោះទីមសុទ្ធា
៤៥. វត្ត អង្គ្រង
៤៦. វត្ត ឯកសុវណ្ណ
៤៧. វត្ត បញ្ញា
៤៨. វត្ត សំពៅ
៤៩. វត្ត ពោធិវណ្ណារាម
៥០. វត្ត ស្វាយធំ
៥១. វត្ត ក្តាំងងារ
៥២. វត្ត ព្រៃកល្វេង
៥៣. វត្ត តាប៉ុន
៥៤. វត្ត តាមឹម
៥៥. វត្ត ព្រះពន្លា
៥៦. វត្ត តាក្រាម
៥៧. វត្ត កែងមុនីរាម
៥៨. វត្ត រាំងកេសី
៥៩. វត្ត បាណោក
៦០. វត្ត បុទមបេង
៦១. វត្ត ត្រង់ពិសី
៦២. វត្ត ស្លក្រាម
៦៣. វត្ត ពោធិលង្កា
៦៤. វត្ត ស្វាយព្រៃ
៦៥. វត្ត ទីយវនារាម

ជ) នៅក្នុងខេត្ត ស្វាយរៀង ចំនួនវត្ត ៤២ បានទទួល ១ ចប់ ក្នុងមួយវត្ត ត្រូវជា ៤២ ចប់ ( សេចក្តីសំរេចលេខ ២១០ - ១៩៩៥ ក.ធ.ស ចុះថ្ងៃទី ០៦ ខែ តុលា ១៩៩៥ ) ដូចខាងក្រោម :

១. វត្ត ជម្ពូព្រឹក្សា (មេគណ)
២. វត្ត ចេក (អនុគណ)
៣. វត្ត ត្រពាំងគ្រួស (អនុគណ)
៤. វត្ត ព្រៃខ្លួត (អនុគណ)

| | |
|---|---|
| ៥. វត្ត ខ្នាយ (អនុគណ) | ២៤. វត្ត ព្រៃអង្គុញ |
| ៦. វត្ត ស្វាយតាសាន (អនុគណ) | ២៥. វត្ត ពោធិថ្មី |
| ៧. វត្ត សន្តិភាព (អនុគណ) | ២៦. វត្ត ព្រៃកដើមជ្ជប |
| ៨. វត្ត ថ្មី (អនុគណ) | ២៧. វត្ត ចំបក់ធំ |
| ៩. វត្ត ជ្រាង | ២៨. វត្ត សិរីវង្ស |
| ១០. វត្ត តាស្វស | ២៩. វត្ត សុវណ្ណរាម |
| ១១. វត្ត ស្លា | ៣០. វត្ត ពោធិបដ្ឋាន |
| ១២. វត្ត តាជ័យ | ៣១. វត្ត ពេជ្រមន្ត្រី |
| ១៣. វត្ត ស្វាយជ្រំ | ៣២. វត្ត សាមគ្គីរង្សី |
| ១៤. វត្ត ល្វើន | ៣៣. វត្ត ព្រៃអង្គ |
| ១៥. វត្តបឹងរ៉ៃ | ៣៤. វត្ត ត្រពាំងសាន |
| ១៦. វត្ត ចារ | ៣៥. វត្ត ក្តីកណ្តាល |
| ១៧. វត្ត ប្រា | ៣៦. វត្ត កោះអណ្តែត |
| ១៨. វត្ត ទួលសុក្រម | ៣៧. វត្ត ភ្នំស្រេវ |
| ១៩. វត្ត អំពិលពោធិធំ | ៣៨. វត្ត ព្រៃត្នាន់ |
| ២០. វត្ត ស្វាយទទ្ទឹម | ៣៩. វត្ត ពោធិឧត្តម |
| ២១. វត្ត ចន្ត្រី | ៤០. វត្ត ផ្កា |
| ២២. វត្ត ត្រពាំងជ្រឹង | ៤១. វត្ត ថ្មាធ្នង់ |
| ២៣. វត្ត អំពិល | ៤២. វត្ត កំពង់អំពិល |

ឈ) នៅក្នុងក្រុងព្រះសីហនុ វត្តចំនួន ៩ បានទទួល ១ ចប់ ក្នុងមួយវត្ត ត្រូវជា ៩ ចប់ ( សេចក្តីសំរេចលេខ ១៨៨ . ១៩៩៥ ក.ធ.ស ចុះថ្ងៃទី ១៩ ខែ កញ្ញា

ឆ្នាំ ១៩៩៥ ) ដូចខាងក្រោម ៖

១. វត្ត ជោតញ្ញាណ
២. វត្ត ឥន្ទញ្ញាណ
៣. វត្ត ពោធិមានជ័យ
៤. វត្ត ព្រៃនប់
៥. វត្ត មុនីសាលព្រឹក្ស
៦. វត្ត វាលមាស
៧. វត្ត តានៃ
៨. វត្ត សាវ៉ាយ
៩. វត្ត ស្នាច់ដែង

ញ) នៅក្នុងក្រុងកែប - បូកគោ វត្តចំនួន ៤ បានទទួល ១ ចប់ ក្នុងមួយវត្ត ត្រូវជា ៤ ចប់ ( សេចក្តីសំរេចលេខ ២២១ - ១៩៩៥ ក.ធ.ស ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៥ ) ដូចខាងក្រោម ៖

១. វត្ត កែវក្រសាំង
២. វត្ត ភ្នំលាវ
៣. វត្ត ព្រៃតាកុយ
៤. វត្ត កំពង់ត្រឡាច

*( នៅមានតទៅខេត្តផ្សេងទៀត )*

# បេសកកម្ម

របស់លោក យី ធន់ ទីប្រឹក្សាអមក្រសួងធម្មការ និងសាសនា
នៅទីក្រុង ឡាហ័រ សាធារណរដ្ឋអ៊ិស្លាម ប៉ាគីស្ថាន
ពីថ្ងៃ០១ ដល់ថ្ងៃ ០៨ មករា ឆ្នាំ ១៩៩៦

---

តាមសេចក្ដីអញ្ជើញរបស់អង្គការមូលនិធិ ហៃនរិសបីល និងតំណាងរបស់អង្គការនេះនៅអាស៊ី ដែលមានទីស្នាក់ការនៅទីក្រុងឡាហ័រ ប្រទេសប៉ាគីស្ថាន ព្រមទាំងដោយបានទទួលសេចក្ដីអនុញ្ញាតពីក្រសួងធម្មការ និងសាសនាផង ខ្ញុំបានទៅចូលរួមប្រជុំជាមួយដៃគូទាំងឡាយ ដែលកំពុងអនុវត្តគម្រោងការផ្សេងៗ ជាមួយអង្គការ ហៃនរិសបីល នៅទីក្រុង ឡាហ័រ ចាប់ពីថ្ងៃទី ០៤ ដល់ថ្ងៃទី ០៧ ខែមករា ឆ្នាំ ១៩៩៦ ។

ដោយនៅក្រុងភ្នំពេញ ពុំទាន់មានស្ថានទូតប៉ាគីស្ថាន ខ្ញុំត្រូវចេញដំណើរពីទីក្រុងភ្នំពេញ តាំងពីថ្ងៃទី ០១ មករា ឆ្ពោះទៅទីក្រុងបាងកក ដែលនៅទីនោះខ្ញុំត្រូវឈប់សំរាក ១ ថ្ងៃ ដើម្បីសុំទិដ្ឋាការពីស្ថានទូតប៉ាគីស្ថាន ប្រចាំក្រុងបាងកក ។

នៅយប់ថ្ងៃទី ០២ មករា ១៩៩៦ ខ្ញុំបានចេញដំណើរពីទីក្រុងបាងកកឆ្ពោះទៅប្រទេសប៉ាគីស្ថាន ហើយបានទៅដល់ក្រុងឡាហ័រ នៅម៉ោង ១២ យប់ថ្ងៃដដែល ។ នៅទីនោះ ខ្ញុំត្រូវបានអ្នកស្រី រ៉ូសាន់ ដុនជីបហ្វូយ ដែលជាតំណាងអង្គការ ហៃនរិសបីល ប្រចាំទ្វីបអាស៊ី ទទួលស្វាគមន៍យ៉ាងកក់ក្ដៅ ។

គណៈប្រតិភូទាំងអស់ដែលត្រូវចូលរួមក្នុងអង្គប្រជុំនោះ ត្រូវបានគេនាំទៅឱ្យស្នាក់នៅក្នុងសណ្ឋាគារដ៏បុរាណមួយឈ្មោះ ហ្វាឡេតទី នៃទីក្រុង ឡាហ័រ ។ នៅក្នុងការរង់ចាំការញ្ជើញមកដល់នៃគណៈប្រតិភូ នៃប្រទេសផ្សេងៗ គណៈប្រតិភូ

ដែលទៅដល់ក្រុង ឡាហ័រមុនគេ ក្នុងនោះមានគណៈប្រតិភូពីកម្ពុជាផងដែរ ត្រូវបានគេនាំឱ្យទៅធ្វើទស្សនកិច្ចនៅតាមមជ្ឈមណ្ឌលវប្បធម៌នានា របស់ទីក្រុងឡាហ័រ ។

នៅថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៦ អង្គប្រជុំបានប្រព្រឹត្តទៅយ៉ាងឧឡារិក នៅនាសណ្ឋាគារ ហូលីដេអិន ដោយមានដៃគូគម្រោងរបស់អង្គការ ហែននិសបីល មកពីប្រទេសនានា គឺ :

១- ប្រទេសប៉ាគីស្ថាន :

. មានសមាជិក ៤ រូប មកពីសាខាមូលនិធិ ហែននិសបីល នៅទីក្រុងឡាហ័រ ដឹកនាំដោយអ្នកស្រី រ៉ូសាន់ ដុនជិបហួយ ។

. សមាជិក ៤ រូបទៀត មកពីអង្គការសៀកកាតបាគស ដែលដឹកនាំដោយអ្នកស្រី ហ្វារីដា សាហ៊ិត ។

. និង ៣ រូបទៀត មកពីអង្គការមូលនិធិ អៅរ៉ាត ដែលដឹកនាំដោយលោក ឆាល អាមសាតអាលី ។

២- ប្រទេសអាល្លឺម៉ង់ :

មានលោកបណ្ឌិត ម៉ាឌីល បូម៉ាន់ តំណាងមូលនិធិ ហែននិសបីល និងលោកស្រី អង់ហ្គែលលិកា ភូស្ទ័រ សមាជិកសភា និងជាតំណាងអង្គការបោននីស ៩០ បៃតង ។

៣- ប្រទេសបង់ក្លាដែស មានគណៈប្រតិភូបីក្រុមដែរគឺ :

ក/ លោក ស៊ីស៊ី ទុត្តៈ តំណាងវិទ្យាស្ថានសិល្បៈ ល្ខោន,

ខ/ លោក កាស៊ី ខាហ្សេ អាឡាំ តំណាងអង្គការប្រូស៊ីកា,

គ/ អ្នកស្រី រ៉ូកេយ៉ា កាបៀ តំណាងអង្គការនារីប្រូគតិសង្ឃ,

៤- ប្រទេសថៃឡង់ មានតំណាងអង្គការ ៣ គឺ :

ក/ លោក ប្រាផា ហុតានុវត្រ, កញ្ញា សុបត្រា និងភិក្ខុ ទីមាន សំរួយ មកពីអង្គការអាស្រម,

ខ/ លោក វិធូន បន្យាកុល មកពីអង្គការមិត្រនៃប្រជាជន,

គ/ លោក សីរី សុវណ្ណ កួនកចន មកពីអង្គការគម្រោងស្រោចស្រង់បរិដ្ឋាន,

៥- ព្រះរាជាណាចក្រកម្ពុជា មាន :

ក/ បណ្ឌិត ហៃគ័រ ឡូសម៉ាន់ ទីប្រឹក្សារបស់គម្រោង ហៃនរិសបឺល នៅកម្ពុជា,

ខ/ លោក ឃីធន់ តំណាងពុទ្ធសាសនបណ្ឌិត្យ,

គ/ បណ្ឌិត ហោម៉ា គុណាតាលិកេ ទីប្រឹក្សាគម្រោងនៅកម្ពុជា,

ឃ/ អ្នកស្រី ចន្ទ សុប៊ុនណារី តំណាងសមាគមដូនជី,

មិនបានចូលរួមក្នុងអង្គប្រជុំលើកទី ២ នៃដៃគូគម្រោងរបស់អង្គការ ហៃនរិសបឺល នេះមាន :

១. តំណាងប្រទេសឥណ្ឌា,

២. តំណាងគម្រោងនៅសាធារណរដ្ឋសង្គមនិយមវៀតណាម,

៣. តំណាងអង្គការអភិវឌ្ឍន៍សង្គមជនបទ នៅកម្ពុជា,

៤. តំណាងដៃគូគម្រោងនៃប្រទេសភូមា,

របៀបវារៈនៃអង្គប្រជុំ នៅថ្ងៃទីមួយមាន :

១. របាយការណ៍ ស្តីអំពីសកម្មភាពរបស់សាខាមូលនិធិ ហៃនរិសបឺល នៅ អាស៊ី ,

២. របាយការណ៍របស់ដៃគូគម្រោង ។

ជាកិច្ចចាប់ផ្ដើមបើកកម្មវិធី អ្នកស្រី រ៉ូសាន់ តំណាងសាខាអង្គការ ហៃនរិសបីល ប្រចាំអាស៊ី បានថ្លែងអំពីសកម្មភាពនានារបស់សាខា ក្នុងរយះពេលមួយឆ្នាំ ១៩៩៥ ដែលបានប្រព្រឹត្តទៅដោយជោគជ័យ ។ បន្ទាប់មក អ្នកស្រីបានសុំឱ្យតំណាងដៃគូទាំងអស់ ធ្វើរបាយការណ៍ជាបន្តបន្ទាប់ អំពីសកម្មភាពការងាររបស់គម្រោងនីមួយៗ ដោយចាប់ផ្ដើមពីប្រទេសថៃឡង់, ប្រទេសប៉ាគីស្ថាន, ប្រទេសបង់ក្លាដែស និងក្រោយគេបំផុតគឺ ប្រទេសកម្ពុជា ។

នៅក្នុងឱកាសនោះ ខ្ញុំតំណាងឱ្យពុទ្ធសាសនបណ្ឌិត្យ បានជំរាបជូនអង្គប្រជុំ អំពីស្ថានភាពទូទៅនៃដំណើរការស្តារឡើងវិញផ្នែកពុទ្ធសាសនា ពុទ្ធសាសន-សិក្សាធិការ និងពុទ្ធសាសនបណ្ឌិត្យ នៅកម្ពុជា ដែលទទួលបានលទ្ធផលល្អគួរជាទីពេញចិត្ត ទោះបីនៅក្នុងផ្នែកខ្លះយើងកំពុងជួបប្រទះការលំបាកដោយសារកង្វះខាតខាងធនធានមនុស្ស ខាងថវិកា និងសម្ភារះក៏ដោយ ។ នៅទីចុងបំផុត ខ្ញុំបានសុំឱ្យអង្គការ ហៃនរិសបីល បន្តជួយដល់ពុទ្ធសាសនបណ្ឌិត្យ មួយរយះទៀត ។ ចំពោះសំណូមពរនេះ អង្គការហៃនរិសបីល មិនទាន់បានឆ្លើយតបនៅឡើយ ព្រោះអង្គការនេះ ត្រូវបញ្ចូលទៅក្នុងអង្គការរួមតែមួយ ជាមួយអង្គការថ្មីមួយទៀត ដែលមានឈ្មោះថា អង្គការបៃតង ។

នៅថ្ងៃបន្ទាប់ អង្គប្រជុំបានស្ដាប់របាយការណ៍របស់ដៃគូគម្រោង នៃប្រទេសវៀតណាម - ភូមា ព្រមទាំងលិខិតរបស់ដៃគូគម្រោងរបស់ប្រទេសឥណ្ឌា ដែលមិនបានទៅចូលរួម ដោយមកពីភាពតានតឹងផ្នែកនយោបាយ រវាងប្រទេសប៉ាគីស្ថាន និងឥណ្ឌា ។

បន្ទាប់មកទៀត អង្គប្រជុំបានស្ដាប់របាយការណ៍របស់លោក ម៉ែឌីល ប៊ូម៉ាន់ ដែលជាតំណាងរបស់មូលនិធិ ហៃនរិសបីល នៅប្រទេសអាល្លឺម៉ង់ អំពីទិស

ដៅទៅអនាគតរបស់និន្នាការនយោបាយរបស់ប្រទេសអាល្លឺម៉ង់ ចំពោះអង្គការនានារបស់ប្រទេសអាល្លឺម៉ង់ ដែលកំពុងធ្វើសកម្មភាពនៅក្រៅប្រទេស ។

បន្ទាប់មក លោកស្រី អង់ហ្គែលីកា សមាជិកសភាអាល្លឺម៉ង់ និងជាតំណាងរបស់អង្គការ បៃតង បានជំរាបអង្គប្រជុំ អំពីបំណងរបស់សភាអាល្លឺម៉ង់ ក្នុងការបង្រួមអង្គការទាំងឡាយបញ្ចូលគ្នា ជាអង្គការតែមួយ ហៅថាអង្គការបៃតង ។ អ្នកនយោបាយអាល្លឺម៉ង់ មានបំណងកាត់បន្ថយចំណាយផ្សេងៗរបស់សាខានានានៃអង្គការទាំងឡាយ ដែលកំពុងធ្វើសកម្មភាពនៅអាស៊ី អាហ្វ្រិក អាមេរិកខាងត្បូង អាមេរិកកណ្តាល ។ លោកស្រីបានបន្ថែមថា ទៅអនាគត គេត្រូវបន្ថែមសាខារបស់អង្គការបៃតង ឱ្យបានច្រើននៅក្នុងទ្វីបនីមួយៗ ប៉ុន្តែ ត្រូវប្រើធនធានមនុស្សក្នុងស្រុកវិញ ដើម្បីបន្ថយចំណាយ ព្រោះបើបញ្ជូនមនុស្សពីប្រទេស អាល្លឺម៉ង់ មក នោះ ត្រូវចំណាយអស់ថវិកាច្រើនសំរាប់ចំណាយ ទាំងខាងរដ្ឋបាល ទាំងខាងបៀវត្ស ទាំងខាងទីកន្លែងស្នាក់អាស្រ័យ ។ ល ។

នៅក្នុងឱកាសនោះដែរ លោកស្រីបានសុំឱ្យសមាជិកនៃអង្គប្រជុំគ្រប់ប្រទេស ជួយឱ្យយោបល់ចំពោះការចាត់តាំងជាថ្មីនៃអង្គការ អំពីរបៀបរបបធ្វើការ និងទំនាក់ទំនងរវាងផ្នែកខាងជើង និងខាងត្បូង គឺ រវាងអង្គការកណ្តាល នៅប្រទេសអាល្លឺម៉ង់ និងដៃគូគម្រោងនៅតាមប្រទេសនានា នៅទ្វីបអាស៊ី ។

នៅវេលារសៀលនៃថ្ងៃដដែល សមាជិកអង្គប្រជុំបានពិភាក្សាយ៉ាងល្អិតអំពីតួនាទី និងភារកិច្ចរបស់សាខាអង្គការថ្មី ប្រចាំភូមិភាគទៅអនាគត ព្រមទាំងបានធ្វើសំណូមពរជាច្រើនទៅអង្គការកណ្តាល ឱ្យសម្រួលដល់ការងារដៃគូគម្រោងទៀតផង ។ អ្នកតំណាងជាន់ខ្ពស់ ដែលមកពីប្រទេសអាល្លឺម៉ង់ ទាំងពីររូប បានទទួលសំណូមពរទាំងអស់របស់ដៃគូគម្រោង ដើម្បីរាយការណ៍ជូនគណៈកម្មការកណ្តាលវិញ ។

នៅថ្ងៃទី ៣ អង្គប្រជុំបានធ្វើកិច្ចពិភាក្សាបន្ត អំពីការចាត់តាំងបណ្តាញការងាររបស់អង្គការ អេរិច និងពិភាក្សាអំពីការបែងចែកថវិកាដែលនៅសល់សំរាប់ប្រើប្រាស់ក្នុងឆ្នាំ ១៩៩៦ ។

អង្គប្រជុំបានបញ្ចប់នៅល្ងាចថ្ងៃទី ០៧ មករា វេលាម៉ោង ៥ ល្ងាច ក្នុងស្មារតីសាមគ្គី យោគយល់គ្នាទៅវិញទៅមក ដោយស្មោះអស់ពីចិត្តគ្រប់ៗគ្នា ។

បន្ទាប់ពីពិធីលៀងសាយភោជន៍ បិទអង្គប្រជុំ នៅថ្ងៃទី ០៧ មករា ដដែល ខ្ញុំបានចេញដំណើរទាំងយប់ ពីទីក្រុងឡាហ៊័រ ឆ្ពោះមកមាតុប្រទេសវិញ ហើយបានមកដល់រាជធានីភ្នំពេញ នៅថ្ងៃចន្ទ ទី ០៨ មករា ១៩៩៦ វេលាថ្ងៃត្រង់ ដោយសុវត្ថិភាព ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី ០៨ មករា ១៩៩៦

# គណៈប្រតិភូអង្គការជំនួយសូតូស៊ូជប៉ុន ( ជី.អេស.អ.ស៊ី. ) ចូលរួមក្នុងពិធីចែកគម្ពីរព្រះត្រៃបិដក នៅខេត្តសៀមរាប



កាលពីថ្ងៃអង្គារទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ គណៈប្រតិភូជប៉ុន នៃអង្គការសូតូស៊ូ សាខានៅជីបា - ចំនួន ១១ រូប ដែលដឹកនាំដោយព្រះតេជព្រះគុណ កូណូតៃ ត្សឺ ចៅអធិការវត្ត ស៊ីយូហ៊ូគុ-ជិ និកាយ ហ្សិន និងជាប្រធាននៃមហាវិទ្យាល័យហាណាហ្សូណូ ក្រុងកូបេ ប្រទេសជប៉ុន និងព្រះតេជព្រះគុណ មូចាគូ សិក្យូ ប្រធានគណៈកម្មការបោះពុម្ពឡើងវិញ នៃព្រះត្រៃបិដកភាសាខ្មែរ បានអញ្ជើញទៅចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់គម្ពីរព្រះត្រៃបិដកចំនួន ៤៧ ចប់ ចំពោះព្រះសង្ឃ និង

វត្តចំនួន ៤៧ នៅខេត្តសៀមរាប ។

ពិធីចែកបានប្រារព្ធឡើង នៅវេលារសៀលថ្ងៃអង្គារទី ២០ កុម្ភៈ ១៩៩៦ ត្រូវនឹងថ្ងៃ ២ កើត ខែ ផល្គុន ឆ្នាំ កុរ សប្តស័ក ព.ស. ២៥៣៩ នៅក្នុងបរិវេណព្រះវិហារព្រះអង្គចេក ព្រះអង្គចម នាក្រុងសៀមរាប ។ ចូលរួមជាអធិបតីក្នុងឱកាសនោះ ខាងជប៉ុន គេសង្កេតឃើញមាន លោក តេហ៊្សុកា កូជិ ប្រធានអង្គការ ជី អេស អ ស៊ី ប្រចាំក្រុងភ្នំពេញ, ខាងភាគីកម្ពុជា មានព្រះតេជព្រះគុណមេគណខេត្តសៀមរាប និងព្រះតេជព្រះគុណអនុគណគ្រប់ស្រុក ឯកឧត្តម ឈន អៀម អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ឯកឧត្តម ហែម ប៊ុនហេង អភិបាលរងទី ២ ឯកឧត្តម កង ប៉ាង អភិបាលរងទី ៣ នៃខេត្តសៀមរាប លោក យី ធន់ ទីប្រឹក្សាអមក្រសួងធម្មការ និងសាសនា ។ ក្រៅពីនេះ គេឃើញមានព្រះសង្ឃ មន្ត្រីរាជការគ្រប់មន្ទីរជុំវិញខេត្ត សិស្សានុសិស្ស និងពុទ្ធបរិស័ទរាប់ពាន់នាក់ បាននិមន្ត និងអញ្ជើញចូលរួមយ៉ាងណែនណាន់តាន់តាប់ អធិអធម ។

នៅវេលាម៉ោង ១៣និង៣០នាទីរសៀល ក្បួនដង្ហែគម្ពីរដែលមានរថយន្តតូច ធំជាង ១០០ គ្រឿង និងមានមហាជនជាពុទ្ធបរិស័ទជាង ១ ពាន់នាក់ បានចេញដំណើរសន្សឹមៗ ពីទីលានក្ការបែន មុខប្រាសាទអង្គរវត្ត ដោយមានក្បួនកងអាវុធហត្ថ និងនគរបាលជាអ្នកនាំមុខ ឆ្ពោះមករកទីរួមខេត្តសៀមរាប លើផ្លូវដែលមានចម្ងាយប្រមាណ ៦ គ.ម ។

នៅវេលាម៉ោង ១៥ ក្បួនដង្ហែបានចូលមកដល់កន្លែងប្រារព្ធពិធី ដោយមានស្នូរសំឡេងព្រះធម៌ និងភ្លេងពិណពាទ្យកំដរយ៉ាងរងំ ។ ព្រះអង្គមេគណខេត្ត និងឯកឧត្តមអភិបាលខេត្តរង ហែម ប៊ុនហេង និងឯកឧត្តម កង ប៉ាង បាននាំក្បួនថ្មើរជើងនាំព្រះគម្ពីរទាំង ៤៧ ចប់ ចូលទៅតម្កល់នៅចំពោះព្រះភក្ត្រព្រះអង្គចេក ព្រះអង្គចម ដែលជាទីសក្ការៈសក្តិសិទ្ធិ របស់ប្រទេសកម្ពុជា ។

នៅពេលគណៈអធិបតី ភ្ញៀវកិត្តិយស ព្រមទាំងពុទ្ធបរិស័ទបានចូលកាន់ទីកន្លែងរៀបរយហើយ ពិធីប្រគល់ និងទទួលគម្ពីរ ក៏ចាប់ផ្តើមឡើង ដោយមានព្រះសង្ឃខ្មែរសូត្រធម៌ជយន្តោ រួចព្រះសង្ឃជប៉ុនក៏សូត្រធម៌ ដើម្បីសន្តិភាពដែរ ។ បន្ទាប់ពីជូនជីមួយក្រុមបានសូត្របទសរភញ្ញ មក លោកនាយកមន្ទីរធម្មការ និងសាសនាខេត្តសៀមរាប បានឡើងថ្លែងសុន្ទរកថា រៀបរាប់អំពីស្ថានភាពពុទ្ធសាសនានៅខេត្តសៀមរាប ព្រមទាំងបញ្ជាក់អំពីសេចក្តីត្រូវការចាំបាច់នៃគម្ពីរព្រះត្រៃបិដកដើម្បីទុកប្រើជាមូលដ្ឋាននៃការប្រតិបត្តិព្រះពុទ្ធសាសនា នៅនាពេលបច្ចុប្បន្នរបស់ព្រះសង្ឃ និងពុទ្ធបរិស័ទក្នុងខេត្ត ។

នៅក្នុងឱកាសនោះដែរ ព្រះតេជព្រះគុណ កូណូ តៃត្សឹ ប្រធានគណៈប្រតិភូនៃអង្គការ សូតូស៊ូ ជប៉ុន បានឡើងថ្លែងសុន្ទរកថាប្រកបដោយសារសំខាន់យ៉ាងជ្រាលជ្រៅ ដែលមានខ្លឹមសារជាអាទិ៍ថា :

គណៈប្រតិភូនៃអង្គការ សូតូស៊ូ ជប៉ុន មានកិត្តិយសសូមថ្លែងនូវកតញ្ញុ-តាធម៌ដ៏ជ្រាលជ្រៅប្រកបដោយសេចក្តីសោមនស្សរីករាយឥតឧបមា ដែលបានមកប្រគេន - ជូន នូវគម្ពីរព្រះត្រៃបិដកជាលើកចុងក្រោយបំផុត ចំពោះព្រះតេជព្រះគុណ ចំពោះអស់លោកទាំងអស់នៅក្នុងខេត្តសៀមរាបដ៏ល្បីល្បាញនាពេលនេះ ។ ព្រះតេជព្រះគុណ កូណូ បានសង្កត់ធ្ងន់ថា : ព្រះត្រៃបិដក គឺជាគម្ពីរដែលមានសារ-សំខាន់បំផុត និងជាមូលដ្ឋានគ្រឹះនៃព្រះធម៌របស់ព្រះពុទ្ធ មិនមែនសំរាប់តែអ្នកកាន់ព្រះពុទ្ធសាសនាប៉ុណ្ណោះទេ ប៉ុន្តែចំពោះមនុស្សជាតិទាំងមូល ។ ប៉ុន្តែ គួរឱ្យស្តាយណាស់ នៅប្រទេសកម្ពុជា មានកើតសោកនាដកម្មមួយយ៉ាងសាហាវឃោរឃៅហើយព្រះត្រៃបិដកក៏ត្រូវបំផ្លាញដោយសង្គ្រាមដែរ ។

ព្រះតេជព្រះគុណ កូណូ បានរៀបរាប់ថា : នៅក្នុងឆ្នាំកន្លងទៅនេះ គឺក្នុងឆ្នាំ ១៩៩៤ ដោយមានសេចក្តីអំពាវនាវរបស់ព្រះតេជព្រះគុណ មូចាគូ សីក្យ មហា-

ជន ប្រជាជនជប៉ុនទូទាំងប្រទេស បានចូលរួមធ្វើវិភាគទានគ្រប់គ្នាដើម្បីឧបត្ថម្ភដល់ការបោះពុម្ពឡើងវិញនូវព្រះគម្ពីរព្រះត្រៃបិដកភាសាខ្មែរ និងផ្តល់ជូនប្រជាជនខ្មែរចំនួន ១.២០០ ចប់ ។ នៅពេលនេះ គណៈប្រតិភូរបស់ជប៉ុន និងគណៈកម្មការរបស់ព្រះតេជព្រះគុណ មូចាតូ មានឱកាសដ៏ប្រពៃ ដោយបានមកប្រគល់ជូននូវគម្ពីរចំនួន ៤៧ ចប់ ចំពោះខេត្តសៀមរាបថែមទៀត ។ នេះជាឱកាសដ៏មានន័យជាប្រវត្តិ-សាស្ត្រសំរាប់អង្គការ សូតូស៊ូ, អង្គការសូតូស៊ូ សូមសម្តែងនូវអំណរគុណ និងសេចក្តីរីករាយជាពន្លឹកដែលបានចូលរួមក្នុងពិធីដ៏មហោឡារិកអធិកអធមនេះ ។

ព្រះតេជព្រះគុណ កូណូ បានមានពុទ្ធដីកាបន្តថា ខ្លួនលោកផ្ទាល់ធ្លាប់បានមកទស្សនាប្រទេសកម្ពុជាម្តងកាលពីមុនឆ្នាំ ១៩៧០ ទាំងបានទស្សនាប្រាសាទអង្គរវត្ត ប្រាសាទអង្គរធំទៀតផង ។ ព្រះអង្គរៀបរាប់ថា ពេលនោះជារដូវភ្លៀង ទេសភាពនៃវាលស្រែមានពណ៌បៃតងស្រស់ វត្តអារាមមានដំបូលពណ៌ខៀវ លឿង ក្រហម ចំរុះគ្នា ។ នៅពេលព្រឹកព្រហាម ព្រះអង្គបានឃើញព្រះសង្ឃនិមន្តចេញពីវត្តទៅបិណ្ឌបាត ... នោះគឺជាទស្សនីយភាពដ៏សន្តិភាពមួយសំរាប់ព្រះអង្គ ។ ប៉ុន្តែក្រោយពីនោះបន្តិច ពេលព្រះអង្គត្រឡប់ទៅដល់ប្រទេសជប៉ុនវិញ មានរដ្ឋប្រហារមួយបានកើតឡើង ហើយស្ថានភាពនៅប្រទេសកម្ពុជា ក៏បានប្រែទៅជាសោកនាដ-កម្មភ្លាមដែរ ។ ព្រះអង្គបានបន្តថា ក្រោយមក ព្រះអង្គបានដឹងតាមសារពតិមានថាមានជនភៀសខ្លួនខ្មែរជាង ៧០០.០០០ នាក់ បានរត់ទៅនៅជំរំជនភៀសខ្លួននៅឯជាយដែន ប្រទេសថៃ ។ ព្រះអង្គក៏បានឆ្លៀតឱកាសទៅទស្សនាជំរំទាំងនោះ មានជំរំខាវអ៊ីដាង ជំរំសាកែវ ជាដើម ។ នៅទីនោះ ព្រះអង្គមានអារម្មណ៍ក្រៀមក្រំពន់ពេកណាស់ ។ ព្រះអង្គមានបន្ទូលថា « អាត្មាបានឃើញកុមារីម្នាក់អាយុ ១៣ ឆ្នាំ ឈ្មោះ « លុំ » ធ្វើការជាមួយអង្គការជប៉ុនយ៉ាងលំបាកលំបិន ព្រោះគេត្រូវជួយថែទាំមនុស្សជាច្រើននាក់ ដែលនៅជុំវិញខ្លួន » ។ ព្រះតេជព្រះគុណ កូណូ បន្តថា « ព្រះអង្គ

បានទទួលដំណឹងទៀតថា មានជនភៀសខ្លួនខ្លះ សម្រេចថាមិនត្រឡប់ទៅកាន់កម្ពុជាវិញទេ ពីព្រោះគេបានបាត់បង់មាតុភូមិរបស់គេ ហើយព្រមទាំងធ្លាប់បានទទួលសេចក្ដីរងទុក្ខវេទនាក្រៃលែងក្នុងជីវិតរបស់គេ ។ ព្រះអង្គក៏យល់ថា នោះពិតជាសោកនាដកម្មមួយដ៏អាក្រក់បំផុត ឃោរឃៅបំផុត ដែលបានបំផ្លាញប្រទេសខ្មែរ បំផ្លាញប្រពៃណី វប្បធម៌ របស់ប្រជាជនខ្មែរអស់រលីងពិតមែន ។ ព្រះតេជព្រះគុណ កូណូ បន្តថា « នៅប្រទេសជប៉ុន យើងធ្លាប់បានជួបប្រទះនូវគ្រោះមហន្តរាយបែបនេះដែរ នៅក្នុងសង្គ្រាម កាលពី ៦០ ឆ្នាំមុន ។ យើងមានការសោកស្ដាយណាស់ ចំពោះប្រជាជននៅអាស៊ី ដែលបានរងទុក្ខវេទនាដោយសារសង្គ្រាម ពីព្រោះ ក្នុងពេលនោះ មានព្រះសង្ឃក្នុងនិកាយជាច្រើន បានឧបត្ថម្ភថវិកាចំពោះកងយោធា ដើម្បីធ្វើសង្គ្រាម និងផ្ដល់នូវជួងស្ពាន់ធំៗ ដើម្បីយកទៅរំលាយធ្វើអាវុធ ទាំងព្រះសង្ឃខ្លួនឯង ក៏បានចូលបំរើក្នុងកងទ័ពដើម្បីទៅច្បាំងដែរ ។ ប៉ុន្តែ តាមគោលការណ៍របស់ព្រះពុទ្ធ ព្រះសង្ឃត្រូវប្រតិបត្តិតាមពុទ្ធប្បញ្ញត្តិ និង គោរពជីវិតរបស់ប្រជាជនឯទៀត ។

ដូច្នេះ យើងមានសេចក្ដីខ្មាសអៀនខ្លួនឯងណាស់ ក្នុងការដែលយើងបានធ្វើកំហុសកន្លងទៅនេះ ។ ឥឡូវនេះ យើងសំរេចថា នឹងមិនឱ្យមានកំហុសបែបនេះ កើតឡើងជាថ្មីទៀតឡើយ ។

ព្រះតេជព្រះគុណ កូណូ បានបញ្ចប់សុន្ទរកថារបស់លោកថា « ក្នុងគម្ពីរព្រះត្រៃបិដក និងគម្ពីរធម្មបទ ព្រះពុទ្ធអង្គបានទូន្មានយើងឱ្យគោរពជីវិត មិនមែនចំពោះតែមនុស្សទេ .... តែចំពោះជីវិតសត្វលោកទាំងអស់ ។ អាត្មាសង្ឃឹមថា លោកអ្នកទាំងអស់គ្នា នឹងគោរពប្រតិបត្តិតាមព្រះត្រៃបិដក ដែលអាត្មាភាព យើងខ្ញុំនឹងប្រគេនជូននៅវេលានេះ ដើម្បីជាគុណប្រយោជន៍ដល់ការស្ដាបនាឡើងវិញនូវសន្តិភាព វប្បធម៌ និងប្រទេសជាតិ ដោយដើរតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ

បរមគ្រូរបស់យើង » ។

បន្ទាប់មក គណៈប្រតិភូអង្គការសូត្តស៊ូទាំងអស់បាននិមន្តឡើងទៅប្រគេនគម្ពីរចំនួន ៤៧ កញ្ចប់ជានិមិត្តរូបចំពោះព្រះសង្ឃទាំង ៤៧ វត្ត ដែលត្រូវទទួលគម្ពីរព្រះត្រៃបិដកនាពេលនេះ ជាកិច្ចបញ្ចប់ពិធី នៅវេលាម៉ោង ១៦ និង ៣០ នាទី ល្ងាច ។

កម្ពុជសុរិយា

# ពិធីសម្ពោធបើកអោយប្រើប្រាស់ បណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ



សម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី១ និង សម្តេចព្រះសង្ឃរាជទាំងពីរគណៈ ទ្រង់កាត់ខ្សែបូរជានិមិត្តរូបនៃការបើកឱ្យប្រើប្រាស់បណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ

កាលពីថ្ងៃទី ២៦ ខែមីនា ឆ្នាំ ១៩៩៦ វេលាម៉ោង ៧:៣០ នាទី នៅក្នុងបរិវេណវត្តឧណ្ណាលោម ក្រុងភ្នំពេញ ក្រសួងធម្មការ និងសាសនា បានប្រារព្ធធ្វើពិធីសម្ពោធបើកបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ដែលត្រូវបានជួសជុលឡើងវិញដោយជំនួយរបស់អង្គការហៃនរិសបឺល នៃប្រទេសអាល្លឺម៉ង់ ក្រោមព្រះរាជាធិបតីភាពរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ នាយករដ្ឋមន្ត្រីទី១ នៃព្រះរាជរដ្ឋាភិ-

បាល នៃព្រះរាជាណាចក្រកម្ពុជា និងព្រះអង្គម្ចាស់ក្សត្រី នរោត្តម ម៉ារី រណឫទ្ធិ ។

បានយាង និងអញ្ជើញចូលរួមក្នុងឱកាសនោះ មាន :

- សម្តេចព្រះសង្ឃរាជទាំងពីរគណៈ
- ព្រះមហាថេរក្នុងរាជាគណៈ ដែលជាអាទិ៍មាន សម្តេចព្រះមង្គលទេពាចារ្យ, ព្រះវន្ន័រត, ព្រះពុទ្ធឃោសាចារ្យ,
- ឯកឧត្តម អ្នកតំណាងរាស្ត្រ ឯកឧត្តមរដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ នៃក្រសួងមន្ទីរ ជាច្រើន,
- ឯកឧត្តម ឯកអគ្គរាជទូត និងឯកអគ្គរដ្ឋទូត នៃប្រទេសជាមិត្តមួយចំនួន,
- អ្នកតំណាងអង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិ ព្រមទាំងភ្ញៀវជាតិ និងអន្តរជាតិជាច្រើនរូប ។

ក្រៅពីនោះ គេឃើញពុទ្ធបរិស័ទ, ឥស្លាមបរិស័ទ, សិស្សានុសិស្ស និងមន្ត្រីរាជការក្រសួងធម្មការ និងសាសនា បានអញ្ជើញចូលរួមយ៉ាងច្រើនកុះករក្នុងពិធីនោះដែរ ។

នៅវេលាម៉ោង ៩:០០ គត់ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ និងព្រះជាយា បានស្តេចយាងដល់កន្លែងប្រារព្ធពិធី ដោយមានឯកឧត្តម ហៀន វណ្ណីរ័ត្ន ឯកឧត្តម ឈន អៀម ឯកឧត្តម ឥស្មាឯល ឧស្មាន លោក យី ធន់ និងមន្ត្រីរាជការក្រសួងធម្មការនិងសាសនា ជាច្រើនរូបទៀត ចាំទទួលស្វាគមន៍នៅជណ្តើរព្រះទីនាំងរថយន្ត ដោយមាននារីបីរូបថ្វាយកម្រងផ្កា បាច់ផ្កាជាកិត្តិយសផង ។

បន្ទាប់ពីដំណើរសាកសួរសុខទុក្ខរបស់សម្តេចក្រុមព្រះ និងព្រះជាយា ចំពោះពុទ្ធបរិស័ទ និងសិស្សានុសិស្សដែលឈរអមផ្លូវជារបងកិត្តិយសរួចមក ព្រះអង្គបានយាងឡើងលើវេទិកាកិត្តិយស ថ្វាយបង្គំព្រះសង្ឃ ដែលមានសម្តេចព្រះសង្ឃរាជទាំងពីគណៈជាប្រធាន និងធ្វើគារវកិច្ចចំពោះអង្គទូតនានា ចំពោះភ្ញៀវ

កិត្តិយសជាតិ និងអន្តរជាតិផងដែរ ។

បន្ទាប់ពីព្រះសង្ឃស្វាធ្យាយជយន្តោប្រសិទ្ធពរចំពោះសម្តេចក្រុមព្រះ និងព្រះជាយារួចមក ពិធីសម្ពោធបើកបណ្ណាល័យក៏ចាប់ផ្តើម ដោយគោរពភ្លេងជាតិ ។ កម្មវិធីជាបន្តបន្ទាប់ គឺរបាយការណ៍របស់ឯកឧត្តម ឈន អៀម ស្តីអំពីប្រវត្តិរបស់ពុទ្ធសាសនបណ្ឌិត្យ និងបណ្ណាល័យរបស់ខ្លួន ។ បន្ទាប់មកទៀត លោកស្រីបណ្ឌិត ហៃក ឡូស្មាន់ អតីតទីប្រឹក្សាគម្រោងរបស់អង្គការហៃនរិសបឺល នៃប្រទេសអាល្លឺម៉ង់ បានឡើងថ្លែងរៀបរាប់អំពីវត្ថុបំណងនៃមូលនិធិហៃនរិសបឺលក្នុងការជួយពុទ្ធសាសនបណ្ឌិត្យ ពិសេសគឺ កិច្ចសហប្រតិបត្តិការជំហានដំបូង ដែលមានរយៈពេល ៣ ឆ្នាំ គិតពីឆ្នាំ ១៩៩៣ ដល់ ១៩៩៦ ដែលក្នុងនោះ ការងារសំខាន់គឺការផ្តល់ជំនួយខាងសម្ភារៈ មានការជួសជុលអគារ ២ ខ្នង ការផ្គត់ផ្គង់សម្ភារៈប្រើប្រាស់ក្នុងការិយាល័យ សៀវភៅ ឯកសារក្នុងបណ្ណាល័យ ការបណ្តុះបណ្តាលបុគ្គលិកឱ្យមានជំនាញ និងការជួយឧបត្ថម្ភខាងជីវភាពរបស់បុគ្គលិក ។

នៅក្នុងឱកាសនោះដែរ ឯកឧត្តម ហៀន វណ្ណីរ័ត្ន រដ្ឋលេខាធិការ នៃក្រសួងធម្មការ និងសាសនា ក៏បានថ្លែងសុន្ទរកថាស្វាគមន៍ចំពោះសម្តេចក្រុមព្រះ និងព្រះជាយា ព្រមទាំងថ្លែងនូវអំណរគុណចំពោះអង្គការពីរធំៗ គឺអង្គការ ហៃនរិសបឺល (HBF) និងអង្គការជំនួយសូត្តូស៊ូជប៉ុន (JSRC) ដែលបានជួយឧបត្ថម្ភចំពោះពុទ្ធសាសនបណ្ឌិត្យ តាំងពីឆ្នាំ ១៩៩២ រហូតមក ធ្វើឱ្យអង្គភាពមានរូបរាងឡើង ព្រមទាំងដំណើរការឈានទៅមុខ គួរឱ្យជាទីសង្ឃឹម ។

បន្ទាប់មក សម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី ១ ព្រះអង្គបានធ្វើសង្កថាឆ្លើយតបវិញ ដោយសម្តែងនូវហាឫទ័យសប្បាយរីករាយចំពោះសមិទ្ធផលដែលក្រសួងធម្មការនិងសាសនា ទទួលបាន ទាំងបានសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការហៃនរិសបឺល និងអង្គការជំនួយសូត្តូស៊ូជប៉ុន ដែលបានផ្តល់

ជំនួយឥតចំណែងយ៉ាងធំធេងចំពោះពុទ្ធសាសនបណ្ឌិត្យ ធ្វើឱ្យអង្គភាពនេះអាចធ្វើសកម្មភាពប្រតិបត្តិឡើងវិញ ។

បន្ទាប់ពីមានព្រះបន្ទូលផ្ដែផ្ដាំ ក្រើនរំលឹកចំពោះក្រសួងធម្មការ និងសាសនាឱ្យខិតខំបន្តបំពេញភារកិច្ចរបស់ខ្លួនឱ្យបានកាន់តែខ្លាំងក្លា ដោយសហការឱ្យបានស្និតល្អិតជាមួយក្រសួងសម្ដេចសង្ឃរាជទាំងពីរ សម្ដេចក្រុមព្រះ ស្ដេចបានយាងទៅកាត់ខ្សែបូរ ជានិមិត្តរូបនៃការបើកឱ្យប្រើប្រាស់នូវបណ្ណាល័យពុទ្ធសាសន-បណ្ឌិត្យ ដោយមានសម្ដេចព្រះសង្ឃរាជទាំងពីរគណៈ មួយអន្លើដោយឯកឧត្តមរដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឯកឧត្តមឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត និងភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ យាងនិងអញ្ជើញអមដំណើរផង ។

សម្ដេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី ១ ទ្រង់បានយាងទតបណ្ណាល័យសព្វទីកន្លែងទាំងអស់ រួចទ្រង់បានចុះព្រះហស្ដលេខានៅលើក្រាំងមាស ទុកជាអនុស្សាវរីយ៍ ។

បន្ទាប់មកទៀត សម្ដេចក្រុមព្រះ និងព្រះជាយា ដែលមានសម្ដេចព្រះសង្ឃរាជទាំងពីរគណៈយាងអមដំណើរដដែល បានស្ដេចយាងទតផ្នែកបោះពុម្ពផ្សាយ និងពិព័រណ៌សៀវភៅ ដែលជាសមិទ្ធផលរបស់ពុទ្ធសាសនបណ្ឌិត្យ និងយាងទតប្លង់អគារថ្មីរបស់ពុទ្ធសាសនបណ្ឌិត្យ ដែលកំពុងជួបការលំបាកក្នុងការសុំច្បាប់អនុញ្ញាតសាងសង់ ។

បន្ទាប់ពីមានព្រះបន្ទូលសំណេះសំណាលអស់ពេលដ៏យូរមក សម្ដេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី ១ និងព្រះជាយា ព្រះអង្គបានស្ដេចយាងត្រឡប់ទៅកាន់រាជដំណាក់វិញ ដោយមានការហែហមជូនដំណើរ ដូចកាលស្ដេចយាងមកដល់ដែរ ។

ពិធីសម្ពោធបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ បានបញ្ចប់នៅម៉ោង ១១:១៥ ថ្ងៃត្រង់ ក្នុងបរិយាកាសរីករាយអធិកអធមក្រៃលែង ។

---

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



ពិធីប្រគេនសៀវភៅ នៅវត្តជ្រោយអំពិល ចំពោះវត្តនានា ក្នុងខេត្តកណ្ដាល

( សូមអានអត្ថបទ នៅទំព័រ ១១៧ )

ឆ្នាំទី ៥០ លេខ ២ ខែ មេសា - ឧសភា - មិថុនា

ព.ស ២៥៤០ គ.ស ១៩៩៦

ភ្នំពេញ



# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពី ពុទ្ធសាសនបណ្ឌិត្យ


ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន ៖

ទីប្រឹក្សា : **ហៀន ចណ្ណារក្ខ**

នាយកការផ្សាយ : **ឈន អៀម**

និពន្ធនាយក : **យី ធន់**

និពន្ធនាយករង : **ឱម ខែម**

គណៈកម្មការនិពន្ធ

សម្ដេចព្រះធម្មលិខិត **លាស់ ឡាយ**, ព្រះពុទ្ធឃោសាចារ្យ **ហេង លាងហោ**

លោក **ម៉ែន ប្រាង**, លោក **អាំ ឆន**

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

នៃក្រសួងធម្មការ និងសាសនា . ភ្នំពេញ

## សេចក្តីកែតម្រូវ ៖

កម្ពុជសុរិយាលេខ ១ - ១៩៩៦ នៅក្នុងអត្ថបទស្តីពី វាក្យស័ព្ទសំស្ក្រឹត ក្នុងភាសាខ្មែរបុរាណ ទំព័រ ៧៨ បន្ទាត់ ៥ ត្រង់ឃ្លាថា ៖ « *នៅក្នុងសិលាចារឹក ស្តុកកក់ធំ Stuk Kak Thom, K 935 ( ក្នុងខេត្តប្រាជិនបុរី ប្រទេសថៃ )* » សូមកែតម្រូវលេខ « *K 935* » ជា « *K 235* » ដូច្នេះវិញ ។

ごあいさつ

この本は、世界宗教者平和会議日本委員会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました。

この本が、日本の宗教者とカンボジアの人々との友情のきずなとなり、カンボジアの宗教と文化の発展に貢献できれば幸いです。

## ACKNOWLEDGEMENT

The Kampuja Surya Magazine is specially printed as a cooperative project of the Japanese Committee of the World Conference on Religion and Peace (WCRP) and Japan Sotoshu Relief Committee (JSRC).

We pray that this magazine would contribute to the Friendship with Cambodian people and their religious and cultural preservation.

## និវេទនកថា

ទស្សនាវដ្តីកម្ពុជសុរិយានេះ ត្រូវបានបោះពុម្ពឡើងជាពិសេស ទុកដូចជាគម្រោងការងារ របស់គណៈកម្មាធិការជប៉ុននៃក្រុមប្រឹក្សាពិភពលោកស្តីពីសាសនា និងសន្តិភាព (WCRP) ហើយនិងគណៈកម្មាធិការជំនួយសូតូស៊ូជប៉ុន (JSRC) ។

យើងខ្ញុំអធិដ្ឋាន សូមឱ្យទស្សនាវដ្តីនេះ បានជាវិភាគទានរក្សាមិត្តភាពជាមួយប្រជាជនកម្ពុជា និងថែរក្សាសម្បត្តិសាសនានិងវប្បធម៌របស់ប្រជាជនកម្ពុជា ។

# មាតិកាអត្ថបទ

I. អត្ថបទវេជ្ជបាល៖


- ប្រកាសក្រសួង ១


II. អក្សរសាស្ត្រសាសនា ៖


- ប្រវត្តិព្រះពុទ្ធឃោសៈ (ត-ចប់) ( ឈន អៀម ) ៣
- ការបរិនិព្វានរបស់ព្រះសម្ពុទ្ធ ( ម៉ែន ប្រាង និង អាំ ឆន ) ១៤
- សីលវតី ( ដូនជី ) ( គង់ វេទ ) ១៨


III. អក្សរសាស្ត្រទូទៅ ៖


- សុភាសិតច្បាប់ស្រី សុត្តន្តប្រីជា ឥន្ទ ( ត-ចប់ ) ២៦
- ស្ថាននាមវិទ្យា ( បណ្ឌិត ឡុង សៀម ) ៤២
- ផ្ករផ្កាំក្អាមខ្យង ( ធន់ ហ៊ិន ) ៧៥
- សត្វក្អែកគ្មានខ្លាញ់ ( ម៉ែន ប្រាង និង អាំ ឆន ) ៨៣
- ការធ្វើទៀនពីក្រមួនចំបក់ ( មៀច ប៉ុណ្ណ ) ៨៧
- មាតុភូមិ ( ហៀន វណ្ណរត្ន ) ៩៣
- ចន្ទទឹកឃ្មុំ ( ហៀន វណ្ណរត្ន ) ៩៥
- ម្ជូរ និង ចំណីផ្លែឈើ សំរាប់រដូវទាំងបី ( គង់ វេទ ) ៩៧
- សេចក្តីជូនដំណឹងអំពីលទ្ធផលនៃកំណាព្យប្រស្នា ១០១
- ចម្លើយកំណាព្យប្រស្នា ( តឹក ប៊ុនឈឿង ) ១០៧


IV. កំណត់ និង ប្រវត្តិការណ៍ ៖


- ទង់ព្រះពុទ្ធសាសនា ( ព្រះធម្មត្រ័យលោកាចារ្យ ពុធ សុភក្រ ) ១១០
- ការបែងចែកគម្ពីរព្រះត្រៃបិដក ( ត ) (ឱម ខែម ) ១១៣
- ពិធីប្រគេនសៀវភៅចំពោះវត្តនានា ក្នុងខេត្តកណ្តាល ( ឱម ខែម ) ១១៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ : ១១២ / ៩៦ កធស

## ប្រកាស

រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ,
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងព្រះរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ,
- បានឃើញព្រះរាជក្រមលេខ នស / រកម/ ០១៩៦ _ ១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួង ធម្មការ និង សាសនា ,
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃ ៣០ មិថុនា ១៩៩២ ស្តីពី ការរៀបចំ និងដំណើរប្រព្រឹត្តទៅនៃទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ ,
- ពិនិត្យសមត្ថភាពការងារ និងលទ្ធភាពរបស់មន្ត្រីរាជការ នៅក្នុងពុទ្ធសាសន-បណ្ឌិត្យ ,
- អនុលោមតាមសំណូមពរ និង ការងារចាំបាច់របស់ក្រសួងធម្មការ និង សាសនា ,

## សំរេច

*ប្រការមួយ* - គណៈកម្មការទស្សនាវដ្តីកម្ពុជសុរិយា ដែលតែងតាំង ដោយសេចក្តីសំរេចលេខ ១០ / ៩៤ កធស_ពប ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៣

របស់ក្រសួងធម្មការ និងសាសនា ត្រូវទុកជាធរមានដដែល ។

*ប្រការ ២ .* សេចក្តីសំរេចលេខ ២១៦ / ៩៥ កធស ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការប្រគល់ភារកិច្ចបន្ថែមជូនឯកឧត្តម យី ធន់ ដើម្បីដឹកនាំការស្រាវជ្រាវនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ, ប្រមូលចងក្រងឯកសារ និងការងារគ្រប់គ្រងបណ្ណាល័យ នៅពុទ្ធសាសនបណ្ឌិត្យ ត្រូវទុកជានិរាករណ៍ ។

*ប្រការ ៣.* ឯកឧត្តម យី ធន់ ត្រូវបន្តបំពេញភារកិច្ចជាទីប្រឹក្សាអមក្រសួងធម្មការ និងសាសនា តាមការសំរេចរបស់អនុក្រឹត្យលេខ ២១ អនក្រ ចុះថ្ងៃទី ៧ ខែ មីនា ឆ្នាំ ១៩៩៤ តទៅ ។

*ប្រការ ៤ .* សេចក្តីប្រកាសនេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៩៦

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា ហៀង វណ្ណារត្ន

# អំពីប្រវត្តិព្រះពុទ្ធឃោសៈ

(ត.ចប់)

រៀបរៀងដោយ **ឈន អៀម**

## ស្នាដៃ

មានទស្សនៈកន្ទែកពីគ្នាយ៉ាងច្រើនទាក់ទងនឹងស្នាដៃនិពន្ធរបស់ព្រះពុទ្ធឃោសៈ ។ បណ្ដាស្នាដៃទាំងនោះដែលគេបានទទួលស្គាល់ជាទូទៅ ត្រូវបានគេរៀបរាប់ដូចតទៅនេះ : *ញាណោទ័យ* (ត្រូវបានសរសេរមុនពេលលោកនិមន្តទៅកាន់ប្រទេសស្រីលង្កា), សាមន្តបាសាទិកា (ជាអដ្ឋកថា លើគម្ពីរប្រាំនៃវិន័យបិដក), *កង្ខា-វិតរណី* (ស្ដីពីបាតិមោក្ខ), *វិសុទ្ធិមគ្គៈ*, ហើយនិងបណ្ដាអដ្ឋកថាលើគម្ពីរសុត្តន្តបិដក គឺ*សុមង្គលវិលាសិនី* (ស្ដីពីទីឃនិកាយ), *បបញ្ចសូទនី* (ស្ដីពីគម្ពីរមជ្ឈិមនិកាយ), *សារត្ថប្បកាសិនី* (ស្ដីសំយុត្តនិកាយ), មនោរថបូរណី (ស្ដីពីគម្ពីរអង្គុត្តរនិកាយ), និងគម្ពីរទាំងឡាយក្នុង *ខុទ្ទកនិកាយ*, អដ្ឋកថាទាំងឡាយស្ដីពី *ខុទ្ទកបាឋៈ* និងស្ដីពី *សុត្តនិបាត* (ទាំងពីរនេះ គេហៅថា បរមត្ថជោតិកា) ។ លោកបានសរសេរអដ្ឋកថាលើអភិធម្មបិដកដែរ : គឺ *អត្ថសាលិនី* (ស្ដីពីធម្មសង្គណី), *សម្មោហវិនោទនី* (ស្ដីពីវិភង្គៈ) និងបញ្ចប្បករណដ្ឋកថា ស្ដីពីគម្ពីរទាំងប្រាំ ដែលនៅសល់ (ធាតុកថា, បុគ្គល-បញ្ញត្តិ, កថាវត្ថុ, យមកៈ និងបដ្ឋានៈ) ។ គេបានយល់ព្រមជាទូទៅថា អដ្ឋកថាលើគម្ពីរ *ធម្មបទ* គឺប្រហែលជាត្រូវបានព្រះពុទ្ធឃោសៈសរសេរមែន, ប៉ុន្តែ មិនមែន *ជាតកដ្ឋកថា* លើ *ជាតក* ទេ, បើទោះបីជាសេចក្ដីបញ្ចប់នៃគម្ពីរសរសេរបញ្ជាក់ថាជាស្នាដៃរបស់មហាអដ្ឋកថាចារ្យ (ព្រះពុទ្ធឃោសៈ) ក៏ដោយ, ក៏លក្ខណៈពិសេស

លើស្នាដៃទាំងនេះ អាចរកឃើញនៅក្នុងទីផ្សេង ក្រោមឈ្មោះរបស់ស្នាដៃទាំងនោះជាបន្តបន្ទាប់ ។

## ទស្សនវិជ្ជា

ព្រះពុទ្ធឃោសៈបានសិក្សាព្រះត្រៃបិដកភាសាបាលីអំពីព្រះថេរៈរេវតៈ ។ ការសិក្សានេះ បានធ្វើអោយផ្ទុះចំណង់ដ៏អន្ទះអន្ទែងនៅក្នុងចិត្តរបស់លោក ចង់ស្គាល់ ចង់ចេះសាសនារបស់ព្រះពុទ្ធ ដែលបានធ្វើអោយលោកប្រែក្លាយដោយចៃដន្យទៅជានិស្សិតដ៏ប្តូរផ្តាច់ម្នាក់នៃទស្សនវិជ្ជារបស់ព្រះពុទ្ធសាសនា ។ ដូចបានបញ្ជាក់ប្រាប់រួចហើយ លោកគឺជាអ្នកជឿកាន់តាមប្រព័ន្ធទស្សនៈ *បតញ្ជលី;* នៅក្នុងអត្ថបទសរសេររបស់លោក, ព្រះពុទ្ធឃោសៈតែងប្រឆាំង *បកតិវាទ*, ពោលគឺប្រព័ន្ធទស្សនៈសំខ្យា និងយោគៈ ដែលជឿក្នុងទ្វិកគោលការណ៍ (dual principles) នៃ *បុរុសៈ* និង *ប្រកូតិ* ។ លោកតែងវែកញែកជានិច្ចនូវទស្សនៈ ពុទ្ធសាសនាស្តីពីអវិជ្ជា អោយផ្សេងអំពីទស្សនៈរបស់ *ប្រកូតិ* ដ៏ជាមូលហេតុនៃវត្ថុទាំងឡាយ ។ លោកបានធ្វើអោយឃើញផ្សេងគ្នា នូវទស្សនៈពុទ្ធសាសនាស្តីពី*នាមរូប* អំពីទស្សនៈធម្មតា ស្តីពី *បុរុសៈ* និង *ប្រកូតិ* ។ នៅក្នុងស្នាដៃរបស់លោក ព្រះពុទ្ធឃោសៈតែងបង្ហាញនូវការសព្វព្រះទ័យរបស់លោកពីមុនចំពោះប្រព័ន្ធទស្សនៈសំ-ខ្យា និងយោគៈ ។ លោកបានប្រើប្រាស់ការប្រៀបធៀបមនុស្សខ្វាក់ និង មនុស្សខ្វិន ។ តាមការប្រៀបធៀបនេះ លោកបានពន្យល់បំភ្លឺទស្សនៈ*បុរុសៈ* និង*ប្រកូតិ* ។ គេគ្មានសង្ស័យទេថាព្រះពុទ្ធឃោសៈបានផ្អែកទស្សនៈយល់ឃើញរបស់លោក លើអាជ្ញានុភាព (authority) នៃទស្សនវិទូពុទ្ធសាសនិកពីបុរាណ, ជាអាទិ៍ នាគសេន និងអស្វឃោសៈ ។ យើងយល់ស្របជាមួយលោក អូលត្រាម៉ារ៉េ (Oltramare) ក្នុងការគាំទ្រថា ទស្សនៈពុទ្ធសាសនាស្តីពី *នាមរូប,* ចាប់ពីកាលបរិច្ឆេទណាមួយនោះ, បានទោរទន់ទៅរកទស្សនៈសំខ្យា ស្តីពី *បុរុសៈ* និង*ប្រកូតិ* ។ យើងអាចរក

ឃើញនៅក្នុងសំនេររបស់ព្រះពុទ្ធឃោសៈ នូវនិន្នាការដ៏មានចរិតលក្ខណៈជាការគិតរបស់ពុទ្ធសាសនា ដែលអោយពណ៌ដល់ទស្សនវិស័យ នៃទស្សនវិជ្ជារបស់លោក ។ គម្ពីរអភិធម្មរបស់លោក, *ញាណោទ័យ*, ឬការភ្ញាក់ឡើងនៃវិជ្ជា គឺជាផលិតផលនៃអានុភាពពុទ្ធសាសនា ។ ទស្សនវិជ្ជាពុទ្ធសាសនាទាំងមូល មួយអន្លើដោយពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ឈរលើមូលដ្ឋានចិត្តវិជ្ជា ។ ប៉ុន្តែ គេកាន់តែឃើញដំណើរទៅមុខខាងចិត្តវិជ្ជានៅក្នុងស្នាព្រះហស្តរបស់ព្រះពុទ្ធឃោសៈ ។ ព្រះពុទ្ធ-ឃោសៈ បានអធិប្បាយចិត្តវិជ្ជារបស់លោកនៅក្នុងខ័ន្ធទាំងប្រាំ ។

គឺព្រះពុទ្ធឃោសៈនោះហើយ ដែលលោកបានធ្វើអោយរីកចំរើន និងធ្វើអោយកាន់តែសុក្រឹតឡើងទៀត នូវប្រព័ន្ធទស្សនៈរបស់ពុទ្ធសាសនា ។ ការពន្យល់អំពីអត្ថបទធម៌ ជាអក្សរសាស្ត្រ និងជាទស្សនវិជ្ជា គឺប្រាកដជាការពន្យល់ ដែលព្រះពុទ្ធឃោសៈ និងសិស្សគណ ( School ) របស់លោក បានធ្វើឡើង ។ វាជាការពិបាកនឹងរកអោយឃើញនូវវិភាគទានផ្ទាល់ខ្លួនរបស់លោកចំពោះឃ្លាំងចំណេះវិជ្ជាពីបុរាណកាលពេកណាស់, ប៉ុន្តែ ទោះជាយ៉ាងនេះក្តី, យើងក៏នៅតែជំពាក់គុណចំពោះព្រះអដ្ឋកថាចារ្យដ៏ល្បីល្បាញនេះ ដែលស្នាព្រះហស្តកាត់ថ្លៃពុំបានរបស់លោក បានធ្វើអោយទៅជាសាមញ្ញ នូវអ្វីៗជាច្រើនដែលស្មុគស្មាញ និងធ្វើអោយងាយយល់ងាយចូលចិត្ត នូវអ្វីដែលពិបាកយល់, មិនច្បាស់លាស់ ។ ទស្សនវិជ្ជាពុទ្ធសាសនាអាចមានកំណើតមកពីពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ និងពីក្រុមអដ្ឋកថាចារ្យ និងទស្សនវិទូដែលជាសាវ័ករបស់ព្រះពុទ្ធ ។ ប៉ុន្តែ ព្រះពុទ្ធឃោសៈ បានធ្វើអោយទស្សន-វិជ្ជាពុទ្ធសាសនា មានទ្រង់ទ្រាយដ៏សុក្រឹត និងគ្រប់ជ្រុងជ្រោយ តាមរយៈអត្ថា-ធិប្បាយ និងការបកស្រាយផ្ទាល់ខ្លួនលោក ។ គំនិតទស្សនវិជ្ជារាយប៉ាយនៅក្នុងព្រះត្រៃបិដក ត្រូវបានព្រះពុទ្ធឃោសៈចងក្រងក្នុងទ្រង់ទ្រាយមួយមានប្រព័ន្ធម៉ត់ចត់ នៅក្នុងស្នាព្រះហស្តទាំងឡាយរបស់លោក ។

នៅក្នុងទីនេះ មានការប៉ុនប៉ងមួយ ដើម្បីសង្ខេបទស្សនៈរបស់ព្រះពុទ្ធ-ឃោសៈ ស្តីពីគំនិតទស្សនវិជ្ជាមួយចំនួន របស់ពុទ្ធសាសនា ។ ចំពោះ *អវិជ្ជា* ដែលគេតែងអោយន័យជាទូទៅថា ភាពល្ងង់ខ្លៅនោះ, ព្រះពុទ្ធឃោសៈ បានលើកឡើងនូវចំណុចមួយដ៏មានសារសំខាន់បំផុត ។ តើ *អវិជ្ជា* នេះ អាចត្រូវបានគេចាត់ទុកជាគោលការណ៍ ឬសគល់អហេតុ ដូចជា *មូលប្រកូតិ* របស់ទស្សនវិជ្ជាសំខ្យាបានឬទេ ? ព្រះពុទ្ធឃោសៈបានយល់ស្របថា នៅក្នុងអត្ថបទខ្លះ *អវិជ្ជា* អាចមានន័យប្រ-ហាក់ប្រហែលនឹង *មូលប្រកូតិ* របស់ប្រព័ន្ធសំខ្យា ។ ចំពោះអដ្ឋកថាចារ្យ ខាងពុទ្ធ-សាសនាវិញ, អវិជ្ជាមិនត្រូវបានគេយល់ទៅតាមខ្សែបន្ទាត់របស់ប្រកូតិសំខ្យាទេ ។ នៅក្នុងខ្សែច្រវាក់ នៃហេតុភាព, អវិជ្ជាគឺជាចំណងដ៏ចម្បង នៃការអន្ទោលកើត និងស្លាប់ នៅក្នុងវដ្តសង្សារ ។ លោកគីត ( Keith ) ចង្អុលប្រាប់ថា ភាពល្ងង់ខ្លៅ ( អវិជ្ជា ) នៅក្នុងខ្សែច្រវាក់របស់វា មានន័យជាកំណត់ច្បាស់លាស់ ហើយពុំមានអត្ថន័យជាវដ្តសង្សារ ដូចគ្នានឹងអត្ថន័យនៃភាពល្ងង់ខ្លៅ ( អវិជ្ជា ) នៅក្នុង*វេទ-ទាន្តៈ*ទេ, តាមរយៈនេះ ភាពដាច់ខាត ( the absolute ) ឆ្លងចូលទៅក្នុងពិសោធនិយម ( the empirical ) ។ នោះគឺតណ្ហា ( ចំណង់, តម្រេក ) ដែលបង្កើតចេញជាភាពល្ងង់ខ្លៅ ( អវិជ្ជា ) , ហើយតម្រេកក៏ងើបឡើងបន្តវេនពីព្រោះ វេទនា ( feelings ) ដែលអន្ទងហៅរកតម្រេកនេះ ត្រូវបានអវិជ្ជាជ្រួតជ្រាបចូលជោគជាំហើយ ។ ព្រះពុទ្ធបានស្វែងរកឃើញ នូវដំណើរអន្ទោលកើត-ស្លាប់ក្នុងវដ្តសង្សារនេះ ដោយបានបញ្ជាក់ប្រាប់ពីល័ក្ខខ័ណ្ឌផ្ទាល់ នៃអំពើពីរយ៉ាងជាអាទិ៍ អវិជ្ជា និងចំណង់ក្នុងការកើត ( *ភវតណ្ហា* ) ។ យោងតាមព្រះពុទ្ធឃោសៈ អវិជ្ជាជាប់ទាក់ទងនឹងការចង់បាននូវអ្វីនោះដែលគេមិនគប្បីបាន ឧទាហរណ៍ បាបកម្មខាងផ្លូវកាយ . ល . ។ វាតែយ៉ាងនេះឯង នៅឬដ៏ឫសគល់នៃជីវិតរបស់យើងក្នុងលោកនេះ ។ អវិជ្ជា ជាហេតុនៃការរស់រានរបស់សង្ខារទាំងអស់ក្នុងជីវិតលោកិយ

ហើយវានៅពីខាងក្រោយអរូបសង្ខារ ។ គេបានបង្ហាញព្រះរូបព្រះពុទ្ធ ដែលកំពុងសំដែងធម៌ដល់ភិក្ខុទាំងឡាយ ស្តីពីខ្សែច្រវាក់នៃហេតុភាព ដែលផ្តើមពីអវិជ្ជា ហើយបញ្ចប់ត្រឹមជាតិ ( កំណើត ), ជរា, និងមរណៈ ។ នៅក្នុងខ្សែច្រវាក់នៃហេតុភាពនេះ យើងឃើញថា វិញ្ញាណទាំងប្រាំមួយ មានកំណើតចេញមកពីនាម និងរូប ។

យោងតាមព្រះពុទ្ធឃោសៈ, ចិត្តគឺជាសភាវៈដែលស្គាល់ ឬដឹងវត្ថុខាងក្រៅ ។ ចរិតលក្ខណៈរបស់ចិត្ត គឺការស្គាល់ ឬដឹង ឬវិញ្ញាណ, ហើយចិត្តតែងចិតជាមួយនឹងឥន្ទ្រិយវិញ្ញាណ ។ អ្វីៗដែលគេបានឃើញតាមរយៈភ្នែក, ឮតាមរយៈត្រចៀក, ... ទាំងអស់នេះគេដឹងដោយសារចិត្ត ។ ចិត្ត (Mind) មិនភ្ជាប់ខ្លួនទៅនឹងអង្គភាពអ្វីមួយទេ ។ នៅពីក្រោយឥន្ទ្រិយវិញ្ញាណ, ចិត្ត ដឹង-ស្គាល់ វត្ថុទាំងឡាយ, ទទួលវត្ថុទាំងនោះ ហើយសំដែងអោយឃើញប្រាកដឡើងនូវស្ថានភាពនៃការទទួលនោះ ។ បើគ្មានចិត្តនៅជាប់ជាមួយទេ, នោះក៏គ្មានការដឹង-ស្គាល់តាមភ្នែក, តាមត្រចៀក, ... បានឡើយ ។ យោងតាមទស្សនៈរបស់ព្រះអដ្ឋកថាចារ្យ, ចិត្តក្តី, មនោក្តី, វិញ្ញាណក្តី គឺមានន័យតែដដែល ( ចិត្តំ ឥតិបិ មនោ ឥតិបិ វិញ្ញាណំ ) ។ គេគប្បីយល់ចរិតក្រឡិចក្រឡុចរបស់ចិត្ត ដោយយោងទៅតាមចរិតលក្ខណៈនៃការសេពគប់, ទីកន្លែង, កម្មវត្ថុ, កិរិតទាំងបីនៃការប្រៀបធៀប និងភាពគ្របដណ្តប់ (dominance) ។ នៅក្នុងកថាវត្ថុប្បករណដ្ឋកថា, ចិត្ត និងចេតសិក ត្រូវបានប្រើសម្រាប់កត់សម្គាល់ន័យដូចគ្នា ពោលគឺ ស្មារតី ។ អនុលោមតាមគម្ពីរវិសុទ្ធិមគ្គៈ, ចិត្ត គឺជាធាតុនៃស្មារតី-មនសិការ (mind-consciousness) ។ លោក គីត (Keith) និយាយថា បញ្ញាបានលេចឡើងក្រោមទិដ្ឋភាពប្លែកៗ : ក្នុងឋានៈជាចិត្ត, បញ្ញាប្រមូលផ្តុំនូវអំពើ, ក្នុងឋានៈជាស្មារតី, វាធ្វើសំយោគ, ក្នុងឋានៈជាវិញ្ញាណ, វាបង្កបង្កើតជាសេចក្តីវិនិច្ឆ័យ, ក្នុងឋានៈជាការដឹង (sense) វាមានមនសិការអំពីវត្ថុ ។ ស្មារតី គឺជាសកម្មភាពខាងបញ្ញា សម្របសម្រួល, ប៉ុន្តែទស្សនាទាន (con-

ception) អំពីទំនាក់ទំនងនៃអារម្មណ៍ និងស្មារតី គឺច្របូកច្របល់ ។

សង្ខារ មានន័យថា ការរួមផ្សំ ។ សង្ខារ ឬការរួមផ្សំនៃចិត្ត មានចរិតលក្ខណៈផ្គុំផ្សំ មានមុខងារបញ្ចូលគ្នា និងមានការស្តែងឡើងរវល់ជាប់ ។ សង្ខារមានបីប្រភេទ ៖ ជាសីលធម៌, អសីលធម៌ និងមិនជាប់លាប់ ។ ចំណុចសំខាន់អំពីសង្ខារគឺថា វាជាចេតសិក, គឺជាការងារនៃចិត្ត ។ អភិសង្ខារ ត្រូវបានគេប្រើជា សទិសន័យនៃពាក្យ សង្ខារ ។ សង្ខារខន្ធ មានចំណុចជាច្រើន ដូចចំណុចបដិច្ចសមុប្បាទ ។ ពាក្យទាំងពីរនេះ យោងទៅរកចិត្ត ។ សង្ខារ មានសទិសន័យជាមួយកម្មៈ ហើយប្រើជាសំខាន់ចំពោះចេតនា ។

ខន្ធ ត្រូវគេប្រើក្នុងន័យថា ដុំ ឬគំនរ ។ គេហៅខន្ធនេះថា សង្ខារ ។ ខន្ធអាចមានន័យថា ក្រុម ដែរ ។ វាត្រូវគ្នានឹងន័យភាសាសំស្ក្រឹតថា អង្គ ដូចជាក្នុងពាក្យធម្មខន្ធនៅក្នុងគម្ពីរឆន្ទោគ្យឧបនិស័ទ ។ ដំបូងគឺ រូប ដែលកត់សម្គាល់យ៉ាងសាមញ្ញ នូវគុណភាពខាងសម្ភារៈ ។ បន្ទាប់មកគឺវេទនា ។ បន្ទាប់មកទៀតគឺ សញ្ញា រួចទើបមកដល់សង្ខារ និងវិញ្ញាណ ។ ការផ្គុំផ្សំខន្ធទាំងប្រាំ កើតបានជាបុគ្គល ។ រូបខន្ធ មានប្រាំយ៉ាង ។ គេចែកជាផ្នែកធំពីរ ជាអាទិ៍ គឺភូតរូប និងឧបាទាយរូប ។

វិញ្ញាណ គឺជាមនសិការ ដែលរត់នាំមុខ បន្តមិនដាច់អំពីអត្តសញ្ញាណ ។ វិញ្ញាណ គឺការស្គាល់-ដឹង ។ វិញ្ញាណក្ខន្ធ គឺជាមនសិការ ដ៏ជាផ្នែកមួយនៃសង្ខារ ។ មនោវិញ្ញាណធាតុ ត្រូវបានគេហៅដោយឈ្មោះបី គឺ មនោ ក្នុងន័យនៃការវាស់, វិញ្ញាណ ក្នុងន័យនៃការវែកញែក, និងធាតុ ក្នុងន័យទស្សនវិជ្ជា នៃតថភាពចុងក្រោយ ឬការគ្មានអង្គជីវិត ។ មានភាពផ្សេងគ្នា រវាងការឃើញធម្មតា និងការឃើញដោយមានចិត្តចូលរួម ( មនសិការ ), យោងតាមទស្សនៈរបស់ព្រះពុទ្ធឃោសៈ ។ ដូច្នេះ, ទោះបីជាការឃើញសាមញ្ញក្តី, ការឃើញដោយមានចិត្តរួមក្តី ឬការស្គាល់ក្តី និងការយល់ក្តី គឺវាតែដដែល ដោយសារទាក់ទងនឹងការដឹង, ការឃើញសាមញ្ញ គឺការកត់

សម្គាល់ដ៏សាមញ្ញ នូវវត្ថុទាំងឡាយ ដូចជា វត្ថុមានពណ៌ខៀវ, បៃតង, លឿង, រួចទើបឈានចូលដល់កំណត់ចរិតលក្ខណៈនៃវត្ថុ ។ យោងតាមព្រះពុទ្ធឃោសៈ ចិត្តៈ និង មនៈ មានន័យដូចវិញ្ញាណ ។ គេចែកចិត្ត ចេញជា ៨៩ ថ្នាក់ ។ ការរៀបរាប់លំអិតពីការបែងចែកជាផ្នែកៗ នៃស័ព្ទភ្ជាប់ជាមួយវិញ្ញាណ មានអធិប្បាយយ៉ាងក្បោះក្បាយ នៅក្នុងគម្ពីរវិសុទ្ធិមគ្គ ។

អាយតនៈ ត្រូវបានលោកស្រី រីស ដាវិត អោយនិយមន័យថាជាដ៏មូល (sphere) ។ អ្នកប្រាជ្ញខ្លះទៀត បកប្រែពាក្យអាយតនៈថាជាអង្គវិញ្ញាណ (organ of sense) និងជាកម្មវត្ថុនៃវិញ្ញាណ (object of sense) ។ តាមគម្ពីរវិសុទ្ធិមគ្គ, អាយតនៈមានចំនួនដប់ពីរ ។ វិញ្ញាណទាំងប្រាំមួយ មានលក្ខណសម្បត្តិប្រាំមួយយ៉ាងផ្សេងៗ ពីគ្នា ដើម្បីទទួលអារម្មណ៍ ជាអាទិ៍ ភ្នែក, ត្រចៀក, ច្រមុះ, អណ្តាត, កាយ ។ អង្គវិញ្ញាណទាំងប្រាំ គឺ ភ្នែក, ត្រចៀក, ច្រមុះ, អណ្តាត, កាយ រួមទាំងចិត្តផង ក៏ថ្លឹបានជាសឡាយតនៈ គឺអាយតនៈប្រាំមួយ ។ ត្រឹះទាំងដប់ពីរ សម្រាប់អំពើរបស់ចិត្ត គឺ វិញ្ញាណប្រាំ កម្មវត្ថុវិញ្ញាណប្រាំ, ចិត្តហើយនិងការគិត (thought) ។

ផស្សៈ ( កាប៉ះពាល់ ) កើតចេញពីអង្គវិញ្ញាណទាំងប្រាំមួយ និងកម្មវត្ថុនៃវិញ្ញាណ គឺ អាយតនៈ ។ ព្រះពុទ្ធឃោសៈ បានចង្អុលប្រាប់ថា អង្គវិញ្ញាណកើតចេញពី កម្មៈ ( អំពើ ), គឺ កម្មៈ នេះហើយដែលធ្វើអោយអង្គវិញ្ញាណផ្សេងៗ ពីគ្នា ។ យោងតាមព្រះពុទ្ធឃោសៈ ផស្សៈ មានន័យថាការប៉ះពាល់ ។ ចរិតលក្ខណៈរបស់ផស្សៈ គឺការពាល់, ស្ទាប ; មុខងាររបស់វាគឺ នាំបុគ្គលទៅអោយប៉ះទង្គិចជាមួយវត្ថុខាងក្រៅ ហើយឥទ្ធិពលរបស់វា គឺប៉ះពាល់គ្នា, ជួបគ្នា ។ វត្ថុដែលចូលមកក្នុងគន្លងរបស់វា បង្កើតជាផស្សៈ ។ វាឥតមានរូបរាងទេ វាមានអត្ថិភាពដោយសារការតោងជាប់ទៅនឹងវត្ថុណាមួយ ។ ទំនាក់ទំនងរវាងផស្សៈ និងកម្មវត្ថុនៃផស្សៈ គឺជាទំនាក់ទំនងរវាងភ្នែក និងរូប, ត្រចៀក និងសំឡេង ( ស្នូរ ), ចិត្ត និងកម្មវត្ថុ

នៃគំនិត ។ ផស្សៈ គឺជាភាគមួយនៃ សង្ខារ ។ នៅក្នុងគម្ពីរវិសុទ្ធិមគ្គ លោកបាន បញ្ជាក់ថា ផស្សៈ កើតមកពី អាយតនៈ ទាំងប្រាំមួយ ។ ផស្សៈ មានប្រាំមួយយ៉ាង គឺ ចក្ខុ-ផស្សៈ ( ការប៉ះពាល់តាមភ្នែក ), សោត-ផស្សៈ ( ការប៉ះពាល់តាម ត្រចៀក ), ឃាន-ផស្សៈ ( ការប៉ះពាល់តាមច្រមុះ ), ជិវ្ហា-ផស្សៈ ( ការប៉ះពាល់តាម អណ្ដាត ), កាយ-ផស្សៈ (ការប៉ះពាល់តាមកាយ ), និង ចិត្ត-ផស្សៈ ( ការប៉ះពាល់ តាមផ្លូវចិត្ត ) ។ ការប៉ះពាល់ ( ផស្សៈ ) គឺជាល័ក្ខខ័ណ្ឌមួយនាំមុខនៃអំពើទាំង អស់ ។ វាជាដើមហេតុនៃអារម្មណ៍ទាំងអស់ ។

យោងតាមព្រះពុទ្ធឃោសៈ, វេទនា មានន័យថា អ្វីៗដែលមានចរិត លក្ខណៈទទួលអារម្មណ៍ ; វាមានបីថ្នាក់ យោងតាមកំណើតរបស់វា គឺ ល្អ, អាក្រក់ និងអព្យាក្រឹត ( មិនល្អ មិនអាក្រក់ ), ទោះបីថ្នាក់ទាំងបីនេះ មានធម្មជាតិដូចគ្នា ( ដដែល ) ត្រង់ការទទួលអារម្មណ៍ក៏ដោយ ។ វេទនា មានន័យថា អារម្មណ៍ (sensation or feeling) ដែលជាអារម្មណ៍រីករាយ ឬឈឺចាប់ ។ ដោយការប៉ះ ពាល់ត្រូវ ( ផស្សៈ ), វេទនា ក៏កើតឡើង ។ ដោយផស្សៈមានប្រាំមួយយ៉ាង, ដូច្នេះ, អារម្មណ៍ ( វេទនា ) ក៏មានប្រាំមួយបែបដែរ ។ ដោយផស្សៈ ជាមូលហេតុនៃ អារម្មណ៍, ដូច្នេះ អារម្មណ៍ក៏ជាមូលហេតុនៃចំណង់ ( តណ្ហា ) ។ វេទនា រួមមានទាំង អារម្មណ៍សប្បាយ និងអារម្មណ៍ទុក្ខព្រួយ, វាគ្របដណ្ដប់អារម្មណ៍គ្រប់យ៉ាង ទាំង ខាងផ្លូវកាយ ទាំងខាងផ្លូវចិត្ត ។ វេទនា អាចជាកាយិកៈ ឬមានសិកៈ ។ ក្រោមទិដ្ឋ-ភាពជាអារម្មណ៍, វេទនា អាចជាសេចក្ដីសប្បាយរីករាយ, ឬជាសេចក្ដីឈឺចាប់ ឬមិន មែនជាសេចក្ដីឈឺចាប់ - មិនមែនជាសេចក្ដីរីករាយ ពោលគឺ អារម្មណ៍ជាឧបេក្ខា ។

វត្ថុទាំងអស់ ដែលមានចរិតលក្ខណៈជាការឃើញ ឮ, ដឹងដោយញាណ (perception) លោកអោយឈ្មោះថា សញ្ញាខន្ធ ដែលមានបីយ៉ាងគឺ កុសល, អកុ-សល, និង អព្យាកតៈ ។ សញ្ញា មិនអាចកើតមាន ដោយគ្មានវិញ្ញាណទេ ។ សញ្ញា គឺ

គ្រាន់តែជាការឃើញ ដឹង, ឮ, លើរូបភាពខាងក្រៅនៃវត្ថុ, ចំណែកវិញ្ញាណ មានន័យថាជាការយល់ដឹងជ្រាលជ្រៅអំពីវត្ថុ ។ សញ្ញាខន្ធ គឺជាខន្ធទីបី ។ ខន្ធនេះត្រូវបានចែកចេញជាប្រាំមួយ : ចក្ខុ សោត ឃាន ជីវ្ហា កាយ និងមនោសម្ផស្សជាសញ្ញា ។ សញ្ញាខន្ធ (perceptiont) ស្ដែងឡើងភ្លែតក្នុងខណៈខ្លី បីដូចផ្លេកបន្ទោរ បណ្ដាលមកពីអសមត្ថភាព ដើម្បីយល់ចាក់ធ្លុះក្នុងវត្ថុ ។ សញ្ញា គឺជាឈ្មោះនៃវត្ថុជាក់ស្ដែង ( សភាវៈ ) ។ សញ្ញានិតត្ត បង្ហាញនូវស្ថានភាពដែលបានដឹង, ឮ, ឃើញ, ... ដោយការកត់សម្គាល់ ។ អភិក្រមទាំងបីនេះ មានទំនាក់ទំនងគ្នាដ៏ជិតស្និទ្ធពេកទៅ រហូតដល់ក្នុងការអនុវត្តជាក់ស្ដែង គេពុំអាចដឹងបានថា ណាជាសញ្ញាខន្ធ (perception) ណាជាមនសិការ (consciousness), ណាជាការយល់ដឹង (understanding) បានទេ ។

កម្មៈ ត្រូវបានព្រះពុទ្ធឃោសៈ អោយនិយមន័យថាជា ចេតនា (volition) ហើយលោកបានដកស្រង់ពុទ្ធដីកាថា *«ចេតនាហំ ភិក្ខវេ កម្មំ វទាមិ »* ។ កម្ម ឬអំពើមួយមិនទាន់ទៅជាអំពើបានទេ, រហូតដល់មានឆន្ទៈស្ដែងឡើងនៅក្នុងការប្រព្រឹត្តអំពីនោះ ។ កម្មៈ មានន័យថាចិត្តល្អ និងអាក្រក់, ជាកុសល និងអកុសល ( កម្ម នាម កុសលាកុសលចេតនា ) ។ ព្រះពុទ្ធឃោសៈបានពោលថា ចេតនាតាមផ្លូវសិលធម៌ ពុំអាចកំណត់បានទេ, ចេតនាពុំមានលទ្ធផលជាសីលធម៌ទេ ។ កម្មចែកជាបួនប្រភេទ : ១. កម្ម ដែលផ្ដល់ផលក្នុងជាតិនេះ, ២. កម្ម ដែលផ្ដល់ផលក្នុងជាតិខាងមុខ, ៣. កម្ម ដែលផ្ដល់ផលម្ដងម្កាល, ៤. កម្ម ពីអតីត ។ កម្ម ចែកសត្វអោយទាប អោយខ្ពស់ ។ គ្មានអ្នកបង្កើតកម្ម និងគ្មានអ្នករងផលវិបាកទេ ; មានតែបាតុភាពប៉ុណ្ណោះ ដែលបន្ត *( កម្មស្ស ការកោ នត្ថិ )* ។ កម្ម មានបុគ្គលភាពផ្ទាល់របស់ខ្លួន, មានទាយាទផ្ទាល់របស់ខ្លួន ; សត្វ ត្រូវច្រូតកាត់ផលនៃកម្មរបស់ខ្លួន ទោះជាផលល្អក្ដី អាក្រក់ក្ដី ។

ការផ្តុំផ្សំខន្ធទាំងប្រាំ បង្កើតបានជាបុគ្គល ។ បុគ្គលភាព មានន័យថារូប ពោលគឺ ខន្ធទាំងប្រាំ ។ បុគ្គលម្នាក់ៗ គ្មានអ្វីក្រៅតែពីការរួមផ្សំ នៃធាតុផ្តុំទាំងប្រាំ ឬបឋមធាតុទាំងបួន ហើយនិង រូបធាតុ (matters) ដែលចេញពីបឋមធាតុទាំងបួននោះទេ ។ ចំណុចនេះ គេអាចធ្វើការប្រៀបធៀប បំភ្លឺជាមួយនឹងរទេះ ហើយនិងផ្នែកផ្សេងៗរបស់រទេះ ។

នៅក្នុងនាមរូប, នាម យោងទៅរកធាតុផ្សំទាំងបី ដែលមានជាអាទិ៍គឺវេទនា, ពីព្រោះធាតុទាំងបីនេះ « ទោរទន់ » ឆ្ពោះទៅរកវត្ថុ ។ រូបធាតុ (matter) ពោលគឺ អ្វីនោះដែលប្រែប្រួលស្ថានភាព ឬល័ក្ខខ័ណ្ឌរបស់វា បណ្តាលមកពីហេតុទាំងបួន មានត្រជាក់ ឬកំដៅ ជាដើម ។ ទស្សនៈ ស្តីពីនាម និងរូប លេចចេញមកពីទ្វិកមតិ (dual idea) ស្តីពី ចិត្ត និងរូបធាតុ ។ រូប ឬទ្រង់ទ្រាយ ត្រូវបានគេហៅយ៉ាងនេះ បណ្តាលមកពីវាស្តែងឡើងអោយឃើញខ្លួនឯង ។ ប៉ុន្តែនាមវិញ ជាសភាវៈសុខុម ( ល្អិតក្រៃលែង ) ត្រូវពឹងផ្អែកលើឈ្មោះ ដើម្បីធ្វើខ្លួនអោយគេស្គាល់ ។ នាម ឬឈ្មោះ មានបួនយ៉ាង : ១. ឈ្មោះផ្តល់អោយក្នុងឱកាសពិសេស, ២. ឈ្មោះផ្តល់អោយដោយសារគុណធម៌របស់ខ្លួន, ៣. ឈ្មោះផ្តល់អោយដោយការទទួលស្គាល់, ៤. ឈ្មោះទាំងឡាយដែលលេចចេញពីខ្លួនឯង ឬលេចចេញជាសយម្ភូត (spontaneously) ។

សីល មានន័យថា ទម្លាប់ ឬចរិយា ។ សីល គឺជាគ្រឹះនៃគុណសម្បត្តិល្អៗទាំងអស់ ។ សីលបរិសុទ្ធភ្តិ, ចិត្តបរិសុទ្ធភ្តិ, ញាណបរិសុទ្ធភ្តិ, មិនមានប្រយោជន៍អ្វីឡើយ, ប្រសិនបើគុណធម៌ទាំងនោះ មិននាំទៅរកការរំដោះទុក្ខទេ, នៅក្នុងគម្ពីរអត្ថសាលិនី, យើងឃើញថា ចំណាត់ថ្នាក់គុណធម៌មានជាអាទិ៍ដូចតទៅនេះ : ចារិត្ត-សីល ( សីលធម៌វិជ្ជមាន ) ផ្ទុយទៅនឹងវារិត្តសីល ( សីលធម៌អវិជ្ជមាន ) ។ ព្រះពុទ្ធបានបញ្ញត្តឱ្យសាវ័ករបស់ព្រះអង្គប្រតិបត្តិតាមសិក្ខាបទសីលធម៌មួយចំនួន ( ចារិត្ត-

សិល ), ប៉ុន្តែ ឱ្យវៀរចាកសិក្ខាបទមួយចំនួន ( វារិត្តសីល ) ។

នៅក្នុងគម្ពីរវិសុទ្ធិមគ្គ យើងឃើញព្រះពុទ្ធឃោសៈ ណែនាំអោយកាន់សិក្ខាបទ ( សីល ) អោយបានម៉ឺងម៉ាត់ ហើយលោកបានលើកឡើងពីទោសនៃការបំពារបំពានលើសិក្ខាបទនោះៗ ។ ការវៀរចាកអំពើផ្តាច់ផ្តិលជីវិត, វៀរចាកការនិយាយកុហក, ញុះញង់ ឬនិយាយប៉ប៉ាច់ប៉បោចឥតប្រយោជន៍, ត្រូវបានរាប់ចូលទៅជាសិក្ខាបទហាមឃាត់, ប៉ុន្តែ ព្រហ្មចរិយធម៌ខាងការសេពកាម (sexual purity) ត្រឡប់ទៅជាសីលសិក្ខាបទ ជាវិជ្ជមានទៅវិញ ។ ទីបញ្ចប់របស់មនុស្ស គឺរំដោះខ្លួនឯង, ប្រសិនជាអាចធ្វើបានគឺ រំដោះនៅក្នុងជាតិនេះតែម្តង, អោយផុតពីគ្រឿងស្រវឹង, ពីចំណង់ចង់កើតទៀតនៅក្នុងភពនេះ ឬ ក្នុងរូបភព, និងពីអវិជ្ជាដែលមិនយល់ពីអរិយសច្ចៈទាំងបួន ។ គោលដៅរបស់មនុស្ស គឺបំបាក់ច្រវាក់នៃហេតុភាព ហើយរំដោះខ្លួនពីតណ្ហា ។ គេមិនអាចរំលត់តណ្ហាបានទេ, បើអវិជ្ជានៅតែមាន, ដោយហេតុនេះ ការរំលត់អវិជ្ជា គឺជាការចាំបាច់ ។ សីល, សមាធិ, បញ្ញាទាំងបីនេះ សំខាន់ណាស់ ។ សមាធិ ដែលជ្រួតជ្រាបដោយសីល បានផលល្អ ; ឯបញ្ញាដែលជ្រួតជ្រាបដោយសមាធិ ក៏បានផលល្អ ហើយអាត្មាខ្លួនឯង ដែលជ្រួតជ្រាបដោយបញ្ញា នឹងត្រូវបានរំដោះអោយផុតពីការគ្របសង្កត់នៃតណ្ហា ពីមិច្ឆាទិដ្ឋិ និងពីអវិជ្ជា ។ សមាធិ នឹងត្រូវសំរេចបាន តែតាមរយៈសីល ។ សីល និងបញ្ញា ទាំងពីរនេះត្រូវបានចាត់ទុកជាគុណធម៌សារវន្តបំផុត ។

---

# ការបរិនិព្វាននៃព្រះសម្ពុទ្ធ

គ្រានោះ បន្ទាប់ពីព្រះមានព្រះភាគទ្រង់គង់នៅក្នុងភោគនគរ តាមសមគួរដល់ពុទ្ធអធ្យាស្រ័យហើយ ក៏ទ្រង់នាំព្រះអានន្ទ និងភិក្ខុសង្ឃជាច្រើនរូប ទៅកាន់ក្រុងបាវា ចូលទៅគង់នៅក្នុងអម្ពវ័ន ( ព្រៃស្វាយ ) ជិតក្រុងបាវានោះ ។ នាយចុន្ទកុម្មារបុត្ត ជាម្ចាស់ព្រៃស្វាយ ឮដំណើងនោះ ក៏ចូលទៅបង្គំគាល់ព្រះមានព្រះភាគ សូមអារាធនាដើម្បីទទួលភត្តាហារក្នុងថ្ងៃស្អែក ។ ព្រះសម្ពុទ្ធទ្រង់ទទួលនិមន្តន៍ដោយតុណ្ហីភាព ។ នាយចុន្ទត្រឡប់ទៅគេហដ្ឋានវិញ បានឱ្យគេចាត់ចែងខាទនីយភោជនី-យាហារ (១) ព្រមទាំងសូករមទ្ទវៈ (២) ក្នុងផ្ទះរបស់ខ្លួន ។

លុះព្រឹកឡើង ព្រះសម្ពុទ្ធ មួយអន្លើដោយភិក្ខុសង្ឃ បាននិមន្តទៅកាន់ផ្ទះរបស់នាយចុន្ទ ហើយទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះទ្រង់គង់ហើយ ក៏ត្រាស់នឹងនាយចុន្ទថា ម្នាលនាយចុន្ទ ! ចូរអ្នកអង្គាស ( ប្រគេន ) ខាទនីយភោជនី-យាហារដល់ភិក្ខុទាំងឡាយចុះ, ឯសូករមទ្ទវៈ ចូរអ្នកអង្គាសតែតថាគតបានហើយ ។ នាយចុន្ទ ក៏ចាត់ចែងតាមពុទ្ធដីកា ។ លុះទ្រង់ធ្វើភត្តកិច្ចរួចហើយ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលនាយចុន្ទ ចូរអ្នកយកសូករមទ្ទវៈដែលនៅសល់នេះ ទៅកប់ចោលចុះ ព្រោះតថាគតមិនឃើញមានមនុស្សសត្វណាមួយក្នុងលោក ដែលបរិភោគនូវសូករមទ្ទវៈនេះហើយ សូករមទ្ទវៈនោះរលួយទៅដោយល្អឡើយ វៀរលែងតែតថាគតចេញ ។ នាយចុន្ទ ក៏យកសូករមទ្ទវៈដែលនៅសល់ទាំងប៉ុន្មាន ទៅកប់ចោលក្នុងរណ្តៅ តាមព្រះតម្រាស់ ។

---

(១) ខាទនីយ និងភោជនីយាហារ គឺបង្អែម និងចង្អាប ។ (២) សូករមទ្ទវៈ សាច់ជ្រូកដែលគេចិញ្ចាំឱ្យល្អិតទន់ ហើយចំអិនដោយល្អ ។ មា្យ៉ាងទៀត ជាឈ្មោះភោជនដែលគេពាក់ពែងដោយសាច់ជ្រូក ត្រូវតាមតម្រានៃម្ហូបមួយបែប មានរសឆ្ងាញ់ ( អដ្ឋកថា ) ។

បន្ទាប់ពីឆាន់សូករមទ្ទវៈនោះមក ព្រះមានព្រះភាគទ្រង់មានអាពាធដ៏ខ្លាំងកើតឡើង ( ដោយធ្លាក់ព្រះលោហិតតាមព្រះឱស្ឋ ) ជិតនឹងបរិនិព្វាន តែព្រះមានព្រះភាគទ្រង់មានព្រះសតិ និង សម្បជញ្ញៈរឹងមាំ ទ្រង់អត់សង្កត់នូវវេទនានោះបានមិនមានការលំបាកឡើយ, ហើយទ្រង់ត្រាស់នឹងអានន្ទថា ម្នាលអានន្ទ, មក ! យើងទៅកាន់ក្រុងកុសិនារា ។

ព្រះសម្ពុទ្ធទ្រង់យាងទៅដល់ក្រោមដើមឈើមួយដើម ហើយមានពុទ្ធ-ដីកាថា " ម្នាលអានន្ទ ចូរអ្នកក្រាលសង្ឃាដីឱ្យមានជាន់ ៤ តថាគតល្ហិតល្ហៃណាស់ តថាគតអង្គុយសិន, ចូរអ្នកទៅដងទឹកមកឱ្យតថាគតឱ្យបានឆាប់, តថាគតស្រេកទឹកណាស់ តថាគតនឹងឆាន់ទឹកបន្តិច " ។ ព្រះអានន្ទក្រាបទូលថា " បពិត្រព្រះអង្គដ៏ចម្រើន អម្បាញ់មិញនោះ គេបររទេះចំនួន ៥០០ ឆ្លងកាត់ស្ទឹងនោះ, ទឹកនោះតិចកង់រទេះក៏កិនល្អក់វឹកវរហូរមក, បពិត្រព្រះអង្គដ៏ចម្រើន ស្ទឹងកកុធៈនៅជិតនេះមានទឹករងថ្លា មានរសជាតិឆ្ងាញ់ ត្រជាក់ មានកំពង់ក៏ស្រួល ជាទីគួរត្រេកអរ ព្រះមានព្រះភាគនឹងសោយទឹកក៏បាន នឹងស្រង់ព្រះកាយឱ្យត្រជាក់ស្រួលក៏បាន ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ប្រើអស់វារៈបីដង ទើបព្រះអានន្ទកាន់បាត្រដើរតម្រង់ទៅស្ទឹងនោះ ។ ពេលនោះ ដោយអានុភាពនៃបារមីរបស់ព្រះសម្ពុទ្ធ ទឹកស្ទឹងតូចដែលទើបនឹងត្រូវរទេះ ៥០០ បរកាត់ល្អក់កករថ្មីៗនោះ ក៏ត្រឡប់ទៅជាថ្លាបរិសុទ្ធវិញ ។ ព្រះអានន្ទ ក៏ដងទឹកនោះដោយបាត្រយកទៅថ្វាយព្រះអង្គសោយ ។

បន្ទាប់មក ព្រះអង្គបាននាំព្រះអានន្ទ និងព្រះសង្ឃទៅកាន់ស្ទឹងកកុធៈ ។ ព្រះអង្គទ្រង់ចុះក្នុងស្ទឹងនោះ ស្រង់ផង សោយផង រួចទើបយាងត្រឡប់មកវិញ ហើយចូលទៅរកអម្ពវ័ន, ទ្រង់ល្ហិតល្ហៃក្រៃពេក, ទ្រង់សំរាកព្រះកាយនៅទីនោះ ។ ក្នុងឱកាសនោះ ព្រះសម្ពុទ្ធទ្រង់មានពុទ្ធដីកាផ្តាំនឹងព្រះអានន្ទថា : ម្នាលអានន្ទ បើមានបុគ្គលណាមួយ ញ៉ាំងសេចក្តីក្តៅក្រហាយស្តាយក្រោយ ឱ្យកើតឡើងដល់នាយចុន្ទ

ថា " ម្នាលអាវុសោចុន្ទ អ្នកពេញជាមនុស្សឥតលាភ, អត្តភាពជាមនុស្ស គឺអ្នកបានដោយអាក្រក់ ព្រោះព្រះតថាគតសោយបច្ឆិមបិណ្ឌបាតរបស់អ្នកហើយ ទ្រង់បរិ-និព្វាន, ម្នាលអានន្ទ អ្នកគប្បីបន្ទោបង់វិប្បដិសារីរបស់នាយចុន្ទថា ម្នាលអាវុសោ-ចុន្ទ អ្នកពេញជាមនុស្សមានលាភ, អត្តភាពជាមនុស្ស គឺអ្នកបានដោយប្រពៃហើយ ព្រោះថា ព្រះតថាគតទ្រង់សោយបច្ឆិមបិណ្ឌបាតរបស់អ្នក ហើយទ្រង់បរិនិព្វាន, ម្នាលអាវុសោចុន្ទ ពាក្យនេះ យើងបានស្តាប់ បានទទួលចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ដូច្នេះថា ចង្ហាន់បិណ្ឌបាតពីរកាល មានផលស្មើគ្នា មានវិបាកស្មើគ្នា មានផលច្រើនផង មានអានិសង្សច្រើនផង ក្រៃលែងជាងចង្ហាន់បិណ្ឌបាតដទៃ ។ ចង្ហាន់បិណ្ឌបាតទាំងពីរកាលនោះគឺ :

- ចង្ហាន់បិណ្ឌបាតដែលព្រះតថាគតឆាន់ហើយ ត្រាស់ដឹងនូវអនុត្តសម្មា-សម្ពោធិញ្ញាណ ១,
- ចង្ហាន់បិណ្ឌបាតដែលព្រះតថាគតសោយហើយ ចូលបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ១ ។

បន្ទាប់ពីសម្រាកព្រះកាយនៅស្ទឹងកកុធះមក, ព្រះមានព្រះភាគទ្រង់នាំព្រះអានន្ទ និងភិក្ខុជាច្រើនទៅកាន់ត្រើយខាងនាយនៃស្ទឹងហិរញ្ញវតី ចូលទៅកាន់សាល-វ័ន ( ព្រៃរាំង ) របស់ពួកមល្លក្សត្រ ដែលជាទីចូលទៅក្នុងក្រុងកុសិនារា ។ លុះចូលទៅដល់ហើយ ទ្រង់ត្រាស់ឱ្យព្រះអានន្ទរៀបចំគ្រែ ឱ្យមានសំណើងបែរទៅទិសខាងជើង ត្រង់ចន្លោះសាលព្រឹក្សទាំងគូ ហើយទ្រង់សម្រេចសីហសេយ្យា (១) ផ្អៀងទៅខាងស្តាំ ទ្រង់យកព្រះបាទឆ្វេងតម្រួតលើព្រះបាទស្តាំ ! ទ្រង់ចូលបរិនិព្វានដោយស្ងប់ស្ងាត់នៅទីនោះឯង ក្នុងបច្ឆិមយាមនៃរាត្រី ១៥ កើត ខែពិសាខ ក្នុងព្រះជន្មគំរប់ ៨០ ឆ្នាំគត់ ។

(១) ទ្រង់សម្រេចសីហសេយ្យា គឺទ្រង់សម្រេចការផ្ទំ ។

# សេចក្ដីបន្ថែម

*តាមអដ្ឋកថា ប្រាប់សេចក្ដីថា :*

- ពេលដែលព្រះសម្ពុទ្ធទ្រង់ប្រឈួនធ្លាក់ព្រះលោហិតនោះ សក្កទេវរាជបានយកភាជន៍មាស ( កន្ថោមាស ) មកត្រងព្រះលោហិត ហើយដាក់លើព្រះកេសទូលយកទៅ ។

- ពួកព្រះរាជា បន្ទាប់ពីទ្រង់ជ្រាបថា ព្រះសម្ពុទ្ធប្រឈួនបណ្ដាលមកពីនាយចុន្ទ ឱ្យឆាន់សាច់ជ្រូក ក៏ទ្រង់ព្រះពិរោធយ៉ាងខ្លាំងរហូតចង់ធ្វើគត់នាយចុន្ទទៀតផង ប៉ុន្តែត្រូវបានព្រះមានព្រះភាគទ្រង់ធ្វើអន្តរាគមន៍ឃាត់ និងពន្យល់ឱ្យព្រះរាជាទាំងនោះជ្រាបច្បាស់ថា ការប្រឈួនធ្លាក់ព្រះលោហិតនេះ ពុំមែនបណ្ដាលមកពីការឆាន់សាច់ជ្រូកទេ គឺបណ្ដាលមកពីពៀរវេរាក្នុងអតីតជាតិរបស់ព្រះអង្គតាមមកឱ្យផល ។

- ពៀរវេរានោះ គឺកាលព្រះអង្គជាពោធិសត្វនៅឡើយ ទ្រង់សោយព្រះជាតិជានាយពាណិជម្នាក់ បានដឹកនាំកងរទេះចំនួន ៥០០ ទៅជួញនៅស្រុកឆ្ងាយ ។ ក្នុងពេលទៅដល់ស្ទឹងមួយនោះ គោស្រេកទឹកយ៉ាងខ្លាំង តែនាយពាណិជមិនឈប់សំរាកឱ្យគោផឹកទឹកឡើយ ចេះតែបង្ខំបរទៅយ៉ាងប្រញាប់ ។ ពួកគោទាំងឡាយ ត្រូវរងការលំបាកវេទនាយ៉ាងខ្លាំងដោយសារស្រេកទឹក ។ អំពើនេះ បណ្ដាលឱ្យព្រះអង្គទទួលបាបកម្មជាច្រើនជាតិមកហើយ រហូតដល់ពេលនេះទៀត ។

រៀបរៀងដោយ **ម៉ែន ប្រាជ** និង **អាំ ឆន**

ពិនិត្យនិងកែសម្រួលដោយ **ឱម ខែម**

# សីលវតី (ដូនជី)

## I. ប្រវត្តិសីលវតី

កាលពីសម័យអង្គរ មានព្រះមហាក្សត្រ ១ អង្គ ទ្រង់ឡើងសោយរាជ្យ បន្ទាប់ពីព្រះបាទភុវនាទិត្យវរ្ម័ន ក្នុងអំឡុងសតវត្សទី ១២ គ.ស. ១១៤៧ - ១១៧៧ ( ៣០ ឆ្នាំ ) ។ នោះ គឺព្រះបាទជយវរ្ម័នទី ៧ ។

- ព្រះអង្គជាក្សត្រ មានមនសិការជាតិពិត ,
- ព្រះអង្គជាក្សត្រ មានទសពិធរាជធម៌ពិត ,
- ព្រះអង្គជាក្សត្រ មានព្រហ្មវិហារធម៌ពិត ,
- ព្រះអង្គជាក្សត្រ មានតក្កវិជ្ជា ( សម្មាសង្កប្បៈ ) ជ្រាលជ្រៅពិត ,
- ព្រះអង្គជាក្សត្រ មានទស្សនៈ ឥតលើសខ្វះ ( សម្មាទិដ្ឋិ ) ពិត ,
- ព្រះអង្គជាក្សត្រ មានពុទ្ធិ បញ្ញាញាណ វាងវៃពិត,
- ព្រះអង្គជាក្សត្រ មានគំនិត " សន្តិភាព - អភិវឌ្ឍន៍ " ពិត ,
- ព្រះអង្គជាក្សត្រ មានតេជះបារមី គួរបូជា និងកោតស្ញប់ស្ញែងពិត ,
- ព្រះអង្គ ជាអបិច្ឆតាជន ( ប្រាថ្នាតិច មិនឃ្លានអំណាច ) ,
- ព្រះអង្គ ជាអច្ឆរិយជន ( បូរស្លាប់រស់នឹងប្រទេសជាតិ ) ,
- ព្រះអង្គ ជាស្ថាបនិក សាងក្រុងអង្គរទី ៣ ( អង្គរធំ ) ,
- ព្រះអង្គ ជាបិតាគមនាគមន៍ សង្គមកិច្ច និងសេដ្ឋកិច្ច (ក្សេត្រកម្ម) ,
- ព្រះអង្គ ជាព្រហ្មញ្ញសាសនិក និងជាពុទ្ធសាសនូបត្ថម្ភក៏ យ៉ាងមុតមាំ

ព្រះបាទជយវរ្ម័នទី ៧ ព្រះអង្គមានអគ្គមហេសីពីរ ជាបងប្អូនបង្កើតនឹងគ្នា ។ ព្រះអគ្គមហេសីទី ១ (ប្អូន) ព្រះនាម ជ័យរាជទេវី ។ ព្រះអគ្គមហេសីទី ២ (បង) ព្រះនាម ឥន្ទ្រទេវី [១] ។

ព្រះនាង ឥន្ទ្រទេវី ជាអ្នកប្រាជ្ញអក្សរសិល្ប៍ គឺចេះអក្សរ ភាសាសំស្ក្រឹតច្បាស់លាស់ និងចេះវិទ្យាសាស្ត្រផ្សេងៗទៀតជាច្រើន មានគណិតវិទ្យា ជាដើម, ហើយព្រះនាងជាស្ត្រីមានបញ្ញាឆ្លៀវឆ្លាត ពិបាករកគូប្រដូច ។

ព្រះនាងត្រូវបានតែងតាំងផ្ទាល់ពីព្រះរាជា ជាសកលវិទ្យាធិការ ( Recteur ) នៅសកលវិទ្យាល័យឈ្មោះ « ទិលកគុត្តរៈ » ហើយព្រះនាងក៏ជាសាស្ត្រាចារ្យមុខវិជ្ជាសាសនា បង្រៀនស្ត្រីខ្មែរនៅក្នុងវត្តមួយឈ្មោះ « នរេន្ទ្រាស្រម » ទៀតផង ។

ព្រះសកម្មភាពខាងលើនេះ ស្របនឹងភាសិតបុរាណថា « សំណាបយោងដី ស្រីយោងប្រុស » = ( ស្រីគ្រប់លក្ខណ៍ ) ។ គឺព្រះនាងមានមធ្យោបាយល្អ ត្រជាក់ព្យាយាមយ៉ាងទទូចលួងលោមបញ្ចុះបញ្ចូលព្រះស្វាមី ( ដែលពីដើមជាអ្នកព្រហ្មញ្ញនិយម ) ឱ្យងាកព្រះទ័យមកកាន់ពុទ្ធសាសនាវិញបានដូចបំណងប្រាថ្នា ។ ក្រោយពីជឿស៊ប់ក្នុងពុទ្ធសាសនាហើយ ( តែក៏មិនលះបង់ព្រហ្មញ្ញសាសនាដែរ ), ព្រះបាទជយវរ្ម័នទី ៧ ទ្រង់ចាប់យកឧត្តមគតិសាសនាទាំងពីរ : ព្រហ្មញ្ញសាសនា និងពុទ្ធសាសនា ជានយោបាយបង្រួបបង្រួមជាតិ ដឹកនាំ និងកសាងមាតុប្រទេសឱ្យទទួលបាននូវសុខសន្តិភាព និងសម្បូររុងរោចន៍បន្តមក ... ។

រីឯព្រះអគ្គមហេសីទី ១ « ជ័យរាជទេវី » ជាព្រះកនិដ្ឋភគិនីវិញ ព្រះនាង

---

(១) សៀវភៅជ័យវរ្ម័នទី ៧ របស់លោក ហ្ស៊រក សឺដេស ប្រែសម្រួលដោយក្រមការ ជុំ ម៉ៅ ទំព័រ ២១ - ២២ ។

ពុំមានទេពកោសល្យអ្វីខ្ពង់ខ្ពស់ ( ដូចម្ចាស់បង ) តែព្រះនាងជានារីដែលមានព្រះទ័យពោរពេញដោយក្តីមេត្តា ប្រោសប្រណីដល់ពួក « ក្មេងស្រីកំព្រា » ឬជាក្មេងទុរគតក្រវេទនា ដោយប្រការផ្សេងៗ ។ ព្រះនាងចាត់ឱ្យគេស៊ើបយកដំណឹងពិត ពីទីកន្លែង និងចំនួន ហើយព្រះនាងទ្រង់យាងចុះធ្វើទំនាក់ទំនងពន្យល់ ណែនាំ និងប្រមូលក្មេងស្រីទាំងនោះឱ្យទៅរស់នៅជាក្រុម បួសជាសីលវតី (ដូនជី) ក្នុងមណ្ឌល នាភូមិមួយឈ្មោះ « ធម្មកេរ្តិ៍ » ដោយរបបឧបត្ថម្ភជាព្រះរាជទ្រព្យ ចេញពីព្រះនាងផ្ទាល់ ។

តាមប្រវត្តិក្នុង « អាទិទេពអង្គរ » ( Les Dieux d' Angkor ) មានចំណារខ្លះ ចារសរសើរពីគុណសម្បត្តិផ្នែកទស្សនៈថា ព្រះនាងជ័យរាជទេវី ទ្រង់មានព្រះគំនិត « បណ្តុះ ដាំ ជាដរាប, ពុំមានព្រះគំនិតក្តិចបំផ្លាញឡើយ » ។

យោងតាមប្រវត្តដ៏ខ្លីបន្តិចនេះ អាចឱ្យយើងសន្និដ្ឋានបានថា « ដូនជី » នៅក្នុងមណ្ឌលនៃភូមិធម្មកេរ្តិ៍នោះហើយ ជាកំណើតដើមនៃដូនជី គឺសីលវតី ឬសិលវន្តីនោះឯង ។

នេះជាព្រះកេរដ៏មានតម្លៃមួយផ្នែកពុទ្ធសាសនា នៃព្រះនាងជ័យរាជទេវី ដែលបានបណ្តុះផ្សាំ ដាំទុក តាំងពីសម័យអង្គរ ហើយអាចរស់នៅលើទឹកដីខ្មែរ ជាអ្នកកាន់ពុទ្ធសាសនា រហូតមកដល់បច្ចុប្បន្ននេះ ។

និយមន័យនៃ « សីលវតី » ៖ សីលវតី ជាអ្នកណា ? មានតួនាទីជាអ្វី ? ឋានៈប្រហែល ឬស្មើនឹងអ្នកណា ? មានគោលប្រតិបត្តិដូចម្តេច ?

• សីលវតី = អ្នកមើលឃើញនូវទុក្ខក្នុងសង្ខារ ហើយយកធម៌ជាទីពឹងរបស់ខ្លួន ។ សីលវតី គឺដូនជីនោះឯង ។ ដូនជី បើសរសេរថា « ដូនជីវ៍ » មានន័យរឹតតែត្រឹមត្រូវមែនទែន ព្រោះ ( *ធម្មេន ជីវតិ សីលមស្សាតិ > សីលវតី* = អ្នកណាមានជីវិតរស់ដោយធម៌ជាប្រក្រតី, អ្នកនោះបានឈ្មោះថា « សីលវតី » ) ។

• លោកមានតួនាទី ជាអ្នកសិក្សាធម្មវិន័យ និងជាអ្នកទ្រទ្រង់សីល រក្សា

សីលឱ្យផ្លូវផង់ ដូចសត្វត្រដេវរិចរក្សាពងវាយ៉ាងប្តូរផ្តាច់ យ៉ាងនោះឯង ។

• លោកមានឋានៈប្រហែល ឬស្មើនឹងសាមណេរ ( លោកនេន ) ព្រោះលោកមានសីល ១០ ដូចសាមណេរដែរ ។

សីលវតី និងសាមណេរ ប្លែកគ្នាដោយចំណុច ៣ ៖ ភេទ, សម្លៀកបំពាក់ និងការទទួលផ្នួស ( បព្វជ្ជា ) គឺ ៖

ក / សាមណេរ ភេទប្រុស, សីលវតី ភេទស្រី

ខ/ សាមណេរ ស្លៀកដណ្តប់ស្បង់ចីពរ, សីលវតី បិទបាំងកាយដោយអាវ និងសំពត់សសុទ្ធ ( មិនមែនជាពណ៌អម្ពត់ ),

គ/ សាមណេរ ទទួលផ្នួសដោយមានភិក្ខុ ជាអ្នកបំបួស ( ឧបជ្ឈាយ៍ ) ហៅថាបួសដោយ « សម្បទាកម្ម » ឯសីលវតី បួសដោយ « ចេតនាកម្ម » ។ គឺលោកមានអារម្មណ៍នឿយណាយក្នុងភាពជាគ្រហស្ថ ( អ្នកគ្រប់គ្រងផ្ទះ គ្រួសារ ) ដែលមានជីវិតប្រកបដោយកង្វល់សៅហ្មង, មើលឃើញនូវជីវិតរបស់ខ្លួនថិតនៅក្នុងអនិច្ចំ (មិនទៀង), ទុក្ខំ (ជាទុក្ខ), អនត្តា (មិនមែនខ្លួន) ឬមានឆន្ទៈចង់រំលៀកខ្លួន ឱ្យឃ្លាតឆ្ងាយពីអកុសលកម្ម ... ហើយតាំងចិត្តបួសដោយមិនមានឧបជ្ឈាយ៍ ( អ្នកឱ្យត្រៃសរណគមន៍ ) ។ ប្រភេទអ្នកបួសដោយចេតនាកម្មនេះ កើតមានឡើងតាំងពីមុនព្រះពុទ្ធបានត្រាស់ម្ល៉េះ ដូចជា តាបស, ឥសី ជាដើម ។

ទាំងអ្នកបួសដោយសម្បទាកម្ម ទាំងអ្នកបួសដោយចេតនាកម្ម មានឈ្មោះថា " សមណៈ បព្វជិត អ្នកបួសដូចគ្នា " ។ ព្រោះផ្នួសនោះ សម្រេចឡើងដោយសទ្ធា ជឿស៊ប់ ហ៊ានលះបង់សម្បត្តិផ្ទាល់ខ្លួន ៖ សក់ ចិញ្ចើម ទ្រព្យសម្បត្តិ និងគ្រួសារ ហើយចូលមកជ្រកកោនក្រោមព្រះរតនត្រ័យ ៖ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងស្មើជីវិតនោះ, ជាកត្តាខ្លឹមសារ ឬជាទិសដៅចម្បងរបស់គេ ។

## II . មូលហេតុនាំឱ្យកើតសីលវតី

មូលហេតុដែលនាំឱ្យកើតសីលវតី ឬ សីលវន្តី, ពោលដោយសង្ខេបក្នុងទីនេះ មានកត្តា ២ គឺ : ការរកទីពឹងជីវិត និងការភ្ញាក់រលឹកក្នុងសង្ខារ ។

* *កត្តារកទីពឹងជីវិត* : យើងគ្រប់គ្នា, កាលបើជីវិតត្រូវជួបនឹងវិបត្តិជាទុក្ខ : ព្រួយ ពិបាកចិត្ត, ក្រៀមក្រំចិត្ត និងចំបែងចិត្ត ដោយការបាត់បង់ធនធានយសស័ក្តិ, ព្រាត់ប្រាសកូន ប្រពន្ធ ប្ដីសី [១] ... កំព្រាឯកោ រស់នៅតែលតោលតែម្នាក់ឯង ឬធ្លាក់ខ្លួនជាមនុស្សក្រីក្រ, ស្វែងរកទីពឹងតាមផ្លូវចិត្ត និងតាមសម្ភារៈឥតជួបប្រទះ, ចម្បង, មនុស្សមិនទាន់ចង់ស្លាប់ មុនពេលដាច់ខ្យល់ព្រោះតែការខ្វះអាហារ ។ នោះហើយដែលគេម្នាក់ៗ ត្រូវស្វែងរកច្រក ឬផ្លូវដើរ ។

ធ្វើជម្រើសមើលទៅ ពុំឃើញអ្វីប្រពៃជាងការលះបង់គ្រហស្ថភាពហើយចូលទៅកាន់អាវាស ទ្រទ្រង់សីល ១០ ជាសីលវតី ឬសីលវន្តី នោះឡើយ ។

* *កត្តាភ្ញាក់ឭកក្នុងសង្ខារ* : នោះ, ពុំដូចកត្តាទី ១ ទេ ។ ចិត្ត និងជីវិតគេឥតមានវិបត្តិ ។ ពំនឹងជីវិត មានគ្រប់គ្រាន់ ។ ជីវិតគេស្រស់បំព្រងក្នុងការរស់នៅ ។ ប៉ុន្តែ គេជាមនុស្សមានបុព្វនិស្ស័យ មានធម្មសង្វេគ និងភ្ញាក់រឭកក្នុងសង្ខារ ។ គេមានការភិតភ័យថា « អនិច្ចំ ទុក្ខំ អនត្តា ជាមរតករបស់អាត្មាអញ » ។ បើធ្វើដំណើរចេញពីនេះ ( ស្លាប់ទៅ ) អញត្រូវមានស្បៀងជាប់ជាមួយ គឺកុសល ។ បុណ្យកុសល ជានិស្ស័យយាននាំអាត្មាអញឱ្យចេញផុតពីវដ្ដលោក ឆ្លងដល់វិវដ្ដ-លោក បានដោយពិត ។

ដោយសារទស្សនៈនេះ, ទើបគេសុខចិត្តខ្ជាក់ចេញ នូវអ្វីៗជាសម្បត្តិគ្រហស្ថទាំងអស់ ហើយចូលមកសន្សំស្បៀង (កុសល) ដោយទ្រទ្រង់ភេទជាសីល-

(១) ប្ដីសី = ប្ដីដ៏មានសិរីសម្រាប់ប្រពន្ធ ។

វតី ឬសិលវន្តី ដែលឆ្ងាយពីភាពសាំញ៉ាំ គឺកិលេសនោះឯង ។

យើងគួរគប្បីភ្ញាក់រឭកក្នុងសង្ខារតាំងពីមជ្ឈិមវ័យទៅ កុំចាំបច្ឆិមវ័យមកដល់, ព្រោះជីវិតយើងគ្រប់រូប « មិនទៀង » សោះឡើយ ។

## III . ទិសដៅប្រតិបត្តិ

គ្រាន់តែទទួលផ្នួសហើយ ទ្រទ្រង់សីលហើយ, សីលវតីទាំងឡាយនៅមានករណីយកិច្ចច្រើនទៀត ដែលត្រូវដើរទៅកាន់ទិសដៅប្រតិបត្តិរបស់ខ្លួន ។ ក្នុងទិសដៅប្រតិបត្តិនោះ ត្រូវបានចែកចេញជា ២ ដំណាក់ គឺ : ដំណាក់អប់រំ និងដំណាក់ប្រតិបត្តិ ។

*ក / ដំណាក់អប់រំ :* មុននឹងឈានដល់ប្រតិបត្តិបាន គេត្រូវទទួលការអប់រំ គឺសិក្សាធម្មវិន័យណាដែលចាំបាច់សិន ។ អប់រំបន្ទំលក្ខណៈចរិយា (កាយ វាចា) ឱ្យប្លែកពីគ្រហស្ថ ។ ហាត់ពត់ចិត្ត ឱ្យចូលទៅក្នុងគន្លងស្ងប់ចាកនីវរណៈ និងលោកធម៌ ។

អ្នកធ្វើដំណើរតាមផ្លូវ ត្រូវស្គាល់ផ្លូវ ។ ដើម្បីស្គាល់ ត្រូវសាកល្បង ឬរៀនសូត្រ ។ ដើម្បីចេះ យល់ដឹងពីផ្លូវ គឺធម៌អាថ៌បាន គេអាចសន្សំតាមរយៈស្តាប់ធម្មទេសនា, ធ្វើធម្មសាកច្ឆា និងស្តាប់ទ្រឹស្តី ពីប្រាជ្ញ បណ្ឌិត ដែលជំនាញក្នុងធម៌អាថ៌ ។ ដោយសីលវតីខ្លះ មិនចេះទាំងអក្សរផង លុះតែក្រេបជញ្ជក់តាមវិធីស្តាប់កត់ចំណាំនេះ ទើបអាចទៅជាអ្នកឆ្លៀវឆ្លាតក្នុងធម៌បាន ។

- ស្តាប់ធម្មទេសនា : ការស្តាប់ធម៌ទេសនា ដោយយកចិត្តទុកដាក់ ( ធម្មគារវ ) ជាការសិក្សាមួយដែរ ។ ការស្តាប់ទេសនាម្តង គឺជាការចូលបន្ទប់រៀនម្តង ធម្មកថិក ជាសាស្ត្រាចារ្យ, អ្នកស្តាប់ ជានិស្សិត ។ អនុវត្តដោយវិរិយៈតាមវិធីនេះ ញយៗទៅ យើងនឹងអាចក្លាយទៅជាបណ្ឌិតបាន ។

- ធម្មសាកច្ឆា ( សាកសួរធម៌ ) : ការជួបគ្នា ការប្រជុំគ្នា និងការចូលខ្លួនទៅជិតអ្នកប្រាជ្ញ ទៅជិតធម៌ ពោលពីធម៌ ឆ្លល់ពីធម៌ និងដោះស្រាយធម៌ ... ឈ្មោះហៅថា « ធម្មសាកច្ឆា » ។ យើងមិនចេះ មិនយល់ ត្រង់ចំណុចណាមួយ ហើយលើកចំណុចនោះសួរ, លោកប្រាប់មកនោះ គឺជាការដោះស្រាយបំភ្លឺ ។ យើងអាចយល់ដឹងរឹតតែច្បាស់ថែមទៀត ដោយវិចារណញ្ញាណ ត្រិះរិះពិចារណា ។

- អានសៀវភៅធម៌ក្តី ចូលវត្តសិក្សាក្តី ចូលរួមសិក្ខាសាលាក្តី ឬចូលសន្និសីទ សន្និបាតក្តី ដោយយកត្រចៀក និងឆន្ទៈសិក្សាទៅជាមួយផងនោះ, សុទ្ធតែជាករណីបង្ហូរចូលនូវពុទ្ធិសម្រាប់ខ្លួន ។

រួមន័យមក, វានៅត្រង់ខ្លឹមសារនៃសុភាសិត ដែលលោកពោលថា :

*« សុ. ចិ. បុ. លិ. ហិ សម្បន្នោ លហុំ សោ បណ្ឌិតោ ភវេ » ។*

*ការស្តាប់ ការគិត ពិនិត្យវេ ចេះឆ្លល់សួរគេ និងកត់ត្រា*

*បំពេញន័យនេះ ៤ ប្រការ នឹងបាននាមថា « បណ្ឌិត » ឆាប់ ។*

*ខ / ប្រតិបត្តិ:* កាលបើមានទុន ( ពុទ្ធិ ) ផ្នែកធម៌វិន័យ បានជាយានហើយ សីលវតី ឬ សីលវន្តទាំងឡាយ អាចឈានទៅកាន់គុណធម៌ខ្ពស់មួយកម្រិតទៀត គឺ « សមាធិ » ។ សមាធិ ជាវិធីសាស្ត្របាត់ពត់ចិត្ត ទាក់ទាញចិត្តឱ្យនៅនឹង ឱ្យស្ងប់ និងឱ្យមូលក្នុងអារម្មណ៍តែមួយ ។ គេដើរតាមវិធីនេះ តាមរយៈភាវនាបរិកម្មនូវកម្មដ្ឋាន = ថ្នាលការងាររបស់យោគី ។ កម្មដ្ឋាន ជាគ្រាប់ពូជ, សីល ជាធរណីឋាន, ឈាន សមាបត្តិ ជាពន្លកត្រួយ ( វិសុទ្ធិមគ្គ សមាធិនិទ្ទេស ) ។ ដូចនេះ, យោគី មុននឹងទទួលយកកម្មដ្ឋាន ត្រូវជម្រះសីលឱ្យបរិសុទ្ធជាបឋម ។

កម្មដ្ឋាន ជាមូលដ្ឋានប្រតិបត្តិរបស់យោគី មាន ៤០ : កសិណ ១០, អសុភ ១០, អនុស្សតិ ១០, អប្បមញ្ញា ៤, ព្រហ្មវិហារ ៤, ធាតុវវដ្ឋាន ១ និងបដិក្កូលសញ្ញា ១ រួមត្រូវជា ៤០ ។ នេះជាឈ្មោះ និងចំនួនការងារ គឺកម្មដ្ឋាន ។

នៅមានអន្លើធមិជាគ្រឿងផ្សំ អបស្ថុប និងជួយសម្រួលកម្មដ្ឋាននោះ ជាច្រើនទៀត : លះបង់បលិពោធ ( កង្វល់ ) ១០ យ៉ាង, ការគប់រកកល្យាណមិត្ត គឺអាចារ្យ, ការប្រគល់ខ្លួនចំពោះអាចារ្យ ( អ្នកដឹកនាំកម្មដ្ឋាន ), គប្បីមានអជ្ឈាសយធមិ ៦ យ៉ាង, និងគប្បីស្គាល់ច្បាស់នូវមូលកម្មដ្ឋានពីរ : សព្វត្ថកម្មដ្ឋាន និងបារិហារិយកម្មដ្ឋាន ថែមទៀត [១] ។ ល ។

ប៉ុណ្ណេះជាអាទិ៍, ជាកិច្ចប្រតិបត្តិ ដើម្បីឈានទៅកាន់ទិសដៅនៃសីលវតី ឬសីលវន្តី ដែលលះបង់ផ្ទះសម្បែង ហើយចូលមកតស៊ូ អត់ធ្មត់ ទទួលយកកម្មសិទ្ធិដ៏សមរម្យនៅត្រឹមតែ : សំពត់ អាវសសុទ្ធ ២-៣ សម្រាប់, អាវទ្រនាប់ (សំកិច្ចកៈ) ១-២, សំពត់ទ្រាប់អង្គុយ ( និសីទនៈ ) ១-២, ឆត្រ ឬក្រុត, ឈើច្រត់, ចង់យាម ឬស្បោង និងដែកកេះ ១ ប៉ុណ្ណោះ ។ អបិច្ឆតា ជាគ្រឿងបន្ទ្រោមលោកធមិ នីវរណធមិ និងលោភៈ ជាដើម ។

ការលាងជម្រះនូវគ្រឿងមន្ទិល មាននីវរណធមិជាបឋមនេះ ឱ្យរបេះបន្តិចម្តងៗ ហើយឈានទៅកាន់ឧត្តមធមិ គឺឈាន សមាបត្តិបាន, នោះជាទិសដៅ ដ៏កំពូលនៃយោគីជាសីលវតី ឬសីលវន្តី ដែលមានវីរិយៈប្រកបហើយយ៉ាងតឹងរ៉ឹង ។

« ... *ភិក្ខវេ ខយវយធម្មា សង្ខារា អប្បមាទេន សម្បាទេថ !* » = ម្នាលភិក្ខុទាំងឡាយ ! សង្ខារធមិទាំងឡាយ មានកិរិយាអស់ទៅ សូន្យទៅជាធម្មតា ( អ្នកទាំងឡាយ ចូរប្រតិបត្តិឱ្យបានម៉ត់ចត់ នូវធមិ-វិន័យនោះ ) ដោយសេចក្តីមិនប្រមាទចុះ !

ដោយ **គង់ ខេង**

(១) សូមពាចដានអានក្នុងសមាធិនិទ្ទេសថែមទៀត ផងចុះ ។

# សុភាសិតច្បាប់ស្រី

(តចប់)

បើនួនជាមានចិត្តឧបត្ថម្ភ
កុសលនាំជួយឱ្យបានក្តីសុខ
នឹងប្រាកដកេរ្តិ៍ឈ្មោះឮសុសស្រុក
ដរាបលុះឆ្ពោះមុខកាន់ពិមាន ។
ទេពសោឡសទាំងអស់នឹងសាទរ
ចំរើនពរបរិបូណ៌សុខក្សេមក្សាន្ត
ប្រកបយសខ្ពស់ល្អតវង្សវ៉ាន[១]
ព្រោះដែលបានប្រតិបត្តិម៉ែឪល្អ ។
មែនស្រីណាឫស្យាធ្វើទុច្ចរិត
ពុំមានគិតគុណលោកចិញ្ចឹមមក
ឃើញម៉ែឪដល់នូវសេចក្តីក្រ
មិនតបគុណលោកប៉ុនកេសី ។
(៨៥) គិតខ្មាសគេក្រែងមានគេសួរថា
នេះមាតាបិតាខ្លួនឬអ្វី ?
កែបន្លប់លុបគុណបុព្វការី
បដិសេធបិទសេចក្តីដទៃផ្តាស ។
យកឪពុកម្តាយខ្លួនជាខ្ញុំឯង
ស្តីគំហកស្តីកំហែងមិនក្រែងចាស់
ប្រើវិរកទូលតាមក្រោយមិនមានខ្មាស
តាំងប្រើប្រាស់សព្វទិនមិនបូជា ។
ស្រីយ៉ាងនេះតែរលត់ផុតជីវី
គង់មិនរួចឡើយអំពីជាតិនិរយា
មិនឃើញសែងសុរិយ័នព្រះចន្ទ្រា
នៅសោយទុក្ខវេទនាក្នុងអវិចិ ។
បើរស់នៅជាមនុស្សយើងនេះណា
ហ្វូងទេព្តានឹងផ្តាសាប្រក្រតី
ឱ្យពោកយ៉ាកលំបាកកើតអប្រិយ
លើសលែងក្តីដែលធ្វើឱ្យលោកក្តៅ ។
ទោះជាមានធនធានទ្រព្យទាំងឡាយ
គង់អន្តរាយខ្ចាយពាសវិនាសទៅ
កើតចោរភ័យអគ្គីភ័យមកសត្រូវ
ព្រោះចិត្តខ្មៅទុច្ចរិតគិតនេរគុណ ។
(៩០) ស្រីយ៉ាងនេះប្រុសកុំនែបរអែបរួមរ័ក
នឹងថយស័ក្តិយសសាបលាភខាតទុន
ត្រឹមតែម៉ែឪវាគ្មានការុណ្យ
នេរគុណមិនមានគិតអនិច្ចា ។

(១) វ៉ាន ប្រែថា " ពូជ " (ពាក្យថៃ) ។

ស្រីមិនល្អគួរកុំគប់សម្ភពជិត យកជាមិត្រឱ្យហ្មងដល់អាត្មា
គួរចៀសវាងឱ្យឆ្ងាយចេញពីវា ស្វែងរកគ្នាចិត្តបុណ្យដឹងគុណគាប់ ។
ចូរទូន្មានចិត្តខ្លួនឱ្យស្លូតត្រង់ រក្សាវង្សជាក្រមុំតាមក្រមច្បាប់
កុំមួម៉ៅទៅដោយការសាប់ឡាប់ មើលសណ្ដាប់អ្នកល្អតវង្សវ៉ាន ។
កុំធ្វើក្រៅច្បាប់ស្រីឱ្យក្ដីខុស ស្រឡាញ់ប្រុសក្រៅចិត្តម៉ែឪប្រាណ
កាត់ប្រយោជន៍សាលោហិតមិត្រសន្ដាន ឱ្យលោកបានទុក្ខទោសក្នុងលោកិយ ។
ប្រុសជ្វជាតិញាតិស្អប់បំបែកចេញ ទៅស្រឡាញ់រត់តាមយកជាប្ដី
ជំរត់គ្នាទៅឡើងលោកមន្ត្រី តជាក្ដីនឹងម៉ែឪនៃប្រាណ ។
(៩៥) ម៉ែឪសោតក្រោធសល់ទាល់គំនិត មិនដឹងគិតកែការក្ដីនោះបាន
នាំគ្នាយំក្រំចិត្តអាណិតប្រាណ ព្រោះកូនគ្មានអៀនខ្មាសផ្ដាសខុសផ្លូវ ។
លេបក៏ស្លាក់ខ្ជាក់ក៏ស្លែងលែងមិនបាន នឹងគិតអានការអៀនគ្មានផ្លូវទៅ
ខ្លះមិនដឹងគេក៏សួរដល់ម៉ែឪ ថានាងនោះកូនចៅអ្នកណាហ្ន៎ ! ។
ខ្លះដែលស្គាល់គេក៏ប្រាប់គ្នាសាយសុស ថានាងនោះកូនអ្នកនោះឮគេថា
រត់តាមប្រុសថាឈ្មោះដូច្នោះខុសពង្សា អនិច្ចាម៉ែឪនៅមិនសុខ ។
ខ្មាសអើយសែនខ្មាសគេពេកក្រៃ កូនចង្រៃអប្បលក្ខណ៍បំបាក់មុខ
មិនអាណិតចិត្តអ្នកម្ដាយឪពុក បំណាច់ថ្នមតាំងទុកតាងនេត្រា ។
នៃអនង្គនារីរូបប្រសើរ នាងកុំដើរផ្លូវខុសណ៎ានួនណ៎ា
ចូរតាំងឱ្យសណ្ឋិតដោយឥរិយា ការក្ដីវង្សពង្សាឋាននន្ដរ ។
(១០០) កើតជាស្រីគ្មានអ្វីសងគុណម៉ែ រក្សាតែក្ដីលោកឱ្យថាវរ [១]
ស្មើសងគុណដែលលោកពឧទរ ប្រាកដឮនាមករខ្ចរខ្ចាយទៅ ។
ចូរស្ងួនចិត្តគិតកាយជាក្រមុំ កុំនិយមឱ្យខុសពីម៉ែឪ

(១) ថាវរ « មាំមួន » ពាក្យបាលី, សំស្រ្កឹតក្លាយជា «ស្ថាពរ» ។

ស្ងួនរក្សាចរិតឱ្យត្រឹមត្រូវ ដិកល់នៅក្នុងពាក្យឱវាទទាន ។
ទោះប្រស្រ័យចរចានរណានោះ កុំពោលពាក្យទ្រគោះឱ្យមោះមាន
មិនគួរស្តីអញមឹងឱ្យខឹងខាន ពាក្យតិរច្ឆានកុំថ្លែងសំដែងចេញ ។
ឬនឹងរៀនផ្លូវឈ្នួញជួញលក់ដូរ ស្តីឱ្យគួរពោលពាក្យជាសម្លាញ់
ទើបលក់ដូរទិញងាយបានចំណេញ ព្រោះគេពេញចិត្តចាប់ដោយវាចា ។
ជាមនុស្សនេះនឹងសំគាល់ត្រឹមខ្យល់មាត់ ការមានខ្សត់កើតយសព្រោះជិវ្ហា
បើពាក្យល្អពាក្យពិរោះចេញកាលណា គេមេត្តារាប់អានបានលាភលន់ ។
(១០៩) ទោះប្រុសណាមកប៉ងបំណងចង់ កុំពិរោធក្រោធបង្កើតអាក់អន់
កាលមិនស្នេហ៍ក៏កុំតែតពាក្យព័ន្ធ វានឹងបណ្តោយជាន់ព្រោះធ្លាប់ស្និទ្ធ ។
ឯជាតិប្រុសទោះជាព្រើលមិនមើលឋាន បើព្រមល្មមប្រាណទើបប៉ានជិត
បើស្រីវាទំពារឹងនឹងនៅនិត្យ មិនប៉ានជិតចូលស្នេហ៍ទេអនង្គ ។
ទឹកនឹងប្លូរ ៗ តាមប្រឡាយជីក ផ្កានឹងរីក ៗ តាមសែងសុរិយង់
ព្រះពាយផាត់គន្ធភមរ[(១)] ត្រង់ ប្រុសអាចចង់ព្រោះស្រីចើកបើកអាការ ។
ហេតុនោះនួនចូរស្ងួនរក្សាប្រាណ កុំឱ្យមានហ្មងសៅផ្លូវឧច្ចារ
កាត់តម្រាយប្រឡាយប្រុសប្រើអាការ កុំស្និទ្ធស្នាលដោយអាសារការមិនត្រូវ ។
ពាក្យសំដីស្តីតាមការណ៍ដែលមាន និយាយបានមិនហាមទេឆោមឆ្នៅ
ហាមតែកេរ្តិ៍ឥរិយាការមិនត្រូវ បង្ហាញផ្លូវឱ្យប្រុសខុសវេណី ។
(១១០) ច្បាប់លោកហាមគួរតាមច្បាប់លោកហាម កុំមួតាមកាមរាគរោលឥន្ទ្រិយ
គិតឱ្យត្រូវតម្រាប់ច្បាប់នារី ប្រកបការរកស៊ីតាមធម្មតា ។
មួយការដេកដើរឈរអង្គុយក្តី ចូររវាំងកាយស្រីតាមឥរិយា
កុំបន្ទាន់រាន់ដើរភ្លេតភ្លាត់ថា មែនបើភ្លាត់បាទាដួលខ្មាសគេ ។

---

(១) គន្ធ " ក្លិន " ភមរ «កន្លង់» ។

យើញអ្នកចាស់ឬអ្នកធំប្រជុំខាង      កុំគ្រវាសដៃកាងបំបែរវេ
ចូរឱនតួចរទៅសុំផ្លូវគេ      ឱ្យគេអត់ទោសមេស្ទួមយាត្រា ។
មួយបើទៅផ្ទះគេដោយមានកិច្ច      តែស្ទួវេច[(១)] ធុរះឆាប់ម្ទីម្នា
កុំនៅយូរក្រែងគេជិនកើតនិន្ទា      សេចក្ដីជួប្រច័ក្សជាមានដល់កាយ ។
បើអង្គុយចូររវាំងសំពត់ស្លៀក      នឹងស្បៃកៀកចោមពុងសំយុងជាយ
មើលសម្រួលឱ្យស្រួលលំនាំកាយ      យាមសប្បាយនឹងសើច ៗ ឱ្យគួរ ។
(១១៩) ប្រើសន្សឹមញញឹមតែត្រឹមភ័ក្ត្រ      កុំសើចហើាស្ទួរលាក់ឱ្យលាន់សូរ
កុំឆ្កាដៃឆ្កាជើងឡើងអម្បូរ      ពាក្យមិនគាប់ពេលមិនគួរឱ្យឮឆ្ងាយ ។
នឹងតែងតួក៏កុំមួតែការតែង      នឹងលាបប្រេងក៏កុំលាបឱ្យហូរខ្ចាយ
នឹងលាបម្សៅកុំលាបឱ្យលឿងកាយ      គេនឹងសើចឡកឡាយដល់ឆោមឆ្លៅ ។
កាលយាមត្រុដិសង្ក្រាន្តមានការហ្លួង      តែងឱ្យសមតាមក្រសួងតាមពង្សផៅ
លុះអស់ខែត្រទេសកាលធ្វើការទៅ      កុំមួនៅតែងតួអស់ខួបខែ ។
ខ្លួនអ្នកក្រត្រូវពិនិត្យគិតរកស៊ី      តាមវេណីត្រកូលវង្សឪម៉ែ
ដាំដំណាំដូងស្លាចំការស្រែ      ឧស្សាហ៍ថែមើលស្មៅជួយដាក់ជី ។
រៀនវិជ្ជាឱ្យចេះជាគ្រូគេ      ទើបទំនេរមិនស្ទួវនឿយឥន្ទ្រិយ
ចេះសើរ ៗ មិនស្មាត់ហាត់តិមធី[(២)]      ជានារីមិនចេះអ្វីបីនឿយឯង ។
(១២០) មានខ្ញុំស្រីខ្ញុំប្រុសប្រើសប្បាយ      ខ្លួនជានាយល្ងង់ការវាមិនក្រែង
ចេះជាជាងមិនព្រួយទៅរើកសែង      ការផងឯងត្រូវយកចិត្តទុកដាក់ ។
មានមាសប្រាក់ដាក់ទុកសម្រាប់កាយ      កុំចែកចាយឱ្យគេរួតថាមានប្រាក់
ការគួរចាយឱ្យចាយបំរុងស័ក្តិ      សង៉ាភ័ក្ត្រព្រោះប្រាក់តាំងជាមុខ ។
កុំកកាញ់កំណាញ់ក្រៅតម្រា      កុំសទ្ធាធ្វើបុណ្យយល់ដោយមុខ

(១) ស្ទួវេច គឺ ស្រេច, រួច, ចប់ ។ (២) តិមធី " ពេញចិត្ត, ហួសចិត្ត " ពាក្យថៃ ។

កុំអាងប្រាក់ចាក់ចាយវាយស៊ុកគ្រលុក ចាយមើលមុខទុកមើលក្រោយការគ្រាក្រ ។
ជាស្ត្រីភ្នាក់ងារចំណែកផ្ទះ មើលជម្រះបោសច្រាសតាំងឱ្យល្អ
ទាំងផ្ទះបាយឧសទឹកស្រូវអង្ករ គ្រឿងដាំស្លថៃទាំឱ្យមាំមួន ។
អ្វីវាយរើសទុកតាមកន្លែង អ្វីបាត់ខំស្វែងរកឱ្យធួន
ដល់ត្រូវការមានស្រាប់សម្រាប់ខ្លួន មិនលំបាកយ៉ាកនួនណ៌ានួនណ៌ា ។
(១២៩) មួយសោតយប់និទ្រាវេលាដេក ចូលដំណេកបោសច្រាសទីនិទ្រា
អុជទៀនធូបប្រណម្យផ្ដុំបូជា ក្រាបវន្ទារំលឹកគុណព្រះរតនត្រៃ ។
បីដងស្រេចសន្សឹមនិទ្រាទៅ ទើបកើតនៅវិបុលមង្គលជ័យ
ពេលនឹងក្រោក ៧ មុនអរុណខៃ កុំដេកហួសដល់ថ្ងៃចង្រៃខ្លួន ។
ក្រោកចេញមកយកទឹកទន់លុបភ័ក្ត្រ សំអាងខ្លួននួនអ្នកឱ្យសមសួន
ប្រកបការបណ្ដាមានរបស់ខ្លួន មើលថែធួនក្នុងក្រៅតាមក្រឹត្យស្រី ។
កុំប្រមាទសង្ហាររអាត្មាក្មេង ប្រកបលេងដោយល្បែងពុំជួក្ដី
អំពើពាលនាំពៅឱ្យអប្រិយ ការលោកិយច្រៀងរាំនាំវង្វេង ។
កុំគប់ស្រីសាមាន្យសន្ដានជួ ដែលតែងតួខុសចរិតចិត្តអ្នកលេង
តែសុរិយាទន់ ៧ ចេញទន្ទេង តាំងសំដែងក្លែងឱ្យប្រុសយល់ឡែបខាយ ។
(១៣០) តែព្រឹកព្រាងស្អាងស្អិតសិតសយសក់ ឆ្នុះកញ្ចក់រយដងហ្មងតែកាយ
ត្រង់កិច្ចការរកស៊ីក៏នឿយណាយ ដើរកៃក្រាយគប់ភៀនពាលដូចគ្នា ។
តែឮស័ព្ទសូរស្គរឬគងឃ្មោះ ក៏ត្រាច់ដើរស៊ើបស្ទុះសួរគេថា
ថ្ងៃនេះកើតមានល្ខោនរាំភូមិណា លុះដល់ថារាំងណោះស្ទុះលឡើក ។
ចូលជ្រកជ្រៀតបៀតប្រុសត្រដុសប្រាណ នឹងដូចប្លុងកម្មដ្ឋានគ្មានកំរើក
ប្រុសលលាមល្ងកផ្ទិតដោយចិត្តចើក លុះល្ខោនលើកវ៉ារាំនាំគ្នាទៅ ។
ទាល់ខុសខ្មោចកេរ្តិ៍អសោចិ៍ឮសុសស្រុក ម្ដាយឪពុកដាក់មុខទុក្ខផ្សាក្ដៅ

អាប់ទាំងអង្គអាប់ទាំងវង្សពង្សពូជផៅ ព្រោះមិនត្រូវច្បាប់បុរាណបាននិន្ទា ។
(១៣៩) ខ្លះស្រឡាញ់អ្នកលេងចេះច្រៀងត តែឮឡូឡើងតាំងរៀបបរិស្លា
ប្រោះទឹកអប់ផ្ទុំត្រឡប់ទាំងកាយា បប្លូលភៀនយាត្រាទាំងរាត្រី ។
ចូលទៅស្តាប់ចិត្តមិនចាប់ទំនុកច្រៀង អង្គុយមៀងមើលប្រុសដែលបេត្តិ
ប្របៀតក្រោយលួចឱ្យស្លាបារី ប្រុសបានទីនាំលីលាចូលស្តុក ។
លលើទៅឥតខ្មាសផ្តាសវង្វេង ដូចដីរីចុះប្រេងគ្រលែងភ្លុក
ហ្មខ្វាន់ [១] កាប់សាប់សិរបំបែរមុខ មិនរារុកចាក់វាងវាងចូលរោង ។
ញាតិសន្តានដាស់តឿនឱ្យនឹងហ៊ុំ ត្រឡប់ខឹងតបតកែប៉ផ្លូង
ជេរគេឯងថាក្លែងជាស្រីរោង ឆ្កាដៃព្រោងកែខ្លួនថាន្លួនជា ។
កោតហ៊ុំន្លួនចោលក្បួនសុភាសិត មិនប្រព្រឹត្តតាមពង្សវង្សមេបា
ទៅស្រឡាញ់អ្នកលេងតែងកាយា នាំផឹកស្រាជក់អាភៀនញៀនអស់ប្រាណ ។
(១៤០) ខ្លះស្រឡាញ់ប្តីគេ ៗ មានប្រាក់ លួចលាក់ស្នីគ្រស្នោះចិត្តមិនគិតស្មាន
ប្រពន្ធគេ ៗ ដឹងខឹងរំខាន ខ្លួនទៅបានក៏បានជាចុងគេ ។
មែនប្រទះប្រពន្ធដើមឆ្នើមប្រច័ណ្ឌ ខឹងក្តួចកាន់ចងអាឃាដបញ្ចោរជេរ
ខ្លួនជាចុងប្រុងចុះនៅក្រោមគេ សុខគ្មានទេមេអើយកុំសង្ស័យ ។
ខំផ្គាប់គេយកចិត្តស្និតគេគាប់ គុណាត្រឡប់ជាទោសទាំងយប់ថ្ងៃ
កោតចិត្តកនិដ្ឋាពេញចង្រៃ យកប្តីគេខុសនិស្ស័យបានក្តីក្តៅ ។
ស្តាយអើយស្តាយរូបរាងស្រស់ពិសី មិនគប្បីយកប្តីឱ្យហ្មងសៅ
ញាតិសន្តានបងប្អូនស្តីប្រដៅ មិនតាមវង្សពង្សផៅទើបសៅហ្មង ។
យកប្តីគេឱ្យគេជេរបរាមុខ កំឡោះគេពេញស្រុកម្តេចមិនចង
គេទំនេរតាមតែចិត្តន្លួនល្ងង នឹងបែរខ្នងឬបែរមុខតាមសុខចិត្ត ។

(១) ហ្ម គឺ ទម័ក ; ខ្វាន់ គឺ មង្គល, សួស្តី ។ បានសេចក្តីថា ទម័កជាមង្គល ។

(១៤៥) នេះកម្មអ្វីទៅបានឯប្ដីគេ ឱ្យគេជេរជៀលប្រាណគ្មានអាណិត
ព្រោះនួននាងឆោមឆ្លៅខ្លៅមិនគិត ទៅជឿចិត្តប្រុសប្រឡោមលោមឱ្យលង់ ។

ស្រីពួកនេះគ្មានចំរើនទេឆោមឆ្លៅ ស្រីណានៅឆោតទៅក៏អស់ទ្រង់
ឯនារីទើបតែពេញចំទង់ កុំព្រាប់យកទុកអង្គឱ្យអប្រិយ ។

សុភាសិតយើងតែងទុកទូន្មាន ខំរើសយកទុកប្រាណជាច្បាប់ស្រី
ទាញយកតួស្រីជួមកស្រដី ជាទិតៀនស្មារតីស្រីរាល់គ្នា ។

មានស្រីខ្លះក្លាហានមិនមានកេរ្តិ៍ គប់ប្រុសពីរតាមអំពើចិត្តពាលា
រងឯណោះរ៉ាប់ឯណេះមិនចេះរា ប្រុសដឹងគ្នាកើតសម្លាប់កាប់គ្នាឯង ។

ទាល់លុះនូវព្រះរាជអាជ្ញាហ្លួង ត្រូវគេខ្នងផ្ទងកច្រវាក់វែង
ឱ្យឡើងលើឈើអណ្ដែតគេដោតខ្វែង បីថ្ងៃតែងស្លៀកសំណាញ់សៀតផ្កាច្បា ។

(១៥០) ដើរអាក្រោសឮសុសទៅទាំងស្រុក ស្រមូញមុខកើតទុក្ខអនេកណា
សែនខ្មាសសល់ទាល់តួតួរអនិច្ចា ព្រោះប្រាថ្នាប្រុសពីរស៊ីមិនឈប់ ។

មានស្រីខ្លះលុះល្បែងលេងបៀរប៉ោ ប្រុសចោមឆោលេងភ្នាល់ទាល់ព្រលប់
ចាញ់អស់ប្រាក់គ្មានចាក់ក៏ពុំឈប់ ដល់ពេលយប់យកទ្រព្យលក់ឱ្យចិន ។

មួយដំឡឹងពីរដំឡឹងក៏ព្រមស្មគ្រ ឱ្យតែខាងបានប្រាក់ចាក់ប៉ោសិន
នួនមិនមានរើសមុខថាយួនចិន សំដែងក្បិនចុះក្បួនអ្នកស៊ីឆ ។

ឱ ! អនិច្ចានារីរូបស្រស់ល្អាវ កំពុងសាវទើតពកពន្លកល្អ
មិនរក្សាឥរិយាឱ្យនឹងហ្ន៎ នឹងបានឥវង្សវែងអង្វែងទៅ ។

នេះបង្អឹកាច់លក់កំពុងពក ចុះថ្លៃថោកក៏យកឱ្យអាស្រូវ
កោតហ្ន៎គេម្ដេចគេដើរខុសផ្លូវ ត្រដរទៅទាល់លុះចុះរោងវែង ។

(១៥៥) នឹងពឹងញាតិគេក៏ស្អប់មិនរាប់អាន ព្រោះសន្ដានគិតខុសលុះដោយល្បែង
គេបានហាមខ្លួនមិនតាមត្រឡប់ក្លែង ថាគេព្យាបាទឯងមិនឱ្យបាន ។

ដល់ធ្លាក់ខ្លួនទួនក្លាយជាខ្ញុំគេ   នឹងបែរវេរកញ្ញាតិជួយប្រោសប្រាណ
ញាតិឯណានីមួយនឹងជួយបាន   សំបុត្រសានឡើងជារៀលបីរយបាទ ។
មុខក្រជាំខំបំរើការប្រាក់គេ   ខ្ជិលគេជេរវាយទៅតាមមារយាទ
ទោសទាំងនេះព្រោះចៅមិនតាមញាតិ   គិតប្រមាទល្បែងភ្នាល់ដល់វេទនា ។
ប្រុសអ្នកល្អកាលណានឹងក្លាហាន   មករួមស្ថានយកចៅជាភរិយា
មានតែពួកអ្នកលេងល្បែងដូចគ្នា   នោះទើបវាយកចៅទៅតាមកម្ម ។
មានស្រីខ្លះឆ្លាសឆ្លៀវកៀវចង់ប្រុស   ដែលមានយសខ្ពស់ស័ក្តិដ៏មួនមាំ
ស្វែងរៀនស្នេហ៍ឡែកលំដាក់ប្រចាំ   សាំទាំងថ្នាំយ៉ាបៀ [១] បានដូចប៉ង ។
(១៦០) ប្រុសក៏លង់វង្វេងស្រឡាញ់ខ្លាំង   វាក៏តាំងតែងខ្លួនឱ្យនួនល្អង
បង្កាច់ប្រុសឱ្យលុះក្នុងបំណង   ចាំចិត្តចងចុះអំណាចខ្លាចវាខ្លប ។
វាក៏លួចលាក់ប្រាក់ចាយតាមចិត្ត   លេងបាំងផ្ចិតទល់មុខគ្មានរបាប
ប្អូនប្រាំដងម្តង ១ ផ្ទេរពីដប   ទាល់តែក្របធ្លាក់ក្រត្រដរទៅ ។
ខ្សែសង្វារចារ៉ុកន្ត្រមកងអង្កាំ   ក៏លួចយកទៅបញ្ចាំគ្មានសល់នៅ
លេងគ្រឿងយសទាល់តែអស់ពីទូទៅ   ប្តីមិននៅក៏ចាយជាតិឱ្យគេ ។
ប្តីត្រឡប់ដឹងសព្វជាអស់ធន   ទោះជាខឹងនឹងប្រពន្ធមិនប៉ានជេរ
ក្រែងវាលែងឯងខានមិនបានស្នេហ៍   ក៏ខំតែបាំងបិទយកចិត្តវា ។
បងប្អូនដឹងគេក៏ខឹងទៅប្រាយប្រាប់   ចៅប្តីនោះមិនជឿស្តាប់ពាក្យគេថា
ត្រឡប់ខឹងនឹងពួកញាតិកា   ទាល់តែធ្លាក់សក្តានិច្ចាខ្លួន ។
(១៦៥) ឱ ! អាណិតមនុស្សប្រុសមកលុះលង់   ឱ្យមាតុគ្រាមគ្របអង្គមិនគង់ក្បួន
អស់សម្បត្តិមាសប្រាក់ធ្លាក់ទាំងខ្លួន   វាមានប្រុសដល់បីបួនក៏បិទទៅ ។
កើតទាំងនេះក៏ព្រោះភ្លើងរាគរោល   មិនកញ្ជ្រោលដោលចេញសម្ងំនៅ

---

(១) យ៉ាបៀ = ថ្នាំបំពុល (ពាក្យថៃ) ។

ទាល់តែឱ្យវារោលរលាកក្តៅ ក៏ស៊ូទៅតាមកម្មចាំចិត្តស្នេហ៍ ។
ខាងវាសោតចេះតែសាងសំអាងអង្គ ឱ្យប្រុសលង់ក្នុងកាមតាមតែបែរ
គប់សហាយប្តីដឹងក៏ប្រឹងកែ ស៊ូស្បថស្បែឱ្យប្តីចុះជឿចិត្ត ។
ស្លាបារីផ្តាប់ប្តីពេញប្រអប់ ប្តីក៏សព្វគាប់ចិត្តរឹងស្មាលស្និទ្ធ
ស្មានប្រពន្ធស្ម័គ្រស្មោះអស់ពីចិត្ត តែងមិតវាងវុលដល់សហាយ ។
ផ្តង់ទាំងពីរមិនឱ្យប្រុសសន្ទិះ ផ្តាប់ឯណោះផ្តង់ឯនេះបានសប្បាយ
មាយានេះប្រុសមិនដឹងក្នុងឡែបខាយ តាំងចិត្តហ្មាយថាប្រពន្ធខ្លួនស្លូតត្រង់ ។
(១៧០) ទោះគេប្រាប់ក៏មិនស្តាប់មិនជឿស្តែង ព្រោះឃើញវាផ្តាប់ឯងនោះពេញវង្ស
មិនសង្កេតមើលហេតុទៅខាងក្នុង ឃើញតែក្រៅហើយក៏ស្លុងជឿថាជា ។
ប្រុសល្ងង់ល្ងីតដោយឫទ្ធិរាគរោលខ្លាំង មោហៈបាំងមើលមិនយល់កលមាយា
ឱ ! អនិច្ចាជាតិប្រុសនេះខុសគ្នា ម្តេចក៏គ្មានបញ្ញារំពឹងខ្លះ ។
ខ្លះនោះសោតឆោតនៅខ្លៅខ្លាចស្រី វាប្រើជ្រប់កេសីស្នើកញ្ចះ
បើទៅរកស៊ីមកពុំបានខ្លះ តែដល់ផ្ទះវាក៏ជះដូចភ្លើងព្រៃ ។
កាលរកបានគ្រាន់ក្សាន្តអររីក បើមិនបាននោះកុំនឹកឡើយអ្នកម៉ែ
បាយនឹងស៊ីឃើញជាមិនឆ្អែតផ្ទៃ យប់នោះដេកទីទៃហើយតាជី ។
ឃើញតែបានត្រង់បង់មិនចង់បង់ តែមិនយកចិត្តចង់ជួយស្វាមី
ការតិចតួចក៏ដំរូចប្រើតែប្តី ហោចទៅដល់ស្លាបារីប្តីមូរឯង ។
(១៧៥) ស្រូវអង្ករដាក់ទុកជង្រុកធំ កើបដូរនំដូរមីស៊ីជាល្បែង
ចាយក៏ធំស៊ីក៏ធំមិនមានក្រែង តែប្តីខ្ជិតវាក៏ខ្នែងចំទែងឈ្លោះ ។
មួយបើទាល់គិតកលកុបាកប្តី បិទសេចក្តីអាក្រក់ទុកក្នុងពោះ
ប្តីដឹងដល់ផ្តាល់នេះវាផ្ទួញនោះ ប្តីថាច្នោះវាថាច្នេះមិនចេះយ៉ម ។
មានស្រីខ្លះមាក់ងាយព្រោះប្តីខ្សត់ កិនសង្កត់ឱ្យលុះអំណាចព្រម

ប្រើឫកពាលើកស័ក្តិហាក់ចៅចម
តែប្តីឈមវាក៏ប្រែកែមិនប្រប ។
ញាតិសន្តានខាងប្តីមិនរាប់អាន
តែសន្តានខាងខ្លួនចេះប្រកប
ញាតិណាមានរាប់អានទៅអរអប
ញាតិណាក្របក្រប្រាក់ហាក់វាហី ។
មានស្រីខ្លះមាក់ងាយព្រោះប្តីខ្លៅ
បង្អាប់ទៅតាមការមិនជួក្តី
ប្រើទ្រគោះស្តីគំរបបង្រ្កបប្តី
ធ្វើអ្វី ៗ ទោះជាត្រូវក៏នៅខុស ។
(១៨០) បានបន្តិចប៉ុចអួតបញ្ឆេងឆង
ថាចេះចាត់ចេះចែងទើបបានខ្ពស់
អនិច្ចាហ៊ំពួកយើងប្រុស ៗ
នឿយស្ទើរតែមិនរស់ឈ្មោះមិនមាន ។
មានស្រីខ្លះមាក់ងាយព្រោះប្តីទាប
អួតអត្តភាពមានពង្សវង្សសន្តាន
និយាយអ្វីនឹងប្តីពុំឱនប្រាណ
ប្តីហើបបានតែមួយម៉ាត់កាត់យកឯង ។
គ្មានគោរពប្រតិបត្តិបំរើប្តី
បើធ្វើអ្វីឱ្យតែដៃចង្អុលខ្វេង
តាំងចំទួយដៃចំទាស់បង់ចំខែង
ស្តីកំហែងតែងគំហាកបង្រ្កបប្តី ។
ប្តីពុំប៉ានហើបហាថាអ្វីឱ្យ
ចេះតែដោយឱ្យប្រើធ្វើអ្វី ៗ
ទាស់បន្តិចវាក៏ក្អិចប្តីឯមន្ត្រី
អាងតែប្តីឥតញាតិជាអ្នកធំ ។
ញាតិខាងគេ ៗ ក៏កាន់វាក៏កឹង
ឯងមិនខុសវាក៏ខឹងរឹងបង្ខំ
ពោងទន់តាមទើបបានគ្រាន់សម្ងំ
តែងឯខំវាក៏ខែងឯងក៏ខូច ។
(១៨៥) ប្រពន្ធធំលើសប្តីអប្រិយពិត
ឱ ! អាណិតចៅប្តីគ្មានពង្សពូជ
រីងឯណាក៏បានព្រោះប្រាណតូច
ពោងទទួលខុសខូចលើអាត្មា ។
នៃអនង្គនារីរូបចំណាប់
អញ្ជើញស្តាប់ស្រីខូចណ៏ានួនណ៏ា
ស្រីពួកនេះសឹងចុះក្នុងតម្រា
ត្រកូលកាឡកណ្ណីស្រីសាមាន្យ ។
នាងកុំព្រាប់តាមគេណ៏ាមេទូច
នឹងអាប់អង្គពង្សពូជវង្សសន្តាន
ឧស្សាហ៍តាំងសតិរំលឹកប្រាណ
បើឯងបានស្វាមីគប្បីផ្គង់ ។
បំរុងផ្គាប់ដោយកាយវាចាចិត្ត
សុចរិតចិត្តស្មោះភក្តិត្រង់

ចូរស្ងួនស្ងៀមចៀមតួ(១) បន្ទន់អង្គ កុំប្រកួតកាន់វង្សឱ្យកីនណា ។
ពេលនិទ្រាចូរបោសទីដំណេក កាលនឹងដេកៗឆ្វេងនៃភស្តា
កុំទន្ទឹមក្បៀកកើយខ្នើយស្មើគ្នា ចូរនិទ្រាខិតក្រោមល្មមប្រតិបត្តិ ។
(១៩០) ដល់ពេលក្រោកចូរនាងក្រោកមកមុនប្តី ស្លាបារីទឹកទន់នាងរៀបចាត់
ពេលល្មមដាស់ ៗ ប្តីដោយកិច្ចវត្ត គឺលើកហត្ថស្ទាំចាប់បាទព្រះភស្តា ។
ប្តីចេញមកយកទឹកទន់លុបភ័ក្ត្រ កន្សែងសាក់ហុចឱ្យជូតភក្ត្រា
ចេញមកចាត់ដាំស្លតាមវេលា ស្រេចកាលណាលើកមកតាំងតាមទី ។
អញ្ជើញប្តីបរិភោគគ្រឿងក្រយា លាងដៃស្វាមីឱ្យអស់រាគី(២)
អង្គុយនៅបំរើប្រចាំទី ប្តីហូបរួចស្ងួមស៊ីជាក្រោយបោង ។
បើប្តីហៅចូលផាសអធ្យាស្រ័យ នាងលើកដៃសំពះបានបីដង
អង្គុយបត់បាទាណានួនល្អង ជាទំនងគោរពនូវភស្តា ។
សូវេចបាយខ្វល់ខ្វាយក្នុងការខ្លួន មើលថៃថ្លួនសព្វទីស្រែចំការ
ខាងការស្រីភ្នាក់ងារនៃអាត្មា ខំឧស្សាហ៍កុំប្រមាទឱ្យខាតខាន ។
(១៩៥) ប្តីទៅព្រៃនាងស្រីរក្សាផ្ទះ មើលដំរះបោសច្រាសលំនៅស្ថាន
ប្តីរកស៊ីបានមកឱ្យកល្យាណ រក្សាទុកកុំមានក្តីមាក់ងាយ ។
អធ្យាស្រ័យពួកញាតិសាលោហិត យកជាមិត្ររួមទុក្ខសុខសម្លាយ
បានអ្វីប្លែកគប្បីនាងចែកចាយ មើលនាយអាយឱ្យគួរនឹងសន្តាន ។
កុំឆ្មើងឆ្មៃកាន់ខ្លួននួនវល័ក្ខណ៍ ឱ្យកីនស័ក្តិកីនយសហួសវង្សវ៉ាន
ប្រើមធ្យមឱ្យសមនឹងសន្តាន រក្សាប្រាណរៀនប្រេបស្រេបភស្តា ។
ប្រការមួយរៀនស៊ីឱ្យគួរស្តាប់ បញ្ចេញស័ព្ទឱ្យសមនឹងវាចា
បើប្តីផ្ទាក់នាងផ្ទមយកចិន្តា ប្រឡោមស្វាមីមិនឱ្យមានមោះ ។

(១) ចៀមតួ = ប្រុងខ្លួន (ពាក្យថៃ) ។ (២) រាគី = គ្រឿងមន្ទិល ។

មែនប្ដីភ្លើងឯងទឹកលត់ឱ្យភ្លែត　　កុំកហេតុឱ្យកើតជាជំលោះ
ទោះប្ដីខឹងនាងប្រឹងអត់ឱនចុះ　　យកពិរោះតតបឱ្យគាប់កល ។
(២០០) នឹងនិយាយចាយចាត់ប្រយ័ត្នមាត់　　កុំនិយាយច្រើនបទនាំរវល់
ភ្លើងខាងក្រៅកុំការចូលមណ្ឌល　　ភ្លើងខាងក្នុងប្រុងដឹកល់កុំនាំចេញ ។
ការឯណាអប្រិយដែលប្ដីហាម　　ប្រព្រឹត្តតាមបែបផែនឱ្យមែនមិញ
កុំកេងកាងអាងជ្បិតប្ដីស្រឡាញ់　　គិតកកាញ់ការមិនគាប់នឹងធ្លាប់ទៅ ។
ទោះពិរោធក្រោធខឹងនឹងភស្ដា　　កុំនិន្ទាស្ដីដើមយល់មិនត្រូវ
ប្រឹងលេបទុកកត់ទុកក្នុងកាយចៅ　　ឧស្សាហ៍បិទបាំងទៅកុំប្រែះប្រាយ ។
មែនបើទាស់កើតមោះឈ្លោះប្រកែក　　កុំភូកស្រែកចេញស័ព្ទឱ្យឮឆ្ងាយ
មើលបើប្ដីមាត់ខ្លាំងជាងសូរសាយ　　ចូរចៀសចេញឱ្យឆ្ងាយពីនោះទៅ ។
ទំរាំក្សាន្តចិត្តប្ដីស្ងួមឡើងមក　　មើលលែលកយកចិត្តភស្ដាចៅ
ឃើញស្ងប់ស្ងាត់បាត់បានស្ងួមឆោមឆៅ　　និយាយទៅឱ្យឃើញហេតុនោះហោង ។
(២០៤) ភ្លើងកំពុងឆេះខ្លាំងកុំតាំងដុត　　យកឆ្នួនចេញឱ្យផុតកុំគរកង
គង់រលត់ផុតឆ្នួនទេនួនល្អង　　បើប្ដីឆ្លងនាងកុំឆ្កឹះកឹះផ្ដេញផ្ដាល់ ។
ឈ្លោះប្រកែកបែកចិត្តឥតប្រយោជន៍　　កើ្តអសោចិ៍កើតអសារការគ្មានផល
ហេតុនោះនួនចូរស្ងួនកុំខ្វាយខ្វល់　　រក្សាកេរ្តិ៍តាមកលឱ្យកើតស័ក្តិ ។
ថ្នមចិត្តចៅកុំចេកពីចិត្តប្ដី　　ចូរភក្ដីសុចរិតស្វាមីភ័ក្តិ
ដូចយ៉ាងនាងសិតាប្រកបល័ក្ខណ៍　　ទសភ័ក្ត្រមិនអាចនឹងជិតបាន ។
សុចរិតចិត្តល្អនឹងកើតផល　　ជាកុសលចំរើនសុខក្សេមក្សាន្ត
ទេពនិករឱ្យពរបរិបូណ៌បាន　　ភ្លឺក្នុងស្ថានមនុស្សលោកយោគសួគ៌នាយ ។
កិត្តិគុណកិត្តិយសស័ព្ទសុសសព្វ　　ក្លិនត្រឡប់សព្វទិសពិដោរសាយ
ឥតពូជពង្សវង្សវែងអង្វែងឆ្ងាយ　　ជនទាំងឡាយសឹងសរសើរនួនអនង្គ ។

(២១០) ការប្រព្រឹត្តិស្លូតត្រង់ត្រូវចិត្តប្តី ប្តីក៏រីតបេតិ្តភួចភិសះវង់
ទោះរូបនាងអាក្រក់ពិការអង្គ តែចិត្តត្រង់ប្តីក៏ត្រេកដេកមិនឆ្ងាយ ។
មែនរូបល្អតែចិត្តចោរអប្រិយ ដូចកាកីកែវកបរូបឆើតឆាយ
ចោរចើកចោលព្រហ្មទត្តក្សត្រពណ្ណរាយ ទៅសហាយនឹងគ្រូឱរត់ចោលប្តី ។
បានសុបណ្ណមិនឆ្អន់មិនឆ្អែតឈប់ ទៅសម្ភពគន្ធីន [(១)] ទៀតជាបី
ត្រូវបណ្តែតពោងពាយក្នុងជលធី ស្ងួនជីវីក្នុងទឹកនឹកអនិច្ចា ។
នេះព្រោះចិត្តរាយមាយមិនសន្តោស បានទុក្ខទោសចុះត្រូវព្រះអាជ្ញា
រឿងនិទានក៏មានក្នុងសាស្ត្រា នាងឧស្សាហ៍មើលទុកជាច្បាប់ស្រី ។
ច្បាប់ស្រីហ្លួងអង្គដួងទ្រង់តែងទុក មានទំនុកពិស្តារតាមបាលី
ចូររកយកមកមើលណ៎ានាងស្រី ជាគ្រឿងតឿនស្មារតីបានក្តីគាប់ ។
(២១៩) សុភាសិតយើងនេះតែងសង្ខេប ព្រោះមានបែបបុរាណក៏ច្រើនច្បាប់
នឹងតែងសាំក៏សាំកីនតម្រាប់ អញ្ជើញស្តាប់តែសង្ខេបជាបែបថ្មី ។
ខ្ញុំសូមទោសអ្នកស្រីដែលប្តីលែង នឹងស្រីល្បែងប្រព្រឹត្តក្បត់ចិត្តប្តី
បើបានឮចូរអំណត់កាន់ខន្តី កុំស្រដីនិន្ទាខ្ញុំអ្នកតែង ។
បន្តិចថាអាចារ្យអាងប្រាជ្ញព្រោក លើកប្រយោគថាទៅតែឯងៗ
បានតម្រាពីណាមកសំដែង តែងឡើងតែងឱ្យយើងនេះខ្លាចប្តី ។
ខាងប្រុសតើម្តេចមិនតែងមិនចែងចាត់ ឱ្យប្រតិបត្តិប្រពន្ធខ្លះកើតឬអី
នេះអាងគាត់ៗ ប្រុសចេះស្រដី បង្គាប់ស្រីឱ្យតែស្រីទាបជាងប្រុស ។
ខាងប្រុសគេមានស្រីពីរបីបាន ច្បាប់គ្មានហាមប្រាមថាមានទោស
ត្រង់យើងស្រីលេងខ្លះផ្តាសថាខុស អាងតែប្រុសចេះតែងមកក្លែងថា ។
(២២០) លេងបៀប៉ោរអស់ប្រាក់ៗ យើងមាន ទៅសូមទានពីគាត់មកកាលណា

(១) គន្ធីន : «អ្នករបាំ» សៀមអានថា ចន្ទីន ។

រវល់អ្វីមកបាមយើងគ្រប់គ្នា    បើគាត់ជាក៏ជាតែគាត់ទៅ ។
បើស្រីណាដៀលច្នេះឱ្យស្រីនោះ    ធ្លាក់ទៅចុះក្នុងស្ថាននរកជ្រៅ
យមបាលអុជអាលដោយដែកក្ដៅ    មានដង្កូវចុះមាត់ព័ទ្ធពេញប្រាណ ។
ក្លិនក៏ស្អុយឆ្អាបឆ្អេះអសោចិ៍ឆ្ងាយ    ពិការកាយកើតស្លាប់រាប់ពុំបាន
អស់កំណាត់មកកើតជាប្រេតប្រាណ    ជាតិរច្ឆានរងទុក្ខឥតសុខា ។
កើតជាមនុស្សមាត់ស្អុយអ្នកផងស្អប់    គ្មានគេគប់ចង់យកជាភរិយា
កើតវិបត្តិខ្ចាត់ខ្ចាយព្រាត់ប្រាស់គ្នា    ហ្វូងទេវាផ្ដាសាឱ្យវិបរិត ។
បើស្រីណាកបកេរ្តិ៍ឥរិយាគាប់    បានត្រងត្រាប់ស្ដាប់យកទុកក្នុងចិត្ត
ប្រតិបត្តិធ្វើតាមសុភាសិត    ទេពមានឫទ្ធិចូលជួយចំរើនជ័យ ។
(២២៩) ឱ្យស្រីនោះបរិបូណ៌សុខក្សេមក្សាន្ត    ស្លាប់ទៅបានកើតក្នុងសួគ៌ាល័យ
សោយសម្បត្តិឥតទុក្ខឥតការភ័យ    សម្រាន្តពិមានជាឧឡារ ។
ទេពអប្សរអរឱនមកស្នងស្នើ    ចោមជុំស្នើបំរើជាបរិវារ
ស្ងូត្រថ្វាយជ័យឱ្យស័ព្ទសាធុការ    ជាអស្ចារ្យឮសព្ទទាំងរាត្រី ។
សោយសុខសួគ៌អស់ផលចុះមកកើត    យកកំណើតជាមនុស្សក្នុងលោកិយ៍
កើតក្នុងវង្សព្រះបរមចក្រី    កបរាសីល្បីកេរ្តិ៍សព្វទិសា ។
ទ្រង់ព្រះរូបឆើតឆោមជាចមស្រី    លើសនារីក្នុងស្ថានយើងនេះណា
ជាឯកអគ្គមហេសីនៃចក្រា    សែនសុខាព្រាដល់និព្វាននាយ ។
នៃអនង្គនារីនាងចូរស្ដាប់    ប្រុងត្រងត្រាប់យកទុកក្នុងអង្គកាយ
ប្រតិបត្តិឱ្យត្រូវដូចបរិយាយ    នឹងសំរេចដូចហ្មាយនេះជៀងជាក់ ។
(២៣០) មួយសូមទោសពួកប្រុសកំឡោះក្មេង    បណ្ដាលេងចង់ស្រីតាមក្តីស្ម័គ្រ
ក្រែងស្រីណាចង់តឹងមិនបានអ្នក    អ្នកកុំអាក់អន់ចិត្តដល់ខ្ញុំឯង ។
ថាពីដើមចង់ងាយសប្បាយចិត្ត    ដល់មានសុភាសិតអាចារ្យចែង

ពួកស្រី១ វាចេះមិនលុះល្បែង ព្រោះអាចារ្យឥន្ទតែងបានជាតឹង ។
កុំគិតក្រែងថាខ្ញុំឈ្មានីសអ្នក មិនឱ្យបានរួមរ័កនឹងស្រីហ្នឹង
តែគឺមោះស្រីនោះគេល្អដឹង បានជារឹងគេមិនតាមចិត្តអ្នក ។
វិស័យស្រីល្អកបរិយា ចាំមាតាបិតាគេទុកដាក់
រូបអ្នកឯងប្រាថ្នាលេងលួចលាក់ តែបានស្ម័គ្រផ្តេតហើយក្រែងឆ្អើមវិញ ។
ហេតុនោះបានជាមិនចង់គប់ ប្រែត្រឡប់ជាស្អប់មិនស្រឡាញ់ [(១)]
ចាំម៉ែឪគេដាក់គេដាវិញ មោះនឹងចេញមោះនឹងចោលបង្គោលមាន ។
(២៣៩) ដូចអ្នកឯងស្វែងរកប្រពន្ធល្អ ប្រាថ្នាតពូជពង្សវង្សសន្តាន
បើស្រីនោះរូបល្អម្ចូបគ្មាន អ្នកមិនហ៊ាននឹងចូលទៅសម័ន្ធ ។
ការលេងស្រីនេះមិនងាយទេណាំអ្នក ស្រីអប្បល័ក្ខណ៍នោះមានគ្រប់ដឹបន់
លេងឯណោះលេងឯណេះមិនចេះស្រន់ អ្នកឯងមុនគេក្រោយដោយពេញស្រុក ។
ស្រីចង់ងាយបានងាយលែងក៏ងាយ អ្នកកុំហ្មាយថាបានសេចក្តីសុខ
ស្រីសាមាន្យយើងបានសំដែងទុក មានខាងមុខមកហើយចូរមើចុះ ។
មួយទាសីខ្ញុំគេអ្នកទៅតាមស្ម័គ្រ វាពោងអ្នក១ ឯងក៏តេះតុះ
ត្រូវគេចាប់សែនខ្មោចក៏ខូចឈ្មោះ កេរ្តិ៍ឮសុសខ្មាសគេសព្វទិសា ។
ជូនប្រទះស្រីឈ្លួលបបួលលេង បានមួយភ្លេងពីរភ្លេងក៏ភ្ជាត់ថា
ដេកសន្លឹងតមថ្នាំត្រាំសុរា ចុះអនិច្ចាបង់ប្រាក់ទិញថ្នាំធៀប ។
(២៤០) ស្រីក៏ខូចប្រុសក៏ខិលមានច្រើនយ៉ាង នឹងអែបអាងទាញយកមកតែងប្រៀប
លើសកម្លាំងនឹងលើកសរសេរធៀប យើងរាយរៀបតែល្មមចូលចិត្តបាន ។
លោកណាបានអានមើលសុភាសិត មិនគាប់ចិត្តក៏ចៀសចេញកុំអាន

(១) ត្រង់ចុងឃ្លានេះ កប់ជួន, បើថា «ប្រែត្រឡប់ជាស្អប់កើតទុក្ខម្នេញ»ទើបជាប់ជួនតាមច្បាប់កាព្យ ។

បើលោកណាគាប់ចិត្តតាមសណ្ឋាន អញ្ជើញអានប្រយ័ត្នបក្រាំង ខ្ញុំ ។[១]
កុំឱ្យខ្ចាយទឹកមាត់ជិតប្រឡាក់ កុំឱ្យធ្លាក់ពីដៃក្រាំងទក់គ្រាំ
ក្រដាសដាចដាច់ផ្ទត់ចេញពីពុម្ព អាណិតខ្ញុំបំណាច់ខ្ញុំតែងតាំង ។
បរិយាយច្រើន១ គេនឹកំណត់ ខ្ជិលរោយមាត់កាយហត់អស់កំឡាំង
ពេលក៏ជួនបញ្ចប់ចុះឯវិ និដ្ឋិតំចប់ស្ទេះប៉ុណ្ណេះហោង ។

---

(១) កាលដែលឧកញ៉ាសុត្តន្តប្រីជា ឥន្ទ តែងសុភាសិតនេះ បានសរសេរចុះក្នុងក្រាំងជាដំបូង ។

# ស្ថាននាមវិទ្យា
## ( TOPONYMIE )

នៅតាមសិលាចារឹកកម្ពុជា ពីសតវត្សទី VI - XIV គេអាចស្រង់បាន នាមឈ្មោះទីកន្លែង ដែលយើងនឹងហៅថា « ស្ថាននាម » ចំនួនជាង ១.៥០០ ។ ស្ថាននាមកម្ពុជទេស ត្រូវបានគេបង្កបង្កើតឡើង ដោយការប្រើពាក្យខ្មែរសុទ្ធ ពាក្យខ្មែរលាយសំស្ក្រឹត និងពាក្យសំស្ក្រឹតសុទ្ធ ។ ស្ថាននាមទាំងនេះ ទាក់ទងទៅនឹងភូមិឋានដ៏ធំៗ ដែលជាកម្មសិទ្ធិរបស់វត្តអារាម ឬអាស្រម ឬជាកម្មសិទ្ធិរបស់មហា-គ្រួសារនៃពួកសេដ្ឋី ដែលទ្រទ្រង់ព្រាហ្មណ៍សាសនា ។

ជាស្ថាននាមសំគាល់នូវការបែងចែកដែនដីនៃកម្ពុជាបុរាណ ជាភូមិ ជាស្រុក ជាវិស័យ Visaya ( ខេត្ត ) ជាប្រមាណ នៃកម្ពុជទេស ។

ពាក្យថា កម្ពុជទេស កម្វុជទេឝ Kamvujadeça ជាពាក្យសំស្ក្រឹតដែលមានន័យថា ប្រទេស « ជាកូនចៅនៃមហាឥសីកម្ពុ » ហើយពាក្យនេះត្រូវបានចារនៅក្នុងសិលាចារឹកជាភាសាខ្មែរ នៅវត្តសំរោង ស្រុកបាភ្នំ ( K 956 សតវត្សទី IX ) និងនៅក្នុងសិលាចារឹកស្តុកកក់ធំ ខេត្តប្រាជីនបុរី ( K 235, ឆ្នាំ ១០៥២ គ.ស. ) គឺជាឈ្មោះនៃប្រទេសខ្មែរ ដែលយើងនឹងប្រើតទៅមុខទៀត នៅក្នុងការសិក្សាអំពីស្ថាននាមសម័យអង្គរ ។

គឺដោយសារស្ថាននាម តាមសិលាចារឹកសម័យអង្គរនេះហើយ ដែលអ្នកស្រាវជ្រាវបារាំងឈ្មោះ Georges Maspéro បានធ្វើផែនទីភូមិសាស្ត្រនៃកម្ពុជ-ទេស នៅសតវត្សទី X គឺជាផែនទីនយោបាយនៃប្រទេសកម្ពុជា នៅសម័យអង្គរ ។

នៅពេលក្រោយមកទៀត ដោយយោងទៅតាមន័យនាមឋានខ្មែរផង នាមឋានសំស្ក្រឹតផង ដែលគេបានស្រង់នៅក្នុងសិលាចារឹកជាភាសាខ្មែរ និងភាសា

សំស្ក្រឹត ។ លោក L. Sédov បានរៀបចំផែនទីនៃចក្រភពកម្ពុជទេសពីសតវត្ស ទី IX - XIV ដោយបានបញ្ជាក់ទាំងបំណែងចែកទឹកដី ជាភូមិភាគធំៗ នៃប្រទេស នាសម័យអង្គរ ។

រហូតមកដល់សម័យបច្ចុប្បន្ន ការស្រាវជ្រាវខាងវិស័យស្ថាននាមកម្ពុជា មានចំនួនតិចស្តួចស្តើង ។

មានស្នាដៃស្តីអំពីស្ថាននាមវិទ្យា នៃប្រទេសកម្ពុជាបច្ចុប្បន្នមួយ សរសេរដោយអ្នកស្រី សាវរស់ ពៅ ក្នុងក្របខណ្ឌនិក្ខេបបទថ្នាក់បណ្ឌិត ហើយបោះពុម្ពផ្សាយជាភាសាបារាំង ។ នៅក្នុងស្នាដៃរបស់ខ្លួន សាវរស់ ពៅ បានប្រើប្រាស់ឯកសារសិលាចារឹកកម្ពុជា ជាញឹកញាប់ក្នុងការពន្យល់នាមឈ្មោះទីកន្លែងខ្មែរ ក្នុងសម័យបច្ចុប្បន្ន ។

វិធីស្រាវជ្រាវតាមបែបប្រវត្តិសាស្ត្រ និងបែបប្រៀបធៀប បានអនុញ្ញាតឱ្យអ្នកនិពន្ធបានតាមដានការវិវត្តន៍នៃសូរស័ព្ទ និងសេម៉ង់ទិក (Sémantiques) របស់ស្ថាននាមមួយចំនួននៅប្រទេសកម្ពុជា ។ និក្ខេបបទនេះ មិនបានអធិប្បាយដ៏ល្អិតល្អន់អំពីស្ថាននាមដទៃទៀតដ៏តូចតាច ហើយមិនតែប៉ុណ្ណោះ ស្ថាននាមខ្មែរមានច្រើនឥតឧបមា ដែលរក្សាទុកនៅក្នុងការហៅរបស់សហគមន៍ខ្មែរនៅប្រទេសថៃឡង់ដ៍ (ខ្មែរសុរិន្ទ) និងនៅប្រទេសវៀតណាមខាងត្បូង (ខ្មែរកម្ពុជាក្រោម) ។

ការសិក្សាស្ថាននាមតាមសិលាចារឹក អាចឱ្យគេធ្វើការសន្និដ្ឋានបានថា ស្ថាននាមមួយចំនួនធំដែលកើតឡើងពីពាក្យខ្មែរបុរាណ ឬសំស្ក្រឹត ដែលបានរក្សាទុកនៅក្នុងភាសាខ្មែរបច្ចុប្បន្ន ។

រចនាសម្ព័ន្ធស្ថាននាមខ្មែរបុរាណ ដែលជាទន្លេ ស្ទឹង បឹងបួរ ត្រពាំង និងបច្ចេកពាក្យផ្នែករុក្ខវិទ្យា ឬមួយសត្វវិទ្យា ពុំសូវមានការប្រែប្រួលខ្លាំងគួរឱ្យចាប់អារម្មណ៍នោះទេ គឺថា ពាក្យទាំងនេះអាចត្រូវគេយល់បានសំរាប់អ្នកដែលនិយាយ

ភាសាខ្មែរ ក្នុងសម័យបច្ចុប្បន្ន ម្យ៉ាងទៀត តាមការសិក្សាស្ថាននាម គេអាចនិយាយបានថា ៖ ទស្សនៈ និងផ្នត់គំនិតប្រជារាស្ត្រកម្ពុជា មានការប្រែប្រួលបន្តិចបន្តួច នៅក្នុងបញ្ញត្តិ ដែលទាក់ទងទៅនឹងការបង្កើតស្ថាននាម ។

កត្តាមួយដ៏សំខាន់នៅក្នុងការសិក្សាស្រាវជ្រាវកំណាកំណើតស្ថាននាម គឺស្ថិតនៅលើកត្តាដែលបញ្ជាក់ថា ស្ថាននាមទាំងអស់នៅក្នុងភាសាខ្មែរ គឺជាឯកតាទាំងឡាយ ដែលកកើតឡើងចេញពីវចនស័ព្ទនៃភាសាខ្មែរបុរាណ ឬមួយនៃភាសាខ្មែរពីបរមបុរាណ មានពីភាសាមន - ខ្មែរ ជាដើម ។ ដោយហេតុថា ស្ថាននាម ក៏ជាឯកតា (Unité) វចនស័ព្ទដែលបានកកើតឡើង ដោយការប្រើពាក្យធម្មតា នៅក្នុងភាសានិមួយៗ គេអាចប្រើប្រាស់ស្ថាននាម ដើម្បីស្រាវជ្រាវរកវចនស័ព្ទនៃភាសា ហើយតាមការសិក្សាបបនេះ គេក៏អាចដឹងអំពីប្រវត្តិនៃពាក្យ និងប្រវត្តិនៃស្ថាននាមនិមួយៗ ។

ស្ថាននាមបុរាណនៃប្រទេសកម្ពុជា មួយចំនួនធំ មានប្រភពចេញមកពីភាសាសំស្ក្រឹត ហើយស្ថាននាមទាំងនេះ មានរចនាសម្ព័ន្ធខុសគ្នាពីស្ថាននាមដែលមានប្រភពពីភាសាខ្មែរសុទ្ធសាធ ។ ស្ថាននាមជាភាសាសំស្ក្រឹត ត្រូវបានបង្កបង្កើតឡើងដោយមន្ត្រីជាន់ខ្ពស់ ដោយព្រាហ្មណ៍បុរោហិត ដែលបំរើការនៅព្រះរាជវាំង ។

ប្រសិនបើសម័យអង្គរ គេបានប្រទះឃើញនូវស្ថាននាមជាភាសាសំស្ក្រឹត ដែលមានចំនួនច្រើនជាអតិបរមានោះ បានសេចក្តីថា ព្រាហ្មណ៍បុរោហិតមន្ត្រីរាជការ មួយចំនួនធំ បានចេះយ៉ាងស្ទាត់ជំនាញនូវភាសាសំស្ក្រឹត ។ ហើយដែលគេទុកដូចជាភាសាសាសនាផង ភាសានៃកិត្យានុភាពផង និងភាសារាជខុទ្ទកាល័យផង ។ តាមការសិក្សាស្ថាននាម និងសិលាចារឹកនានាជាភាសាសំស្ក្រឹត ដែលគេរកឃើញនៅស្រុកចុងកាត់មាត់ញក គេអាចសន្និដ្ឋានបានថា អ្នកស្រុក និងប្រជាជនសាមញ្ញ ក្រៅពីអ្នកក្រុង ក៏ចេះភាសាសំស្ក្រឹត ព្រោះនៅសម័យនោះ ភាសា

សំស្ក្រឹត បានត្រូវគេប្រើប្រាស់ជាទូទៅនៅអាស៊ីអាគ្នេយ៍ ( ប្រទេសចាម្ប៉ា ថៃ មន ឥណ្ឌា ឥណ្ឌូនេស៊ី ) ។

ស្ថាននាមសំស្ក្រឹត បានត្រូវគេប្រើប្រាស់ជាផ្លូវការសំរាប់ដាក់ឈ្មោះ ប្រាសាទ ព្រះវិហារ រដ្ឋធានី ទីក្រុង ភូមិភាគ ដែនដី និងចំណុចភូមិសាស្ត្រ ដទៃទៀត នៃកម្ពុជទេស ។

ការសិក្សាស្ថាននាមជាភាសាសំស្ក្រឹត មិនគ្រាន់តែផ្តល់សារសំខាន់ ក្នុងការស្វែងយល់អំពីឥទ្ធិពលភាសាសំស្ក្រឹត មកក្នុងភាសាខ្មែរប៉ុណ្ណោះទេ ប៉ុន្តែ នៅលើមូលដ្ឋាននៃការស្រាវជ្រាវប្រវត្តិសាស្ត្រ ស្ថាននាមទាំងនេះមានសារសំខាន់ ព្រោះអាចបំភ្លឺបាននូវកំរិតឥទ្ធិពលសាសនា ( ព្រាហ្មណ៍សាសនា - ពុទ្ធសាសនា ) និងជំនឿដទៃទៀត នៅក្នុងសម័យកាលមហានគរ និងមុនមហានគរ ។

ព្រមជាមួយគ្នានេះ ការសិក្សាអំពីស្ថាននាមខ្មែរ ដែលភាគច្រើនជាស្ថាន-នាមដែលមានដើមកំណើតពីបរមបុរាណ ។ ពីដើម គ.ស ឬ ពីមុន គ.ស តំរូវឱ្យមានការឧបត្ថម្ភ ឬមួយមានការស្វែងយល់អំពីវិទ្យាសាស្ត្រ មនុស្សសាស្ត្រដទៃទៀត ជាពិសេស ការស្វែងយល់អំពីចំណេះដឹងប្រវត្តិសាស្ត្រ និងភូមិសាស្ត្រ ។ ជួលកាលតំរូវឱ្យមានការយល់ដឹងអំពីបសុវិទ្យា និងរុក្ខវិទ្យា ដោយហេតុថា ស្ថាននាមនៃប្រទេសកម្ពុជា ជាច្រើន បានត្រូវបង្កបង្កើតនៅលើការរួមផ្សំ នៃពាក្យដែលសំគាល់នូវរុក្ខ-ជាតិ សត្វចតុប្បាទ ឬមួយបក្សាបក្សីទាំងឡាយ ។ បានសេចក្តីថា ជាស្ថាននាមដែលបង្កបង្កើតឡើងនៅលើមូលដ្ឋាននៃភាពរស់រវើកនៃបរិដ្ឋាន គឺនៅលើមូលដ្ឋានធម្ម-ជាតិជុំវិញខ្លួននៃទិដ្ឋភាព នៃទេសភាព ។

ព្រាហ្មណ៍សាសនា ក៏បានផ្តល់ឥទ្ធិពលដ៏សំបើមនៅក្នុងការបង្កបង្កើតស្ថាននាមសម័យបុរាណ មានជាពិសេស គឺឈ្មោះអាស្រម ឈ្មោះទីក្រុង និងឈ្មោះទន្លេ ( មានទន្លេសិប្បនិម្មិតជាដើម ) ។ ទឹកដីនៃប្រទេសកម្ពុជា ដែលប្រកបដោយ

លក្ខណៈខុសគ្នា រវាងដីទាប ( ដីក្រោម ) ដីទំនាប ដីលិចទឹក ត្រពាំង បឹងបួរ ទាំងអស់នេះ បានបង្កបង្កើតជាមូលដ្ឋានដ៏ល្អសំរាប់ការហៅឈ្មោះទីកន្លែង គឺការបង្កបង្កើតស្ថាននាមទៅតាមលក្ខណៈនៃទិដ្ឋភាពទីតាំងទីកដី ។

នៅក្នុងការសិក្សាដែលនឹងមានតទៅ យើងបានកំរិតនៅក្នុងដំណាក់កាលទី ១ ការសិក្សាត្រឹមតែការស្វែងរកនូវនិយមន័យរបស់ស្ថាននាម នៅក្នុងភាសាខ្មែរបុរាណប៉ុណ្ណោះ ។

ការស្រាវជ្រាវ និងស្វែងរកទីតាំងនៃស្ថាននាមបុរាណ ទាក់ទងទៅនឹងដំណាក់កាលទី ២ ដែលទាមទារឱ្យមានការសិក្សាប្រៀបធៀបរវាងស្ថាននាមបុរាណ និងស្ថាននាមបច្ចុប្បន្ន ។

កិច្ចការនេះ ជាកិច្ចការអនាគត ប៉ុន្តែមានសារសំខាន់ ព្រោះតាមការសិក្សាបែបនេះ យើងនឹងអាចធ្វើផែនទីភូមិសាស្ត្រ ប្រវត្តិសាស្ត្រនៃប្រទេសយើង នាសម័យមហានគរ ។

## I . បច្ចេកពាក្យ នៃស្ថាននាមវិទ្យា
## ( Termes Toponymiques)

នៅក្នុងភាសាខ្មែរបុរាណ ជាពិសេសភាសាខ្មែរបុរាណនាសម័យអង្គរ បច្ចេកពាក្យនៃស្ថាននាមវិទ្យា បានត្រូវបង្កើតឡើង ហើយបានត្រូវគេយល់នូវអត្ថន័យ ដោយការសិក្សាអំពីអត្ថបទដែលទាក់ទងទៅនឹងស្ថាននាមវិទ្យា ឬទាក់ទងទៅនឹងភូមិវិទ្យា ។

បច្ចេកពាក្យទាំងនេះ បានត្រូវប្រើប្រាស់ ដូចជាពាក្យ វេយ្យាករណ៍ morphèmes បញ្ជាក់ការកំណត់ព្រំដែនរវាងពាក្យសមាស និងឈ្មោះទីកន្លែង ( ស្ថាន-

នាម ) ហើយម្យ៉ាងវិញទៀត បច្ចេកពាក្យទាំងនេះ ក៏ជាពាក្យដែលអាចផ្តល់ពត៌មានដល់លក្ខណៈពិសេសនៃទីកន្លែងដែលគេឱ្យឈ្មោះ ។ នៅក្នុងភាសាខ្មែរគឺ បច្ចេក-ពាក្យទាំងនេះហើយ ដែលបានត្រូវប្រើដើម្បីបង្កើតឈ្មោះទីកន្លែង ដែលជាការបែងចែកទឹកដីតាមរបៀបរដ្ឋបាល ។

ឧទាហរណ៍ : ដូចជា ភូមិភាគ ខេត្ត ស្រុក ភូមិ ទីក្រុង បុរី ព្រៃ វត្តអារាម ភូមិស្ថាន ផ្លូវគមនាគមន៍ ច្បារដំណាំ ភ្នំ ដីទំនាប ដីទួល ទីវាល ស្រែ និងចំការ (ក្សេត្រ) កំពង់ បឹង ទន្លេ ស្ទឹង ត្រពាំង ទំនប់ ។ ល ។

បច្ចេកពាក្យទាំងនេះ គេអាចសន្មតបានថាជាបច្ចេកពាក្យខាងភូមិវិទ្យាផងដែរ ( Termes Géographiques ) គឺជាបច្ចេកពាក្យ ដែលត្រូវបង្កបង្កើតឡើងដោយរដ្ឋបាលរាជការ ដើម្បីដាក់ឈ្មោះដោយបំណែងចែកទឹកដី តាំងពីទឹកដីដ៏ធំៗ រហូតដល់ដីស្រែ ចំការ សំរាប់ធ្វើដំណាំស្រូវ ។

### I. ១. Pramana, Praman

បច្ចេកពាក្យ « ប្រមាន - ប្រមាណ » បានត្រូវប្រើប្រាស់នៅសម័យអង្គរ ដើម្បីឱ្យឈ្មោះដល់បំណែងចែកទឹកដីដ៏ធំៗ ឬមួយភូមិភាគ នៃកម្ពុជទេស ។

តាមសិលាចារឹក យើងបានឃើញដែនដីប្រមាណ pramāna ប្រហែលជា ២០ គឺជាផែនដីដ៏ធំៗ នៃប្រទេស :

| | |
|---|---|
| ប្រមាន ជ្រៃនន្ត | Pramān Jrainan K 393 |
| | < jrai + nanta « ល្អ, ប្រសើរ » |
| ប្រមាន វ្រៃស្វាយ | Pramān Vrai Svay K 989 |
| | =ព្រៃស្វាយ (ប្រហែលនៅសុខោទ័យ) |
| ប្រមាន វ្រៃវ្យេក | Pramān Vrai Vyek K 105 |

| | |
|---|---|
| | អ្នកស្រី. សាវរស់ ពៅ ថា « ព្រៃពើក » hyp. (?) |
| ប្រមាន វ្រៃរម្យត | Pramãn Vrai Rmyat K 380 |
| | = ព្រៃរមៀត |
| ប្រមាន តេំខ្យល | Pramãn Teṃ Khyal K 944 |
| | = ដើមខ្យល់, ទិសខាងត្បូង |
| ប្រមាណ ជេង្វ្នំ | Pramāṇa Jeṅ Vnaṃ K 876 |
| | = ជើងភ្នំ ( ប្រហែលជើងភ្នំដងរែក ) |
| ប្រមាន អមោឃបុរ | Pramãn Amoghapura K 211 |
| | = អមោឃៈ ជាឈ្មោះរបស់ព្រះសិវ |
| ប្រមាណ ល្ទៅ | Pramāṇa Ldau K 569 ( បន្ទាយស្រី ១២២៦ ស.ក ) = រណ្ដៅ |
| ប្រមាណ មល្យង | Pramāṇa Malyaṅ K 713 |
| | ជាពាក្យមលេ ៖ មល្យង ជាឈ្មោះទីកន្លែង លោក G.Cœdès ថាប្រហែលជានៅតំបន់ពោធិសាត់ |
| ប្រមាណ សន្ទុក | Pramāṇa Sanduk K 756 |
| | = សន្ទុក ៖ ជាឈ្មោះរុក្ខជាតិ |
| ប្រមាន ល្វោ | Pramãn Lvo K 292 |
| | < Lopvapura = ល្វោ ៖ ( លពបុរី បច្ចុប្បន្ននៅប្រទេសថៃ ) ជាទីក្រុង |
| ប្រមាន អនិន | Pramãn Anin K 989 |
| | < Aninditapura skt ទីក្រុងដ៏ប្រសើរ, ដ៏បរិសុទ្ធ... |
| ប្រមាន ភីមបុរ | Pramãn Bhimapura K 292 |

= ភិម : អស្ចារ្យ

ប្រមាន៑ ស្រេឞ្ឋបុរ Pramãn Śreṣṭhapura K 944

= ស្រេស្ឋ : ឈ្មោះព្រះសិវៈ , ល្អប្រសើរ ( វត្តភូ )

ប្រមាណ ឧក្របុរ Pramãṇa Ukrapura K 183

= ឧក្រ ( សំ . ) ខ្លាំងពូកែ

ប្រមាន៑ ប្រឝន្តគ្រាម Pramãn Praśantagrãma K 187

សំ. = ប្រសន្ត : សុខសាន្ត, គ្រាម ភូមិ (ភូមិសុខសាន្ត)

ប្រមាន៑ បុរន្ទរបុរ pramãn Purandarapura K 989

សំ. = បុរន្ធរ : ឈ្មោះព្រះឥន្ទ្រ

ប្រមាន៑ ឝម្ភុបុរ Pramãn Śambhupura K 125

សំ. = សម្ភុ : ឈ្មោះព្រះព្រហ្ម

ប្រមាន៑ ឥន្ទ្របុរ Pramãn Indrapura

សំ. = ឥន្ទ្រ : ព្រះឥន្ទ្រ

ប្រមាន៑ ឝតគ្រាម Pramãn Śatagrãma K 989

សំ. = សតគ្រាម : ភូមិ ឬជនបទមួយរយ

នៅក្នុងសិលាចារឹកវត្តព្រៃវែង សម័យសតវត្សទី ៧ (សិលាចារឹកអ្នកតា) មានឈ្មោះ Pramãna Mahãtmal មានសរសេរពាក្យថា

តើភូមិភាគនេះនៅឯណា ? ឬមួយក៏មានទីតាំងនៅកន្លែងវត្តព្រៃវែង សព្វថ្ងៃ ។ នៅក្នុងសិលាចារឹកនេះទៀត ក៏មានសរសេរឈ្មោះ ព្រះបាទឥសានវរ្ម័ន ជាព្រះមហាក្សត្រ លើមហាក្សត្រសមន្តរាជ នៃភូមិភាគទាំងបី ។

តើប្រមាណមហាត្មល ជាភូមិភាគមួយក្នុងបណ្តាភូមិភាគ ( ឬទីក្រុង ) ទាំងបី កន្លែងដែលមានចារនៅក្នុងសិលាចារឹកវត្តព្រៃវែង ឬទេ ?

ក្នុងបណ្ដាភូមិភាគប្រមាណ Pramãn ដែលត្រូវបានពណ៌នាតាមឧទាហរណ៍ខាងលើនេះ យើងអាចសង្កេតឃើញថា ភូមិភាគ « ប្រមាណ »

Pramãn : ពាក្យនេះមានន័យពីរ មានន័យថា : រង្វាស់, ការប៉ាន់ស្មាន

Pramãn មួយចំនួនមានដើមកំណើតពីពាក្យខ្មែរ ហើយឈ្មោះភូមិភាគចំនួន ១១ មានដើមកំណើតពីសំស្ក្រឹត ។

ម្យ៉ាងវិញទៀត តាមសិលាចារឹក K 989 ភូមិភាគប្រមាណមួយ មានឈ្មោះថា Śatagrãma ដែលមានន័យថា « ភូមិចំនួនមួយរយ » បានសេចក្ដីថាតាមរយៈអត្ថន័យរបស់ភូមិភាគនេះ យើងអាចទាញមតិដែលបញ្ជាក់ពីទំហំដីធំធេងនៃស្ថាននាម ដែលបានប្រើប្រាស់ពាក្យ « Pramãṇa » នៅខាងដើម ។

នៅក្នុងសិលាចារឹកនៃប្រទេសចាម្ប៉ា នាសម័យអង្គរ ក៏មានការប្រើប្រាស់ « Pramãn » សំរាប់សំគាល់នូវភូមិភាគផ្សេងៗ នៃប្រទេសចាម្ប៉ា ផងដែរ ។

## I. ២. Viṣaya 𑀯𑀺𑀱𑀬

ពាក្យសំស្ក្រឹត មានន័យថា តំបន់, ខេត្ត

ពាក្យ « វិសយ » សំរាប់សំគាល់នូវបំណែងចែកទឹកដីរដ្ឋការ ឬក៏បំណែងចែករាជការមួយៗ ដ៏ច្បាស់លាស់នៅក្នុងសម័យអង្គរ ។ តាមសិលាចារឹកនានា ពាក្យវិសយ Viṣaya សំគាល់នូវទីរួមខេត្ត ដែលនៅក្នុងនោះ មានស្ថាប័នរាជការផ្សេងៗ ខាងគ្រហស្ថ និងសាសនា ។

Viṣaya និមួយៗ ស្ថិតនៅក្រោមការត្រួតត្រារបស់ Khloñ Viṣaya ( ស្ដេចត្រាញ់ ឬចៅហ្វាយខេត្ត ) ។

រាជការដែលធ្វើការអម «ខ្លោញវិសយ» គឺមានខ្លោញវលវិសយ Khloñ

Vala Viṣaya K 221 ។ ខ្លោញទទួលបន្ទុកខាងកិច្ចការធញ្ញជាតិ គឺមានស្រូវ អង្ករ ជាអាទិ ។ ខ្លោញទទួលបន្ទុកខាងកិច្ចការទារប្រេង មានប្រេងធ្វើអំពីរុក្ខជាតិ និងប្រេងធ្វើអំពីខ្លាញ់គោ។ វ្រីហិ បយ៉ាំ វិសយ Vrihi Paryyāṅ Viṣaya K 444 ព្រុងទាំងមានខ្លោញ ឬមួយក៏អធិបតី ទទួលបន្ទុកតុលាការ ដែលនៅតាមសិលាចារឹកថា សភាវិសយ Sabhā Vis

បើប្រៀបធៀបទៅនឹងសម័យបច្ចុប្បន្ន ពាក្យ Viṣaya មានន័យថា ជាបំណែងចែកទឹកដីរដ្ឋបាល ដូចជាខេត្តដែរ ។

វិសយ ករោំ Viṣaya Karoṃ K 235

វិសយ ជេង តរាញ Viṣaya Jeṅ tarāñ K 238

វិសយ វ្យាធបុរ Viṣaya Vyādhapura K 211

វិសយ កន្សិន Viṣaya Kansin K 105

គួរកត់សំគាល់ថា មានឈ្មោះស្ថាននាមខ្លះ ដែលត្រូវបានបង្កបង្កើតឡើង ដោយការប្រើពាក្យ ភូមិសាស្ត្រ ប្រមាណ ផង និងពាក្យ វិសយ ផង ។

ឧទាហរណ៍ ៖ ប្រមាន ស្រេស្ឋបុរ វិសយ ស្រេស្ឋបុរ

ប្រមាណ សន្ទុក វិសយ សន្ទុក

- Çreṣṭhapura = បុរីដ៏ល្អ, ដ៏ប្រសើរ, គឺជាភូមិភាគនៅខាងទិសឧត្តរនៃកម្ពុជទេស គឺនៅតំបន់វត្តភូ ឬហៅថាតំបន់ចំប៉ាសាក់ នៅខាងភូមិភាគឧត្តរ ។

តាមមតិអ្នកស្រាវជ្រាវខ្លះ « Çreṣṭhapura » គឺជារាជធានីចាស់នៃប្រទេសចេនឡា ហើយព្រះមហាក្សត្រដែលសោយរាជ្យមុនគេនៅទីនោះ ព្រះនាមថា « ស្រេស្ឋវរ្ម័ន Çreṣṭhavarman » ។

- Sanduk = ប្រហែលជាចេញមកពីពាក្យ * Stuk, sdok

មានន័យថា ធំ មាំមួន ប៉ុន្តែ ន័យរបស់ពាក្យនេះម្យ៉ាងទៀត គឺ «បឹង» ។

សព្វថ្ងៃ មានពាក្យ « ភ្នំសន្ទុក » ដែលនៅលើនោះមានប្រាសាទបុរាណ តាមសិលាចារឹក ក៏មានសរសេរអំពី « mahãnasa » = អ្នកធ្វើម្ហូបអាហារនៅ វិសយសន្ទុក « Viṣaya Sanduk » ។

ប្រសិនបើពាក្យ « Çresṭhapura & Sanduk » បានត្រូវប្រើប្រាស់ សំរាប់សំគាល់ភូមិភាគផង ខេត្តផង គេអាចសន្និដ្ឋានថា នៅតាមសិលាចារឹកមាន ពាក្យសំគាល់ភូមិភាគដទៃទៀត ដែលត្រូវគេប្រើសំរាប់សំគាល់ខេត្ត ។ យើងបានរក ឃើញប្រមាណ ប្រហែលចំនួន ២០ ហើយក្នុង Pramān និមួយៗ មាន « Viṣaya » គឺខេត្តច្រើន ។ ដូច្នេះ Viṣaya នៅសម័យបុរាណ ជាពិសេសនៅសម័យ អង្គរ មានមិនតិចជាងពាក្យរបស់ « ជីវតាក្វាន់ » ដែលបានសរសេរថា នៅកម្ពុជា មានខេត្តច្រើនជាង ៩០ ។

### I. ៣. Sruk

តាមនិរុត្តិវិទ្យា ពាក្យ « Sruk » ដែលគេបានប្រទះឃើញតាមសិលា ចារឹកតាំងពីសតវត្សទី ៧ (  ) រួមជាមួយប្រភពដើមនៃពាក្យមនបុរាណ Scruk, Sruk មានន័យថា : ជ្រក, ជំរក réfuge, se réfugier ។ ពាក្យ « Scruk » នៅក្នុងភាសាមន ប្រហែលជាមានកំណើត និងមានន័យដើមដូចគ្នា ហើយដែលប្រែមកថា « ជំរក » បានសេចក្តីថា ដើមឡើយ ពាក្យស្រុកក្នុងភាសា ខ្មែរ មានន័យថា « ជំរក » ហើយពាក្យ « ជ្រក » ក៏មានដើមកំណើតមានទំរង់ ទៅតាមពាក្យ « Cruk ច្រុក » ។

នៅក្នុងភាសាខ្មែរ និងខ្មែរដទៃ ខ្យល់ព្យញ្ជនៈ Ca និង Sa មានទំនាក់ ទំនងគ្នាខាងសំនួរ ដូចពាក្យ « ឆី » និងពាក្យ « ស៊ី » ។

នៅសម័យមុនអង្គរ ពាក្យ « Sruk » សំគាល់តែភូមិដ៏តូចតាចទេ ហើយ

ស្រុកថ្មី « ស្រុក៑ ថ្មិ Sruk Tmi̋ » ស្រុកដែលទើបនឹងបង្កើតថ្មី ហើយប្រហែលជានៅមុនដំបូង មានផ្ទះតែពីរ-បី ប៉ុណ្ណោះ ។

នៅសម័យអង្គរ ពាក្យ « ស្រុក » បានពង្រីកនូវនិយមន័យរបស់ខ្លួនដោយសារការអនុវត្តន៍នយោបាយពង្រីកទឹកដី នៃព្រះមហាក្សត្រអង្គរ ព្រះមហាក្សត្រដែលជាតំណាងព្រះឥស្វរ ឬព្រះវិស្ណុលើផែនដី នាសម័យមុនអង្គរ និងអង្គរ មានភារៈគ្រាន់តែរក្សាផៃផ្ទែករោម ( ដែនដី ) របស់ព្រះអង្គប៉ុណ្ណោះទេ ប៉ុន្តែ ព្រះអង្គមានភារៈពង្រីកទឹកដីរបស់ព្រះអង្គ ។ នេះគឺជាទស្សនៈរបស់ព្រាហ្មណ៍និយម ។

មកដល់សម័យអង្គរ ពាក្យ ស្រុក ត្រូវបានគេប្រើជាពាក្យសំរាប់សំគាល់បំណែងចែកទឹកដីខាងរដ្ឋការ ហើយជាបច្ចេកពាក្យខាងភូមិសាស្ត្រដែលបញ្ជាក់នូវឯកតាខាងរដ្ឋបាលតូចៗ ដែលមានអភិបាលរបស់ខ្លួន គឺមានប្រធានស្រុក ប្រធានស្រុក៑ K 153 ឬមានខ្លោញស្រុកខ្លោញ៑ស្រុក៑ K 99 មានអធិការត្រួតគុណសម្បត្តិ និងបទឧក្រិដ្ឋ ឬក៏អាចហៅម្យ៉ាងទៀតថា « អធិការផ្នែកសន្តិសុខ គុណទោសឧក្កស្រុក៑ » មានតុលាការស្រុកសភាស្រុក៑ K 208 ។

នៅក្នុងអត្ថបទនៃសិលាចារឹក K 258 ដែលមានកាលបរិច្ឆេទនៅសតវត្សទី១១ គេអាចអានកន្សោមពាក្យដូចតទៅខ្លោញ៑ស្រុក៑ទសគ្រាម Khloñ Sruk Daçagrãma ( គឺអាចបកប្រែតាមភាសាសម័យថា « អភិបាលស្រុកដែលមានភូមិ ១០ ) ។ ហេតុដូចនេះ ពាក្យថា Sruk គឺសំដៅលើទីប្រជុំភូមិតិច ឬច្រើន គឺជាពាក្យដែលមានន័យប្រហាក់ប្រហែលគ្នា នៅក្នុងភាសាសម័យ ។ ក៏ប៉ុន្តែ នៅសម័យអង្គរ « ស្រុក » បានមានន័យថា « Sruk » ផង ឬក៏ជា « ស្រុកទេស » ផង ស្រុក៑ទេស Srukdeça គឺសំគាល់នូវនគរ ។

ក្នុងអត្ថបទសិលាចារឹក ស្តីអំពីសម្បថ តម្រួតពលរបស់ព្រះបាទសូរ្យវរ្ម័នទី ១ មាននិយាយថា « តំរួតពលនិមួយៗ តំណាងឱ្យស្រុកនិមួយៗ នៅមហាសករាជ

៩៣៣ ។

លោកអែមូនីញេ (Aimonier) ជាអ្នកស្រាវជ្រាវសិលាចារឹកជាតិបារាំង នៅចុងសតវត្សទី ១៩ ដើមទី ២០ បានអានសិលាចារឹកនេះ ហើយបានសរសេរនៅក្នុងសៀវភៅរបស់គាត់ (Le Cambodge 1904) ។ លោកបានអានសិលាចារឹក និងរាប់ក្នុងនេះ ឃើញមានស្រុកចំនួន ៤០០ ។ ក្រោយមកជាង ៥០ ឆ្នាំ លោក Georges Cœdès បានអានសិលាចារឹកភិមានាកាសសាជាថ្មី ហើយស្រង់បានឈ្មោះស្រុកតែ ២០០ ប៉ុណ្ណោះ ។ បញ្ហាចោទថា តើនៅក្នុងសម័យអង្គរ នៅក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១ នាដើមសតវត្សទី ១១ កម្ពុជទេស មានស្រុកចំនួនប៉ុន្មាន ? ហើយបើរាជទូតចិនឈ្មោះ ជូតាក្វាន់ ដែលបានមកដល់ទីក្រុងអង្គរ ឆ្នាំ ១២៩៦ គាត់បានសរសេរថា ចក្រភពអង្គរ មានខេត្តរហូតជាង ៩០ ។ បញ្ហានេះ តំរូវឱ្យមានការស្រាវជ្រាវ និងមានការសិក្សាអំពីស្ថាននាមសម័យអង្គរ ដោយប្រៀបធៀបនឹងស្ថាននាមសម័យបច្ចុប្បន្ន ដែលស្ថិតនៅក្នុង និងក្រៅប្រទេស ជាពិសេស នៅក្នុងប្រទេសសៀម និងវៀតណាម ។

ឧទាហរណ៍ ខ្លះៗ អំពីស្រុក :



Sruk Daṃnap pāk K 467 ស្រុកទំនប់ប៉ាក់
Sruk Stuk Rmmāṅ K 817 ស្រុកស្តុករមាំង
Sruk Saṃroṅ K 713 ស្រុកសំរោង
Sruk Kaṃveṅ K 292 ស្រុកកំពែង
Sruk Vnur Vinau K 467 ស្រុកផ្នូរព្នៅ
Sruk Travāṅ Vo K 393 ស្រុកត្រពាំងពោធិ៍
Sruk Vrai Trapek K 720 ស្រុកព្រៃត្របែក

ស្រុក សុខគ្រាម Sruk Sukha Grãma K 105 ( ភូមិដ៏សុខសាន្ត )
ស្រុក មធុរបុរ Sruk Madhurapura K 292 ( ស្រុកទឹកឃ្មុំ )
ស្រុក ភទ្រសិង្ហ Sruk Bhadra Siṅha K 292 ( តោដ៏ប្រសើរ )
ស្រុក រាជកុល Sruk Rãjakula K 380 ( រាជវង្ស )

### I. ៤. Camṇat ចំនត់

នៅសម័យអង្គរ ពាក្យ ចំនត Camṇat ឬ ចំនាត Camṇãt មានន័យថា « ភូមិ ភូមិទើបបង្កើតថ្មី » ។ ពាក្យនេះជានាមស័ព្ទ កើតចេញមកពីកិរិយាស័ព្ទ ចត Cat ឬ ចាត Cãt ដោយការប្រើផ្នត់ « - amṇ n- » គួរកត់សំគាល់ផងដែរថា នៅក្នុងភាសាខ្មែរបុរាណ ឋានន្តរនាមក្តី នរនាមក្តី ស្ថាននាមក្តី ច្រើនត្រូវបានបង្កបង្កើតដោយផ្នត់ « amṇ, amṇ n- » ខុសប្លែកពីភូមិធម្មតា ដែលមានអ្នករស់នៅច្រើនប្រភេទ តាមសិលាចារឹក ពាក្យ « ចំនាត់ Camṇãt ចំនាត់ » ត្រូវបានគេប្រើសំគាល់ភូមិថ្មី ហើយតូច មិនតែប៉ុណ្ណោះ ជាភូមិដែលជាកម្មសិទ្ធិរបស់អភិជនណាមួយ ។ « Camṇat » ជាពាក្យបញ្ជាក់នូវបំណែងចែកទឹកដីដ៏តូច ប្រហាក់ប្រហែលនឹងភូមិដែលទើបនឹងបង្កើតថ្មី ដោយអភិជនក្តី ដោយក្រុមអ្នកប្រកបការងារក្តី ។

ឧទាហរណ៍ ៖ ក្រុមអ្នកចំរៀង ដូច្នេះ គេមិនអាចច្រឡំ ចំនត និងស្រុកបានឡើយ ។ ប៉ុន្តែ នៅក្នុងចំនត ជួនកាលក៏អាចមានព្រះវិហារផងដែរ ។

ឧទាហរណ៍ ៖

ចំនត់ ទន្លេ Camṇat Danle K 420 « ស្រុកទន្លេ »
ចំនត់ ស្វាយ Camṇat Svãy K 249 « ភូមិស្វាយ »
ចំនត់ ចំរ្យាង Camṇat Camṛyyãṅ « ភូមិអ្នកចំរៀង »

ក្នុងពាក្យ Camṇat Camṛyyāṅ ឬចំនត អ្នកចំរៀង គេអាចយល់នូវតួនាទីដ៏សំខាន់របស់អ្នកចំរៀងនៅបុរាណកាល ។

បើសិនតាមសិលាចារឹកនិមួយៗ មានចុះឈ្មោះអ្នកចំរៀង និងអ្នកភ្លេង ព្រមទាំងអ្នករបាំ និងសិល្បករចម្លាក់ទៀតផង ទាំងអស់នេះបញ្ជាក់ឱ្យឃើញថា វត្តអារាមខាងព្រហ្មញ្ញសាសនា មានតំរូវការជាចាំបាច់នូវសិល្បៈចំរៀង តូរ្យតន្ត្រី និងនាដ្យកម្ម ដើម្បីបង្កើតទំនាក់ទំនង ឬដើម្បីបំរើទេវតា និងអាទិទេព ។

« Cat caṃnat çrī kamvuja kṣetra sthāpanā linga »

K 910 ចត់ ចំនត់ ស្រី កម្វុជ ក្សេត្រ ស្ថាបនាលិង្គ

តាមសិលាចារឹកសម័យអង្គរ ដែលគេបានរកឃើញ គេអាចប្រទះឃើញឈ្មោះភូមិ សំគាល់ដោយពាក្យ « ចំនត់ » ចំនួនប្រហែល ៦០ ។

## I. ៥. Anrāy អន្រាយ

តាមសិលាចារឹកសតវត្សទី ១០ ពាក្យ « anrāy » មានន័យថាជា « ភូមិ » របស់វត្តអារាម បានសេចក្ដីថា ជាភូមិដែលមានភារៈនឹងបំពេញការងារសំរាប់ប្រយោជន៍នៃវត្តអារាម ( Village prestataire ) ។

ជួនកាលមុខពាក្យ « អន្រាយ » គេប្រើពាក្យ « វ្រះ » គឺ Vraḥ Anrāy គឺជាភូមិរបស់ព្រះវិហាររបស់វត្តអារាម ( K 570 ) ។

ភូមិបែបនេះ រមែងមានពួកកសិករដែលធ្វើការសំរាប់វត្តអារាមណាមួយ កសិករបែបនេះ មិនមែនជាកសិករប្រកបដោយស្វយ័តភាពទេ គេអាចប្រើពាក្យម្យ៉ាងទៀតបានថា ជាកសិករដែលបំពេញងារ ឬជាកសិករអ្នកងារ ។

« ងារ : besogne » អ្នកធ្វើការដោយប្រើកំលាំង le corvéable

អាន្រាយ លិង្គបុរ Anrãy Lingapura K 257

ភូមិលិង្គ

អាន្រាយ កញ្ញ្យង Anrãy Kanhyań K 571

« ភូមិកន្ទៀង = ក្សត្រី »

អាន្រាយ ពិងថ្មោ Anrãy Piṅ thmo K 700

« ភូមិបឹងថ្ម »

អាន្រាយ ថ្មោវ្វក Anrãy Thmo Vvak K 570

« ភូមិថ្មពួក ឬថ្មពួក »

អាន្រាយ វ្នំ ព្រាហ្មណ Anrãy Vnaṃ Vrãhmṇa K 571

« ភូមិភ្នំព្រាហ្មណ៍ »

## I. ៦. Bhūmi ភូមិ

ពាក្យថា « ភូមិ » ជាពាក្យសំស្រ្កឹត ដែលនៅក្នុងភាសាខ្មែរបានខ្ចីមកប្រើ ហើយមានន័យថា ដី ដែនដី ដីធ្លី ដីមានម្ចាស់ ។ យើងអាចថា ដីហ៊ុំព័ទ្ធដោយរបង ឬដោយព្រំប្រទល់ ។

នៅតាមសិលាចារឹកនានា ដីភូមិ គឺអាចទិញ ឬលក់បាន ក៏ប៉ុន្តែ មនុស្ស ដែលមានសិទ្ធិទិញ ឬលក់ដីភូមិ មិនមែនបណ្តាអ្នកបំរើទេ គឺសុទ្ធតែពួកអភិជន មានតាំងពីពួក Vãp ឬពួក loṅ ជាដើម ។

គេអាចទិញ ឬលក់ដី ដោយប្រើមាសប្រាក់ ផលដំណាំ សត្វពាហនៈ ឬក៏ ធនធានមនុស្ស ឬជារូបិយប័ណ្ណ ។

ឧទាហរណ៍ ៖ សម័យសូរ្យវរ្ម័នទី ២ ស្តេចត្រូវទិញដី ( ឬថ្មដី ) ជាមួយ អភិជនដែលជាម្ចាស់កម្មសិទ្ធិផ្ទាល់ ដើម្បីសាងសង់ប្រាសាទ ។

ម្យ៉ាងទៀត នៅតាមសិលាចារឹកផ្សេងៗ គេឃើញមានពាក្យ

- duñ bhūmi K 258 « ទុញ ភូមិ »

ទុញ ភូមិ = ទិញភូមិ ឬទិញដី

- cãt bhūmi K 258 « ចាតិភូមិ »

ចាត ភូមិ = រៀបចំដីធ្វើផ្ទះសំបែង

- bhūmi rãjya prasãda K 342 « ភូមិរាជប្រសាទ »

ភូមិ រាជ្យប្រសាទ = ភូមិអំណោយដោយព្រះមហាក្សត្រ ។

ក្នុងក្របខណ្ឌជាពាក្យសំគាល់នូវស្ថាននាម : ភូមិ bhūmi គឺជាដីរុំព័ទ្ធដោយរបង ឬជាភូមិឋាន domaine របស់ឯកជន ឬរបស់វត្តអារាម ហើយទំរង់សមាសភាព នៃភូមិសម័យនោះ ពុំដូចជាសមាសភាពនៃភូមិសម័យបច្ចុប្បន្នទេ ។

ឧទាហរណ៍ :

bhūmi Svasti « ភូមិស្វស្តិ » K 158 ភូមិសួស្តី

bhūmi Teṃ Jrai « ភូមិតេំជ្រៃ » K 91 ភូមិដើមជ្រៃ

bhūmi Vraḥ Aṃvil « ភូមិវ្រះអំវិលិ » K 736 ភូមិព្រះអំពិល

bhūmi Thkal it « ភូមិថ្កលឥតិ » K 89 ភូមិថ្កល់ឥត

bhūmi Yogendrãlaya « ភូមិយោគេន្ទ្រាលយ » K 33

bhūmi Çivã « ភូមិសិវា » K 216

យោគេន្ទ្រាលយ = យោគ + ឥន្ទ្រ + អាលយ

នៅក្នុងសិលាចារឹក គេសង្កេតឃើញថា និយមន័យរបស់ពាក្យ « ភូមិ » បានរីកធំ ហើយភូមិបានទៅជាពាក្យសំគាល់ទីកន្លែងដែលមានគេរស់នៅ, ទីកន្លែងដែលមានបណ្ដាជនគ្រប់ស្រទាប់រស់នៅ ។

ឧទាហរណ៍ :

ភូមិ តូយ៌្យ bhūmi Turyya K 191 ( ភូមិអ្នកតូរ្យតន្ត្រី )

ភូមិ វគ៌្គខ្មាប bhūmi Vargga Khmāp K 265 ( ភូមិរបស់ពួកកាប់ ឬភូមិអ្នកកាប់ឈើ ? )

ភូមិ បក្សក្នេត bhūmi Paksa knet K 258 ( ភូមិរបស់អ្នកប្រកបការងារនៅថ្ងៃខ្នើត ពី ១ កើត ទៅ ១៥ កើត ជាអ្នកប្រកបការងារដើម្បីវត្តអារាម ) ។

* ពាក្យថា « បក្សក្នេត Pakṣa Knet បក្សក្នេត » ច្រើនមានប្រើតាមសិលាចារឹកតាំងពីសម័យមុនអង្គរ សំរាប់សំគាល់អ្នកធ្វើការខាងខ្នើត ជាពាក្យប្រើទូទៅ ជាមួយនឹងពាក្យមួយទៀតថា «បក្សរណ្ណោច Pakṣa Rṇṇoc បក្សរណ្ណោច» ដែលជាអ្នកប្រកបការងារ ចាប់ពីថ្ងៃ ១ រោច ដល់ថ្ងៃ ១៥ រោច ។

ពាក្យទាំង ២ នេះ ចង់បង្ហាញពីរបៀបរបបនៃការបំពេញការងាររបស់ប្រជាពលករ ដែលយើងអាចនិយាយថា ប្រជាពលករបំពេញងារសំរាប់រាជការ ( កិច្ចការសំរាប់បំរើរដ្ឋ ) ឬបំពេញងារសំរាប់វត្តអារាម ។ បានសេចក្ដីថា អ្នកទាំងនោះធ្វើការសំរាប់វត្តអារាម ឬរាជការចំនួន ១៥ ថ្ងៃ ហើយមកបំពេញការងារសំរាប់គ្រួសារខ្លួនចំនួន ១៥ ថ្ងៃ ។

អ្នកទាំងនោះ ប្រហែលជាបំពេញការងារដោយគ្មានប្រាក់ឈ្នួល ដូចជាបច្ចុប្បន្នសម័យទេ ។ ក៏ប៉ុន្តែ គេមិនអាចនិយាយថា អ្នកទាំងនោះគ្មានបានទទួលរង្វាន់អ្វីសោះឡើយ ដោយហេតុថា តាំងពីសម័យអង្គរ មានការប្រើពាក្យឈ្នួល « ជ្នួល » សំរាប់សំគាល់នូវមនុស្សដែលគេជួល ។

ចំពោះមន្ត្រីវិញ ឬក៏មន្ត្រីជាន់ខ្ពស់ របស់ដែលគេទទួលក្នុងការបំពេញងារ (ការងារ) គឺជាទ្រព្យសម្បត្តិ មានតាំងពីស្រូវ អង្ករ រហូតដល់សត្វពាហនៈ មាស ប្រាក់ ឬក៏ដីធ្លី ។

ចំពោះមន្ត្រីជាន់ខ្ពស់ ដូចមានសិលាចារឹកស្តុកកក់ធំជាសក្ខីភាព ត្រកូលអភិជន ច្រើនតែទទួលនូវ « ភូមិរាជ្យប្រសាទ » បានសេចក្តីថា ជាដីភូមិអំណោយដោយព្រះមហាក្សត្រ ។

នៅសម័យអង្គរ « ភូមិ, bhūmi » មានពាក្យសំគាល់ថា « ភូមិឋាន » ( domaine ) ដែលជាដីធ្លីហ៊ុំព័ទ្ធដោយរបងមានទំហំតូច ឬធំ គឺជាដីធ្លីឯកជន ជាកម្មសិទ្ធិរបស់កុដុម្ពិក៍ របស់វត្តអារាម របស់គ្រួសារសេដ្ឋី ឬក៏របស់មហាគ្រួសារអភិជនណាមួយ ( famille sacerdotale ) ។

ឧទាហរណ៍ : គ្រួសាររបស់ព្រាហ្មណ៍បុរោហិត សិវកៃវល្យ

គ្រួសារព្រាហ្មណ៍បុរោហិតសិវកៃវល្យនេះហើយ ដែលជាម្ចាស់ភូមិ ម្ចាស់ទឹកដីស្តុកកក់ធំ ហើយតាមពិតទៅ មិនគ្រាន់តែជាម្ចាស់ដីទេ ប៉ុន្តែជាម្ចាស់សំណង់ដែលមានព្រះវិហារ និងប្រាសាទនានា សំរាប់ធ្វើពិធីបូជាព្រាហ្មណ៍សាសនាទៀតផង ។

នៅសម័យក្រោយមកទៀត ភូមិបានក្លាយទៅជាទីប្រជុំជន ដែលមានបណ្តាជនរស់នៅទីនោះ ហើយមិនមែនស្ថិតនៅក្រោមការគ្រប់គ្រងរបស់វត្តអារាមទៀតឡើយ ។

ភូមិ បានប្រែក្លាយទៅជាបំណែងចែកទឹកដីរដ្ឋការ ដ៏តូចរបស់ប្រទេសកម្ពុជា ។

## II . បច្ចេកពាក្យនៃស្ថាននាម ប្រើប្រាស់សំរាប់សំគាល់ជលនាម Hidronumes

នៅទីនេះ នៅក្នុងការសិក្សានេះ យើងប្រើបច្ចេកពាក្យ « ជលនាម » Hydronymes ដើម្បីសំគាល់នាមឈ្មោះផ្លូវទឹកទាំងតូចទាំងធំ សំគាល់នូវទឹកន្លែង

ដែលមានទឹកជាធម្មជាតិ ឬជាសិប្បនិម្មិត គឺជាល្អាងទឹកជីកដោយអ្នកស្រុក ។

តាមសិលាចារឹកសម័យអង្គរ គេឃើញមាននាមឈ្មោះ ទន្លេ បឹងបួរ ជាច្រើន ដែលទាក់ទងទៅនឹងកំណកំណើតនៃស្ថាននាម សំគាល់នូវឈ្មោះ ភូមិ ស្រុក ខេត្ត និងភូមិភាគ ។ ព្រឹត្តិការណ៍ទាំងអស់នេះ បញ្ជាក់ឱ្យឃើញនូវព្រឹត្តិការណ៍ប្រវត្តិ-សាស្ត្រ ទាក់ទងទៅនឹងការអភិវឌ្ឍន៍ និងត្រួសត្រាយប្រទេស នៅសម័យមុនអង្គរ និងសម័យអង្គរ ។ ការអភិវឌ្ឍន៍ទាំងនេះ មានការត្រួសត្រាយកាប់ឆ្ការដីថ្មីៗ ការស្ថាបនាទីក្រុង និងវត្តអារាម ការកសាងប្រព័ន្ធបង្ហូរទឹក ដោយសំណង់ទំនប់តូច ឬធំ ព្រមទាំងការជីកប្រឡាយទឹក និងព្រែកជីក ព្រមទាំងល្អាងរក្សាទឹកដ៏ធំៗ ដែលសម័យនោះគេហៅថា « ទន្លេ » តដាក Taṭāka ( សំស្ក្រឹត ) ឬបារាយណ៍ ។

ក្នុងការស្រាវជ្រាវរបស់ខ្លួន អ្នកស្រាវជ្រាវរុស្ស៊ីម្នាក់ឈ្មោះ ប័យកូ (Boiko) បានសរសេរថា « ប្រទេសកម្ពុជាសម័យអង្គរ បានគ្របដណ្តប់ដោយប្រព័ន្ធធារាសាស្ត្រដ៏រីកចំរើនបំផុតនៅអាស៊ី ។

ដូចយើងបានជ្រាបរួចមកហើយថា តាំងពីសម័យបរមបុរាណមក ប្រទេសកម្ពុជា មានស្ថានភាពល្អខាងភូមិសាស្ត្រ ដោយហេតុថា នៅកណ្តាលប្រទេស មានទន្លេចតុមុខដែលជាផ្លូវទឹក ដែលជាទីជំនួបគ្នារវាងទន្លេមេគង្គ និងទន្លេសាប ហើយគឺទីជំនួបគ្នាពីទន្លេសាប ទន្លេមេគង្គនេះហើយដែលមានកំណកំណើតនៃស្ទឹង ព្រែក អូរ បឹងបួរ ត្រពាំង ប្រកបដោយចំនួនច្រើនមហិមា ។

## II. ១. Danle 

ពាក្យ « ទន្លេ, Danle » ជាជលនាម ដែលបញ្ជាក់នូវទន្លេផង និងល្អាងទឹកផង ។

ពាក្យនេះ អាចកើតចេញមកពីពាក្យ :

* ត្លេ tle = ទឹក : ជាពាក្យដែលគេរកឃើញនៅក្នុងភាសាហ្មង ( ភាសា តៃដោយវិធីប្រើផ្នត់ជ្រែក « -ន-/ -អន-; - n - / -an- » ( tle + -an- > Tanle )

មុនដំបូង ពាក្យ Danle ជាពាក្យសំគាល់ផ្លូវទឹកដ៏ធំ គឺសំគាល់ទន្លេ ឬ នទី ។ នៅក្នុងសិលាចារឹក K 22 សតវត្សទី VII ស្ថាននាម Danle Krau ទន្លេក្រៅ ( Fleuve extérieur ) គឺជាឈ្មោះដៃទន្លេមេគង្គ ដែលចេញពី ចតុមុខបែកទៅទិសខាងត្បូង ។

ពាក្យនេះបានប្រើជាសមាសធាតុនៃស្ថាននាម ១ ដែលគេប្រើហៅដៃ ទន្លេមេគង្គ ។ នៅក្នុងអត្ថបទសិលាចារឹក K 268 សតវត្សទី XI ពាក្យ Danle សំគាល់នូវអាងទឹកដ៏ធំ ឬសំគាល់នូវបារាយណ៍ ដែលគេបានជីក ។

ឧទាហរណ៍ : ចត៑ ស្រុក៑ ស្ថាបនា ជ្យក៑ ទន្លេ

Cat sruk sthāpanā jyak danle

កសាងស្រុក ស្ថាបនាព្រះវិហារ ជីក បារាយណ៍ ( អាងទឹក )

ឧទាហរណ៍ : ស្រុក៑ ទន្លេក្រៅ

តាមសិលាចារឹក គេពុំទាន់រកឃើញនូវជលនាមសំគាល់ទន្លេមេគង្គទេ ហើយឈ្មោះទន្លេមេគង្គនេះទៀត ក៏ត្រូវបានអ្នកប្រាជ្ញខាងភូមិសាស្ត្រ អក្សរសាស្ត្រ ជាច្រើន លើកយកមកជាកម្មវត្ថុនៃការសិក្សា ។ ប៉ុន្តែ ទោះបីអ្នកស្រាវជ្រាវនានា មានមតិខុសគ្នាខ្លះក្តី ក៏គេនៅតែយល់ថា ពាក្យ « មេកុង គឺជាពាក្យ មន-ខ្មែរ ដែល មានន័យថា « មេទឹក » ។ នៅក្នុងភាសាខ្មែរ ជួនកាលគេសរសេរថា « មេកុង » ជួនកាលថា « មេគង្គ » ( មេ + គង្គ ឬគង្គា ) ។

នៅក្នុងសិលាចារឹក មានពាក្យដែលជាស្ថាននាម គឺជានាមនៃទីក្រុងមួយ ដែលនៅជិតទន្លេ ហើយទីក្រុងនោះឈ្មោះថា « គង្គបុរ Gaṅgapur ប្រែថា « បុរី

ស្ថិតនៅជិតមាត់ទន្លេគង្គា » គេអាចចោទសួរថា « ទន្លេគង្គា » ជាឈ្មោះទន្លេមេគុង ពីបុរាណកាលមកឬ ?

បញ្ហានេះ នឹងមានអត្ថាធិប្បាយនៅក្នុងស្ថាននាមជាភាសាសំស្ក្រឹត ។ នៅក្នុងសិលាចារឹកបែកបាក់មួយ គឺសិលាចារឹក K 455 សតវត្សទី XI យើងអាចអានឃ្លាដូចតទៅ « Danle ta pvan » ទន្លេ ត ប្វន ។

នៅក្នុងសមាសពាក្យ នៃពាក្យនេះ គឺ ពាក្យ « ទន្លេ ត ប្វន » យើងមិនអាចបញ្ជាក់ឱ្យបានច្បាស់លាស់ថា ជាពាក្យសំរាប់ហៅឈ្មោះទន្លេចតុមុខ នាសម័យបច្ចុប្បន្ននេះ ឬយ៉ាងណា ?

## II. ២ Cdiṅ ច្ទិង , ច្ទិង Chdiṅ ឆ្ទិង

ពាក្យ Cdin ជាពាក្យដ៏បរមបុរាណបំផុតនៅក្នុងភាសាខ្មែរ ហើយនៅក្នុងសិលាចារឹក គេប្រទះឃើញនៅក្នុងអត្ថបទ នាសតវត្សទី VI - VII ។

រីឯពាក្យ Chdiṅ ជាពាក្យចេញមកពីពាក្យ Cdiṅ ហើយដែលត្រូវបានគេប្រើប្រាស់នៅសម័យអង្គរ ។

នៅសម័យអង្គរ រហូតដល់ចុងក្រោយ ភាសាខ្មែរនៅតែបានប្រើប្រាស់ពាក្យ Chdiṅ ដដែល ហើយពុំទាន់ឃើញមានប្រើពាក្យ « sdiṅ » ដែលជារូបស័ព្ទមានប្រើនៅសព្វថ្ងៃនេះទេ ។

ពាក្យនេះអាចចេញមកពីឫសគល់នៃពាក្យមួយ គឺពាក្យ « រុង៑ ruṅ » ruṅ រុង៑ = ប្រែថា ជ្រៅ ទូលាយ ធំ ។ ពាក្យរុង៑ ruṅ ជាពាក្យមន-ខ្មែរ ហើយមាននិយមន័យស្របគ្នានឹងពាក្យ « ក្រុង Kruṅ » = ទន្លេ ឬស្ទឹង ។

ជាធម្មតា នៅក្នុងភាសាខ្មែរ ក៏ដូចជាភាសាមនដទៃ នៅលើមូលដ្ឋាននៃសូរស័ព្ទវិទ្យា ទំនាក់ទំនង និងការផ្លាស់ប្តូរទៅវិញទៅមក រវាងសំឡេងព្យញ្ជនៈ

/ r / ~ / d / ~ / l /

/ c / ~ / s /

ព្រមទាំងស្រះ / i / ~ / u /

ឧទាហរណ៍ ៖ ទិញ < ទុញ

ទំនាក់ទំនងរវមែងមានវត្តមានជាប្រក្រតីរវាងភាសាមន - ខ្មែរ និមួយៗផង ។ បានសេចក្តីថា នៅក្នុងភាសាខ្មែរ នៅក្នុងសម័យកាលនិមួយៗ គេតែងសង្កេតឃើញភាពខុសគ្នាក្នុងការបំភ្លឺសូរស័ព្ទនៃពាក្យខ្លះៗ ដែលគេហៅថា ជាពាក្យនៃគ្រាម ភាសាឧទាហរណ៍ ៖ គ្រាមភាសារអង្គរបុរី ចូលចិត្តប្រើពាក្យ « ច » ជំនួស « ស » ។

ម្យ៉ាងវិញទៀត ប្រសិនបើពាក្យ « ឆ្ពិង » ជាពាក្យបានកកើតមកដោយមានលក្ខណៈប្លែកក្តី ក៏គេអាចពន្យល់បានតាមនិន្នាការរបស់ខ្លួន នៅក្នុងការបង្កើតពាក្យ ភាសាខ្មែរបានខិតខំរកមធ្យោបាយដើម្បីជៀសវាងនូវការប៉ះទង្គិចនៃពាក្យ « សទិសស័ព្ទ Homonymes » ។

នៅក្នុងភាសាខ្មែរបុរាណចេញពីពាក្យ « ruṅ » គឺមានការកកើតពាក្យ Kuruṅ មានន័យថា ៖ ស្តេច មហាក្សត្រ

siṅ > smiṅ ( ស្វត្រធមិ )

Smiṅ នៅក្នុងភាសាមន សំគាល់ ៖ ព្រះមហាក្សត្រ

នៅក្នុងព្រះអត្ថបទនានានៃសិលាចារឹក មានការរកឃើញចំនួន ស្ទឹងរហូតដល់ ៣៤ ប៉ុន្តែចំនួននេះ នៅពុំទាន់អស់នៅឡើយទេ ទោះបីពាក្យ Cdiṅ ជាពាក្យបរមបុរាណក្តី ប៉ុន្តែ គេប្រើប្រាស់ពាក្យនេះ សំគាល់នូវផ្លូវទឹកផង ជនបទភូមិស្រុកផង ។

ពាក្យ « Cdiṅ » ដែលជាជលនាម ហើយបានប្រែក្លាយជានាមនៃជនបទ

ដោយហេតុថា គេសំគាល់ឃើញនូវពាក្យស្រុកដែលស្ថិតនៅពីមុខពាក្យ Cdiṅ ឬ Chdiṅ

ឧទាហរណ៍ :

Cdiṅ Kryel K 134 ច្ទិង៑ក្រេ្យល៑ ( ក្រៀល )

Cdiṅ Ramāṅ K 139 ច្ទិង៑រមាង៑ ( រមាំង )

Chdiṅ Gmuṃ K 913 ឆ្ទិង៑ឃ្មុំ ( ឃ្មុំ )

Chdiṅ Jrvak K 31 ឆ្ទិង៑ជ្រ្វក៑ ( ជ្រក )

Chdiṅ Thlāṅ K 654 ឆ្ទិង៑ថ្លាន៑ ( ពស់ថ្លាន់ )

Chdiṅ Taṃriy Slāp K 654 ឆ្ទិង៑តំរិយ៑ស្លាប៑ ( ដំរីស្លាប់ )

Chdiṅ Ransi K 654 ឆ្ទិង៑រន្សិ ( ឫស្សី )

Chdiṅ Svāy K 31 ឆ្ទិង៑ស្វាយ៑ ( ស្វាយ )

Chdiṅ Gargyar K 235 ឆ្ទិងគរ៑គ្យរ៑ ( គគីរ )

Chdiṅ Kaṃvyiṅtvaṅ K 31 ឆ្ទិង៑កំវ្យិង៑ត្វង៑ ( កំពីងដួង )

Chdiṅ Prai K ឆ្ទិង៑ប្រៃ ( ប្រៃ )

Chdiṅ Vrāc K ឆ្ទិង៑វ្រាច៑ ( ដើមព្រិច )

បណ្តាឈ្មោះស្ទឹងដែលរកឃើញនៅក្នុងសិលាចារឹក គឺមានតែស្ទឹង ៣ ទេ ដែលមានឈ្មោះជាភាសាសំស្ក្រឹត គឺ :

ឆ្ទិង៑ វ្រិទន៑ Chdiṅ Vridan ឆ្ទិង៑ វ្រិទន៑

ឆ្ទិង៑ មេរេន Chdiṅ Merena ឆ្ទិង៑មេរេន

ឆ្ទិង៑ ជៃរាគ Chdiṅ Jairāga ឆ្ទិង៑ជៃរាគ

ឈ្មោះស្ទឹងដទៃទៀត គឺជាឈ្មោះដែលកកើតឡើងដោយពាក្យខ្មែរដើមសុទ្ធសាធ ។ បាតុភូតបែបនេះ បញ្ជាក់ឱ្យយើងយល់ថា ឈ្មោះស្ទឹង ឬទន្លេ គឺជា

ឈ្មោះដែលស្ថិតក្នុងស្រទាប់នៃវាក្យស័ព្ទ ដ៏បរមបុរាណបំផុត ។ គឺដោយសារការសិក្សាពាក្យទាំងនេះហើយដែលគេអាចស្គាល់ឈ្មោះទឹកន្លែង ឬផ្លូវទឹកដែលមាននៅក្នុងតំបន់ ឬប្រទេសណាមួយដ៏ជាក់លាក់ ។

ម្យ៉ាងវិញទៀត ពាក្យសំគាល់ភូមិភាគទឹកដី ឬដីធ្លីដែលជាកម្មសិទ្ធិរបស់ឯកជន អាចកកើតឡើងដោយសារពាក្យថ្មី ឬពាក្យដែលភាសាខ្មែរបានខ្ចីមកពីភាសាសំស្ក្រឹត ។

ហេតុការណ៍ទាំងអស់នេះ បញ្ជាក់ឱ្យយើងយល់ម្យ៉ាងទៀតថា ស្ថាននាមដែលមានចំណាស់ចាស់ជាងស្ថាននាមទាំងឡាយ ដែលបានកកើតឡើងដោយសារការប្រើពាក្យសំស្ក្រឹត ហើយជលនាមជាភាសាខ្មែរ គឺមានឈ្មោះ ទន្លេ ស្ទឹង បឹង គឺជាឈ្មោះដែលកើតចេញមកពីស្រទាប់នៃវចនស័ព្ទ ដ៏បុរាណបំផុត ។

**II. ៣ . Canhvar**  .  **Canhor** 

ពាក្យ « ចន្ហ្វរ » កើតចេញមកពីពាក្យ « ហ្វរ ឬហោរ hvar, hor » ដោយការប្រើបុព្វបទ «ចន- , Can-» ហើយបុព្វបទ ( préfixe ) ចន-, Can - នេះទៀត គ្រាន់តែជាវ៉ារីយ៉ង់ (Variante) នៃអន្តរបទ ឬបទជ្រែក -ន-, -ម- នៅក្នុងសិលាចារឹក K 341 សតវត្សទី ៧ ។

គេបានឃើញពាក្យនេះ បន្ទាប់ពីពាក្យ « ទ្វិង » ហើយតាមលំដាប់នៃការរៀបរាប់របស់អត្ថបទ គេអាចសន្និដ្ឋានបានថា ផ្លូវទឹក « ចន្ហ្វរ » ជាផ្លូវទឹកតូចជាងស្ទឹង ឬក៏គ្រាន់តែជាចំណែកដ៏តូច ឬមួយគ្រាន់តែជាព្រែកដែលចេញមកពីស្ទឹង ។

ម្យ៉ាងវិញទៀត គួរកត់សំគាល់ថា នៅក្នុងសម័យបុរាណ ពាក្យ « ទ្វិង » មានន័យថា ជាទន្លេផង ជាស្ទឹងផង គឺជាន័យតាមភាសាខ្មែរទំនើប ។

ឧទាហរណ៍ :

Canhvar Krvac K 353 ចន្ទ្វារ ក្រ្វច ( ក្រូច )

Canhvar Vracc K 192 ចន្ទ្វារ វ្រច្ច ( ព្រិច )

Canhvar Ransi K 257 ចន្ទ្វារ រន្សិ ( ឫស្សី )

Canhvar Aleṅ K 720 ចន្ទ្វារ អ្លេង ( ដីឥដ្ឋ ? )

Canhvar Ramcyak K 571 ចន្ទ្វារ រំច្យក ( រំចេក )

**II. ៤. Pralãy : ប្រលាយ៑**

ពាក្យនេះអាចមានទំនាក់ទំនងខាងនិយមន័យជាមួយនឹងពាក្យ «បន្លាយ» ( K ២៣៨ ) = ធ្វើឱ្យវែង និងពាក្យមួយចំនួនទៀត ដែលឃើញនៅក្នុងភាសាសម័យ ដូចជាពាក្យ « ប្លាយ, អន្លាយ, ទាំងឡាយ » ។ ល ។ ដែលមានដក់នូវនិយម-ន័យថា អ្វីដែលវែងឆ្ងាយ ។

ខាងក្រោមពាក្យ « Pralãy » កើតចេញមកដោយការប្រើបុព្វបទ «ប្រ Pra » ជាបុព្វបទដែលគេបានប្រើប្រាស់ ដើម្បីបង្កើតពាក្យជានាមស័ព្ទផងដែរ ( វែង > ប្រវែង ) ហើយកុំច្រឡំនឹងមុខងារមួយទៀតរបស់បុព្វបទ «ប្រ, Pra» នៅក្នុងការបង្កើតកិរិយាស័ព្ទ ( Pronominal à valeur réciproque ) ។ នៅក្នុងសិលាចារឹក K 221 ឆ្នាំ ១០០៧ មានការប្រើពាក្យនេះសំគាល់នូវទីកន្លែង ដែលអ្នកស្រុករស់នៅ គឺសំគាល់នូវស្រុក ។ នៅក្នុងសិលាចារឹក K 207 មានជនបទដែលគេហៅថា « ប្រលាយរុង Pralãy Run » គឺប្រលាយធំ ។ ប៉ុន្តែ ជាប្រលាយដឹកដោយអ្នកស្រុក ។

ឧទាហរណ៍ : Sruk Pralãy K 221 ស្រុក៑ ប្រលាយ៑

Sruk Pralãy Slã k 207 ស្រុក៑ ប្រលាយ៑ស្លា

II . ៥ . Piṅ បិង , ពិង

អក្ខរាវិរុទ្ធនៃពាក្យ Piṅ មានដូចគ្នានឹងសម័យមុនអង្គរ និងអង្គរ គឺជាពាក្យដែលមានន័យថា បឹងបួរ ទន្លេ ហើយប្រហែលជាពាក្យ Piṅ នេះ សំគាល់នូវបឹងបួរ ដែលមានផ្ទុះពើក ។ ( បឹង > ត្រពាំង )

ពាក្យ « Piṅ » អាចសន្និដ្ឋានបានថា ជាពាក្យមានដើមកំណើតមន - ខ្មែរ ហើយគួរកត់សំគាល់ផងដែរថា នៅក្នុងភាសាមន Piṅ មានន័យថា « ពេញ » ហើយពាក្យ « Piṅ » ដូចគ្នានៅក្នុងភាសាជនជាតិ « ស្រែ » ( នៅវៀតណាម ) មានន័យថា « បឹង, បឹងបួរ, ទន្លេ » ដូចជានៅក្នុងភាសាខ្មែរបុរាណ ។ តាមអត្ថបទផ្សេងៗ ដែលមាននៅក្នុងភាសា មន-ខ្មែរ ដទៃ ចំពោះពាក្យ Piṅ នេះ គេអាចទាញនិយមន័យថា « ពាក្យ Piṅ ក្នុងភាសាខ្មែរបុរាណ ជាពាក្យ ដែលបានកកើតឡើងដោយ រូបារម្មណ៍ ឬមួយដោយរូបារម្មណ៍នីយកម្ម នៃពាក្យដែលសំគាល់នូវអ្វីមានភាព « ពេញ » ដូចជាពាក្យ ទឹកពេញ ។ ដូច្នេះហើយបានជា Pin សំគាល់នូវជលនាម ដែលមានទឹកពេញទាំងរដូវប្រាំង និងវស្សា ។

នៅក្នុងសិលាចារឹក K221 ឆ្នាំ ១០០៩ ពាក្យ « បឹង » ត្រូវបានប្រើប្រាស់ដូចជានាមស័ព្ទទី ២ នៅក្នុងសមាសពាក្យសំរាប់សំគាល់ភូមិ

ឧទាហរណ៍ : តែំបិង៑ teṃ Piṅ ទើំពិង

វាប៑ ស្រី តែំបិង៑ Vāp Śrī Teṃ Piṅ ឃ្លានេះអាចបកប្រែបានថា « លោក វាបស្រ៊ី » ( មានលំនៅនៅភូមិ ) ដើមបឹង ។

តាមឃ្លាដ៏តូចនេះយើងអាចយល់ថា បឹងដែលមាននិយាយនៅក្នុងអត្ថបទគឺជាបឹងធំ ហើយដែលមានភូមិ ៣ នៅទីនោះ គឺភូមិតែំបិង Bhūmi Teṃ Piṅ ភូមិកន្តាលបិង Bhūmi Kantāl Piṅ និងភូមិចុងបិង Bhūmi Cuṅ Piṅ ។

ពាក្យ Piṅ បានទៅជាវាក្យស័ព្ទមួយដ៏សំខាន់ដែលមានគេប្រើប្រាស់ជា

ញឹកញាប់នៅក្នុងភាសាខ្មែរសម័យបុរាណ ក៏ដូចជាសម័យបច្ចុប្បន្ន ។ ក៏ប៉ុន្តែ ឫសគល់ និងនិយមន័យរបស់ពាក្យនេះស្ថិតនៅស្រពិចស្រពិល ។

តាមទំរង់ខាងសូរស័ព្ទ ពាក្យ « Piṅ » ក្នុងភាសាខ្មែរ អាចប្រៀបបាន ទៅនឹងពាក្យ Piṅ នៅក្នុងភាសាមនបុរាណ និងក្នុងភាសា « រំស្រ » ( នៅវៀតណាម ) ហើយដែលមានន័យថា « ពេញ Beñ » ។

យើងអាចសន្និដ្ឋានបានថា ពាក្យ « Piṅ ឬ Piṅ Pur បឹងបួរ » នៅក្នុងភាសាខ្មែរបុរាណ បានកកើតឡើងដោយវិធីរូបារម្មណ៍នីយកម្ម Métaphori-sation នៃពាក្យ Piṅ ដែលជាពាក្យមន-ខ្មែរ ហើយនិយមន័យនៃពាក្យ « បឹង » ធ្វើឱ្យយើងនឹកឃើញទៅដល់រអាងទឹក ដែលមានទឹកពោរពេញនៅក្នុង ខួបប្រាំង - វស្សា ៖ បឹងបួរ ។

**II. ៦. Travaṅ** [illegible] , [illegible] **Travāṅ** [illegible]

ត្រវង៑, ត្រវាង៑ < ត្រ + វង៑ ( វង់ ) , វាង៑

ពាក្យនេះ គឺជាពាក្យកម្លាយកកើតចេញមកពីពាក្យ « Vaṅ វង៑ » អ្វីដែលមានរាងមូល ហើយដែលមានទំនាក់ទំនងនឹងពាក្យសម័យ គឺពាក្យ « វង់ ឬ ពង់ » គឺជាពាក្យដែលកកើតឡើងដោយរូបារម្មណ៍នីយកម្ម នៃពាក្យ « វង៑ » ជាមួយនឹងបុព្វបទ « Tra ត្រ » ។ មិនតែប៉ុណ្ណោះ ប្រហែលជាពាក្យ « វង៑ » ក្នុងពាក្យ « វង៑ចក៑ [illegible] » K 9 សតវត្សទី ៦ មានន័យថា ត្រពាំង, ត្រពាំងចក ហើយគេអាចសន្និដ្ឋានបានថា « វង៑ចក៑ Vaṅcak = ត្រពាំងចក » នៅសម័យនោះ វាត្រូវបានគេប្រើប្រាស់ជាស្ថាននាម ដូចមានពាក្យនេះនៅក្នុងឃ្លាតទៅ .... āy vaṅ cak sre sanre ៨០ = អាយ៑ វង៑ ចក៑ ស្រេ សន្រេ ៨០ .... = [illegible] « នៅត្រពាំងចក មានស្រែចំនួន ៨០ » ។

ក្នុងសិលាចារឹកផ្សេងៗ គេអាចសង្កេតឃើញថា ពាក្យត្រពាំង សំគាល់នូវអាងទឹកធម្មជាតិផង ឬអាងទឹកជីកដោយបុគ្គលណាមួយ ឬដោយអ្នកស្រុកផង ។

ឧទាហរណ៍ : . Travaṅ Ci Dok ត្រវង៑ ចិ ទោក៑ K 30 (KPA)

« ត្រពាំងជីកដោយលោកតាដោក »

- Travāṅ Rāmapāla ត្រវាង រាមបាលៈ K 22 (KA)

« ត្រពាំងជីកដោយរាមបាល »

- Travāṅ Kaṃsteṅ ត្រវាង៑ កំស្តេង៑ K 262 (KA)

« ត្រពាំងជីកដោយមន្ត្រីកំស្តេង »

តាមឧទាហរណ៍ខាងលើនេះ យើងមិនអាចទាន់ដឹងច្បាស់ថា ពាក្យណាជាស្ថាននាម ពាក្យណា ជាពាក្យធម្មតានៅឡើយទេ ។ ក៏ប៉ុន្តែ បើកាលណាពាក្យ «ត្រវាង» បានត្រូវប្រើប្រាស់ដើម្បីបង្កើតជាស្ថាននាម ដោយមានការផ្សំនឹងពាក្យដែលសំគាល់នូវរុក្ខជាតិ ឬសំគាល់នូវសត្វ នោះគេអាចយល់បានថា គឺជាស្ថាននាមពិតប្រាកដ ហើយស្ថាននាមនោះទៀត បានសេចក្តីថា ត្រពាំងដែលគេនិយមនោះគឺជាត្រពាំងដែលបានកកើតឡើងដោយធម្មជាតិ ។

ឧទាហរណ៍ : Travāṅ Krave ត្រវាង៑ក្រវេ K 222 ត្រពាំងក្រពើ

Travāṅ Krapi ត្រវាង៑ក្របិ K 843 ត្រពាំងក្របី

Travāṅ Tannot ត្រវាង៑តន្នោត៑ K 991 ត្រពាំងត្នោត

នៅក្នុងសិលាចារឹកជាភាសាខ្មែរ មានស្ថាននាមដែលត្រូវបានបង្កើតឡើងដោយពាក្យត្រពាំង «ត្រវង៑, ត្រវាង៑» ចំនួនប្រហាក់ប្រហែល ១៥០ ។ របស់ដែលសំខាន់នៅក្នុងការសិក្សាស្ថាននាមវិទ្យា ជាពិសេស នៅក្នុងការសិក្សានាម Hydronymes ពាក្យ Travaṅ Travāṅ បានត្រូវអ្នកស្រុកប្រើប្រាស់ជាញឹកញាប់ដើម្បីបង្កើតស្ថាននាមដទៃទៀត ដែលមានទំហំធំសំរាប់សំគាល់ភូមិ ស្រុក

ខ័ណ្ឌ នៅក្នុងភាសាខ្មែរ បច្ចុប្បន្ននេះទៅជាពាក្យដែលត្រូវបានគេប្រើប្រាស់សំរាប់បង្កើតស្ថាននាម ដែលជាលំនៅស្ថាន គឺមានតាំងពីភូមិ ឃុំ ស្រុក ខេត្ត ។

## II. ៧ . Stuk ស្ទុក៑ , ស្តុក៑

ពាក្យ « Stuk » កាលពីដើមឡើយ អាចមានទំនាក់ទំនងខាងសេម៉ង់ទិក ( Sémantique ) ជាមួយនឹងពាក្យមនបុរាណ គឺពាក្យ « Sduk » និងពាក្យ Sduk Piṅ ដែលមានន័យថា « ពេញ » ។ នៅក្នុងភាសាខ្មែរទំនើប ពាក្យ Stuk មានន័យទី ១ គឺ រ៉ុងប៉ុង ធំ

ទី ២ គឺព្រៃ ៖ ជាពាក្យដែលអ្នកស្រុកប្រើប្រាស់សំគាល់ស្ថាននាមផ្សេងៗនៅប៉ែកភូមិភាគពាយព្យ នៃប្រទេសកម្ពុជា គឺប៉ែកខាងខេត្តបាត់ដំបង ។

ខុសពីពាក្យ « ត្រវង៑, ត្រវាង៑ » ដែលសំគាល់ល្អាងទឹក ដែលគេជីកក្តីដែលមានលក្ខណៈជាធម្មជាតិក្តី ពាក្យ « Stuk » នៅសម័យបុរាណ បានសំគាល់នូវអាងទឹកធម្មជាតិ ដែលនៅទីនោះ មានមច្ឆសត្វ និងធម្មជាតិដ៏ពិសេស ។

ឧទាហរណ៍ ៖ Stuk Khyoṅ K 207 ស្តុក៑ ខ្យោង៑ ( ខ្យង )

Stuk Kaṃvis K 292 ស្តុក៑កំវិស៑ ( កំពិស )

Stuk Jleṅ K 760 ស្តុក៑ ជ្លេង៑ ( ឈ្លើង )

Stuk Krañ K 206 ស្តុក៑ ក្រាញ៑ ( ត្រីក្រាញ់ )

Stuk Sno K 158 ស្តុក៑ស្នោ ( ស្នោ )

Stuk Kak K 275 ស្តុក៑ កក៑ ( កក់ )

Sruk Stuk Kok K 684 ស្រុក៑ស្តុក៑កោក៑ ( ស្តុកគោក )

Sruk Stuk Kandel K 713 ស្រុក៑ស្តុក៑កន្ទេល៑ ( ស្តុកកន្ទេល )

Sruk Stuk Aṃvil K 374 ស្រុក៑ស្តុក៑អំវិល៑ ( ស្តុកអំពិល )

Sruk Stuk Ransi K 219 ស្រុកស្តុករន្សិ ( ស្តុកឫស្សី )

តាមសិលាចារឹក K 44 និង 341 ដែលមានកាលបរិច្ឆេទ គ.ស. ៦៧៤ និង ៧០០ ពាក្យ Stuk ឬមួយក៏ Sduk ជាទីកន្លែងខាងសេដ្ឋកិច្ចដ៏សំខាន់មួយរបស់វត្តអារាម និងអ្នកស្រុក បានសេចក្តីថា Stuk ជាមូលដ្ឋានខាងសេដ្ឋកិច្ចដ៏សំខាន់នៅក្នុងជីវភាពរបស់អ្នកស្រុក នាសម័យនគរភ្នំ ហើយដើម្បីបញ្ជាក់នូវមតិនេះ យើងអាចឱ្យឧទាហរណ៍ដូចតទៅ ៖

ស្តុកប្លេ Stuk Ple 

ប្លេ > ផ្លែ < ផល Phala ( សំស្ក្រឹត )

« ផលិតផលបានមកពីស្តុក « បឹង » ហើយផលិតផលទាំងនោះ គឺមានច្រើនបែបច្រើនយ៉ាង តាំងពីមច្ឆជាតិ ធញ្ញជាតិ រុក្ខជាតិ ដែលជារបស់របរសំរាប់ទ្រទ្រង់ជីវភាព » ។

 K 341

Caṃnyar thmur Stuk Piṅ phoṅ

Caṃnyar < Cyar = Si = ស៊ី

« ចំណីគោ ស្តុកបឹងផង »

ទីវាលស្មៅ ( ចំណីរបស់សត្វគោ ) ព្រមទាំងបឹងបួរទាំងឡាយ ។

ទាំងអស់នេះ គឺជាការពណ៌នាមួយស្តីអំពីទ្រព្យសម្បត្តិដ៏ស្តុកស្តម្ភ ដែលជាកម្មសិទ្ធិរបស់វត្តអារាម នាសម័យមុនអង្គរ និងអង្គរ ហើយដែលជាវត្តអារាមខាងព្រហ្មណ៍សាសនាផង ខាងពុទ្ធសាសនាមហាយានផង ។ នៅក្នុងសិលាចារឹកសម័យមុនអង្គរ ស្ថាននាមដែលមានពាក្យ Stuk ចូលជាសមាសពាក្យ ពុំទាន់មានន័យទូលំទូលាយ ហើយក្លាយទៅជាភូមិ ជាស្រុក ដូចសម័យអង្គរទេ ។ ជាធម្មតា អ្នកស្រុក

ចូលចិត្តទៅរស់នៅបង្កបង្កើតជាភូមិស្រុក នៅតំបន់ណាដែលមានត្រពាំងបឹងបួរ មានព្រៃព្រឹក្សា ហើយកាលណាភូមិឋាននោះ កាន់តែមានផ្ទះសំបែងច្រើន មានមនុស្សរស់នៅច្រើន ភូមិឋាននោះ ក៏ប្រែក្លាយទៅជាស្រុក ។

តាមអត្ថបទសិលាចារឹក មានពាក្យ « កក៑ ( កក់ ) » ដែលជារុក្ខជាតិមួយសំខាន់ សំរាប់បំរើសុខុមាលភាពរបស់អ្នកស្រុក តាមសិលាចារឹក គេអាចស្រង់ពាក្យ « ស្តុក៑ កក៑ » « ត្រពាំងកក់ : ត្រវងកក » ប៉ុន្តែ គេមិនទាន់រកឃើញពាក្យ « បឹងកក : បិងកក » ហើយពាក្យខាងក្រោយនេះសំខាន់ណាស់ ព្រោះជាពាក្យដែលអាចចោទជាបញ្ហាបានថា ជាពាក្យដើមនៃពាក្យ « បាងកក Bang Kok » នៅក្នុងភាសាខ្មែរសម័យបច្ចុប្បន្ន ហើយជាស្ថាននាមសំរាប់សំគាល់រាជធានីនៃប្រទេសសៀម ។

## II. ៨. Laṅlaṅ , Laṅloṅ លង្លង៑ , លង្លង៑ , លង្លោង៑

ជាល្អាងទឹកដ៏ជ្រៅ ដែលកើតឡើងដោយធម្មជាតិ ។ ពាក្យនេះមានទំរង់ជាពាក្យ « ផ្ទួន » ( Réduplication ) កកើតឡើងដោយផ្ទត់ដើម laṅ បូកជាមួយនឹងពាក្យដើម : laṅ + laṅ loṅ ។ ហើយពាក្យនេះ អាចមានទំនាក់ទំនងនឹងពាក្យសម័យថ្មី laṅ, លង់ដែលមានន័យពីរយ៉ាងគឺ ជ្រៅ, លិច, លង់, លង់ទឹក ។ នៅក្នុងភាសាខ្មែរសម័យ គឺមានរក្សានូវពាក្យដើម ដែលមានទំរង់ជាពាក្យ « អន្លង់ » ប៉ុន្តែ អន្លង់ក្នុងភាសាសម័យ គឺរអាងទឹកដ៏ធំ ខុសគ្នាពីនិយមន័យបុរាណ ដែលមានន័យថា « រអាងទឹកជ្រៅ ហើយដែលអាចលង់បាន » ។

នៅក្នុងសិលាចារឹក ពាក្យនេះមិនសូវមានផលិតភាពដូចពាក្យដទៃទេ ហើយជាឧទាហរណ៍ យើងអាចស្រង់ពាក្យបាន ដូចតទៅ :

លង្លង៑ អង្គញ៑ Laṅlaṅ Aṅgañ K 158 លង្លង៑ អង្គញ៑ (អង្គុញ)

លង្លង៑ ចក្ក Laṅlaṅ Cakk K 720 លង្លង៑ ចក្ក (ចក)

Damnap Lanlan Ven K 720 ទំនបលង្លងវែង (លន្លងវែង)

Khlon Vala Lanlan Krvac K 720 ខ្លោញ វល លង្លងក្រូច

« មេទ័ពលន្លង់ក្រូច » ( ខ្លោញពល លន្លង់ក្រូច )

តាមឧទាហរណ៍ខាងលើ គេអាចធ្វើការសន្និដ្ឋានបានថា នៅក្នុងភាសាខ្មែរបុរាណ ថាពាក្យ « លង្លង, លន្លង់ » សំគាល់នូវល្អាងផ្ទុកទឹកដ៏ធំ ហើយជ្រៅដោយហេតុថា គេបានយកពាក្យនេះទៅប្រើសំរាប់សំគាល់ភូមិឋាន ដូចជាពាក្យត្រពាំង និងបឹងផងដែរ ប៉ុន្តែពាក្យ lanlan ធ្វើឱ្យយើងយល់ម្យ៉ាងទៀតថា ជាពាក្យសំគាល់ « ល្អាងទឹកដ៏ជ្រៅ ជាល្អាងទឹកកកើតឡើងដោយធម្មជាតិ » ។

*( នៅមានត )*

បណ្ឌិត **ឆ្យុង សៀម**
សាស្ត្រាចារ្យសិលាចារឹក និងអក្សរសាស្ត្រ
នៅសកលវិទ្យាល័យភូមិន្ទ ភ្នំពេញ
ជាសហការីបណ្ឌិតសភាវិទ្យាសាស្ត្រ
វិជ្ជាស្ថានបូពិសាស្ត្រ សហព័ន្ធរុស្សី

# សាស្ត្រា
# ផ្គរផ្ដាំក្ដាមខ្យង

## អារម្ភកថា

កាលខ្ញុំនៅតូច ខ្ញុំតែងឮចាស់ៗនិយាយថា " ផ្គរផ្ដាំក្ដាមខ្យង " ។ ពេលណាគាត់ឮស្នូរផ្គរគ្រហឹមជារឿយៗ នៅនាចុងរដូវវស្សាចុងឆ្នាំ ក្នុងខែអស្សុជ ដល់ដើមខែកត្តិក ផ្គរលាន់នោះ ពុំមាននាំភ្លៀងមកជាមួយផងទេ ឬបើមាន ក៏គ្រាន់តែជារលឹមតិចតួចប៉ុណ្ណោះ ។ ពេលនោះ ស្រូវនៅក្នុងស្រែកំពុងលាស់ដង្ហូខ្លះ កំពុងផ្ទើខ្លួនខ្លះ ឬកំពុងចេញ និងដាក់គ្រាប់ខ្លះ ។ ស្របពេលជាមួយនោះឯង គេឃើញក្ដាមកាយរន្ធនៅតាមភ្លឺស្រែ តាមដំបូក ឬដោយនៅកៀនកោះ ។ មានក្ដាមខ្លះទៀតវាកាយរន្ធនៅក្នុងស្រែតែម្ដង រីឯសត្វខ្យង ក៏បាត់ខ្លួនពីក្នុងស្រែដែរ ។

ខ្ញុំជាប់ចិត្តនឹងអព្ភូតហេតុធម្មជាតិបែបនេះណាស់ ។ ចាស់បុរាណយើងហាក់ដូចជាមានការយកចិត្តទុកដាក់នឹងការផ្លាស់ប្ដូររបស់ធម្មជាតិនេះ ក្នុងមនោ-សញ្ចេតនាស្នេហា និងស្វាគមន៍យ៉ាងរីករាយ ។ ខ្ញុំតែងមានអារម្មណ៍អណ្ដែតត្រសែតទៅតាមភាពល្អឥតខ្ចោះនៃធម្មជាតិនេះពន់ពេក ។

នៅក្នុងឆ្នាំ ១៩៦៥ នៅវត្តមហាមន្ត្រី ជាអារាមដែលខ្ញុំស្នាក់នៅ គឺនៅកុដិលេខ ១៩ ខ្ញុំជួនជាបានប្រទះសាស្ត្រាស្លឹករឹតខ្នាតតូចមួយ ដែលកវីបុរាណបានចារជាបទកាកគតិ ដោយដាក់ឈ្មោះថា" សាស្ត្រាផ្គរផ្ដាំក្ដាមខ្យង" ។ មួងនេះ វាហាក់ដូចជា

គាប់ជួនពន់ពេកណាស់សម្រាប់រូបខ្ញុំ ដែលមាន " ជំនឿ " កាលពីនៅជាកុមារថា នៅពេលផ្គរលាន់ឮលន្លោច ហាក់បីដូចជា " ផ្តាំ " ក្តាមខ្យងឱ្យកាយរន្ធមែនៗ ។ ខ្ញុំបានស្តាប់ព្រះសាមណេរខ្លះ អានសាស្ត្រានោះកំសាន្តផង យកមកអានខ្លួនឯងផង អានសាចុះសាឡើងយ៉ាងយកចិត្តទុកដាក់ រហូតដល់ចាំមាត់ស្ទាត់មកដល់ឥឡូវនេះ ។ សាស្ត្រានោះ វាហាក់ដូចជាធ្វើឱ្យខ្ញុំពេញចិត្តពន់ពេក ព្រោះវាស្របទៅនឹងនិស្ស័យ របស់ខ្ញុំជាអ្នកស្រឡាញ់ធម្មជាតិផង ស្រឡាញ់អក្សរសាស្ត្រជាតិផង ។

តាមការយល់របស់ខ្ញុំផ្ទាល់ សាស្ត្រាស្លឹករឹតនោះ មិនមែនមានតែមួយច្បាប់នោះទេ គឺច្បាស់ជាមានការចារចម្លងត១គ្នា ពីវត្តមួយទៅវត្តមួយ ពីតំបន់មួយទៅតំបន់មួយទៀត ។ ប៉ុន្តែ ក៏មិនមែនសម្បូរណាស់ណាដែរ ។ ចំណេរកាលក្រោយមក ខ្ញុំក៏ឃើញមានការបោះពុម្ពជាសៀវភៅខ្នាតតូចស្តើង ដែលគេដាក់ឈ្មោះថា " **សាស្ត្រាក្តាម** " ។ ប៉ុន្តែ ខ្ញុំមិនបានចាំពីសម័យកាលគេបោះពុម្ពនោះទេ ។

ដោយហេតុថា ស្នាដៃទាំងនោះ ទោះជាសាស្ត្រាស្លឹករឹតក្តី ជាសៀវភៅបោះពុម្ពក្តី ត្រូវទទួលការបំផ្លិចបំផ្លាញអស់ទៅ រកច្បាប់ដើមមិនឃើញមានសោះ ទើបខ្ញុំសម្រេចចិត្តចម្លងចេញពីការចេះចាំរបស់ខ្ញុំ ជូនពុទ្ធសាសនបណ្ឌិត្យ ឱ្យបោះពុម្ពជាថ្មី ដើម្បីឱ្យស្នាដៃនេះចាប់កំណើតកើតមាន និងរស់រានឡើងវិញសម្រាប់ទុកជាឯកសារពីបុរាណ និងសម្រាប់ការអានលេងកំសាន្តរបស់ជនានុជន ។ កាលក្នុងឆ្នាំ ១៩៩៥ ពេលខ្ញុំនៅវ៉ាស៊ិងតុន ក៏មានខ្មែរអ្នកស្នេហាអក្សរសាស្ត្រ និងវប្បធម៌ជាតិ បានមកសុំចម្លងយកកំណាព្យនេះពីខ្ញុំដែរ រួមទាំងកំណាព្យផ្សេងៗទៀត ដែលខ្ញុំបានចេះចាំ មានបទ នមោ, កខ, អក្សរល្បួន, អក្សរសង្វាស, គោព័ទ្ធស្ទឹង, រលកខ្ទប់ច្រាំងជាដើម របស់លោកគ្រូ អៀង សាយ និងកំណាព្យខ្លះទៀតរបស់កវីសន្ធរ-ម៉ុក ។

នៅក្នុងសាស្ត្រា " ផ្គរផ្តាំក្តាមខ្យង " ពុំមានចំណារត្រង់ណាដែលប្រាប់

ថា តើលោកណា ឬព្រះសង្ឃអង្គណា ជាកវីនិពន្ធនោះទេ ។ ស្នាដៃនេះ ក៏មិនមែនជាចាស់យូរយារប៉ុន្មានដែរ ។ បើរិភាគមើលតាមអក្ខរាវិរុទ្ធ និងតាមពាក្យពេចន៍ ដែលគេប្រើនៅក្នុងសាស្ត្រានោះ គេអាចយល់បានថា សាស្ត្រានោះត្រូវគេតាក់តែងចងក្រងឡើង ស្រករគ្នានឹងសាស្ត្រានានាឯទៀតដែរ ។រីឯពាក្យពេចន៍ដែលគេប្រើ គឺជាពាក្យពេចន៍សាមញ្ញបំផុតនៅក្នុងសម័យជាន់ថ្មីយើងនេះឯង ។ លើកលែងតែពាក្យបន្តិចបន្តួច ដែលខ្មែរយើងសម័យបច្ចុប្បន្នលែងប្រើក្នុងន័យនោះទៅហើយ ដូចជា " បទ " ដែលមានន័យថា " ដ្បិត " ឬថា " រី " និងពាក្យ " ភាន " ដែលមានន័យថា " ឯង " ។ ល ។ សូមលោកអ្នកអានស្វែងយល់ថែមទៀតចុះ ។

ថ្វីបើចាស់បុរាណបានហៅផ្គរលាន់ចុងឆ្នាំ ថា " ផ្គរផ្ដាំក្ដាមខ្យង " ក៏ដោយក៏នៅក្នុងអត្ថបទកំណាព្យនេះ គេពុំឃើញមានតួអង្គ " ខ្យង " ចូលរួមជាមួយផងឡើយ ។ ប្រការនេះ គឺជាការងាយយល់ទេ ព្រោះថា ពាក្យ " ខ្យង " ទោះបីមានន័យចំហាក្ដី ក៏ខ្មែរយើងតែងតែប្រើជាប់ជាមួយពាក្យ " ក្ដាម " ឱ្យទៅជាបរិវារ-ស័ព្ទ ។ នៅក្នុងភាសាសាមញ្ញ ខ្មែរយើងតែងប្រើពាក្យទាំងពីរនេះជាប់ជាមួយ ជានិច្ច ។ សត្វទាំងពីរនេះ គឺជាម្ហូបសាមញ្ញបំផុតរបស់កសិករខ្មែរយើង ។ វារស់នៅក្នុងទឹកក៏បាន លើគោកក៏បាន ក្នុងដីក៏បាន ។ គេអាចយកក្ដាម និងខ្យងទៅចម្អិនចូលគ្នាបានដោយឥតទាស់ឡើយ ទោះបីជាស្ងោរក្ដី, លីងក្ដី, ឆាក្ដី, បង់ក្នុងសម្លក្ដី ។ គឺជាម្ហូបដ៏មានឱជារស ហើយពុំមានប៉ះពាល់ដល់សុខភាពរបស់មនុស្សផង ។

កំណាព្យស្ដីពី " ផ្គរផ្ដាំក្ដាមខ្យង " នេះ ខ្ញុំបានចម្លងចេញវិញទាំងស្រុងតាមអ្វីដែលខ្ញុំបានចាំ ដោយឥតមានកែប្រែ ឬបញ្ចេញបញ្ចូលពាក្យពេចន៍អ្វីឡើយ គឺមានកែសម្រួលតែអក្ខរាវិរុទ្ធរបស់ពាក្យ ឱ្យស្របទៅតាមវចនានុក្រមខ្មែរ របស់សម្ដេចព្រះមហាសុមេធាធិបតី ជួន ណាត ប៉ុណ្ណោះ ។

សូមឱ្យភាសា និងអក្សរសាស្ត្រខ្មែរ ទទួលបានសេចក្ដីរុងរឿងឡើងវិញ ដូចកាលសម័យសង្គមរាស្ត្រនិយម ។

ភ្នំពេញ, ខែមេសា ១៩៩៦

**ចន់ ហ៊ិន**

អតីតសាស្ត្រាចារ្យភាសាបារាំង-ខ្មែរ

# ផ្គរផ្ដាំក្អាមខ្យង

(បទកាកគតិ)

ព្រហាមផ្គរធ្ងន់ ផ្គរពុំទុរជន នឹងក្អាមឡើយណា
ហាក់ដូចញាតិសាច់ សន្ដានផងគ្នា បទ(*) ចេញរស្សា
ផ្គរនឹងលាទៅ ។

ផ្គរមានមេត្តា ផ្គរផ្ដាំក្អាមថា បទក្អាមកម្លៅ
ចាំរុីយអស់ក្អាម ធ្វើរន្ធឱ្យជ្រៅ ខ្លួនឯងកម្លៅ
ជាសត្វតិរច្ឆាន ។

---

(*) បទ = ដ្បិត, រី ។

អញនឹងលាទៅ អញឱ្យហៅចៅ មកប្រាប់ប្រមាណ
ក្រែងឥតនឹងអញ មានភ័យក្នុងប្រាណ រិះគិតរកឋាន
លំនៅកំបាំង ។

រកកៀនរកកោះ កន្ទៀតចន្លោះ ប្របមាត់ត្រពាំង
តាំងពីឥឡូវ កុំឱ្យដល់ប្រាំង ក្រែងដីរីងគាំង
កកាយមិនបាន ។

បទអញនេះនែ ពួមនុស្សស្រដី ចង់ឆីក្បាលភាន(**)
ថាឯងពិសារ អាត្មាឯងមាន ខ្លាញ់ពន់ប្រមាណ
ថានឹងជុតឆី ។

មនុស្សលោកវាថា បុកក្តាមពិសារ នឹងអំពិលខ្ចី
នឹងស្លឹកសណ្តែក នឹងម្ទេះលាស់ថ្មី បុកពុំទាន់ឆី
ស្រក់ទឹកមាត់មុន ។

មនុស្សលោកវាថា ខែចេញវស្សា ក្តាមវែងខ្លាញ់លន់
ទន្ទឹងតែព្រឹក វាដើររកគន់ បើវាឃើញរន្ធ
វាជីកយកហោង ។

ខ្លះរកជញ្ជាត់ វាថាឯងកាត់ ស្រវវាជាម្តង
ប្រាមប្រាប់កូនចៅ សាច់ផៅញាតិផង កុំឱ្យឃ្មើសឃ្នង
ប្រហែសខ្លួនប្រាណ ។

ខ្លួនឯងពាយងាយ ម្តេចឃើញកកាយ ភ្លឺស្រែជាស្ថាន
លេចទឹកទាល់អស់ ស្រវលាស់ពុំបាន វាជីកយកប្រាណ
ជាអាហារវា ។

(**) ភាណ = ឯង

វាយកទៅដុត ខ្លាញ់ឯងរលត់ ទាំងភ្លើងសោះសា
ឆ្អិនស្រេចហើយនែ បូកវៃទំពា គ្រិបក្រុបមហិមា
ផ្សំនឹងបាយកក ។

វាធីខ្លួនឯង វាថាជាល្បែង ឆ្ងាញ់ដូចគេត្បក
បើឆីទទេ មិនដូចបាយកក វាចង់ទៅរក
នឹងដុតឆីទៀត ។

ចៅឯងរិះរក ត្រពាំងមានថ្ម ចៅយកខ្លួនសៀត
ប្រយ័ត្នឱ្យល្អ ប្របថ្មចង្អៀត បំបាំងប្របៀត
កុំឱ្យឃើញខ្លួន ។

ចៅមើលមនុស្សលោក វាដើរមកឈ្លោក រវៀសរត់ពួន
ឱ្យវាកំបាំង ខាងច្រាំងលាក់ខ្លួន កុំឱ្យវាជួន
វាចាប់យកទៅ ។

បងបទអញអាសូរ ជួយរិះគិតគូរ ប្រាមប្រាប់ប្រដៅ
អញយល់អស់ក្ដាម តាមតែនឹងនៅ ឱ្យមនុស្សក្បាលខ្មៅ
វាយកឆីបាន ។

ផ្ដែផ្ដាំស្រេចហើយ ទើបក្ដាមឆ្លាស់ឆ្លើយ អ្នកអើយសុំទាន
អ្នកស្មើឪពុក បង្កើតខ្ញុំបាន ស្មើអ្នកធ្វើស្ពាន
ឱ្យខ្ញុំនៅពោង ។

បងបទអ្នកប្រដៅ អស់អាថិវាក់ជ្រៅ ខ្ញុំអរកន្លង
គុណអ្នកក្រាស់ក្រៃ ថ្លាថ្លៃជាម្ដង ខ្ញុំចាប់ចាំចង
ទុកលើសិរសា ។

ផ្គរអើយអ្នកស្ដាប់ ខ្ញុំនឹងថ្លែងប្រាប់ ពីខ្លួនខ្ញុំណា

មានកាលមួយថ្ងៃ ខ្ញុំចរយាត្រា រកឆីនៅនា
ផ្កាមួយធំក្រៃ ។
វាដើរងងះ ស្រាប់តែពើបពះ ចេញមករវៃ
ក្រឡេកឃើញខ្ញុំ លោកច្រំនឹងដៃ តេជះខ្ញុំវៃ
ខ្ញុំវេះរួចហោង ។
ខ្ញុំផ្ដាច់ក្រោមគល់ វារកពុំយល់ វាស្ដាយកន្លង
វាថាក្ដាមធំ ឆីបាយឆ្អែតម្ដង វាចោរទ្រើសឃ្នង
ចង់បានខ្ញុំណា ។
វាចាប់ពុំបាន វាដើរទៅស្ថាន ឯទៀតសោះសារ
ចាប់អស់ក្ដាមផង ដាក់ពេញត្រកវា ហើយចរយាត្រា
វិលវឹងទៅស្ថាន ។
ខ្ញុំមើលទៅយល់ ក្នុងត្រករងល់ កង្កែបក្ដាមផង
ខ្ញុំគិតអនិច្ចា អាត្មាខ្ញុំហោង ក្រែងដូចក្ដាមផង
នៅក្នុងត្រកវា ។
ផ្គរអើយខ្ញុំចាល ត្រង់ជីកត្រង់ខារ ខ្ញុំខ្លាចណាស់ណា
វាឈឺអស់អង្គ វាខ្លាចវាផ្សារ វាមុតអាត្មា
របើកខ្ចាត់ខ្ចាយ ។
បើនៅតែខ្ញុំ ធ្វើរន្ធមិនធំ មិនឱ្យឃើញងាយ
បទតែកង្កែប ស្របែបអន្តរាយ វាទៅនៅឆ្ងាយ
ខ្ទេចទាំងជាកាច ។
បើឮភ្លៀងម្ដង វាយំរំពង ហើយលោតប្រសាច
វាសើចវាលេង មិនក្រែងមិនខ្លាច វាអាងអំណាច

អ្វីនៅខ្លួនវា ។

មិនរាងមិនចាល    គេធ្វើងៀតហាល    ដុតធីពិសារ
វាយកទៅលោត់    វាកាត់បាទា    កាត់ទាំងសិរសា
ហើយវាសំអុះ ។

វាក៏បង់ម្រេច    នូវខ្ទឹមបន្ទិច    ប្រហុកបង់ចុះ
ហើយបង់ស្លឹកគ្រៃ    បង់ខ្ទឹមបង់សោះ    ភ្លក្សហើយថាអុះ
ពិសារក្អាត់ហោង ។

កង្កែបពាលោ    វាលេងសើចហ៊ោ    មិនគិតក្រែងឆ្គង
វាមិនដូចខ្ញុំ    បារម្ភក្អាត់ហោង    ចាំពាក្យអ្នកបង
អ្នកផ្តែផ្តាំថា ។

ក្អាមអើយក្អាមស្តាប់    អញនឹងថ្លែងប្រាប់    អញនឹងលាកលា
ចូរក្អាមប្រយ័ត្ន    នឹងមនុស្សផងណា    វាមកពាធា
យកក្អាមធីបាន ។

ក្អាមអើយអញលា    អញចរយាត្រា    ត្រាច់ត្រង់ទៅស្ថាន
ខែចៃត្រចូលឆ្នាំ    អញវិលមកស្ថាន    ដ្បិតងារក្នុងប្រាណ
អញវិលមកហោង ។

**ចប់**

# សត្វក្អែកគ្មានខ្លាញ់ (១)

បណ្ដាបក្សីទាំងអស់ក្នុងលោក ក្អែកជាបក្សីដ៏ចម្លែក ព្រោះសត្វនេះ ពុំមានខ្លាញ់នៅក្នុងខ្លួនទេ ។

ក្នុងគម្ពីរមង្គលត្ថទីបនី ដែលជាអដ្ឋកថា និយាយបំភ្លឺសេចក្ដីរបស់មង្គលសូត្រ ៣៨ ប្រការ, ជាវណ្ណកម្មរបស់អ្នកប្រាជ្ញពុទ្ធសាសនាមួយអង្គ គឺព្រះសិរីមង្គលាចារ្យ បាននិយាយទាក់ទងដល់មូលហេតុដែលបណ្ដាលឱ្យក្អែកក្លាយទៅជាសត្វឥតមានខ្លាញ់ ដូចបក្សីនានានោះ ។ ក្នុងគម្ពីរនេះ មានសេចក្ដីដំណាលថា :

កាលពីព្រេងនាយ ព្រះសម្មាសម្ពុទ្ធទ្រង់ជាពោធិសាត់ កំពុងកសាងបារមីនៅឡើយ បានសោយព្រះជាតិជាសត្វក្អែកមួយ ដោយមានពួកក្អែកចំនួន ៨ ម៉ឺនក្បាល ជាបរិវារ ហើយរស់នៅក្នុងព្រៃស្មសានមួយដ៏ធំ ។ ក្នុងថ្ងៃមួយនោះ មានបុរោហិតម្នាក់ របស់ព្រះចៅក្រុងពារាណសី បានចេញទៅងូតទឹកខាងក្រៅក្រុង ។ ជួនពេលនោះ សត្វក្អែកពីរ កំពុងទំលើកំពូលខ្លោងទ្វារក្រុង ។ ចំណោមក្អែកទាំងពីរនេះ ក្អែកមួយបានពោលថា " នែសម្លាញ់, ខ្ញុំនឹងជុះអាចម៍ដាក់ក្បាលបុរោហិតនេះឥឡូវ " ។ ឯក្អែកមួយទៀត ក៏ឃាត់ថា " នែរ៉ុយ, កុំធ្វើយ៉ាងនេះឡើយ ព្រោះបុរោហិតនេះ ជាឥស្សរជនរបស់ព្រះរាជា បើឯងចចេសធ្វើ នឹងមានបាបធ្ងន់ណាស់ម្យ៉ាងទៀត បើបុរោហិតនេះខឹង ប្រាកដជារកវិធីធ្វើឱ្យពួកក្អែកយើងទាំងអស់វិនាសពុំខាន " ។

ក្អែកមួយនោះមិនស្ដាប់តាម ក៏បានជុះអាចម៍ដាក់ក្បាលបុរោហិតនោះទៅ ។ បុរោហិត កើតការខឹងសម្បារយ៉ាងខ្លាំងចំពោះសត្វក្អែកនោះ ហើយគិតថា

(១) អត្ថបទនេះ ដកស្រង់ពីមង្គលត្ថទីបនី ភាគ ៣ ពីទំព័រ ១៣៤ ដល់ទំព័រ ១៣៨ ។

« អញនឹងចងពៀរវេរាជាមួយសត្វក្អែកទាំងឡាយឱ្យទាល់តែបាន » ។

គាប់ជួនគ្រានោះ មានស្ត្រីម្នាក់កំពុងអង្គុយចាំស្រូវ ដែលខ្លួនហាលកណ្តាលថ្ងៃក្តៅ ។ សត្វពពែមួយក្បាល បានមកស៊ីស្រូវនោះ ។ ស្ត្រីម្ចាស់ស្រូវ ក៏ស្ទុះទៅយកអង្កត់ភ្លើងវាយពពែនោះ ។ ភ្លើងក៏ឆេះរោមពពែ ។ ពពែក្តៅ បោលស្ទុះទៅត្រដុះនឹងខ្ទមស្មៅមួយ ក្បែររោងដំរី ។ ខ្ទមស្មៅ ក៏ត្រូវភ្លើងឆេះយ៉ាងសន្ធោសន្ធៅហើយឆាបឆេះរាលទៅដល់រោងដំរីទៀត ។ ដំរីជាច្រើនក្បាលដែលនៅក្នុងរោងនោះ ត្រូវភ្លើងឆេះរលាក ដំបៅពេញទាំងខ្លួន ។ ពួកពេទ្យហ្មដំរី មិនអាចព្យាបាលដំបៅដំរីទាំងនោះឱ្យជាសះស្បើយបានឡើយ ក៏ក្រាបទូលចំពោះព្រះរាជា ។ ព្រះចៅក្រុងពារាណសី ទ្រង់ត្រាស់បញ្ជាឱ្យហៅបុរោហិតមកសួរថា " តើអ្នក ចេះថ្នាំព្យាបាលដំរីខ្លះដែរឬទេ ? " ។ បុរោហិត ក្រាបទូលថា " បពិត្រព្រះមហារាជ ទូលព្រះបង្គំចេះ ប៉ុន្តែត្រូវមានខ្លាញ់វារ ( វសា ) របស់ក្អែក ទើបអាចព្យាបាលបាន " ។ ព្រះរាជាទ្រង់ត្រាស់ឱ្យគេរកខ្លាញ់ក្អែក ដើម្បីផ្សំថ្នាំព្យាបាលដំរី ។

ចាប់ពីពេលនោះមក ប្រជារាស្ត្របាននាំគ្នាសម្លាប់សត្វក្អែក គ្រប់ទីកន្លែងគរជាគំនរ ប៉ុន្តែពុំបានខ្លាញ់សោះ ។ សត្វក្អែកទាំងឡាយ កើតមានភ័យរិបរិតឥតឧបមា លាក់ខ្លួន ពួនអាត្មា មិនហ៊ានឱ្យមនុស្សឃើញឡើយ ។

ក្អែកពោធិសត្វ ដឹងហេតុនោះហើយ ប្រាថ្នានឹងធ្វើការសង្គ្រោះដល់ញាតិ បាននឹករលឹកដល់បារមីទាំងឡាយ ទ្រង់ញ៉ាំងមេត្តាបារមីឱ្យប្រព្រឹត្តទៅខាងមុខ ហើយហើរលឿនស្លៅចូលតាមប្រឡោះបង្អួចទៅនៅក្រោមព្រះទីតាំងរបស់ព្រះរាជា ។ ពេលនោះ មនុស្សម្នាក់បានឃើញក្អែកពោធិសត្វ ក៏ចង់ស្ទុះទៅចាប់ ។ ព្រះរាជាទ្រង់ឃាត់អ្នកនោះ ។ ក្អែកពោធិសត្វបានសម្រាកបន្តិច ក៏ចេញពីក្រោមព្រះទីនាំងមកក្រាបទូលថា " បពិត្រព្រះមហារាជ ធម្មតាព្រះរាជាគ្រប់គ្រងរាជសម្បត្តិ មិនទ្រង់លុះដោយអគតិ មានឆន្ទាគតិ ជាដើម ទើបត្រឹមត្រូវ, មុននឹងទ្រង់បំពេញព្រះរាជកិច្ច

ណាមួយ ត្រូវតែទ្រង់ព្រះតម្រិះព្រះរាជកិច្ចនោះ ឱ្យបានល្អិតល្អន់ម៉ត់ចត់សិន ទើបត្រឹមត្រូវ, ព្រះអង្គបំពេញតែព្រះរាជកិច្ចណាដែលមានផលប្រយោជន៍ ទើបគួរ, តាមពិត ព្រះរាជាទាំងឡាយក្នុងកាលមុន មិនទ្រង់បំពេញនូវព្រះរាជកិច្ចណា ដែលបំពេញហើយ ឥតហុចផលប្រយោជន៍ឱ្យនោះឡើយ, បុរោហិត ជាអ្នកលុះក្នុងអំណាចនៃពៀរវេរា ទើបបានពោលពាក្យកុហកឱ្យគេរកខ្លាញ់ក្អែក, តាមពិតនោះ ក្អែកទាំងឡាយ មិនដែលមានខ្លាញ់ទេ " ។

ព្រះចៅក្រុងពារាណសី លុះទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ទ្រង់មានព្រះរាជហឫទ័យត្រេកអរក្រៃលែង បានឱ្យក្អែកពោធិសត្វនោះ ទំលើព្រះទីនាំងមាសដ៏ប្រសើរ ទ្រង់ត្រាស់ឱ្យរាជបុរសលាបប្រេង ដែលស្លហើយយ៉ាងប្រណីតៗ ទ្រង់ព្រះរាជទាន នូវភោជនដ៏មានរសជាតិឆ្ងាញ់ដាក់ក្នុងចានមាស ដូចជាព្រះក្រយាស្ងោយដែរ ។ លុះក្អែកពោធិសត្វទទួលទានអាហារឆ្អែតស្កប់ស្កល់ហើយ ទើបព្រះរាជាទ្រង់មានព្រះបន្ទូលសួរថា " ម្នាលបណ្ឌិត, ព្រោះហេតុអ្វីបានជាខ្លាញ់រាវរបស់ក្អែកទាំងឡាយមិនមាន ? ( *បណ្ឌិត កេន ការណេន កាកានំ វសា នត្ថិ* ) " ។

ក្អែកពោធិសត្វ កាលដែលទ្រង់សំដែងធមិដល់ព្រះរាជានោះ បានពោលនូវគាថា ថា :[(១)]

*និច្ចំ ឧព្វិគហទយា សព្វលោកវិហេសិតា*
*តស្មា នេសំ វសា នត្ថិ កាកានស្មាក ញាតិនន្តិ ។*

" ក្អែកទាំងឡាយ ជាសត្វមានហឫទ័យភ្ញាក់ផ្អើលជានិច្ច ត្រូវមនុស្សលោកទាំងពួងបៀតបៀនហើយ ព្រោះហេតុនោះបានជាខ្លាញ់រាវនៃពួកក្អែក ជាញាតិនៃពួកខ្ញុំលបង្គំនោះមិនមាន " ។

ព្រះរាជាទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ទ្រង់មានព្រះហឫទ័យជ្រះថ្លា

(១) គម្ពីរព្រះត្រៃបិដក បាលី - ខ្មែរ ភាគទី ៥៨ ទំព័រទី ៦១

ហើយបានបូជារាជសម្បត្តិដល់ក្អែកពោធិសត្វ ។ ក្អែកពោធិសត្វបានញុំាងព្រះរាជាឱ្យស្ថិតនៅក្នុងសីល ៥ បានទូលសុំឱ្យព្រះរាជាទ្រង់អភ័យទោសដល់សព្វសត្វ រួចបានថ្វាយព្រះរាជសម្បត្តិដល់ព្រះរាជាវិញ ហើយហើរត្រឡប់ទៅកាន់កន្លែងដើម ។

ចាប់តាំងពីពេលនោះមក ព្រះរាជាទ្រង់បានធ្វើទានដល់សព្វសត្វ ទ្រង់បានតម្កល់ទានជាប្រចាំដល់សត្វក្អែកទាំងឡាយ ទ្រង់បានឱ្យគេដាំបាយលាយជាមួយម្ហូបដែលមានរសជាតិឆ្ងាញ់ សម្រាប់ពួកក្អែក ជារៀងរាល់ថ្ងៃ ទ្រង់បានរំលែក ព្រះក្រយាស្ងោយរបស់ព្រះអង្គ ព្រះរាជទានដល់ក្អែកពោធិសត្វនោះ ជានិច្ចកាល ។

ប្រែនិងរៀបរៀងដោយ

**ម៉ែន ប្រាជ និង អាំ ឆន**

ពិនិត្យនិងកែសម្រួលដោយ ឱម ខែម

# ការធ្វើទៀនពីក្រមួនចំបក់ [១]

តាំងពីយូរអង្វែងមកហើយ ខ្មែរយើងចេះធ្វើទៀនពីក្រមួនឃ្មុំ ដោយដាក់ប្រនេះអំបោះនៅកណ្ដាល យកសាច់ក្រមួនមករុំស្រោបពីខាងក្រៅ ហើយលញ់ឱ្យមូល, មានវែង មានខ្លី, មានធំ មានតូច តាមខ្នាតដែលសង្គមត្រូវការ ។ ទៀនដែលធ្វើពីក្រមួនឃ្មុំនេះ គេយកទៅប្រើប្រាស់ក្នុងពិធីបុណ្យទាន ពិធីសែនព្រេន បន់ស្រន់ខ្មោច អារក្ស អ្នកតា ឬប្រើប្រាស់ក្នុងពិធីចាំបាច់ផ្សេងៗ មានពិធីអាពាហ៍ពិពាហ៍ ចូលម្លប់ ចេញម្លប់ ល្បៀងអារក្ស និងបុណ្យចូលវស្សា ជាដើម ។ ប៉ុន្តែទៀនវស្សាតាមធម្មតា គេសិតទៀនមួយយ៉ាងធំ វែង ល្មមអុជបានពេញបីខែ ដែលជារយៈពេលចូលវស្សា ។ លុះពេលជាខាងក្រោយមក ប្រទេសក្រៅបានផលិតទៀនជាទ្រង់ទ្រាយធំ ហើយគេបាននាំចូលមកលក់ក្នុងស្រុកខ្មែរយើង ដោយតម្លៃថោកល្មមនោះ ប្រជាជនខ្មែរយើងក៏ធ្វើទៀនក្រមួនឃ្មុំ សំរាប់តែប្រើក្នុងពិធីសំខាន់ៗ និងចាំបាច់ប៉ុណ្ណោះ គេនាំគ្នាទិញទៀននាំចូលនេះប្រើប្រាស់រហូតមកដល់សព្វថ្ងៃ ។

នៅក្នុងអំឡុងឆ្នាំ ១៩៤០ - ៤១ សង្គ្រាមលោកលើកទីពីរបានផ្ទុះឡើង, ការផ្គត់ផ្គង់ទំនិញផ្សេងៗពីបរទេសចូលមកកម្ពុជា មានផលិតផលទៀននេះ ជាដើម ត្រូវបានកាត់ផ្ដាច់ ។ ក្នុងកាលៈទេសៈដ៏លំបាកនេះ គំនិតច្នៃប្រឌិតធ្វើទៀនពីក្រមួនចំបក់ ក៏ត្រូវបានស្ដែងចេញជារូបរាងឡើង ។ តើគេធ្វើទៀនពីក្រមួនចំបក់នេះដូចម្ដេច ?

---

(១) ខ្ញុំបានសរសេរចងក្រងអត្ថបទនេះឡើង តាមការសង្កេតផ្ទាល់របស់ខ្ញុំ ទៅលើមជ្ឈដ្ឋានសង្គមដែលខ្ញុំរស់នៅ គឺនៅស្រុកគីរីវង្ស ខេត្តតាកែវ ។ ពិសេស គឺការសង្កេតនិងចូលរួមដោយផ្ទាល់ជាមួយឪពុកម្ដាយខ្ញុំ អ្នកធ្វើទៀនពីក្រមួនចំបក់នេះតែម្ដង ។

## * អំពីដើមចំបក់ និងផ្លែវា

អស់លោកអ្នកអានភាគច្រើន ធ្លាប់ស្គាល់ ធ្លាប់ឃើញដើមចំបក់ស្រាប់ហើយ ។ គេសង្កេតឃើញដើមចំបក់ដុះនៅតាមព្រៃភ្នំ និងព្រៃធម្មតានៃប្រទេសយើង ។ ចំបក់ជាប្រភេទដើមឈើរឹង ដែលមានទំហំធំដូចឈើទាល ឬផ្ចឿក ដែរ ។ ដើមណាដែលចាស់បំផុត អាចមានទំហំដល់ទៅ ៤ ឬ ៥ ឱប នៅត្រង់គល់ ហើយមានកំពស់ រហូត ២៥ ឬ ៣០ ម៉ែត្រទៀតផង ។ សំបកចំបក់មានពណ៌ក្រហមប្រផេះ ។ ខ្លឹមវាពណ៌ ស ប្រហែលនឹងសាច់ស្រាយដែរ ។ វាមានស្លឹកមូលទ្រវែងប្រហាក់ប្រហែលនឹងស្លឹកល្មុត ។ នៅរដូវដើមឆ្នាំ គឺរវាងខែចេត្រ ពិសាខ ចំបក់ចាប់ផ្តើមចេញផ្កា ដែលមានក្លិនក្រអូបសាយភាយពាសពេញព្រៃ[(១)] ។ ផ្លែចំបក់មានទំហំប៉ុនមេជើង ចំពោះដើមចាស់ និងមានទំហំប៉ុន១កដៃ ចំពោះដើមសាវ ។ កាលណាផ្លែទុំ វាមានពណ៌ក្រហមព្រឿង ; សាច់សំបកខាងក្រៅមានរស់ជាតិផ្អែមលាយចត់បន្តិចៗ ។ ផ្លែចំបក់ទុំជ្រុះធ្លាក់មកដី គរកៀវនៅក្រោមដើម ។ កាលណាសាច់ក្រៅរលួយអស់ទៅ នៅសល់តែគ្រាប់រឹង ដែលប្រជាជនខ្មែរយើងតែងតែយកគ្រាប់នោះមកដាប់យកសាច់ហូបឆៅ ឬក៏យកមកលីងឱ្យឆ្អិនហូប ឈ្ងុយដូចសណ្តែកដី ។ ហូបសាច់ចំបក់ច្រើន គេមានអារម្មណ៍ឈឺក្បាល តឹងច្រមុះបន្តិចៗ ។ បាតុភូតនេះធ្វើឱ្យគេកត់សំគាល់ដឹងថា គ្រាប់ចំបក់អាចមានជាតិប្រេង ។

## * ការសាកល្បងចំរាញ់យកប្រេងចំបក់ធ្វើក្រមួន

ដោយការកត់សំគាល់ដឹងថាគ្រាប់ចំបក់មានជាតិប្រេងដូច្នេះហើយបានជា នៅពេលដែលប្រទេសយើងខ្វះទៀនប្រើប្រាស់ទាំងស្រុងនោះ នាំឱ្យគេធ្វើការ

---

(១) ដោយមានអារម្មណ៍ចំពោះផ្កាចំបក់ ទើបចាស់បុរាណតែងជាបទប្រពៃណីមួយឱ្យឈ្មោះថា « បទចំបក់រោយ » គឺផ្កាចំកប់រុះរោយ មុននឹងចេញជាក្តិបចំបក់ ។ បទចំបក់រោយនេះ សំរាប់លេងក្នុងពិធីរាពាហ៍ពិពាហ៍ ឬលេងកំដរក្នុងពិធីបុណ្យផ្សេងៗ ។

សាកល្បងចំរាញ់យកប្រេងពីសាច់គ្រាប់ចំបក់មកធ្វើក្រមួន ។

ឆ្នាំ ១៩៤០ - ៤១ ចំបក់នៅត្រទេសកម្ពុជាយើង នៅបណ្តាឃុំនានាមានផ្លែច្រើនជាងឆ្នាំណាៗទាំងអស់ ពិសេសនៅស្រុកគិរីវង្ស ខេត្តតាកែវ ។ អ្នកដែលធ្វើការសាកល្បងផលិតទៀនពីក្រមួនចំបក់ (១) ក៏បាននាំគ្នាទៅដឹកជញ្ជូនផ្លែចំបក់ដែលជ្រុះទាំងគំនរៗ យកមកចាក់គរទុកនៅផ្ទះ ដើម្បីដាប់គ្រាប់ឆ្កឹះយកសាច់ ។ គឺសាច់នេះហើយដែលគេត្រូវយកទៅបុកឱ្យម៉ដ្ឋ រួចយកទៅចំហុយលើរបួលធំៗមុននឹងយកទៅវាយកៀបពៀតចំរាញ់យកប្រេង ។ មធ្យោបាយងាយស្រួលក្នុងការកៀប-ពៀតចំរាញ់យកប្រេងចំបក់ គេត្រូវធ្វើផ្ទោះមួយដែលមានបង្គោលពីរនៅសងខាងកប់ទៅក្នុងដីជម្រៅកន្លះម៉ែត្រ ។ បង្គោលនេះគេដាប់សឹកធ្នឹមពីរដែលមានប្រវែងប្រមាណ ១ ម៉ែត្រ ២ តឹក ទៅ ១ ម៉ែត្រកន្លះ ពីបង្គោលមួយទៅបង្គោលមួយ ។ ធ្នឹមក្រោមមានចោះប្រហោងមូល មានវិជ្ឈមាត្រ ពី ១ តឹកកន្លះ ទៅ ១ តឹក ៨ ហ៊ុន ហើយមានជម្រៅប្រហែល ២ តឹក ។ នៅបាតប្រហោងនេះ គេខ្វៃរន្ធតូចៗជាច្រើនទៀត ដូចរន្ធប៉ែននំបញ្ចុក ទុកសំរាប់ឱ្យប្រេងចំបក់ហូរធ្លាក់ទៅខាងក្រោម ។ ធ្នឹមលើមានទំហំប៉ុន ឬតូចជាងធ្នឹមក្រោម សំរាប់កៀបសង្កត់ពៀតស្នួលប៉ែនទៅក្នុងប្រហោងធ្នឹមក្រោម ដើម្បីចំរាញ់បញ្ចេញជាតិប្រេងចំបក់ឱ្យហូរចេញតាមរន្ធប៉ែន ។ សាច់ចំបក់បុកម៉ដ្ឋ ត្រូវបានចំហុយឱ្យឆ្អិន ហើយបញ្ជូនទៅសិប្បករពីរនាក់ដែលមានភារៈចាំចំរាញ់យកប្រេង ។ ម្នាក់ៗឈរនៅបង្គោលម្ខាង ។ កាលណាគ្រាប់ចំបក់ចំហុយ បានចាក់ទៅក្នុងប្រហោងប៉ែនខាងធ្នឹមក្រោមហើយ គេសឹកស្នួលប៉ែនទៅលើប្រហោងប៉ែន ហើយសឹកធ្នឹមលើពីលើស្នួលប៉ែន រួចសិប្បករទាំងពីរនាក់

(១) ក្នុងចំណោមអ្នកសាកល្បងនោះ ក៏មានគ្រួសារខ្ញុំផងដែរ, ពេលយប់ ឪពុកម្តាយខ្ញុំបានចាត់ចែងឱ្យបងប្អូនខ្ញុំដាប់គ្រាប់ចំបក់យកសាច់ចំរាញ់ធ្វើក្រមួន ។

វាយស្មៀត ដើម្បីឱ្យក្បៀបសង្កត់ទៅលើស្នូលប៉ែនដែលសង្កត់បន្តទៅលើសាច់ចំបក់ ចំហុយឆ្អិននោះ ដវាបទាល់តែចេញជាតិប្រេង ហូរតាមរន្ធប៉ែនធ្លាក់ទៅលើថានដែក ធំ ដែលដាក់ត្រងនៅពីក្រោមប៉ែន ។ ប្រេងនេះមានសម្បុរលឿងព្រឿងៗ ដូចប្រេងដូង ។ ពេលណាវាត្រូវធាតុត្រជាក់ វាក៏កករឹង មានពណ៌សដូចទឹកដោះគោ ។ នេះហើយជាក្រមួនចំបក់ ដែលគេយកទៅធ្វើទៀន ។ ចលនាដឹកប្រមូលផ្លែចំបក់ពីព្រៃ, ចលនាដាប់ផ្លែចំបក់យកសាច់, ចលនាបុកលំអិតសាច់ចំបក់ និងចំហុយឱ្យឆ្អិន, ចលនាចំរាញ់យកប្រេងចំបក់ ចេះតែប្រព្រឹត្តទៅឥតឈប់ឈរ ។ គេកត់សំគាល់ឃើញមានសិប្បករតិចណាស់ ដែលធ្វើអាជីវកម្មផលិតក្រមួនចំបក់នេះ ព្រោះគេឃើញការងារនេះលំបាកស្មុគស្មាញ ហើយគេពុំសូវដឹងច្បាស់លាស់អំពីលទ្ធផលចុងក្រោយ ថាតើមុខរបរនេះបានចំណេញ ឬក៏ចំណាយពេលវេលា និងកម្លាំង ខាតឥតប្រយោជន៍។

## * ការសាកល្បងផលិតទៀនចំបក់

ដំបូង ខ្ញុំសង្កេតឃើញម្តាយខ្ញុំកាត់ធាងល្ហុងយ៉ាងច្រើន ដែលមានខ្នាតធុនធំ ធុនមធ្យម និងធុនតូច ។ ធាងល្ហុងទាំងនោះ ត្រូវបានយកទៅកាត់តម្រឹមខាងគល់ និងខាងចុង ។ គាត់យកផ្នុកធ្វើអំពីស្រទបចេកមកចុកប្រហោងខាងគល់ឱ្យជិត រួចយកសរសៃអំបោះមួយភ្ជាប់ពីបាតផ្នុកខាងក្រោម ទាញឱ្យតឹងយ៉ាងត្រង់ទៅមាត់បំពង់ខាងលើ ហើយយកកន្លះឫស្សី ឬកន្លះដូង ពុះច្រៀកគាបសរសៃអំបោះដាក់ឱ្យចំកណ្តាលប្រហោងបំពង់ ។ បំពង់ធាងល្ហុងដែលបានរៀបចំបែបនេះរួចហើយនោះ ត្រូវបានដាក់បញ្ឈរនៅក្នុងថាំងមួយដែលមានទឹកជិតពេញ ។ ក្រមួនត្រូវបានយកទៅស្លឱ្យរលាយក្នុងអំបែងមួយធ្វើពីដែកប៉ោត ដែលមានរាងកណ្តុកនៅត្រង់ត្លួអំបែង ហើយមានមាត់ចំពួយរាងវៀវតូច សំរាប់ចាក់ក្រមួនរលាយទៅក្នុងបំពង់ពុម្ព ។ បំពង់ពុម្ពដែលត្រាំក្នុងទឹកត្រជាក់ គឺបង្កលក្ខណៈងាយស្រួលឱ្យក្រមួនឆាប់កករឹងទៅជា

ទៀន ។ លុះក្រមួនកកត្រជាក់ហើយ ម្ដាយខ្ញុំក៏យកពុម្ពផាងល្ហុងមកច្រៀកសំបកខាង១ចេញ ឱ្យនៅសល់តែទៀនរាងមូលទ្រវែងពណ៌សភ្លឺង ។

ទៀនដែលផលិតបាន ទោះបីជាមានរូបរាងពេញលក្ខណៈជាទៀន ក៏ប៉ុន្តែនៅមានចំណុចខ្វះខាត ដោយដើមទៀនមិនសូវត្រង់ ព្រោះវាមានរាងកោងបន្តិចទៅតាមទម្រង់ផាងល្ហុង ទោះបីគេកាត់ឱ្យខ្លី១ តាមខ្នាតហើយនោះក្ដី ។ តែទោះជាយ៉ាងនេះក៏ដោយ ក៏ផលិតករនៅតែពេញចិត្តនឹងផលិតផលដែលគេបានច្នៃបង្កើតឡើងយ៉ាងលំបាកនេះ ហើយលទ្ធផលប៉ុណ្ណោះ ក៏អាចឆ្លើយតបបានខ្លះ១ទៅនឹងសំណូមពររបស់សង្គមក្នុងតំបន់នោះ នាសម័យកាលនោះហើយ ។

## * ការសាកល្បងផលិតទៀនចំបក់ជំហានទីពីរ

ឪពុកម្ដាយខ្ញុំបានចំណាយពេលយ៉ាងច្រើន ដើម្បីរិះរកវិធីផលិតទៀនឱ្យបានត្រង់ល្អជាងមុន ។ ថ្ងៃមួយ ឪពុក និងបង១ខ្ញុំ បានឡើងទៅលើភ្នំព្រះស្បូក[១] ហើយកាប់ពក[២] យ៉ាងច្រើនមកទុកនៅផ្ទះ ។ គឺពកនេះហើយដែលជាវត្ថុចាំបាច់សំរាប់យកមកធ្វើបំពង់ពុម្ព ។ ពកដែលកាប់យកមកពីព្រៃ សុទ្ធតែតម្រូវទៅតាមខ្នាតដូចពោលខាងលើ គឺធុនធំ ធុនកណ្ដាល និងធុនតូច ។ របៀបដាក់ប្រឆេះ ដាក់ផ្នុកនិងរបៀបចាក់ក្រមួនក្នុងពុម្ពបំពង់ ក៏ធ្វើដូចគ្នានឹងលើកមុនដែរ ខុសគ្នាត្រង់នៅលើកនេះ ពុម្ពបំពង់ធ្វើពីពក មានលក្ខណៈត្រង់ល្អ ស្មើលើស្មើក្រោម ។

ទៀនដែលបានយកមកចេញពីបំពង់ពក ឃើញថាត្រង់ល្អ ដូចពុម្ពពិត១ ។

---

(១) ភ្នំព្រះស្បូក ស្ថិតក្នុងភូមិសាស្ត្រឃុំតាអូរ ស្រុកគីរីវង្ស ខេត្តតាកែវ ។ ភ្នំនេះមានកំពស់ប្រហែល ១០០០ ម៉ែត្រ ហើយមានពកដុះ យ៉ាងសម្បូរ ។

(២) ពកជារុក្ខជាតិសន្តានឫស្សីដើមវាមានប្រហោងធំ សាច់វាស្តើង . ដើមត្រង់ល្អណាស់ ។ វាមានសណ្ឋានទ្រង់ទ្រាយដូចដើមម៉ៃសាក់ . តែវាមានដើមធំ១ ជាងហើយមានសាច់ខាងស្តើងជាងម៉ៃសាក់ ។

ទាំងផលិតករផ្ទាល់ ទាំងអតិថិជនអ្នកប្រើប្រាស់ តែងតែពេញចិត្តពេញថ្លើមនឹងការច្នៃប្រឌិត និងការរកឃើញ ( découverte ) នេះណាស់ ។ បើប្រៀបធៀបទៅនឹងបរិមាណទៀនផលិតចេញពីរោងចក្រទំនើប ឃើញថាខុសគ្នាច្រើនណាស់ ។ យើងផលិតដោយដៃ មិនបានច្រើនទេ ប៉ុន្តែត្រង់គុណភាព ឃើញហាក់ដូចជាមិនលើសខ្វះខុសគ្នាប៉ុន្មានឡើយ ។

## * អំពីការកែលំអផលិតកម្មទៀនចំបក់

ក្រោយពីបានកែលំអខាងគុណភាព ខាងសណ្ឋានទ្រង់ទ្រាយឱ្យបានល្អប្រហាក់ប្រហែលនឹងទៀនផលិតចេញពីរោងចក្រហើយនោះ ឪពុកម្ដាយខ្ញុំជាផលិតករ ក៏បានគិតច្នៃធ្វើទៀននេះឱ្យមានពណ៌លឿង ក្រហម ដូចទៀននាំចូលពីប្រទេសឧស្សាហកម្ម ។ ការងារនេះងាយធ្វើទេ គេគ្រាន់តែយកល័ខដែលមានពណ៌ទាំងពីរខាងលើមកក្លូរលាយជាមួយក្រមួននោះ ជាការស្រេចទៅហើយ ។ រីឯពណ៌សវិញ គឺជាពណ៌ធម្មជាតិរបស់ក្រមួនចំបក់ស្រាប់ ។

ការរកឃើញថ្មីនេះផ្ដល់នូវអត្ថប្រយោជន៍ពីរយ៉ាងសំខាន់គឺ :

១ . ឆ្លើយតបបានទៅននឹងតម្រូវការរបស់សង្គមក្នុងគ្រាដែលប្រទេសខ្វះទំនិញនាំចូល ។

២ . លើកស្ទួយជីវភាពផលិតករធ្វើក្រមួន និងធ្វើទៀនចំបក់ឱ្យបានធូរធាជាងពេលធម្មតា ។

ដើមចំបក់ ជារុក្ខជាតិមួយដែលផ្ដល់នូវវត្ថុធាតុដើមយ៉ាងសំខាន់ សំរាប់ផលិតទៀន ។ បច្ចុប្បន្ននេះ ទោះបីគេចង់ធ្វើទៀនពីក្រមួនចំបក់ទៀត ក៏ដើមចំបក់នៅប្រទេសយើងមាននៅសល់តិចតួចណាស់ ពុំអាចផ្ដល់ផ្លែឱ្យផលិតទៀនប្រើ-ប្រាស់តាមសំណូមពរបានឡើយ ។

ដោយ **មៀច ប៉ុណ្ណ**

# មាតុភូមិ

ស្រាវជ្រាវ និងរៀបរៀងដោយ

**ហៀន ចណ្ណារ៉ុត្ន**

មាតុភូមិ មិនមែនគ្រាន់តែជាវាលស្រែដ៏ធំធេង ឬ ខ្នងភ្នំ ជុំជិះប៉ូកនោះទេ, មិនមែនកំពូលដ៏ស្រួចស្រិមស្ដែនៃព្រះវិហារ ឬ ចុងឈើខ្ពស់លលៃ ដ៏មានស្លឹកខៀវខ្ចីនោះទេ, ឬក៏ថា ចំរៀងលាន់ខ្ទ័រ របស់ក្មេងឃ្វាលក្របី គោ ចៀម ពពែ សេះ នោះក៏មិនមែនទៀត ។

មាតុភូមិ គឺអានុភាពនៃសេរីភាព គឺអ្វីដែលធ្វើឱ្យបេះដូងយើងរញ្ជួយ គឺកិត្តិគុណនិងសុកិត្តិស័ព្ទ ដែលមិនអាចបំភ្លេចបានឡើយ នៃបុព្វបុរសរបស់យើងបានសាងទុកមកជាកេរដំណែលឱ្យយើង ។

មាតុភូមិនោះទៀត គឺទន្លេដ៏បវរ ដែលហូរស្រោចស្រពមកលើដីស្រែចំការរបស់យើង គឺព្រៃព្រឹក្សាលតាវល្លិ ដ៏មានពណ៌ខៀវស្រងាត់ ផ្ដល់នូវម្លប់ដ៏ត្រជាក់ត្រជុំ ត្រឈឹងត្រឈៃដល់យើង និងព្រះធរណី ដ៏មានជីជាតិ លាតសន្ធឹងយ៉ាងវែងអន្លាយ ក្រោមជំហានជើងដែលយើងកំពុងត្រាច់ចរយាត្រាទៅនេះ ។

ពេលណា មាតុភូមិមានទុក្ខវេទនាដោយខ្មាំងសត្រូវចូលមកយាយី រុករានទន្ទ្រាន ពេលនោះ គឺអ្នកនេះហើយជាអ្នកការពារ ។ ជាពលរដ្ឋល្អ, អ្នកត្រូវមានករណីយកិច្ច និងកាតព្វកិច្ចចំពោះប្រទេសជាតិមាតុភូមិ ជាដរាប ។

ត្រូវស្រឡាញ់ ត្រូវហ៊ានលះបង់ជីវិតដើម្បីមាតុភូមិ !

ជនជាតិអ៊ីស្រាអែល ជាគំរូដ៏ប្រសើរនៃវីរភាព សាមគ្គីភាព និងពលិកម្មក្នុងការស្រឡាញ់ជាតិមាតុភូមិ ទោះបីគេឃ្លាតចាកមាតុភូមិ ទៅរស់នៅប្រទេស

ផ្សេងច្រើនតំណក្តី ដោយសារសង្គ្រាម តែពេលណាប្រទេសជាតិមាតុភូមិ ត្រូវការគេភ្លាម គេស្ម័គ្រចិត្តមកបំរើទាំងញញឹម ដោយលះបង់ប្រាក់កាស ប្រាជ្ញា ស្មារតី គ្រប់មធ្យោបាយ រហូតដល់អាយុជីវិត ព្រោះគេយល់ច្បាស់ថា បើប្រទេសសាបសូន្យ ជាតិរលាយ ខ្លួនគេរស់នៅ ក៏គ្មានន័យដែរ ។

លោកអតីតប្រធានាធិបតី ចន កេណ្ណឌី (John Kennedy) នៃសហរដ្ឋអាមេរិក បានមានប្រសាសន៍ថា ៖ « *ចូរអ្នកកុំសួរខ្ញុំ ថាតើប្រទេសជាតិមាតុភូមិបានធ្វើអ្វីខ្លះដល់ខ្ញុំ ?* » តែចូរសួរថា ៖ « *តើខ្លួនខ្ញុំផ្ទាល់បានធ្វើអ្វីខ្លះហើយ ជូនប្រទេសជាតិមាតុភូមិខ្ញុំ ?* » ។

---

សេចក្តីទុក្ខរបស់ប្រជារាស្ត្រ គឺ ៖

*១. តម្លាន* ជារោគដ៏កាចសាហាវ,

*២. សេចក្តីក្រ* ជាទុក្ខនៅក្នុងសង្គម ,

*៣. ការជំពាក់បំណុល* ជាទុក្ខរបស់សង្គម ,

*៤. ការរស់នៅ* ជាទុក្ខធំជាងគេ ។

# ចន្ទទឹកឃ្មុំ
## ( Honey Moon )

ស្រាវជ្រាវ និងរៀបរៀងដោយ

**ហៀន ចណ្ណារ័ក្ខ**

ប្រជាជននៃលោកខាងលិច តែងស្គាល់ពាក្យនេះដោយពិស្តារ ។ ស័ព្ទនេះសំដៅយកឱកាសមួយ ដែលគូស្វាមីភរិយាទាំងពីរនាក់ ទើបរៀបអាពាហ៍ពិពាហ៍ថ្មោងថ្មី ធ្វើដំណើរទៅកាន់ទីឆ្ងាយពីភូមិឋានលំនៅដែលខ្លួននៅ ដើម្បីមើលទេសភាពនាមាត់សមុទ្រ ក្រោយមេឃាដ៏មានពណ៌ខៀវខ្ចី ទស្សនាឆ្នេរទន្លេដ៏ស្រស់បំព្រងកំពង់ផែ និវេសនដ្ឋាន ប្រាង្គប្រាសាទបុរាណ អច្ឆរិយវត្ថុ ។ ល ។ និង ។ ល ។ ហើយក្រេបជញ្ជក់នូវរសជាតិស្នេហារបស់គេ ផ្អែមត្រជាក់ ក្លិនប្រហើរ ក្រអូបសាយ ជាពិសេសទៅទៀតគឺ ទឹកឃ្មុំដែលច្បុតមកពីស្ថានព្រះចន្ទ មិនមែនទឹកឃ្មុំនាស្ថានមនុស្សលោកយើងនេះទេ ។ គេគិតថា ចន្ទទឹកឃ្មុំដែលគេកំពុងភ្លក្សរសជាតិនេះគ្មានថ្ងៃណាបញ្ចប់ឡើយ ។

គេចាប់ផ្ដើមកសាងអនុស្សាវរីយ៍មួយថ្មីស្រឡាង ដែលគេនឹងចងចាំក្នុងក្រអៅបេះដូងនៃគេទាំងពីរនាក់ ជាមួយនឹងវាចាទន់ភ្លន់ ផ្អែមល្ហែម ល្អកល្អើន ។ ពេលនេះ នាលោកនេះ គេភ្លេចស្ងួន្យឈឹងនូវអ្វីៗទាំងអស់ ..... ។

តើរឿងនេះ មានប្រវត្តិយ៉ាងណាទៅដែរ ?

នៅកប់ក្នុងបាតព្រះវិហារបាក់បែកមួយកន្លែង នៃប្រទេសអេស្ប៉ាញ (Espagne ) គេបានជីករកឃើញក្នុង ឆ្នាំ ១៨២៣ ពិន្ទុងពីរបិទជិតឈើងដែលពេញ

ទៅដោយទឹកឃ្មុំដ៏បរិសុទ្ធ មានរសជាតិផ្អែមឆ្ងាញ់ ដូចទឹកឃ្មុំថ្មោងថ្មី ។ គេបានស្រាវជ្រាវទៅទៀតឃើញថា ព្រះវិហារនេះបានសាងឡើងក្នុងសតវត្សទី ២ នៃគ្រឹស្តសករាជ ។

ចំណាស់នៃទឹកឃ្មុំនេះ មានអាយុ ១៦០០ ឆ្នាំមកហើយ តែរក្សានូវរសជាតិ និងគុណភាពដដែលគ្មានផ្លាស់ប្តូរ ។

តាមទម្លាប់នៃជនជាតិអ៊ីរ៉ុបខ្លះ នាថ្ងៃអាពាហ៍ពិពាហ៍ គេឱ្យកូនកម្លោះបីកូនក្រមុំឆ្លងកាត់មាត់ទ្វារចូលទៅកាន់បន្ទប់ផ្សំដំណេក ដែលគេយកទឹកឃ្មុំទៅប្រោះព្រំលើក្តារក្រាលផ្លូវចូល ។ គេជឿថាធ្វើបែបនេះ នាំមកនូវជោគជ័យ សេចក្តីសុខសាន្ត អាយុយឺនយូរ ព្រមទាំងសុភមង្គលគ្រប់ប្រការដល់កូនកម្លោះក្រមុំ តាមសេចក្តីប្រាថ្នារបស់គេរៀងៗខ្លួន ។ នេះហើយឬ ចន្ទទឹកឃ្មុំ ។

# ម្រនិចចំណាំផ្លូវឈើ

## (សំរាប់រដូវទាំងបី)

ឈ្មោះ និងចំនួនខែ ក្នុងរដូវនីមួយៗ

| ចន្ទគតិ [(១)] | សុរិយគតិ |
|---|---|
| - ហិមៈ (៤ខែ) អស្សុជ . កត្តិក . មិគសិរ . បុស្ស | តុលា . វិច្ឆិកា . ធ្នូ . មករា |
| - គិម្ហៈ (៤ខែ) មាឃ ផល្គុន . ចេត្រ . ពិសាខ | កុម្ភៈ . មីនា . មេសា . ឧសភា |
| - វស្សៈ (៤ខែ) ជេស្ឋ . អាសាឍ . ស្រាពណ៍ . ភទ្របទ | មិថុនា . កក្កដា . សីហា . កញ្ញា ។ |

## ១. អំពីរដូវ

រដូវស្រុកខ្មែរលោកកំណត់ ចែងជាក់ប្រាកដថាមាន ៣ [(១)]
* ទី១ ហិមៈត្រជាក់ដី ខ្យល់បក់ប៉ឺៗ សន្សើមធ្លាក់ ។
ជំនោររអឹក កត្តិកដល់ ត្រីស្រូវហុចផលជាពំនាក់
ប្របាក អំបុក សំប៉ូរជាក់ នេះជាលក្ខណៈហិមមន្ត ។
* ទី២ គិម្ហៈធ្លាក់កំដៅ ភាយៗ ខ្លោចស្មៅលតាវ័ន
ស្លឹកឈើរុះរោយរាយគរខ្ពាន់ វ៉ៃយំរោទ៍លាន់រំពងភ្នំ ។
ត្រពាំងបឹងបួហួររហ័ស ហួតហែងរីងខះងាប់ខ្យងត្រី

---

(១) ខែជាសុរិយគតិ ត្រូវបានខែជាចន្ទគតិ ពី ១ សប្តាហ៍ ដល់ ២០ ថ្ងៃ ក៏សឹងមាន ។ សូម ពិនិត្យមើលតាមប្រតិទិន ។

(២) ក្នុងសៀវភៅភូមិសាស្ត្រថ្មី ចែងថា រដូវស្រុកខ្មែរមានតែពីរ : រដូវក្តៅ និងរដូវភ្លៀង ។

អាកាសគិម្ហៈឡើងក្ដៅធំ ក្ដួតភ្លើងឆេះភ្នំឆេះឈើព្រៃ ។
* ទី៣ វស្សន្តរដូវភ្លៀង កង្កែបស្រែកច្រៀងប្រកាសន័យ
ឱ្យកសិករគិតលកលៃ នង្គ័លឈើព្រៃត្រៀមភ្ជួររាស់ ។
រវាំងមើលភ្លឺដាច់រលុប លើកប៉ះតទប់កុំឱ្យទាស់
ត្រួសសំអាតព្រៃដែលល្វតលាស់ គរដុតទាំងអស់ប្រោះជាជី ។
ក្នុង ១ រដូវមាន ៤ ខែ ទំនៀមស្រុកខ្មែរប្រសិទ្ធី
សម្របទិដ្ឋភាពព្រះធរណី អាកាសហុចទីដាច់ពីគ្នា ។
លំហើយកំដៅនិងធ្លាក់ភ្លៀង កើតមានទាត់ទៀងរៀងគ្រប់គ្រា
ប្លែកដាច់ស្រឡះតាមវេលា ទើបប្រាជ្ញព្រឹទ្ធាកំណត់ចែង ។
ស្របតាមរដូវទាំងបីជាក់ ភោគផលគ្រប់ថ្នាក់គ្រប់កន្លែង
ជាម្ហូរបង្អែមកើតជាក់ស្ដែង ដាំដុះតាក់តែងជាចំណី ។
ប្រជាខ្មែរយើងគ្រប់តំបន់ មានផលគ្រប់គ្រាន់សម្រាប់អី
ទាំងម្ហូរផ្លែឈើជាចំណី រដូវទាំងបីជាធម្មតា ។

## ២- អំពីម្ហូរ

* ហិមៈរដូវត្រូវប្រើជួរ នូវអស់គ្រឿងម្ហូរចុងវស្សា
អ្នកស្រុកនិយមផ្សំអាហារ សណ្ដាន់ក្រូចឆ្មារជាប្រក្រតី ។
ស្លម្ហូរញាំភ្លាទឹកជ្រលក់ ឬក៏ស្ងោរជ្រក់យោងគ្រឿងអី
បង្កកម្លាយម្ហូបចំណី ឱ្យកើតរសថ្មីឆ្ងាញ់ពីសា ។
* គិម្ហៈរដូវត្រូវសុំប្ដូរ ម្ហូរពេញពោរតាមត្រូវការ
អំពិលក្រសាំងទុំត្រៀបត្រា ទាំងស្វាយខ្ចីណាសុទ្ធជូរស្រស់ ។
សម្លបន្លែសម្លសាច់ មានជាតិមិនដាច់ឆើតបង្អស់

ដោយចេះប្រើម្ទេសនិងរបស់ ទើបបានឆ្ងាញ់ស្រស់ជាលំនឹង ។
* វស្សន្តរដូវត្រូវក្រដែរ គ្រឿងម្ទេសស្រុកខ្មែរស្ទើរដាច់ឈឹង
គេប្រើតែម្ទេសទ្រលឹងទឹង សណ្តាន់ក្រៀមរីងហាលត្រៀមទុក ។
គេបែរមកប្រើអស់ម្ទេសស្លឹក ដូចជាម្ទេសព្រឹក (១) បាន ១ មុខ
ស្លឹកថ្មីងទ្រមូងបុកគ្រលុក ត្រងយកទឹកទុកធ្វើគ្រឿងស្ល ។
ពុំនោះបុកម៉ដ្ឋធ្វើបន្លែ ក៏បានម្យ៉ាងដែរនៅពេលក្រ
ជាម្ទេសបន្លែគ្រឿងសម្ល ជូរឆ្ងាញ់ជ្រះកសម្លសាច់ ។
សាច់ឈ្លូសប្រើសក្តាន់ឬទន្សាយ ជាប់មាត់ភ្លេចបាយស្រស់បណ្តាច់
អស់ម្ទេសពួកស្លឹកជួបនឹងសាច់ ជាគ្រឿងចាំបាច់សម្លខ្មែរ ។
មុខម្ទេសស្រុកយើងរដូវបី មានពេញលើដីចំការស្រែ
ជាម្ទេសសម្រាប់អាហារខ្មែរ សង្ខេបខ្លីតែប៉ុណ្ណោះឯង ។

## ៣- ចំណីផ្លែឈើ

* ហិមៈរដូវត្រូវបានឱ ផ្លែឈើថ្មីៗ នៅរៀងរាយ
អំបុកដូងខ្ចីឱសប្បាយ ទឹកត្នោតផ្អែមសាយគ្រាវដីឡូង ។
កត្តិកអុំទូកអកអំបុក ផ្លែឈើច្រើនមុខដល់ថ្មីថ្មោង
ចេកល្ហុងនិងមៀនទុំរយោង កើតឡើងព្រាតព្រោងតាមត្រូវការ ។
* គិម្ហៈរដូវនៅរីតច្រើន ផលាកើតកើនច្រើនត្រៀបត្រា
ឪឡឹកម្នាស់ទុំពេញចំការ ខ្នុរណាំងបាយស្រាស្វាយហុចផល ។
សេដាមង្ឃុតល្មុតធូរេន មាក់ប្រាងគូលេនព្រីងក៏ដល់

(១) វុក្ខជាតិនេះ មានជាតិជូរតែពេលព្រឹក ទើបគេហៅថា ម្ទេសព្រឹក

ទុំទាន់តែគ្នាច្រើនកកកុល់ នេះហើយជាផលរដូវប្រាំង ។
* វស្សន្តភ្លៀងជន់លិចភូមិស្ថាន ផ្លែឈើខ្លះបាននៅសម្រាំង
សាវម៉ាវសិរមាន់ទុំប្រណាំង គុយត្រៀលក៏តាំងមានមុខដែរ ។
ក្រឡាញ់សង្ស័របន្តទុំ ជាឈើព្រៃភ្នំតាមវាលស្រែ
ចេញផលផ្តល់មកជាហូរហែ សម្រាប់យើងខ្មែរបរិភោគា ។
ផលខ្លះកើតមកពីការដាំ នៅរៀងរាល់ឆ្នាំប្រាំងវស្សា
តែផលខ្លះទៀតក្រៅចំការ ជាផលព្រឹក្សាព្រៃបពិត ។
អស់មួយដល់មួយមិនព្រួយគិត បានលៀងជីវិតជាទៀងទាត់
គ្រាន់ជាគ្រឿងផ្សំកំដរមាត់ ត្រូវតាមកំណត់រដូវបី ។
ជាការបង្កើនច្រើនថែមទៀត គួរយើងឆ្លាស់ឆ្លៀតដោយឃ្នាតខ្មី
ប្រញ៉ាប់ប្រញ៉ាល់ដៃទាំងប្រុសស្រី ពង្រីកផលថ្មីឱ្យកើនទ្វេ ។
កសិកម្មជាត្រើយជីវិតខ្មែរ ដីចំការស្រែក្បែរទន្លេ
ប្រយុទ្ធយកផលកុំទំនេរ សេដ្ឋកិច្ចជាមេជីវិតថ្កើង ។

ដោយ **គង់ ខេង**

# សេចក្ដីជូនដំណឹង

## អំពីលទ្ធផលនៃចម្លើយ " កំណាព្យប្រស្នា"

## ដែលបានចុះក្នុងទស្សនាវដ្ដីកម្ពុជសុរិយា លេខ ៤ ឆ្នាំ ១៩៩៥

គណៈកម្មការនិពន្ធ នៃទស្សនាវដ្ដីកម្ពុជសុរិយា មានកិត្តិយសសូមប្រគេន និងជូនដំណឹងចំពោះព្រះតេជព្រះគុណ និងចំពោះអស់លោក អ្នក នាងកញ្ញា ព្រមទាំងមិត្តអ្នកអានជាទីគោរពថា គណៈកម្មការបានទទួលលិខិតជាច្រើនដែលបានរួមចំណែកដល់ការឆ្លើយប្រស្នា ។ នៅក្នុងចំណោមលិខិតទាំងនោះ មានលិខិតចំនួន ៥៧ បានឆ្លើយត្រូវដូចគ្នា ទាំងមានសម្នួសកាព្យល្អប្រហាក់ប្រហែលគ្នា ។ គណៈកម្មការបានសំរេចជូនរង្វាន់ដល់អ្នកឆ្លើយត្រូវទាំងអស់ ដោយធ្វើការជ្រើសរើស និងរៀបចំណាត់ថ្នាក់ ជាបីរង្វាន់ គឺ :

*ក / រង្វាន់ពិសេស* ត្រូវបានប្រាក់ ចំនួន ១០.០០០ ៛ ០០ ត្រូវប្រគល់ជូនទៅលោក តឹក ប៊ុនឈៀង និស្សិតមហាវិទ្យាល័យវេជ្ជសាស្ត្រ ឱសថសាស្ត្រ និងទន្តសាស្ត្រ ។

*ខ/ រង្វាន់លេខ ១* ត្រូវបានប្រាក់ចំនួន ៦.០០០ ៛ ០០ មាន ១៨ រង្វាន់ ត្រូវប្រគល់ជូនទៅជយលាភី ដូចខាងក្រោម :

១. លោក ជា សុភឿន គរុនិស្សិតនៃមហាវិទ្យាល័យគរុកោសល្យ ផ្នែកភូមិវិទ្យា ។

២. លោក យ៉ៃ វិបុល និស្សិតមហាវិទ្យាល័យអក្សរសាស្ត្រ ឆ្នាំទី ១ ។

៣. ភិក្ខុ ខឹម ម៉ី វត្តមហារាជដ្ឋាន ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្ដាល ។

៤. លោក គិត វណ្ណី គរុនិស្សិតនៃមហាវិទ្យាល័យគរុកោសល្យ ផ្នែកអក្សរសាស្ត្រ មនុស្សសាស្ត្រ ។

៥. លោក យ៉ង គិមស៊ាន គរុនិស្សិតនៃមហាវិទ្យាល័យគរុកោសល្យ ផ្នែកអក្សរសាស្ត្រ ។

៦. លោក ប៊ូ ចេន គរុនិស្សិតនៃមហាវិទ្យាល័យគរុកោសល្យ ។

៧. លោក ជួប ហ៊ីង គរុនិស្សិតនៃមហាវិទ្យាល័យគរុកោសល្យ ។

៨. ភិក្ខុ ខឹម រតនា សមណសិស្សនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត នៅវត្តឧណ្ណាលោម កុដិលេខ ១១ ។

៩. លោក សុង សៀង និស្សិតមហាវិទ្យាល័យអក្សរសាស្ត្រ ឆ្នាំទី ១ សកលវិទ្យាល័យ ភ្នំពេញ ។

១០. លោក មាឃ បូរ៉ា គរុនិស្សិតនៃមហាវិទ្យាល័យគរុកោសល្យ ។

១១. លោក ជួន សោរិទ្ធី គរុនិស្សិតនៃមហាវិទ្យាល័យគរុកោសល្យ ។

១២. លោក ប៊ូ សន គរុនិស្សិតនៃមហាវិទ្យាល័យគរុកោសល្យ ។

១៣. លោក ញឹម សេង និស្សិតសកលវិទ្យាល័យ ភ្នំពេញ ផ្នែកអក្សរសាស្ត្រ មនុស្សសាស្ត្រ ។

១៤. ភិក្ខុ សេង ចន្ទ្រា ( ឧប្បលត្ថេរ ) នៅវត្តស្លា ឃុំកំពង់ឫស្សី ស្រុកពារាំង ខេត្តព្រៃវែង ។

១៥. លោក ប៊ួយ វុទ្ធី គរុនិស្សិតនៃមហាវិទ្យាល័យគរុកោសល្យ ផ្នែកអកសរសាស្ត្រខ្មែរ ។

១៦. លោក ជាង យុនឡា គរុនិស្សិតនៃមហាវិទ្យាល័យគរុកោសល្យ ផ្នែកភូមិវិទ្យា ។

១៧. លោក នៀ សារ៉ាន់ថា គរុនិស្សិតនៃមហាវិទ្យាល័យគរុកោសល្យ

ផ្នែកអក្សរសាស្ត្រខ្មែរ ។

១៨. រិន ចន្ទ ( មិនប្រាប់ភេទ មុខរបរ និងទីកន្លែង ) ។

*គ / រង្វាន់លេខ ២* ត្រូវបានប្រាក់ចំនួន ៤.០០០ ៛ ០០ មាន ៣៨ រង្វាន់ ត្រូវប្រគល់ជូនទៅជ័យលាភី ដូចខាងក្រោម ៖

១. លោក ហេង ដេត និស្សិតមហាវិទ្យាល័យ អក្សរសាស្ត្រ មនុស្សសាស្ត្រ ឆ្នាំទី ១ នៃសកលវិទ្យាល័យ ភ្នំពេញ ។

២. លោក ហេង ប៊ុនវ៉ា និស្សិតសកលវិទ្យាល័យ ភ្នំពេញ ផ្នែកគណិតវិទ្យា ឆ្នាំទី ៣ ស្នាក់នៅវត្តបទុមវតី ។

៣. ភិក្ខុ សៀង សុជិត សមណសិស្សនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ឆ្នាំទី ២, គង់នៅវត្តបទុមវតី ។

៤. សាមណេរ ភោន វាសនា សមណសិស្សនៃពុទ្ធិកបឋមសិក្សា វត្តបទុមវតី ។

៥. សឹង វុទ្ធិវិទ្ធ ( មិនប្រាប់ភេទ មុខរបរ និងទីកន្លែង ) ។

៦. សាមណេរ ធូ ទីន សមណសិស្សនៃពុទ្ធិកបឋមសិក្សា វត្តឧណ្ណាលោម ភ្នំពេញ ។

៧. ភិក្ខុ ឡុង នី កុដិលេខ ៣, វត្តឧណ្ណាលោម ភ្នំពេញ ។

៨. ភិក្ខុ អាង ជាតិឡោច សមណសិស្សនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ឆ្នាំទី ៣, វត្តឧណ្ណាលោម ភ្នំពេញ ។

៩. សាមណេរ ជួន ប៉ាន សមណសិស្សនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ឆ្នាំទី ៣, កុដិលេខ ៣ វត្តឧណ្ណាលោម ។

១០. ភិក្ខុ សេង រដ្ឋា នៅវត្តបទុមវតី, ភ្នំពេញ ។

១១. ភិក្ខុ ឈោត រ៉ង សមណសិស្សនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ភ្នំពេញ ឆ្នាំទី ១ ។

១២. ភិក្ខុ សេង សុមុនី ( បទុមវត្សា ) សមណសិស្សនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត, កុដិលេខ ១, វត្តឧណ្ណាលោម ភ្នំពេញ ។

១៣. ភិក្ខុ ហោ ណាំហុង សមណសិស្សនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ឆ្នាំទី ៤, វត្តឧណ្ណាលោម ភ្នំពេញ ។

១៤. ភិក្ខុ គង់ ង៉ែត សមណសិស្សនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ភ្នំពេញ ឆ្នាំទី ២, វត្តឧណ្ណាលោម ។

១៥. ភិក្ខុ អោម សុផុន សមណសិស្សនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ភ្នំពេញ ឆ្នាំទី ៤, នៅវត្តបទុមវតី ។

១៦. ភិក្ខុ ដុល សម្បត្តិ សមណសិស្សនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ភ្នំពេញ ឆ្នាំទី ៤, នៅវត្តនាគវ័ន ។

១៧. ភិក្ខុ ស៊ុម វាសនា សមណសិស្សនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ភ្នំពេញ, នៅវត្តសំពៅមាស ។

១៨. ភិក្ខុ សុខ កយ សមណសិស្សនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត, នៅវត្តឧណ្ណាលោម ភ្នំពេញ ។

១៩. លោក ណុប កងរាជអាវុធហត្ថ ( P.M ) នៅតាកែវក្រុង ។

២០. លោក ឡាក់ សាម៉ុន សាស្ត្រាចារ្យ អនុវិទ្យាល័យព្រៃទប់ ខេត្តតាកែវ ។

២១. ភិក្ខុ នេត្រ ពារា សមណសិស្សនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ឆ្នាំទី ៤, វត្តឧណ្ណាលោម ភ្នំពេញ ។

២២. ភិក្ខុ ឡាក់ សុភ័ក្រ្ត សមណសិស្សនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត,

ឆ្នាំទី ៤, វត្តឧណ្ណាលោម ភ្នំពេញ ។

២៣. លោក សេង គៀន គ្រូបង្រៀន នៅភូមិព្រៃមាស ឃុំកំពង់ឫស្សី ស្រុកពារាំង ខេត្តព្រៃវែង ។

២៤. ភិក្ខុ គីម សុហេង នៅកុដិលេខ ១១, វត្តឧណ្ណាលោម ភ្នំពេញ ។

២៥. .............. ( អត់ប្រាប់ឈ្មោះ មុខរបរ ទីកន្លែង ) ។

២៦. ភិក្ខុ ងឹម ហឿន នៅវត្តនាគវ័ន, ភ្នំពេញ ។

២៧. ភិក្ខុ ម៉ែន ចាន់ នៅវត្តឧណ្ណាលោម, ភ្នំពេញ ។

២៨. ភិក្ខុ រ័ត្ន វ៉ៃ សមណសិស្សនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ឆ្នាំទី ៤ នៅវត្តឧណ្ណាលោម, ភ្នំពេញ ។

២៩. ភិក្ខុ នូ សុភាព សមណសិស្សនៃពុទ្ធិកបឋមសិក្សា វត្តឧណ្ណាលោម កុដិលេខ ១១, ភ្នំពេញ ។

៣០. ភិក្ខុ ឈុន រ័ត្ន សមណសិស្សនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត, កុដិលេខ ១១ វត្តឧណ្ណាលោម ។

៣១. លោក ចាន់ ធី គរុនិស្សិត មហាវិទ្យាល័យគរុកោសល្យ ។

៣២. លោក ឈឹម ផាន់ណា គរុនិស្សិតមហាវិទ្យាល័យគរុកោសល្យ ។

៣៣. ភិក្ខុ ញៀម ចាន់ដារ៉ា សមណសិស្សនៃពុទ្ធិកវិទ្យាល័យព្រះសុរា-ម្រឹត ឆ្នាំទី ៤, នៅវត្តឧណ្ណាលោម ភ្នំពេញ ។

៣៤. ភិក្ខុ ស៊ុន សុផន សមណសិស្សនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត, នៅវត្តឧណ្ណាលោម, ភ្នំពេញ ។

៣៥. លោក អ៊ិន សុឃន់ នៅភូមិអណ្តូងស្រែន ឃុំច្រេស ស្រុកមេសាង ខេត្តព្រៃវែង ។

៣៦. ភិក្ខុ ឈឹម វាសនា នៅវត្តបទុវតី, ភ្នំពេញ ។

៣៧- លោក ខាន់ រដ្ឋា បុគ្គលិកការិយាល័យសរុប នៃទីស្តីការរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

៣៨- អ្នកស្រី សេង សុវត្ថា អនុប្រធានការិយាល័យបណ្ណាល័យ និង ពតិមាន, អគ្គលេខាធិការដ្ឋានរដ្ឋសភា ។

គណៈកម្មការនិពន្ធ សូមនិមន្ត និងអញ្ជើញជ័យលាភីទាំងប៉ុន្មាន ដូចរាយ ព្រះនាម និងនាមខាងលើទៅបើករង្វាន់នៅផ្នែកទស្សនាវដ្ដី នៃពុទ្ធសាសនបណ្ឌិត្យ ដែលមានទីស្នាក់ការបណ្ដោះអាសន្ន នៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ នៅរាល់ ម៉ោងធ្វើការ ។

ទន្ទឹមនឹងនេះដែរ គណៈកម្មការ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះឯកឧត្តម វណ្ណ ស៊ុនហេង អ្នកតំណាងរាស្ត្រមណ្ឌលព្រៃវែង ដែលបានបរិច្ចាគ ថវិកាផ្ទាល់ខ្លួន សំរាប់ឧបត្ថម្ភចំពោះជ័យលាភីទាំងអស់ ដែលបានឆ្លើយត្រូវប្រស្នា លើកនេះ ។

កម្ពុជសុរិយា

# ចំម្លើយកំណាព្យប្រស្នា

គណៈកម្មការនិពន្ធ មានកិត្តិយសនឹងចុះផ្សាយអត្ថបទរបស់និស្សិត តឹក ប៊ុនឈឿង ដែលបានទទួលចំណាត់ថ្នាក់ « ក » ជាជំនួសចម្លើយរបស់ម្ចាស់សំណួរ ដែលមានសេចក្ដីដូចខាងក្រោម :

ចម្លើយកំណាព្យប្រស្នា ក្នុងកម្ពុជសុរិយា លេខ ៤ ឆ្នាំ ១៩៩៥

( បទពាក្យប្រាំពីរ )

១. ខ្ញុំលើកហត្ថឱនសិរសី បង្គំគុណបីថ្លៃបវរ
ព្រះពុទ្ធព្រះធម៌ព្រះសង្ឃល្អ មានច្រើនតំណពីដូនតា ។
២. តាំងតែពីលោកអ្នកមានគុណ ធំហើយសែនធ្ងន់លើលោកា
ជាម្លប់ត្រជាក់លើគ្រួសារ មាតាបិតាទាំងពីរប្រាណ ។
៣. ព្រមទាំងលោកគ្រូនិងអ្នកគ្រូ ដែលជាគំរូនាំដើមដាន
រៀនលេខអក្ខរៈតាមលំអាន តាមចាស់បូរាណព្យបានចារទុក ។
៤. ឱ្យរៀនសព្វសាស្ត្រមិនថាអ្វី បែបបទប្លែកថ្មីរាយទំនុក
ស្លូត្រស្ដាប់កំសាន្តកែអផ្សុក ផ្ដល់នូវក្ដីសុខគ្រប់អាត្មា ។
៥. ខ្ញុំសូមវន្ទាប៉ុណ្ណឹងចុះ ញាតិញោមស្រីប្រុសលោកយាយតា
ឥឡូវរៀបរាប់ជាប់អក្ខរា ទោះខុសម្ដេចម្ដាសូមខន្តី ។
៦. បរិយាយលេខនេះដោយសំណួរ លើកយកមកសួរជនប្រុសស្រី
ខ្ញុំរេរិះគិតលលកលៃ លេងជាសំដីតាមប្រស្នា ។
៧. សំណួរនោះថ្លែងចែងសេចក្ដី ពីតាឥសីលោកថ្លែងសារ
ផ្ញើទៅស្រីម្នាក់ដោយលាក់ការណ៍ មិនឱ្យនរណាមើលយល់បាន ។

៨. ជូនខ្ញុំប្រទះសារសម្ងាត់ មើលកាត់ខ្លឹមសារថាស្មាន១
ក្រែងមិនប្រាកដញ្ញាតិសន្តាន ព្រោះអីខ្ញុំអានតាមយល់ដឹង ។

៩. " *(៣) ធំរងេមីធរលងលីភ្នំកែ (១០) ទឹកសាលលមមីលោរករយ*
*(១០) ដីទ្នៃលះអមីដុងដើរយ (៤) សេចមេឆ្ងាឆ្ងាមីយយយលខ្ពដូស្រី* " ។

១០. មុខឃ្លាទីមួយមានលេខ៣ ខ្ញុំលែបន្ថែមហើយសំរេច
រួចរាប់បី១យូរបន្តិច បាក់លេចខ្លឹមសារអាចនឹងយល់ ។

១១. នៅឃ្លាទី ពីរ ទីបី-បួន រាប់តាមចុងជួនដោយខំប្រឹង
ផ្លាស់ប្តូរកន្លែងឱ្យលំនឹង សារជាដំណឹងមិនវែងឆ្ងាយ ។

១២. « *មើលភ្នំធំធេងវែងរលីក មើលទឹករលករលាមសាយ*
*មើលដីដីដុះវែងអន្លាយ មើលមេឃខ្ពស់ឆ្ងាយដូចឆ្ងាយស្រី* » ។

១៣. សារនេះឥសីបានផ្ចិតផ្ចង់ បំណងថ្លែងស័ព្ទសារសេចក្តី
ពីទុក្ខក្រៀមក្រំព្រាត់ប្រាសស្រី ដូចព្រាត់ផែនដីខាន់រស់នៅ ។

១៤. ទោះភ្នំសែនធំស្ទើរបែកផ្សេង ទោះបីវាលវែងទឹកសែនជ្រៅ
សម្លឹងមេឃខ្ពស់ហួសនឹងទៅ គង់នៅទាបជាងការព្រាត់ប្រាស ។

១៥. ឱសេកសារិកាអ្នកជាសត្វ នៅពេលអ្នកព្រាត់ទុក្ខខ្លាំងណាស់
ទុក្ខជំងឺ១ថែមលើចាស់ រហ័សស្លាប់ទៅនៅធ្វើអ្វី ។

១៦. នេះឃុតក្នុងរឿង " សេកសារិកា " បូរាណបានចារលេងសំដី
ជូនជនរួមជាតិខ្មែរប្រុសស្រី ដឹងហើយលកលែរកហេតុផល ។

១៧. នេះហើយជាកម្មនាំឱ្យសត្វ តែងតែខ្វាត់ព្រាត់តែងអំពល់
កើតចាស់ឈឺស្លាប់រសិលវល់ ថ្ងៃណានឹងដល់ត្រើយនិព្វាន ។

១៨. ខ្ញុំសូមអធិប្បាយប៉ុណ្ណឹងចុះ សូមញាតិស្រីប្រុសសន្តោសប្រាណ
សូមជូនពរជាបរិយោសាន សូមថ្វាយសីលទានខ្ញុំបានធ្វើ ។

១៩. ដល់ព្រះបិតាព្រះជាយា ញាតិមិត្តមីងមាសពូអន្ទើ
សូមឆ្លងផុតទុក្ខសុខប្រសើរ គ្មានសុខអ្វីស្មើជាងក្តីស្ងប់ ។
២០. សូមសន្តិភាពគ្រប់អាត្មា ទើបជាតិប្រជាលោកពិភព
សឹងសន្តិភាពសុខសាយសព្វ លែងឈ្លោះទាស់ស្អប់កាប់ចាក់គ្នា ។
២១. ឱ្យខ្មែរសាមគ្គីរួបរួមជាតិ កុំតាំងវិវាទចងវេរា
កើតគិតគុំឈ្លោះគ្រោះភយា ខ្មាំងឆ្លៀតស្រវាយកទឹកដី ។
២២. ឱ្យទឹកដីខ្មែរឋិតថេរនៅ ស្ងួតហួតដំបៅយូររុំរ៉ៃ
សូមរោគទុរភីក្សទុក្ខភិតភ័យ សង្គ្រាមចង្រៃបាត់ទៅឆ្ងាយ ។
២៣. សូមមេឃទឹកភ្លៀងទៀងរដូវ ដំណាំស្រែស្រូវដុះស្គុសស្គាយ
សូមសន្តិភាពសុខសប្បាយ កើតសព្វសុះសាយក្នុងខេមរា ។

ដោយ **គីក ប៊ុនឈឿង**
និស្សិតមហាវិទ្យាល័យ វេជ្ជសាស្ត្រ ឱសថសាស្ត្រ និងទន្តសាស្ត្រ
សព្វថ្ងៃស្នាក់នៅ វត្តមហាមន្ត្រី កុដិលេខ ១០ សង្កាត់អូឡាំពិក
ខណ្ឌចំការមន រាជធានីភ្នំពេញ

# ទង់ព្រះពុទ្ធសាសនា

តាំងពីព្រះសម្ពុទ្ធបរមគ្រូទ្រង់បរិនិព្វានទៅ ពុំទាន់មានពុទ្ធសាសនិកប្រទេសណាមួយ បានផ្ដើមបង្កើតទង់ពុទ្ធសាសនាអោយមានរូបរាងឡើងជាពិតប្រាកដ ដូចក្នុងប្រពៃណីឯទៀតៗ នៅឡើយ ។

លុះដល់ថ្ងៃអង្គារ ៦ រោច ខែជេស្ឋ ឆ្នាំខាល ទោស័ក ព.ស ២៤៩៤ ត្រូវនឹងថ្ងៃទី ៦ ខែមិថុនា គ.ស ១៩៥០ ទើបពុទ្ធិកប្រទេសទាំង ២៩ មានប្រទេសស្រីលង្កា ជាដើម បានជួបប្រជុំធ្វើសន្និសីទលើកដំបូង នៅទីក្រុងកូឡំបូ ប្រទេសស្រីលង្កា ដើម្បីបង្កើតពុទ្ធិកសមាគមពិភពលោក, ដែលកាលនោះ គណៈប្រតិភូខ្មែរយើង មានសម្ដេចព្រះមហាសុមេធាធិបតី ជួន ណាត ជោតញ្ញាណោ សង្ឃនាយកគណៈមហានិកាយ ជាប្រធាន ទៅរួមប្រជុំផង, បានមូលមតិគ្នាបង្កើតទង់ពុទ្ធសាសនាឡើង ហៅថា " ទង់ពុទ្ធិកសមាគមពិភពលោក ។ " តាមលក្ខន្តិកៈនៃសមាគមនេះដែលមាន ២៧ មាត្រា ត្រង់មាត្រាទី ២៦ ចែងថា : "*ទង់របស់ពុទ្ធិកសមាគមពិភពលោក ជាទង់មានពណ៌ ៦ តម្រូវនឹងឆព្វណ្ណរង្សីរបស់ព្រះសម្ពុទ្ធជាម្ចាស់ ទុកជាមូលដ្ឋាន តាមគំរូដែលក្រុមប្រឹក្សាប្រតិបត្តិបានធ្វើហើយ* " ។ ដូច្នេះ ទង់ពុទ្ធសាសនា ក៏ឧប្បត្តិឡើងជាស្ថាពរ តាំងពីកាលនោះមក ។

ទង់ពុទ្ធសាសនា មាន ៦ ពណ៌នោះ គឺ :

១- ខៀវ, ២- លឿង, ៣- ក្រហម, ៤- ស, ៥- ហង្សបាទ ជម្ពូខ្ចីដូចជើងហង្ស, ៦- ផ្លេក ពន្លឺពេជ្រ ។ ពណ៌ផ្លេកនេះ គឺគេយកពណ៌ទាំងប្រាំខាងដើមមួយៗ មកដាក់បញ្ចូលគ្នាជា ១ ពណ៌ ។

ព្រះបរមលោកនាថ ព្រះអង្គមាន រង្សី ៦ ពណ៌ ផ្សាយចេញពីព្រះវរកាយយ៉ាងនេះ ដោយលទ្ធផលនៃទានបរមត្ថបារមី ដែលព្រះអង្គបានសាងពីអតីតភពយ៉ាង

មហាស្ចារ្យ ហើយដែលមិនអាចអ្នកណាមួយធ្វើដូចព្រះអង្គបាន ។

ឯរស្មីមួយៗ ជាតំណាងព្រះជាតិមួយៗ គឺ :

*១. រស្មីពណ៌ខៀវ* : ជាតំណាងព្រះអង្គ កាលទ្រង់សោយព្រះជាតិជាព្រះបាទស្រីភិវាស្ត្រ ។ កាលនោះ ព្រះឥន្ទ្រាធិរាជបាននិម្មិតខ្លួនជាព្រាហ្មណ៍ចាស់ម្នាក់ចូលមកសូមព្រះនេត្រព្រះអង្គទាំងគូ ព្រះអង្គទ្រង់ឆ្កៀលព្រះនេត្រទាំងពីរអោយទៅឥន្ទព្រាហ្មណ៍ ។

*២. រស្មីពណ៌លឿង* : ជាតំណាងព្រះអង្គ កាលទ្រង់សោយព្រះជាតិជាវិនិបណ្ឌិត ។ កាលនោះ ព្រះឥន្ទ្រាធិរាជបាននិម្មិតខ្លួនជាយក្សធ្វើជាងមាស ។ វិនិបណ្ឌិតបានអារសាច់ខ្លួនអោយជាងមាស ដើម្បីដំផែធ្វើជាមាសបិទព្រះពុទ្ធរូប ។

*៣. រស្មីពណ៌ក្រហម* : ជាតំណាងព្រះអង្គ កាលទ្រង់សោយព្រះជាតិជាបទុមមាណព ។ គ្រានោះ មានពស់មួយប្រកបដោយពិសដ៏ពន្លឹកចឹកមាតាព្រះអង្គ ។ ព្រះអង្គទ្រង់យកកាំបិតមកពុះទ្រូង លូកយកបេះដូងមកផ្សំថ្នាំព្យាបាលមាតាអោយគង់ជីវិត ។

*៤. រស្មីពណ៌ស* : ជាតំណាងព្រះអង្គ កាលទ្រង់សោយព្រះជាតិជាព្រះបាទវេស្សន្តរ ។ កាលនោះ ព្រះអង្គបានប្រទានដំរីមង្គលមួយ ជាសត្វសំរាប់រាជ្យដ៏មានអវៈយវៈសសុទ្ធ ដល់ពួកព្រាហ្មណ៍លិង្គរដ្ឋ ; ពួកអ្នកនគរនាំគ្នាខឹង ហើយបំបរបង់ព្រះអង្គអោយទៅនៅនាវង្កតបពិត ។

*៥. រស្មីពណ៌ហង្សបាទ* : ជាតំណាងព្រះអង្គ កាលទ្រង់សោយព្រះជាតិជាវិជ្ជាធរ ។ មាតាព្រះអង្គត្រូវយក្សចាប់យកបាន ព្រះអង្គទ្រង់អារសាច់អោយយក្សបរិភោគជំនួសជីវិតមាតា ជាវិជ្ជាធរ ។

*៦. រស្មីពណ៌ផ្លេក* : ជាតំណាងព្រះអង្គ កាលទ្រង់សោយព្រះជាតិជាទន្សាយឈ្មោះ សោមបណ្ឌិត ។ ព្រះអង្គមានព្រះតម្លាសទ្ធាចង់បំពេញទាន គ្រានោះ

ព្រះឥន្រ្ទាធិរាជបាននិម្មិតខ្លួនជាព្រាហ្មណ៍ចាស់ម្នាក់អត់អាហារដើរចូលមក ។ ទន្សាយសោមបណ្ឌិត បានលោតចូលក្នុងភ្នក់ភ្លើង ដើម្បីចំអិនសាច់ព្រះអង្គអោយដល់ព្រះឥន្រ្ទព្រាហ្មណ៍បរិភោគ ។

រស្មីទាំង ៦ ពណ៌នេះ បានផ្សាយចេញអំពីព្រះវរកាយនៃព្រះអង្គ ក្នុងពេលត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងពេលសំដែងបាដិហារ្យដើម្បីបំបាត់នូវអស្មិមានះនៃព្រះញាតិរបស់ព្រះអង្គ ដែលសំគាល់ថាព្រះអង្គជាមនុស្សនៅក្មេង មិនគួរគោរព និងក្នុងពេលដែលព្រះអង្គទ្រង់ធ្វើយមកប្បាដិហារ្យផ្ចាញ់ពួកតិរ្ថិយ លើដើមគណ្ឌាមព្រឹក្ស ដើមស្វាយរបស់នាយគណ្ឌៈ ។

ដូច្នេះហើយបានជា ពុទ្ធិកសមាគមពិភពលោក ដែលធ្វើនៅប្រទេសស្រីលង្កាលើកទី ១ នោះ បានផ្តើមធ្វើទង់ពុទ្ធសាសនា មាន ៦ ពណ៌ តម្រូវនឹងឆព្វណ្ណរង្សីរបស់ព្រះសម្ពុទ្ធព្រះបរមគ្រូជាម្ចាស់ ។

- សង្គមជាតិខ្មែរ មានវឌ្ឍនភាពជឿនលឿនទៅមុខបាន អាស្រ័យដោយពុទ្ធសាសនិកមានចំណេះដឹង ( ផ្លូវលោក ផ្លូវធម៌ ) ។

- មុននឹងអោយទេវតាជួយអ្នក ត្រូវអ្នកជួយខ្លួនអ្នកជាមុនសិន ។

- មុននឹងអោយព្រះពុទ្ធជួយអ្នក ត្រូវអ្នកចេះពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាមុនសិន ។

បទុមវតី, ខែមេសា ឆ្នាំ ១៩៩៦

ព្រះធម្មត្រ័យលោកាចារ្យ ពុត សុភ័ក្រ

ចម្លងចាកឯកសារសម្តេចព្រះសង្ឃរាជ ប៊ូរ គ្រី

# ការបែងចែកគម្ពីរព្រះត្រៃបិដក

## (ត)

### ខេត្តព្រៃវែង

ដ) នៅក្នុងខេត្តព្រៃវែង វត្តចំនួន ៩៨ បានទទួល ១ ចប់ ក្នុងមួយវត្ត ត្រូវជា ៩៨ ចប់ ( សេចក្ដីសំរេចលេខ ១៨៧.៩៥ កធស ចុះថ្ងៃទី ១៨.៩.១៩៩៥ ) ដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១ . វត្ត ស្វាយអាត់ | (មេគណ) | ១៦ . វត្ត ចុងក្រូច | |
| ២ . វត្ត ស្វាយប្លុទុម | (អនុគណ) | ១៧ . វត្ត ព្រៃញោជើង | |
| ៣ . វត្ត ស្វាយទង | (អនុគណ) | ១៨ . វត្ត ព្រៃស្លា | |
| ៤ . វត្ត ឃ្លាំង | (អនុគណ) | ១៩ . វត្ត មេសរប្រចាន់ក្រោម | |
| ៥ . វត្ត សិរីសាគរ | (អនុគណ) | ២០ . វត្ត ត្នោត | |
| ៦ . វត្ត ក្រាំងស្វាយ | (អនុគណ) | ២១ . វត្ត មេលប់ | |
| ៧ . វត្ត សំពៅមាស | (អនុគណ) | ២២ . វត្ត ព្រៃដើមថ្នឹងត្បូង | |
| ៨ . វត្ត មហាគង្គារតនារាម | (អនុគណ) | ២៣ . វត្ត អំបែងចេស | |
| ៩ . វត្ត រោងដំរី | (អនុគណ) | ២៤ . វត្ត ផាត់សណ្ដោង | |
| ១០. វត្ត កំពង់ពពិល | (អនុគណ) | ២៥ . វត្ត ព្រៃកចង្ក្រានលើ | |
| ១១. វត្ត ជម្ពូព្រៃ | (អនុគណ) | ២៦ . វត្ត ស្វាយទាប | |
| ១២. វត្ត ប្រស្រែ | (អនុគណ) | ២៧ . វត្ត ខ្នារ | |
| ១៣. វត្ត តាម៉ិញ | (អនុគណ) | ២៨ . វត្ត ចារ | |
| ១៤. វត្ត ស្មាយពល | | ២៩ . វត្ត ព្រៃស្វាយ | |
| ១៥. វត្ត កញ្ចុំ | | ៣០ . វត្ត ធម្មគេរី | |

៣១ . វត្ត ពោធិទង
៣២ . វត្ត ថ្មពួន
៣៣ . វត្ត ខ្នាយក្រូវ
៣៤ . វត្ត ពោធិព្រឹក្ស
៣៥ . វត្ត ជោរ
៣៦ . វត្ត ទួលសង្កែ
៣៧ . វត្ត ជាច
៣៨ . វត្ត កំចាយមារ
៣៩ . វត្ត ពោន
៤០ . វត្ត កីងស្វរិយា
៤១ . វត្ត ទួលរវៀង
៤២ . វត្ត ត្រពាំងប្រៃយ៍
៤៣ . វត្ត ឈូក
៤៤ . វត្ត ព្រជី
៤៥ . វត្ត ខ្សោក
៤៦ . វត្ត ស្វាយប្រព្រឹក្ស
៤៧ . វត្ត មេបុណ្យ
៤៨ . វត្ត ព្រៃជ្រាំង
៤៩ . វត្ត អង្គរឃ្លោកថ្មី
៥០ . វត្ត ដីផុច
៥១ . វត្ត ពោធិមង្គល
៥២ . វត្ត វស្នីសាមគ្គី
៥៣ . វត្ត ច័ន្ទគ្រឹស្នា
៥៤ . វត្ត ព្រៃខ្លា
៥៥ . វត្ត សំរោង
៥៦ . វត្ត ព្រៃឃ្មេស
៥៧ . វត្ត ជ័យមង្គល
៥៨ . វត្ត ស្រះកណ្តាល
៥៩ . វត្ត បឹងព្រះ
៦០ . វត្ត សិរីសន្ធាយ
៦១ . វត្ត គោកសណ្តែក
៦២ . វត្ត ឃ្លាំងសេដ្ឋី
៦៣ . វត្ត បាខៅ
៦៤ . វត្ត ទ្រូងខ្លា
៦៥ . វត្ត អំពិល
៦៦ . វត្ត គោខ្ចក
៦៧ . វត្ត សិរីសង្គម
៦៨ . វត្ត កស្សបះ
៦៩ . វត្ត ថ្មី (គ្រើល)
៧០ . វត្ត ព្រៃពោន
៧១ . វត្ត ស្វរិយាវង្ស
៧២ . វត្ត ត្នាតកាង
៧៣ . វត្ត សិរីសារពេជ្រ
៧៤ . វត្ត កណ្តាល

| | |
|---|---|
| ៧៥ . វត្ត ព្រហ៊្វត | ៨៧ . វត្ត ព្រៃកញ្ជ្រៀង |
| ៧៦ . វត្ត ព្រះដីធំ | ៨៨ . វត្ត ចាក់ខ្លាញ់ |
| ៧៧ . វត្ត ចាងណាង | ៨៩ . វត្ត សុវណ្ណរង្សី |
| ៧៨ . វត្ត ហារ | ៩០ . វត្ត ក្តីកណ្តាល |
| ៧៩ . វត្ត សន្ធាជ័យ | ៩១ . វត្ត សំសមី |
| ៨០ . វត្ត រតនរង្សី | ៩២ . វត្ត ពពិល |
| ៨១ . វត្ត ពោធិគុម្ពព្រៃមាន | ៩៣ . វត្ត បទុមរតនៈ |
| ៨២ . វត្ត ព្រៃផ្តៅ | ៩៤ . វត្ត ជ្រៃទោល |
| ៨៣ . វត្ត យុវនាថនារាម | ៩៥ . វត្ត ស្វាយស្វខោ |
| ៨៤ . វត្ត កោះអណ្តែត | ៩៦ . វត្ត ជម្ពូវ័ន |
| ៨៥ . វត្ត ពោធិរង្សី | ៩៧ . វត្ត ឃ្នា |
| ៨៦ . វត្ត ឧត្តមសមាគម | ៩៨ . វត្ត ព្រៃតាហ៊ីង |

## ខេត្តសៀមរាប

៩) នៅក្នុងខេត្តសៀមរាប វត្តចំនួន ៥០ បានទទួល ១ ចប់ ក្នុងមួយវត្ត ត្រូវជា ៥០ ចប់ ( សេចក្តីសំរេចលេខ ៣១០-៩៥ កធស ចុះថ្ងៃទី ២៣-១២-១៩៩៥) ដូចខាងក្រោមនេះ

| | | | |
|---|---|---|---|
| ១ . វត្ត កេសរារាម | (មេគណ) | ៧ . វត្ត ប្រាសាទរាជា | (អនុគណ) |
| ២ . វត្ត ព្រះឥន្ទកោសីយ៍ | (អនុគណ) | ៨ . វត្ត ជ័យឧត្តមចុងកាល់ | (អនុគណ) |
| ៣ . វត្ត រលួស | (អនុគណ) | ៩ . វត្ត ចារឈូក | (អនុគណ) |
| ៤ . វត្ត ប្រាសាទបន្ទាយស្រី | (អនុគណ) | ១០. វត្ត ពួក | (អនុគណ) |
| ៥ . វត្ត គោកធ្លកលើ | (អនុគណ) | ១១. វត្ត ពោធិក្រឡាញ់ | (អនុគណ) |
| ៦ . វត្ត សុវណ្ណបទុម | (អនុគណ) | ១២. វត្ត ជ្រោយនាងងួន | (អនុគណ) |

១៣ . វត្ត ព្រះព្រហ្មរ័ត្ន
១៤ . វត្ត ដំណាក់
១៥ . វត្ត រាជបូព៌ (ប្រគេនព្រះមហាវិមលធម្ម)
១៦ . វត្ត រាជបូព៌
១៧ . វត្ត ព្រះឥន្ទកោសា
១៨ . វត្តពោធិលង្កា
១៩ . វត្ត អដ្ឋិស្មសាន
២០ . វត្ត ពោធិបន្ទាយជ័យ
២១ . វត្ត អង្គរខាងត្បូង
២២ . វត្ត ប្រាសាទឥន្ទ្រា
២៣ . វត្ត ស្វាយ
២៤ . វត្ត ចន្លោង
២៥ . វត្ត ពុទ្ធស្ថាននគររាជ ធម្មមេត្តា
២៦ . វត្ត បាគង
២៧ . វត្ត ខ្សាច់
២៨ . វត្ត បន្ទាយឫស្សី
២៩ . វត្ត ច័ន្ទរង្សី
៣០ . វត្ត រកា
៣១ . វត្ត គគីរ
៣២ . វត្ត ស្វាយធំ
៣៣ . វត្ត ត្របែកឯករង្សី
៣៤ . វត្ត សំរោង
៣៥ . វត្ត មុនធ្យាន
៣៦ . វត្ត លោមព្រលឹង
៣៧ . វត្ត ប្រាសាទសេម៉ាល័យ
៣៨ . វត្ត សូរិយារោងគោ
៣៩ . វត្ត បុទ្ធិសារាម
៤០ . វត្ត ប្រាសាទធ្មង់
៤១ . វត្ត គោកខ្ពស់
៤២ . វត្ត ប្រម៉ា
៤៣ . វត្ត ដូនជ្រាំ
៤៤ . វត្ត ខ្នាត
៤៥ . វត្ត ធិបតី
៤៦ . វត្ត សំពៅលូន
៤៧ . វត្ត ភ្នំទ្រង់បាត
៤៨ . វត្ត វេទ្យវ័នគោកក្រោល
៤៩ . វត្ត កោះប្រាសាទប្រិយ៍
៥០ . វត្ត អធ្វា

*( នៅមានតទៅខែត្តផ្សេងៗទៀត )*

# ពិធីប្រគេនសៀវភៅ
## ចំពោះវត្តនានា ក្នុងខេត្តកណ្តាល



ឯកឧត្តម ឈិន អៀម ប្រគេនសៀវភៅជានិមិត្តរូបចំពោះព្រះសង្ឃ

កាលពីថ្ងៃទី ១០ កក្កដា ១៩៨៦ វេលាម៉ោង ៨ ព្រឹក ពុទ្ធសាសនបណ្ឌិត្យ នៃក្រសួងធម្មការ និង សាសនា បាននាំយកសៀវភៅ ៥ មុខ ចំនួន ១៩១៧ ក្បាល ទៅប្រគេនចំពោះវត្ត ៣៥៩ ក្នុងខេត្តកណ្តាល ។

ពិធីនេះបានប្រព្រឹត្តទៅ នៅក្នុងបរិវេណវត្តជ្រោយអំពិល ឃុំព្រែកឯង ស្រុកកៀនស្វាយ ខេត្តកណ្តាល ក្រោមអធិបតីភាព ឯកឧត្តម ឈិន អៀម អនុរដ្ឋ-លេខាធិការ ក្រសួងធម្មការ និងសាសនា, ឯកឧត្តម ចក់ សារិ អភិបាលខេត្តកណ្តាល, ព្រះវិមលវេទី ឡុង យុង មេគណខេត្តកណ្តាល ដោយមានមន្ត្រីសង្ឃស្រុក គ្រប់ស្រុក មន្ត្រីរាជការរបស់មន្ទីរធម្មការ និងសាសនា ខេត្ត-ស្រុក មន្ត្រីតំណាងអង្គការ

ជំនួយសូត្តូស្វ៊ូ ជប៉ុន ព្រមទាំងពុទ្ធបរិស័ទជាច្រើនរួបច្ចូលរួមផង ។

សៀវភៅទាំង ៥ មុខនោះ រួមមាន :

- បទានុក្រមធម្មបទ ១២៣ ក្បាល
- ភាណវារៈបាលី ៣៥៩ ក្បាល
- សត្តបរិត្ត-ទ្វាទសបរិត្ត ៣៥៩ ក្បាល
- ឧប្បត្តិហេតុនៃគម្ពីរព្រះត្រៃបិដក ៣៥៩ ក្បាល
- ព្រះត្រៃបិដកភាសាខ្មែរ ៣៥៩ ក្បាល

មានប្រសាសន៍ក្នុងឱកាសនោះ, ឯកឧត្តម ឈន អៀម អនុរដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា បានប្រគេន និងជម្រាបត្រួសៗ អំពីភារកិច្ច និងសកម្មភាពផ្សេងៗរបស់ពុទ្ធសាសនបណ្ឌិត្យ បច្ចុប្បន្ន ដែលទទួលបន្តវេនពីមុនរបស់ពុទ្ធសាសនបណ្ឌិត្យ និងបំពេញតួនាទីជាស្ថួលមួយ ចាប់តាំងពីរិដ្ឋាស្ថាននេះ ត្រូវបានរៀបចំអោយដំណើរការឡើងវិញ នៅក្នុងឆ្នាំ ១៩៩២ គឺការប្រមូលចងក្រង រក្សាឯកសារ និងបោះពុម្ពឡើងវិញនូវសៀវភៅចាំបាច់ និងបន្ទាន់ សំរាប់បំរើសេចក្តីត្រូវការចំពោះមុខរបស់ព្រះសង្ឃ និងពុទ្ធបរិស័ទ ។

ចាប់ពីពេលនោះមក ដោយបានទទួលការឧបត្ថម្ភដ៏ឧត្តុង្គឧត្តមពីអង្គការជំនួយសូត្តូស្វ៊ូ ជប៉ុន និងជំនួយសប្បុរសធម៌ដទៃទៀត ពីប្រទេសជប៉ុន, ពីប្រទេសអាល្លឺម៉ង់ និងពីអង្គការសាសនា ប្រទេសតៃវ៉ាន់ ផងដែរ ពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពឡើងវិញ នូវសៀវភៅពុទ្ធសាសនា ជាច្រើនសែនក្បាល និងបានចែកប្រគេនសៀវភៅទាំងនោះមួយចំនួន ទៅដល់វត្តអារាម និងសាលាពុទ្ធិកសិក្សានានា ហើយមួយចំនួន ដាក់ជាវជាសាធារណៈ ក្នុងតម្លៃពាក់កណ្តាលនៃថ្លៃបោះពុម្ព សំរាប់បង្វិលទុនយកមកបោះពុម្ពសៀវភៅឯទៀតៗ ដូចជាសៀវភៅផ្នែកអក្សរសិល្ប៍ជាដើម ។

ឯទស្សនាវដ្ដី « កម្ពុជសុរិយា » ដែលជាទស្សនាវដ្ដីផ្សព្វផ្សាយអក្សរសាស្ត្រពុទ្ធសាសនា, អក្សរសាស្ត្រជាតិ, វប្បធម៌ ប្រពៃណីជាតិ ព្រមទាំងអត្ថបទគោលការណ៍សំខាន់ៗ ដទៃទៀត ដែលគួរអោយចង់ដឹង, ឥឡូវនេះ ត្រូវបានចេញផ្សាយឡើងវិញហើយ បន្ទាប់ពីបាត់ឈ្មោះបាត់សំឡេងអស់ពេលជិតពីរទសវត្សកន្លងទៅ ។

ជាមួយនឹងការបោះពុម្ពសៀវភៅខាងលើនេះ គម្ពីរព្រះត្រៃបិដកទាំង ១១០ ភាគ ក៏ត្រូវបានបោះពុម្ពឡើងវិញជាជំហានដំបូង ចំនួន១២០០ ចប់ ផងដែរ ។

មកដល់ពេលនេះ សៀវភៅដែលបានបោះពុម្ពរួចហើយ ពិតមែនតែពុំទាន់គ្រប់គ្រាន់តាមសេចក្ដីត្រូវការ ប៉ុន្តែបានរួមវិភាគមានយ៉ាងធំធេងដល់ការស្រោចស្រង់ អោយរស់ឡើងវិញនូវវប្បធម៌ពុទ្ធសាសនា និងវប្បធម៌ខ្មែរ នៅកម្ពុជា ។

ភ្ជាប់ទៅនឹងការបោះពុម្ពផ្សាយនេះ, ឯកឧត្តម ឈន អៀម ក៏បានទាញអារម្មណ៍អោយព្រះសង្ឃគ្រប់វត្ត ផ្ដោតព្រះទ័យទុកដាក់ទៅលើការរៀបចំអោយមានបណ្ណាល័យនៅក្នុងវត្ត សំរាប់បំរើសាធារណជនគ្រប់ស្រទាប់បានចូលអាន ចូលសិក្សា ពីព្រោះបណ្ណាល័យនៅតាមសាលានានា សំរាប់បំរើតែសិស្សក្នុងសាលានោះៗប៉ុណ្ណោះ, សាធារណជន ឬយុវជនមិនមែនជាសិស្ស មិនអាចចូលអាន ឬខ្ចីសៀវភៅពីសាលានោះ យកទៅអានឯផ្ទះបានទេ ។ ដូច្នេះ មានតែព្រះសង្ឃជាចៅអធិការវត្តគ្រប់វត្តនីមួយៗ ខិតខំកសាងបណ្ណាល័យឡើង ដើម្បីធ្វើអោយវត្តរបស់យើងនីមួយៗ ក្លាយជាមជ្ឈមណ្ឌលវប្បធម៌របស់ប្រជាជន ពោលគឺ ជាកន្លែងកសាងធនធានមនុស្ស នៅមូលដ្ឋាន រួមចំណែកអភិវឌ្ឍន៍សង្គមជាតិ ។

ឯសៀវភៅផ្លូវធម៌ និងផ្លូវលោក ព្រមទាំងទស្សនាវដ្ដីកម្ពុជសុរិយា សូមព្រះតេជព្រះគុណគ្រប់វត្ត ជួយជាវយកមកតម្កល់ទុកនៅបណ្ណាល័យវត្ត សំរាប់បំរើការសិក្សារបស់ប្រជាជន ។

នៅទីបញ្ចប់ ឯកឧត្តម ឈន អៀម បានថ្លែងក្នុងនាមពុទ្ធសាសនបណ្ឌិត្យ និងក្នុងនាមព្រះសង្ឃ នូវកតញ្ញូតាធមិដ៏ជ្រាលជ្រៅចំពោះអង្គការជំនួយស្មូត្តស៊្វិជប៉ុន និងសប្បុរសជនជប៉ុន ព្រមទាំងសមាគមពុទ្ធសាសនា នៅតៃវ៉ាន់ ដែលបានជួយបោះពុម្ពសៀវភៅជាច្រើនក្បាល ទាំងចំណេះដឹងខាងផ្លូវលោក និងផ្លូវធមិ កន្លងមកនេះ ហើយតាមរយៈសៀវភៅទាំងនេះ សូមព្រះសង្ឃយើង ប្រជាជនយើង បានល្អូតលាស់ដុះដាលដោយវិជ្ជា និងវិបុលសុខគ្រប់ប្រការ ហើយរួមគ្នាកសាងប្រទេសជាតិ និងព្រះពុទ្ធសាសនា អោយបានរីកចំរើនជាភិយ្យោភាព ក្រោមម្លប់សន្តិភាពមួយដ៏ស្ថិតស្ថេរ ។

ថ្លែងស្វាគមន៍ក្នុងឱកាសនោះដែរ ឯកឧត្តម ចក់ សារិ អភិបាលខេត្តកណ្តាល បានសំដែងអំណរគុណចំពោះឯកឧត្តមអនុរដ្ឋលេខាធិការ ឈន អៀម ដែលបានខិតខំធ្វើអោយពុទ្ធសាសនបណ្ឌិត្យដំណើរការបានល្អ រួមចំណែកយ៉ាងសំខាន់ដល់ការស្តារវិស័យពុទ្ធសាសនា និងកសាងប្រទេសកម្ពុជាឡើងវិញ ខាងវិស័យវប្បធមិ អក្សរសាស្ត្រ, និងអរគុណជាអនេក ចំពោះអង្គការជំនួយស្មូត្តស៊្វិជប៉ុន សប្បុរសជនជប៉ុន និងអង្គការពុទ្ធសាសនាតៃវ៉ាន់ ក្នុងការរួមវិភាគទានធ្វើអោយពុទ្ធសាសនា នៅកម្ពុជា មានពន្លឺរស្មីឡើងវិញ ។

ពិធីនេះ បានបញ្ចប់ក្រោមបរិយាកាសរីករាយ ដោយមានថតរូបរួមគ្នា ទុកជាអនុស្សាវរីយ៍ផង ។

មុននឹងវិលត្រឡប់ទៅភ្នំពេញវិញ ឯកឧត្តម ឈន អៀម បានអញ្ជើញចូលមើលបណ្ណាល័យវត្តជ្រោយអំពិល ដែលនៅទីនោះ ឯកឧត្តមបានសំដែងការសប្បាយរីករាយយ៉ាងខ្លាំង ដោយបានឃើញការរៀបចំទុកដាក់សៀវភៅបានល្អ ។

**ឱម ខែម**

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



ឧទ្ទេសកថា « ក្រោមការដឹកនាំរបស់ព្រះធម៌ - ឆ្ពោះទៅរកការអភិវឌ្ឍន៍ និងការដុះដាល »

( សូមអានអត្ថបទ នៅទំព័រ ៧១ )

ឆ្នាំទី ៥០ លេខ ៣ ខែ កក្កដា - សីហា - កញ្ញា

ព.ស ២៥៤០ គ.ស ១៩៩៦

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពី ពុទ្ធសាសនបណ្ឌិត្យ


ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

ទីប្រឹក្សា : **ហៀន ចណ្ណារក្ខ**

នាយកការផ្សាយ : **ឈន អៀម**

និពន្ធនាយក : **យី ធន់**

និពន្ធនាយករង : **ឱម ខែម**

គណៈកម្មការនិពន្ធ

សម្ដេចព្រះធម្មលិខិត **លាស់ ឡាយ**, ព្រះពុទ្ធឃោសាចារ្យ **ហេង លាងហោ**

លោក **ម៉ែន ប្រាង**, លោក **អាំ ឆន**

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

នៃក្រសួងធម្មការ និងសាសនា . ភ្នំពេញ

## ごあいさつ

この本は、世界宗教者平和会議日本委員会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました。

この本が、日本の宗教者とカンボジアの人々との友情のきずなとなり、カンボジアの宗教と文化の発展に貢献できれば幸いです。

## ACKNOWLEDGEMENT

The Kampuja Surya Magazine is specially printed as a cooperative project of the Japanese Committee of the World Conference on Religion and Peace (WCRP) and Japan Sotoshu Relief Committee (JSRC).

We pray that this magazine would contribute to the Friendship with Cambodian people and their religious and cultural preservation.

## និវេទនកថា

ទស្សនាវដ្តីកម្ពុជសុរិយានេះ ត្រូវបានបោះពុម្ពឡើងជាពិសេស ទុកដូចជាគម្រោងការងារ របស់គណៈកម្មាធិការជប៉ុននៃក្រុមប្រឹក្សាពិភពលោកស្តីពីសាសនា និងសន្តិភាព (WCRP) ហើយនិងគណៈកម្មាធិការជំនួយសូតូស៊ូជប៉ុន (JSRC) ។

យើងខ្ញុំអធិដ្ឋាន សូមឱ្យទស្សនាវដ្តីនេះ បានជាវិភាគទានរក្សាមិត្តភាពជាមួយប្រជាជនកម្ពុជា និងថែរក្សាសម្បត្តិសាសនានិងវប្បធម៌របស់ប្រជាជនកម្ពុជា ។

# មាតិកាអត្ថបទ

## I. អក្សរសិល្ប៍ពុទ្ធសាសនា :


- ការអប់រំពុទ្ធសាសនា ( ឈន អៀម ) ១
- កបិនទេសនា ( ម៉ែន ប្រាង និង អាំ ឆន ) ៣១


## II. អក្សរសាស្ត្រទូទៅ :


- ស្ពាននាមវិទ្យា ត - ចប់ ( បណ្ឌិត ឡុង សៀម ) ៤៧
- ក្រោមការដឹកនាំរបស់ព្រះធម៌ (ភិក្ខុសាស្ត្រាចារ្យ ធម្មវិហារិ) ៧១
- សិទ្ធិមនុស្ស និងពុទ្ធសាសនា ( ឈន អៀម ) ៨៦
- តម្លៃនៃជំហានទី ១ ( មៀច ប៉ុណ្ណ ) ១០៣
- ទំនួញតាចាស់ម្ចាស់ខ្សែដៀវ ( ខៀវ បញ្ញារុឌ្ឍ ) ១០៦
- រដូវធ្វើប្រហុក ( ខៀវ បញ្ញារុឌ្ឍ ) ១០៨
- សេចក្តីជូនដំណឹង អំពីលទ្ធផលនៃកំណាព្យប្រស្នា ១១០
- ចម្លើយកំណាព្យប្រស្នា ( ភិក្ខុ ព្រហ្ម សុជាតិ ) ១១១
- * កំណាព្យប្រស្នា ( វណ្ណ ស៊ុនហេង ) ១១៦


## III. កំណត់ និងប្រវត្តិការណ៍ :


- ការបែងចែកគម្ពីរព្រះត្រៃបិដក ( ត ) ១១៧
- មន្ត្រីសង្ឃ ៦ អង្គ ត្រូវបានតែងតាំងតម្លើងទៅក្នុងថ្នាក់ ១១៩

# ការអប់រំរបស់ពុទ្ធសាសនា

រៀបរៀងដោយ **ឈុន អៀម**

*១. សេចក្តីផ្តើម :*

មានមនុស្សតិចតួចណាស់ ដែលបានដឹងពីវិភាគទានរបស់ព្រះពុទ្ធសាសនា ចំពោះការអប់រំ ។ សូម្បីតែនៅក្នុងប្រទេសកាន់ពុទ្ធសាសនាទាំងឡាយ ដែលមានប្រពៃណីទទួលការអប់រំពីពុទ្ធសាសនាជាប់មិនដាច់ អស់កាលជាច្រើនសតវត្សហើយក៏ដោយ ក៏ប្រព័ន្ធអប់រំបច្ចុប្បន្ននៃប្រទេសនោះ លែងទៅជាការវិវត្តន៍ដោយផ្ទាល់នៃប្រពៃណីអតីតកាលនោះទៀតហើយ ទាំងមិនថិតនៅក្នុងបែបបទណាមួយ ដែលជាប់ទាក់ទងជាមួយការអប់រំរបស់ពុទ្ធសាសនាដែរ ។ ប្រពៃណីអប់រំរបស់ព្រះពុទ្ធ-សាសនា ត្រូវបានគេបោះបង់ចោលស្ទើរតែទាំងស្រុង, ប៉ុន្តែ នៅមានសេសសល់តែបន្តិចបន្តួច ដែលគេឃើញមានរក្សាទុកនៅក្នុងការចាត់តាំងរបស់វត្តអារាម សម្រាប់ការហ្វឹកហ្វឺនភិក្ខុ-សាមណេរ ។ ការខ្វះខាតឯកសារ ស្តីពីការអប់រំរបស់ពុទ្ធសាសនាគឺជាចំណុចខ្សោយដ៏គួរអោយសោកស្តាយ ។ គេពិបាកនឹងនិយាយពីប្រវត្តិទ្រឹស្តី ឬការអនុវត្តន៍វិស័យអប់រំរបស់ពុទ្ធសាសនា នៅក្នុងចំណោមប្រជាជនកាន់ព្រះពុទ្ធ-សាសនាទាំងឡាយពេកណាស់ ពីព្រោះតែខ្វះឯកសារជាប្រវត្តិសាស្ត្រសរសេរទុក ។ គេអាចពិនិត្យឃើញថា មានស្នាដៃជាសៀវភៅរាប់រយក្បាល ស្តីពីពុទ្ធសាសនា វប្បធម៌ និងអរិយធម៌ពុទ្ធសាសនា, ឬប្រវត្តិពុទ្ធសាសនា, ប៉ុន្តែសៀវភៅជាស្នាដៃទាំងនោះ បាននិយាយយោងដល់ការអប់រំរបស់ពុទ្ធសាសនាតែបន្តិចបន្តួចប៉ុណ្ណោះ ។ ប្រសិនបើមានការនិយាយយោងដល់ការអប់រំនោះវិញ ក៏ពុំមានផ្តល់អោយនោះកំណត់នៅត្រឹមតែជាផ្លាក ឬឃើហោរបស់ការអប់រំឥណ្ឌា នៅក្នុងមជ្ឈមណ្ឌល ដូចជា

តក្កសិលា, ពារាណសី, ដូចដែលមានរៀបរាប់នៅក្នុងគម្ពីរជាតកពុទ្ធសាសនា, ឬក៏ជាសេចក្តីរាយការណ៍អំពីមជ្ឈមណ្ឌលសិក្សារបស់ពុទ្ធសាសនា នៅក្នុងប្រទេសឥណ្ឌា និងស្រីលង្កា ដូចដែលអ្នកធ្វើដំណើរចិនដ៏សំខាន់ៗ គឺលោក ហ្វា-ហៀន ( Fa-Hien ) ហៀន-ត្សាង ( Hiuen-Tsang ) និង អ៊ី-ត្សឹង ( I -Tsing ) បានមើលឃើញ ហើយកត់ត្រាទុកមកនោះ ប៉ុណ្ណោះ ។

ប្រសិនបើមានការនិយាយទាក់ទងដល់ពេលថ្មីៗវិញ ក៏គេឃើញមានតែការនិយាយយោងទៅរកប្រព័ន្ធអប់រំពុទ្ធសាសនា និងសាលាវត្ត ដែលគេទុកនៅជួរក្រោយ សោះតែនឹងបំភ្លេចចោល បើប្រៀបធៀបទៅនឹងការចាប់ផ្តើមនៃការអប់រំបច្ចុប្បន្ន ។ គេបានប៉ុនប៉ងរកដំណោះស្រាយទស្សនវិជ្ជាពុទ្ធសាសនា ស្តីពីការអប់រំកន្លងមក ប៉ុន្តែ គេបានទទួលលទ្ធផលតិចតួចតែប៉ុណ្ណោះ ។

## *២. គ្រឹះនៃការអប់រំរបស់ពុទ្ធសាសនា :*

បេសកកម្មអប់រំពេលសែសិបប្រាំឆ្នាំរបស់ព្រះពុទ្ធ ក្នុងឋានៈជាសាស្ត្រាចារ្យគោចរ គឺជាបេសកកម្មដើម្បីប្រកាសមាគ៌ារំដោះផុតទុក្ខ ។ ព្រះអង្គត្រូវបានគេថ្វាយព្រះនាម ប្រកបដោយប្រជាប្រិយភាពថា ជាសាស្ត្រាចារ្យនៃមនុស្ស និងទេព្តា ( សត្ថា ទេវមនុស្សានំ ) និងជាមគ្គុទ្ទេសក៏ដែលទូន្មានមនុស្ស ( បុរិសទម្មសារថិ = នាយសារថីដឹកនាំមនុស្ស ) ។ នេះជាពាក្យសរសើរពីរម៉ាត់ ក្នុងបណ្តាគោរម្យងារសរសើរទាំងប្រាំបួនពាក្យ ដែលគេបានប្រើរហូតមកដល់សព្វថ្ងៃ នៅក្នុងបទនមស្សការ ចំពោះព្រះពុទ្ធ ។ សីល, សមាធិ, និងបញ្ញា ដែលសម្រេចបានតាមរយៈការយល់ដឹងនូវធម្មជាតិនៃជីវិត កង្គុជាជំហានសំខាន់ៗនៃមាគ៌ា ដែលព្រះពុទ្ធបានប្រៀនប្រដៅ ។ មាគ៌ាប្រៀនប្រដៅនេះ ណែនាំអោយប្រកាន់នូវជីវិតឧស្សាហ៍ព្យាយាមសិក្សា និងការធ្វើសមាធិ សំដៅហ្វឹកហ្វឺន និងទូន្មានចិត្ត ។ វាជាការសមហេតុ-ផល

ណាស់ ដែលប្រព័ន្ធសាសនាមួយ ដូចពុទ្ធសាសនាបានចាត់ទុកអវិជ្ជា ជាឫសគល់នៃទុក្ខវេទនាគ្រប់យ៉ាង និងប្រកាន់ចាត់ទុកចិត្ត ដែលមិនបានធ្វើអោយរីកចំរើនថាជាឧបសគ្គមូលដ្ឋានដល់ការរំដោះផុតទុក្ខនោះ ។ គេគួរតែអោយតម្លៃយ៉ាងខ្ពស់ លើការអភិវឌ្ឍន៍ផ្លូវចិត្ត ( ខួរក្បាល ) និងលើដំណើរការអប់រំសមស្របបំផុត សម្រាប់សម្រេចគោលដៅនេះ ។

ប្រព័ន្ធអប់រំដ៏ច្បាស់លាស់មួយ បានចាប់ផ្តើមវិវត្តក្នុងកំឡុងពេលព្រះពុទ្ធគង់ធរមាននៅ ។ មានកត្តាបួនយ៉ាងទាក់ទងនឹងការខិតខំខាងផ្នែកអប់រំរបស់ព្រះអង្គ ។ កត្តាទាំងបួននោះ គឺជាគ្រឹះនៃការអប់រំ ហើយមានរៀបរាប់ដូចតទៅ :

ក/ ព្រះពុទ្ធ ទុកជាគ្រូគំរូ ,

ខ/ ព្រះសង្ឃ ទុកជាសមាគមសិក្សា ,

គ/ វត្តអារាម ទុកជាមូលដ្ឋានស្ថាប័នសម្រាប់ពុទ្ធិកសិក្សា ,

ឃ/ សេរីនិយមខាងបញ្ញារបស់ពុទ្ធសាសនា ទុកជាការជំរុញលើកទឹកចិត្តទៅរកការអភិវឌ្ឍន៍ខាងការសិក្សាអប់រំ ។

*២.១. ព្រះពុទ្ធទុកជាគ្រូគំរូ :*

*២.១.១. គោលការណ៍តរុកោសល្យ និងវិធី ( បង្រៀន ) របស់ ព្រះពុទ្ធ :*

គេឥតមានការសង្ស័យឡើយថា ព្រះពុទ្ធគឺជាសាស្ត្រាចារ្យដ៏ជំនាញមួយរូប ហើយព្រះអង្គមានជំនឿយ៉ាងមោះមុតក្នុងអានុភាពនៃពាក្យពោលដើម្បីបញ្ចុះបញ្ចូលមនុស្ស អោយផ្លាស់ប្តូរបែបបទនៃជីវិតរបស់គេ, អោយគេព្រមប្រកាន់យកតម្លៃថ្មី និងស្វែងរកគោលដៅថ្មី ។ នៅពេលមួយនោះ កាលដែលគ្រូប្រដៅសាសនាជាបដិបក្ខទាំងឡាយ បានពឹងផ្អែកលើមន្តអាគម និងសកម្មភាពអច្ឆរិយៈ ដើម្បីបញ្ចុះ

បញ្ចូល ប្រមូលសាវ័កអោយបានច្រើនសម្រាប់ក្រុមរបស់គេ, ព្រះពុទ្ធបានប្រកាន់យកតែអច្ឆរិយភាពតែមួយប្រភេទប៉ុណ្ណោះ គឺ « អច្ឆរិយភាពនៃការប្រៀនប្រដៅ » ( អនុសាសនីបាដិហារិយៈ ) ។

ធម៌ទេសនារបស់ព្រះអង្គ ត្រូវបានត្រៀមរៀបចំដោយម៉ត់ចត់បំផុត ។ ភាពច្បាស់លាស់ និងការនិទានរៀបរាប់ប្រកបដោយហេតុ-ផល គឺជាលំអដល់ព្រះធម៌ទេសនារបស់ព្រះអង្គ ដែលទ្រង់បានសម្តែងទៅតាមព្រះតំរិះផ្ទាល់របស់ព្រះអង្គ ។ នៅក្នុងព្រះធម៌ទេសនានេះ ព្រះអង្គតែងមានពុទ្ធដីកាទៅកាន់ក្រុមតូច ឬធំ ហើយអូសទាញក្រុមនោះៗបន្តិចម្តងៗ មកកាន់ចំណុះនៃទស្សនៈ ដែលព្រះអង្គចង់អោយគេយល់ ។ ឧទាហរណ៍ជាក់ស្តែងអំពីការងារនេះ គឺធម្មចក្កប្បវត្តនសូត្រ និងសតិបដ្ឋានសូត្រ ។ មានលក្ខណៈពិសេសមួយចំនួន ត្រូវបានស្រង់ចេញមកពីព្រះធម៌ទេសនាទាំងនោះ, ព្រះអង្គតែងចាប់ផ្តើមដោយពុទ្ធដីកាយ៉ាងចាប់អារម្មណ៍ ជាឧទាហរណ៍ដូច្នេះថា : « មានអច្ឆន្តិកនិយម[(១)] ( Extremes ) ពីរយ៉ាង ដែលអ្នកស្វែងរកសច្ចធម៌មិនត្រូវប្រកាន់យក » ឬ « មានមាគ៌ាមួយដ៏ប្រាកដប្រជា និងត្រឹមត្រូវ, . ល . » ។

ព្រះអង្គបានធ្វើការវិភាគទស្សនៈនីមួយៗទៅដល់ធាតុផ្សំ ( សង្ខតធាតុ ) ហើយទ្រង់បានបង្ហាញធាតុផ្សំទាំងនោះទៅតាមលំដាប់លេខរៀង សម្រាប់ធ្វើជាក្របខ័ណ្ឌជួយអោយមើលឃើញគំនិតទាំងឡាយតាមលំដាប់លំដោយ និងសម្រាប់ជាជំនួយដល់ការចងចាំ ។

ព្រះពុទ្ធប្រើប្រាស់ការប្រៀបធៀប និងការប្រដូចដោយសេរី និងដោយញឹកញាប់ ហើយច្រើនតែទាញយកការប្រៀបផ្ទឹម ឬការប្រដូចទាំងនោះ ពីជីវភាព

---

(១) អច្ឆន្តិកនិយមពីរយ៉ាង : កាមសុខល្លិកានុយោគ គឺការប្រព្រឹត្តជាប់ជានិច្ចចំពោះកាមសុខ, អត្តកិលមថានុយោគ គឺការប្រកបព្យាយាមតឹងពេក នាំអោយនឿយហត់ឥតប្រយោជន៍ ។

រាល់ថ្ងៃរបស់មនុស្ស ឧទាហរណ៍ ការងាររបស់កសិករ, អ្នកលក់សាច់, អ្នកលក់ផ្កា, អ្នកអុំទូក, ទាហាន, មន្ត្រីរាជការ ។ ព្រះអង្គតែងតែទេសនាម្តងហើយម្តងទៀត អំពីទស្សនៈសំខាន់ៗ, ឬត្រឡប់មកសំដែងអំពីទស្សនៈទាំងនេះឡើងវិញ នៅពេលណាមានឱកាសហុចអោយ ។ ការសំដែងអំពីទស្សនៈទាំងឡាយបែបនេះ ត្រូវបានធ្វើអោយរីកចំរើនស្ទើរតែដល់កំរិតជារូបមន្តគំរូ ឬជារូបមន្តទូទៅ ដែលគេតែងតែលើកយកមកសូត្យ ឬនិយាយយោងដល់ ។ ធម៌ទេសនាបាននាំអ្នកស្តាប់បន្តិចម្តងៗ ទៅកាន់សេចក្តីសន្និដ្ឋាន ដែលតាមធម្មតាគឺជាការទូន្មានដ៏ខ្លាំង អោយបន្តដំណើរលើមាគ៌ានៃការរំដោះផុតទុក្ខ ដែលព្រះអង្គបានគាំទ្រ ។

ការសន្ទនារបស់ព្រះអង្គជាមួយមនុស្សជាបុគ្គលម្នាក់ៗ មានសកម្មភាពរស់រវើក ដោយសារព្រះអង្គបានប្រើប្រាស់ពាក្យស្លោកសិក្សាផ្សេងទៀតជាច្រើន : តាមធម្មតា ព្រះអង្គតែងញ៉ាំងអោយអ្នកពិភាក្សាជាមួយព្រះអង្គ បំភ្លឺអំពីទស្សនៈយល់ឃើញរបស់គេ ហើយអោយគេប្រកាន់ជំហរមួយច្បាស់លាស់ ។ ប៉ុន្តែ ព្រះពុទ្ធនឹងមិនប្រើវិធីនេះទេ ប្រសិនបើព្រះអង្គមិនបានយល់ច្បាស់ថា ព្រះអង្គបានយល់ច្បាស់លាស់រួចហើយ នូវគោលជំហររបស់អ្នកពិភាក្សាជាមួយព្រះអង្គ ។ ការបំភ្លឺបញ្ជាក់លើបុព្វកថា ( Premise ) គឺព្រះអង្គធ្វើឡើងយ៉ាងប្រញាប់នៅរាល់ពេលផ្តើមជជែកម្តងៗ ។ ប្រសិនបើព្រះអង្គមិនយល់ស្រប, ព្រះអង្គមិនធ្លាប់ដែលបានបន្ទុះបង្អាប់ដៃគូជជែក ( បដិវាទី ) ឬគំនិតរបស់គេឡើយ, ប៉ុន្តែព្រះអង្គតែងចាប់ផ្តើមចោទជាសំណួរតបទៅវិញ ។ សំណួរចោទនោះ គឺជាសំណួរត្រិះរិះស្រាវជ្រាវជានិច្ច, ដែលរៀបចំឡើងយ៉ាងម៉ត់ចត់ ដើម្បីបញ្ចុះបញ្ចូលដៃគូពិភាក្សា អោយយល់ពីការខុសឆ្គងនៃទឡ្ហីករណ៍របស់គេ ។ ដៃគូពិភាក្សា ត្រូវបានអូសទាញបន្តិចម្តងៗទៅរកការធ្វើសម្បទាន ហើយនៅទីបំផុតឈានទៅបោះបង់ជំហរដើមរបស់ខ្លួន ។ ជាញឹកញយ អារម្មណ៍ដែលគេទទួលបាននោះ គឺថា ព្រះពុទ្ធអង្គទ្រង់បានចាត់តាំង

ឡើងវិញ នូវដំណើរគំនិតរបស់ដៃគូពិភាក្សា ដោយការចោទសួររន្ធើនផ្ទួនៗ ។ ការប្រៀបធៀប និងការប្រដូច ត្រូវបានយកមកប្រើក្នុងការរៀបចំ និងការពន្យល់សំណួរទាំងឡាយនោះៗ ។ រឿងនិទានដកស្រង់ពីរឿងព្រេង និងពីប្រវត្តិសាស្ត្រក៏មានយ៉ាងសម្បូរនៅក្នុងធម្មទេសនារបស់ព្រះអង្គ ។ ការវាយតម្លៃពីគោលជំហរខាងដើមរបស់ដៃគូពិភាក្សា បានឈានមកដល់ចំណុចនៃការខ្មាសអៀន និងការប្រកាសលែងប្រកាន់យកជំហរនោះដោយត្រង់ៗ, ហើយស្ថានភាពបែបនេះ ធ្លាប់បានកើតមាននៅក្នុងឱកាសជាច្រើន តែកាលណាដៃគូពិភាក្សាបានបោះបង់ចោលជំហររបស់ខ្លួន ហើយត្រៀមខ្លួនដើម្បីយល់ព្រមដើរតាមព្រះពុទ្ធតែប៉ុណ្ណោះ ។

គឺមានតែក្រោយពេលនៃចំណុចយល់ព្រមដូច្នេះបានកើតឡើងទេ, ទើបព្រះពុទ្ធចាប់ផ្តើមអធិប្បាយអំពីទស្សនៈផ្ទាល់របស់ព្រះអង្គ, ស្តីពីចំណុចពិភាក្សាគ្នានោះ ទោះបីជាប្រធានបទពិភាក្សាគ្នាជាអ្វីក៏ដោយ, ក៏ព្រះពុទ្ធតែងអូសទាញដៃគូពិភាក្សាបន្តិចម្តងៗ មកកាន់ការទេសនាអំពីមាគ៌ានៃការរំដោះអោយផុតទុក្ខដែរ ។

ទោះបីនៅក្នុងការសំដែងធម៌ និងការទេសនាក្តី ឬនៅក្នុងការសន្ទនា និងការជជែកដេញដោលក្តី, ព្រះពុទ្ធអង្គតែងប្រកាន់យកនូវចង្កោមគោលការណ៍អនុវត្តជាគំរូមួយចំនួនសម្រាប់ការអប់រំ ។ ព្រះអង្គតែងគិតគូរដល់កិរិតបញ្ញារបស់ «សិស្ស» ។ ព្រះអង្គបានអធិប្បាយអំពីទស្សនៈតែដដែល នៅក្នុងបែបបទផ្សេងៗគ្នាយ៉ាងច្រើន ដោយអនុលោមទៅតាមធម្មជាតិ ( ឬ និស្ស័យ ) និងសមាសភាពនៃអង្គប្រជុំ ។ ព្រះអង្គបានចាប់ផ្តើមពីអ្វីដែលស្គាល់ ហើយសង្កត់លើអ្វីដែលស្គាល់នោះទុកដូចជាគោលការណ៍មូលដ្ឋាននៃការប្រៀនប្រដៅ ( ការបង្រៀន ) របស់ព្រះអង្គ ។ ព្រះអង្គតែងចៀសវាងនូវការអធិប្បាយជាទ្រឹស្តី ដោយចាត់ទុកនេះជាការខ្ជះខ្ជាយពេលវេលា ។ ព្រះអង្គតែងណែនាំថា បុគ្គលម្នាក់ៗគប្បីខិតខំ " ស្វែងយល់នូវអ្វី តាមដូចដែលអ្វីនោះកើតមានយ៉ាងពិតប្រាកដ " ដោយយកចិត្តទុកដាក់លើការ

ស្គាល់ និងការណ៍ពិតទាំងពីរនេះ ។

ប៉ុន្តែថា, ព្រះពុទ្ធបានផ្តល់តម្លៃដ៏តិចតួចដល់ការចេះដឹង ដើម្បីចេះដឹង ( Knowledge per se ), ចំណេះដឹងណាមួយនឹងមានសុពលភាព (Validity) តែកាលណាចំណេះដឹងនោះ ត្រូវបានគេយកទៅអនុវត្តប្រើប្រាស់បានប៉ុណ្ណោះ ។ ចំណេះដឹងតិចតួច ប៉ុន្តែ ត្រូវបានគេយកមកប្រើប្រាស់បានដោយត្រឹមត្រូវ, ចំណេះដឹងនោះ ត្រូវបានគេចាត់ទុកថាមានតម្លៃខ្ពស់ជាងចំណេះដឹងដ៏ធំសម្បើម ដោយគ្មានការប្រើប្រាស់ជាក់ស្តែងកើតនូវអ្វីដែលគេបានរៀនសូត្រនោះ ។ អ្នកទាំងឡាយណាដែលជឿតាមបែបខាងក្រោយនេះ ( ពោលគឺមានចំណេះដឹងច្រើន ប៉ុន្តែចំណេះដឹងនោះ អនុវត្តប្រើប្រាស់ពុំកើត ), អ្នកទាំងឡាយនោះ ត្រូវបានគេរិះគន់ថា ដូចអ្នកគង្វាលគោ ដែលថែទាំហ្វូងគោសម្រាប់តែផលប្រយោជន៍របស់អ្នកដទៃ ។ ព្រះអង្គមានព្រះទ័យសោមនស្សកើតឡើង តែកាលណាព្រះអង្គបានជ្រាបច្បាស់ថា សិស្សរបស់ព្រះអង្គបានយល់ពិតប្រាកដ នូវអ្វីដែលព្រះអង្គកំពុងទេសនា ( អធិប្បាយ ) ។ ព្រះអង្គតែងសាកល្បងមើលមនុស្សទាំងនោះ ក្នុងពេលព្រះអង្គកំពុងបន្តស្វែងចោទសំណួរ ។ ព្រះអង្គបានប្រើប្រាស់ចង្កោមពាក្យសទិសន័យ សម្រាប់ពាក្យទាំងឡាយដែលមានសារសំខាន់ ឬមានន័យជ្រាលជ្រៅទូលំទូលាយ ។ ព្រះអង្គបានលើកយករឿងនិទានទាំងឡាយមករៀបរាប់ ។ កាលណាមានលក្ខខណ្ឌសមស្របហើយ ព្រះអង្គតែងសង្ខេបមេរៀនទៅជារូបមន្តមួយខ្លី, តាមធម្មតា ផ្តុំផ្សំទៅជាគាថាមួយបទ ដែលមានព្យាង្គសាមសិបពីរ ។

អត្ថប្រយោជន៍នៃកំណាព្យ ត្រូវបានគេទទួលស្គាល់ថាជាជំនួយដ៏ពិសេសមួយ សម្រាប់ជួយអោយងាយចងចាំ ។ ដោយព្រះអង្គឯងជាកវីស្រាប់ផង ការប្រើប្រាស់កំណាព្យ ដើម្បីពង្រីកការចេះដឹង ត្រូវបានព្រះពុទ្ធអង្គបន្តប្រើប្រាស់ជាប្រចាំ ។ ប្រធានបទប្រជាប្រិយ៍ភាគច្រើន ត្រូវបានព្រះអង្គអធិប្បាយនៅក្នុងព្រះធម្មទេសនា

ជាពាក្យកាព្យ ។ ប៉ុន្តែ ព្រះអង្គមិនបានគាំទ្រអោយមានការសំដែងធម៌របស់ព្រះអង្គ ជាកំណាព្យសំស្ក្រឹតទេ, ដ៏ជាមធ្យោបាយផ្សព្វផ្សាយរបស់ទស្សនវិទូជាវរជន និងគ្រូប្រដៅសាសនា ក្នុងសម័យកាលរបស់ព្រះអង្គ ។ ព្រះអង្គគាប់ព្រះទ័យអនុញ្ញាតអោយបុគ្គលម្នាក់ៗ សិក្សាទ្រឹស្ដីជាភាសាកំណើតផ្ទាល់របស់គេ ហើយព្រះពុទ្ធអង្គឯង បានជ្រើសរើសគ្រាមភាសានៃសម័យនោះ ដើម្បីទេសនាផ្សព្វផ្សាយ គឺភាសាមាគធី ជាជាងប្រើភាសាសំស្ក្រឹតសម្រាប់តែពួកវរជន ។

*២.១.២. អំពីការចាត់តាំងការសិក្សា : តួនាទីនៃគ្រូ :*

គ្រូត្រូវជំរុញសិស្សរបស់ខ្លួនអោយជជែក និងអោយពិភាក្សាដេញដោល ហើយជាញឹកញយ លោកគ្រាន់តែតាំងខ្លួនជាអាជ្ញាកណ្ដាលប៉ុណ្ណោះ ។ លោករៀបចំសិស្សពូកែលេចធ្លោជាងគេ អោយធ្វើជាគ្រូសម្រាប់អ្នកឯទៀត ។ គ្រូវាយតម្លៃសមត្ថភាពបង្រៀនរបស់គរុសិស្ស ហើយចាត់ថ្នាក់គរុសិស្សទាំងនោះ ទៅតាមជំនាញ និងវិធីសាស្ត្ររបស់គេ ។

ព្រះពុទ្ធបានចាត់តាំង *សង្ឃ* ទៅជាសមាគមសិក្សាមួយ ដែលនៅក្នុងសមាគមនេះ សមាជិកទាំងឡាយត្រូវចំណាយពេលនៃការរស់នៅរបស់ខ្លួនរៀនសូធ្យ, អនុវត្តតាមនូវអ្វីដែលគេបានរៀន, បង្រៀនអ្នកដទៃ, ចូលរួមក្នុងការពិភាក្សាដេញដោល និងការពិភាក្សាដើម្បីបំភ្លឺទស្សនៈទាំងឡាយ, ចងចាំព្រះធម៌ទេសនា និងពុទ្ធឱវាទ, ហើយនិងបន្តផ្សព្វផ្សាយព្រះធម៌ទេសនា និងពុទ្ធឱវាទទាំងនោះដោយពាក្យផ្ទាល់មាត់ សម្រាប់ការថែរក្សាអោយគង់វង្ស, ពង្រីកអន្តរកថាធ្វើអោយចំរើនឡើង, និងបញ្ចុះបញ្ចូលសមាជិក អោយមានចំនួនកាន់តែច្រើនឡើងៗ ដែលជាអ្នកមានប្រាថ្នាបន្តដំណើរសិក្សាអស់ពេលមួយជីវិត តាមទំនងដូចគ្នានេះ ។

ក្នុងព្រះឋានៈជាសាស្ត្រាចារ្យមួយរូប ព្រះពុទ្ធបានបង្ហាញអោយឃើញនូវ

ព្រះសមត្ថភាពដ៏អស្ចារ្យដទៃទៀតជាច្រើន ។ ព្រះអង្គអាចបង្វែរព្រឹត្តិការណ៍ឯណាមួយ អោយទៅជាឱកាសមួយសម្រាប់ការប្រៀនប្រដៅ ។ ប្រសិនបើឱកាសទាំងអស់ ដែលព្រះអង្គបានប្រើសម្រាប់សំដែងធមិទេសនាដល់អង្គប្រជុំ ត្រូវបានគេធ្វើវិភាគទុកដូចជាថ្នាក់រៀនវិញ, នោះគេនឹងមានសេចក្តីចម្លែកក្នុងចិត្ត ចំពោះទេពកោ-សល្យរបស់ព្រះអង្គ ក្នុងការប្រើស្ថានភាពណាមួយ ឬការប្រជុំមនុស្សណាមួយ អោយប្រែក្លាយទៅជាឱកាសមួយ សម្រាប់ប្រៀនប្រដៅចំណេះវិជ្ជាណាមួយទៅវិញ ។ យ៉ាងណាមិញ, ពួកក្មេងប្រឡែងលេងជាមួយសត្វពស់មួយ, មនុស្សចាស់ត្រូវកូនរបស់ខ្លួនបោះបង់ចោល, ការដេញតាមរកឃាតករចោរប្លន់ម្នាក់, ពិធីបូជា-យញ្ញរបស់ព្រាហ្មណ៍ម្នាក់, សង្គ្រាមរវាងបងប្អូនឯង និងឱកាសដូចគ្នានេះជាច្រើនទៀត បានផ្តល់ឱកាសឱ្យព្រះអង្គសម្រាប់ធ្វើជា " ថ្នាក់រៀន " របស់ព្រះអង្គ ។ មានពេលខ្លះ ព្រះអង្គបានថ្មៃប្រឌិតបង្កើតឱកាសបែបនេះ ដោយព្រះអង្គឯង ។ ព្រះអង្គមិនដែលខកខានប្រើប្រាស់ឱកាសទាំងឡាយ ដែលអ្នកដទៃហុចអោយនោះទេ ។ ព្រះអង្គត្រៀមចាំទទួលជានិច្ច នូវការនិមន្តន៍របស់មនុស្សដទៃ ហើយទ្រង់គាប់ព្រះទ័យជានិច្ច ចូលរួមក្នុងការសួរដេញដោលណាក៏ដោយ ។ ថ្វីបើព្រះអង្គប្រើវោហារស័ព្ទនិយាយយ៉ាងសុក្រឹតក៏ដោយ ក៏ព្រះអង្គនៅជាអ្នកស្ទាត់ជំនាញដូចគ្នា ក្នុងការប្រើវិធីប្រៀនប្រដៅដទៃទៀត ។ វិធីធ្វើអោយគេស្វែងរកឃើញដោយខ្លួនឯង ( Dis-cover method ) ត្រូវបានព្រះពុទ្ធរកឃើញតាំងពីយូរយារណាស់មកហើយ, ហើយប្រហែលជាវិធីមួយដ៏សុក្រឹតបំផុត ។ ការអនុវត្តនីវិធីនេះ ត្រូវបានព្រះពុទ្ធយកមកប្រើក្នុងពេលដែលមាតាម្នាក់កំពុងរងទុក្ខសោកយ៉ាងក្រៀមក្រំ ចំពោះមរណ-ភាពនៃបុត្ររបស់ខ្លួន រហូតដល់ស្ត្រីជាមាតានោះបានរកឃើញនូវសកលភាព នៃមរណភាព តាមរយៈការស្វែងរកសុំគ្រាប់ស្ពៃអំពីផ្ទះណាមួយ ដែលមិនធ្លាប់ឃើញមរណភាពសោះ ( សូមអាន រឿងកិសាគោតមី ) ។ អក្សរសាស្ត្រពុទ្ធសាសនា បាន

ចាត់ទុកព្រះមោគ្គល្លានថាជាអ្នកវាងវៃមួយរូប ក្នុងការប្រើព្រឹត្តិការណ៍ដើម្បីប្រៀន-ប្រដៅធម៌ នៅពេលដែលលោកប្រើរូបតំណាងកងចក្រ ( Diagrammatic representation ) ដើម្បីពង្រឹង និងធ្វើអោយសម្បូរនូវមេរៀនរបស់លោក ។

យោងតាម *ទិវ្យាវទាន,* ព្រះអានន្ទបានរៀបរាប់ថា ព្រះមោគ្គល្លាន បានលំអការទេសនារបស់លោក ស្តីពីបដិច្ចសមុប្បាទធម៌ ដោយប្រើរូបកងចក្រ ដែលនៅក្នុងរូបកងចក្រនោះ លោកបានពិពណ៌នារៀបរាប់ពីកត្តាជាមូលហេតុទាំងដប់ពីរ ។ ព្រះពុទ្ធមិនគ្រាន់តែបានសម្តែងការសរសើរចំពោះព្រះមោគ្គល្លានប៉ុណ្ណោះទេ, ព្រះអង្គបានណែនាំអោយគេតាំងបង្ហាញរូបកងចក្រនោះ នៅលើក្លោងទ្វារវត្តវេឡុវ័ន ក្នុងក្រុងរាជគ្រឹះទៀតផង ។ រូបបង្ហាញនេះ ត្រូវបានអោយឈ្មោះជាប់តមកថា ជាកំណើតនៃ " សង្សារចក្រ " ( The Wheel of Becoming ) ដែលគេបានឃើញរូបគូរក្នុងល្អាងភ្នំ នាសតវត្សទី ៧ នៅអជន្តា ( Ajanta ), ក្នុងស្ថានភាពជាបំណែកៗ ។ នោះក៏ជាប្រធានបទដ៏ជាប្រជាប្រិយមួយ នៅក្នុងរូបគំនូរទាំងឡាយរបស់ប្រទេសទីបេត៍ និងនៅនេបាលីតង្កា ( Nepali Tangka ) ផងដែរ ។

ព្រះពុទ្ធអង្គឯង ក៏ត្រូវបានគេពោលសរសើរថា ព្រះអង្គបានប្រើចង្កោមរូបភាពចក្ខុទស្សន៍ បង្កើតឡើងដោយបាដិហារ្យ ដើម្បីផ្លាញ់យុវក្សត្រីកោងកាចមួយអង្គ ប្រកបដោយចរិតល្ងិចល្ងើរ និងមានរូបសម្ផស្សឆើតឆាយ ( សូមអាន រឿង អភិរូបា នន្ទាថេរី ) ។

វាក៏មានសារសំខាន់ធំធេងដែរ ដូចជាការអនុវត្តន៍ជាក់ស្តែង នូវការប្រើឧបករណ៍អប់រំមួយចំនួន, នោះគឺទស្សនៈមួយចំនួនរបស់ព្រះពុទ្ធ ស្តីពីការបង្រៀន និងការរៀន ហើយនិងមុខវិជ្ជាទាក់ទងទៅនឹងការរៀន និងការបង្រៀននោះ ។ អត្ថបទដ៏មានប្រយោជន៍មួយ នៅក្នុងសិង្គាលោវាទសូត្រ បានរៀបរាប់ពីករណីយកិច្ចរបស់គ្រូ និងសិស្ស ដូចខាងក្រោម ៖

. *គ្រូគប្បី :*

១) បង្ហាញសេចក្ដីស្រឡាញ់រាប់អានចំពោះសិស្សរបស់ខ្លួន ;

២) ហ្វឹកហ្វឺនគេក្នុងផ្លូវគុណធម៌ និងសុចរិយាធម៌ ;

៣) បង្រៀនគេដោយយកចិត្តទុកដាក់, ផ្ដល់អោយគេនូវចំណេះវិទ្យា-សាស្ត្រ និងគតិបណ្ឌិតរបស់បោរាណាចារ្យ ;

៤) និយាយល្អអំពីគេប្រាប់មិត្តភ័ក្តិ និងបងប្អូន ; និង

៥) គ្រប់គ្រងគេ អោយផុតពីគ្រោះថ្នាក់ ។

. *សិស្សត្រូវ :*

១) ជួយគ្រូរបស់ខ្លួន ;

២) ក្រោកឈរនៅចំពោះមុខគ្រូ និងបម្រើលោក ;

៣) ស្ដាប់ដោយយកចិត្តទុកដាក់ និងដោយសេចក្ដីគោរពនូវអ្វីទាំងអស់ដែលលោកបង្ហាត់បង្ហាញ ;

៤) បំពេញករណីយកិច្ចចាំបាច់ សម្រាប់ផាសុកភាពផ្ទាល់ខ្លួនរបស់លោក;

៥) ទទួលយកការប្រៀនប្រដៅរបស់លោក ដោយយកចិត្តទុកដាក់ ។

ទាំងនេះ ត្រូវបានកំណត់ថា ជាកាតព្វកិច្ចរវាងគ្រូ និងសិស្ស ក្នុងក្របខ័ណ្ឌផ្លូវលោក, ពីព្រោះ សូត្រដដែលនេះ ( សិង្គាលោវាទសូត្រ ) ក៏បានកំណត់ករណីយ-កិច្ច មួយចំនួនទៀត រវាងគ្រូប្រដៅសាសនា និងសាវ័កជាគ្រហស្ថរបស់ខ្លួនដែរ ។ ក្នុងករណីនេះ ខ្លឹមសារសីលធម៌ ស្ដីពីអ្វីដែលបានបង្រៀន ក៏ត្រូវបានគេយកចិត្តទុកដាក់ដល់ ហើយកាតព្វកិច្ចមួយចំនួន ត្រូវបានគេកំណត់អោយសាវ័កជាគ្រហស្ថធ្វើខ្លួនអោយបានសមស្រប ដើម្បីអោយចូលទទួលចំណេះវិជ្ជា ពីគ្រូខ្លួនបាន ។ ក្នុងករណីទាំងពីរនៃការអប់រំតាមផ្លូវលោក និងតាមផ្លូវសាសនា, កាតព្វកិច្ចដែលដាក់ចុះអោយសិស្ស ឬសាវ័កប្រតិបត្តិ ដែលទាក់ទងនឹងការសិក្សារៀនសូត្រ

សូត្យ គឺជាកិច្ចការសំខាន់ ។ សិស្សត្រូវត្រងត្រាប់នូវអ្វី ដែលគ្រូបានប្រៀនប្រដៅ ដោយសេចក្តីគោរព និងដោយយកចិត្តទុកដាក់ ។ ក៏ដូចគ្នាដែរ សាវ័កជាគ្រូហស្ថ ត្រូវជួយគ្រូអាចារ្យរបស់ខ្លួនដោយសេចក្តីគោរព និងដោយការយកចិត្តទុកដាក់ទាំងដោយកាយ, វាចា, និងចិត្ត ។

មិនដែលមានពេលណាមួយ ដែលព្រះពុទ្ធបានគាំទ្រការទទួលជឿ នូវអ្វីមួយ ដោយហាមមិនអោយសួរដេញដោល, ដោយអាងអំណាចជាគ្រូអាចារ្យនោះឡើយ ។ ការអាងអំណាចជាគ្រូអាចារ្យបែបនេះ មុខជាផ្ទុយទៅនឹងគោលការណ៍ជាមូលដ្ឋានផ្ទាល់មួយ ក្នុងបណ្តាគោលការណ៍មូលដ្ឋានទាំងឡាយរបស់ព្រះអង្គ ដើម្បីធានាចំពោះបុគ្គលម្នាក់ៗ នូវសិទ្ធិពេញលេញ និងឥតឥវ៉ាបាន ដើម្បីគិតគូរសម្រាប់ខ្លួនឯងផ្ទាល់ ។ របៀបដោះស្រាយរបស់ព្រះពុទ្ធ ចំពោះការសិក្សារៀនសូត្យ គឺជាការហ្វឹកហាត់ដោយសេរី និងឥតមានចំណងនូវសមត្ថភាពខាងបញ្ញាផ្ទាល់របស់បុគ្គល ដើម្បីត្រិះរិះ ។ របៀបដោះស្រាយនេះ ជារបៀបសមស្របជាមួយនឹងគោលការណ៍ឈានមុខរបស់ព្រះអង្គ ដែលទ្រង់បានប្រកាសយ៉ាងមហោឡារិកចំពោះអ្នកស្រុកកាលាម ( សូមអាន កាលាមសូត្រផង ) ។

### *២.១.៣. ការបង្រៀន - ការរៀន : ដំណើររីកចំរើន តាមលំដាប់ លំដោយ :*

វិធីដែលព្រះពុទ្ធបានសំដែងទុកមក សម្រាប់ដំណើរត្រួតពិនិត្យដោយខ្លួនឯង នូវរាល់ចំណេះដឹងទាំងអស់នេះ គឺការសង្កេត ( An observation ) និងការធ្វើវិភាគ ( An analysis ) ។ ទស្សនវិជ្ជា ឬសាសនាផ្ទាល់របស់ព្រះអង្គ ត្រូវបានគេពណ៌នាថាជា *ឯហិ បស្សិកោ* ( ចូរមក ហើយពិនិត្យ ឬសង្កេតមើល ), *បច្ចត្តំ វេទិតព្វោ* (បុគ្គលម្នាក់ៗ គប្បីយល់ដឹងដោយឯករាជ្យ) ។ គេបានផ្តល់វិសេសស័ព្ទ

ដល់ពុទ្ធសាសនា តាំងតែពីដំបូងទីម្ល៉េះ នៅក្នុងការផ្សព្វផ្សាយរបស់ខ្លួនថាជា *វិភជ្ជ-វាទ*, ដែលមានន័យថាជាទ្រឹស្តីវិភាគ ( The doctrine of analysis ) ជំហរ របស់ព្រះពុទ្ធ ក៏ត្រូវបានគេចាត់ទុកជាជំហរនៃអ្នកចង្អុលប្រាប់ផ្លូវ, ចំណែកឯបុគ្គល ម្នាក់ៗ ត្រូវខិតខំស្វែងយល់នូវសច្ចៈសម្រាប់ខ្លួនដោយខ្លួនឯងផ្ទាល់ ។

តាមពិត, គេគួរតែចោទសួរក្នុងទីនេះថា តើតួនាទីរបស់គ្រូ ឬអាចារ្យ តាមដូចដែលព្រះពុទ្ធបានគិតនោះ គឺជាតួនាទីអសកម្ម ឬយ៉ាងណា ? ។ ចម្លើយដ៏ខ្លី របស់យើង ស្តីពីព្រះពុទ្ធក្នុងឋានៈព្រះអង្គជាគ្រូ ឬជាអាចារ្យនោះ បានបង្ហាញថា ព្រះ ពុទ្ធពុំមែនជាបុគ្គលអសកម្មសោះឡើយ ។ នៅក្នុងកន្លែងដ៏ច្រើន ព្រះពុទ្ធបាន ពិពណ៌នាអំពីតួនាទីរបស់ព្រះអង្គយ៉ាងល្អិតល្អន់គ្រប់គ្រាន់ដែរហើយ ។ ក្នុងពេលមាន ពុទ្ធដីកាទៅកាន់ ភទ្ទាលិ នៅក្នុងគម្ពីរមជ្ឈិមនិកាយ, ព្រះអង្គប្រដូចព្រះអង្គទៅនឹង អ្នកពង្រាបសេះដ៏ជំនាញម្នាក់ ។ ព្រះអង្គលើកយកភាពស្របគ្នារវាងវិធីរបស់ព្រះអង្គ ហើយនិងវិធីហ្វឹកហ្វឺនតាមលំដាប់ថ្នាក់ ដែលអ្នកពង្រាបសេះបានយកមកប្រើជាមួយ សេះថ្មីមួយ ។ ព្រះសូត្របាននិទានថា : " តាមគន្លងនេះ ព្រះពុទ្ធបានផ្តល់ឱកាសល្អដល់ មនុស្សគ្រប់រូប ដែលទទួលយកនូវការណែនាំរបស់ព្រះអង្គ តាមរយៈការហ្វឹកហាត់ ប្រមូលផ្តុំអារម្មណ៍ ដោយមានបែបបទត្រឹមត្រូវ, ដោយប្រការនេះ ជួយធ្វើអោយ ការគិតបានបរិសុទ្ធ ។ ឱកាសល្អ ដែលម្នាក់ៗទទួលបាននោះ គឺការរំដោះខ្លួនអោយផុត ពីតណ្ហាទាំងអស់ ហើយនិងការធ្វើអោយខ្លួនគេក្លាយទៅជាបុគ្គលមានគុណធម៌ខ្ពស់ ក្នុងលោក " ។

នៅក្នុងមជ្ឈិមនិកាយនេះទៀត, វិធីរបស់ព្រះពុទ្ធស្តីពីការចាប់ផ្តើមតាម លំដាប់ថ្នាក់, ដំណើររីកចំរើនបន្តិចម្តងៗ, និងការឡើងពីមួយថ្នាក់ទៅមួយថ្នាក់ទៀត ចាប់ពីជំហានទាបឡើងទៅ ត្រូវបានគេប្រៀបប្រដូចទៅនឹងដំណើរសិក្សាក្នុង សិល្បៈបាញ់ធ្នូ និងការរាប់លេខដែរ ។ " កាលណាយើងបង្រៀនសិស្សដំបូង យើង

នាំអោយសិស្សរាប់ មួយ, ពីរ, បី, បួន, ... ហើយចេះតែរាប់បន្តរហូតដល់រយ, ពាន់ " ។ នៅក្នុងឧទានគាថា, ព្រះពុទ្ធបានពន្យល់វិធីបែបនេះ វែងឆ្ងាយទៀតថា " បីដូចជាមហាសាគរក្លាយទៅជាជ្រៅនោះ គឺជ្រៅបន្តិចម្តងៗ ដល់ជ្រៅបំផុត រួចក្លាយទៅជារាក់ជាលំដាប់ ហើយពុំមានជង្ហុកភ្លាមៗនោះទេ, តាមគន្លងនេះដូចគ្នា, នៅក្នុងព្រះធម៌ និងវិន័យនេះ, ការហ្វឹកហាត់ ត្រូវប្រព្រឹត្តទៅតាមលំដាប់ថ្នាក់, ការរៀនសូត្រក៏ប្រព្រឹត្តទៅមួយថ្នាក់ម្តងៗ ហើយមិនអាចឈានទៅមុខភ្លាម ចាប់យកចំណេះដឹងបានទាំងស្រុងនោះទេ " ។

នៅក្នុងទីផ្សេងទៀតនៃគម្ពីរ *មជ្ឈិមនិកាយ*, ព្រះពុទ្ធប្រៀបព្រះអង្គឯងទៅនឹងទ្រមាក់ដំរី ។ តាមរយៈដំរីផ្សាំងហើយ ទ្រមាក់ខិតខំអូសទាញដំរីព្រៃអោយចេញមកក្នុងព្រៃរបោះ រួចទាក់វាយកចេញពីព្រៃ, តាមរយៈការផ្សាំបន្តិចម្តងៗ រហូតដល់ធ្វើអោយដំរីព្រៃនោះ ផ្សាំនឹងបរិដ្ឋាននៃភូមិ ហើយអាចរស់នៅជាធម្មតាជាមួយមនុស្សបាន ។

ដើម្បីសង្ខេបសេចក្តីរៀបរាប់ទាំងនេះ, គេអាចសន្និដ្ឋានបានថា ព្រះពុទ្ធបានប្រគល់ចំពោះគ្រូ ឬសាស្ត្រាចារ្យ នូវការងាររៀបចំ និងការគ្រប់គ្រងលំហាត់ជឿនលឿនតាមលំដាប់ ប្រកបដោយវិធីសាស្ត្រត្រឹមត្រូវ ។ គួរកត់សំគាល់ក្នុងទីនេះថា ហេតុដែលព្រះពុទ្ធអង្គបានអោយទម្ងន់ខ្លាំងទៅលើវគ្គហ្វឹកហ្វឺនខាងផ្លូវចិត្តនោះក៏ព្រោះតែលំហាត់ខាងផ្លូវចិត្ត គឺជាលំហាត់មួយដ៏លំបាក ដែលគេអាចសំរេចបានតែតាមវិធីធ្វើអោយកើនតាមលំដាប់លំដោយ ។ *សីល* គឺជាការរៀបចំត្រឹះប៉ុណ្ណោះ ។ ដោយចាប់ផ្តើមពីការយកចិត្តទុកដាក់ដ៏ធម្មតា, ( ដែលតាមរយៈនេះ គេរៀនអោយចេះភ្ញាក់រលឹកចំពោះអ្វីទាំងអស់ ដែលគេធ្វើនៅគ្រប់ពេលគេដឹងខ្លួន ), ឆ្លងតាមការឃ្លាំមើលលើដង្ហើមចេញ . និងដង្ហើមចូល, ដំណើរនៃការហ្វឹកហាត់ចិត្តបានឈានទៅមុខ តាមរយៈ*សមាធិ* លើប្រធានបទផ្សេងៗមួយចំនួន រហូតដល់ឈានដល់ស្ថាន-

ភាពខាងផ្លូវចិត្តដ៏ខ្ពង់ខ្ពស់ជាង ដែលគេហៅថា *ឈ្យាន* ឬ *ឈាន* ។

ក្នុងទីនេះ ព្រះពុទ្ធបានទទួលស្គាល់អត្ថន័យនៃភាពផ្សេងគ្នា រហូតដល់រវាងបុគ្គលម្នាក់ៗ ហើយបានធ្វើអោយរីកចំរើន នូវវគ្គរៀនសូធ្យសមាធិសម្រាប់បុគ្គលម្នាក់ៗ ដើម្បីជាគុណប្រយោជន៍ដល់សាវ័កទាំងឡាយរបស់ព្រះអង្គ ដោយអនុលោមទៅតាមក្របខ័ណ្ឌចិត្តសាស្ត្ររបស់បុគ្គលម្នាក់ៗ ។ ការប្រមូលផ្តុំចិត្តដែលជាគោលដៅនៃការហ្វឹកហ្វឺន គឺជាមធ្យោបាយតែមួយគត់ ដើម្បីទៅដល់គោលដៅនៃទីបញ្ចប់ ។

ទីអវសាននៃដំណើរសិក្សានេះ គឺបញ្ញា ។ ដោយសារបញ្ញានេះ សាវ័ក ឬសិស្ស បានទៅដល់គោលដៅដ៏ខ្ពស់បំផុត គឺអាណាចក្រអមតៈ ។ នៅក្នុងទីនេះ សាវ័ក ឬសិស្ស ទម្លាក់ចោលនូវអ្វីៗទាំងអស់នៅឯក្រោយ រួមទាំងពាក្យប្រៀន-ប្រដៅរបស់ព្រះពុទ្ធផង ។ ពុទ្ធឱវាទ ត្រូវបានគេប្រើសម្រាប់ជាក្បូនឆ្លងកាត់ទឹកប៉ុណ្ណោះ ពុំមែនជាកម្មសិទ្ធិ ដែលគេត្រូវតែរក្សានោះទេ ។

### *២.២. សង្ឃ ទុកជាសមាគមសិក្សា :*

ក្នុងរង្វង់ពេលប៉ុន្មានខែ ក្រោយការចាប់ផ្តើមបេសកកម្មរបស់ព្រះអង្គមក, ព្រះពុទ្ធបានទទួលស្គាល់ថា ការផ្សព្វផ្សាយព្រះធម៌ ដូចជាព្រះធម៌របស់ព្រះអង្គនេះ ទាមទារអោយមានអង្គការចាត់តាំងមួយសមស្រប និងមាននីតិវិធីត្រឹមត្រូវ ។ ជាមួយនឹងបរិស័ទ ដែលទើបតែមកចូលរួមជាមួយព្រះអង្គ ក្នុងស្ថានភាពជាអ្នកគ្មានផ្ទះ ( ជាបព្វជិត ) នោះ ព្រះពុទ្ធបានបង្កបង្កើតជា *សង្ឃ* គឺជាអង្គការចាត់តាំងមិនទាន់បានត្រឹមត្រូវនៅឡើយទេ កាលពីដំបូងទីនោះ ។ នីតិវិធីដែលព្រះអង្គបានប្រកាន់យក គឺត្រូវបញ្ជូនសមាជិកទាំងហុកសិបរូប ជាក្រុមដំបូងដែលគេទៅកាន់គ្រប់ទិសទី ដើម្បីប្រកាសនូវការកើតមានទ្រឹស្តីថ្មី ។ ការងាររបស់បេសកកម្មដើមទីនេះ បាន

ត្រួសត្រាយផ្លូវសម្រាប់អោយប្រព័ន្ធអប់រំរបស់ព្រះពុទ្ធសាសនាបានលេចធ្លោឡើង ។ នៅក្នុងប្រព័ន្ធអប់រំនេះ ភិក្ខុគឺជាគ្រូដ៏មានសក្តានុភាព អាចបំបួសបព្វជិតថ្មីបញ្ចូលក្នុងផ្លូវ *សង្ឃ* ឬទាក់ទាញអ្នកគាំទ្រជាគ្រហស្ថ ។

ខ្លឹមសារនៃការប្រៀនប្រដៅ ( ការបង្រៀន ) របស់ភិក្ខុទាំងហុកសិបរូបនោះ បានមកពីព្រះពុទ្ធ ដោយរួមទាំងវិធីសាស្ត្របង្រៀនផង ។ ភិក្ខុទាំងនោះបានត្រាប់តាមព្រះពុទ្ធ ក្នុងការប្រើវិធីសាស្ត្របង្រៀននោះ ។ ព្រះពុទ្ធអង្គឯង បានពន្យល់ជាញឹកញយនូវវិធីសាស្ត្រ ព្រមទាំងទស្សនៈ ឬគំនិតនៃការរៀន និងការបង្រៀនរបស់ព្រះអង្គ ។ គម្ពីរ *អង្គុត្តរនិកាយ* មាននិយាយពីការសង្កេតពិនិត្យសម្រាប់ការអប់រំយ៉ាងទូលំទូលាយជាពិសេស ។

ធម្មទេសនា គឺការពន្យល់ផ្សព្វផ្សាយធម៌ ត្រូវបានព្រះអង្គធ្វើអោយរីកចំរើនទៅជាការបង្រៀន, ឯធម្មសវនា គឺការស្តាប់ធម៌ ត្រូវបានគេធ្វើជាទ្រង់ទ្រាយមួយនៃការរៀន ។ នៅក្នុងការកត់សម្គាល់រកភិក្ខុទាំងឡាយមានសមត្ថភាព ដើម្បីបំពេញបេសកកម្មផ្សព្វផ្សាយព្រះធម៌, ព្រះពុទ្ធបានចេញសេចក្តីណែនាំដូចតទៅដែលគេឃើញមានទាំងនៅក្នុង *វិន័យបិដក* ទាំងនៅក្នុង *អង្គុត្តរនិកាយ* ។

" ភិក្ខុមួយរូប ស័ក្តិសមនឹងបំពេញបេសកកម្មមួយបាន កាលណាភិក្ខុនោះមានគុណធម៌ប្រាំបីយ៉ាង ។ តើគុណធម៌ទាំងប្រាំបីយ៉ាងនោះ គឺអ្វីខ្លះ ? នោះគឺ ភិក្ខុនោះជាអ្នកចេះស្តាប់គេ, ជាអ្នកចេះធ្វើអោយអ្នកដទៃស្តាប់ខ្លួន, ជាអ្នកចេះរៀន, ជាអ្នកចេះចងចាំ, ជាអ្នកចេះទទួលស្គាល់គេ, ជាអ្នកចេះធ្វើអោយអ្នកដទៃទទួលស្គាល់ខ្លួន, ជាអ្នកស្ទាត់ជំនាញដើម្បីស្គាល់អ្នកមានវិរិយភាពម៉ឺងម៉ាត់ និងអ្នកគ្មានវិរិយភាពម៉ឺងម៉ាត់, ហើយនិងមិនមែនជាអ្នកបង្កអោយមានការច្របូកច្របល់ ។ ភិក្ខុមួយរូប ដែលជាអ្នកស័ក្តិសមបំពេញបេសកកម្ម កាលណាភិក្ខុនោះមានគុណធម៌ទាំងប្រាំបីប្រការនេះ ។ ឥឡូវនេះ ព្រះសារីបុត្តមានគុណធម៌ទាំងប្រាំបីយ៉ាងនេះ ។

ដោយហេតុនេះ លោកជាអ្នកស័ក្តិសមបំពេញបេសកកម្មហើយ " ។

" លោកមិនរន្ធត់ញាប់ញ័រ កាលណាលោកឋិតនៅចំពោះមុខអង្គប្រជុំធំ, លោកមិនបាត់ខ្សែគំនិតនៃការនិយាយ, ឬស្រពេចស្រពិលលើសេចក្តីអធិប្បាយ ។ លោកនិយាយចេញច្បាស់លាស់ ដោយឥតញញើតញញើម; គ្មានបញ្ហាចោទសួរណាមួយធ្វើអោយលោកតក់ស្លុតបានទេ ។ ភិក្ខុដូចនេះ ស័ក្តិសមបំពេញបេសកកម្មបាន " ។

ចរិតលក្ខណៈដែលលើកឡើងបំភ្លឺហើយនេះ គឺជាចរិតលក្ខណៈរបស់គ្រូ ឬសាស្ត្រាចារ្យដ៏មានសមត្ថភាពម្នាក់ ។

គុណសម្បត្តិរបស់អ្នកស្តាប់ ក៏បានទាក់ទាញអារម្មណ៍របស់គ្រូ ឬសាស្ត្រាចារ្យវិញដែរ ។ ពេលនោះ ព្រះពុទ្ធទ្រង់មានពុទ្ធដីកាថា : មានមនុស្សបែបនេះឃើញមាននៅក្នុងលោក :

« មនុស្សក្បាលទទេ, ជាមនុស្សលេលា ដែលមិនអាចមើលឃើញ,
ទោះបីសេពគប់ញឹកញយជាមួយមិត្តភ័ក្តិ,
ស្តាប់គេនិយាយឮទាំងខាងដើម, កណ្តាល, ចុង,
ក៏មិនអាចក្តាប់ការនិយាយនោះបានសោះ ។
មិនមែនជារបស់មនុស្សនោះទេ ។

គ្រាន់បើជាងមនុស្សនេះ គឺមនុស្សមានខួរក្បាលរាយមាយ,
ជាអ្នកសេពគប់ជាមួយមិត្តភ័ក្តិជាញឹកញយ,
ឮគេទាំងអស់គ្នានិយាយតាំងពីខាងដើម, កណ្តាល, ចុង,
ហើយអង្គុយនៅទីនោះ អាចក្តាប់បានគ្រប់ពាក្យ,

ប៉ុន្តែ, ក្រោកឡើង, គ្មានចងចាំអ្វីសោះ ។ ខួរក្បាលរបស់គេទទេស្អាត ។

គ្រាន់បើជាងមនុស្សទាំងពីរបែបនេះ គឺមនុស្សមានបញ្ញាទូលំទូលាយ ។

គេសេពគប់ជាមួយមិត្តភ័ក្តិជាញឹកញយ,

ឮគេទាំងអស់គ្នាជជែក តាំងតែពីខាងដើម, កណ្តាល, ចុង,

ហើយពេលអង្គុយនៅទីនោះ, អាចក្តាប់បានគ្រប់ពាក្យ,

ចងចាំទាំងអស់ក្នុងខួរក្បាល, ម៉ឺងម៉ាត់, ដាច់ខាត,

ស្ទាត់ជំនាញក្នុងព្រះធម៌ និងក្នុងអ្វីសមស្របទៅនឹងព្រះធម៌ ។

នេះហើយ ជាមនុស្សបញ្ចប់នូវទុក្ខសោកបាន ។ »

ដោយទទួលស្គាល់វិវិធភាពនៃការផ្សេងៗគ្នារបស់បុគ្គលម្នាក់ៗ នៅក្នុងក្រុមមនុស្ស ដែលជួបជុំគ្នាជាអង្គប្រជុំ, ព្រះពុទ្ធតែងតែប្រកាន់យករបៀបដោះស្រាយបញ្ហាជាបុគ្គលៗ ដោយឡែកៗពីគ្នា ។ ព្រះអង្គមិនដែលធ្លាប់ទេសនាដល់អ្នកចង់ស្តាប់ធម៌ ប៉ុន្តែ ឃ្លានអាហារ និងហេវហត់ទេ ។ ដរាបដល់គេបានបរិភោគឆ្អែតហើយសម្រាកស្រួលខ្លួនរួច ទើបព្រះអង្គប្រោសប្រទានធម៌ទេសនា ។ ព្រះអង្គមិនធ្លាប់ជជែកពីអនិច្ចតាធម៌នៃជីវិត ឬអំពីភាពទៀងទាត់នៃមរណភាពជាមួយស្ត្រីណាម្នាក់ ដែលចិត្តថ្លើមរបស់គេពោរពេញដោយសេចក្តីទុក្ខសោក ចំពោះកូនដែលស្លាប់នោះទេ ។ ព្រះអង្គច្នៃបង្កើតលំហាត់ងាយៗ សម្រាប់មនុស្សទាំងឡាយ ដែលមានសមត្ថភាពខួរក្បាលទន់ខ្សោយ ។

ដូចគ្នានេះដែរ, *ធម្មសាកច្ឆា* ក៏ជាមធ្យោបាយមួយជួយបំភ្លឺ, ជួយវាយតម្លៃ, និងជួយវិភាគឱវាទប្រៀនប្រដៅរបស់ព្រះពុទ្ធ ។ ធម្មសាកច្ឆានេះ ក៏ត្រូវបានចាត់ទុកជាសកម្មភាពខាងបញ្ញាដ៏សំខាន់មួយរបស់សង្ឃដែរ ។ ប្រហែលយើងអាច

ក្រឡេកមើលដំណើរប្រព្រឹត្តទៅនៃធម្មសាកច្ឆា អំពីការពិភាក្សាដេញដោលរវាងព្រះនាគសេន និងព្រះរាជាមេនន្ទេរ ( Menander ) ដូចដែលបានរៀបរាប់នៅក្នុងមិលិន្ទបញ្ហា ។ ប្រសិទ្ធភាពនៃដំណើរប្រព្រឹត្តទៅនៃធម្មសាកច្ឆា ដែលទុកជាវិធីសាស្ត្ររៀនសូធ្យនោះ គឺល្អប្រសើរណាស់ ។

ដោយហេតុថា ចំនួនភិក្ខុសង្ឃកាន់តែច្រើនឡើង ហើយក្រុមបរិស័ទទាំងឡាយអាចបានជួបគាល់ព្រះពុទ្ធ តែម្តងម្កាលប៉ុណ្ណោះ, ប្រព័ន្ធស្ថាប័នមួយសម្រាប់ហ្វឹកហ្វឺន និងធ្វើអោយចំណេះដឹង និងបទពិសោធន៍បានថ្មីជានិច្ច ត្រូវតែបង្កើតអោយមានជាការចាំបាច់ ។ ហេតុការណ៍ដែលព្រះសង្ឃពុទ្ធសាសនិក បានដោះស្រាយការងារនេះសំរេចបានដោយប្រសិទ្ធភាពនោះ ថ្វីបើការយល់ដឹងរបស់យើង អំពីប្រតិបត្តិការដ៏ពិតប្រាកដនៅក្នុងកំឡុងសម័យព្រះពុទ្ធគង់នៅនោះ មានកំរិតទាបក៏ដោយ ។ ប៉ុន្តែ យើងមានឯកសារអក្សរសាស្ត្រជាបន្តបន្ទាប់ ដែលបាននិយាយរៀបរាប់ពីសកម្មភាពអប់រំរបស់បេសកជន ជាសង្ឃសាវ័ករបស់ព្រះពុទ្ធ ។

ឱវាទរបស់ព្រះពុទ្ធ ត្រូវបានភិក្ខុសង្ឃរៀនសូធ្យចាំមាត់ ហើយរៀបចំឱវាទទាំងនោះ ទៅតាមទ្រង់ទ្រាយអក្សរសាស្ត្រ ក្នុងចំណាត់ថ្នាក់ដំបូងបំផុតមួយដែលគេអោយឈ្មោះថា *នវង្គសត្ថុសាសនៈ* ( ពាក្យប្រៀនប្រដៅរបស់ព្រះបរមគ្រូមានអង្គប្រាំបួន ) ។ គេបានព្យាយាមរៀបចំតាមបែបផ្សេងទៀតដែរ ។ ក្រោយពេលព្រះពុទ្ធបរិនិព្វានទៅបានបីខែ, សាវ័កទាំងឡាយរបស់ព្រះអង្គ បានធ្វើការសូធ្យផ្ទៀងផ្ទាត់ឡើងវិញនូវពាក្យប្រៀនប្រដៅ ( ព្រះធម៌ ) ទាំងអស់ ហើយកំណត់ចំណាត់ថ្នាក់យ៉ាងម៉ត់ចត់បំផុត ។ ព្រះត្រៃបិដកក្នុងទ្រង់ទ្រាយបច្ចុប្បន្ន ត្រូវបានរៀបចំហើយស្រេចបាច់ នៅក្នុងរង្វង់បីសតវត្សដំបូង ។

ក្នុងអំឡុងកាលព្រះពុទ្ធគង់ធរមាននៅឡើយ, ក៏មានអដ្ឋកថា ( អត្ថាធិប្បាយ ) ស្តីពីឱវាទប្រៀនប្រដៅមួយចំនួន បានចាប់ផ្តើមកើតមានរួចស្រេចទៅ

ហើយ ។ សេចក្ដីសង្ខេបសម្រាប់ស្ងូធ្យអោយចាំមាត់ ក៏ត្រូវបានគេធ្វើអោយកើតមានឡើង ដើម្បីសម្រួលការរំលឹកយកមករៀបរាប់ ។ ប្រព័ន្ធធ្វើតារាងរៀបរៀងតាមលំដាប់អក្សរ ក៏បង្កើតអោយមានឡើងហើយដែរ ។

ភិក្ខុ និងភិក្ខុនីទាំងឡាយ បានរៀបចំ និងសំដែងធម៌តាមបែបរបស់ផងខ្លួន ហើយឈានដល់តែងជាកំណាព្យសរសើរពីមាគ៌ានៃជីវិតរបស់ខ្លួន និងសរសើរពីការដឹកនាំរបស់ខ្លួន និងសរសើរពីការដឹកនាំរបស់ព្រះពុទ្ធ ( សូមអាន ថេរគាថា និងថេរីគាថា ) ។ ភិក្ខុ ភិក្ខុនីទាំងនោះ បានបង្កើតស្នាដៃអក្សរសាស្ត្រ សម្រាប់ការសិក្សាយ៉ាងច្រើនសន្ធឹកសន្ធាប់ ដែលនៅក្នុងនោះ លោកបានធ្វើការសិក្សា និងធ្វើវិភាគយ៉ាងល្អិតល្អន់ នូវពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។ ស្នាដៃទាំងអស់នេះ មិនអាចកើតមានបាននៅក្នុងអំឡុងពេលខ្លី នៃពីរសតវត្សដំបូងបានទេ, ប្រសិនបើមុខងារអប់រំរបស់ព្រះសង្ឃពុទ្ធសាសនិក មិនត្រូវបានចាត់តាំងយ៉ាងរឹងមាំ តាំងតែពីដំបូងទី នៃសកម្មភាពចាត់អោយទៅបំពេញបេសកកម្មរបស់ព្រះពុទ្ធនោះ ។

នេះអាចមានន័យថា សូម្បីនៅក្នុងពេលមុន មានវត្តអារាមកើតឡើងក៏ដោយ ក៏ព្រះសង្ឃបានកើតទៅជាស្ថាប័នអប់រំគោចររួចស្រេចទៅហើយ ។ ការណ៍ពិត គឺនៅក្នុងប្រព័ន្ធបែបនេះហើយដែលភិក្ខុសង្ឃខ្លះ ត្រូវតែមានមុខជំនាញ, ហើយគំនិតបែបនេះ ត្រូវបានសំរេចឡើង ដោយការចង្អុលតែងតាំងភិក្ខុសង្ឃខ្លះ អោយក្លាយជាអ្នកជំនាញខាងទ្រឹស្ដី ( ព្រះអភិធម្ម ), ភិក្ខុសង្ឃខ្លះជាអ្នកជំនាញខាងវិន័យ ( ពោលគឺជាធម្មធរ និងវិន័យធរ ) ហើយភិក្ខុសង្ឃខ្លះទៀត ជាបណ្ឌិតខាងបិដក ឬបិដកទាំងបី ( ត្រៃបិដក ) ។ នៅក្នុងអំឡុងពេលនោះ និន្នាការចង់អោយមានមុខជំនាញដោយឡែក១ ហាក់ដូចជាត្រូវបានពង្រីកយ៉ាងវែងឆ្ងាយ ពីព្រោះយើងបានឃើញបានឮ នៅក្នុងអក្សរសិលាចារឹករបស់ព្រះបាទអសោក មាននិយាយអំពីភិក្ខុ-សង្ឃ ដែលជាអ្នកឯកទេសនៅក្នុងអត្ថបទដោយឡែក១ខ្លះ នៃគម្ពីរព្រះពុទ្ធសាសនា

( ពោលគឺជា ទីឃភាណកៈ, មជ្ឈិមភាណកៈ ... ) ។

*២.៣. វត្តអារាម គឺជាស្ថាប័នមូលដ្ឋានសម្រាប់ការអប់រំរបស់ពុទ្ធសាសនា :*

តាមរយៈដំណើរប្រព្រឹត្តទៅជាលំដាប់លំដោយនេះ, វត្តអារាមបានក្លាយទៅជាស្ថាប័នសម្រាប់ការអប់រំជាប្រពៃណី ដែលត្រូវបានគេរក្សាទុករហូតមកដល់បច្ចុប្បន្ន, សូម្បីវត្តអារាមមួយយ៉ាងតូច តាំងនៅកៀនកោះដាច់ស្រយាលមួយនៃប្រទេសកាន់ពុទ្ធសាសនា ក៏គង់បានទៅជាមណ្ឌលរៀនសូត្រមួយដ៏សំខាន់ដែរ ។ នៅក្នុងការរីកដុះដាលនៃប្រព័ន្ធអប់រំរបស់វត្ត កើតមានគោលការណ៍ដ៏មានអត្ថន័យមួយចំនួន ត្រូវបានគេយកមកអនុវត្ត ។

ភិក្ខុ និងភិក្ខុនី ត្រូវចេះដឹងឱវាទប្រៀនប្រដៅរបស់ព្រះពុទ្ធមួយចំនួនយ៉ាងសមស្រប ។ នៅក្នុងព្រះរាជបញ្ញត្តិ ភាព្រូ ( Bhabru Edict ) ព្រះបាទអសោកបានបង្គាប់អោយភិក្ខុ និងភិក្ខុនី រៀនអត្ថបទប្រាំពីរជាកំហិត ។ សូម្បីពេលបច្ចុប្បន្ននេះ ប្រពៃណីពុទ្ធសាសនានៅក្នុងប្រទេសស្រីលង្កា បានតម្រូវអោយអ្នកណាមួយដែលមានប្រាថ្នាចង់បួសអោយប្រឡងចំណេះដឹង អំពីអត្ថបទជាគ្រឹះនៃគម្ពីរពុទ្ធ-សាសនាមួយចំនួនសិន, ទើបអនុញ្ញាតអោយបួសបាន ។ ភិក្ខុ និងភិក្ខុនីជាថេរៈ ត្រូវចូលរួមជាទៀងទាត់នៅក្នុងការពិភាក្សា សិក្សា ដើម្បីបង្កើនចំណេះដឹង និងការយល់ និងដើម្បីដឹកនាំការប្រតិបត្តិទន្ទឹមគ្នានឹងការទូន្មានប្រៀនប្រដៅអ្នកបួសថ្មី និងសាមណេរទាំងឡាយ ។ វត្តអារាម ត្រូវតាំងខ្លួនជាមជ្ឈមណ្ឌលសម្រាប់ការអប់រំរៀបរយ និងមិនរៀបរយរបស់គ្រហស្ថ ដែលរស់នៅជិតខាងវត្តអារាម ។

នៅប្រទេសកម្ពុជា ក៏កើតមានវិធានការណ៍ប្រហាក់ប្រហែលគ្នានេះដែរ, ប៉ុន្តែមិនជាសូវតឹងរ៉ឹង, ម៉ត់ចត់ពេកទេ ។ នៅក្នុងបណ្តាឆ្នាំមុនប្រទេសកម្ពុជា បានទទួលឯករាជ្យក្នុងឆ្នាំ ១៩៥៣ និងបណ្តាឆ្នាំក្រោយប្រទេសបានឯករាជ្យ បន្តបន្ទិច

មក, យុវជនណា មានបំណងប្រាថ្នាសុំផ្នួសជាសាមណេរ ឬសុំឧបសម្បទាជាភិក្ខុ តែងត្រូវបានគេបញ្ជូនអោយទៅសិក្សាវិន័យធមិអាថ៌ នៅវត្តអស់ពេលជាច្រើនខែ ។ បន្ទាប់មក, កាលបើកិរិតចេះដឹងធមិវិន័យជាមូលដ្ឋានបានសមស្របល្មមហើយ, បេក្ខសមណះនោះ ត្រូវទៅសុំសេចក្ដីអនុញ្ញាតដើម្បីបួស អំពីអាជ្ញាធរឃុំ ដែលនៅពេលនោះ អាជ្ញាធរឃុំ បានធ្វើតេស ( Test ) ជាសំណួរផ្ទាល់មាត់ ចំពោះបេក្ខ-សមណះនោះ លើចំណេះដឹងធមិវិន័យ ជាមូលដ្ឋាន ។ ក្រោយពេលបានបញ្ជាក់ឃើញថា បេក្ខសមណះមានចំណេះដឹងធមិ-វិន័យ សមស្របហើយ ទើបអាជ្ញាធរឃុំចេញលិខិតអនុញ្ញាតអោយបួសដល់បេក្ខសមណះនោះ ។ លិខិតអនុញ្ញាតនោះ មានឈ្មោះថា « បដិញ្ញាណ » ។

ការពោលនេះ មានន័យថា វត្តអារាម គប្បីរៀបចំចាត់ចែងដោយខ្លួនឯងអោយទៅជាស្ថាប័នអប់រំមួយ តាមបែបបទណាមួយ ។ ទីមួយ, វត្តអារាមនោះត្រូវផ្ដល់អោយមានការអប់រំជាដំបូងនិងជាប់លាប់ សម្រាប់ភិក្ខុ និងភិក្ខុនីដោយផ្ទាល់ ។ ក្នុងដំណាក់កាលដំបូង, វត្តអារាមត្រូវរៀបចំអោយមានយ៉ាងហោចណាស់ នូវសេវាកម្មប្រចាំកាលណាមួយជាកំណត់ សម្រាប់អ្នកជំនាញខាងសូធ្យអត្ថបទធមិបានមកសំដែង ។ អ្នកជំនាញគោចរនេះ គឺជាបាតុភូតមួយ មាននៅក្នុងដំណាក់កាលដំបូងប៉ុណ្ណោះ ។ ទីពីរ, វត្តអារាមត្រូវចាត់ចែងការអប់រំសម្រាប់គ្រហស្ថ ។ ការអប់រំនេះអាចកំណត់ត្រឹមតែការសំដែងធមិទេសនាជាទៀងទាត់ តាមកាលកំណត់ ឬជាការសំដែងធមិទេសនាម្ដងម្កាល ស្ដីពីប្រធានបទសាសនា ជាដំណាក់កាលដំបូង ។ ប៉ុន្តែ ចំពោះគ្រហស្ថ ដែលស្វែងរកចំណេះដឹងជ្រាលជ្រៅ ដូចជាត្រៀមខ្លួនដើម្បីចូលបួសទៅក្នុងជួរសង្ឃ ឬដើម្បីចូលរួមក្នុងការសិក្សា សម្រាប់ការកសាងខ្លួន, ការសំដែងធមិទេសនា ត្រូវប្រព្រឹត្តទៅដោយមានវិសាលភាពទូលំទូលាយ ។ មិនយូរប៉ុន្មាន ការប្រៀនប្រដៅសម្រាប់យុវជន ក៏បានក្លាយទៅជាការទទួលខុសត្រូវផ្នែក

សង្គមកិច្ចរបស់ភិក្ខុសង្ឃដែរ ។

ក្នុងការវិវត្តន៍នៃតួនាទីខាងអប់រំ, វត្តអារាមពុទ្ធសាសនា បានកត់ត្រាទុកនូវសកម្មភាពដ៏គួរអោយកត់សំគាល់ និងសមិទ្ធផលមួយចំនួន ដូចខាងក្រោមនេះគឺ :

(i) ពុទ្ធសាសនិកជន, ក្នុងចំណោមក្រុមសាសនាទាំងអស់ នៃប្រទេសឥណ្ឌា, គឺជាមនុស្សដំបូងគេ ដែលបានទទួលស្គាល់នូវសារសំខាន់នៃអក្ខរកម្ម ។ បើប្រមើលមើលទៅក្រោយ នាឆ្នាំ ៨៤ មុនគ្រឹស្តសករាជ, គម្ពីរពុទ្ធសាសនា ត្រូវបានកត់ត្រាជាអក្សរ ( នៅក្នុងប្រទេសស្រីលង្កា ) ហើយការជឿទុកចិត្តពីដំបូងទី ទៅលើទម្លាប់សូត្រផ្ទាល់មាត់ ត្រូវបានកាត់បន្ថយ ។ សិល្បៈនៃការសរសេរ បានធ្វើដំណើរទៅកាន់ប្រទេសជាច្រើន ជាមួយលទ្ធិពុទ្ធសាសនា ។ ការកត់ត្រាដែលប្រើក្នុងគម្ពីរពុទ្ធសាសនាពីដំបូងទី (ឧទាហរណ៍ អក្សរព្រាហ្មី របស់សិលាចារឹកព្រះបាទអសោក) បានក្លាយជាមូលដ្ឋាននៃអក្ខរះរបស់ប្រទេសអាស៊ីជាច្រើន ។ ភិក្ខុសង្ឃ គឺជាអ្នកលើកស្ទួយអក្ខរកម្មដ៏ជាប់លាប់ និងជាអ្នកលើកស្ទួយទម្លាប់អានអក្សរ ក្នុងចំណោមសិស្សគណរបស់លោក ។ អត្ថន័យនៃការព្យាយាមទាំងនេះ ត្រូវបានគេប្រតិបត្តិកាន់តាមរហូតមកដល់សព្វថ្ងៃ ។ ប្រទេសកាន់ពុទ្ធសាសនាទាំងឡាយនៅអាស៊ី ត្រូវបានគេកត់សម្គាល់ឃើញថា បានទ្រទ្រង់អត្រាអក្ខរកម្មខ្ពស់ជាងប្រទេសជិតខាង ដែលមិនកាន់ពុទ្ធសាសនា តាំងពីយូរណាស់មកហើយ មុនពេលការអប់រំជាសកលបានកើតមាន រួចបានក្លាយទៅជាកម្មវត្ថុនៃការយកចិត្តទុកដាក់ខ្ពស់ សម្រាប់ការអប់រំប្រជាពលរដ្ឋរបស់ជាតិនីមួយៗ នោះទៅទៀត ។

(ii) ការស្វែងរកវិជ្ជា ធ្វើអោយភិក្ខុ និងភិក្ខុនីពុទ្ធសាសនិក ចេញទៅបំពេញបេសកកម្មដ៏យូរលង់ ដោយត្រូវឆ្លងកាត់ព្រៃរហោស្ថាននៃទ្វីបអាស៊ីទាំងមូល ។ ឬមួយលោកទាំងនោះ ធ្វើដំណើរទៅដោយផ្ទាល់ខ្លួនឯង ដើម្បីស្វែងរកគ្រូ និងក្បួនច្បាប់ ដូចដែលអ្នកធ្វើដំណើរចិនទាំងឡាយកានធ្វើ, ឬមួយលោកទាំងនោះ

ត្រូវបានប្រទេសឆ្ងាយៗ គេនិមន្តអោយមកធ្វើជាគ្រូ ។ លោកទាំងឡាយខ្លះទៀត ធ្វើដំណើរក្នុងឋានៈជាបេសកជនចាត់តាំងដោយខ្លួនឯង ដោយមានចំណង់ខ្លាំងក្លា ចង់ផ្សព្វផ្សាយព្រះធម៌ទេសនារបស់ព្រះពុទ្ធ ។ គ្រូដ៏អង់អាចក្លាហាន និងអ្នកដែលស្វះស្វែងរកវិជ្ជារាប់រយរូប ត្រូវបានគេកត់ត្រាទុកនៅក្នុងប្រវត្តិសាស្ត្រទាំងឡាយរបស់ប្រទេសអាស៊ី ស្ទើរតែទាំងអស់ ។

តាមឯកសារប្រវត្តិសាស្ត្រចិន គេបានអោយដឹងថា នៅសម័យនគរភ្នំនាឆ្នាំ ៥០៣ នៃគ្រឹស្តសករាជ ព្រះសង្ឃខ្មែរពីរអង្គ គឺព្រះសង្ឃបាលត្ថេរ និងព្រះមន្ទ្រសេនត្ថេរ ត្រូវបានអធិរាជ លាង-វូ-ទី នៃប្រទេសចិន និមន្តអោយទៅបំពេញបេសកកម្មជួយបកប្រែគម្ពីរព្រះត្រៃបិដកទៅជាភាសាចិន ។

ដោយឡែក នៅសម័យកាលក្រោយមកទៀត យើងបានដឹងតាមសិលាចារឹក និងឯកសារផ្សេងៗទៀត ដែលទាក់ទងនឹងប្រវត្តិពុទ្ធសាសនាថា ព្រះមហាក្សត្រខ្មែរពីបុរាណ តាំងពីព្រះបាទ *កៅណ្ឌិន្យជយវរ្ម័ន* រហូតមកដល់ព្រះបាទ *ជយវរ្ម័នទី ៧* បានជ្រះថ្លា និងបានទំនុកបំរុងពុទ្ធសាសនា អោយចំរើនរុងរឿងទាំងខាងសម្ភារៈ ដូចជាវត្តអារាម សេនាសនៈ ជាដើម, ទាំងខាងការសិក្សានៅក្នុងវត្តអារាមនានា ។ លើសនេះទៀត ព្រះអង្គ ( ជយវរ្ម័នទី ៧ ) បានបំបួសព្រះរាជបុត្រពីរអង្គ ជាភិក្ខុភាវៈក្នុងពុទ្ធសាសនា, ភិក្ខុមួយអង្គព្រះនាម *រតនភាណុ* មួយអង្គទៀតព្រះនាម *រតនសិង្ហៈ* ។

មកដល់រជ្ជកាលព្រះបាទ *ជយវរ្ម័នទី ៧* នៅរាជធានីមហានគរ (នគរធំ) ក្នុងគ្រឹស្តសករាជ ១១៨១ ព្រះអង្គមានព្រះសទ្ធាជ្រះថ្លាជ្រាលជ្រៅ, ទ្រង់បានកសាងវត្តអារាម និងទំនុកបំរុងព្រះសង្ឃអោយសិក្សារៀនសូត្រ រហូតទ្រង់បានបញ្ជូនព្រះរាជឱរសមួយព្រះអង្គ អោយទៅសិក្សាវិជ្ជាខាងពុទ្ធសាសនា នៅឯលង្កាទ្វីប ( ស្រីលង្កា ) ។ ព្រះរាជបុត្រអង្គនោះ មាននាមថា *តាមលិន្ទៈ* បានទ្រង់ផ្នួសជាភិក្ខុភាវៈក្នុង

វត្ត *មហាវិហារ* ក្នុងគ្រឹស្តសករាជ ១១៩០[(១)] ។

(iii) វត្តអារាមទាំងឡាយ បានក្លាយទៅជាឃ្លាំងផ្ទុកអត្ថបទសរសេរដោយដៃ និងឯកសារទាំងឡាយដ៏មានតម្លៃ ។ វិហារពុទ្ធសាសនានីមួយៗ មានបណ្ណាល័យរបស់ខ្លួនមួយយ៉ាងសមរម្យ ហើយស្ថាប័នដ៏មានអាយុចំណាស់ៗ ត្រូវបានគេប្រែក្លាយអោយទៅជារតនាគារនៃអក្សរសាស្ត្រ យ៉ាងពិតប្រាកដ ។ បណ្ណាល័យទាំងឡាយរបស់មហាវិហារនៃអនុរាធបុរៈក្នុងប្រទេសស្រីលង្កា និងនាលន្ទាក្នុងប្រទេសឥណ្ឌា មានផ្ទុកសៀវភៅក្បួនច្បាប់ស្តីពីប្រធានបទផ្សេងៗជាច្រើន ដែលតម្កល់ទុកច្រើនសតវត្សមកហើយ ។ គំនរគម្ពីរ, សៀវភៅ ក្បួនច្បាប់យ៉ាងច្រើនសម្បើមក៏គេឃើញមាននៅទុងហ្វាង ( Tung Huang ), ប៉ូតាឡា ( Potala ) និងវត្តអារាមនៅប្រទេសកូរ៉េ ។ នេះក៏ជាភស្តុតាងបញ្ជាក់អោយឃើញនូវទម្លាប់របស់វត្តអារាមពុទ្ធសាសនា ក្នុងការកសាង និងទ្រទ្រង់អោយមានបណ្ណាល័យដ៏ទូលំទូលាយ សម្រាប់បណ្តុះបណ្តាលការអប់រំ ។

(iv) សកម្មភាពអប់រំ ដែលកាលដើមឡើយ កំណត់ត្រឹមតែរៀនចំណោះវិជ្ជាខាងសាសនា ក៏ត្រូវបានពង្រីកក្នុងពេលក្រោយមកទៀត អោយទៅជាសកម្មភាពសិក្សា គ្របដណ្តប់ទៅលើចំណេះវិជ្ជាទាំងអស់ ។ ចាប់ផ្តើមពីការសិក្សាភាសាសាស្ត្រ និងអក្សរសាស្ត្រ, វត្តអារាមបានពង្រីកវិស័យសិក្សារបស់ខ្លួន ទៅដល់ការសិក្សាខាងឱសថសាស្ត្រ ហោរាសាស្ត្រ និងគណិតសាស្ត្រ ។ វត្តអារាមណាដែលតាំងទីនៅកណ្តាលគេ ត្រូវតែបានពង្រីកអោយទៅជាស្នូល នៃមហាវិទ្យាល័យនានា (នាលន្ទា គឺជាឧទាហរណ៍ដ៏សំខាន់មួយ) ហើយទាក់ទាញអ្នកប្រាជ្ញបណ្ឌិតទាំងឡាយមកពីគ្រប់ទិសទីនៃពិភពពុទ្ធសាសនា ។

(១) អាន «ពុទ្ធសាសនានៅប្រទេសកម្ពុជាសង្ខេប» . ហួត តាត សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក គណៈមហានិកាយ ទំព័រ ៤ ៥ ៦ ។

(v) វត្តអារាមទាំងឡាយ បានអភិវឌ្ឍទៅជាមជ្ឈមណ្ឌល សម្រាប់សកម្មភាពអក្សរសាស្ត្រ ។ ចាប់ផ្ដើមពីការបង្រៀនអក្ខរកម្ម, ការខំខ្នះខ្នែងត្រូវបានកំណត់ត្រឹមតែការធ្វើអធិប្បាយពន្យល់អោយចេះអាន សរសេរអក្សរ ។ ក្នុងពេលក្រោយមក វត្តអារាមទាំងនោះបានក្លាយទៅជាមជ្ឈមណ្ឌលសម្រាប់ធ្វើការពិសោធន៍នូវរូបភាពថ្មីៗ សម្រាប់បង្រៀនអក្សរសាស្ត្រ ។ ស្មារតីខំស្វែងរកមធ្យោបាយថ្មីៗដើម្បីផ្សព្វផ្សាយព្រះធម៌ ត្រូវបានគេបង្ហាញអោយឃើញជាគំរូយ៉ាងច្បាស់រួចហើយ ដោយហេតុថា ព្រះសង្ឃពុទ្ធសាសនិកមិនស្ទាក់ស្ទើរ ហើយមិនខ្លាចសាកល្បងបង្រៀននូវរូបភាពអក្សរសាស្ត្រថ្មីណាមួយ សម្រាប់អក្សរសាស្ត្រសាសនាឡើយ ។ កំណាព្យ និងរឿងល្ខោនជាភាសាសំស្ក្រឹតល្អៗ ទាំងពីរបែបនេះ ត្រូវបានព្រះសង្ឃយកមកប្រើតាំងតែពីដើមទី សម្រាប់ធ្វើអោយមានការអភិវឌ្ឍន៍ ឧទាហរណ៍ *ពុទ្ធ-ចរិត, សុន្ទរានន្ទកាវ្យៈ* និង *សារិបុត្រប្រករណៈ* របស់លោក *អស្វឃោសៈ* ។ ការពិសោធន៍ផ្សាយរូបភាពអក្សរសាស្ត្រថ្មីៗ ត្រូវបានស្ថាប័នវត្តអារាមបន្តធ្វើរហូតមកដល់សព្វថ្ងៃនេះ ។ ជាឧទាហរណ៍ជាក់ស្ដែង, នៅប្រទេសកម្ពុជាយើង អក្សរសាស្ត្រសម័យថ្មីជាច្រើន ផុសចេញពីវត្តអារាម គឺដូចជា សាស្ត្រាច្បាប់, សាស្ត្រាល្បែង, សាស្ត្រាទេសន៍ ជាច្រើន ។ ល ។

សាស្ត្រាល្បែងមួយចំនួន ដែលមានដំណើរកំសត់ ត្រូវចំផ្នត់អារម្មណ៍កំសត់ទុក្ខសោករបស់ប្រជាពលរដ្ឋ ដូចជារឿងព្រះជិនវង្ស, រឿងវរវង្ស សូរវង្ស, រឿងសង្ខសិល្បជ័យ ជាដើម ត្រូវបានគេយកទៅច្នៃលេងជារឿងល្ខោននៅលើឆាក និងបានទទួលស្វាគមន៍គាប់ចិត្តពីប្រជាពលរដ្ឋយ៉ាងក្រៃលែង ។

ក្រៅពីរឿងសាស្ត្រាល្បែង, ក៏មានអក្សរសិល្ប៍ពុទ្ធនិយមមួយចំនួន ដូចជារឿងក្នុងបញ្ញាសជាតក, រឿងក្នុងទសជាតក ក៏ត្រូវបានគេជ្រើសរើសយករឿងពិ-រោះៗ ដើម្បីអោយព្រះសង្ឃទេសនាក្នុងពិធីបុណ្យធំៗ តាមប្រពៃណីរបស់ពុទ្ធ-

សាសនាបែបខ្មែរ ជាឧទាហរណ៍ បុណ្យឆ្លងព្រះវិហារ, បុណ្យចូល-ចេញវស្សា, បុណ្យភ្ជុំបិណ្ឌ ឬបុណ្យសាលា ( គឺបុណ្យដែលគេប្រារព្ធគាស់សពឪពុកម្ដាយយកឆ្អឹងមកបូជា រួចរើសយកសំណល់ឆ្អឹងដាក់ក្នុងក្រឡ ឬថូ ដើម្បីធ្វើបុណ្យទក្ខិណានុប្បទានឧទ្ទិសកុសលដល់លោកអ្នកដ៏មានគុណទាំងនោះ ចំនួនច្រើនថ្ងៃ ខ្លះបីយប់ បីថ្ងៃ, ខ្លះប្រាំពីរយប់ ប្រាំពីរថ្ងៃ មុននឹងយកអដ្ឋិធាតុនោះ ទៅបញ្ចុះក្នុងចេតិយ៍នៅក្នុងទីវត្តអារាមណាមួយ ដែលបានសាងសង់ទុករួចហើយ ) ។ ក្នុងពិធីបុណ្យធំៗបែបនេះ, គេពុំសូវលោះខានលើកយករឿងមហាវេស្សន្តរ ឬរឿងក្នុងមហាជាតក៏ មកទេសនាឡើយ ។ រីឯក្រុមល្ខោនបាសាក់ ឬក្រុមល្ខោននិយាយ ក៏ចូលចិត្តលើកយករឿងមហាវេស្សន្តរ ទៅសំដែងនៅលើឆាកដែរ ។ រឿងមហាវេស្សន្តរ បានជះឥទ្ធិពលយ៉ាងជ្រៅទៅក្នុងសតិអារម្មណ៍ប្រជាពលរដ្ឋខ្មែរ ស្ដីពីទានបរិច្ចាគ ។ ដោយសារឥទ្ធិពលនេះ ទើបគេសង្កេតឃើញកើតឡើងនូវអគារសិក្សា, មន្ទីរព្យាបាលរោគ, សាលាសំណាក់ ជាដើម ដែលជាអំណោយសប្បុរសរបស់ពុទ្ធសាសនិកជន ។

(vi) វត្តអារាម បានធ្វើអោយល្អសុក្រឹត នូវសិល្បៈចម្លាក់ និងសិល្បៈគំនូរ ដើម្បីជាជំនួយចក្ខុទស្សន៍យ៉ាងស័ក្តិសិទ្ធិ សម្រាប់បង្រៀនរឿងនិទាន និងផ្សាយព្រះធម៌របស់ព្រះពុទ្ធ ។ ការប្រើសិល្បៈបែបនេះ មានគុណប្រយោជន៍ពីរយ៉ាង គឺសម្រាប់បង្ហាញសោភណភាពផង និងសម្រាប់ជំនួយការអប់រំផង ។ នេះជានវកម្ម ( Innovation ) ដ៏សំខាន់មួយរបស់ពុទ្ធសាសនា ។ ម្យ៉ាងទៀត វិធីសាស្ត្របែបនេះ បានបំបាត់ការចុញទ្រាន់ពីដំបូងទី ចំពោះការពិពណ៌នា អំពីព្រះពុទ្ធក្នុងទ្រង់ទ្រាយជាមនុស្ស ដោយប្រើរូបភាព ជានិមិត្តរូបជាជំនួសវិញ ។

សព្វថ្ងៃ, វិហារពុទ្ធសាសនា គឺជាកន្លែងរក្សា និងជាកន្លែងលើកស្ទួយទេពកោសល្យសិល្បៈក្នុងស្រុក ។ រូបភាពលើជញ្ជាំងវិហារ គឺជាប្រភពដើមដែលផ្ដល់ពតិមានខាងសាសនា និងផ្ដល់ការអប់រំដល់មនុស្សទូទៅ ។

(vii) វត្តអារាម បានដើរតួនាទីនាំមុខក្នុងសហគមន៍ ក្នុងឋានៈជាមណ្ឌលផ្សាយចេញនូវគំនិត និងបច្ចេកទេសថ្មីៗ ។ លោកសង្ឃដឹកនាំប្រជាជនកសាងផ្លូវ, មន្ទីរពេទ្យ, មណ្ឌលក្មេងកំព្រា និងបង្កើតភាពសប្បាយរីករាយដទៃទៀត ដែលប្រព្រឹត្តទៅនៅក្នុងវត្តអារាមសម្រាប់សហគមន៍ ។ លោកបានលើកស្ទួយការងារសហប្រតិបត្តិការក្នុងកសិកម្ម និងសំណង់ សម្រាប់បំរើសាធារណជន និងឯកជន ។ វត្តអារាម នៅតែបន្តតួនាទីជាកន្លែងជួបជុំប្រជាជន ដើម្បីចាត់តាំងសកម្មភាពអភិវឌ្ឍសហគមន៍ នៅក្នុងប្រទេសកាន់ពុទ្ធសាសនានានា ។ លោកសង្ឃនៅតែបានតាំងខ្លួនជានិច្ច ជាអ្នកផ្ដើមគំនិតការងារ, ជាអ្នកនាំធ្វើការងារ, និងជាអ្នកជំរុញរាល់ការងារ ។

(viii) តាមរយៈបុណ្យទានរបស់ខ្លួន, វត្តអារាមក៏បានដើរតួនាទីជាអ្នកលើកស្ទួយសិល្បៈប្រជាប្រិយដែរ ទោះបីជាសិល្បៈតុបតែងលំអប្រើប្រាស់សម្ភារៈក្នុងមូលដ្ឋានរបស់ខ្លួន ដូចជា ស្លឹកចេក ស្លឹកដូង, ឫស្សី ... ក្ដី ឬទោះបីជាសិល្បៈសំដែងតាមរូបភាពជារបាំ និងជារឿងល្ខោនក្ដី ។ តន្ត្រីប្រជាប្រិយ ក៏បានទទួលការលើកទឹកចិត្តយ៉ាងច្រើន អំពីពិធីបុណ្យទានទាំងនោះដែរ ។ ក្រៅពីការចិញ្ចឹមចិត្តប្រជាជនអោយចូលរួមរក្សា និងអោយចេះស្រឡាញ់មរតកវប្បធម៌ជាតិ, ពិធីបុណ្យទាន ពិធីដង្ហែក្បួន, ការតាំងពិព័រណ៍ ហើយនិងពិធីដទៃទៀត ដែលរៀបចំឡើង និងប្រព្រឹត្តទៅនៅក្នុងវត្តអារាម បានជួយជំរុញអោយមានការរីកចំរើនដល់សិល្បករ, អ្នកភ្លេង, អ្នករបាំ និងអ្នកលេងល្ខោនអាជីពទាំងអស់ ។ ជាទូទៅ វត្តនៅក្នុងភូមិតែងជួយឧបត្ថម្ភដល់គ្រួសារណា ដែលបន្តហ្វឹកហ្វឺនសិល្បៈទាំងនេះ ។ បន្ថែមលើនេះ, បុណ្យទានទាំងអស់នេះ ក៏បានជួយអោយសិល្បកម្មក្នុងស្រុក មានដំណើរការល្អដែរ ។

នៅប្រទេសកម្ពុជាយើង, វង់ភ្លេងពិណពាទ្យ, វង់ភ្លេងផែយ៉ាំ និងនៅក្នុងខេត្តខ្លះ វង់ភ្លេងយីកេ ឬវង់ភ្លេងត្រុដិ ច្រើនតែជារបស់វត្ត ហើយត្រូវបានវត្តជួយ

បង្កបង្កើត និងឧបត្ថម្ភ រហូតបានដល់ក្លាយទៅជាក្រុមសិល្បៈអាជីពផង ក៏សឹងមាន ។ ក្រៅពីនេះ មានវត្តអារាមនៅតាមដងទន្លេមួយចំនួន បានជំរុញ និងលើកទឹកចិត្តការកសាងទូក-ង ឬទូកម្ចង ដើម្បីលើកកំពស់ស្មារតីកីឡាករក្នុងការប្រកួតប្រជែងផង និងដើម្បីបង្ហាញនូវវិរភាពអង់អាច និងការប៉ិនប្រសប់របស់សិល្បៈជាមរតកនៃបុព្វបុរសខ្មែរ ក្នុងការធ្វើសឹកសង្គ្រាមតាមទូក ឬសំពៅ កាលពីអតីតកាលផង ដូចមានរូបចម្លាក់នៅប្រាសាទបាយ័ន ជាសក្ខីភាពស្រាប់ ។

## *២.៤- ការរំដោះបញ្ញាខាងស្មារតីរបស់ពុទ្ធសាសនា គឺជាការលើកទឹកចិត្តដល់ការធ្វើអោយវិស័យអប់រំរីកចំរើន :*

កត្តាដ៏ចម្បងមួយ នៃអាកប្បកិរិយារបស់ពុទ្ធសាសនា ចំពោះការរៀន, ការបង្រៀន និងការស្រាវជ្រាវ គឺជាការលើកទឹកចិត្តអោយមានសេរីភាពរូបនីយកម្មខាងបញ្ញាស្មារតី ដែលព្រះពុទ្ធអង្គទ្រង់បានសំដែងទុកមក ។ ឱវាទទូន្មានរបស់ព្រះអង្គចំពោះសាវ័កទាំងឡាយ, ដូចបានចង្អុលបញ្ជាក់ខាងដើមរួចហើយ, គឺអោយចៀសវាងការជឿដោយឥតពិចារណាទៅតាមទម្លាប់ប្រពៃណី និងគម្ពីរនិយម ហើយសូម្បីតែឱវាទប្រៀនប្រដៅរបស់ព្រះអង្គ ក៏អោយដាក់ក្រោមការត្រួតពិនិត្យរិះគន់ដែរ ( សូមសិក្សាកាលាមសូត្រ បន្ថែម ) ។

យោងតាមទស្សនវិស័យសង្គម, ព្រះអង្គបានលើកស្ទួយសមត្ថភាពរបស់បុគ្គលម្នាក់ៗ ដោយមិនគិតពីវណ្ណៈ, ឋានៈ, ជំនឿ ឬភេទទេ ដើម្បីបានសម្រេចគោលដៅដ៏ខ្ពស់បំផុតខាងបញ្ញា និងស្មារតីនៃមាគ៌ារំដោះផុតទុក្ខរបស់គេ តាមមធ្យោបាយអនុវត្តន៍ជាក់ស្តែង និង ប្រកបដោយសេចក្តីព្យាយាមមុតមាំ ។ យោងតាមទស្សនវិស័យខាងបញ្ញា, ព្រះអង្គបានបរិហាររិះគន់ទាំងអភិរក្សនិយម ទាំងការទទួលយកដោយស្ងាត់ស្ងៀម នូវគំនិតណាមួយក្រោមអានុភាព ឬអំណាចគាបសង្កត់របស់

នវណាមួយ ។ នៅក្នុងវិនយប្បញ្ញត្តិ សម្រាប់ភិក្ខុទាំងឡាយ មានសេចក្តីចែងទុកមក ថា សិស្ស" គប្បីតស៊ូដោយការជជែកតវ៉ាចំពោះទ្រឹស្តីខុសឆ្គងឯណាមួយ ដែលគ្រូ បានតម្រូវអោយប្រកាន់យក ឬបានប្រើអោយអ្នកដទៃអោយប្រកាន់យក " ។ ការ គូសបញ្ជាក់នេះ គឺបានសំដៅដល់ការជំរុញអោយចេះវិភាគ និងអោយចេះពិនិត្យ អង្កេត នូវទស្សនៈ ទ្រឹស្តីណាមួយ មុននឹងទទួលជឿប្រតិបត្តិតាម ឬក៏មិនទទួលជឿ, មិនប្រតិបត្តិតាម ។

គោលការណ៍ទាំងឡាយនេះ បានផ្តល់ចំពោះការអប់រំរបស់ពុទ្ធសាសនា នូវ ការបើកចំហដ៏សំខាន់ ដែលទាក់ទងទាំងសិស្សគណ និងទាំងអត្ថន័យនៃវិជ្ជា ត្រូវ បានរៀន ឬបង្រៀន ។ វត្តអារាមទាំងឡាយ ត្រូវបានគេបើកទ្វារចំហសម្រាប់មនុស្ស គ្រប់ថ្នាក់ ហើយជាពិសេសនោះ បានផ្តល់លទ្ធភាពដល់អ្នកអន់ថយខាងសេដ្ឋកិច្ច និង ខាងសង្គម អោយអាចចូលទៅសិក្សារៀនសូត្របាន ។ សេរីភាពខាងការវិភាគ និង ខាងការពិនិត្យអង្កេត, នៅពេលដាក់ឱវាទប្រៀនប្រដៅរបស់ព្រះពុទ្ធ ក្រោមការមិន យល់ស្រប, ក្រោមការច្នៃធ្វើអោយថ្មី, ក្រោមការបកស្រាយថ្មី, ហើយសូម្បីតែ ក្រោមការបកស្រាយខុសក៏ដោយចុះ, ក៏បានជួយបណ្តុះខាងស្មារតីសន្តោស ដែល បានជ្រួតជ្រាបនៅក្នុងប្រព័ន្ធអប់រំរបស់ពុទ្ធសាសនាដែរ ។ មិនត្រឹមតែបានបញ្ចូលនូវ ការសិក្សាប្រព័ន្ធសាសនា និងទស្សនវិជ្ជា ជាបដិបក្ខនៅក្នុងកម្មវិធីសិក្សានៅក្នុងថ្នាក់ រៀន, និងមុខវិជ្ជាទាំងឡាយដែលមិនទាក់ទងដល់គោលបំណងសាសនាប៉ុណ្ណោះទេ, ប៉ុន្តែ នៅបានអនុញ្ញាតអោយបញ្ចូលសកម្មភាពសិក្សាទាំងឡាយនោះ ប្រព្រឹត្តទៅនៅ ក្នុងវត្តអារាមពុទ្ធសាសនាទាំងឡាយថែមទៀត ។ គឺសកម្មភាពទាំងអស់នោះហើយ ដែលបណ្តាលអោយកើតមាននិកាយ និងគណៈពុទ្ធសាសនាយ៉ាងច្រើន ។

( នៅមាន ត )

# កឋិនទេសនា

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

## នមត្ថុ រតនត្តយស្ស

សូមនមស្សការចំពោះព្រះរតនត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ដោយសេចក្ដីគោរព ។

*ឥតោ បរំ* តពីបទនមស្សការនេះទៅ អាត្មាភាពនឹងសំដែងអំពីកឋិន ព្រម ទាំងអានិសង្សនៃកឋិន ដើម្បីជាទីសណ្ដាប់ ដូចតទៅ ៖

ពាក្យថា *កឋិន* បើប្រែតាមធាតុថា កិរិយារស់នៅដោយក្រ ១ កិរិយា ពោលសរសើរ ១ ។ ឯអត្ថថា « កិរិយារស់នៅដោយក្រ » នោះ លោកប្រៀបដូចជា ស្នឹង ដែលបុគ្គលកាត់យកឈើស្រស់មកបោះធ្វើជាស្នឹង ។ ឈើស្នឹងនោះ រស់ដុះ លូតលាស់ឡើង ដោយក្រក្រៃពេក មានឧបមាយ៉ាងណា កឋិនដែលកើតឡើងពេញ ទីជាកឋិនបាន ដោយក្រពន់ពេក ក៏មានឧបមេយ្យ ដូច្នោះដែរ ។

ចំណែកអត្ថថា « កិរិយាពោលសរសើរ » នោះ គឺវត្តមានវិសេស ដែល ព្រះអរិយបុគ្គលទាំងឡាយ មានព្រះពុទ្ធជាដើម តែងពោលសរសើរថា មានផល វិសេស សម្រេចដល់បុគ្គលទាំងពីរខាង គឺខាងទាយកអ្នកឱ្យ ក៏បានអានិសង្សច្រើន ខាងបដិគ្គាហកៈ គឺភិក្ខុអ្នកទទួលក្រាលកឋិន និងបុគ្គល-គណៈ ឬសង្ឃ ដែលអនុ-មោទនាកឋិន ក៏បានសម្រេចអានិសង្សទាំង ៥ រហូតដល់អស់កឋិនក្ខេត្ត ( គឺរហូត ដល់ពេញបូរមី ខែផល្គុន ) ។

កឋិនស័ព្ទនេះ បើប្រែតាមអត្ថមាន ២ គឺ « កាន់យកព្រម » ១ « ស្ថិត ស្ថេរ » ១ ។

ដែលថា កាន់យកព្រម គឺភិក្ខុអ្នកក្រាល ឬអ្នកអនុមោទនា អាចកាន់យកអានិសង្ស ៥ ។ ដែលថា ស្ថិតស្ថេរនោះ គឺភិក្ខុអ្នកក្រាល និងអ្នកអនុមោទនាកឋិនអាចធ្វើអានិសង្ស ៥ ឱ្យមានទីបំផុតត្រឹមថ្ងៃ ១៥ កើត ខែផល្គុន ឬថា តាំងនៅក្នុងខាងក្នុងនៃកឋិនក្ខេត្ត ។ បានសេចក្តីថា បើភិក្ខុបានក្រាលគ្រង ឬអនុមោទនាកឋិនតាំងពីថ្ងៃ ១ រោច ខែអស្សុជទៅ អានិសង្សកឋិនទាន មាន ៥ ខែ, បើបានក្រាល ឬអនុមោទនាកឋិន តាំងពីថ្ងៃ ១៥ កើត ខែកត្តិកទៅ នោះអានិសង្សទាំង ៥ តាំងនៅអស់កំណត់ហោមន្តរដូវត្រឹមតែ ៤ ខែ ។

ឯរឿងកឋិននេះ មាននិទានពិស្តារក្នុងកឋិនក្ខន្ធកៈ ដែលព្រះសង្គីតិ-កាចារ្យទាំងឡាយ មានព្រះមហាកស្សបត្ថេរជាប្រធាន បានសង្គាយនាទុកមកថា ៖

សម័យមួយ សម្តេចព្រះភគវន្តមុនី ស្តេចគង់សម្រាន្តក្សាន្តព្រះឥរិយាបថអភិរមដោយព្រហ្មវិហារ នៅក្នុងព្រះមហាវិហារជេតពន សុគន្ធកុដី ជាអារាមដែលអនាថបិណ្ឌិកសេដ្ឋីសាងថ្វាយ ពុំឆ្ងាយពីក្រុងសាវត្ថី ។ គ្រានោះ មានភិក្ខុ ៣០ អង្គមានប្រក្រតីគង់នៅក្នុងនគរបាវា បបួលគ្នាត្រាច់គោចរទៅកាន់នគរសាវត្ថី ដើម្បីចូលទៅគាល់ព្រះបរមសាស្តា ។ ទើបតែមកដល់ពាក់កណ្តាលផ្លូវ គាប់ជួនជាដល់ថ្ងៃចូលព្រះវស្សា នឹងស្រូតដំណើរទៅមុខទៀតមិនទាន់ ក៏នាំគ្នាចូលទៅអាស្រ័យចាំវស្សា នៅក្នុងក្រុងសាកេត ជាខេត្តចំណុះនគរសាវត្ថី អស់ចំនួន ៣ ខែ ។ លុះដល់ចេញវស្សា បវារណាហើយ ភិក្ខុទាំង ៣០ រូបនោះ ក៏នាំគ្នាលាចេញពីសាកេតបុរី ធ្វើដំណើរបន្តទៅកាន់នគរសាវត្ថី ; ទទួលរដូវនោះ នៅមានភ្លៀងរលឹមជោគជាំនៅឡើយ តាមផ្លូវដែលទៅមក ពោរពាសដោយទឹក និងភក់ល្បាប់ រអិលប៉ប្រិចប៉ប៉ាច់ ។ ឯចីវរ ស្បង់ សង្ឃាដី នៃភិក្ខុទាំងនោះ ក៏ជិតជាមប្រឡាក់ ទទឹកជោកដោយទឹកភ្លៀងពៃរវៀង១ខ្លួន ទាំងសរីរកាយនៃភិក្ខុទាំងនោះ ក៏នឿយហត់ មានសភាពទ្រុឌទ្រោមជាខ្លាំង ។ លុះដល់នគរសាវត្ថីហើយ ក៏នាំគ្នាចូលថ្វាយបង្គំគាល់សម្តេចព្រះជិនស្រី

ក្នុងព្រះជេតពនមហាវិហារ ។ ព្រះមានព្រះភាគ ជាអគ្គបុគ្គល ស្ដេចទ្រង់យល់ភិក្ខុទាំង ៣០ រូបនោះ ដែលមានត្រៃចីវរសៅហ្មង ដោយទឹកភ្លៀងទទឹកជោកជ្រោះហើយ ទ្រង់មានបន្ទូលរាក់ទាក់ទៅរកភិក្ខុទាំងនោះ ប្រកបដោយព្រះមហាករុណា ក្នុងវេនេយ្យពុទ្ធបរិស័ទ ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលអំពីសេចក្ដីលំបាករបស់ខ្លួន ដែលមកតាមផ្លូវ ដោយសព្វគ្រប់តាមដំណើរ ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សំដែងនូវធម្មីកថា ប្រារព្ធអំពីសំសារៈវដ្ដ ដែលមិនមានទីបំផុត ប្រោសប្រទានភិក្ខុទាំងនោះ ។ លុះចប់ហើយ ភិក្ខុទាំងនោះ ក៏បានលុះព្រះអរហត្ដទាំងអស់អង្គ ហើយនាំគ្នាថ្វាយបង្គំលាព្រះមបរមសាស្ដា ទៅកាន់ទីលំនៅរបស់ខ្លួនអស់ទៅ ។

បន្ទាប់ពីនោះមក ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា ប្រសិនបើតថាគតបានតែងតាំងកឋិនត្ថារកិច្ចទុកអំពីគ្រាមុន ម្ល៉េះភិក្ខុទាំងឡាយនោះ នឹងបានលះចីវរ ១ ទុកនៅទីកន្លែង ជាប់មកតែស្បង់ និងចីវរប៉ុណ្ណោះ នឹងមានអត្ដភាពស្រាល មិនលំបាកយ៉ាងនេះសោះឡើយ ហើយកឋិនត្ថារកិច្ចនេះសោត ព្រះពុទ្ធទាំងឡាយរាល់ព្រះអង្គ ក៏តែងតែទ្រង់អនុញ្ញាតដល់សាវ័ក មិនដែលលះបង់ផង ។

លុះព្រះមានព្រះភាគទ្រង់ព្រះតម្រិះយ៉ាងនេះហើយ ទើបទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកជួបប្រជុំ ហើយទ្រង់អនុញ្ញាតកឋិនត្ថារកិច្ច ដោយព្រះពុទ្ធដីកាថា៖ *អនុជានាមិ ភិក្ខវេ វស្សំ វុដ្ឋានំ ភិក្ខូនំ កឋិនំ អត្ថរិតុំ ។ អត្ថតកឋិនានំ វោ ភិក្ខវេ បញ្ច កប្បិស្សន្តិ* ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យពួកភិក្ខុ ដែលបានចាំវស្សាអស់ត្រៃមាសហើយ ក្រាលកឋិនបាន, ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុទាំងឡាយដែលបានក្រាលគ្រងកឋិន និងភិក្ខុដែលបានអនុមោទនាកឋិននោះរួចហើយ នឹងបានសម្រេចអានិសង្ស ៥ ប្រការ ។

ឯដំណើរ ឬប្រភពដែលនាំឱ្យកើតមានកឋិនឡើងក្នុងពុទ្ធសាសនា ដូច

ន័យដែលបានពណ៌នានេះឯង ។

ក្នុងខន្ធកៈវិន័យ លោកពោលថា កឋិនទាន ជាទានមានផលានិសង្សច្រើន ដល់ទាយកទាយិកាអ្នកឱ្យផង ដល់ភិក្ខុសង្ឃអ្នកក្រាលគ្រង អនុមោទនាផង ។ ម្យ៉ាងវិញទៀត កឋិនទាននេះ ជាទានមានកាលបរិច្ឆេទ អាចធ្វើបានតែពីថ្ងៃ ១ រោច ខែអស្សុជ ដល់ថ្ងៃ ១៥ កើត ខែកត្តិក នៃឆ្នាំនីមួយៗប៉ុណ្ណោះ បើផុតពីរយៈកាលនេះទៅ មិនអាចនឹងធ្វើបានទេ ។ ចំណែកសង្ឃទានក្តី បាដិបុគ្គលិកទានក្តី ជាទានមិនមានកំណត់កាលបរិច្ឆេទឡើយ ទាយកទាយិកាដែលមានសទ្ធាជ្រះថ្លា ចង់ធ្វើពេលណាក៏បាន ចំពោះអ្នកណាមួយក៏បាន មិនមានការហាមប្រាម ដូចកឋិនទានទេ ។ ដោយកឋិន ជាទានពិសេសប្លែកពីទាននានា អ្នកធ្វើ និងអ្នកទទួល ត្រូវតែមានការឈ្លាសវៃក្នុងការធ្វើ និងការទទួល ។

បដិគ្គាហកៈ គឺភិក្ខុអ្នកទទួល កាលបើពុំយល់ដឹងនូវបុព្វកិច្ច ៧ ប្រការ គឺការកាត់ដេរ គក់ ជ្រលក់ ជាដើម មិនយល់ដឹងនូវអានិសង្សទាំង ៥ និងមាតិកា ទាំង ៨ មានបក្កមនន្តិកា ការចៀសចេញចាកកឋិនាវាស ជាដើម ក៏មិនអាចនឹងធ្វើកឋិនត្ថារកិច្ចនោះបានឡើយ ។

មួយទៀត លោកពោលក្នុងកឋិនក្ខន្ធកៈនោះថា សំពត់ចីវរពុំត្រូវខ្នាត ខាតមាត្រា គឺធំ ឬវែងហួសប្រមាណជាងចីវរព្រះសុគត ១ សំពត់ចីវរនោះពុំបានកាត់ជាកន្សៀងតូច-ធំ ឱ្យជាបញ្ចខ័ណ្ឌ (មានកន្សៀង១០) សត្តខ័ណ្ឌ (មានកន្សៀង១៤) នវខ័ណ្ឌ (មានកន្សៀង១៨) ឬជាឯកាទសខណ្ឌ (មានកន្សៀង២២) ជាដើម ១ ក៏ក្រាលមិនឡើងជាកឋិន ។

ចំណែកពណ៌ចីវរនោះទៀតសោត ក៏ព្រះសម្មាសម្ពុទ្ធ ទ្រង់អនុញ្ញាតទុកក្នុងចីវរក្ខន្ធកៈថា ៖ *អនុជានាមិ ភិក្ខវេ ឆ រជនានិ មូលរជនំ ខន្ធរជនំ តចរជនំ បត្តរជនំ បុប្ផរជនំ ផលរជនំ* ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទឹកជ្រលក់ ៦

យ៉ាងគឺ ទឹកជ្រលក់កើតពីមើម, - កើតពីដើម, - កើតពីសំបក, - កើតពីស្លឹក, - កើតពីផ្កា, - កើតពីផ្លែ ។

ទឹកជ្រលក់ ៦ យ៉ាងនេះ សំដៅយកពណ៌លឿងស្រអាប់ តួយ៉ាងពណ៌ជ្រលក់ខ្លឹមខ្នុរច្រើនលើកច្រើនដង បានពណ៌បែបណា ពណ៌បែបនោះ ហៅថា ទឹកអម្ពត់ សមគួរដល់សមណៈប្រើប្រាស់ស្លៀកដណ្តប់ ។

ឯសំពត់វិញ ព្រះភគវ័តបរមសាស្តាទ្រង់អនុញ្ញាតសំពត់ ៦ យ៉ាង មានសំពត់ធ្វើពីសំបកឈើ សំពត់ធ្វើពីសំឡីកប្បាស ជាដើម ។

ក្នុងគម្ពីរសមន្តបាឋ ពោលថា *យេន កេនចិ ទេវេន វា មនុស្សេន វា បញ្ចន្នំ សហធម្មិកានំ អញ្ញតរេន ទិន្នំ វដ្តតិ* អ្នកដែលគួរនឹងធ្វើកឋិនទានបាននោះគឺទេវតាក្តី មនុស្សក្តី សហធម្មិកទាំង ៥ គឺភិក្ខុ, ភិក្ខុនី, សាមណេរ, សាមណេរី, និងសិក្ខមានាក្តី ទាំងអស់នេះ សុទ្ធតែជាអ្នកគួរជាទាយកធ្វើកឋិនទានបាន ។

កឋិនទាន ជាទានវិសេសវិសាល មានផលានិសង្សច្រើន គ្រាន់តែព្រះអរហំសម្មាសម្ពុទ្ធ អនុញ្ញាតហើយភ្លាម ព្រះបាទបសេនទិកោសល ក៏បានចាត់ចែងធ្វើកឋិនទានជាដំបូងបំផុត ដូចមានរឿងដំណាលយ៉ាងសង្ខេបតទៅនេះ :

កាលនោះ ព្រះបាទបសេនទិកោសល បានចាត់ចែងកឋិនទានដង្ហែទៅវេរប្រគេនព្រះសង្ឃ មានព្រះមហាកច្ចាយនត្ថេរជាប្រធាន ។ ព្រះមាហាកច្ចាយនត្ថេរ បានទទួលក្រាលគ្រងកឋិននោះ តាមគន្លងកឋិនតារកិច្ច ដោយសព្វគ្រប់ ។ នៅពេលនោះឯង ព្រះសាស្តាបានសម្តែងសរសើរកុសលផលបុណ្យកឋិនទាននៃព្រះបាទបសេនទិ-កោសល ជាអនេកបរិយាយ ដោយព្រះអង្គបាននាំអតីតនិទានរបស់ព្រះអង្គ កាលយោនយកកំណើតជានរជីវទុគ្គតបរមពោធិសត្វ បានជួយចាត់ចែងកឋិនទានកុដុម្ពីក៍ម្នាក់ នាំទៅថ្វាយព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមបទុមុត្តរៈ ព្រះអង្គទ្រង់បានឱ្យព្រះសុជាតត្ថេរ ជាអគ្គសាវ័ករបស់ព្រះអង្គ ធ្វើការក្រាលគ្រងក្នុងគ្រានោះ ។ កាលបាន

សម្តែងពីផលានិសង្សនៃកឋិនទាន និងនាំអតីតនិទាននេះរួចមក ព្រះបរមសាស្តានៃយើង ក៏ទ្រង់អនុញ្ញាតសំពត់កឋិនដល់ភិក្ខុទាំងឡាយ ដែលមានត្រៃចីវរទុព្វលភាព ហើយទ្រង់បញ្ញត្តនូវសិក្ខាបទ ដែលព្រះសង្គីតិកាចារ្យ បានពោល ទុកក្នុងគម្ពីរមហា-វគ្គ ដោយពិស្តារ ហើយទ្រង់ទេសនាសរសើរផលានិសង្សកឋិនទាននេះថា មានផលវិសេសពន់ប្រមាណ ។

លំដាប់នោះ ព្រះនារទត្ថេរ បានស្តាប់ធម្មទេសនា អំពីកឋិនានិសង្សនោះហើយ មានព្រះហឫទ័យប្រកបដោយបីតិជ្រះថ្លាក្រៃពេក ក៏គិតថា កឋិនមានផលានិសង្សច្រើនអនេកយ៉ាងនេះ អាត្មាអញ គួរតែនឹងចាត់ចែងធ្វើឡើង ថ្វាយដល់ជីនុំសង្ឃបានម្តងទៅចុះ ។ កាលគិតយ៉ាងនេះហើយ ក៏រលះរលាំងប្រញាប់ប្រញាល់និមន្តទៅកាន់ត្រកូលជាញាតិរបស់លោក ហើយបបួលពួកញាតិទាំងនោះឱ្យជួយក្នុងការធ្វើកឋិនទាន លុះបានគ្រប់គ្រឿងសម្រាប់កឋិនហើយ លោកព្រមទាំងពួកញាតិបាននាំកឋិនទៅថ្វាយព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ដែលគង់ចាំវស្សាអស់ត្រីមាសក្នុងអាវាសវត្តមួយ ។

គ្រានោះ ព្រះមានព្រះភាគទ្រង់ឱ្យប្រជុំភិក្ខុ ៥០០ រូប ធ្វើកិច្ចទាំងឡាយមានការដេរចីវរកឋិនជាដើម ឱ្យសម្រេចសព្វគ្រប់ក្នុងគ្រានោះឯង ។ កាលដែលព្រះនារទត្ថេរ ធ្វើកឋិនដើម្បីភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាននោះ ក៏កើតជាអស្ចារ្យដល់ជីនុំសង្ឃ នាំគ្នានិយាយសរសើរបុណ្យកុសលនៃព្រះនារទត្ថេរ ជាអនេកបរិយាយ ។ កាលនោះ ព្រះសម្ពុទ្ធទ្រង់នាំអតីតនិទានរបស់ព្រះអង្គ កាលកើតជាស្តេចបរមចក្រ-ពត្រាធិរាជមួយព្រះអង្គ ទ្រង់ព្រះនាមបរមចក្កវិជិតរាជ ប្រកបដោយអំណាចជាធំក្នុងទ្វីបទាំង ៤ មានទ្វីបតូច ២.០០០ ជាបរិវារ ព្រះអង្គបានសាងកឋិនទានថ្វាយព្រះពុទ្ធ ទ្រង់ព្រះនាមកោណ្ឌញ្ញ ៈ ដែលបានត្រាស់ដឹងក្នុងសារកប្ប[១] នោះ មកសំដែង

(១) សារកប្ប គឺកប្បដែលមានព្រះពុទ្ធត្រាស់តែ ១ ព្រះអង្គ ។

ប្រាប់ភិក្ខុទាំងឡាយ ដោយពិស្តារ ។

ក្នុងទីនេះ សម្តែងសេចក្តីខ្លី១ ឱ្យឃើញតួបុគ្គលអ្នកធ្វើ គឺព្រះបាទបសេនទិកោសល ជាបច្ចុប្បន្ននិទាន, ព្រះនរជីវទុគ្គតពោធិសត្វ និងនាយកុដុម្ពិក នោះក្តី ស្តេចបរមចក្កវិជិតរាជនោះក្តី ជាអតីតនិទាន ។ ចំណែកខាងព្រះសង្ឃអ្នកធ្វើ គឺព្រះនារទត្ថេរ ជាបច្ចុប្បន្ននិទាន ។

ក្នុងកឋិនត្ថារវិនយកម្ម ព្រះមានព្រះភាគទ្រង់ត្រាស់ថា *អត្ថតកឋិនានំ វោ ភិក្ខវេ បញ្ចានិសង្សានិ កប្បិស្សន្តិ* ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយបានក្រាលគ្រង ឬអនុមោទនាកឋិនហើយ និងបានសម្រេចអានិសង្ស ៥ ប្រការ គឺ :

១. *អនាមន្តចារោ* ភិក្ខុណាពុំបានលា ពុំបានប្រាប់ភិក្ខុជាសព្រហ្មចារី នៅក្នុងអារាមជាមួយគ្នា ហើយត្រាច់ទៅកាន់ត្រកូល ទីកន្លែងដទៃ ក្នុងវេលាព្រឹក ឬវេលាល្ងាច ភិក្ខុនោះត្រូវអាបត្តិ ដោយចារិតសិក្ខាបទ ។ ប៉ុន្តែ បើភិក្ខុនោះ បានគ្រងកឋិនក្តី បានអនុមោទនាកឋិនក្តី ទោះបីមិនបានប្រាប់ មិនបានលាភិក្ខុជាសព្រហ្មចារី នៅជាមួយគ្នា ហើយទៅកាន់ត្រកូល ឬទីកន្លែងដទៃ ក៏ឥតត្រូវអាបត្តិ ព្រោះអានិសង្សនៃកឋិន អាចការពារអាបត្តិដល់ភិក្ខុនោះឯង ។

២. *អសមាទានចារោ* ភិក្ខុណាលះត្រៃចីវរឯណាមួយ ដែលជាទីរក្សាក្នុងកាលអរុណរះឡើង ទុកហើយចេញចាកទីលំនៅ ឱ្យកន្លងអរុណ មាត្រាតែរាត្រីមួយ នឹងត្រូវអាបត្តិ ដោយចីវរប្បវិកប្បនសិក្ខាបទ ប៉ុន្តែ បើភិក្ខុនោះបានក្រាលគ្រង អនុ-មោទនាកឋិន ទោះបីលះត្រៃចីវរទុកឱ្យកន្លងរាត្រី ក៏ឥតត្រូវអាបត្តិ ព្រោះអានិសង្សនៃកឋិននោះឯង ។

៣. *គណភោជនំ* ភិក្ខុទទួលចង្ហាន់គណភោជន តាំងពី ៤ រូបឡើងទៅ ហើយមានទាយកមកនិមន្តដោយវោហារគ្រហស្ថ មិនសមគួរដល់សមណកប្បជាដើមថា និមន្តលោកឆាន់បាយ ឆាន់សម្ល ឆាន់ត្រី ជាដើម ហើយទៅឆាន់ ក៏ត្រូវ

អាបត្តិ ដោយគណភោជនសិក្ខាបទ ។ តែបើភិក្ខុតាំងពី ៤ អង្គឡើងទៅ បានក្រាល ឬអនុមោទនាកឋិនហើយ ទោះបីជាឆាន់ភោជននៃទាយកនោះ ក៏ឥតត្រូវអាបត្តិឡើយ ។

៤. *យាវទត្ថចីវរំ* ភិក្ខុបានចីវរលាភទាំងពួងមក ហើយពុំបានអធិដ្ឋានវិកប្ប ទុកឱ្យកន្លង ១០ រាត្រីទៅ ក៏ពុំត្រូវអាបត្តិដែរ ។

៥. *យោ ច តត្ថ ចីវរុប្បាទោ សោ នេសំ ភវិស្សតិ* ចីវរដែលកើតពីទាយកថ្វាយចំពោះជាសង្ឃមានក្តី ចីវរដែលកើតអំពីធរណីសង្ឃ គឺផ្លែស្រែចំការវត្តក្តី មតកចីវរ គឺចីវររបស់ភិក្ខុ សាមណេរ ដែលអនិច្ចធម្មក្តី សង្ឃិកចីវរទាំង ៣ ប្រការ ដែលកើតក្នុងដែនកឋិនាវាស ក៏បានដល់ភិក្ខុដែលបានក្រាល ឬអនុមោទនាកឋិន ពួកមួយនោះឯង តែភិក្ខុដែលដាច់វស្សាក្តី ភិក្ខុដែលចូលបច្ឆិមវស្សា គឺចូលក្នុងថ្ងៃ ១ រោច ខែស្រាពណ៍នោះក្តី មិនត្រូវបានចំណែកចីវរនោះឡើយ ។

កឋិនទាន មានផលានិសង្សដល់ភិក្ខុអ្នកក្រាលគ្រង ឬអនុមោទនា ដូចបានរៀបរាប់មកហើយនោះឯង ។

ចំណែកទាយកទាយិកា អ្នកបរិច្ចាគទ្រព្យធនធ្វើជាកឋិនទាន ព្រមទាំងអស់លោកអ្នកមានចិត្តជ្រះថ្លា បានយកកម្លាំងកាយចិត្តជួយខ្វល់ខ្វាយចាត់ចែងក្នុងកឋិនទាន ក៏មានផលានិសង្សច្រើនដូចគ្នា សមដូចជាព្រះអនាវរណញ្ញាណ ទ្រង់ត្រាស់សំដែងក្នុងកាលទានសូត្រថា ៖

*កាលេ ទទន្តិ សប្បញ្ញោ វទញ្ញូ វីតមច្ឆរា* ជនអ្នកមានប្រាជ្ញាទាំងឡាយ ជាអ្នកដឹងនូវពាក្យពេចន៍នៃអ្នកប្រាជ្ញ ជាអ្នកមានសេចក្តីកំណាញ់ទៅប្រាសហើយ រមែងឱ្យនូវទានក្នុងកាល ។

*កាលេន ទិន្នំ អរិយេសុ ឧជុភូតេសុ តាទិសុ* ទានដែលបុគ្គលឱ្យហើយដល់ព្រះអរិយបុគ្គលទាំងឡាយ ជាបុគ្គលមានកាយ និងចិត្តត្រង់ ជាអ្នកមិនញាប់ញ័រ

ដោយលោកធម៌ទាំង ៨ ប្រការ គឺមានលាភ ឥតលាភ, មានយស ឥតយស, សេចក្ដីសុខ សេចក្ដីទុក្ខ, ការសរសើរ ការតិះដៀល ។

*វិប្បសន្នមនា តស្ស វិបុលា ហោតិ ទក្ខិណា* ទក្ខិណាទានរបស់បុគ្គលនោះ ជាទានមានផលពេញវិសេស ព្រោះមានចិត្តជ្រះថ្លា ។

*យេ តត្ថ អនុមោទន្តិ វេយ្យាវច្ចំ ករោន្តិ វា* ជនទាំងឡាយឯណា គ្រាន់តែអនុមោទនា គ្រាន់តែធ្វើនូវការខ្វល់ខ្វាយ ។

*តេបិ បុញ្ញស្ស ភាគិនោ* ជនទាំងឡាយដែលគ្រាន់តែបានជួយអនុ-មោទនា ឬគ្រាន់តែបានជួយខ្វល់ខ្វាយ ជាអ្នកមានចំណែកបុណ្យដោយពិត ។

*តស្មា ទទេ អប្បដិវានចិត្តោ យត្ថ ទិន្នំ មហប្ផលំ* ព្រោះហេតុនោះ ទានដែលបុគ្គលឱ្យហើយដល់បុគ្គលឯណា ជាទានមានផលានិសង្សច្រើន ជនដែលមានចិត្តមិនរួញរា គប្បីឱ្យ ។

*បុញ្ញានិ បរលោកស្មឹ បតិដ្ឋា ហោន្តិ បាណិនំ* បុណ្យទាំងឡាយ រមែងបានជាទីពឹងរបស់សត្វទាំងឡាយ ក្នុងបរលោក ។

ម្យ៉ាងវិញទៀត ក្នុងគម្ពីរសំយុត្តនិកាយ ត្រង់ទេវតាសំយុត្ត បានដំណាលថា មានទេវតាមួយអង្គ ទូលសួរព្រះសម្ពុទ្ធថា បពិត្រព្រះមានព្រះភាគដ៏ចម្រើន អ្នកដែលមានសម្បុរល្អនោះ តើបានធ្វើទានអ្វី ?

ព្រះសាស្ដាទ្រង់ត្រាស់ថា *វត្ថទោ ហោតិ វណ្ណទោ* អ្នកឱ្យសំពត់ជាទានបានឈ្មោះថា ឱ្យពណ៌សម្បុរជាទាន គឺឈ្មោះថា បានឱ្យវណ្ណទាន ដល់អ្នកទទួលបានក្នុងបច្ចុប្បន្ន ហើយអ្នកម្ចាស់ទាននោះ រមែងមានសម្បុរល្អ គ្រឿងស្លៀកពាក់ និងទ្រព្យសម្បត្តិក្នុងអនាគតជាតិ តួយ៉ាងដូចជានាងឧម្មាទន្តី ជាដើម ។

មានសេចក្ដីដំណាលថា ក្នុងកាលកន្លងទៅហើយ មាននាងកញ្ញាម្នាក់ ជាកូនអ្នកទីទ័លក្រ នៅនគរពារាណសី ។ ថ្ងៃមួយ នៅរដូវចូលឆ្នាំ នាងបានឃើញពួក

កញ្ញា កូនអ្នកមានសម្បត្តិ ស្លៀកពាក់សំពត់អាវក្រហមល្អ១ ដើរលេងកំសាន្តតាមប្រពៃណី ។ នាងចង់ល្អដូចគេ ក៏បានសុំលាមាតាទៅរកស៊ីឈ្នួលគេ ដើម្បីយកសំពត់ពណ៌ក្រហមមួយត្បូង ( មួយសម្រាប់ ) ។

នាងទៅរកស៊ីឈ្នួលនៅផ្ទះគហបតីម្នាក់ ។ គេថា លុះត្រាតែធ្វើការឱ្យគេគ្រប់ ៣ ឆ្នាំ ទើបគេឱ្យសំពត់ពណ៌ក្រហមមួយសម្រាប់ ។ នាងកញ្ញានោះ ក៏សុខចិត្តស៊ីឈ្នួលគេតាមការកំណត់ ប៉ុន្តែ ដោយនាងជាក្មេងឧស្សាហ៍ព្យាយាមក្នុងកិច្ចការងារគហបតីពេញចិត្តនឹងនាង ហើយបន្ថយពេលវេលាធ្វើការ ៣ ឆ្នាំនោះ មកនៅត្រឹមតែមួយឆ្នាំ ។ គ្រប់មួយឆ្នាំហើយ គហបតីក៏ប្រគល់សំពត់ក្រហម ១ សម្រាប់ ព្រមទាំងសំពត់ដទៃទៀតមួយចំនួនដល់នាងកញ្ញា រួចបញ្ជូនឱ្យត្រឡប់ទៅផ្ទះវិញ ។

ពេលនាងធ្វើដំណើរទៅផ្ទះ ដល់ពាក់កណ្តាលផ្លូវ នាងបានជួបព្រះអរហន្តមួយអង្គ ជាសាវ័ករបស់ព្រះពុទ្ធកស្សបៈ ដែលត្រូវចោរដណ្តើមយកស្បង់ចីវរអស់ហើយលោកខ្មាស់ស្លឹកឈើបិទបាំងរាងកាយ និមន្តដើរមកជិតនាង ។ នាងមានចិត្តអាណិតលោកយ៉ាងខ្លាំង បានប្រគេនសំពត់មួយអាវចំពោះលោក ។ កាលលោកយកទៅស្លៀក នាងឃើញពណ៌ល្អ ក៏ប្រគេន ១ អាវទៀត ហើយឃើញលោកមានរស្មីល្អដូចព្រះអាទិត្យទើបរះ ក៏ធ្វើសេចក្តីប្រាថ្នាថា ដោយអំណាចផលនៃទាននេះ សុំឱ្យនាងខ្ញុំមានរូបល្អអស្ចារ្យក្នុងអនាគតជាតិ បើបុរសណាបានឃើញ ឱ្យភ័ន្តស្មារតី កុំឱ្យទប់ចិត្តបាន ។ ព្រះថេរៈ ក៏ធ្វើអនុមោទនា ហើយនិមន្តចៀសចេញទៅ ។

ដោយអំណាចផលានិសង្សនោះ លុះនាងអស់អាយុសង្ខារ ក៏បានទៅកើតជាទេពធីតាក្នុងទេវលោក ។ កាលច្យុតចាកទេវលោក ក៏បានមកកើតជាកូនសេដ្ឋីនៅអរិដ្ឋបុរី ក្នុងសិវរដ្ឋ ។ នាងមានរូបឆោមល្អជាទីពេញចិត្ត អ្នកស្រុកតែងហៅនាងថា ស្រីកែវ លុះនាងពេញវ័យ បើបុរសណាមួយបានឃើញនាង បុរសនោះឯង តែងភ័ន្តភាំងស្មារតី រកគិតអ្វីមិនឃើញ ហាក់ដូចជាឆ្កួត ។ ហេតុនោះហើយ ទើបអ្នក

ស្រុកឱ្យឈ្មោះថា ឧម្មាទន្តី ( ធ្វើឱ្យបុរសឆ្កួត ព្រោះសម្រស់ ) ។

ចំណែកសេដ្ឋីជាបិតា កាលឃើញសភាពបែបនេះ ក៏ថ្វាយដំណឹងចំពោះព្រះរាជា ។ ព្រះរាជាទ្រង់បានសណ្ដាប់ ទ្រង់សព្វព្រះរាជហឫទ័យ ចាត់ឱ្យពួកព្រាហ្មណ៍ទៅពិនិត្យលក្ខណៈ បើឃើញល្អពិតមែន នឹងដណ្ដឹងយកជាព្រះទេពី ។

លុះព្រាហ្មណាណ៍ទាំងនោះទៅដល់ផ្ទះនាង សេដ្ឋីជាបិតា បានរៀបភោជនាហារឱ្យបរិភោគ ។ ពេលពួកព្រាហ្មណ៍កំពុងបរិភោគ សេដ្ឋីឱ្យនាងជាកូន តែងខ្លួនចេញមកបង្ហាញ ។ លំអររបស់នាងចោលស្រមោលសម្ផស្ស ទៅប៉ះខ្សែភ្នែករបស់ពួកព្រាហ្មណ៍ ធ្វើឱ្យពួកព្រាហ្មណ៍ទាំងនោះវង្វេងស្មារតី ដោយកិលេសគ្របសង្កត់ ។ ព្រាហ្មណ៍ខ្លះដាក់បាយលើក្បាល ខ្លះញាត់ក្នុងក្លៀក ខ្លះទះជញ្ជាំង ដូចមនុស្សឆ្កួត ។

នាងឧម្មាទន្តី ឃើញដូច្នោះ ក៏បណ្ដេញពួកព្រាហ្មណ៍ទាំងនោះឱ្យចេញទៅ ។ ដោយខ្មាសគេខ្លាំងពេក ព្រាហ្មណ៍ទាំងនោះទៅទូលព្រះរាជាថា នាងនោះជាស្ត្រីឆ្កួត ជាកាឡកិណ្ណី មិនល្អទេ ។ ព្រះរាជាក៏ឈប់ត្រូវការ ។

ក្រោយមកមិនយូរប៉ុន្មាន នាងឧម្មាទន្តី បានជាភរិយារបស់អភិបារកអាមាត្យ ជាអាមាត្យសំណប់របស់ព្រះរាជា ។ ថ្ងៃមួយ ជាថ្ងៃនក្ខត្តឫក្ស ព្រះរាជាទ្រង់គង់លើព្រះទីនាំងដំរី ប្រទក្សិណព្រះនគរ ។ នាងឧម្មាទន្តី ពេលនោះកំពុងឈរក្បែរបង្អួច មើលក្បួនហែព្រះរាជា ។ ព្រះរាជាឃើញនាង ក៏ជ្រាបភ្លាមថា នាងហ្នឹងហើយជាស្រីកែវ ដែលអញឱ្យព្រាហ្មណ៍ទៅពិនិត្យនោះ ក៏ទ្រង់ព្រះវិតក្កយ៉ាងខ្លាំង ផ្ទំមិនលក់សោយមិនបាន ស្គមព្រះអង្គ ព្រោះតែចង់បាននាងជាព្រះទេពី ប៉ុន្តែ ទ្រង់ជ្រាបថា នាងជាភរិយារបស់មហាអាមាត្យទៅហើយ ក៏ចេះតែលាក់ព្រះទ័យប្រតិព័ទ្ធនោះ ពុំឱ្យនរណាដឹងឡើយ ។

មហាអាមាត្យ ជាប្ដីរបស់នាងឧម្មាទន្តី បានពិនិត្យដឹងរឿងហេតុនោះ ក៏ចាត់មនុស្សម្នាក់ឱ្យទៅជ្រកសំងំក្នុងព្រៃ ក្រោយខ្ទមអ្នកតាមួយ ហើយមហាអាមាត្យ

ខ្លួនឯង ធ្វើជាទៅបន់អ្នកតានោះ សួរពីរឿងព្រះអាការៈរោគរបស់ព្រះរាជា ។

មហាអាមាត្យទៅដល់ខ្ទមអ្នកតាហើយ ក៏សួរថា លោកតា ព្រះរាជាទ្រង់ប្រឈួនដោយព្រះអាការៈរោគអ្វី បានជាទ្រង់ផ្ទំពុំលក់ សោយពុំបាន ? ។

អ្នកដែលនៅក្រោយខ្ទមអ្នកតាឆ្លើយថា ព្រះរាជាទ្រង់ប្រឈួន ព្រោះរោគប្រតិព័ទ្ធស្រឡាញ់ស្រីកែវ ជាភរិយារបស់លោកហ្នឹងឯង ។

មហាអាមាត្យទូលព្រះរាជាតាមដំណើរនោះ ព្រះរាជាទ្រង់ពិចារណាថា ខ្ញុំសេចក្ដីប្រតិព័ទ្ធរបស់អញនេះ ទោះបីលាក់ទុកតែក្នុងចិត្ត មិនឱ្យអ្នកណាមួយដឹង ក៏គង់តែមានអ្នកតាដឹងបានដែរ ហើយទ្រង់ខំកាត់ព្រះទ័យចេញផុតពីរឿងនេះ ។

ឯនាងឧម្មាទន្តី ដែលមានរូបល្អ ត្រកូលខ្ពស់ បានជាភរិយាមហាអាមាត្យមានទ្រព្យសម្បត្តិច្រើន ក៏ដោយអំណាចផលានិសង្សនៃចីវរទាន ដែលនាងបានប្រគេនហើយដល់ព្រះអរហន្តក្នុងសម័យពុទ្ធកាលនៃព្រះសម្មាសម្ពុទ្ធព្រះនាមកស្សបៈនោះឯង ។

រឿងរ៉ាវទាំងឡាយដែលពណ៌នាអំពីអានិសង្សនៃចីវរទាន មានច្រើនឥតគណនា កុំថាឡើយដល់ការប្រគេនត្រៃចីវរធំដុំ សូម្បីតែប្រគេនសំពត់បរិក្ខារតូចតាច ក៏មានផលានិសង្សច្រើន ដូចជាការប្រគេនសំពត់រុំដំបៅជាដើម ឧទាហរណ៍ដូចជារឿងនាងអសន្ធិមិត្តា ជាដើម ។

មានសេចក្ដីដំណាលថា មុនពុទ្ធកាលនៃព្រះសក្យមុនីគោតមយើង មានព្រះបច្ចេកពុទ្ធច្រើនអង្គ គង់លើភ្នំគន្ធមាទន៍ ក្នុងចំណោមព្រះបច្ចេកពុទ្ធទាំងនោះ មានព្រះបច្ចេកពុទ្ធមួយអង្គកើតដំបៅ ហើយនិមន្តទៅស្វែងរកទឹកឃ្មុំ មកលាយថ្នាំព្យាបាល ។ ព្រះបច្ចេកពុទ្ធអង្គនោះ ហោះចុះទៅត្រង់កំពង់ទឹកមួយ បានឃើញនាងកុម្ភទាសីម្នាក់ ចុះមកដងទឹក ហើយសួរថា ទីនេះមាននរណាមានទឹកឃ្មុំដែរឬទេ អាត្មានឹងសុំបិណ្ឌបាតគេយកទៅធ្វើថ្នាំព្យាបាលដំបៅ ។ នាងកុម្ភទាសីនោះ បាន

ចង្អុលបង្ហាញថា នុ៎ះហ្ន៎ផ្ទះមធុពាណិជ អ្នកលក់ទឹកឃ្មុំ សូមនិមន្តទៅបិណ្ឌបាតគេចុះ ទោះបានក្តី មិនបានក្តី សូមនិមន្តត្រឡប់មកប្រាប់ខ្ញុំព្រះករុណាផង ។

កាលព្រះបច្ចេកពុទ្ធនិមន្តទៅដល់ផ្ទះមធុពាណិជ បានសុំបិណ្ឌបាត គេជ្រះថ្លាបានយកទឹកឃ្មុំមកដាក់បាត ឃើញទឹកឃ្មុំហូរហៀរចេញពីមាត់បាតស្រក់ធ្លាក់លើដី មានក្លិនសាយទៅក្នុងអាកាស ។ ពាណិជក៏ប្រាថ្នាថា ដោយផលទឹកឃ្មុំនេះ សូមឱ្យខ្ញុំបានជាស្តេចចក្រក្នុងជាតិខាងមុខ មានអំណាចធំ ផ្សាយទៅក្នុងដីមួយយោជន៍ ទៅលើអាកាសមួយយោជន៍ ។

ព្រះបច្ចេកពុទ្ធធ្វើអនុមោទនា ហើយនិមន្តមកប្រាប់នាងកុម្ភទាសីវិញ នាងកុម្ភទាសីសួរថា កាលដែលមធុពាណិជប្រគេនទឹកឃ្មុំនោះ គាត់តាំងសេចក្តីប្រាថ្នាដូចម្តេចខ្លះ ? ព្រះបច្ចេកពុទ្ធប្រាប់ថា គាត់ប្រាថ្នាឱ្យបានជាស្តេចចក្រ មានអំណាចទៅក្នុងផែនដីមួយយោជន៍ ទៅលើអាកាសមួយយោជន៍ នាងក៏និមន្តព្រះបច្ចេកពុទ្ធឱ្យរង់ចាំបន្តិច ដើម្បីខ្លួនទៅយកសាដកថ្មីមកប្រគេន សម្រាប់លោករុំដំបៅ ហើយតាំងសេចក្តីប្រាថ្នា សូមឱ្យខ្ញុំបានជាទេពី របស់មធុពាណិជ នៅពេលដែលគាត់បានជាស្តេចចក្រនោះ ។

ដោយអំណាចនៃផលានិសង្សមធុទាន និងចីវរទាននោះ អ្នកទាំងពីរបានសម្រេចដូចសេចក្តីប្រាថ្នា គឺ :

- មធុពាណិជ ក្នុងជាតិខាងមុខ បានជាព្រះបាទធម្មាសោក នៅក្រុងបាតលិបុត្ត នៃមជ្ឈិមប្រទេស ( ឥណ្ឌា ) ។ ស្តេចអង្គនេះ ជាស្តេចចុល្លចក្រក្នុងជម្ពូទ្វីប មានអំណាចផ្សាយទៅក្នុងផែនដី និងលើអាកាសមួយយោជន៍ ពួកនាគនៅក្នុងសមុទ្រ និងពួកទេវតានៅលើអាកាស តែងនាំបណ្ណាការផ្សេងៗ មកថ្វាយព្រះអង្គ ។ ស្តេចចក្រអង្គនេះហើយ ដែលជាអគ្គពុទ្ធសាសនូបត្ថម្ភក៏ បានរៀបចំផ្សព្វផ្សាយព្រះពុទ្ធសាសនាទៅកាន់ទ្វីប និងប្រទេសនានាក្នុងលោកដ៏បូងបង្អស់ ដោយទ្រង់បាន

ឧបត្ថម្ភតតិយសង្គាយនា ក្នុងពុទ្ធសករាជជាង ២០០ ឆ្នាំ ។

- នាងកុម្ភទាសី បានជានាងអសន្ធិមិត្តា ជាព្រះទេពី នៃព្រះបាទធម្មាសោក ដោយអំណាចផលានិសង្សនៃការលើកដៃចង្អុលបង្ហាញផ្លូវព្រះបច្ចេកពុទ្ធ ទៅកាន់ផ្ទះមធុពាណិជ ដើម្បីបិណ្ឌបាតទឹកឃ្មុំ កាលពីអតីតជាតិនោះ នាងមានរូបឆោមល្អ មានព្រហស្តស្រល្វត ហាក់ដូចជាឥតសន្លាក់ឡើយ ដូច្នេះហើយ ទើបប្រាកដនាមថា ព្រះនាងអសន្ធិមិត្តា ។

កាលព្រះបាទអសោកមហារាជ បានសោយរាជ្យភ្លាម ពុំទាន់លើកនាងស្នំណាមួយឱ្យជាអគ្គមហេសីពេញលក្ខណៈនៅឡើយ ។ ថ្ងៃមួយ នាងអសន្ធិមិត្តា ទតតាមបង្អួច ឃើញទេវតាយកអំពៅមួយដើមពីព្រៃហិមពាន្តមកថ្វាយ ព្រះនាងទទួលយកអំពៅនោះមកសោយ ។ ពេលព្រះនាងកំពុងសោយអំពៅនោះ ព្រះបាទធម្មា-សោក បានយាងចូលមកក្នុងបន្ទប់ព្រះនាង សួរថា ម្ដេចក៏នាងសោយអំពៅមានសាច់រឹងដូច្នេះ ។ ព្រះនាងក្រាបទូលតបវិញថា ខ្ញុំម្ចាស់ទទួលព្រះរាជទានលមើល ព្រោះអំពៅនេះកើតដោយបុណ្យរបស់ខ្ញុំម្ចាស់ ។

ព្រះរាជាឮថា អំពៅកើតឡើងដោយបុណ្យព្រះនាង ក៏ទ្រង់ពិរោធយ៉ាងខ្លាំង ហើយត្រាស់ថា បើដូច្នោះ ព្រឹកស្អែក, យើងនឹងនិមន្តព្រះសង្ឃ ៥០០ អង្គមកទទួលភត្តក្នុងព្រះរាជវាំង ហើយយើងនឹងប្រគេនចីវរមួយត្រៃៗ ក្នុងមួយអង្គ, នាងចូររកចីវរដែលកើតពីបុណ្យរបស់នាងប្រគេនលោក គឺមិនឱ្យយកព្រះរាជទ្រព្យក្នុងឃ្លាំង ចំណាយធ្វើចីវរនោះទេ បើរកមិនបានគ្រប់ ៥០០ ត្រៃទេ នោះយើងនឹងសម្លាប់នាងពុំខាន ។

គ្រានោះ កាលបានសណ្ដាប់ដូច្នោះ ព្រះនាងផ្ទំពុំលក់សោះយប់នោះ បានទៅគង់នៅក្បែរមាត់បង្អួចបួងសួងរកបុណ្យ ព្រេងវាសនាពីបុព្វជាតិ ។ ដោយអំណាចផលានិសង្សចីវរទាន ដែលព្រះនាងបានថ្វាយសំពត់សម្រាប់រុំដំបៅដល់ព្រះ

បច្ចេកពុទ្ធនោះ ក៏ក្តៅដល់អាសនាព្រះឥន្ទ្រាធិរាជ។ បានឱ្យទេវបុត្រមួយអង្គ យក ប្រអប់ទិព្វតូចមួយ ពេញដោយត្រៃចីវរមកថ្វាយព្រះនាង ហើយបើកមាត់ប្រអប់ បន្តិចឡើង ហូតយកជាយចីវរបន្តិចមានទំនងដូចប្រអប់កន្សែងក្រដាសសព្វថ្ងៃនេះ បង្ហាញព្រះនាងថា « នេះជាប្រអប់ដាក់ត្រៃចីវរ ដែលកើតពីវត្តទានរបស់ព្រះនាង កាលដែលនៅជានាងកុម្ភទាសីនោះ សូមព្រះនាងហូតយកចីវរមួយត្រៃម្តងៗ ប្រគេន ព្រះសង្ឃមួយត្រៃសម្រាប់មួយអង្គ, គ្រប់ ៥០០ អង្គចុះ ហើយបើចង់ហូតយកក្រៅ ពីនេះទៀត ក៏បានតាមព្រះទ័យ ។

លុះព្រឹកស្អែក, ព្រះរាជាទ្រង់ឱ្យសេវកាមាត្យ និមន្តព្រះសង្ឃ ៥០០ អង្គ មកទទួលភត្ត ទ្រង់ឱ្យហៅព្រះនាងអសន្ធិមិត្តា យកចីវរមកប្រគេនព្រះសង្ឃ ។ ព្រះនាងបានកាន់ប្រអប់ទិព្វនោះ ហូតយកចីវរមួយត្រៃម្តងៗ ថ្វាយព្រះរាជា, ព្រះរាជាទ្រង់ប្រគេនព្រះសង្ឃ ១ អង្គ បាន ១ ត្រៃ គ្រប់ ៥០០ អង្គ ។ ព្រះនាងថែម ទាំងហូតយកសំពត់មួយអាវ១ ថ្វាយព្រះរាជវង្សានុវង្សគ្រប់ៗ អង្គ និងមន្ត្រីគ្រប់ៗ រូប ដែលយាងអញ្ជើញចូលរួមក្នុងពិធីនោះ ។ ព្រះមហាក្សត្រ ទ្រង់ឃើញអព្ភូតហេតុ អស្ចារ្យដូច្នោះ ទ្រង់លើកអសន្ធិមិត្តាជាព្រះរាជឯកអគ្គមហេសី ។

ថ្ងៃក្រោយមក ព្រះរាជាទ្រង់ជ្រាបថា នាងស្នំឯទៀតៗ ច្រណែន ក៏បញ្ជា ឱ្យគេធ្វើនំផ្លែអាយ គ្រប់ចំនួនស្នំដែលមានទាំងប៉ុន្មាន ។ ក្នុងនំផ្លែអាយទាំងអស់នោះ មាននំផ្លែអាយតែមួយ ដែលព្រះអង្គទ្រង់បង្កប់ព្រះទម្រង់ជាស្នួល ដោយមិនឱ្យ នរណាម្នាក់ដឹងឡើយ ហើយឱ្យនាងស្នំទាំងអស់ ចូលចាប់យកម្នាក់មួយ ម្នាក់មួយ ។ ព្រះអង្គបានឱ្យស្នំឯទៀតចាប់យកមុន, នៅសល់តែនំមួយ ទើបឱ្យព្រះនាងអសន្ធិ-មិត្តា ចាប់យក រួចទើបទ្រង់ឱ្យបើកនំដំណាលគ្នាក្នុងកណ្តាលជំនុំ ។ ព្រះនាង អសន្ធិមិត្តា, ពេលបើកនំនោះទៅ បានឃើញព្រះទម្រង់ភ្លីផ្លេកៗ យ៉ាងអស្ចារ្យ ។

ព្រះមហាក្សត្រចុល្លចក្រ ក៏ទ្រង់ប្រកាសកណ្តាលជំនុំថា នេះហើយជាភព្វ

វាសនារបស់នាងអសន្ធិមិត្តា ដែលបានសាងពីបុព្វជាតិមក ដូច្នេះ នាងត្រូវបានជាព្រះរាជឯកអគ្គមហេសីរបស់យើង ចូរនាងទាំងឡាយកុំច្រណែនឡើយ ។

លុះបានជាឯកអគ្គមហេសីហើយ ព្រះនាងអសន្ធិមិត្តា ទ្រង់សោយព្រះបរមសុខ ក្នុងសិរីរាជសម្បត្តិ ក្រោមម្លប់ព្រះរាជសម្ភារបារមី នៃព្រះបាទធម្មាសោកមហារាជាធិរាជជាស្តេចចុល្លចក្រ នៅក្នុងជម្ពូទ្វីប លុះអស់ព្រះជន្មាយុ បានទៅកើតក្នុងទេវលោកទៀត ។

សេចក្តីសុខក្នុងបច្ចុប្បន្នជាតិ និងអនាគតជាតិ ដែលព្រះនាងអសន្ធិមិត្តា បានទទួលនោះ ដោយអំណាចផលានិសង្សនៃចីវរទាន ដែលនាងបានថ្វាយសំពត់សម្រាប់រុំដំបៅដល់ព្រះបច្ចេកពុទ្ធ ពីបុព្វជាតិនុ៎ះឯង ។

*សាធវោ សាធុសប្បុរសទាំងឡាយ !* ការសំដែងរៀបរាប់ពីកឋិន និងអានិសង្សកឋិន ដោយត្រួសៗមកនេះ ទុកជាប្រទីបជួយបំភ្លឺបន្ថែមក្នុងការយល់ដឹងរបស់ពុទ្ធបរិស័ទទាំងឡាយ ដែលមានសទ្ធាជ្រះថ្លា បានលះបង់ទ្រព្យធនធ្វើកឋិន-ទាន កប់តម្កល់ទុកជាបុញ្ញនិធិក្នុងព្រះពុទ្ធសាសនា ចប់តែប៉ុណ្ណេះ ដោយសង្ខេប ។

# ស្ថាននាមវិទ្យា

( TOPONYMIE )

( ត . ចប់ )

## III. ធរណីនាម (Eronymes)

លក្ខណៈដីដែលកកើតឡើងដោយធម្មជាតិ ជាទូទៅនាមស្ថានមាន ជលនាម ( ឈ្មោះផ្លូវទឹក ឬក៏រអាងទឹក ) មានធរណីនាម គឺជានាមឈ្មោះគិរីបពិត ទីទួលទាំងឡាយ មាននគរនាម គឺនាមផ្លូវគមនាគមន៍ គ្រឹះស្ថាន និងសំណង់គ្រប់បែប យ៉ាង ។ ( នគរនាម : Urbanymes ) មានតារានាម ( Cosmonymes ផ្កាយដុះកន្ទុយ, ផ្កាយព្រះគ្រោះ, ផ្កាយព្រះសុក្រ ) ទាំងអស់នេះ គឺជាតារានាម ដែល គេសិក្សានៅក្នុងតារាសាស្ត្រ ។

កម្ពុជទេស គឺជាប្រទេសកម្ពុជា សម័យមុន សម័យអង្គរ មានលក្ខណៈ ភូមិសាស្ត្រពិសេស ប្រកបទៅដោយស្ថាននាមទីតាំង មានដីទាប ជួនកាលទីដីលិចទឹក ហើយដែលសិលាចារឹក ហៅថា : « Phdai Karoṃ ផ្ទៃករោំ = ផ្ទៃក្រោម » និងម្យ៉ាងទៀត ប្រកបដោយលក្ខណៈពិសេសដែលមានទីទួល មានទឹកព័ទ្ធជុំវិញ នៅ រដូវវស្សា និងមានដីនៅភូមិភាគដ៏ខ្ពស់ៗ ប្រកបដោយភ្នំ និងជងភ្នំខ្ពស់ទាប ។

### III. ១- Vnaṃ វ្នំ . ភ្នំ

ភ្នំ អាចហៅថា បរិត : បពិត ឬគិរី ( សំស្ក្រឹត ) ។ ប៉ុន្តែ « ភ្នំ » ជាពាក្យ ខ្មែរសុទ្ធសាធ (ដោយកម្លាយសូរមកពីពាក្យ « វ្នំ » សម័យបុរាណ) ។ ឯពាក្យទាំង

៣ ខាងក្រោមនេះ គឺជាពាក្យសំស្ក្រឹត ហើយពាក្យទាំង ៣ នេះ គឺវាប្រកបដោយផលិតពាក្យ នៅក្នុងការបង្កបង្កើតស្ថាននាម នៃប្រទេសកម្ពុជា ។

ពាក្យ « វ្នំ » សព្វថ្ងៃហៅថាភ្នំ គឺជាពាក្យខ្មែរដើម ។ គេអាចនិយាយម្យ៉ាងទៀតថា ជាពាក្យ « មន - ខ្មែរ » ដែលអាចកើតឡើងដោយសារការផ្សំរវាងផ្នត់ជ្រែក « - ក - ; - ន - » និងពាក្យ « Vaṃ , baṃ »
មកខាងមុខ ឬឡើងលើ ហើយនៅក្នុងភាសាខ្មែរបុរាណ គេប្រទះឃើញពាក្យ Kra vaṃ : « ក្រពុំ » សព្វថ្ងៃ ។

ឧទាហរណ៍ : ពាក្យ « Vnaṃ » បានត្រូវប្រើប្រាស់សំរាប់សំគាល់នូវស្ថាននាម ។

| | | | |
|---|---|---|---|
| វ្នំ ថ្មោ | Vnaṃ Thmo | K 273 | វ្នំ ថ្មោ (ថ្ម) |
| វ្នំ សោ | Vnaṃ So | K 541 | វ្នំ សោ (ស) |
| វ្នំ ករោំ | Vnaṃ Karoṃ | K 262 | វ្នំ ករោំ (ក្រោម) |

តាមអត្ថបទសិលាចារឹក ឬតាមអត្ថន័យរបស់អត្ថបទ គេអាចពន្យល់បានថា ស្ថាននាម ភ្នំ ថ្ម បញ្ជាក់ឱ្យដឹងថា សមាសភាពនៃភ្នំនោះប្រកបទៅដោយធាតុថ្មច្រើនជាងរុក្ខជាតិដែលដុះនៅទីនោះ ។

ភ្នំស គឺជាភ្នំដែលគ្មានរុក្ខជាតិ ហើយប្រកបទៅដោយផ្ទាំងសិលា ។

ភ្នំក្រោម គឺជាភ្នំដែលស្ថិតនៅតំបន់នៃដីវាល ឬស្ថិតនៅក្នុងផ្ទៃក្រោមជិតមាត់បឹង ។

គឺជាឈ្មោះភ្នំក្រោម ដែលស្ថិតនៅមាត់បឹងទន្លេសាប មានចម្ងាយប្រ-ហែល ១៥ គ.ម ពីទីរួមខេត្តសៀមរាប ( ភាគខាងត្បូង ) ។

វ្នំ មាស៑ Vnaṃ Mās K 814 វ្នំមាស ( មាស ) គឺជាភ្នំដែលនៅទីនោះ ប្រហែលជាមានលោហធាតុមាស ហើយដែលអ្នកស្រុកបានជីក

យកមកធ្វើជាគ្រឿងអលង្ការ និងជារូបិយប័ណ្ណប្រើប្រាស់ ក្នុងទំនាក់ទំនងខាងពាណិជ្ជកម្ម ។

នៅក្នុងអត្ថបទសិលាចារឹក មានស្ថាននាមជាង ៣០ ដែលបានកកើតឡើងដោយសារការប្រើពាក្យ « វ្នំ » ។

ស្ថាននាមប្រកបដោយពាក្យ « វ្នំ » ខ្លះ បានប្រែក្លាយទៅជាឈ្មោះជនបទ ។ ឧទាហរណ៍ ៖

ស្រុក វ្នំ ទិ Sruk Vnaṃ Ti K 720 ស្រុក វ្នំ តី ( ភ្នំដី )

ស្រុក វ្នំ ប្រអប Sruk Vnaṃ Pra - ap K 219 ស្រុកវ្នំប្រអបិ ( ភ្នំប្រអប់ ) ។

នៅក្នុងសិលាចារឹកខ្លះ ស្ថាននាមប្រកបដោយពាក្យ « វ្នំ » បានត្រូវបកប្រែជាភាសាសំស្ក្រឹត ក្នុងសិលាចារឹកសំស្ក្រឹត ។

ដោយសារការបកប្រែនេះហើយ បានសេចក្តីថា ការបកប្រែពីខ្មែរទៅសំស្ក្រឹត គេអាចយល់នូវនិយមន័យមួយចំនួននៃពាក្យខ្មែរដើម ហើយដែលនិយមន័យនេះ បានបាត់បង់នៅក្នុងភាសាខ្មែរសម័យ ។ ឧទាហរណ៍ ៖

វ្នំ រុង Vnaṃ Ruṅ K 254 វ្នំ រុង ( ភ្នំរុង )
skt : Pṛthuçaila ( çaila = ភ្នំ )

វ្នំ ថ្មេ Vnaṃ Thṅe K 524 វ្នំ ថ្មេ ( ភ្នំខ្មៅស្រគាំ )
skt : Syãmãdri ( ãdri = ភ្នំ )

វ្នំ រហេក Vnaṃ Rhek K 32 វ្នំ ហេក ( ភ្នំរំហេក )
skt : Phinãcala ( acala = ភ្នំ )

នៅក្នុងសម័យនគរភ្នំ ពាក្យ " ភ្នំ " មានអត្ថន័យជានិមិត្តរូបនៅក្នុងគំនិតរបស់ខ្មែរ ដោយហេតុថា " ភ្នំ " គឺជាលំនៅរបស់ទេវ និងទេពតាទាំងឡាយ ហើយ

ដើម្បីធ្វើពិធីបន់ស្រន់ ដល់អាទិទេព ដល់ព្រះឥស្វរ ដែលជាអាទិទេពនៃភ្នំ គឺត្រូវតែមានទេវស្ថាន ឬមួយក៏ជាព្រះវិហារដែលជាសំណង់ស្ថិតនៅលើកំពូលភ្នំ ។ មិនតែប៉ុណ្ណោះ ព្រះមហាក្សត្រ ក៏ជាស្តេចភ្នំដែរ គេហៅព្រះអង្គថា " សៃលេន្ទ្រ Çailendra " ។

នៅក្នុងសម័យកាលកម្ពុជទេស ( កម្វុជទេស ) គឺសម័យកាលអង្គរ ព្រះបាទជ័យវរ្ម័នទី II បានប្រារព្ធនូវកល្យាណពិធី នៅលើភ្នំ មហេន្ទ្របពិត ( មហេន្ទ្រ-បវ៌ិត Mahendra parwata ) គឺភ្នំគូលេន ដើម្បីប្រកាសនូវឯករាជ្យនៃកម្ពុជ-ទេស, នូវស្ថានភាពរបស់ព្រះមហាក្សត្រកម្វុជទេស ដែលបន្ទាប់ពីពិធីនោះមក ព្រះអង្គបានឡើងទៅជា " ទេវរាជា " ជាចក្រវាទិន Cakravãtin ( ‹ Cakra-vartti ) ឬជាអធិរាជនៃចក្រភព ។

សម័យអង្គរ នៅក្រោមចក្រភពនៃព្រាហ្មណ៍សាសនា ដែលពន្យល់ថា ភ្នំគឺទេវស្ថាន និងក្រោមឥទ្ធិពលនៃស្ថាបនកម្ម អាស្រម និងប្រាសាទដ៏ធំធេង ពាក្យ " វ្នំ " បានពង្រីកនូវនិយមន័យ ឬសេម៉ង់ទិក ( sémantique ) របស់ពាក្យនេះបានរីកធំទូលាយទៅបាន ក៏ដោយសារទស្សនីយភាពដ៏ធំធេងនៃសិលាប្រាសាទ ដែលត្រូវបានសង់ឡើងលើដីទួលខ្ពស់ ។

ឧទាហរណ៍ ដូចជាមានវាក្យថា :

ធ្វេ វ្រះ វ្នំ ថ្វេ វ្រះ វ្នំ Thvə Vraḥ Vnaṃ K 105

= ស្ថាបនាប្រាសាទ ។

ខ្លោញ វ្រះ វ្នំ ខ្លោញ វ្រះ វ្នំ Khloñ Vraḥ Vnaṃ K 344

= ចៅអធិការវត្ត ឬអាស្រម ។

រហូតមកដល់សម័យបច្ចុប្បន្ន ពាក្យ វ្នំ បានក្លាយទៅជាបច្ចេកទេស នៃស្ថាននាម ដែលត្រូវបានគេប្រើប្រាស់ សំរាប់សំគាល់ស្ថាននាមសំខាន់ៗ ទាំងឡាយ

សំរាប់ប្រទេស ។

នៅក្នុងភាសាខ្មែរទំនើប ពាក្យ Vnaṃ បុរាណ បានត្រូវផ្លាស់ប្តូរអក្ខរាវិរុទ្ធិរបស់ខ្លួន មកជា Bhnaṃ " ភ្នំ " ហើយពាក្យនេះបានត្រូវប្រើប្រាស់ សំរាប់សំគាល់ស្រុកនានា ។ ដូចជា :

ស្រុក ភ្នំក្រវាញ នៅខេត្ត ពោធិសាត់
ស្រុក ភ្នំស្រុក នៅខេត្តបាត់ដំបង
ស្រុក ភ្នំស្រួច នៅខេត្តកំពង់ស្ពឺ
ស្រុក បាភ្នំ នៅខេត្តព្រៃវែង ជារាជធានីចាស់មួយ នៃនគរភ្នំ ដែលគេហៅថា វ្យាធបុរ ។

ពាក្យ Vnaṃ បុរាណ បានបង្កបង្កើតឱ្យមានពាក្យ " វ្នង៑ " ដែលគេហៅថា " ម្នង " ឬមានន័យថា : អ្នកភ្នំ គឺជាពាក្យសំរាប់សំគាល់នូវជនជាតិមន-ខ្មែរ ដែលមានលំនៅស្ថាននៅស្រុកខ្មែរផង ស្រុកវៀតណាមផង និងស្រុកលាវផង ។

ស្ថាននាមសំគាល់នូវរាជធានីខ្មែរ សព្វថ្ងៃ គឺ " ភ្នំពេញ " បានត្រូវបកស្រាយថាជាភ្នំរបស់ដូនពេញ ឬក៏បកស្រាយថា ភ្នំកកើតឡើងដោយសារដូនពេញ និងអ្នកស្រុក ដើម្បីសង់វិហារខាងពុទ្ធសាសនាមួយនៅទីនោះ ។ តាមការពន្យល់របស់វចនានុក្រមខ្មែរ និងរឿងព្រេងខ្មែរ ដូនពេញបានឃើញដើមគគីរធំមួយអណ្តែតតាមទឹកហូរ នៃទន្លេមេគង្គ បានស្រែកអំពាវនាវដល់អ្នកស្រុកឱ្យជួយស្រង់គល់គគីរ ហើយទាំងអស់គ្នាក៏បានឃើញទិដ្ឋភាពដ៏អស្ចារ្យ " ព្រះពុទ្ធរូបមុខ ៤ " ហើយទាំងអស់គ្នាក៏មានសទ្ធាជ្រះថ្លា លើកដីពូនជាភ្នំ ដើម្បីសង់ព្រះវិហារនៅលើភ្នំនោះ ។

ការពន្យល់និយមន័យរបស់រាជធានី មានលក្ខណៈទាក់ទងទៅនឹងទេវកថា ហើយសំរាប់ការស្រាវជ្រាវខាងប្រវត្តិវិទ្យា គឺជាការពិបាកយល់បន្តិច ។ ដោយបង្កើត

ឡើង នៅសតវត្សទី XV ដោយព្រះបាទពញាយ៉ាត បន្ទាប់ពីបោះបង់ចោលអង្គរ ភ្នំពេញ កាលពីមុន គឺជាជនបទមួយដែលស្ថិតនៅតាមមាត់ទន្លេមេគង្គ ហើយប្រហែលជាទីនោះ គឺមានភ្នំមួយ ដែលកកើតឡើងដោយធម្មជាតិ ហើយដែលនៅជុំវិញ មានសុទ្ធតែត្រពាំង បឹងបួរ ។ ភស្តុតាងថា នៅទីនោះមានត្រពាំង បឹងបួរ គឺសំណល់នៃការហៅឈ្មោះតាមសង្កាត់ផ្សេងៗនៃទីក្រុងភ្នំពេញ ហើយសង្កាត់ដែលមានបឹងពីមុខ ក៏មិនតិចដែរ ។ ហេតុដែលគេអាចធ្វើការពិភាក្សាបានចំពោះពាក្យ ភ្នំពេញ គឺពាក្យខាងក្រោយ គឺពាក្យ " ពេញ " ដែលនៅក្នុងភាសាខ្មែរសម័យទំនើប អាចបកប្រែបានថា ៖ បរិបូណ៌ គ្រប់គ្រាន់ ខ្ពស់ស្មើ ហើយគោងយល់ថា ការផ្លាស់ប្តូរអត្ថន័យរបស់ពាក្យ " ពេញ " បានប្រព្រឹត្តទៅតាំងពីបុរាណកាលមក ។ នៅក្នុងភាសាខ្មែរបុរាណ គឺមានពាក្យ បិង៑ piṅ ដែលនៅក្នុងភាសាខ្មែរបុរាណ មានន័យថា " បឹង " ប៉ុន្តែនៅក្នុងភាសាមន-ខ្មែរ ដទៃទៀត ពាក្យ / piṅ / ប៊ិង / មានន័យថា " ពេញ " ផង និង " បឹង " ផង ។

ដូច្នេះ យើងអាចយល់នូវទំនាក់ទំនងរវាងពាក្យ ពេញ និង បឹង ដែលកាលពីដើមឡើយ ជាពាក្យតែមួយ ដែលមានសូរស័ព្ទតែមួយ ប៉ុន្តែមានន័យ ២ គឺ " ពេញ " និង " បឹង " ។ នៅក្នុងអត្ថបទស្រាវជ្រាវ អំពីរាជធានីចាស់នៃប្រទេសកម្ពុជា លោក ប៉ូល ពេរី បានសរសេរពាក្យ ភ្នំពេញ ថា " Ponom Beng " គឺជាពាក្យដែលសរសេរឡើងនៅឆ្នាំ ១៦៤១ ដោយអ្នកដំណើរជនជាតិហូឡង់ម្នាក់ Hollandais ។

នៅក្នុងពាក្យ Ponom Beng គេអាចវែកញែកសមាសពាក្យ "Ponom ‹ vnaṃ " និងពាក្យ " Beng " ដែលកើតចេញពីពាក្យខ្មែរបុរាណ Piṅ មានន័យថា " បឹង " ដូច្នេះ ដោយយោងទៅលើទំនៀមទម្លាប់នៃការបង្កបង្កើតពាក្យនៅក្នុងភាសាខ្មែរ គេអាចសន្និដ្ឋានបានថា ឬក៏បកប្រែពាក្យ " ភ្នំពេញ " បានថា

គឺជាភ្នំ ( ដែលមាន ) បឹងនៅជុំវិញ ។ ហើយតមក និយមន័យប្រកបដោយទេវកថា ឬអច្ឆរិយភាព គឺជាស្រទាប់សេម៉ង់ទិកថ្មី ដើម្បីលំអនូវពាក្យដែលសំគាល់រាជធានី នៃប្រទេសកម្ពុជា តែប៉ុណ្ណោះ ។

តាមសិលាចារឹក មានការប្រើពាក្យ Vnaṃ Kantal វ្នំកន្តាល សំរាប់សំគាល់ភ្នំបាខែងសព្វថ្ងៃ និងពាក្យ Vnaṃ Karoṃ វ្នំករោំ សំរាប់សំគាល់ភ្នំក្រោមសព្វថ្ងៃ ( ជាកន្សោមពាក្យមានក្នុងឃ្លាមួយ ) ដែលមានពាក្យដូចតទៅ " បូជាវ្នំករោំ " មានន័យថា " ធ្វើសក្ការបូជាភ្នំក្រោម " ។

III. ២. **Vnur** វ្នុរ

Vnur ជាដីទួល ហើយជាពាក្យសទិសស័ព្ទនឹងពាក្យសំស្ក្រឹត ស្ថលៈ sthãla ។ ដូចជានៅក្នុងពាក្យខ្មែរថា ថឡាបរិវ៉ាត់ ( នៅខេត្តស្ទឹងត្រែង ) ហើយដែលលោក ប៉ូល ពេរី សន្និដ្ឋានថា ជារាជធានី របស់ព្រះបាទភវវរ្ម័ន I ។

ពាក្យ " វ្នុរ > ថ្នួរ ( សម័យបច្ចុប្បន្ន ) "

ពាក្យនេះកើតឡើងដោយកិរិយាស័ព្ទ ឬគុណស័ព្ទ វុរ Vur ដែលមាននៅក្នុងភាសាមនបុរាណ ដែលមានន័យថា ខ្ពស់, ទួល, បូកនឹងផ្នត់ដែក [- ន -], [- n -] ។ គួរកត់សំគាល់ថា ផ្នត់ដែក [- ន -] ពុំមានទំរង់ជាពាក្យពេញលេញទេ ។ បានសេចក្តីថា មានទំរង់ជាព្យញ្ជនៈប៉ុណ្ណោះ ក៏ប៉ុន្តែព្យញ្ជនៈ [- ន -] នេះ អាចសន្មតជាពាក្យវេយ្យាករណ៍ដ៏សំខាន់ ជាបរមពាក្យ គឺជាពាក្យដែលគ្មានន័យផ្ទាល់ខ្លួន ជាពាក្យដែលអាចបង្កបង្កើតពាក្យដទៃទៀត ជាពាក្យកម្លាយ រាប់រយ រាប់ពាន់នៅក្នុងភាសាខ្មែរ ។ ភាសាទាំងឡាយណានៅឥណ្ឌូចិន ដែលបានប្រើផ្នត់ដែក [- n -] នេះ ដើម្បីបង្កើតពាក្យដទៃទៀត នៅក្នុងភាសាទាំងនោះ គេសន្មតឈ្មោះថា ភាសាខ្មែរ-មន ។ នៅក្នុងភាសាខ្មែរបច្ចុប្បន្ន មានកិរិយាស័ព្ទ " ពូន " ដែលក្លាយចេញមក

ពីកិរិយាស័ព្ទ " វ្វន " Vvan សម័យអង្គរ ហើយគេអាចសន្និដ្ឋានបានថា ពាក្យ " វ្វន " នេះ មានសំនូវស្របគ្នានឹងកិរិយាស័ព្ទ វុរ ដូចមនបុរាណ ដោយហេតុថា នៅក្នុងភាសាមន-ខ្មែរ ព្យញ្ជនៈចុងព្យាង្គ [- រ] អាចក្លាយទៅជាព្យញ្ជនៈចុងព្យាង្គ [- ន] ក៏ប៉ុន្តែ ព្យញ្ជនៈចុងព្យាង្គ [- ន] មិនអាចក្លាយទៅជា [- រ] បានឡើយ ។

នៅក្នុងសិលាចារឹក K 44 ឆ្នាំ ៦៧៤ គ.ស ពាក្យ វ្នុរ បានដើរតួជានាម-ស័ព្ទធម្មតា ហើយមិនទាន់បានក្លាយជាសមាសពាក្យ ក្នុងការបង្កបង្កើតស្ថាននាមទាំងឡាយទេ ។ ក្នុងសិលាចារឹកនោះ មានសរសេរពាក្យថា ៖

Vnaṃ Vrai Vnur វ្នំ វ្រៃ វ្នុរ បកប្រែថា " ភ្នំព្រៃ (និង) ដីទួល " ។

នៅសម័យអង្គរ ពាក្យ " Vnur " មានទំរង់ជានាមស័ព្ទធម្មតាផង ជាសមាសពាក្យនៃស្ថាននាមផង ។ មិនតែប៉ុណ្ណោះ នៅសម័យអង្គរ មានពាក្យសំគាល់ភូមិ និងស្រុក ដែលប្រកបដោយសមាសពាក្យ Vnur ។ ឧទាហរណ៍ ៖

| | | |
|---|---|---|
| ស្រុក វ្នុរ កំទ្វាត | sruk Vnur Kaṃdvãt | K 292 |
| ស្រុក វ្នុរ វិនៅ | sruk Vnur Vinau | K 467 |
| ស្រុក វ្នុរ លង្កា | sruk Vnur Laṅkã | K 549 |
| ស្រុក វ្នុរ ខ្វេក លេ | sruk Vnur Khvek le | K 817 |
| ស្រុក វ្នុរ ខ្វេក កន្តាល | sruk Vnur Khvek Kantãl | K 817 |
| ស្រុក វ្នុរ ខ្វេក ករោំ | sruk Vnur Khvek Karoṃ | K 817 |

ក្នុងក្របខ័ណ្ឌជាសមាសភាពនៃស្ថាននាម ពាក្យ Vnur បូកជាមួយនឹងពាក្យនៃស្ថាននាមមួយទៀត ។

ដូចជាពាក្យ Vnur Kaṃdvãt បានត្រូវគេប្រើប្រាស់ សំរាប់សំគាល់ស្រុក ដែលជាដែនដីរដ្ឋបាល នៅសម័យកម្ពុជទេស ។ ជាពាក្យធម្មតា នៅសម័យអង្គរ

" Vnur " សំគាល់នូវទីទួលដ៏ធំ ហើយវែង ហើយដែលស្ថិតនៅមាត់ទឹក ។ ឧទាហរណ៍ខាងក្រោម បញ្ជាក់នូវនិយមន័យរបស់ពាក្យ Vnur នៅសម័យដើម ។

ឧទាហរណ៍ នៅលើផ្នូកខ្សាច់តែមួយ អាចមានភូមិស្រុករហូតដល់បី ដែលស្ថិតនៅជិតជាប់គ្នា ៖ នៅតាមមាត់ទន្លេ ភូមិស្រុកលើគេ គេហៅថា Sruk Vnur Khvek le បន្ទាប់ Sruk Vnur Khvek Kantāl តមកទៀត ស្រុកនៅខាងក្រោមចរន្តទឹកហូរ ពីលើមកក្រោម ឬពីជើងមកត្បូង គឺមាន Sruk Vnur Karoṃ ។

ជាពាក្យធម្មតា មានពាក្យ Vrai Vnur ព្រៃវ្នុរ K 258 គឺ ឈើព្រៃដែលដុះលើផ្នូរ ។

នៅក្នុងភាសាខ្មែរសម័យ ពាក្យ វ្នុរ Vnur បានក្លាយទៅជាពាក្យ Phnur " ផ្នូរ " ដែលមានពាក្យរក្សានូវនិយមន័យផង ( ឧទាហរណ៍ ៖ ផ្នូរខ្សាច់ ) និងពាក្យ ដែលបាត់បង់នូវនិយមន័យដើមផង ។ ( ដូចជាពាក្យ ៖ ផ្នូរខ្មោច ) ។

III. ៣ - **Cok** ចុក **Chok** ឆោក

នៅក្នុងពាក្យនេះ គ្មាននៅក្នុងភាសាខ្មែរសម័យថ្មី ប៉ុន្តែ នៅបានរក្សាស្ថាននាមខ្មែរមួយ នៅកម្ពុជាក្រោម គឺ ស្រុក សុក ត្រាំង ( Sruk Suk Trāṅ ) ពាក្យ Suk ត្រូវគ្នានឹងពាក្យ Cok សម័យមុនអង្គរ ហើយស្នូរព្យញ្ជនៈ " Ca" ដើមព្យាង្គ ដូចជាពាក្យ " Cdiṅ " ជាដើម ( ជាពាក្យ KPA ) បានត្រូវរក្សាទុកនៅក្នុងគ្រាមភាសាខ្មែរ នៅអង្គរបុរី ។

នៅសម័យអង្គរ ពាក្យ " Chok " ជាសមាសពាក្យនៃស្ថាននាម គឺជាពាក្យ អូម៉ូនីម Omonymes នឹងពាក្យមួយទៀត គឺ " Chok" សំរាប់សំគាល់ផ្ទៃលទឹក ដែលទាបក្ររអាញ K 263 Chok ... ។

នៅសម័យមុនអង្គរ គេប្រទះឃើញពាក្យនេះ នៅក្នុងសមាសពាក្យ ដូចតទៅ ៖

| | | |
|---|---|---|
| ចក អំវិល | Cok Amvil | K 129 |
| ចក ស្វាយ | Cok Svāy | K 134 |
| ចក រង្សី | Cok Ransi | K 134 |

នៅសម័យអង្គរ មាន ៖

| | | |
|---|---|---|
| ស្រុក ឆោក វេង | Sruk Chok Veṅ | K 720 |
| ស្រុក ឆោក ត្របេក | Sruk Chok Trabek | K 165 |
| ស្រុក ឆោក សង្កេ | Sruk Chok Saṅke | K 344 |
| ឆោក គរ្គ្យារ | Cok gar gyar | |

នៅសម័យអង្គរ ពាក្យ " Cok " បានក្លាយទៅជាពាក្យ " ឆោក Chok " ហើយពាក្យនេះ បានទៅជាពាក្យសំគាល់នូវស្ថាននាមដែលជាស្រុក ជាច្រើន ឧទាហរណ៍ ៖ ស្រុក ឆោកវេង, ស្រុក ឆោកត្របេក, ស្រុក ឆោកសង្កេ ។ គួរសំគាល់នូវពាក្យ " Chok Gargyar " ឆោក គរ្គ្យារ ( = ឆោក គរគីរ ) នៅសម័យអង្គរ គួរកត់សំគាល់ថា ឆោកគរគីរ គឺជាស្ថាននាមសំគាល់រាជធានីកម្ពុជាមួយ ស្ថាបនាដោយព្រះបាទជ័យវរ្ម័នទី IV នៅសតវត្សទី X ដែលភាសាខ្មែរសម័យហៅថា " កោះកេរ្តិ៍ KOH KE " ( K 72, K 235, K 293, K 682, K 814 ) ។

នៅក្នុងពាក្យនេះ គឺពាក្យ " ឆោក គរ្គ្យារ ( គគ្យារ ) មានពាក្យ គគ្យារ ត្រូវនឹងពាក្យ " គគីរ " សម័យថ្មី ដែលជាពាក្យសំគាល់នូវរុក្ខជាតិផង និងជាសមាស-ពាក្យនៃស្ថាននាមទៀតផង ( ដូចជា ស្រុក គគីរ ) ។

នៅក្នុងសិលាចារឹកនានា គេរកឃើញស្ថាននាមដែលមានធាតុផ្សំ ចោក / ឆោក ចំនួនប្រហែល ៣០ ។

### III. ៤. Tpal ត្បល៑ Thpal ថ្បល៑

គឺជាពាក្យដែលមានន័យថា ទីទួល, គុម្ព ( គុម្ពឈើ, ដំណាំឈើ ) ។ តាមការវិភាគខាងវេយ្យាករណ៍ គេអាចសន្និដ្ឋានបានថា ពាក្យនេះ កើតមកពីបុព្វបទ ( préfixe ) t + *pal : pal មានន័យថា អ្វីដែលប្រមូលផ្ដុំ អ្វីដែលមានចំនួនច្រើន ហើយន័យរបស់ពាក្យនេះ បានស្ថិតនៅក្នុងពាក្យកម្លាយ ដូចជាពាក្យ : អំវល់, អំពាល់ , អំបាល ampāl ... ។

នៅសម័យមុនអង្គរ តាមសិលាចារឹក K 9 ឆ្នាំ ៦៣៦ គ.ស ពាក្យ "ត្បល៑ " គឺជានាមស័ព្ទ ដែលមានន័យថា " ដំណាំ " ។

ត្បល៑ ។ ស្លា ទំ ត គ្វិ ៗ ១២៣ ៕

ដំណាំមួយ ដើមស្លានៅទីនោះ ( តគី ) ១២៣ ដើម

Tpal 1 Slā teṃ ta gui 100.20.3

នៅសម័យអង្គរ ពាក្យ Tpal បានក្លាយទៅជាពាក្យ Thpal ផង និងពាក្យ Tampal ផង ។ នៅសម័យអង្គរ ពាក្យ ថ្បល៑ បានពង្រីកនូវសេម៉ងទិក របស់ខ្លួន ដោយពាក្យនេះមានន័យថា " ហ្វូង " ។

ឧទាហរណ៍ : ហ្វូងគោ ជាដើម, និងជាពាក្យសំរាប់ប្រើប្រាស់បង្កើតស្ថាននាមសម័យអង្គរ ។ បានសេចក្ដីថា ជាពាក្យសំគាល់នូវ ភូមិឋាន មានច្បារដំណាំប្រកបដោយរុក្ខជាតិ ហើយក្រោយមក បានក្លាយជាស្ថាន- នាមនានា សម័យអង្គរ ។

ឧទាហរណ៍ :

សង៑ គោ ចាលា ទុក ថ្បល៑ saṅ go çālā duk thpal K 76

" សង់ក្រោលគោ សំរាប់ដាក់ ហ្វូងមេគោ "

Thpal = troupeau (ហ្វូងសត្វពាហនៈ) ។

នៅសម័យអង្គរ ពាក្យ Thpal បានក្លាយទៅជាសមាសពាក្យ នៅក្នុង

ស្ថាននាម ដែលជាស្ថាននាមមានទំហំធំៗ សំរាប់សំគាល់ភូមិស្រុកទាំងឡាយ ហើយទាំងអស់ នៅក្នុងសិលាចារឹក គេប្រទះឃើញស្ថាននាមទាំងនេះ ចំនួន ១៥ ។

ឧទាហរណ៍ : ស្រុក ថ្បល ចារ Sruk Thpal Cār K 292

ស្រុក ថ្បល ក្រសាង Sruk Thpal Krasāṅ K 292

ស្រុក ថ្បល តង្កោ Sruk Thpal Taṅko K 292

តាមឧទាហរណ៍ខាងលើ យើងអាចសង្កេតឃើញថា ពាក្យ " ថ្បល " ទោះបីបានទៅជាសមាសពាក្យនៃស្ថាននាមក៏ដោយ ក៏ពាក្យនេះ រក្សានូវនិយមន័យដើមរបស់ខ្លួន ព្រោះថា ថ្បលចារ ថ្បលក្រសាង ថ្បលតង្កោ អាចប្រែមកជាភាសាខ្មែរទំនើបថា " ច្បារដំណាំចារ, ច្បារដំណាំ ដើមក្រសាំង, ច្បារដំណាំ ដើមដង្កោ " ។

នៅសម័យអង្គរ នៅក្នុងសិលាចារឹក K 262, K 263 នៅក្នុងកន្សោមពាក្យ Sruk Tampal គឺមានតំបល ដែលជាស្ថាននាម ហើយដែលជាពាក្យកម្លាយចេញមកអំពីពាក្យ : Thpal <tpal + - am - ( infixe ) ។

គេបានសន្និដ្ឋានថា " ផ្នត់ដែក " [ - am - ] ជាផ្នត់ដែកដ៏សំខាន់ ឬបើតាមភាសាវិទ្យា គេអាចឱ្យឈ្មោះថាជា " បរមាណូ វាក្យស័ព្ទ " មួយ ដែលមានថាមពលបង្កបង្កើតពាក្យ រាប់រយ រាប់ពាន់ នៅក្នុងភាសា ហើយផ្នត់ដែក (infixe) [ - am - ] ផ្ទាល់ខ្លួន ពុំអាចមានរូបរាងជាពាក្យពេញលក្ខណៈឡើយ ។

នៅសតវត្សទី XIV - XV ពាក្យនេះ ត្រូវបានភាសាថៃ ខ្ចីទៅប្រើ ហើយនៅមធ្យមសម័យ ដោយភាសាខ្មែរ និងសៀម មានទំនាក់ទំនងគ្នាដ៏ល្អ ដូច្នេះ ពាក្យ "tpal, tampal " ដែលបានក្លាយទៅជាពាក្យសៀមថា " taṃ pan" បានត្រូវភាសាខ្មែរយើងខ្ចីមកវិញ នៅក្នុងភាសាខ្មែរទំនើប ពាក្យនេះសំគាល់នូវដែនដី ភូមិ-ភាគ ដ៏ទូលំទូលាយនៃប្រទេស ។

III. ៥. **Thalã** ថលា **Sthalã** ស្ថលា

ពាក្យ Thalã ឬ Sthalã ជាពាក្យមួយចេញពីពាក្យសំស្ក្រឹត Sthala ប្រែមកថា : ទីទួល, ដីគោក ។

នៅក្នុងសិលាចារឹក យើងបានឃើញអំពីពាក្យ Vnur សំគាល់នូវទីទួល ឬដីគោក ដែលមានទឹកព័ទ្ធជុំវិញ ឬនៅជិតមាត់ទឹក ។

រីឯពាក្យ " Sthalã" សំគាល់នូវទីដីទួល ឬដីគោកដែលមិនមែននៅជិតមាត់ទឹក ។ នៅសតវត្សទី VII ពាក្យនេះត្រូវបានប្រើប្រាស់នៅក្នុងសិលាចារឹកដូចជាពាក្យដទៃទៀតធម្មតា ។ ឧទាហរណ៍ :

ស្រុ ឌ ញុង ថលា K 76 " ស្រែនៅជិតទីទួល "

ស្រុខំឈត្យល៊ិថលា K 76 " ស្រែខាងត្បូងទីទួល "

ភូមិ ថលា ក្រកុះហ Bhūmi Thalã Krakuḥh " ភូមិទួលដើមកកោះ " K 262 ។

នៅក្នុងភាសាខ្មែរសម័យបច្ចុប្បន្ន គេបានភ្លេចពាក្យមួយ ដែលជាស្ថាននាមដ៏សំខាន់ បានសេចក្តីថា គេបានភ្លេចពាក្យ " ថលា " ក្នុងក្របខណ្ឌជាសាធារណនាម ប៉ុន្តែពាក្យនេះ បានត្រូវរក្សាទុកនៅក្នុងស្ថាននាមរបស់ស្រុកមួយ គឺថាឡាបរិវ៉ាត់ Sruk Thãlã parivãt ( thala parivath ) នៅខេត្តស្ទឹងត្រែង ដែលជាស្ថាននាមដ៏បរមបុរាណ សំគាល់នូវរាជធានីនៃប្រទេសកម្ពុជា សម័យនគរភ្នំកសាងឡើងដោយព្រះបាទភវវរ្ម័ន I នៅរវាងសតវត្សទី VI - VII ( តាមអត្ថបទរបស់លោក Paul Lévi ដែលមានចំណងជើងថា " Thala Barivath au Stuṅ Treṅ sites de la capitaledu souverain Khmer Bhavavarman 1er " Journale Asiatique en 1970 ។

### III. ៦. Tkol ត្កោល , ថ្កល Thkval

ត្កោលិ (KPA), thkval ថ្កលិ (KA) " ទួល " ។ ពាក្យនេះប្រហែលជាមានជាតិស័ព្ទទាក់ទងទៅនឹងពាក្យ " kalkval " K 668, កលិក្វលិ " ទំរ, ជើងតំកល់ " ។ ពាក្យនេះកើតឡើងដោយការដាក់ផ្នត់ដើមទៅលើពាក្យ " kol " កោលិ និងអាចត្រូវគ្នានឹងពាក្យសម័យបច្ចុប្បន្ន kal / kol " កល់ " ។

នៅក្នុងអត្ថបទសិលាចារឹក គេរកឃើញស្ថាននាម ដែលមានពាក្យ tkol / thkvol នេះ ប្រហែល ១០ ដែលគឺជាឈ្មោះភូមិឋាន, និងវត្តនានា ។ ឧ.

ត្កោល វសេនិ — tkol vasen ត្កោលិ វសេនិ K 648, ( vasen ជានរនាម ; ភូមិឋាន ត្កោល វសេន ) ។

ស្រុក ថ្កល់ អិត — sruk thkval it ស្រុកិ ថ្កលិ អិតិ K 89, ( it " អិដ្ឋ ដីអិដ្ឋ " ; ភូមិ ថ្កល អិត ) ។

ស្រុក ថ្កល ធំ — sruk thkval dhaṃ ស្រុកិ ថ្កលិ ធំ K 105, " ( dhaṃ ធំ " ; ស្រុក ថ្កលធំ ) ។

វ្រះ ថ្កល ចស — vraḥ thkval cas វ្រះ ថ្កលិ ចសិ K 293, (vraḥ " ព្រះ, ប្រាសាទ, វត្ត "; cas " ចាស់ " ; ប្រាសាទ ថ្កល ចស ) ។

### III. ៧. Gok គោក

គោកិ " ទីទួល ", " ទួលមានទឹកព័ទ្ធជុំវិញនៅរដូវវស្សា ឬរដូវទឹកឡើង " ។

តាមរឿងព្រេងខ្មែរ ប្រទេសកម្ពុជាបុរាណ មានឈ្មោះថា : nagar gok dhlak នគរ គោក ធ្លក " នគរដែលមានដើមធ្លកដុះ (nagar " នគរ ",

gok " គោក ", dhlak " ដើមធ្លក " ) ។

ពាក្យ gok " គោកិ " និងពាក្យ thalā / sthalā ដែលរៀបរាប់ខាងលើ អាចចាត់ទុកថាជាវេវចនស័ព្ទ ។ ការអះអាងនេះ អាចបញ្ជាក់បាន ដោយហេតុថា នៅក្នុងសិលាចារឹក មានករណីមួយចំនួន ទីកន្លែងតែមួយ មានឈ្មោះជាខ្មែរផង និងជាភាសាសំស្ក្រឹតផង ។ ឧទាហរណ៍ :

គោកិ វកុល — gok vakula K 754 គោក វកុឡ, ( vakula " ឈ្មោះដើមឈើ " សំស្ក្រឹត : vakula thala ភូមិគោកវកុល " )

គោកិ សំលាញ — gok saṃlāñ K 754 គោកិសំលោញ " ភូមិគោកសំលាញ ", សំស្ក្រឹត : tālisat thala តាលិសតិថលា, (saṃlān" ឈ្មោះដើមឈើ ")។

នៅក្នុងអត្ថបទ K 31 ( គ.ស ១០១៩ ) ពាក្យ gok " គោកិ " ស្ថិតនៅក្នុងស្ថាននាមដែលជាឈ្មោះទន្លេ ។ ឧទាហរណ៍ :

ឆ្ទិង គោកិ ក្រវេ — chdiṅ gok krave ឆ្ទិង គោកិ ក្រវេ " ទន្លេឈ្មោះគោកក្រវេ ", ( gok krave " គោកក្រពើ " ) ។

## III. ៨. Kaṃvaṅ កំវង់ , កំវង

កំវង "កំពង់" ផ្ទុយពីមតិរបស់ S. Lewitz ដែលចាត់ទុកថា ពាក្យនេះជាពាក្យកម្ចី ពីភាសាឥណ្ឌូនេស៊ី យើងចាត់ទុកថា ពាក្យនេះមានដើមកំណើតជាពាក្យខ្មែរ ។ ពាក្យ kaṃvaṅ កំវង៑ អាចចាត់ទុកថា ជាកម្លាយបុរាណចេញពីពាក្យ* kvaṅ ក្វង៑ ដែលប្រហែលជាមានជាតិស័ព្ទ ទាក់ទងទៅនឹងពាក្យ kvuṅ ក្វុង៑ K 855

" កំពូល, ទីទួល " ។ នៅសតវត្សទី VII ពាក្យនេះមានអត្ថន័យច្រើនយ៉ាង តែន័យទាំងនោះតែងតែរក្សាទុកនូវន័យដែលទាក់ទងទៅនឹង" ទីទួល, ទីខ្ពស់" ។ ឧទាហរណ៍ៈ

| | | |
|---|---|---|
| ស្រេ ឰ កំវង៑ | sre ai kaṃvaṅ | ស្រេ ឰ កំវង៑ K 726 " ស្រែនៅឯកំពង់ " |
| ជេង៑ កំវង៑ | jeṅ kaṃvaṅ | ជេង៑ កំវង៑ K 9 " ជើងកំពង់, មាត់កំពង់ " |
| កំវង៑ ខ្តារ៑ | kaṃvaṅ khtār | កំវង៑ ខ្តារ៑ K 421 " កំពង់ក្តាម " ។ |

នៅក្នុងអត្ថបទសិលាចារឹកនានា គេរកឃើញស្ថាននាមដែលមានពាក្យ kaṃvaṅ ចំនួន ១០ ។ ឧទាហរណ៍ ៈ

| | | |
|---|---|---|
| កំវង៑ តំរ្យ | kaṃvaṅ taṃrya | កំវង៑ តំរ្យ K 183, taṃrya " ដំរី " |
| កំវង៑ ត្វង៑ | kaṃvaṅ tvaṅ | កំវង៑ ត្វង៑ K 516, tvaṅ " ដូង " |
| កំវង៑ វ្រ្យង៑ | kaṃvaṅ vryaṅ | កំវង៑ វ្រ្យង៑ K 206, vryaṅ " ព្រីង " |
| កំវង៑ អចាស៑ | kaṃvaṅ acās | កំវង៑ អចាស៑ K 726, acās " ចាស់ " |
| កំវង៑ រ្យ្យប៑ | kaṃvaṅ ryyap | កំវង៑ យ្យ៉ប៑ K 88, ryyap " រាប " |
| កំវង៑ តទិង៑ | kaṃvaṅ tadiṅ | កំវង៑ តទិង៑ K 105, tadiṅ " ទទឹង " |

នៅក្នុងភាសាខ្មែរបច្ចុប្បន្ន ពាក្យ kaṃvaṅ នេះ ត្រូវបានរក្សាទុកក្នុងទំរង់ kaṃvaṅ " កំពង់ " ។ ពាក្យកំពង់នេះ គេនិយមប្រើប្រាស់ណាស់ ក្នុងសមាសភាពឈ្មោះនៃស្រុក និងទីក្រុងដែលស្ថិតនៅតាមដងទន្លេ និងសមុទ្រ ហើយក្នុងនោះ មានឈ្មោះទីរួមខេត្តប្រាំ នៃប្រទេសកម្ពុជា ។

### III. ៩. Jaroy ជរោយ៑

ជរោយ " ជ្រោយ " ។ ពាក្យនេះអាចមានជាស័ព្ទទាក់ទងទៅនឹងវេវចនស័ព្ទរបស់វា គឺពាក្យ jaroy ជ្រោយ " ស្រួច, មុត " ។ ឧទាហរណ៍ :

ជរោយ៑ វោ jaroy vo ជរោយ៑ វោ K 207, (vo " ពោធិ៍ ")

ភូមិ ជរោយ៑ សង្កេ bhūmi jaroy saṅke ភូមិ ជរោយ៑ សង្កេ K 693, ( saṅke" សង្កែ " ) ។

ស្រុក៑ ជរោយ៑ចារ៑ sruk jaroy cār ស្រុក៑ ជរោយ៑ ចារ៑ K 218, ( cār " ដើមចារ " ) ។

### III. ១០. Rlaṃ រ្លំ . លំ

លំ " ដីបាក់, ច្រាំងបាក់ " ។ ពាក្យនេះ ត្រូវបានកើតឡើងដោយវិធីបន្លាស់ ( conversion ) កិរិយាស័ព្ទបុរាណ rlaṃ K 720 " រលំ " ។

នៅក្នុងអត្ថបទសិលាចារឹក K 341 ( គ.ស ៦៧៤ ) ពាក្យ rlaṃ មាននិយថា ដីដែលស្ថិតក្នុងកម្មសិទ្ធិរបស់វត្តអារាម ។ ឧទាហរណ៍ :

ចញ្វារ៑ រ្លំ ស្រេ វ្នុរ៑ canhvar rlaṃ sre vnur K 341 ចន្វារ៑ លំ ស្រែវ្នុរ៑ " អួរ, ច្រាំងបាក់, ស្រែ, ខ្ពង់ " ។

នៅក្នុងសមាសភាពនៃស្ថាននាម ពាក្យនេះគេប្រើសំរាប់ដាក់ឈ្មោះទីកន្លែងដីបាក់ដោយសារខ្សែទឹក ។ ឧទាហរណ៍ :

ស្រេ ល៉ំ ទំនប បាក sre rlaṃ daṃnap pãk K 476 ស្រែ លំ ទំនប បាក (damnap pãk " ទំនប់បាក់ " ) ។

ភូមិ ល៉ំ ស្លុត bhūmi rlaṃ slut K 237, ភូមិ លំ ស្លុត, ( slut " រលំ, ស្រុត " ) ។

ល៉ំ ហ្មះ ទិក rlaṃ hmaḥ dik K 343, រំ ហ្មះ ទិក, (hmaḥ " កខ្វក់ ", dik " ទឹក ") ។

## IV. បច្ចេកពាក្យស្ថាននាមវិទ្យា សំរាប់ដាក់ឈ្មោះទីកាំងភូមិសាស្ត្រ ដទៃទៀត

IV. ១. **Vrai** ថ្រៃ , ថ្រៃ វ្រៃ

វ្រៃ " ព្រៃ " ។ រចនាសម្ព័ន្ធនៃពាក្យ vrai វ្រៃ ដែលគេជួបប្រទះក្នុងសិលាចារឹក តាំងពីសតវត្សទី VII មកនោះ យើងនឹងធ្វើការវិភាគពិសេស ។ ពាក្យនេះ អាចចាត់ទុកថាជាពាក្យកម្លាយចេញពីពាក្យ * pri ប្រិ ដែលស្ថិតនៅក្នុងស្ថាននាមសមាសចំរុះ គឺថាស្ថាននាមនេះផ្សំឡើងដោយពាក្យខ្មែរពីរ និងពាក្យសំស្ក្រឹតមួយ ។

មត៑ ប្រិ គ្រាម mat pri ggrãma K 278 មត៑ ប្រិ គ្រាម ( mat " រំភ្នក ", pri " ព្រៃ ", grãma " ភូមិ " ) : " ភូមិដែលតាំងនៅតាមមាត់ព្រៃ ។ នៅក្នុងអត្ថបទសំស្ក្រឹត ស្ថាននាមនេះត្រូវគ្នាទៅនឹងស្ថាននាម vananestra វននេស្ត្រ K534 ។

នៅក្នុងសិលាចារឹក សតវត្សទី VII ពាក្យ vrai ត្រូវគេប្រើប្រាស់ជាធាតុនៃឈ្មោះព្រៃ និងតំបន់ព្រៃ ។ ឧទាហរណ៍ :

វ្រៃ ត្លន៑ vrai tlann K 561, វ្រៃ ត្លន្ន, (tlann " ពស់ថ្លាន់ ")

វ្រៃ ទំរោក៑ vrai daṃrok K 18, វ្រៃ ទំរោក៑ ( daṃrok " ដើមកន្ទ្រោក " )

វ្រៃ វេក្ក vrai vekk K 107, វ្រៃ វេក្ក ( vekk " យោលដោយខ្យល់ " ) ។

ចាប់ពីដើមសម័យអង្គរមក ពាក្យ vrai ត្រូវបានគេប្រើប្រាស់ជាធាតុផ្សំនៃស្ថាននាមសំរាប់ហៅទីប្រជុំជន ។ នៅក្នុងអត្ថបទសិលាចារឹកជាច្រើន ក្នុងសម័យនោះ រៀបរាប់ពីការកាប់គាស់ព្រៃ សំអាតដី ដើម្បីបង្កើតភូមិថ្មីៗ ។ ឧ.

ឆ្កា វ្រៃ ចត៑ ស្រុក៑ chkā vrai cat sruk K 344, ឆ្កា វ្រៃ ចត៑ ស្រុក៑ " ឆ្ការព្រៃ ដើម្បីបង្កើតភូមិ " ។

ឆ្កា វ្រៃ ថ្វេ ទេវស្ថាន chkā vrai thve devasthāna K 736, ឆ្កា វ្រៃ ថ្វេ ទេវស្ថាន " ឆ្ការព្រៃ ស្ថាបនាព្រះវិហារ " ។ ដើម្បីរំលឹកអនុស្សាវរីយ៍ទីព្រៃកាប់ឆ្ការនេះ គេហៅ ភូមិថ្មីនេះដោយឈ្មោះដដែល ។ ឧទាហរណ៍ៈ

ភូមិ វ្រៃ ខ្លា bhūmi vrai khlā K 34, ភូមិ វ្រៃ ខ្លា ( khlā " ខ្លា" ) ។

ខ្លោញ៑ វ្នំ វ្រៃ គ្មុំ khloñ vnaṃ vrai gmuṃ K 669, ខ្លោញ៑ វ្នំ វ្រៃ គ្មុំ (gmuṃ " ទឹកឃ្មុំ " ) ។

ស្រុក៑ វ្រៃ រន្លវស៑ sruk vrai ranlvas K 344, ស្រុក វ្រៃ រន្លិវស៑ (ranlvas " រលួស " ) ។

ស្រុក៑ វ្រៃ ត្បេង៑ sruk vrai tpeṅ K 292, ស្រុក វ្រៃ ត្បេង៑ ( tpeṅ " ត្បែង " ) ។

នៅក្នុងសិលាចារឹកនានា គេបានរកឃើញស្ថាននាម ដែលមានពាក្យ

" វ្រៃ " vrai ចំនួន ៦៣ ។ នៅក្នុងភាសាខ្មែរសម័យបច្ចុប្បន្ន ពាក្យនេះត្រូវរក្សាក្នុងទំរង់ brai / prey " ព្រៃ " ហើយពាក្យនេះ នៅតែចូលរួមយ៉ាងសកម្មក្នុងការបង្កើតឈ្មោះទីប្រជុំជន ។

IV. ២. **Caṃkār**  , **Caṃkā** 

ចំការិ, ចំកា " ចំការ " ។ ពាក្យនេះ ជាពាក្យកម្លាយ ដោយប្រើផ្នត់ដែកលើកិរិយាស័ព្ទ chkār K 736 ឆ្កា " ឆ្ការ " ។ នៅក្នុងន័យទូលាយជាងនេះ ពាក្យ camkār មានន័យថា ដីខ្ពស់ មិនលិចទឹក ដែលគេដាំដំណាំផ្សេងៗ ផ្ទុយពីដីទំនាប ( karoṃ ) ដែលគេដាំ ស្រូវ ។ ឧទាហរណ៍ :

 caṃkār li K 664, ចំការិលិ " ចំការលើ ", ( li " ខ្ពស់, លើ " ) ។

 sruk caṃkā sdāṅ K 476, ស្រុក ចំកា ស្តាង ( sdāṅ " ស្តាំង " ) ។

 sruk caṃkā puruṣa K 183, ស្រុក ចំកា បុរុឞ ( puruṣa " បុរស " ) ។

IV. ៣. **Sre**  

ស្រេ " ស្រែ " ។ ពាក្យនេះជាពាក្យសំខាន់ណាស់ និងកើតមានជាយូរលង់មកហើយ ។ ពាក្យនេះគេប្រើប្រាស់យ៉ាងទូលាយ ។ វាជាបច្ចេកពាក្យ មិនត្រឹមតែសំរាប់បង្កើតស្ថាននាមនៃទីប្រជុំជនប៉ុណ្ណោះទេ តែក៏សំរាប់បង្កើតនាមរបស់ជនជាតិ មន-ខ្មែរពីរ ដែលជាជនជាតិភាគតិច នៅប្រទេសកម្ពុជា និងនៅវៀតណាម ។ ជនជាតិទាំងពីរនោះគឺ ជនជាតិ ស្រេ Sre និងជនជាតិ សំរែ Saṃre ។

នៅក្នុងសិលាចារឹកនានា ពាក្យ sre គេជួបប្រទះញឹកញាប់ណាស់ ក្នុងឈ្មោះស្រែជាច្រើនរាប់មិនអស់ ដែលជាកម្មសិទ្ធិរបស់វត្តអារាម ឬ របស់ឯកជន ។ ឈ្មោះស្រែនានា អាចចាត់ទុកថាជាស្ថាននាមអថេរ ហើយគេអាចសំគាល់ដោយការប្រើរុក្ខជាតិ ។ ប៉ុន្តែ ឈរលើមូលដ្ឋាននៃឈ្មោះទាំងនេះ គេអាចធ្វើបុនស្ថាបនាវចនស័ព្ទខ្មែរបុរាណមួយចំនួន ដោយឡែក គឺនាមវលិ នៃបច្ចេកពាក្យរុក្ខវិទ្យា ។

ពាក្យ sre " ស្រែ " និងពាក្យ sruk " ស្រុក " នៅក្នុងអត្ថបទសិលាចារឹកមួយចំនួន តែងស្ថិតនៅជិតគ្នា ។ ប្រការនេះ អាចឱ្យយើងនឹកឃើញអំពីស្ថានភាពនៃប្រទេសកម្ពុជា គឺថា ជាប្រទេសដែលទីប្រជុំជនត្រូវព័ទ្ធជុំវិញដោយវាលស្រែ ។

ពាក្យ sre " ស្រែ " ស្ថិតនៅក្នុងសមាសភាព នៃស្ថាននាមដូចតទៅ ៖

ស្រុក៑ ស្រេ ប្រសាទ — sruk sre prasāda K 292, ស្រុក៑ ស្រេ ប្រសាទ " ស្រែព្រះរាជទាន ", ( prasāda " ព្រះរាជទាន " ) ។

ស្រុក៑ កន្តាល៑ ស្រេ — sruk kantāl sre K 425, ស្រុក៑ កន្តាល៑ ស្រេ " ស្រុក កន្តាល " ស្រែ ", (kan tāl " កណ្តាល ") ។

អន្រាយ៑ ស្រេ វ្លេង៑ — anrāy sre vleṅ K 57, អន្រាយ៑ ស្រេ វ្លេង៑ " ស្រែរបស់វត្ត , ភ្លើងជាទីសក្ការៈ ", ( vleṅ " ភ្លើង " ) ។

ឆ្ទិង៑ ស្រេ វ្រះ — chdiṅ sre vraḥ K 966 ឆ្ទិង៑ ស្រេ វ្រះ, ( vraḥ ព្រះ , ព្រះវិហារ , ប្រាសាទ ) ។

## IV. ៤. Gaãṅ ក្លាង៑

គ្លាង ( " លំនៅ " ) ។ តាម P. Dupont ពាក្យ gaãṅ មានប្រភព ចេញពីភាសាមន ។ នៅក្នុងសិលាចារឹក សតវត្សទី XI ពាក្យនេះ គេប្រើជាធាតុផ្សំ នៃស្ថាននាមដែលតាងទីប្រជុំជន ។ ឧទាហរណ៍ ៖

ស្រុក៑ គ្លាង៑ កន្ទិន៑ sruk gaãṅ kandin K 467, ស្រុក គ្លាង កន្ទិន, ( kandin " កន្ទិន " ) ។

ស្រុក៑ គ្លាង៑ រុង៑ sruk gaãṅ ruṅ K 206, ស្រុក គ្លាង រុង ( ruṅ " ធំ " ) ។

គ្លាង៑ ខ្វិត៑ gaãṅ khvit K 393, គ្លាង ខ្វិត (khvit " ខ្វិត ") ។

លើសពីនេះទៀត នៅក្នុងសិលាចារឹកនានា គេរកឃើញស្ថាននាមដែល មានពាក្យ " gaãṅ " ចំនួន ១០ ។

## IV. ៥. Daṃnap ទំនប៑

ទំនប " ទំនប់ " ។ ពាក្យទំនប គឺជាពាក្យកម្លាយចេញពីកិរិយាស័ព្ទ dap ទប " ទប់ " K 90 ដោយប្រើផ្នត់ដែក - aṃn - ។ ពាក្យនេះ គេចាប់ផ្ដើមប្រើ នៅក្នុងសិលាចារឹក សតវត្សទី VII នៅក្នុងន័យ " ទំនប់ " ពេលគេពិពណ៌នា អំពី សំណង់ធារាសាស្ត្រ ដែលសង់ឡើងដោយអ្នកភូមិ អ្នកស្រុក នៅក្នុងសម័យអង្គរ ពាក្យនេះក្លាយជាពាក្យបច្ចេកពាក្យស្ថាននាម សំរាប់ហៅទីប្រជុំជន ។ ឧទាហរណ៍ ៖

ស្រុក៑ ទំនប៑ បាក៑ sruk daṃnap pãk K 467, ស្រុក ទំនប បាក ( pãk " បាក់ " ) ។

ស្រុក៑ វ្រះ ទំនប៑ sruk vraḥ daṃnap K 182, ស្រុក វ្រះ ទំនប (vraḥ " ព្រះ ") ។

ដូច្នេះ ពាក្យនេះមានន័យថា " ទំនប់ដែលសង់ឡើងតាមតំរូវការ របស់វត្តអារាម " ។ ជារួម នៅក្នុងអត្ថបទសិលាចារឹក គេរកឃើញស្ថាននាមដែលមានពាក្យ " ទំនប់ " ចំនួន ១០ ។

## IV. ៦- Cpar  Chpār 

ច្បរ៑ ( KPA ), chpār ឆ្បារ៑ ( KA ) " សួន, ច្បារ ដំណាំ " ។ ពាក្យ cpar គឺជាពាក្យកម្លាយដោយផ្នត់ដែក - P - ទៅលើកិរិយាស័ព្ទ car / cār ចរ៑ / ចារ៑ K 872 " ចារ " ។ ឧទាហរណ៍ :

 bhūmi chpar aṃvau K 194, ភូមិ ច្បារអំពៅ ( aṃvau " អំពៅ " ) ។

 Kaṃmrateṅ jagat chpār ɪansi K 178, កំម្រតេង៑ ជគត៑ ឆ្បារ៑ រន្សិ ( ransi " ឫស្សីៈ វត្តច្បារ រន្សិ " ) ។

 cpar pares ច្បរ៑ បរេស៑ K 9, ( pares " ប្រើស ; វត្តច្បារប្រើស " ) ។

នៅក្នុងអត្ថបទសិលាចារឹក សួនច្បារ និងរមណីយដ្ឋាន ដែលគេហៅដោយពាក្យ cpār / chpār គេអាចដឹងបានថា ជាភូមិឋាននៃវត្តអារាម ព្រហ្មញ្ញសាសនា ដែលមានការថែទាំពិសេស ។ គេអាចនិយាយបានម្យ៉ាងទៀតថា តាមលក្ខណៈនៃអត្ថបទសម័យអង្គរ ក្នុងវត្តនីមួយៗ មានសួនច្បារ ឬ រមណីយដ្ឋាន យ៉ាងហោចណាស់ ក៏មួយដែរ ។ នៅក្នុងសិលាចារឹក ជាភាសាសំស្ក្រឹត ពាក្យ " សួនច្បារ, ច្បារ " ត្រូវនឹងពាក្យសំស្ក្រឹត ārāma អារាម ដែលមានន័យថា " កន្លែង

" សំរាក " ឬ " ( កន្លែង ) រមណីយដ្ឋានផ្នែកសាសនា " ។ ប្រហែលជាដូចនេះ ហើយបានជា ជនជាតិខ្មែរប្រើពាក្យ cpãr / chpãr ជាស្ថាននាម សំរាប់ហៅ ប្រាសាទ ព្រះវិហារ ឬ វត្តអារាម ។

បណ្ឌិត **ឡុង សៀម**
សាស្ត្រាចារ្យសិលាចារឹក និងអក្សរសាស្ត្រ
នៅសាកលវិទ្យាល័យភូមិន្ទ ភ្នំពេញ
ព្រឹទ្ធសហាការីវិទ្យាសាស្ត្រ បណ្ឌិត្យសភា
វិទ្យាសាស្ត្រសហពន្ធរុស្ស៊ី

# ក្រោមការដឹកនាំរបស់ព្រះធម៌

## - ឆ្ពោះទៅរកការអភិវឌ្ឍន៍ និងការដុះដាល



ឧទ្ទេសកថា - ការពិភាក្សា ដើម្បីផ្លាស់ប្តូរទស្សនះ និងកាចេះដឹង

---

ក.ភ.ន. អត្ថបទខាងក្រោមនេះ ត្រូវបានបកប្រែសម្រួលពីអត្ថបទ ដែលមានចំណងជើងថា : « UNDER THE GUIDANCE OF THE DHAMMA - Towards development and growth » របស់ព្រះភិក្ខុ សាស្ត្រាចារ្យ ធម្មវិហារិ ( Bhikkhu Professor Dhammavihari ) ដែលលោកបានធ្វើឧទ្ទេសកថា - សាកច្ឆា ( lecture - discussion ) កាលពីថ្ងៃទី ៧ សីហា ១៩៩៦ នៅពុទ្ធសាសនបណ្ឌិត្យ វត្តឧណ្ណាលោម

ក្រុងភ្នំពេញ ។ ព្រះភិក្ខុ សាស្ត្រាចារ្យ ធម្មវិហារិ សញ្ជាតិស្រីលង្កា មានកិត្តិនាមល្បីល្បាញ ជាអ្នកប្រាជ្ញអន្តរជាតិ សព្វថ្ងៃគង់នៅប្រទេសអូស្ត្រាលី ហើយត្រូវបាននិមន្តមកបំពេញបេសកកម្ម ដើម្បីវាយតម្លៃលើលទ្ធផលនៃកិច្ចសហប្រតិបត្តិការរវាងពុទ្ធសាសនបណ្ឌិត្យ និងមូនិធិ ហ៊ារិចបឺល - ប្រទេសអាល្លឺម៉ង់ ។ ឆ្លៀតឱកាសនេះ, ពុទ្ធសាសនបណ្ឌិត្យ បាននិមន្តលោក អោយធ្វើឧទ្ទេសកថា - ពិភាក្សាមួយពេលព្រឹក ដើម្បីផ្លាស់ប្តូរទស្សនៈ និងការចេះដឹង ។ ដោយមើលឃើញសារប្រយោជន៍នៃទស្សនៈនៅក្នុងអត្ថបទរបស់លោក, ទើបយើងខ្ញុំសម្រេចចិត្តបកប្រែ ហើយចុះផ្សាយ ដូចខាងក្រោមនេះ ។

បកប្រែដោយ **ឈន អៀម**

ប្រសិនបើយើងចង់យល់ទស្សនៈរបស់ព្រះពុទ្ធសាសនា ស្តីពី « ធម្មៈ » ( សំស្ក្រឹត ធមិៈ ) អោយបានពិតប្រាកដ និងត្រឹមត្រូវ យើងត្រូវតែនិយាយដោយឱឡារិកថា ធម្មៈ កើតមានឡើង គឺដើម្បីដឹកនាំយើងក្នុងជីវិតរស់នៅរបស់យើង ។ នៅក្នុងការសំណេះសំណាលរបស់ខ្ញុំព្រះករុណា អាត្មាភាព ចំពោះអស់លោកលោកស្រី ថ្ងៃនេះ, ខ្ញុំព្រះករុណា អាត្មាភាព សុំស្នើលើកយកតែចំណុចជាក់ស្តែងបីប៉ុណ្ណោះ ។ ខ្ញុំព្រះករុណា អាត្មាភាព នឹងខិតខំអោយអស់ពីលទ្ធភាព ដើម្បីអធិប្បាយអោយបានច្បាស់នូវអ្វីដែលពាក្យ « ធម្មៈ » សំដៅដល់ នៅក្នុងបរិបទនៃពុទ្ធសាសនា ។ បន្ទាប់មក ខ្ញុំព្រះករុណា អាត្មាភាព នឹងខិតខំស្រាយបំភ្លឺនូវទស្សនៈអំពីជីវិត ។ សូមកត់សម្គាល់ថា ខ្ញុំព្រះករុណា អាត្មាភាព មិនអធិប្បាយច្រើនទេ អំពីជ្រុងជីវសាស្ត្រ, ឥឡូវនេះ យើងយល់ដឹងច្រើនណាស់អំពីទារកកើតនៅក្នុងបំពង់ពិសោធ ( testtube babies ) និងអំពីភ្រូណ ( មេកំណើត ) បង្កក ( frozen embryos ) ដែលរក្សាទុកក្នុងឃ្លាំងបង្កកខ្លាំង មកដល់ពេលនេះជិតរយៈពេលប្រាំឆ្នាំ

ហើយ ។ មនុស្សជាតិ បានធ្វើជាម្ចាស់លើសិល្បៈរក្សាជីវិតអោយរស់នៅបាននៅក្នុងទីត្រជាក់យ៉ាងខ្លាំង, ប៉ុន្តែ មុខជំនាញនេះ ត្រូវបានគេមើលឃើញថាបាននាំមកនូវមហន្តរាយនៅពេលក្រោយមក ។ សារពត៌មានទីក្រុងម៉ែលបួន ឈ្មោះ « The Age » ( អាយុ ) ចេញថ្ងៃពុធ ទី២៤ ខែកក្កដា ឆ្នាំ ១៩៩៦ បានរាយការណ៍ថា : « ភ្រូណា ( embryos ) ជាង ៣,៣០០ រក្សាទុកក្នុងឃ្លាំងបង្កកខ្លាំង កំពុងត្រូវបានត្រៀមបំផ្លាញចោល នៅថ្ងៃពុធក្រោយ ត្រឹមកំរិតបង្ករយៈពេលប្រាំឆ្នាំ ដោយអាជ្ញាធរបង្កើតមនុស្ស និងភ្រូណាសាស្ត្រ នៃប្រទេសអង់គ្លេស ( Britain's Human Fertilization and Embryology Authority ) ប្រសិនបើឪពុកម្តាយទាំង ៩០០ នាក់ ជាម្ចាស់កម្មសិទ្ធិលើភ្រូណាទាំងនោះ មិនបានទាក់ទងមន្ទីរមេកំណើត ( The fertility clinics ) ដែលភ្រូណាត្រូវបានរក្សាទុកនោះទេ » ។

សេចក្តីសង្កេតរបស់ខ្ញុំព្រះករុណា, អាត្មាភាព នឹងផ្តោតខ្លាំងទៅលើចំណុចដែលថា តើយើងរស់នៅយ៉ាងណា បន្ទាប់ពីយើងបានកើតមក, នៅក្នុងទំនាក់ទំនងបែបណា នៅក្នុងចំណោមមនុស្សជាមិត្រភ័ក្តិរបស់យើង ។ ហើយយើងរស់នៅសំរាប់អ្វីដែរ ក្នុងឋានៈជាបុគ្គល ឬក្នុងឋានៈជាប្រជាជាតិ ។ តើគោលដៅ និងគោលបំណងរបស់យើង គឺអ្វីខ្លះ ? ចំណុចទីបី និងចុងក្រោយ ដែលខ្ញុំព្រះករុណាអាត្មាភាព នឹងអធិប្បាយដល់ គឺទស្សនៈនៃការណែនាំ ។ ក្នុងឋានៈជាមនុស្សកំពុងរស់នៅក្នុងលោកនេះ ជាមួយនឹងសេរីភាពក្នុងការនិយាយ និងសេរីភាពក្នុងការធ្វើ ស្ទើរតែគ្មានព្រំដែន ហើយដោយមានវិស័យដទៃទៀតជាច្រើននៃសេរីភាព ដែលបុរសស្ត្រី និងកុមារ កំពុងតែស្វែងរកសព្វថ្ងៃ, តើយើងអាចរកឃើញចំណែកពេលតិចតួចមួយ នៅក្នុងជីវិតរបស់យើង ដើម្បីបង្កើតទស្សនៈសម្រាប់ណែនាំ, រកឃើញចន្លោះពេលតូច ណាមួយសម្រាប់ទទួលការណែនាំឬទេ ? យើងប្រាកដជាត្រូវការវា, យ៉ាងហោចណាស់ក៏ស្មើនឹងអ្នកជិះម៉ូតូ ត្រូវការច្បាប់ចរាចរ នៅពេលគេជិះម៉ូតូ

របស់គេកាត់តាមផ្លូវចង្អៀត នៃទីក្រុងដែរ ។ គេត្រូវការត្រឹមប៉ុណ្ណេះ បើទោះជាគេច្បាស់ក្នុងចិត្តថា គេកាន់ចង្កូតស្ដាំក៏ដោយ ។ ចំពោះយើង, វាជាច្បាប់ចរាចរនៃជីវិត ដែលចេញមកពីវង្វង់សាសនា ឬពីការលូតលាស់ខាងស្មារតី, ដោយយើងហៅច្បាប់នោះ តាមឈ្មោះអ្វីក៏ដោយ ។

ខ្ញុំព្រះករុណា, អាត្មាភាពដឹងថា ប្រទេសកម្ពុជាពីមុន កាន់ពុទ្ធសាសនា ហើយឥឡូវ ក៏កាន់ពុទ្ធសាសនា ហើយខ្ញុំព្រះករុណា អាត្មាភាព ក៏បានដឹងច្បាស់ដែរថា ខ្ញុំព្រះករុណា អាត្មាភាព កំពុងមានថេរដីកាទៅកាន់អង្គប្រជុំ ដែលជាអ្នកកាន់ពុទ្ធ-សាសនាស្ទើរតែទាំងអស់ ។ ខ្ញុំព្រះករុណា អាត្មាភាព សុំអស់លោក លោកស្រី ខន្តីអភ័យទោសផងចុះ ។ ព្រោះថា ខ្ញុំព្រះករុណា អាត្មាភាព មិនមានបំណងប្រដៅក្រពើអោយហែលទឹកទេ ( to carry coals to Newcastle ) ។ ប៉ុន្តែថា វាស័ក្តិសមនឹងការប៉ុនប៉ងយកមកប្រើឡើងវិញនូវ អនុស្សាវរីយ៍របស់យើងដែលបាត់បង់ទៅអំពីតម្លៃនៃ *ធម៌:* នៅក្នុងជីវិតរបស់យើង ។ ធម៌ៈត្រូវបានយកមកប្រើយ៉ាងចាំបាច់ជានិច្ច ដើម្បីធ្វើអោយមានស្ថិរភាពនៅក្នុងប្រវត្តិមនុស្សជាតិ ។ នៅទីណា មនុស្សបានសំរេចជោគជ័យដ៏ឧត្តុង្គឧត្តម ហើយរក្សាខ្ជាប់នូវជោគជ័យទាំងនោះ អស់រយៈកាលមួយយ៉ាងវែង, នោះក៏ព្រោះតែអរិយធម៌របស់មនុស្សទាំងនោះ ត្រូវបានស្ថាបនាឡើងនៅលើតម្លៃទាំងឡាយ ដែលទៅហួសឆ្ងាយជាងតម្លៃសម្ភារះប្រចាំថ្ងៃគឺនំប៉័ង និងបីរ និងទ្រព្យសម្បត្តិដ៏គ្រោតគ្រាតនេះទៅទៀត ។

បន្ទាប់ពីការមានជីវិត និងការប្រើប្រាស់អស់ពេលជាងម្ភៃប្រាំសតវត្សមក, ពាក្យថា " ធម្មៈ " នៅក្នុងពុទ្ធសាសនា ត្រូវបានទទួលឋានៈដ៏ល្បីរន្ទឺថាជាប្រភពនៃផាសុកភាពផង និងបំណងប្រាថ្នាផង, យើងនឹងពន្យល់ ហើយបំភ្លឺបញ្ហានេះតទៅខាងមុខ ។ ដើម្បីចាប់ផ្ដើម, ពាក្យ " ធម្មៈ" គឺជាពាក្យមានដើមកំណើតពីឥណ្ឌា ហើយត្រូវបានគេប្រើយ៉ាងទូលំទូលាយនៅក្នុងប្រព័ន្ធសាសនាឥណ្ឌា ។ នៅក្នុងអត្ថន័យ

សង្ខេបយ៉ាងខ្លី, ធម្មៈ មានន័យថាជាប្រព័ន្ធនៃការបង្រៀន, ជាទ្រឹស្តី ឬជាប្រពៃណីសាសនា ។ អត្ថន័យគ្រឹះរបស់ធម្មៈ គឺ "អ្វីដែលទ្រទ្រង់ ឬគាំទ្រ, គ្រឹះគាំទ្រ" ។

ដំណាក់ទាំងបួននៃជីវិតជាប្រពៃណីរបស់ជនជាតិឥណ្ឌា ត្រូវបានគេស្គាល់ថា « ចតុ អាស្រម ធមិ » គឺធមិជាអាស្រមបួនយ៉ាង ។ ធមិជាអាស្រមទាំងបួននោះ គឺ ៖ ១. ជីវិតជានិស្សិតកំពុងរៀនច្បាប់សាសនា ដែលគេហៅថា « *ព្រហ្មចារិន* », ២. ជីវិតជាគ្រហស្ថគ្រប់គ្រងផ្ទះ ចិញ្ចឹមបីបាច់គ្រួសារ ឬហៅថា « *គ្រហស្ថ* », ៣. ជីវិតជាអ្នករស់នៅក្នុងព្រៃ លះបង់លោកនេះ ឬ ហៅថា « *វានប្រស្ថ* », ៤. ជីវិតជាអ្នកបួស ឬតាបស ដកខ្លួនចេញផុតស្រឡះ ឬ ហៅថា « *សន្យាសិន* » ។ ឥណ្ឌាក៏មានប្រព័ន្ធអប់រំ សម្រាប់គ្រប់គ្រងជីវិតនៅក្នុងសង្គមមនុស្សដែរ, ពេលខ្លះ ក៏មានភាពរឹងត្អឹងពិបាកកែតម្រូវ ដែលឋិតនៅក្រោមឈ្មោះ « *ធម្មសាស្ត្រ* » ។ ធមិជាអាស្រមទាំងបួននេះ បានគ្របដណ្តប់សង្គមឥណ្ឌាអស់ពេលរាប់រយឆ្នាំហើយ ។ អាស្រមខ្លះ ក្នុងបណ្តាអាស្រមទាំងបួន ពិបាកទទួលយកបាន, មានពេលខ្លះ បង្កើតអោយមានការបែងចែកវណ្ណៈយ៉ាងជូរចត់ ហើយរហូតដល់កើតមានអំពើអយុត្តិធមិសង្គមមកលើមនុស្សប្រុស-ស្រី ដោយសារតែហេតុផលអោយគេស្គាល់ខ្លួនគ្រាន់បើ ។ ចំពោះការប្រព្រឹត្តផ្តេសផ្តាសខុសឆ្គងនេះ វាជាការជាក់ស្តែងណាស់ គឺបណ្តាលមកពីការប្រើបំពាន ឬការរំលោភលើពាក្យ*ធមិៈ* ។

គឺពួកអ្នកកាន់សាសនាជេន, ប្រហែលជាកើតមានមុនសម័យកាលព្រះពុទ្ធគោតមបន្តិច, ដែលបានប្រកាសថា ៖ « ការគោរពចំពោះជីវិតគ្រប់រូបភាព គឺជា*ធមិៈ*ដ៏ខ្ពង់បំផុត ៖ « *អហឹសា បរមោ ធមិះ* » ។ ព្រះពុទ្ធគោតម ដែលបានបដិសន្ធិឡើងនៅក្នុងប្រទេសឥណ្ឌា នាសតវត្សទីប្រាំមួយ មុនគ្រិស្តសករាជ ទ្រង់បានសំដែងធមិដែលបានលើកកំពស់បុរស រួមទាំងស្ត្រីផងដែរ - ដល់កិរិតវិសេសវិសាលខ្ពស់បំផុត, គឺដល់កិរិតជោគជ័យឯតទគ្គៈ ជាទស្សនិជ្ជាដ៏ប្រសើរយ៉ាងពិត សម្រាប់ជីវិតរបស់

មនុស្សជាតិ ក្នុងបច្ចុប្បន្ននេះ ។ គឺព្រះពុទ្ធគោតមនេះទៀត ដែលទ្រង់បានប្រកាសថា « សេចក្តីស្រឡាញ់រាប់អានក្នុងចំណោមមនុស្ស ដោយគ្មានគំនុំគុំគួន និងភាពស្អប់ខ្ពើមគ្នា គឺជាក្រឹត្យក្រមអមតៈ ដែលនាំមកនូវសុខសន្តិភាពលើផែនដីនេះ [ *ន ហិ វេរេន វេរានិ សម្មន្តី'ធ កុទាចនំ, អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ* » ] ។ (ធម្មបទ) ។

ចូរចាត់ទុកមនុស្សទាំងឡាយនៅជុំវិញលោកអ្នកថា ជាមនុស្សមិនខុសអ្វីអំពីលោកអ្នកឡើយ ។ ចូរធ្វើយ៉ាងនេះ នៅលើមូលដ្ឋានឡូស៊ិកជាក់ស្តែង នៃសេចក្តីជឿទុកចិត្ត និងការយកចិត្តទុកដាក់ ដែលលោកអ្នកប្រកាន់យកសម្រាប់ខ្លួនរបស់លោកអ្នក ។ ចូរកុំធ្វើទុក្ខបុកម្នេញអ្នកឯទៀត ពិព្រោះតែលោកអ្នកស្រឡាញ់ខ្លួនរបស់លោកអ្នក ហើយលោកអ្នកក៏មិនចង់អោយអ្នកឯទៀតធ្វើទុក្ខបុកម្នេញលោកអ្នកដែរ ។ ព្រះពុទ្ធមានពុទ្ធដីកាទៅកាន់ព្រះរាជាបសេនទិ នៃរដ្ឋកោសល ថា « ក្នុងគ្រប់ទិសទី ដែលបុគ្គលដើរទៅ, ទោះជាខាងកើត ឬ ខាងលិច, គេនឹងមិនអាចរកឃើញអ្នកដទៃណា ដែលជាទីស្រឡាញ់ជាងខ្លួនរបស់គេឡើយ » ( *សព្វា ទិសា អនុបរិគម្ម ចេតសា នេវ'ជ្ឈគា បិយតរំ អត្តនា ក្វចិ ឯវំ បិយោ បុថុ អត្តា បរេសំ តស្មា ន ហឹសេ បរំ អត្តកាមោ* ) ។ សំយុត្តនិកាយ ។

ច្រើនសតវត្ស មុនការកកើតឡើងនៃធម្មនុញ្ញ ស្តីពីសិទ្ធិជាមូលដ្ឋានរបស់មនុស្ស រួមបញ្ចូលទាំងការគោរពជីវិត និងសិទ្ធិរស់នៅដោយគ្មានការគំរាមកំហែង ឬភ័យខ្លាច, ព្រះពុទ្ធបានដាក់បញ្ញត្តិយ៉ាងច្បាស់លាស់រួចហើយថា : « សត្វមានជីវិតទាំងអស់សុទ្ធតែខ្លាចសេចក្តីស្លាប់ និងសេចក្តីវិនាស ហើយជីវិតនោះជាទីស្រឡាញ់ពេកណាស់ ចំពោះសត្វទាំងអស់កំពុងរស់នៅ » [ *សព្វេ តសន្តិ ទណ្ឌស្ស សព្វេសំ ជីវិតំ បិយំ* ] ។ ព្រះពុទ្ធទ្រង់បានមានពុទ្ធដីកាថា :" ចូរអ្នកចងចាំថា អ្វីដែលជាសច្ចៈចំពោះអ្នក នោះក៏ជាសច្ចៈចំពោះមនុស្សទាំងអស់ដែរ ។ ដោយហេតុនេះ គេមិន

គប្បីផ្តាច់ផ្តិលជីវិតរបស់អ្នកដទៃទេ ។ ទស្សនះស្តីពី *ធម៌ះ* ត្រូវតែបានគេទទួលស្គាល់ថាជាធមិជីថ្លៃថ្នូរយ៉ាងពិតប្រាកដ ។ ទស្សនះនៃធមិនេះ ពិតជាគ្រប់សង្កត់មកលើអស្មិមានះ និងអាត្មានិយមរបស់យើង, ទាំងជាបុគ្គល និងទាំងជាសម្ហូហភាព ។ បុគ្គលត្រូវបន្ធូរបន្ថយក្របខ័ណ្ឌវណ្ណៈរឹងត្អឹងរបស់ខ្លួន ស្តីពីអត្តសញ្ញាណជាតិ និងសាសនា, អត្ត-សញ្ញាណនយោបាយ និងជនជាតិ ព្រមទាំងបន្ធូរបន្ថយសញ្ញាណបំប៉ោងហួសហេតុអំពីឧត្តមភាពដែលកំពុងគំរាមកំហែងពិភពលោកសព្វថ្ងៃ មិនចេះចប់មិនចេះហើយ។

ក្របខ័ណ្ឌរបស់យើងក៏ជា *ធម៌ះ* មួយដែរ ដែលធ្វើអោយជីវិតសម្បូរសប្បាយជាងនេះ ទោះបីជាជឿក្តី ឬមិនជឿក្តី ។ ប៉ុន្តែ ពុទ្ធសាសនាបានបញ្ញត្តិសម្រាប់អោយមានជោគជ័យ និងសុភមង្គលឯបរលោកបាន តែតាមការថែរក្សា និងការពារសមិទ្ធផលរបស់មនុស្សនៅក្នុងលោកនេះប៉ុណ្ណោះ ។ កម្មសិទ្ធិ និងភាពត្រឹមត្រូវនៅក្នុងទំនាក់ទំនងរបស់មនុស្សនៅក្នុងលោកដែលគេរស់នៅសព្វថ្ងៃនេះ គឺជាអ្វីដែលបង្កើតឡើងនូវសុភមង្គលដ៏ពិតក្នុងគ្រប់ទីសទី ។ ការភ្លាំងភ្លាត់ មិនបានរក្សាសិក្ខាបទទាំងប្រាំ នៃបញ្ចសីល ( មានការគោរពជីវិតរស់នៅ, ការគោរពសិទ្ធិរបស់អ្នកឯទៀត ជាម្ចាស់លើកម្មសិទ្ធិ . ល . ) ត្រូវបានគេនិយាយថា នឹងបណ្តាលអោយកើតឡើង នូវការធ្លាក់ចុះប្រកបដោយមហន្តរាយរបស់មនុស្ស នៅក្នុងជីវិតបច្ចុប្បន្ននេះ *( ឥធេ'វ ឯសោ លោកស្មិ មូលំ ខណតិ អត្តនោ* ។ (ធម្មបទ ) ។ វាជាអាកប្បកិរិយាប្រឆាំងសង្គមដោយផ្ទាល់របស់មនុស្ស, ជាអសមត្ថភាពរបស់មនុស្ស ប្រសិនបើមិនអាចរួមរស់នៅបានជាសុខដុមរមនាជាមួយមនុស្សដូចគ្នា, ដោយគ្មានការយោងទៅរកទស្សនះទេវៈ ដែលបង្កអោយមានការភ័យខ្លាច ដែលគ្របសង្កត់មកលើយើងទាំងស្រុងពីខាងក្រៅ ដែលគេនិយាយថាជាអ្នកបង្កសេចក្តីវិនាសអោយមនុស្សនៅក្នុងជីវិតនេះ ។ វាជាអំពើស្វ័យវិវត្តទេ ។ ចូរកុំបន្ទោសអ្នកឯទៀត គឺជាច្បាប់នៅក្នុងពុទ្ធសាសនា ។

ការប្រៀនប្រដៅរបស់ព្រះពុទ្ធ បានទូន្មានយើងថា អ្នកណារស់នៅតាមគន្លងធម្មៈ រមែងរក្សាបានសម្រាប់ខ្លួន នូវសុភមង្គលក្នុងលោកនេះ និងលោកខាងមុខ ។ នៅក្នុងពុទ្ធដីកាផ្ទាល់, ព្រះពុទ្ធបានសំដែងធម្មៈដូចនេះថា : " *ធម្មចារី សុខំ សេតិ អស្មឹ លោកេ បរម្ហិ ច* " ( ធម្មបទ ) ។ សន្តិសុខផ្ទាល់ខ្លួន សម្រាប់ខ្លួនឯងផ្ទាល់ រមែងបានមកតាមរយៈមាគ៌ាដែលបុគ្គលប្រព្រឹត្តចំពោះអ្នកឯទៀត ពោលគឺ ប្រព្រឹត្តស្របតាមធម្មៈ ដែលមានន័យថា ឋិតនៅក្នុងរង្វង់និយាមសង្គម ដែលគេតែងគោរព ( *ធម្មោ ហវេ រក្ខតិ ធម្មចារី* ) ( ធម្មបទ ) ។ ជីវិតមួយដែលរស់នៅក្នុងក្របខណ្ឌនៃធម្មៈនេះ ពោលគឺ រួមបញ្ចូលការគោរពជីវិត, គោរពសិទ្ធិអ្នកឯទៀត ជាម្ចាស់លើកម្មសិទ្ធិ, គោរពកម្មសិទ្ធិនៃការទំនាក់ទំនងភេទ រវាងបុរស និងស្ត្រី . ល . រមែងបង្កើតអោយមានការទុកចិត្តគ្នា នៅកំរិតណាមួយក្នុងសង្គម, ក្នុងផ្ទះ, ឬនៅកំរិតជាតិ ឬអន្តរជាតិ ។

យោងតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ, បុគ្គលដែលសំរេចបាននូវស្ថានភាពមួយនៃសង្គម, ដែលនៅក្នុងនេះ សន្តិភាព និងសុខដុមរមនា តែងគ្របដណ្តប់ ហើយសន្តិសុខនៃជីវិត និងកម្មសិទ្ធិត្រូវបានធានានោះ គឺចេញមកពីជ្រុងពីរជាក់លាក់ គឺ ទីមួយ ភាពត្រឹមត្រូវជាបុគ្គល និងផ្ទាល់ខ្លួន ដែលនៅក្នុងនេះ មនុស្សត្រូវបានគ្រប់គ្រងពីខាងក្នុង តាមរយៈការវិនិច្ឆ័យផ្ទាល់ខ្លួន ។ ដើម្បីសេចក្តីសុខនៅក្នុងលោក, មនុស្សទទួចអោយមានវត្តមាននៃ*គុណធម៌គ្រប់គ្រងលោក* ឬ*លោក-បាលកធម្មា* ពីរយ៉ាង ។ លោកបាលកធម៌ពីរនោះ គឺ *ហិរិ* និង *ឱត្តប្បៈ*, ពោលគឺ សញ្ញាណនៃការអៀនខ្មាស និងសញ្ញាណនៃការភ័យខ្លាច ដែលហាមឃាត់យើងមិនអោយធ្វើអំពើខុសឆ្គង នៅក្នុងទំនាក់ទំនងរបស់យើង ជាមួយនឹងមនុស្សឯទៀត នៃសង្គម ។ យើងត្រូវចងចាំជាប់ថា មនុស្សទាំងនោះ រួមមានទាំងមនុស្សប្រុស - ស្រីរបស់យើង, កុមារ និងចាស់ព្រឹទ្ធាចារ្យរបស់យើង, អ្នកទាំងឡាយនោះ ដែលធ្វើការ

អោយយើង និងអ្នកទាំងឡាយនោះ ដែលបានចេញទៅឆ្ងាយ ដើម្បីណែនាំជីវិតរស់នៅរបស់យើង ដូចជា គ្រូបង្រៀន, និងព្រះសង្ឃយើង ដែលកំពុងថែបំប៉នការដុះដាលខាងស្មារតីរបស់យើង ។ យើងត្រូវមាននិយាម ( វិន័យ ) របស់យើង ដែលគ្រប់គ្រងចរិយារបស់យើង ចំពោះលោកទាំងឡាយនោះ ។

ក្នុងឋានៈជាមនុស្សចាស់ទុំ យើងត្រូវមានស្មារតីភ្ញាក់រលឹក ចំពោះការទទួលខុសត្រូវជាមាតាបិតា ក្នុងការផ្ដល់សេចក្ដីណែនាំដ៏ជាទីទុកចិត្ត និងជាទីស្រឡាញ់រាប់អានយុវជនយើង ( ហេតុនេះ, កាត់បន្ថយបានបញ្ហាបទល្មើសរបស់យុវជន នៅក្នុងសង្គមជាទូទៅ ), ក្នុងឋានៈជានិយោជក ( employers ) យើងត្រូវដឹងអំពីកាតព្វកិច្ចរបស់យើង ដើម្បីទទួលស្គាល់ទំហំការងារ និងគុណភាពការងារដែលបានធ្វើ ហើយត្រូវអោយប្រាក់ឈ្នួលសមស្របចំពោះសេវាកម្ម ដែលវណ្ណៈពលករបានផ្ដល់ ( ហេតុនេះ, បំបាត់នូវសេចក្ដីទាមទារអោយតុលាការខាងការងារ ជួយដោះស្រាយសេចក្ដីតវ៉ា ) ។ ដូចគ្នាដែរ ក្នុងឋានៈជាយុវជនរស់នៅក្នុងសង្គម យើងត្រូវមានសេចក្ដីភ្ញាក់រលឹក អំពីករណីយកិច្ចរបស់យើង ក្នុងការជួយថែទាំនិងការពារចាស់ព្រឹទ្ធាចារ្យ នៅក្នុងសង្គមរបស់យើង ( ធ្វើដូច្នេះ កាត់បន្ថយបាននូវបន្ទុកលើស្ថាប័នជួយមនុស្សចាស់ ហើយកាត់បន្ថយនូវមនុស្សចាស់រស់នៅក្នុងផ្ទះដ៏ចង្អៀតខ្លោចផ្សារបាន ) ។ នៅកន្លែងណា យើងដឹងថាមានការធ្វេសប្រហែសចំពោះកិច្ចការនេះ, ការពូតកំឡាំងគ្នាមួយដ៏សមស្រប តាមរយៈស្មារតីចេះអៀនខ្មាស និងភ័យខ្លាច ( ហិរិ និង ឱត្តប្បៈ ) ត្រូវតែបានធ្វើឡើង ប្រាប់អោយអ្នកដែលមានកំហុសចំពោះករណីយកិច្ចនេះបានដឹង ដើម្បីកែកំហុសបែបនោះឡើងវិញ ។ ការចាត់តាំងទាំងនេះ ត្រូវបានចង្អុលប្រាប់យ៉ាងច្បាស់ នៅក្នុងការប្រៀនប្រដៅរបស់ព្រះពុទ្ធសាសនា ។ ការភ្ញាក់រលឹករបស់សង្គមជាសមូហភាព ដើម្បីរកអោយឃើញនូវសេចក្ដីធ្វេសប្រហែសបែបនេះ ហើយមានសេចក្ដីក្លាហានអនុវត្តភ្លាមៗ ដោយគ្មាន

ការរស់រអែក ឬការប្រកាន់បក្សពួក គឺជាសេចក្តីត្រូវការចាំបាច់ខ្លាំងប្រចាំថ្ងៃនៅក្នុងទីកន្លែងនៃ ពិភពលោកនេះ ។ ជាញឹកញយ គេឃើញថាមនុស្សភាគច្រើនធ្វើថ្លង់ធ្វើខ្វាក់ ចំពោះការងារនេះ ភ្លេចគិតដល់ផលវិបាករបស់ខ្លួន ប្រកបដោយសេចក្តីវិនាស ។ លទ្ធផលគឺថា នៅក្នុងពិភពលោកសព្វថ្ងៃ យើងខ្វះគំរូឪពុក - ម្តាយដែលកូនអាចយកតម្រាប់តាម ។

អាកប្បកិរិយាទាំងអស់នេះ និងការងារសង្គមប្រកបដោយហេតុផលដែលត្រូវតែប្រតិបត្តិតាមយ៉ាងចាំបាច់ គួរតែហូរចេញមកដោយសេរី ដោយគ្មានរអាក់រអួល ដើម្បីជាអត្ថប្រយោជន៍ទៅវិញទៅមក សម្រាប់សមាជិកសង្គមម្នាក់ៗ ។ កិច្ចការនេះតែប៉ុណ្ណោះ នឹងផ្តល់ចំណែកដល់ដំណើរប្រព្រឹត្តទៅដ៏សុខដុម និងប្រកបដោយផលល្អ នៃក្បាលម៉ាស៊ីនដឹកនាំសង្គមរបស់ប្រទេសណាមួយបាន ។ លទ្ធផលណានីមួយ ដែលសម្រេចបាននៅក្នុងវិស័យនេះ ត្រឹមកិរិតក្នុងស្រុក ទោះតិចក្តីច្រើនក្តី ក៏គួរតែត្រូវបានគេទទួលស្គាល់, គាំទ្រ និងឧបត្ថម្ភដល់កិរិតរដ្ឋផង ។ កិច្ចការនេះ អាចត្រូវបានរៀបចំប្រកបដោយប្រសិទ្ធភាព ដើម្បីបង្កើតជាគ្រឹះដ៏ជាទីទុកចិត្តមួយ សម្រាប់ការអនុវត្តច្បាប់នៅក្នុងសង្គមណាមួយ ។ កិច្ចការនេះ អាចយកទៅអនុវត្តបានល្អ ណាស់ នៅក្នុងវិស័យបទល្មើសខាងគ្រឿងញៀន និងខាងភេទ ( sex ) ដែលមនុស្សក្លាយទៅជាទំនិញ សម្រាប់លក់ដូរយ៉ាងគគ្រឹកគគ្រេង ។

ម្យ៉ាងទៀត, ពុទ្ធសាសនា មានជំនឿទុកចិត្តលើអ្នកទាំងឡាយដែលដឹកនាំប្រទេស ថាមានស្មារតីភ្ញាក់រលឹកចំពោះកាតព្វកិច្ចរបស់ខ្លួន ដើម្បីការពារ និងថែរក្សាប្រជារាស្ត្ររបស់ខ្លួន ។ ស្តេច ឬអ្នកគ្រប់គ្រង ដែលមានស្មារតីភ្ញាក់រលឹកចំពោះករណីយកិច្ច ត្រូវបានគេអំពាវនាវសុំអោយបំពេញការងារនេះ ។ ជីវិតរបស់មនុស្សគ្រប់ជាន់ថ្នាក់ កំពុងបំពេញការងារ ឬបំរើការ តាមសមត្ថភាពផ្សេងៗគ្នា ចំពោះទឹកដី, ត្រូវតែបានទទួលកិច្ចការពារ ។ អ្នកទាំងឡាយនោះ រួមមានទាំងអ្នកបំពេញការងារ

នៅក្នុងរដ្ឋាភិបាលរបស់ប្រទេស, បុគ្គលិកយោធាហ្វឹកហ្វឺនដោយពិសេស ក៏ដូច ជាជនស៊ីវិលផងដែរ ។ ការអធិប្បាយនេះ ក៏ត្រូវពង្រីកដល់ទៅសន្តិសុខ សម្រាប់ ធានាជីវិតសត្វបក្សី និងជីវិតសត្វព្រៃផងដែរ ។ សព្វថ្ងៃនេះ វាហាក់បីដូចជារដ្ឋ ទាំងឡាយកំពុងទម្លាក់ចោលអាវុធរបស់ខ្លួន ក្នុងក្តីអស់សង្ឃឹមនៅចំពោះមុខភេរវ-កម្ម និងវិច្ឆេទកម្មទូទាំងសកលលោក, ដោយមិនអាចប្រឈមមុខដោះស្រាយបញ្ហា នេះបាននៅក្នុងរដ្ឋរបស់ខ្លួនផ្ទាល់, នេះមិនទាន់និយាយដល់បញ្ហាសន្តិសុខអន្តររដ្ឋផង ទេ ។ ស្ទើរតែគ្រប់ទីកន្លែង, វាហាក់ដូចជាមានការបែងចែកគ្នាយ៉ាងធ្ងន់ធ្ងរនៅក្នុងរដ្ឋ លើមូលដ្ឋានអត្តសញ្ញាណសាសនា និងជនជាតិ, សូម្បីតែនៅក្នុងបញ្ហាផ្សេងគ្នាដ៏តូច តាចខាងមនោគមវិជ្ជា, បង្កឡើងដោយសកម្មជន ឬក្រុមសកម្មជនរាត់រាយ ។

ក្រោយពេលបាននិយាយរៀបរាប់ រួចហើយនោះបីតាមបែបសាមញ្ញ មួយអំពីទស្សនៈមួយ ដែលអាចអនុវត្តត្រឹមត្រូវជាសាកលបាន ដែលនៅក្នុងទស្សនៈ នេះផ្នែកផ្សេងៗនៃសហគមន៍មនុស្ស ក៏បានយកមករៀបរាប់ដោយមានការគោរព និងការទទួលស្គាល់ ទុកដូចជាបងប្អូនសុទ្ធសាធ ដោយគ្មានគំនិតអាក្រក់ចេញ មកពីជនជាតិ ពីជំនឿសាសនា ឬពីចំណោះដឹងនយោបាយនោះទេ, ឥឡូវចូរយើង ងាកទៅក្នុងទិសនៃការដុះដាល និងអភិវឌ្ឍន៍ ដែលបានគិតទុកជាមុន រួចហើយ សម្រាប់ផ្នែកណាមួយជាក់លាក់ ( any specific segment ) នៃសហគមន៍នោះ ដែលមានកំណត់ព្រំដែននៅលើមូលដ្ឋាន : តំបន់នៃការតាំងទីលំនៅ ឬអ្វីមួយ ផ្សេង ។ ដើម្បីធ្វើអោយគំរូជីវភាពឥតមន្ទិលសៅហ្មង មានជោគជ័យនៅក្នុងភាគ ណាមួយនៃពិភពលោក ទោះជានៅភាគខាងកើត ឬខាងលិច, គេត្រូវតែមានប្រាក់ កាសចាំបាច់ជាមូលដ្ឋាន ដើម្បីទិញអាហារ, ទិញសម្លៀកបំពាក់, ទិញជម្រក និងទិញ ថ្នាំព្យាបាលសុខភាព ។ គ្មានការបដិសេធណាមួយ ដែលថាសេចក្តីត្រូវការទាំងនេះ មិនត្រូវបានគេទទួលស្គាល់ថាជាសេចក្តីត្រូវការជាមូលដ្ឋាននោះឡើយ ។

ប្រសិនបើទស្សនៈនយោបាយ ស្តីពីអ្នកមាន និងអ្នកក្រ ពោរពេញដោយលក្ខណៈស្មុគស្មាញ ត្រូវបានគេគាំទ្រជាសាកល ដោយមានការគោរពកិរិតណាមួយនោះ, វាក៏ត្រូវតែបានគេទទួលស្គាល់ដោយទូលំទូលាយផងដែរថា វាត្រូវតែមានចលនាហូរចេញដ៏សេរី សមហេតុសមផលនៃទស្សនៈដ៏សំខាន់នេះអំពីទីណាដែលសម្បូរហើយ ទៅកាន់តំបន់ទាំងឡាយដែលគេត្រូវការទស្សនៈនយោបាយនោះយ៉ាងខ្លាំងក្លា ។ ប្រវត្តិពិភពលោកជាច្រើនសតវត្សហើយ បានបញ្ជាក់ប្រាប់យើងថាមានតែវិធីដោះស្រាយនេះតែមួយគត់ ហើយមិនមែនការតវ៉ាដោយអាងឧត្តមភាពដ៏គគ្រឹកគគ្រេង សម្រាប់ក្រុមប្រកាន់ទស្សនៈនយោបាយណាមួយ ទោះបីក្រុមនេះមកពីខាងកើត ឬខាងលិច, មកពីខាងត្បូង ឬខាងជើងនោះទេ ។ វិធីតែមួយគត់នេះផ្តល់ចម្លើយសម្រាប់ដោះស្រាយបញ្ហាសានលលោកស្តីពីភាពក្រីក្រ និងទុរ្ភិក្ស, កង្វះអាហារ និងជំងឺ ។ ផ្អែកលើគោលការណ៍សេដ្ឋកិច្ចត្រឹមត្រូវ ស្តីពីការផ្គត់ផ្គង់ និងសំណូមពរ, ការផ្គត់ផ្គង់ជាទូទៅ បំរើសេចក្តីត្រូវការទាំងនោះដោយតម្លៃសមស្រប, មិនជាបញ្ហាទេ ទោះបីតាមរយៈអង្គការពិភពលោកណាមួយ ដែលមានសារសំខាន់ជាងទីផ្សារប្រណាំងប្រជែងខាងទស្សនៈនយោបាយ និងគោលការណ៍សេដ្ឋកិច្ចក្នុងការិយាល័យ ដែលគិតតែអាត្មានិយម ធ្វើឡើងសម្រាប់ការចំណេញផ្ទាល់ខ្លួនរបស់បុគ្គល និងរបស់ក្រុម ក្នុងកំរិតជាតិ និងកំរិតអន្តរជាតិ ។ វាពុំមែនជាការមិនពិតនោះទេ ដែលគោលការណ៍នេះ អនុវត្តបាននៅគ្រប់ទិសទី ចាប់តាំងពីការផ្គត់ផ្គង់នំបុ័ង ( អាហារ ) ប្រចាំថ្ងៃសម្រាប់គ្រួសារ រហូតដល់ការផ្គត់ផ្គង់អាភៀន និងគ្រឿងញៀនឯទៀតដល់ទីផ្សារពិភពលោក ។

គឺនៅទីនេះហើយ ដែលយើងត្រូវការអំពីការអភិវឌ្ឍន៍សេដ្ឋកិច្ចសម្រាប់បណ្តាប្រទេសដែលគេអោយឈ្មោះ ទោះជាត្រឹមត្រូវក្តី មិនត្រឹមត្រូវក្តី ថាប្រទេសអភិវឌ្ឍ, ប្រទេសក្រោមអភិវឌ្ឍ ឬប្រទេសកំពុងអភិវឌ្ឍ ។ មធ្យោបាយគមនាគមន៍

ដែលសព្វថ្ងៃមានប្រភេទអេឡិចត្រូនិកដ៏ទំនើបបំផុត, បណ្តាញចរាចរអាកាសអន្តរជាតិ ទោះបីមានគ្រោះថ្នាក់ប្រកបដោយមហន្តរាយធំផងក្តី បានភ្ជាប់ពិភព-លោកជាមួយគ្នា ដោយមិនគិតពីកាល និងពីចម្ងាយ ។ តើមួយណាគ្រាន់បើជាង, គឺថាតើមធ្យោបាយទាំងឡាយនេះ ក្នុងការប្រមូលផ្តុំដ៏ជោគជ័យរបស់ខ្លួន នៃចំណីបីសាចដូចនៅក្នុងរឿង ម៉ាកបែត របស់លោក សេកស្ពៀរ, ឬដូចជញ្ជាំងទីក្រុងបែរឡាំងដែលពុះប្រទេសអាល្លឺម៉ង់ជាពីរ, យើងមិនចាំបាច់ធ្វើអត្ថាធិប្បាយក្នុងទីនេះភ្លាមទេ។

យើងចាប់អារម្មណ៍យ៉ាងខ្លាំងថា ប្រជាជាតិទាំងឡាយនៅលើពិភពលោកទោះធំក្តី តូចក្តី ដែលបានចូលរួមជាអន្តរជាតិនៅក្នុងប្រភេទនៃចលនាត្រាប់តាមគ្នា និងប្រឡងប្រណាំងគ្នាដូចព្យុះសង្ឃរានេះ ហាក់ដូចជាបានធ្វើអោយមនុស្សជាតិមានសេចក្តីកង្វល់ ។ នៅគ្រប់ទិសទី, ឥឡូវវាបានក្លាយជាសេដ្ឋកិច្ចទីផ្សារនៃការទិញនិងលក់ទៅហើយ ។ ការងារនៅក្នុងវិស័យផលិតកម្ម និងទីផ្សារពិភពលោកក្នុងវិស័យនៃការលក់ កំពុងលេចឡើងរំពងសព្វថ្ងៃនេះ ។ សូម្បីតែការស្វែងរកជោគជ័យខាងនយោបាយ និងដំណើរផ្សងព្រេងពាក់កណ្តាលអាណានិគម ក៏យកលេសតាមខ្សែបន្ទាត់ទាំងនេះដែរ ។ ប្រព័ន្ធផ្សព្វផ្សាយគ្រប់រូបភាព ជាសម្ភារៈបោះពុម្ព ជាវិទ្យុនិងជាទូរទស្សន៍ ទាំងអស់ឃោសនាគគ្រឹកគគ្រេង ដើម្បីទាក់ទាញអារម្មណ៍ ដើម្បីការពារអត្ថប្រយោជន៍អ្នកបរិភោគ អ្នកប្រើប្រាស់ ។ ទោះបីការឃោសនានេះ បំរើពិភពលោកល្អក្តី អាក្រក់ក្តី មិនចាំបាច់ចោទជាបញ្ហាទេ ។ អ្នកទាំងឡាយដែលត្រូវធ្វើការគិតគូរ ក៏ត្រូវបានទទួលការញៀនយ៉ាងស្រួលទៅហើយ ។ និយាយតាមបែបម្យ៉ាងទៀត គឺអ្នកទាំងឡាយនោះ ត្រូវបានគេសណ្តំអោយដេកលក់ និងធ្វើអោយអស់សមត្ថភាពទៅហើយ ។ នៅក្នុងកិរិតគ្រួសារ, អង្គការពាណិជ្ជកម្មទាំងនោះ ធ្វើអោយមនុស្សជឿថា គ្មានព្រំដែនកំណត់ក្នុងការចំណាយដើម្បីមុខមាត់ និងការទិញយ៉ាងស្រវាស្រទេញនោះទេ ។

យើងត្រូវចេញអោយផុតពីភាពច្របូកច្របល់ជាសាកលនេះ ។ ការអភិវឌ្ឍន៍សេដ្ឋកិច្ច ជាបឋម ត្រូវតែបំបែកចេញជាច្រើនផ្នែក ។ ទីឋានណាអាចធ្វើបាន, ក្នុងឋានៈជាទីឋានផ្សេងគ្នាខាងតំបន់ និងវប្បធម៌, គេត្រូវក្តាប់អោយបាននូវភាពទាក់ទងក្នុងស្រុកដ៏មានន័យ ។ ជាញឹកញយ នយោបាយឧស្សាហកម្មធំៗរបស់អ្នកវិនិយោគទុនបរទេស នឹងត្រូវបានមកជំនួសនយោបាយកសិកម្មក្នុងស្រុក ។ ព្រៃឈើក្នុងស្រុកដ៏ច្រើនសន្ធឹកសន្ធាប់ មិនត្រូវអោយគេកាប់រំលំ ធ្វើអោយវាលសម្រាប់បំរើយ៉ាងប៉ិនប្រសប់ នូវសេចក្តីត្រូវការរបស់ឈ្មួញឈើ ដើម្បីដាំស្រូវសាលីនៅលើផ្ទៃដីដែលការបរិភោគ - ប្រើប្រាស់ ស្រូវសាលីនេះ មិនមានប្រយោជន៍ចាំបាច់នោះទេ ។ សូម្បីតែវាមិនបាននាំអោយចំណេញប្រាក់ដុល្លារក៏ដោយចុះ ក៏ប្រជាជននៃប្រទេសមួយនោះ អាចនឹងបានទទួលរង្វាន់យ៉ាងច្រើនខាងសុខភាពល្អ, ខាងទម្លាប់រស់នៅចុះសម្រុងជាមួយវប្បធម៌ ក៏ដូចជាសុខដុមភាព និងបូរណភាពខាងសង្គមដែរ ។ គំរូសង្គមនាំចូល ( Imported social models ) រួមទាំងស្ថាបត្យកម្ម និងផែនការកម្មទីក្រុង និងជនបទផង រមែងនាំទៅរកដោយពិបាកជៀសផុត នូវការបែកខ្ញែកសង្គមដ៏មានគ្រោះថ្នាក់ ។

អនុលោមតាមការត្រិះរិះរបស់ពុទ្ធសាសនា, ការអភិវឌ្ឍន៍សេដ្ឋកិច្ច ជាមួយនឹងការរីកចំរើនសង្គម និងវប្បធម៌ ត្រូវតែកើតឡើងដោយស្របស្រួលជាមួយបំណងប្រាថ្នារបស់ប្រជាជន ហើយដែលការអភិវឌ្ឍន៍ និងការរីកចំរើននេះ កើតមានឡើងដើម្បីប្រជាជន ។ ដូច្នេះ វាត្រូវតែមានការស្របស្រួលគ្នាមួយ ជាមួយទីតាំងតំបន់, ស្របស្រួលចុះសម្រុងគ្នាជាមួយអាកាសធាតុរហូតដល់ស្របស្រួលជាមួយអត្តសញ្ញាណវប្បធម៌ ដែលមានចំណាស់រាប់សតវត្សទៀតផង ។ ប៊ុលដូហ្ស៊ែរ ( Bull-dozers = ត្រាក់ទ័រដ៏ខ្លាំងសម្រាប់រុញ ឬពង្រាបដី ) ដែលជាផលិតផលនៃយុគឧស្សាហកម្មសម័យថ្មី ក៏មិនគួរគប្បីអនុញ្ញាតបើកច្រកអោយដោយឥត

ព្រំដែន រហូតដល់ជាន់កំពូលអត្តសញ្ញាណវប្បធម៌ មានអាយុរាប់រយឆ្នាំនោះទេ ។ យើងសូមបន់ស្រន់ សូមអោយមានសុខភាព និងភាពស្គាល់ប្រមាណត្រឹមគំនិតនេះ ហើយនិងសូមអោយមានការផុសលេចឡើងនៃទេពកោសល្យក្នុងស្រុក ភ្ជាប់ដោយការលើកកម្ពស់ស្មារតីផ្ទាល់របស់ប្រជាជន ។

Bhikkhu Professor Dhammavihari
Buddhist Society of Victoria
71 - 73 Darling Road
Eastern Malvern
Victoria 3145 - Ph (03)95716409
Australia

## ល្បងពិចារណា
## អំពី
# សិទ្ធិមនុស្ស និង ពុទ្ធសាសនា

រៀបរៀងដោយ **ឈន អៀម**

*កំណត់សម្គាល់របស់អ្នករៀបរៀង :*

*ប្រធានបទស្ដីពី « សិទ្ធិមនុស្ស » គឺជាប្រធានបទដ៏ប្រជាប្រិយ កំពុងត្រូវបានអង្គការក្រៅរដ្ឋាភិបាលនានា ក្រោមការឧបត្ថម្ភរបស់លោកខាងលិចយកចិត្តទុកដាក់ផ្សព្វផ្សាយជម្រុញខ្លាំងអោយជ្រួតជ្រាបចូលជ្រៅទៅក្នុងស្រទាប់ប្រជាជនទាំងអស់ក្នុងគ្រប់ទិសទី នៃព្រះរាជាណាចក្រ ចាប់តាំងពីដើមឆ្នាំ ១៩៩២ មក ។ មធ្យោបាយគ្រប់យ៉ាងសម្រាប់ផ្សព្វផ្សាយ និងជម្រុញ « សិទ្ធិមនុស្ស » អោយចូលជ្រៅក្នុងគ្រប់ស្រទាប់ប្រជាពលរដ្ឋខ្មែរ ក៏ត្រូវបានគេកៃនប្រមូលយ៉ាងសកម្ម យកមកប្រើប្រាស់សម្រាប់បំរើគោលដៅនេះ មានជាអាទិ៍ ការបើកវគ្គខ្លី វែង ដើម្បីហ្វឹកហ្វឺនព្រះសង្ឃ, អាចារ្យ, សមាជិកគណៈកម្មការវត្ត, យាយជី, តាជី . . . រហូតដល់ លោកគ្រូ អ្នកគ្រូ, សាស្ត្រាចារ្យថែមទៀត ។*

*សកម្មភាពដ៏គគ្រឹកគគ្រេង នៃការផ្សព្វផ្សាយ « សិទ្ធិមនុស្ស » នេះ ហាក់ដូចជាការប្រកាសអាសន្នចំពោះការស្រុតចុះ នៃសីលធម៌របស់សង្គមខ្មែរ ឬចំពោះការងើបឡើងវិញនៃសង្គមខ្មែរ អំពី « រណ្ដៅមហានរក » ដូច្នោះ ។*

សកម្មភាពនេះ បានបង្កើតចេញជាសតិអារម្មណ៍សង្គម និងបាតុភូតសង្គមប្លែកៗ ដែលផ្តល់ផលវិបាកជាវិដ្ឋមានផង អវិដ្ឋមានផង ។ ជាទូទៅ, មតិរបស់ប្រជាពលរដ្ឋ ចំពោះសកម្មភាពនេះ បានបង្កើតចេញជាទស្សនៈប្លែកៗ ទៅតាមគំនិតយល់ដឹង និងបទពិសោធន៍ ក្នុងជីវភាពសង្គមកន្លងមក ពីព្រោះ សង្គមកម្ពុជា ឬសង្គមខ្មែរនេះ ពុំមែនជាសង្គមដែលទើបកើតមានឡើងនៅលើផ្ទៃកនេះ នៃពិភពលោកទេ, ប៉ុន្តែជាសង្គមមួយដ៏ចាស់ទុំធ្លាប់មានអរិយធម៌ខ្ពង់ខ្ពស់, ធ្លាប់មានប្រវត្តិរុងរឿង, និងធ្លាប់មានប្រពៃណីល្អត្រកាលប្រកបដោយចរិយា-ធម៌ដ៏ប្រសើរ ដែលជាឥទ្ធិពលដ៏យូរលង់ហើយ នៃពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធបរមគ្រូ ។

នៅក្នុងពិធីបើកអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃលើកទី ៥ កាលពីខែឧសភា ១៩៩៦ នៅក្នុងសាលសន្និសិទចតុមុខ ក្រុងភ្នំពេញ, ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ទ្រង់បានមានបន្ទូលទាក់ទងដល់អាយុកាលនៃព្រះពុទ្ធសាសនា ដែលបានផ្សាយចូលមកប្រតិស្ឋាននៅក្នុងប្រទេសកម្ពុជា អស់កាលជាងពីរពាន់ឆ្នាំហើយ ។ ភ្ជាប់ទៅនឹងព្រះរាជយោបល់នេះ, ព្រះអង្គបានសង្កត់ធ្ងន់ថា សង្គមខ្មែរតាមរយៈការគោរពប្រតិបត្តិព្រះពុទ្ធសាសនា ដ៏ជាសាសនាមនុស្សនិយមបំផុត មួយធ្លាប់បានស្គាល់, ធ្លាប់បានគោរពសិទ្ធិមនុស្សតាំងពីព្រេងនាយមក ។ ទើបតែពីខែមេសា ១៩៧៥ មកដល់ដំណាច់ឆ្នាំ ១៩៧៨ ប៉ុណ្ណោះ សង្គមខ្មែរបានអាក់ខានគោរពប្រតិបត្តិពុទ្ធសាសនា ដោយការបង្ខិតបង្ខំពីរបបអមនុស្សធម៌ដ៏អប្រិយ៍ប្រល័យពូជសាសន៍នៃកម្ពុជាប្រជាធិបតេយ្យ ។ ដោយហេតុនេះ សិទ្ធិមនុស្សចំពោះប្រទេសកម្ពុជា ពុំមែនជារឿងថ្មីទេ, ហើយការគោរពសិទ្ធិមនុស្សក្នុងពុទ្ធសាសនា មានគម្ពីរភាពជាង ។

ឥឡូវ ព្រះពុទ្ធសាសនាបានកើតមានឡើងវិញ តាំងតែពីឆ្នាំ ១៩៧៩

*វេងមក ហើយកំពុងតែវិវត្តរីកចំរើនឈានទៅកាន់ភាពរុងរឿងរបស់ខ្លួនពីមុនឡើងវិញ ។ ខ្លឹមសារជាសារវន្តនៃព្រះធម៌របស់ព្រះពុទ្ធ ក៏កំពុងតែជ្រួតជ្រាបចូលក្នុងគំនិតប្រជាពលរដ្ឋខ្មែរឡើងវិញហើយ ។ អ្វីដែលជាឧបសគ្គដល់ការរីកចំរើនខាងបញ្ញា - ស្មារតីយល់ដឹង, ទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស នៅកម្ពុជា, នោះគឺភាពក្រីក្រខាងជីវភាពរបស់ប្រជាជន និងភាពល្ងិតល្ងង់របស់ប្រជាជន បណ្តាលមកពីខ្វះសាលារៀន ខ្វះការអប់រំដែលព្រះរាជរដ្ឋាភិបាលកំពុងតែខិតខំលុបបំបាត់ ។*

*ដើម្បីរួមចំណែកក្នុងការត្រិះរិះអំពីបញ្ហា « សិទ្ធិមនុស្ស » ដោយភ្ជាប់ជាមួយនឹងទ្រឹស្តីនៃពុទ្ធសាសនា, ខ្ញុំបានរៀបរៀងអត្ថបទនេះឡើង ដោយមានបំណងបង្កើនការភ្ញាក់រលឹក និងមោទនភាពរបស់ព្រះសង្ឃ និងពុទ្ធសាសនិក-ជនទាំងក្នុងការខិតខំស្វែងយល់ « សិទ្ធិមនុស្ស » ដែលជាទស្សនៈមនុស្សនិយមសម័យថ្មី និងទាំងក្នុងការខិតខំស្វែងយល់ « ព្រះធម៌របស់ព្រះពុទ្ធ » ដែលជាទស្សនៈមនុស្សនិយមសកល និងជ្រាលជ្រៅ មានអាយុកាលជាងពីរពាន់ឆ្នាំហើយ ដើម្បីសុភមង្គលសម្រាប់សព្វសត្វ ។ ពុទ្ធិយល់ដឹងទស្សនៈទាំងពីរផ្នែកនេះ នឹងជួយរួមវិភាគទានដល់ការស្តារសីលធម៌ និងចរិយាធម៌សង្គមជាតិយើងឆ្ពោះទៅរកការកសាងប្រទេសកម្ពុជា ជានីតិរដ្ឋ ។*

* * *

ក្នុងឋានៈជាសាសនា និងជាទស្សនវិជ្ជាមួយបំរើសុខុមាលភាពរបស់សព្វសត្វ ( *សព្វេ សត្តា សុខិតា ហោន្តុ* ), ពុទ្ធសាសនា គឺពិតជាសាសនាដែលបានយកចិត្តគិតគូរយ៉ាងច្រើនដល់សិទ្ធិមនុស្ស ។ គំនិតគិតគូរពីសិទ្ធិមនុស្សរបស់ពុទ្ធសាសនា

ឃើញមានបញ្ចាំងចេញមកតាមរយៈប្រព័ន្ធតម្លៃ ដែលពុទ្ធសាសនាបានទ្រទ្រង់ និងបានចាត់ទុកជាមាគ៌ាសង្គ្រោះមនុស្សជាតិ ។ ទោះបីជាលទ្ធិពុទ្ធសាសនា ពុំត្រូវបានគេយកមករៀបរាប់ដូចជាបែបបទ ដែលគេនិយាយសព្វថ្ងៃនេះក៏ដោយ ក៏គង់នៅមានមនុស្សទាំងឡាយណា ដែលបានសិក្សាពុទ្ធសាសនាយ៉ាងម៉ត់ចត់នោះ មុខជាមិនខកខានកត់សម្គាល់ឃើញនូវគំនិតយល់ឃើញ ( Concepts ) និងសេចក្តីព្រួយកង្វល់របស់សេចក្តីប្រកាសជាសកល ស្តីពីសិទ្ធិមនុស្ស ដូចដែលបានអនុម័ត ហើយដោយមហាសន្និបាតរបស់សហប្រជាជាតិ កាលពីថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ១៩៤៨, ថាគំនិតយល់ឃើញ និងសេចក្តីកង្វល់ទាំងនោះ ត្រូវបានចារឹកចងក្រងរួចជាស្រេចទៅហើយនៅក្នុងព្រះធម៌ ដ៏ជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។ គោលការណ៍ជាគ្រឹះទាំងឡាយនៃសេចក្តីប្រកាស ក៏ត្រូវបានអក្សរសាស្ត្រ និងប្រវត្តិពុទ្ធសាសនា គាំទ្រ និងពង្រឹងរួចជាស្រេចហើយដែរ ។ គេបានសង្កេតឃើញថា « មានគ្រូប្រដៅសាសនាតិចតួចទេ ដែលមានវោហារពិរោះក្បោះក្បាយ និងឥតមានគំនិតលាក់លៀម ដូចជាព្រះពុទ្ធដែលបានលើកស្ទួយតម្លៃទាំងឡាយ ដូចដែលគំនិតយល់ឃើញសម័យថ្មី ស្តីពី « សិទ្ធិមនុស្ស » បានលើកស្ទួយនោះ ។ ព្រះពុទ្ធបានសំដែងអំពីសិទ្ធិមនុស្សប្រកបដោយអត្ថន័យគម្ភីរភាព និងប្រកបដោយវោហារពន្យល់ពិរោះក្បោះក្បាយដ៏ក្រៃលែង ។

នៅមុនពេលកើតមានការប្រកាស ស្តីពីសិទ្ធិមនុស្ស, ក៏មានការប៉ុនប៉ងច្រើនទៀត ដើម្បីប្រកាសអំពីសិទ្ធិមនុស្សដែរ ដូចជា*ច្បាប់ម៉ាញ៉ា ការតា* « Magna Carta » ដែលប្រជាជនអង់គ្លេសបានប្រកាសឡើងក្នុងឆ្នាំ ១២១៥ ហើយនិង*សេចក្តីប្រកាសអំពីសិទ្ធិរបស់បុរស និងពលរដ្ឋ* . ( The Deelaration of Rights of Man and Citizen ) ដែលជនជាតិបារាំងបានប្រកាសឡើងក្នុងឆ្នាំ១៧៨៩ ។ ប៉ុន្តែថា ទាល់តែមកដល់ពេលដែលសហប្រជាជាតិបានអនុម័តសេចក្តី

ប្រកាសជាសកល ស្តីអំពីសិទ្ធិមនុស្សក្នុងឆ្នាំ ១៩៤៨, ទើប « ជាលើកដំបូងហើយនៅក្នុងប្រវត្តិសាស្ត្រនៃមនុស្សលោក, កើតមានឯកសារមួយចេញជាសេចក្តីប្រកាសជាពាក្យងាយៗ, ខ្លីៗ ស្តីពីសិទ្ធិទាំងឡាយជាសជាតិកសិទ្ធិ ( Inherent rights ) ខាងស៊ីវិល, ខាងនយោបាយ, ខាងសេដ្ឋកិច្ច, ខាងសង្គមកិច្ច និងខាងវប្បធម៌ », ដែលមនុស្សជាតិទាំងមូលមានអំណាចទទួលបាននូវសិទ្ធិទាំងអស់នេះ ។ ដោយហេតុនេះ សេចក្តីប្រកាសជាសកល « បានផ្តល់រង្វាស់មួយអោយមនុស្សប្រុស ស្រី អាចយកមកគិតគូរវាស់វែង ដោយខ្លួនឯងថា តើសិទ្ធិ និងសេរីភាពរបស់ខ្លួន ត្រូវឋិតនៅក្នុងក្របខណ្ឌត្រឹមណា ទើបបានទទួលការគោរព ឬទទួលស្គាល់អំពីរដ្ឋាភិបាល, អំពីអង្គការចាត់តាំង, អំពីក្រុមរបស់ខ្លួនរៀងៗ ខ្លួន, ឬទើបបានមនុស្សទាំងឡាយឯទៀតទទួលគោរព និងទទួសស្គាល់, ហើយត្រឹមកំរិតណា ដែលមនុស្សប្រុស ស្រីជាអ្នកមានសិទ្ធិ ត្រូវគោរពសិទ្ធិ និងសេរីភាពរបស់អ្នកដទៃវិញ ។ »

ពីនោះ មកដល់ពេលនេះ មានរយៈពេល ៤៨ ឆ្នាំហើយ ដែលសេចក្តីប្រកាសជាសកលរបស់សហប្រជាជាតិស្តីពីសិទ្ធិមនុស្ស បានធ្វើឡើង ។ ប៉ុន្តែ សិទ្ធិមនុស្សក្នុងឋានៈជាបញ្ញត្តិស័ព្ទមួយ ( Concept ) កំពុងបន្តវិវត្តទៅមុខនៅឡើយ, ហើយមនុស្សទាំងឡាយដែលសិក្សានូវមុខវិជ្ជានេះ តែងកត់សំគាល់ឃើញដោយមានសេចក្តីព្រួយបារម្ភ នូវកំរិតព្រំដែនដែលបានចែងជាប់ជាមួយនៅក្នុងសេចក្តីប្រកាសនេះ ។ នៅពេលដែលគេកំពុងទទួលស្គាល់នូវសារប្រយោជន៍ នៃសេចក្តីប្រកាសនេះ « ទុកជាសមិទ្ធផលគំរូរួមមួយ ( a common standard of achievement ) សម្រាប់ប្រជាជនទាំងអស់គ្រប់ជាតិសាសន៍ », គេក៏បានកត់សំគាល់ឃើញដែរថា ឯកសារនេះ « *មានទំនោរជាឯកសារតុលាការ នៅក្នុងពាក្យសំដីរបស់ខ្លួន, មានទំនោរជាឯកសារបុគ្គលនិយម នៅក្នុងការអោយទម្ងន់ទៅលើសហគមន៍ ហើយក៏ជាឯកសារកំណត់របាំងនៅក្នុងទស្សនៈរបស់ខ្លួនតែក្នុង*

*វង្វង់សហគមន៍ប៉ុណ្ណោះ* » ។ នេះគ្រាន់តែជាការរិះគន់មួយ ក្នុងចំណោមការរិះគន់ច្រើនទៀត នៃសេចក្តីប្រកាស, ប៉ុន្តែថា ការរិះគន់នេះពុំមែនមានគំនិតមើលស្រាលនូវតម្លៃដ៏ឧត្តុង្គឧត្តមរបស់សេចក្តីប្រកាសនោះ សូម្បីតែបន្តិចក៏ទេដែរ ។ ម៉្យាងទៀត, បន្ថែមពីលើអត្ថន័យតូចចង្អៀតខ្លះៗនេះទៀត, ក៏គេនៅតែពិនិត្យឃើញថា «សេចក្តីប្រកាស ខ្វះទាំងគម្ភីរភាពនៃទស្សនាទាន ខ្វះទាំងការយល់ធ្លុះជ្រៅ (អជ្ឈន្តិកញ្ញាណ) ( lack of both depth of perception and insights ) ដែលមានតែសាសនាទេ ទើបអាចផ្តល់អោយបាន ។ ហើយបើកាលណាប្រៀបផ្ទឹមជាមួយនឹងអ្វី ដែលពុទ្ធសាសនាបានសំដែងដោយយោងដល់សេចក្តីព្រួយបារម្ភ នៃសេចក្តីប្រកាសនេះ, នោះសេចក្តីប្រកាសត្រូវការអោយមានការពង្រីកវិសាលភាព ( ទំហំ ) នៅក្នុងខ្លឹមសាររបស់ខ្លួនថែមទៀត ។ នៅលើចំណុចនេះ មតិយល់ឃើញរបស់សង្គមសព្វថ្ងៃ តាមជ្រុងមួយរបស់ព្រះពុទ្ធសាសនា មានខ្លឹមសារដូចតទៅនេះ :

> « ទស្សនៈរបស់យើងយល់ថា គំនិតយល់ឃើញសម័យថ្មីស្តីពីសិទ្ធិមនុស្ស គឺគ្រាន់តែជាការឆ្លុះបញ្ចាំងចេញនូវមតិ និងទស្សនៈយល់ឃើញមិនទាន់មានភាពសុក្រឹត ដូចមានសំដែងនៅក្នុងធម៌ ។ ព្រះធម៌មានលក្ខណៈមនុស្សធម៌ល្អិតល្អន់ជាង, មានទស្សនវិជ្ជាជ្រាលជ្រៅជាង និងមានយុត្តិធម៌ជាងអ្វីៗទាំងអស់ ដែលយើងជាមនុស្សសម័យថ្មីមិនទាន់អាចបង្ហាញបាន ។ តាមពិត, ទស្សនៈសម័យថ្មីនេះបានអនុវត្តទៅ នៅតែក្នុងបរិបទសង្គមដោយឡែកណាមួយប៉ុណ្ណោះ ។ នៅក្នុងដំណើរកន្លងទៅនៃកាលវេលា, ក្នុងចលនាត្រឡប់ថយក្រោយ, វាបានកើតមាននូវការប្រែប្រួលដ៏ច្បាស់មួយនៃប្រព័ន្ធតម្លៃ ដែលពីមុនមិញមានមូលដ្ឋានលើបរ.ទត្ថភាព និងជំនឿក្នុងសុក្រឹតភាពនៃមនុស្ស, មកកាន់ការទាមទារយ៉ាង

គគ្រឹកគគ្រេង បច្ចុប្បន្នដើម្បីអោយបុគ្គលម្នាក់ៗមានសិទ្ធិ ដោយសំអាងថា នេះជាច្បាប់ធម្មជាតិ ។ ជាមួយសិទ្ធិនេះ គេអាចយកមកប្រើប្រឆាំងទាំងចំពោះរដ្ឋ ទាំងចំពោះមនុស្សគ្នាឯងទៀតផង ។ ទស្សនៈបែបនេះមិនមែនជាបញ្ញត្តិស័ព្ទ ( Concept ) នៅក្នុងព្រះធម៌ទេ ... ។ ទន្ទឹមនឹងការអោយតម្លៃខ្ពស់ ចំពោះសិទ្ធិមនុស្សក្នុងទម្រង់បច្ចុប្បន្នរបស់សិទ្ធិមនុស្សនេះយើងក៏គួរពិចារណា នូវភាពផ្សេងគ្នារវាងទស្សនៈទាំងពីរនេះដែរ, ពិព្រោះនេះ គឺជាភាពផ្សេងគ្នាដ៏មានសារសំខាន់បំផុត តាមទស្សនៈរបស់ព្រះធម៌,ហើយនេះក៏ជាភាពផ្សេងគ្នាដែលទាមទារអោយយកចិត្តទុកដាក់បំផុត ដើម្បីពិចារណាផងដែរ » ។

ទស្សនៈព្រះពុទ្ធសាសនា ស្តីពីសិទ្ធិមនុស្សលេចចេញពីគោការណ៍ជាមូលដ្ឋានពីរយ៉ាង - មួយ ទស្សនៈវិជ្ជា មួយទៀត ចរិយាធម៌ ។ គោលការណ៍ទស្សនវិជ្ជា គឺសព្វសត្វទាំងអស់កើតមកមានជាប់ជាមួយ នូវសេរីភាពពេញលេញ និងការទទួលខុសត្រូវ ។ សត្វទាំងអស់ មិនមែនជាការបង្កើតរបស់អាទិទេពណាមួយទេ, ដូច្នេះសត្វទាំងអស់ចំណុះតែក្រោមក្រឹត្យក្រមហេតុភាពអបច្ច័យនិយម ( nondeterministic causal laws ), ហើយវាសនារបស់គេឋិតនៅក្នុងកណ្តាប់ដៃរបស់គេ ។ « តាមពិត, បុគ្គលម្នាក់ ជាម្ចាស់លើខ្លួនឯងផ្ទាល់ » *( អត្តា ហិ អត្តនោ នាថោ )* ។ ដោយហេតុនេះ, មនុស្សជាតិ មានសេរីភាពដើម្បីសំរេចបាននូវគុណធម៌ដ៏ខ្ពស់បំផុត ទោះបីជាខាងសម្ភារៈ, ខាងស្មារតី, ខាងសីលធម៌ និងខាងបញ្ញា ។ រីឯគោលការណ៍ចរិយាធម៌វិញ គឺមានចរិតលេចធ្លោណាស់នៅថ្នាក់សង្គម ។ ចំណង់ជ្រាលជ្រៅបំផុតរបស់មនុស្ស និងសព្វសត្វមានជីវិត គឺចង់បានសេចក្តីសុខ *( សុខ-កាមានិ ភូតានិ )* ។ ដូច្នេះ វិធីដោះស្រាយបញ្ហារបស់ពុទ្ធសាសនាចំពោះសិទ្ធិមនុស្សគឺមានលក្ខណៈមនុស្សនិយមច្រើនជាង នីតិនិយម ។

ដោយផ្អែកលើគោលការណ៍ជាគ្រឹះទាំងពីរនេះ, ពុទ្ធសាសនាចាត់ទុកមនុស្សជាអ្នកមានសមត្ថភាពគ្រប់គ្រាន់ក្នុងកិច្ចការធានារ៉ាប់រងចំពោះខ្លួនឯងផ្ទាល់ និងចំពោះមនុស្សផងគ្នា នូវជោគជ័យ និងសេចក្តីសុខ ( សុភមង្គល ) នៅក្នុងលោកនេះ ហើយនិងក្នុងការធ្វើអោយបានសំរេចសម្រាប់ខ្លួន នូវការរំដោះផុតទុក្ខ ( ទុក្ខវិមុត្តិ ) ពោលគឺផុតអំពីភាពច្របូកច្របល់នៃជីវិតនេះ នៅទីអវសាន ។ ជោគជ័យលោកិយផ្ទាល់នេះ ត្រូវបានគេសង្ឃឹមថា នឹងបានសំរេចដោយប្រពៃ ( ធម្មលទ្ធៈ ), ហើយព្រះធមិរបស់ព្រះពុទ្ធ ក៏ត្រូវបានតម្រង់ឆ្ពោះទៅរកគោលបំណងនេះមួយចំណែកដែរ ។ គឺនៅក្នុងទីនេះហើយ ដែលសិទ្ធិមនុស្សត្រូវការអោយគេមើលឃើញនៅក្នុងបរិបទសង្គម ។ ជោគជ័យលោកិយនេះ ទាមទារអោយមានការទទួលស្គាល់ទោវិញទៅមកនូវសិទ្ធិមនុស្ស, អោយមានការគោរពសិទ្ធិនៃមនុស្ស និងអោយប្រតិបត្តិខ្ជាប់សិទ្ធិមនុស្ស ។

បរិយាកាសសាសនា និងបរិយាកាសសង្គមទាំងមូល នៃប្រទេសឥណ្ឌាភាគឧត្តរក្នុងអំឡុងពេល និងក្រោយពេលពុទ្ធសាសនាកើតឡើង ហើយនិងក្នុងអំឡុងពេល និងក្រោយពេលប្រព័ន្ធសាសនាឯទៀតៗ កើតឡើងដែរនោះ, ប្រតិកម្មជាទូទៅមួយប្រឆាំងនឹងការដាក់កំណត់ព្រំដែនដោយបង្ខំមកលើសិទ្ធិមនុស្ស ដោយប្រព័ន្ធតម្លៃសាសនាព្រាហ្មណ៍ដ៏មានឥទ្ធិពលនាសម័យនោះ ក៏បានផ្ទុះឡើង ។ សកម្មភាពរបស់ព្រះពុទ្ធ ហើយនិងសកម្មភាពរបស់សាវ័កដំបូងៗ ទាំងឡាយរបស់ព្រះអង្គនៅក្នុងសម័យកាលនោះ, ត្រូវបានតម្រង់ឆ្ពោះទៅរកការទទួលយក និងប្រតិបត្តិតាមនូវគោលការណ៍ទាំងឡាយរបស់សិទ្ធិមនុស្សក្នុងការអនុវត្តន៍ជាក់ស្តែង, មិនគ្រាន់តែជាការខិតខំចង់រៀបចំរចនាសម្ពន្ធសង្គមឡើងវិញប៉ុណ្ណោះទេ, ប៉ុន្តែ ជាការខិតខំចង់អោយមានការទទួលស្គាល់នូវតម្លៃស្មារតីរបស់សង្គមទៀតផង ។

នៅក្នុងបរិបទនេះ, អរិយអដ្ឋង្គិកមគ្គ ដ៏ជាពុទ្ធទស្សនៈ ( Buddhist

concepts ) មូលដ្ឋាន, បញ្ចសីល ហើយនិងគុណធមិដទៃទៀត នៃទស្សនៈពុទ្ធ-សាសនាស្តីពីសប្បុរសធមិ ដូចជាមេត្តា (loving kindness ), អហឹង្សា ( non injury or non violence ) ព្រមទាំងគុណធមិសង្គម បន្ទាប់បន្សំជាច្រើនទៀត ដូចជា ទាន ដែលជាមូលដ្ឋាន នៃបរទត្ថភាពរបស់ពុទ្ធសាសនិកជន, កតញ្ញូតា ( gra-titude ), គារវធមិ ឬការគោរព ( reverence ), បេយ្យវជ្ជៈ ( Courtesy ), សមានត្តតា (equanimity) ភាពទន់ភ្លន់ (humility), ខន្តិ . សោរច្ចៈ (tolera-tion), សច្ចៈ ( Veracity or sincerity ) . ទាំងអស់កត្តិទៅជាមូលដ្ឋានសីលធមិដ៏ជាឫសគល់នៃទំនាក់ទំនងរបស់មនុស្សទៅនឹងមនុស្សផងគ្នា ។ ទាំងអស់នេះនឹងត្រូវបានយកមកប្រើ ដើម្បីភ្ជាប់អំពើរបស់ផងខ្លួនឆ្ពោះទៅរកការទទួលស្គាល់នូវសិទ្ធិមនុស្ស ។ តាមការណ៍ពិត, បញ្ចសីលរបស់ពុទ្ធសាសនា អាចត្រូវបានគេចាត់ទុកថាជាសេចក្តីប្រកាសមុនគេបំផុត ស្តីពីសិទ្ធិមនុស្សនៅក្នុងប្រវត្តិសាស្ត្រនៃមនុស្សជាតិ នៅក្នុងន័យដែលថាបញ្ចសីលបង្កប់ក្នុងអង្គសិក្ខាបទរបស់ខ្លួននូវការទទួលស្គាល់ : ក) សិទ្ធិដើម្បីរស់នៅ, និង ខ) សិទ្ធិធ្វើជាម្ចាស់កម្មសិទ្ធិ ។ នេះជាផ្នែកដ៏ធំទូលាយពីរយ៉ាង ដែលនៅក្នុងផ្នែកទាំងពីរនេះ គេបានរកឃើញ, ហើយរាប់ឃើញមានសិទ្ធិមនុស្សទាំងអស់ ។ វាជាការជាក់ស្តែងណាស់ថា សិទ្ធិមនុស្សទាំងឡាយដូចមានរៀបរាប់នៅក្នុងសេចក្តីប្រកាសជាសកល ដោយអង្គការសហប្រជាជាតិ, បើពិនិត្យអោយបានល្អិតល្អន់ទៅ, គេនឹងឃើញថា សិទ្ធិមនុស្សទាំងឡាយនោះអាចត្រូវបានរាប់បញ្ចូលទៅក្នុងផ្នែកនេះ ឬក្នុងផ្នែកនោះរបស់ផ្នែកទាំងពីរនៃបញ្ចសីល, ឬមួយអាចរាប់បញ្ចូលក្នុងផ្នែកទាំងពីរតែម្តង ។ ជាការជាក់ស្តែង, នៅក្នុងដំណើរធានារ៉ាប់រងសេចក្តីចំរុងចំរើនរបស់មនុស្សជាតិ, ដូចមានអធិប្បាយនៅក្នុង *ចក្កវត្តិសីហនាទសូត្រ*, អ្នកគ្រប់គ្រងអំណាចជាគំរូ ( តាមរឿងនិទានពីព្រេងនាយ ) គឺជាស្តេចចក្រពត្តិ .ត្រូវប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួននូវសីលទាំងប្រាំ ( បញ្ចសីល ) ដែលមាន

ន័យថា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ។ ដូច្នេះ ការគ្រប់គ្រងរដ្ឋជាគំរូតាមទស្សនៈរបស់ពុទ្ធសាសនា តម្រូវអោយមានការទទួលស្គាល់ និងការគោរពសិទ្ធិមនុស្សជាចាំបាច់ ។

យើងបានបញ្ជាក់ពីខាងដើមហើយថា ពុទ្ធសាសនា ជាសាសនាដែលបានគិតគូរខ្លាំង និងខ្វល់ខ្វាយបំផុតដល់ « ជីវិតសត្វទាំងអស់ » *(សព្វេ សត្តា)* ។ ទស្សនៈនេះអាចឃើញមានច្បាស់លាស់ណាស់នៅក្នុងមេត្តសូត្រ ។ យោងតាមសូត្រនេះ, ទស្សនាទានពុទ្ធសាសនា ស្តីពីសិទ្ធិទាំងឡាយមួយអន្លើដោយសញ្ញាណ នៃកិត្តិគុណរបស់ទស្សនាទាននេះ ត្រូវបានគេទទួលស្គាល់ថា ជាទស្សនៈដ៏ថ្លៃថ្នូរឧត្តុង្គឧត្តមបំផុត, ពង្រីកផ្សព្វផ្សាយមេត្តាធម៌ តាំងតែពីរង្វង់មនុស្សជាតិ រហូតដល់ទៅរង្វង់សត្តនិករ ( the animal kingdom ) ។ ប្រការនេះ អាចអោយគេរាស់អត្ថន័យចេញពីហេតុពិតដែលថា ស្តេចចក្រពត្តិត្រូវតែផ្តល់ការថែរក្សា និងកិច្ចការពារ មិនមែនសម្រាប់តែមនុស្សប៉ុណ្ណោះទេ, ប៉ុន្តែ ចំពោះ «សត្វពាឡម្រឹគ និងបក្សាបក្សី» ( មិគបក្ខីសុ ) ទៀតផង ។ សិទ្ធិទាំងឡាយ មិនមែនមានសម្រាប់តែមនុស្សទាំងឡាយទេ, ប៉ុន្តែ សម្រាប់សព្វសត្វមានជីវិតឯទៀតផងដែរ ។ គឺទើបតែនៅក្នុងសតវត្សទី ២០ នេះប៉ុណ្ណោះទេ ដែលគេបានបង្កើត « ក្រុមសិទ្ធិសត្វ » ( ពោល គឺជាក្រុមការពារជីវិតសត្វព្រៃ ) នៅក្នុងប្រទេសមួយចំនួនប៉ុណ្ណោះ ។ អនុលោមតាមឧត្តមគតិដ៏ត្រកាល ស្តីពីសេចក្តីព្រួយកង្វល់របស់ស្តេចចក្រពត្តិដ៏ជាពុទ្ធសាសនិកគំរូ ដែលបានយកព្រះទ័យគិតគូរដល់សិទ្ធិទាំងឡាយ ទាំងរបស់មនុស្ស ទាំងរបស់សត្វ នៅក្នុងបរិបទប្រវត្តិសាស្ត្រពុទ្ធសាសនាដូចនេះហើយ, ទើបព្រះបាទអសោក ជាព្រះរាជាទីមួយ ដែលបានប្រកាន់យកវិធានការណ៍ដ៏សមស្រប ការពារ និងអោយអភ័យដល់សិទ្ធិរស់នៅទាំងមនុស្ស ទាំងសត្វ ។

ការទទួលស្គាល់ និងការគោរពសិទ្ធិមនុស្ស នៅក្នុងបរិបទពុទ្ធសាសនា

ត្រូវតែបានធ្វើអោយចូលជាធរមានបញ្ញត្តិ, ជាសំខាន់នោះ តាមរយៈការបំពេញករណីយកិច្ច និងកាតព្វកិច្ចរបស់ខ្លួនចំពោះសង្គម ។ នេះគឺជាក្រមសីលធម៌បូព៌ាប្រទេសជាទូទៅ, នៅពេលដែលពាក្យ « សិទ្ធិ » ត្រូវបានគេប្រកាសដោយច្បោលៗយ៉ាងកងរំពងនៅក្នុងបរិបទវប្បធម៌បស្ចិមប្រទេស, ពិព្រោះតែសិទ្ធិទាំងឡាយត្រូវបានគេបដិសេធចំពោះមនុស្សភាគច្រើន នៅក្នុងផ្នែកនេះ នៃពិភពលោក ។ នេះប្រហែលជាបណ្ដាលមកពី « ទស្សនៈមួយបានធំធាត់ឡើងនៅលើតម្លៃ ដែលចិញ្ចឹមគំនិតបុគ្គលនិយម និងចិញ្ចឹមជំនឿលើឧត្តមភាព នៃវប្បធម៌របស់ខ្លួន ទៅលើវប្បធម៌របស់ជាតិសាសន៍ដទៃ ( ethnocentrism ), ហើយ ដោយហេតុនេះ គេបានចាត់ទុកពិភពលោកនេះថា ដូចជាគេបានប្រគល់អោយទៅក្រុមណាមួយដើម្បីគេយកទៅធ្វើអាជីវកម្មយ៉ាងចាស់ដៃសម្រាប់ធ្វើមានបានអោយខ្លួនគេផ្ទាល់ ។ ការទទួលស្គាល់ និងការគោរពនូវសិទ្ធិមនុស្សតាមរយៈការបំពេញករណីយកិច្ច និងកាតព្វកិច្ចចំពោះសង្គម បាននាំយកនូវចរិយាធម៌សង្គម និងសីលធម៌សង្គមទៅដាក់នៅជួរមុខ, ហើយដោយហេតុនេះ ធម៌ទេសនារបស់ព្រះពុទ្ធ ដូចជា*សិង្គាលោ-វាទសូត្រ* ដែលបាននិយាយពីទំនាក់ទំនងសង្គមទាំងសងខាងរវាងសិស្ស និងគ្រូ, រវាងបុត្ត-ធីតា និងឪពុក-ម្ដាយ នៅក្នុងបរិបទពុទ្ធសាសនា គឺជាធម៌ដ៏មានសារសំខាន់បំផុតនៅក្នុងចំណុចនេះ ។

សេចក្ដីប្រកាសជាសកល នៃសិទ្ធិមនុស្សមាន ៣០ មាត្រា, ហើយមុននឹងលើកយកមកនិយាយ អំពីទស្សនៈយល់ឃើញរបស់ពុទ្ធសាសនា ចំពោះសេចក្ដីប្រកាសនេះ, យើងគួរគប្បីលើកយកចំណុចខ្វាយខ្វល់ទាំងឡាយដ៏ចម្បងៗ របស់សេចក្ដីប្រកាសជាសកលនោះ មករៀបរាប់សង្ខេបដូចខាងក្រោមនេះ :

* មាត្រា ១ និង ២ បាននិយាយពីហេតុការណ៍ដ៏សំខាន់បំផុតថា មនុស្សទាំងអស់គ្មានអ្វីខុសប្លែកពីគ្នាទេ, កើតមកមានសេរីភាព និងមានសមភាពរស់នៅក្នុង

កិត្តិយស និងក្នុងសិទ្ធិទាំងឡាយ, ហើយសំដៅឆ្ពោះទៅរកគោលការណ៍ជាមូលដ្ឋាន នៃសមភាព និងគ្មានការរើសអើងក្នុងការទទួលនូវសិទ្ធិ និងសេរីភាពជាមូលដ្ឋាន ។

* មាត្រា ៣ ទៅ ២១ បាននិយាយទាក់ទងដល់សិទ្ធិស៊ីវិល និងសិទ្ធិនយោបាយ ដែលមនុស្សជាតិត្រូវមាន ។ មាត្រាទាំងនោះ បានចែងពី

ក / សិទ្ធិដើម្បីរស់នៅ, សេរីភាព និងសន្តិសុខផ្ទាល់ខ្លួន ។

ខ / សេរីភាពផុតពីទាសភាព និងខ្ញុំកញ្ជះគេជាច់ថ្លៃ ។

គ / សេរីភាពផុតពីការធ្វើទារុណកម្ម, ផុតពីអំពើឃោរឃៅ, អមនុស្សធម៌ ឬការធ្វើទោសទុក្ខ ឬការចាត់ទុកជាមនុស្សថោកទាប ។

ឃ / សិទ្ធិអោយគេទទួលស្គាល់ថា ជាមនុស្សម្នាក់នៅចំពោះមុខច្បាប់នៅគ្រប់ទីកន្លែង ។

ង / សិទ្ធិទទួលបានកិច្ចការពារស្មើគ្នាអំពីច្បាប់ ។

ច / សិទ្ធិបានទទួលការជួសជុលសងការខូចខាតចំពោះការរំលោភបំពានសិទ្ធិមនុស្ស ។

ឆ / មានសេរីភាព ផុតពីការចាប់ចង, ឃុំឃាំង ឬនិរទេសដោយតាមតែទំនើងចិត្ត ។

ជ / សិទ្ធិទទួលការវិនិច្ឆ័យ និងជំនុំជំរះត្រឹមត្រូវ និងបើកសវនាការជាសាធារណៈ ដោយតុលាការមួយឯករាជ្យ និងគ្មានប្រកាន់បក្សពួក ។

ឈ / សិទ្ធិជាអ្នកគ្មានទោសរហូតដល់ពេលតុលាការប្រកាសថា មានទោស ។

ញ / សិទ្ធិរួចផុតពីការកាត់ទោសចំពោះអំពើណាមួយ ដែលពុំមែនជាបទល្មើសព្រហ្មទ័ណ្ឌ នៅពេលដែលអំពើនោះត្រូវបានប្រព្រឹត្ត ។

ដ / សេរីភាពផុតពីការជ្រៀតជ្រែកដោយអំណាចទៅក្នុងកិច្ចការឯកជន,

កិច្ចការក្នុងគ្រួសារ, ក្នុងគេហដ្ឋាន ឬលិខិតស្នាម ។

ឋ / សេរីភាពដើរហើរ ផ្លាស់ប្តូរទីលំនៅ រួមទាំងសិទ្ធិចាកចេញពីប្រទេសមួយទៅប្រទេសមួយ ហើយត្រឡប់មកកាន់ប្រទេសរបស់ខ្លួនវិញ ។

ឌ / សិទ្ធិសុំជ្រកកោន ។

ឍ / សិទ្ធិសុំចូលសញ្ជាតិ ។

ណ / សិទ្ធិរៀបអាពាហ៍ពិពាហ៍ និងសិទ្ធិកសាងគ្រួសារ ។

ត / សិទ្ធិមានកម្មសិទ្ធិផ្ទាល់ខ្លួន ។

ថ / សេរីភាពខាងការគិត, មនសិការ និងសាសនា ។

ទ / សេរីភាពខាងមតិ និងសំដែងយោបល់ ។

ធ / សេរីភាពប្រជុំដោយស្ងប់ស្ងៀម និងសេរីភាពបង្កើតសមាគម ។

ន / សេរីភាពចូលរួមក្នុងការគ្រប់គ្រងប្រទេសរបស់ខ្លួន ។

ប / សេរីភាពចូលរួមបំរើការងារសាធារណៈនៅក្នុងប្រទេសរបស់ខ្លួន ។

* មាត្រា ២២ ដល់ ២៧ បានចែងអំពីសិទ្ធិខាងសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។ មាត្រាទាំងនោះ រួមមានសិទ្ធិទាំងឡាយខាង ៖

ក / សិទ្ធិខាងសន្តិសុខសង្គម ។

ខ / សិទ្ធិធ្វើការងារ និងសិទ្ធិជ្រើសរើសដោយសេរីនូវមុខរបរ ។

គ / សិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារស្មើគ្នា ។

ឃ / សិទ្ធិទទួលប្រាក់បំណាច់ត្រឹមត្រូវ និងសមស្របសម្រាប់ទ្រទ្រង់ជីវិតអោយសក្តិសមកិត្តិយសជាមនុស្ស ។

ង / សិទ្ធិបង្កើត និងចូលរួមក្នុងសហជីព ។

ច / សិទ្ធិសំរាក និងលំហែកាយ ។

ឆ / សិទ្ធិរស់នៅតាមខ្នាតមួយ ដើម្បីធានាបានសុខភាព និងសុខុមាលភាព

( រួមមានទាំងអាហារ សំលៀកបំពាក់ លំនៅឋាន និងថ្នាំព្យាបាលរោគ ) ។

ជ / សិទ្ធិសន្តិសុខក្នុងពេលគ្មានការងារធ្វើ ពេលឈឺ, ពេលពិការ, ពេលធ្លាក់ខ្លួនមេម៉ាយ, ពេលជរា ឬពេលមានហេតុការណ៍អ្វីផ្សេងទៀត ហួសពីសមត្ថភាពខ្លួនគ្រប់គ្រងបាន ។

ឈ / សិទ្ធិទទួលកិច្ចគាំពារមាតា និងទារក ។

ញ / សិទ្ធិទទួលការអប់រំ, ដោយឪពុកម្តាយមានសិទ្ធិជ្រើសរើសជាមុននូវប្រភេទការអប់រំណា ដែលយល់ថាសមស្របនឹងកូនរបស់គេ ។

ដ / សិទ្ធិចូលរួមក្នុងជីវភាព វប្បធម៌របស់សមាគមខ្លួន, និង

ឋ / សិទ្ធិទទួលកិច្ចការពារអត្ថប្រយោជន៍ខាងផ្លូវចិត្ត និងខាងផ្លូវសម្ភារៈកើតចេញពីការតែងនិពន្ធខាងចំណេះវិទ្យាសាស្ត្រ, អក្សរសាស្ត្រ និងផលិតកម្មសិល្បៈ ។

* មាត្រា ២៨ បានសង្កត់ធ្ងន់លើហេតុការណ៍ដែលថា មនុស្សគ្រប់រូបមានសិទ្ធិចូលរួមក្នុងរបៀបរៀបរយសង្គម និងរបៀបរៀបរយអន្តរជាតិ ដែលនៅក្នុងរបៀបរៀបរយនេះ សិទ្ធិ និងសេរីភាពដែលបានចែងនៅក្នុងសេចក្តីប្រកាសជាសកល ត្រូវបានគេទទួលស្គាល់យ៉ាងពេញលេញ ។

* មាត្រា ២៩ ចង្អុលប្រាប់ថា មនុស្សម្នាក់ៗ មានករណីយកិច្ចត្រូវបំពេញចំពោះសហគមន៍របស់ខ្លួន, ដែលមានតែនៅក្នុងសហគមន៍នេះទេ ទើបការរីកចំរើនខាងបុគ្គលភាពរបស់ខ្លួនប្រព្រឹត្តទៅបានដោយសេរី និងពេញលេញ ។ មាត្រានេះ ក៏ចង្អុលប្រាប់ផងដែរ នូវកំរិតក្របខណ្ឌនៃសិទ្ធិសេរីភាពរបស់បុគ្គល ។ មាត្រានេះបន្ថែមថា សិទ្ធិ និងសេរីភាព ក៏មិនត្រូវអនុវត្តអោយផ្ទុយទៅនឹងបំណងប្រាថ្នា និង គោលការណ៍របស់សហប្រជាជាតិឡើយ ។

* មាត្រា ៣០ បានចែងថា គ្មានបញ្ញត្តិណាមួយនៅក្នុងសេចក្តីប្រកាស

ជាសកលនេះ អាចនាំអោយគេយល់ច្រឡំថា សម្រាប់អនុវត្តចំពោះរដ្ឋណាមួយ ឬចំពោះក្រុមណាមួយ ឬក៏ចំពោះមនុស្សណាមួយ នូវសិទ្ធិចូលរួមក្នុងសកម្មភាពណាមួយ ឬប្រព្រឹត្តអំពើណាមួយសំដៅបំផ្លាញសិទ្ធិ និងសេរីភាព ដែលមានចែងនៅក្នុងសេចក្ដីប្រកាស ។ មាត្រាបញ្ចប់នេះ គឺថាមាត្រាដ៏ចាំបាច់ក្នុងទស្សនៈដែលថាមនុស្សជាតិមានលក្ខណៈភិនភាគខុសៗ ពីគ្នា ខាងជាតិសាសន៍, វប្បធម៌ . ល ., វាប្រាកដជាអាចកើតមានក្នុងចំណោមករណីជាច្រើន នូវការបកស្រាយមិនត្រឹមត្រូវ ។ ដោយហេតុនេះ ទើបមានប្រការប្រុងប្រយ័ត្នបែបនេះ ។

យើងបានទទួលស្គាល់ថា ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ បានផ្ដល់វិភាគទានយ៉ាងច្រើនចំពោះការយកចិត្តទុកដាក់នៃមាត្រាទាំងឡាយនោះ ។ នៅក្នុងទីនេះ, យើងសុំលើកយកមកពិចារណានូវមាត្រាបួននៃសេចក្ដីប្រកាស ជាអាទិ៍គឺមាត្រាទី១, ទី២, ទី៦ និងទី២៣ ក្រោមពន្លឺនៃខ្លឹមសារដែលយើងនិយាយរួចហើយទាក់ទងនឹងសិទ្ធិមនុស្សនៅក្នុងទស្សនវិស័យរបស់ពុទ្ធសាសនា ។ ក្នុងបណ្ដាមាត្រាទាំងប៉ុន្មាននេះ យើងលើកតែមាត្រាទី១ និងទី២ ដ៏ជាមូលដ្ឋានគ្រឹះគ្របដណ្ដប់ទៅលើមាត្រាឯទៀតៗ នៃសេចក្ដីប្រកាស, ចំណែកឯមាត្រាទី៦ និងទី២៣ គឺជាមាត្រាតំណាងនៃផ្នែកទាំងពីរ គឺ១ សិទ្ធិស៊ីវិល និងសិទ្ធិនយោបាយ, និង២ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិវប្បធម៌តាមលំដាប់លំដោយ ដូចបានកត់សំគាល់រួចមកហើយ ។

មាត្រាទី ១ . មនុស្សទាំងអស់ កើតមកមានសេរីភាព និងសមភាពរស់នៅក្នុងសេចក្ដីថ្លៃថ្នូរ និងសិទ្ធិទាំងឡាយ ។ គេកើតមកមានវិចារណញ្ញាណ ( Reason ) និងមនសិការ ( Conscience ) ហើយគេគប្បីប្រព្រឹត្តចំពោះគ្នាទៅវិញទៅមកក្នុងស្មារតីជាភាតរភាព ។

មាត្រានេះ គឺជាគ្រឹះនៃសិទ្ធិមនុស្សទាំងអស់ ហើយស្របស្រួល ទាំងស្រុងជាមួយនឹងគំនិតពុទ្ធសាសនា ។ ក្នុងទស្សនាទាននេះ វាគ្មានអ្វីថ្មីទេចំពោះពុទ្ធ-

សាសនា ។ ដូចយើងបាននិយាយពីខាងដើមទីហើយ, ទស្សនៈពុទ្ធសាសនាចំពោះសិទ្ធិមនុស្សលេចចេញមកពីសម្មតិកម្មមូលដ្ឋានពីរយ៉ាង, មួយគឺទស្សនវិជ្ជា និងមួយទៀតគឺចរិយាធម៌ ( ethics ) ។ ការយកចិត្តទុកដាក់របស់យើងក្នុងទីនេះ គឺសម្មតិកម្មទស្សនវិជ្ជា ។ ទស្សនវិជ្ជាគាំទ្រថា មនុស្សគ្រប់រូបកើតមកមានសេរីភាព ហើយ និងមានការទទួលខុសត្រូវទាំងស្រុងចំពោះសង្គម ។ មនុស្សពុំមែនជាផលិតកម្មរបស់អាទិទេពអ្នកបង្កើតណាមួយទេ, ហើយដោយហេតុនេះ មនុស្សរស់នៅចំណុះក្រោមក្រឹត្យក្រម ហេតុភាពអបច្ច័យនិយម (the non-deterministic causal laws) ដែលកំពុងតែប្រព្រឹត្តទៅក្នុងចក្រវាឡ ។ វាសនារបស់មនុស្សឋិតនៅក្នុងកណ្ដាប់ដៃរបស់គេផ្ទាល់ ។ សេរីភាពនេះរបស់មនុស្ស បានផ្ដើមមានមកជាមួយនឹងកំណើតរបស់គេផ្ទាល់, ហើយការទទួលស្គាល់សមភាពរបស់មនុស្សនៅក្នុងសេចក្ដីថ្លៃថ្នូរ និងសិទ្ធិទាំងឡាយដោយពុទ្ធសាសនា ត្រូវបានឆ្លុះបញ្ចាំងអោយឃើញច្បាស់នៅក្នុងការអោយតម្លៃលើការជឿទុកចិត្តលើខ្លួនឯង ( self reliance ) ដែលព្រះពុទ្ធបានលើកឡើង និងអោយឈ្មោះថា *អត្តការៈ* ( អំពើ ឬការខិតខំផ្ទាល់ខ្លួន ), *បុរិសការៈ* ( ការខំប្រឹងប្រែងរបស់មនុស្ស ), *បុរិសថាមៈ* ( កំឡាំងផ្ទាល់របស់មនុស្ស ), *បុរិសវិរិយៈ* ( ការព្យាយាមរបស់មនុស្ស ), *បុរិសបរក្កមៈ* ( តម្លៃផ្ទាល់របស់មនុស្ស ) និង*បុរិសធោរយ្ហៈ* ( ការទទួលខុសត្រូវរបស់មនុស្ស ) ។ តម្លៃដ៏លេចធ្លោទាំងនេះរបស់មនុស្ស ត្រូវបានលោកចងក្រងនៅក្នុង *សម្បសាទនិយ-សុត្តន្ត* នៃទីឃនិកាយ ជាឧទាហរណ៍ស្រាប់ ។ ជាងនេះទៀត, ទស្សនៈនេះ ត្រូវបានគេធ្វើអោយកាន់តែប្រាកដឡើងនៅក្នុងការប្រកាសរបស់ព្រះពុទ្ធអង្គដែលថាមនុស្សគ្រប់រូបអាចនឹងកសាងខ្លួនអោយក្លាយជាព្រះពុទ្ធបាន ។ ព្រះពុទ្ធបានរកឃើញនូវសុក្រឹតភាព នៃធម្មជាតិរបស់មនុស្ស ។

ប្រសិនបើបុគ្គលម្នាក់ៗ ជាម្ចាស់លើខ្លួនឯងផ្ទាល់ ដូចជាគាថានៅក្នុងគម្ពីរ

ធម្មបទបានសំដែង, មនុស្សម្នាក់ៗ ពិតជាកើតមកមានសេរីភាព ហើយបើមនុស្ស ទាំងអស់អាចសំរេចបាននូវពុទ្ធភូមិមែន, តើវាមានអ្វីធំធេងជាងសមភាពនៅក្នុង សេចក្ដីថ្លៃថ្នូរ និងសិទ្ធិទាំងឡាយនេះទៀត ?

វិចារណញ្ញាណ និងមនសិការ ត្រូវបានគេទទួលស្គាល់ថាជាសភាវធម៌ មាននៅក្នុងពុទ្ធសាសនា ថ្វីបើសភាវធម៌ក្រោយនេះ គឺមនសិការ ដូចដែលមនុស្ស ភាគច្រើនបានយល់សព្វថ្ងៃនេះ ថាមិនមែនជាទស្សនះពុទ្ធសាសនាក៏ដោយ ។ Reason ប្រែថា « វិចារណញ្ញាណ » តាមការនិយមសព្វថ្ងៃ, ប៉ុន្តែ តាមភាសា បាលី មានន័យថា « ធម្មវិតក្កៈ » ឬ « ធម្មាធិបតេយ្យ », ចំណែកឯ Conscience « មនសិការ », តាមភាសាបាលី គឺ « អត្តាធិបតេយ្យ » ។ សភាវធម៌ទាំងពីរនេះ ទោះបីច្រើន ឬតិច តែងតែប្រព្រឹត្តទៅជាមួយគ្នា ហើយកផ្តុំជាសតិភ្ញាក់រលឹក ស្គាល់ ខុស ស្គាល់ត្រូវ ។ Reason « វិចារណញ្ញាណ » និង Conscience « មនៈ សិការ » បញ្ជាក់ប្រាប់នូវសមត្ថភាពវិនិច្ឆ័យតម្លៃសីលធម៌, គំនិតប៉ងប្រាថ្នា និង អំពើរបស់បុគ្គលម្នាក់ៗ ផ្ទាល់, ហើយជ្រើសរើសយកនូវអ្វីដែលត្រូវ និងសមស្រប តាមបំណងប្រាថ្នា ទាំងសម្រាប់ខ្លួនផង ទាំងសម្រាប់អ្នកដទៃផង ។ ធម៌ទាំងពីរនេះ រួមគ្នាកើតជាចំណែកកផ្តុំទៅជា « សតិន្ទ្រិយ » ( the faculty of mind fulness ) នៅក្នុងអង្គនៃមនុស្ស ។ វិចារណញ្ញាណ និងមនសិការ, តាមការយល់ នៅក្នុងពុទ្ធសាសនា, អាចអោយគេមើលឃើញតាមគំរូរឿងនិទាននៅក្នុង *កាលាមៈ សូត្រ* ដែលបានចង្អុលប្រាប់លក្ខណវិនិច្ឆ័យសម្រាប់វែកញែករវាងអំពើល្អ (កុសល) និងអំពើអាក្រក់ (អកុសល) នៅក្នុងន័យសីលធម៌ ។

*( នៅមាន ត )*

# កម្លៃនៃជំហានធីមួយ

លោក គ្រីស្តូហ្វក្លូឡុម[១] (Christophe Colomb) ជាបុត្រាជាងតម្បាញម្នាក់នៅទីក្រុង ហ្សែន (Gêne) នៃប្រទេសអ៊ីតាលី ។ លោកបានស្ម័គ្រចិត្តចូលបំរើព្រះមហាក្សត្រនៃប្រទេសអេស្ប៉ាញ (Espagne) នៅរវាង គ.ស ១៤៩២ ដែលនៅពេលនោះ ព្រះអង្គបានប្រទានសំពៅបីគ្រឿងដល់លោក ដើម្បីជាមធ្យោបាយធ្វើដំណើរឆ្លងកាត់មហាសមុទ្រ ស្វែងរកពិភពថ្មី១ទៀតក្នុងសកលលោកនេះ ក្នុងទិសដៅធ្វើទំនាក់ទំនងខាងពាណិជ្ជកម្ម ។ លោកបានសម្រេចជោគជ័យដោយបានរកឃើញទ្វីបអាមេរិក នៅ គ.ស ១៥០២ ។ ការរកឃើញពិភពថ្មីនេះ ធ្វើអោយលោកក្លាយទៅជាវីរបុរសម្នាក់ មានឈ្មោះល្បីល្បាញទូទាំងទ្វីបអឺរ៉ុប ។ ពិធីជប់លៀងដ៏ធំមួយត្រូវបានចាត់ចែងឡើង ដើម្បីជូនជាមហាកិត្តិយសចំពោះរូបលោក គ្រីស្តូហ្វក្លូឡុម ។ វរជន និងភ្ញៀវកិត្តិយសដែលបានអញ្ជើញចូលរួម បានឡើងថ្លែងសង្កថាជាបន្តបន្ទាប់ សម្តែងនូវអំណរសាទរ និងកោតសរសើរចំពោះរូបលោក ដែលបានបើកទ្វារជើងមេឃអោយទ្វីបអឺរ៉ុបបានស្គាល់ពិភពថ្មីមួយទៀត ។ ប៉ុន្តែ នៅពេលនោះ គូប្រជែងរបស់លោកម្នាក់ បានឡើងថ្លែងនូវពាក្យសំដីយ៉ាងគ្រោតគ្រាត ជូរចត់ចំពោះលោក ដូច្នេះថា : « គ្រិស្តូហ្វក្លូឡុម មិនមែនជាមនុស្សអស្ចារ្យដូចដែលគេស្មាននោះឡើយ ព្រោះអ្នកផ្សេងទៀត ក៏អាចរកឃើញទ្វីបអាមេរិកដែរ » ។ ពេលនោះ អង្គពិធីជប់លៀងទាំងមូល ស្ថិតក្នុងបរិយាកាសស្ងាត់

---

(១) លោក គ្រិស្តូហ្វក្លូឡុម កើតនៅ គ.ស ១៤៥១ ស្លាប់នៅ គ.ស ១៥០៦ ក្នុងសភាពលំបាកតោកយ៉ាកជាទីបំផុត ។

ជ្រៀប ដោយគេរំពឹងថា នឹងមានប្រតិកម្មយ៉ាងខ្លាំងភ្លាពីលោក គ្រីស្តូហ្វកូឡុម ជាមិនខាន ។ ប៉ុន្តែ សំដីទ្រគោះនេះ ពុំបានធ្វើអោយលោក គ្រីស្តូហ្វកូឡុម ខឹងច្រឡោតបន្តិចណាសោះឡើយ ។ ផ្ទុយទៅវិញ លោកបែរជាញញឹមទទួលអំពើប្រទូសរ៉ាយនេះ ហើយក៏អញ្ជើញទៅកាន់វេទិកា ដែលតាំងនៅកណ្តាលអង្គពិធី ។ លោកនិយាយទៅកាន់ភ្ញៀវទាំងអស់ថា : « តើមានអស់លោកណា អាចដាក់ពងមាន់នេះអោយឈរនឹងលើចានទាបបានឬទេ ? បើអាចធ្វើបាននោះ ចាត់ទុកថា អ្នកនោះមានសមត្ថភាពពិតៗ » ។ បន្ទាប់មក មានមនុស្សជាច្រើនបានឡើងទៅសាកល្បងដាក់ពងមាន់អោយឈរត្រង់នៅលើបាតចាន ក្នុងនោះមានទាំងគូរប្រជែងរបស់លោក គ្រីស្តូហ្វកូឡុម ផងដែរ ។ ក៏ប៉ុន្តែ ពុំមាននរណាម្នាក់មានសមត្ថភាពធ្វើបានតាមសំណូមពរខាងលើនេះឡើយ ។ ឃើញដូច្នេះ លោកគ្រីស្តូហ្វកូឡុម ក៏ឡើងទៅកាន់វេទិកាម្តងទៀត ហើយមានប្រសាសន៍ថា : « នៅទីបំផុត ខ្ញុំឃើញថា អស់លោកមិនអាចសម្រេចនូវវិញ្ញាសានេះបានឡើយ ។ ដូច្នេះ នៅទីនេះ មានតែខ្ញុំទេដែលអាចធ្វើបាន » ។ ពេលដូច្នេះហើយ លោកក៏យកពងមាន់ផ្នែកខាងធំ អុកធ្ងន់ដៃបន្តិចទៅលើបាតចាន ។ ពងមាន់ឈរត្រង់នឹងស្លុក ! ។ អង្គពិធីជប់ល្បៀងទាំងមូល ទះដៃ និងបន្លឺជយឃោសន៍យ៉ាងកងរំពង អបអរសាទរចំពោះប្រាជ្ញាវាងវៃរបស់លោកកូឡុម ។ មានតែគូប្រជែងរបស់លោកម្នាក់ប៉ុណ្ណោះ ដែលពុំមានសមានចិត្តដូចគេឯងផងទាំងពួង ។ បុរសនោះ ដើរទៅកាន់វេទិកា ហើយស្រែកឡើងថា : « បើធ្វើដូច្នេះ ខ្ញុំក៏អាចធ្វើបានដែរ » ។ ក្នុងពេលជាបន្ទាន់នោះ លោកគ្រិស្តូហ្វ ក៏បានឆ្លើយតបភ្លាមៗទៅវិញថា : « លោកអាចធ្វើបានមែន តែធ្វើបានដោយយកតម្រាប់តាមខ្ញុំ ។ ការស្វែងរកទ្វីបអាមេរិក ក៏ដូច្នេះដែរ បើគេអាចរកឃើញ គឺរកឃើញក្រោយខ្ញុំ ! » ។

ចម្លើយប្រកបដោយតក្កភាព (logique) នេះ បានធ្វើអោយអង្គប្រជុំទះដៃអបអរសាទរយ៉ាងកងរំពងម្តងទៀត ធ្វើអោយគូប្រជែងរបស់លោកបានដល់

ក្តីអាម៉ាស់នៅកណ្តាលជំនុំចំណោមមហាជនដ៏ច្រើនកុះករ ។

ដូច្នេះ អ្វីដែលមានតម្លៃជាងគេបំផុតនោះ គឺមានតែជំហានដំបូងនេះទេ ។

ប្រែសម្រួលពីសៀវភៅវេយ្យាករណ៍បារាំង
របស់លោក ក្លូត អូហ្សេ[(១)] (Claude Augé)
ដោយ មៀច ប៉ុណ្ណ ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

(១) លោក ក្លូត អូហ្សេ (Claude Augé) នេះ ជាដៃគូដ៏ចំណានរបស់លោក ឡារុស (Larousse) ក្នុងការនិពន្ធ ចងក្រងវចនានុក្រម ភាសាបារាំង ។

# ធំនួញកាចាស់ម្ចាស់ខ្មែរជៀវ (១)

បទពាក្យប្រាំបួន

ខ្ញុំខ្មែរចាស់ ស្គាល់ខ្លួនច្បាស់ កម្លាំងឱន
ជិតថ្ងៃសូន្យ ចង់អោយកូន ទទួលកេរ
រាប់យប់ថ្ងៃ គិតមមៃ ព្រោះវ័យជ្រេ
ខ្លាចបាត់កេរ តែកូនបែរ ធ្វើកន្តើយ ។
ខ្សែជៀវកេរ ជូនតាខ្មែរ ឱបនឹងទ្រូង
ដេញត្រូង១ លួងបេះដូង ខ្មែរអោយស្បើយ
ទុក្ខកង្វល់ អស់អំពល់ ពាន់ឆ្នាំហើយ
ចុះម្តេចឡើយ ប្រែព្រងើយ គ្មានអ្នកស្នង ។
ធ្លាប់ញញឹម ធ្លាប់សង្ឃឹម ធ្លាប់មានឈ្មោះ
ធ្លាប់តែខ្ពស់ ទទួលយស ពីអ្នកផង
ឥឡូវស្ងាត់ សឹងតែបាត់ សូន្យតែម្តង
ញាតិបងប្អូន ជួយខ្ញុំផង សូមអង្វរ ។
ឱកូនអើយ ម្តេចកន្តើយ នឹងកេរពុក
មិនថែទុក តទៅមុខ កេរអាករ
គ្រាន់ប្រាប់គេ ថាជាតិខ្មែរ មានវប្បធម៌
ថ្លៃបវរ ចាស់បន្ត ទុកអោយអ្នក ។

---

(១) តាមការពន្យល់របស់វចនានុក្រមខ្មែរថា " សាជៀវ ឬ សាយជៀវ " ។

| | | |
|---|---|---|
| ខ្សែមួយពិត | តែកិរិត | សូរពិរោះ |
| ក្រអួនខ្ពស់ | មិនប្លែកខុស | ខ្សែច្រើនជាក់ |
| ពុកអង្វរ | ដញបន្ត | ណាវរលក្ខណ៍ |
| ហើយថ្នមថ្នាក់ | ថៃទុកដាក់ | កេរដូនតា ។ |

**ខៀវ បញ្ញាឧត្ដម**
អនុប្រធានការិយាល័យស្រាវជ្រាវ
ទទួលបន្ទុកផ្នែកសោតទស្សន៍
នៅពុទ្ធសាសនបណ្ឌិត្យ

# រដូវធ្វើប្រហុក

( បទពាក្យប្រាំពីរ )

គោកំពង់ឆ្នាំងពាក់ស្បែកជើង ជួររទេះយើងបរហូរហែ
មានចាស់មានក្មេងមានទាំងឆ្កែ ជាទម្លាប់ខ្មែរតាំងពីដើម ។
ខ្លះដឹកបាវស្រូវខ្លះអង្ករ ខ្លះទៀតដឹកស្ករច្រើនសម្បើម
ងៀតត្រីអន្លង់នៅសើម១ ខ្លះមានទាំងមើមដំឡូងផង ។
ដល់ម្លប់គេឈប់ដាក់ដាំបាយ ក្មេង១សប្បាយស្រែកអឺងកង
កូនប្អូនកាន់ដៃអាកូនបង ដឹកគោទៅចងស៊ីចំបើង ។
ពេលបាយសប្បាយជាងក្នុងហាង ក្មេងម្ខាងចាស់ម្ខាងហ៊ោក្រេវឡើង
ត្រីអន្លង់អាំងកប់ចំបើង អំពិលហាន់ស្តើងដាក់ទឹកត្រី ។
ព័ទ្ធវង់វៃភ្នែនខ្លះបត់ជើង ប្រុស១ភូមិយើងផ្តើមស្រដី
ចំអន់បង្អាប់អោយស្រី១ អ្នកអត់មានប្តីក្រហមមុខ ។
កន្ទេលស្លឹកត្នោតក្រាលតម្រៀប ក្មេង១ ដេកត្រៀបចាស់រៀបទុក
ចានឆ្នាំងក្អមទឹកត្រឡោកស្នុក ចងពាងប្រហុកត្រៀមដំណើរ ។
ទៅដល់គោលដៅមនុស្សកុះករ សំឡេងអ៊ូអរល្អប្រសើរ
ទិដ្ឋភាពសប្បាយគ្មានអ្វីស្មើ ទូកចតមនុស្សដើរដោះដូរគ្នា ។
ខ្លះយកអំបិលដូរអង្ករ យកប៊ីចេងស្ករដូរមាន់ទា
មានទាំងមីសួម្រេចបង្គា បបួលដូរគ្នានឹងស្រូវថ្មី ។
អ្នកភូមិភាគច្រើនកាត់ប្រវាស់ ទុករបស់ខ្លះដូរយកត្រី
សង្វាតធ្វើផ្អកប្រហុកថ្មី បន្តទុកអីអោយដល់ខួប ។

ប៉ូកប៉ាក់ៗស្នូរកាំបិត ប្រសប់ពេកពិតកម្រជួប
ស្រកាវះពោះកាត់ក្បាលគួប បើបានទៅជួបទើបសរសើរ ។
មាត់ទឹកខ្លាញ់ត្រីអណ្តែតត្រា ជម្រះស្រកាជាន់បណ្តើរ
ខ្លះដោតចង្កាក់យកទៅឆ្អើរ អ្នកខ្លះគេធ្វើជាផ្អកម៉ាំ ។
ពេលយប់ចង្កៀងភ្លឺពេញវាល សម្បុរត្រីហាលពេញៗ ខ្លាំ
ស្នូរទះផ្តិបផ្លាប់ព្រោះមូសខាំ ខ្លះលោតទន្ទ្រាំផងអេះផង ។
អ្នកខ្លះឆ្លៀតចៀនប្រហិតលក់ ផ្ទាប់ជាមួយជ្រក់ឈ្ងុំយកន្លង
ក្បែរនោះឃើញមានថាសនំកង មានចេកចៀនផងលក់ហូរហែ ។
ទម្លាប់នេះសល់ពីបូរាណ រស់នៅសុខសាន្តអម្បូរខ្មែរ
ដោះដូរគ្នារស់គួរតែថៃ ថៃសម្បុរខ្មែរអោយគង់វង្ស ។
ពីស្រែមកក្រុងចំការស្រែ ភ្នំបឹងវាលខ្មែរកាលរឿងរុង
វេញបានជាពូជតែមួយផ្លុង ខ្មែររស់បានរុងរឿងទៅអើយ ។

**ខៀវ បញ្ញាចុឡ**

អនុប្រធានការិយាល័យស្រាវជ្រាវ
ទទួលបន្ទុកផ្នែកសោតទស្សន៍
នៅពុទ្ធសាសនបណ្ឌិត្យ

# សេចក្ដីជូនដំណឹង

## ស្ដីពីលទ្ធផលនៃចម្លើយ " កំណាព្យប្រស្នា "

## ដែលបានចុះក្នុងទស្សនាវដ្ដីកម្ពុជសុរិយា លេខ ១ ឆ្នាំ ១៩៩៦

គណៈកម្មការនិពន្ធនៃទស្សនាវដ្ដីកម្ពុជសុរិយា មានកិត្តិយស សូមប្រគេន ជូនដំណឹងចំពោះព្រះតេជព្រះគុណ និងចំពោះអស់លោក អ្នកនាងកញ្ញា ព្រមទាំងមិត្តអ្នកអានជាទីគោរពថា គណៈកម្មការបានទទួលលិខិត ចំនួន ១២ ដែលបានរួមចំណែកដល់ការឆ្លើយប្រស្នា ។ នៅក្នុងចំណោមលិខិតទាំង ១២ នោះ មានលិខិតចំនួនតែ ២ គត់ បានឆ្លើយត្រូវដូចគ្នា, ប៉ុន្តែ លិខិមួយបានឆ្លើយរៀបរាប់សេចក្ដីក្បោះក្បាយ ទាំងមានសម្ផស្សកាព្យល្អ ។ គណៈកម្មការ បានសំរេចជូនរង្វាន់ដល់ជ័យលាភីទាំងពីររូប ដោយរៀបចំណាត់ថ្នាក់ជាពីរ គឺ :

ក) ចំណាត់ថ្នាក់លេខ ១ មានរង្វាន់ជាប្រាក់ ចំនួន ដប់ប្រាំម៉ឺនរៀល (១៥០.០០០) ត្រូវប្រគេនដល់ជ័យលាភីភិក្ខុព្រហ្មសុជាតិសមណសិស្សនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត,គង់នៅវត្តឧណ្ណាលោមក្រុងភ្នំពេញ។

ខ) ចំណាត់ថ្នាក់លេខ ២ មានរង្វាន់ជាប្រាក់ចំនួន ប្រាំពាន់រៀល ( ៥.០០០ ) ត្រូវប្រគេនដល់ជ័យលាភី ភិក្ខុ សួន សុភាព គង់នៅវត្តគន្ធបុប្ផារាម ( ហៅវត្ត អូរគគីរ ) ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ។

គណៈកម្មការនិពន្ធ សូមនិមន្តជ័យលាភី ដូចមានរាយនាមខាងលើ ទៅបើករង្វាន់ផ្នែកទស្សនាវដ្ដី នៃពុទ្ធសាសនបណ្ឌិត្យ នៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ រៀងរាល់ម៉ោងធ្វើការ ។

ទន្ទឹមនេះដែរ គណៈកម្មការសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះឯកឧត្តម វណ្ណ ស៊ុនហេង អ្នកតំណាងរាស្ត្រមណ្ឌលព្រៃវែង ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួនសំរាប់ឧបត្ថម្ភជ័យលាភី ដែលបានឆ្លើយប្រស្នាត្រូវលើកនេះ ។

**កម្ពុជសុរិយា**

# ចម្លើយកំណាព្យប្រស្នា

គណៈកម្មការនិពន្ធ មានកិត្តិយសនឹងចុះផ្សាយអត្ថបទរបស់ភិក្ខុ អគ្គចិត្តោ ព្រហ្ម សុជាតិ សមណសិស្សពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រឹត គង់នៅវត្តឧណ្ណាលោម ដែលបានទទួលចំណាត់ថ្នាក់លេខ « ១ » ជាជំនួសចម្លើយរបស់ម្ចាស់សំណួរ ដែលមានសេចក្តីដូចខាងក្រោម :

## ដំណោះស្រាយប្រស្នា
## ក្នុងកម្ពុជសុរិយា លេខ ១ / ១៩៩៦

បឋមខ្ញុំ ជាតិនិយម ធ្វើគារវា
លើកបាត្ថា ពួសិរសា ប្រណម្យឆ្ពោះ
អង្គបណ្ឌិត ស្នេហាជាតិ សាសនាខ្ពស់
បន្សល់ទស្សន៍ កេរ្តិកិត្តិយស ជូនបច្ឆា ។
លំដាប់ទៀត សូមអនុញ្ញាត ស្ទឹងស្មាធីរះ
រកតម្រិះ ពិចារត្រិះ វិមំសា
ហាក់យល់អាថិ តាមវិចារ. ប្បញ្ញា
មាញចិន្តា ស្រាយប្រស្នា តាមកាព្យា ។
តាមធម្មតា ជាតិមច្ឆា ដែលប្រព្រឹត្ត
ដោយជីវិត វិញ្ញាណកៈ ពិតជាក់ជា
ពុំអាចរស់ ក្នុងលំហ នៃគង្គា

| | | |
|---|---|---|
| ពុះខ្ទាក់ខ្ទា | ខ្ទោកព្យោមា | រយអង្សា ។ |
| ប្រស្នានេះ | លោកត្រិះរិះ | បែបប្រៀបធៀប |
| ចងក្រងរៀប | រៀងផ្ទៀងផ្ទាត់ | ដោយបញ្ញា |
| បានសេចក្តី | សមប្រពៃ | សន្តថា |
| មានខ្លឹមសារ | ចារសុំពេចន៍ | វិស្សជ្ជនា ។ |
| ខ្ញុំឆ្លើយឆ្លង | សាកល្បងតាម | ទស្សនាទាន |
| ដែលខ្ញុំមាន | ជាទម្លាប់ | ក្នុងប្រាជ្ញា |
| ទោះឆ្គាំឆ្គង | គង់នឹងមាន | បណ្ឌិតណា |
| ញាណចាស់ក្លា | ស្រាយបញ្ហា | ប្រស្នាសព្វ ។ |
| ភរីជាតិ | មានកំណើត | កើតក្នុងទឹក |
| ច្រើនសន្ធឹក | នឹកពណ៌នា | នឹងពុំចប់ |
| ថ្លៃងពីត្រី | អនេកក្រៃ | ពុំស្មាញរាប់ |
| ត្រីមានភព្វ | មួយពូជគាប់ | ឫទ្ធិប្លែកគេ ។ |
| វង្សត្រីនោះ | ពុំមានរស់ | ក្នុងជលធារ |
| សមុទ្ទា | ស្ទឹងបឹងបួរ | អូរទន្លេ |
| វារស់នៅ | ល្អាងទឹកមួយ | ប្លែកអស់គេ |
| អគ្គិជាលេរ | រាលរំធរេ | ពួហោដ្ឋា ។ |
| ព្រោះត្រីនោះ | កើតពីមនុស្ស | អ្នកផលិត |
| មាឧត្តចល្អិត | សូន្យចុម្ពិត | ដូចគុលិកា |
| ខ្លួនកំព្រា | ទុគ្គតភាព | ឥតមេបា |
| ហែលខ្សៀវខ្សារ | ហក់ឆ្លេឆ្លា | ក្នុងគង្គា ។ |
| ជនក្នុងលោក | បានបរិភោគ | ត្រីនោះណា |

| | | |
|---|---|---|
| ក្លួចចិន្តា | លិទ្ធជីវ្ហា | ដក់ហាទយា |
| ឱជារស | ផ្អែមល្ហុយជះ | ជាប់នាសា |
| ត្រីនោះណា | មាននាមថា | « នំក្លួនត្រី » ។ |
| ខ្ញុំរាយរាប់ | ចម្លើយភ្ជាប់ | តាមអក្ខរា |
| ប្រើវាចា | ដំណោះស្រាយ | សង្ខេបន័យ |
| ទោះប្រព្រឹត្ត | ត្រូវបធានបទ | ឬឆ្វេងក្តី |
| សូមប្រណី | ប្រោសអភ័យ | ពីសន្តាន ។ |
| យុវ័នខ្ចី | បញ្ញាញៀយ្យ | ពុំឈ្លាសឆ្លាត |
| ទោះឆ្គងខ្លះ | ផ្សេងប្រក្រតី | អាគតដ្ឋាន |
| នៃល្បះកាព្យ | ឬវាទះ | ពុំក្សេមក្សាន្ត |
| ក្តីប្រោសប្រាណ | បានពីប្រាជ្ញ | សព្វទិសា ។ |
| នាមសាសនិក | ឆ្លៀតរំលឹក | ពុទ្ធោវាទ |
| មកញោមញាតិ | គ្រប់សញ្ញាតិ | សាសន៍នានា |
| ព្រាននេសាទ | សូមសង្គ្រោះ | ទោសទណ្ឌា |
| កុំប្រហារ | ពូជមច្ឆា | ជ្រុលភ្លេចគិត ។ |
| សព្វពូជសត្វ | ជាតិតិរច្ឆាន | មិនថាត្រី |
| នាលោកីយ | រស់មានន័យ | ពឹងមនុស្សពិត |
| គ្រប់គ្រងរ័ក្ខ | ស្របតាមគ- | តិបណ្ឌិត |
| ដំណែលសត្វ | ឥតខ្លាយខ្លាត់ | វិបត្តិឈ្មោះ ។ |
| សូមអង្វរ | ដោយមនោ | មុទុទន់ |
| ដល់បងប្អូន | សាងកម្មន្ត | អសោចក្រោះ |
| សព្វសត្វព្រៃ | មានតម្លៃ | ឥតមានមោះ |

គួរស្រណោះ គួរសន្តោស គួរមេត្តា ។
សត្វនានា ជាទ្រព្យា របស់មនុស្ស
សាងកម្មស្មោះ កុំបំបាត់ ជីពបាណា
កាន់អប្បមាទ មើលក្បួនខ្នាត ពិចារណា
ពុទ្ធសាសនា ធម្មនុញ្ញ កុំក្រឡៃ ។
គោរពច្បាប់ ឆាប់នាំខ្លួន ឱ្យសុខសាន្ត
ល្មើសបំពាន ច្បាប់រុញច្រាន ធ្លាក់អវិចី
ក្នុងចក្កវាឡ ច្បាប់ជាធំ ឧត្តមក្រៃ
ច្បាប់មានន័យ សត្វសុខី យូរអង្វែង ។
បើត្រីនំ គួរប្រមុំ ប្រមូលមិត្ត
ធីផ្អែតពិត ព្រោះផលិត ដោយខ្លួនឯង
ចងដាក់ខ្ទះ ថ្លាងឆ្នាំងឃ្លះ ពាងប៉ោតពែង
ត្រីនោះឯង អវិញ្ញាណ គ្មានវេរា ។
ត្រីប្រស្នា អនាម័យ ច្នៃឥតល្បែង
ជួយសពាង្គ កាយថាមពល ផ្តល់សុខជា
ទទួលមាន អស់រយឆ្នាំ ឥតកម្មពៀរ
យើងគ្រប់គ្នា គោះពិសា នំក្លូនត្រី ។
សូមសព្វសត្វ ក្នុងវាលវដ្ត គ្រប់អាត្មា
ផ្សាយចិត្តា ព្រហ្មវិហារ រៀងរាល់ថ្ងៃ
ប្តូរចិត្តចាស់ អកុសល កាន់ចិត្តថ្មី
ស្អាតប្រិមប្រិយ ឈប់ប្រល័យ ហុតឈាមគ្នា ។
ឈប់ងប់ងល់ ប្រជែងត្បុល ក្នុងលោភា

ខាំហែកហួរ ប្រវញ្ចព្យួរ កបជា
ត្រង់ត្រាច់ចរ តាមលំអាន មជ្ឈិមា
ស្រុះស្រួលគ្នា ( សង្គមម្នា ជានាល្បី ។
អវសានល្បះ ផ្ញើពេចន៍ខ្លះ ពររាប់អាន
មកកល្យាណ មិត្តអ្នកអាន ដោយភក្តី
ទាំងព្រះសង្ឃ ទាំងគ្រហស្ថ មិត្តករី
មានស្នាដៃ លាភជាញជ័យ គ្រប់អង្គា ។

ភិក្ខុ អគ្គចិត្តោ ព្រហ្ម សុជាតិ
សមណសិស្ស នៃពុទ្ធិកវិទ្យាល័យ
ព្រះសុរាម្រឹត, ភ្នំពេញ

# កំណាព្យប្រស្នា

បទគោព័ទ្ធស្ទឹង ( ពាក្យ ៧ )

* កម្ពុជាត្លូចពិតសម្បត្តិមាន មានទ្រព្យធនធានសម្បូរផល
ផលភោគគរគោកលោកជួយផ្តល់ ផ្តល់រស់រចល់ដល់កូនខ្មែរ ។
* ខ្មែរបានសុខសាន្តមិនអត់ឃ្លាន ឃ្លានផលយើងមានកេរឪម៉ែ
ម៉ែចែកឱ្យកូនគួរជួយថែ ថែទាំជាតិខ្មែរដីខ្មែរយើង ។
* យើងកុំភ្លេចខ្លួនពួនលាក់មុខ មុខត្រូវរងទុក្ខដោយពួកឈ្លើង
ឈ្លើងឈ្លក់នឹងឈាមសង្គ្រាមភ្លើង ភ្លើងឆេះផ្ទះយើងរួញត្លូចពិត ។
* ពិតណាស់ប្រស្នាផ្តើមសេចក្តី ក្តីព្រួយមមៃរឿងព្រេងព្រឹទ្ធ
ព្រឹត្តិការណ៍ថ្មីថ្មោងតោងពិនិត្យ និត្យនៅជុំជិតលុះឥឡូវ ។
* ឥឡូវបែរមកការចោទឆ្លើយ ឆ្លើយត្រូវចហើយពុំស្ងូវត្រូវ
ត្រូវខំសន្និះត្រិះរិះផ្លូវ ផ្លូវត្រង់ផ្លូវត្រូវចំប្រស្នា ។
*« ប្រស្នាថាខ្មែរមានឈើផ្លែ ផ្លែច្រើនសឹងតែផ្អែមក្រៃណា*
*ណាខ្លះដែលមានរស់ពិសា ? សាស័ព្ទវាចារាប់ឱ្យអស់ ។*
*អស់លោកអ្នកប្រាជ្ញអាចរាប់បាន បានស្គាល់ទាំងប្រាណ(១) ក្រអូបស្រស់*
*ស្រស់ស្រាយឈ្មុយឆ្ងាញ់មិនមានមោះ មោះមើលផ្លែនោះមានប៉ុន្មាន ? »*

**ចណ្ណ ស៊ុនហេង**

(១) ស្គាល់រូបរាង ឬ ស្គាល់ឈ្មោះ ។

# ការបែងចែកគម្ពីរព្រះត្រៃបិដក
(ត)

## ខេត្តកំពត

នៅក្នុងខេត្តកំពត វត្តចំនួន ៥១ បានទទួល ១ ចប់ ក្នុង ១ វត្ត ត្រូវជា ៥១ ចប់ (សេចក្ដីសំរេចលេខ ២០៤/៩៥ កធស ចុះថ្ងៃទី ០៤.១០.១៩៩៥) គឺ :

១. វត្ត ជុំគ្រៀល ( មេគណ )
២. វត្ត ក្បាលរមាស ( អនុគណ )
៣. វត្ត ពិជ័យឧដុង្គ ( អនុគណ )
៤. វត្ត អង្គរជ័យ ( អនុគណ )
៥. វត្ត ក្រាំងដូង ( អនុគណ )
៦. វត្ត ដីក្រហម ( អនុគណ )
៧. វត្ត ដងទង់ ( អនុគណ )
៨. វត្ត អង្គមុនីវន្ត ( អនុគណ )
៩. វត្ត ត្រើយកោះ
១០. វត្ត ប្រាសាទ
១១. វត្ត ពន្លឺ
១២. វត្ត គាថាវង្ស
១៣. វត្ត ក្រាំងស្វាយ
១៤. វត្ត ស្មោរ
១៥. វត្ត កំពូលមាស
១៦. វត្ត ស្រែជា
១៧. វត្ត អង្គចក
១៨. វត្ត អង្គភ្នំតូច
១៩. វត្ត សិរីផានី
២០. វត្ត ព្រៃបន្ទាំ
២១. វត្ត កំពត
២២. វត្ត អណ្ដូងប្រេង
២៣. វត្ត បានៀវ
២៤. វត្ត នារាយណ
២៥. វត្ត អង្គផលាស្អែត
២៦. វត្ត សំឡាញ
២៧. វត្ត អង្គសុត
២៨. វត្ត ធម្មជោតនារាម
២៩. វត្ត ពោធិព្រឹក្ស
៣០. វត្ត សិរីសោភា
៣១. វត្ត កំពង់នង់
៣២. វត្ត ល្អាងទឹកជប់

៣៣. វត្ត ម្រះព្រៅ
៣៤. វត្ត ឧត្តមសិរីរដ្ឋ
៣៥. វត្ត អង្គជុំ ព្រៃនប់
៣៦. វត្ត ព្រៃក្រើស
៣៧. វត្ត យសមន្ត្រី
៣៨. វត្ត សិរីសោភ័ណ
៣៩. វត្ត អង្គរំចេក
៤០. វត្ត ព្រៃក្រឡា
៤១. វត្ត ក្តីចាស់
៤២. វត្ត បរិវាស
៤៣. វត្ត សំណាក់ត្រយឹង
៤៤. វត្ត សម្ពរ
៤៥. វត្ត ភ្នំលេតុង
៤៦. វត្ត ត្រពាំងសាលា
៤៧. វត្ត ព្រៃរោង
៤៨. វត្ត ដងទង
៤៩. វត្ត បទុមរង្សីរតនារាម

( សេចក្តីសំរេចលេខ ២៥៨/៩៥ ចុះថ្ងៃទី ២២ . ២ . ៩៦ )

៥០. វត្ត ពោធិវង្ស ឃុំស្រែក្នុង ស្រុកជុំគិរី

( សេចក្តីសំរេចលេខ ៤៨/៩៦ ចុះថ្ងៃទី ២២ . ២ . ៩៦ )

៥១. វត្ត អង្គចេក ឃុំតានី ស្រុក អង្គរជ័យ

*( នៅមាន ត )*

# មន្ត្រីសង្ឃ ៦ អង្គ នៃគណៈធម្មយុត្តិកនិកាយ ត្រូវបានតែងតាំងតម្លើងទៅក្នុងថ្នាក់

នៅថ្ងៃទី ៥ សីហា ១៩៩៦ ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់សព្វព្រះរាជហឫទ័យ យល់ព្រមតាមសេចក្តីស្នើទូលសុំ នៃសម្តេចព្រះសុគន្ធាធិបតី បួរ គ្រី ព្រះសង្ឃរាជ គណៈធម្មយុត្តិកនិកាយ នៃកម្ពុជា តែងតាំងព្រះសង្ឃ ៦ អង្គ មានឋានន្តរសក្តិ ទីរាជាគណៈ និងឋានានុក្រម នៃគណៈធម្មយុត្តិកនិកាយ ដែលមាននាមដូចតទៅនេះ ត្រូវតម្លើងទៅក្នុងថ្នាក់ ៖

១. ព្រះអរិយមុនី ទី សុភតិ មន្ត្រីសង្ឃ ទីរាជាគណៈថ្នាក់ទោ អោយឡើង ជាមន្ត្រីសង្ឃ ទីរាជាគណៈថ្នាក់ឯក មានឋានន្តរសក្តិជា ព្រះពុទ្ធាចារ្យ ។

២. ព្រះបទុមវង្សា ឡុច សាមិត មន្ត្រីសង្ឃ ទីរាជាគណៈថ្នាក់ត្រី អោយ ឡើងជាមន្ត្រីសង្ឃ ទីរាជាគណៈថ្នាក់ទោ មានឋានន្តរសក្តិជា ព្រះអរិយកស្សប ។

៣. ព្រះធម្មវរោត្តម វង វុន មន្ត្រីសង្ឃ ទីរាជាគណៈថ្នាក់ចត្វា អោយ ឡើងជាមន្ត្រីសង្ឃ ទីរាជាគណៈថ្នាក់ត្រី មានឋានន្តរសក្តិជា ព្រះមហាវីរវង្សាចារ្យ ។

៤. ព្រះធម្មត្រ័យលោកាចារ្យ ពិត សុភ័ក្ត្រ មន្ត្រីសង្ឃ ទីរាជាគណៈថ្នាក់ ចត្វា អោយឡើងជាមន្ត្រីសង្ឃ ទីរាជាគណៈថ្នាក់ត្រី មានឋានន្តរសក្តិជា ព្រះធម្មកវីវង្ស ។

៥. ព្រះគ្រូធម្មរាជា ឡៃ យុវណាត ឋានានុក្រម អោយឡើងជាមន្ត្រី សង្ឃ ទីរាជាគណៈថ្នាក់ចត្វា មានឋានន្តរសក្តិជា ព្រះធម្មត្រ័យលោកាចារ្យ ។

៦. ព្រះគ្រូធម្មសេនា ជិន ណូរ៉ាទ ឋានានុក្រម អោយឡើងជាមន្ត្រីសង្ឃ ទីរាជាគណៈថ្នាក់ចត្វា មានឋានន្តរសក្តិជា ព្រះធម្មវរោត្តម ។

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៥០ លេខ ៤ ខែ តុលា - វិច្ឆិកា - ធ្នូ

ព.ស ២៥៤០ គ.ស ១៩៩៦

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពី ពុទ្ធសាសនបណ្ឌិត្យ

## មាតិកាអត្ថបទ


I. អក្សរសិល្បិ៍ពុទ្ធសាសនា៖

- ការអប់រំពុទ្ធសាសនា ត-ចប់ ( ឈន អៀម ) ១

II. អក្សរសាស្ត្រទូទៅ :

- នរនាម និង ឋានន្តរនាម ( បណ្ឌិត ឡុង សៀម ) ៤២
- បញ្ហានៃសិលាចារឹកពីរ សម័យមុនអង្គរ ៥៣
- សិទ្ធិមនុស្ស និងពុទ្ធសាសនា ត-ចប់ ( ឈន អៀម ) ៦៥
- ប្រវត្តិខ្លែងឡង ឬ ខ្លែងអែក ( មៀច ប៉ុណ្ណ ) ៨៧
- បទ នមោ ( ធន់ ហ៊ិន ) ១០៦
- ថ្នាំ ( ខៀវ បញ្ញា វុឌ្ឍ ) ១១២
- សើចតិចជាងយំ ( មៀច ប៉ុណ្ណ ) ១១៤
- ពួកជនពាល ពង្រាលភ្លើងកាច ( នួច ជឹម ) ១១៦
- ឆ្នាំងដីកំសត់ ( ខៀវ បញ្ញា វុឌ្ឍ ) ១២០

III. កំណត់ និងប្រវត្តិការណ៍ :

- វគ្គបណ្តុះបណ្តាលចំណេះដឹងគ្រប់គ្រងបណ្ណាល័យ ១២២

ごあいさつ

この本は、世界宗教者平和会議日本委員会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました。

この本が、日本の宗教者とカンボジアの人々との友情のきずなとなり、カンボジアの宗教と文化の発展に貢献できれば幸いです。

## និវេទនកថា

ទស្សនាវដ្ដីកម្ពុជសុរិយានេះ ត្រូវបានបោះពុម្ពឡើងជាពិសេស ទុកដូចជា គម្រោងការងាររបស់គណៈកម្មាធិការជប៉ុននៃក្រុមប្រឹក្សាពិភពលោក ស្ដីពី សាសនា និងសន្តិភាព (WCRP) ហើយនិងអង្គការជំនួយសូតូស៊ូជប៉ុន (JSRC) ។

យើងខ្ញុំអធិដ្ឋាន សូមអោយទស្សនាវដ្ដីនេះ បានជាវិភាគទានរក្សាមិត្តភាព ជាមួយប្រជាជនកម្ពុជា និងថែរក្សាសម្បត្តិសាសនា និងសម្បត្តិវប្បធម៌របស់ប្រជាជនកម្ពុជា ។

## Acknowledgment

The Kampuja Suriya Magazine is specially printed as a cooperative project of the Japanese Committee of the World Conference on Religion and Peace (WCRP) and Japan Sotoshu Relief Committee (JSRC).

We pray that this magazine would contribute to the friendship with Cambodian people and their religious and cultural preservation.

# ការអប់រំរបស់ព្រះពុទ្ធសាសនា

( ត ចប់ )

រៀបរៀងដោយ **ឈន អៀម**

នៅពេលព្រះពុទ្ធសាសនា បានផ្សព្វផ្សាយទៅកាន់ផ្នែកទាំងឡាយ នៃទ្វីបអាស៊ី, គោលការណ៍ និងការប្រតិបត្តិទាំងឡាយ ខាងការអប់រំ, ផុសចេញមកពីមូលគ្រឹះទាំងឡាយនោះ បានវិវត្តឆ្លើយតបទៅនឹងសេចក្តីត្រូវការ និងសំណូមពរខាងជីវភាពបញ្ញាស្មារតីនៃម្ចាស់ប្រទេសនីមួយៗ ។ នេះហើយជាបាតុភូតនៃការកើតមាននិកាយ ឬគណៈពុទ្ធសាសនាច្រើនបែបនៅប្រទេសខ្លះនៃទ្វីបអាស៊ី ដូចជានៅប្រទេសជប៉ុន, ប្រទេសកូរ៉េ, ប្រទេសចិន ជាដើម ។ និកាយពុទ្ធសាសនាផ្សេងៗគ្នាទាំងអស់នោះ ឋិតនៅក្រោមនាមបញ្ញត្តិមួយថា « ពុទ្ធសាសនាមហាយាន » ។ ក្រោមនាមបញ្ញត្តិនេះ, ពុទ្ធសាសនិកជនទាំងឡាយនៃប្រទេសនីមួយៗ ឬនៃប្រទេសផ្សេងៗពីគ្នា បានប្រកាន់យកបែបបទប្រតិបត្តិពុំដូចគ្នាទេ តាំងពីការធ្វើពិធី, សម្លៀកបំពាក់, ការប្រព្រឹត្ត សូធ្យធម៌ រហូតដល់ទស្សនៈធំៗខ្លះ ក៏ពុំមានឯកភាពគ្នាសុទ្ធសាធដែរ ។ ប៉ុន្តែ អ្វីដែលជាមូលដ្ឋានរួមគ្នានោះ គឺគោរពប្រតិបត្តិតាមឱវាទប្រៀនប្រដៅរបស់ព្រះពុទ្ធ ដែលត្រូវបានទទួលបកស្រាយប្លែកៗពីគ្នា អនុលោមទៅតាមសេចក្តីត្រូវការ និងសំណូមពរខាងជីវភាពស្មារតីនៃសង្គមនីមួយៗ ឬក្រុមមនុស្សនីមួយៗ ។

ក្នុងប្រទេសអាស៊ីកាន់ " ពុទ្ធសាសនាថេរវាទ " ដូចយ៉ាងស្រីលង្កា, មីយ៉ានម៉ារ ( ភូមា ), ថៃ, លាវ, កម្ពុជា ជាដើមវិញ ក៏គេសង្កេតឃើញភិក្ខុសង្ឃពុទ្ធសាសនិកនៅប្រទេសតែមួយ ឬនៅក្នុងប្រទេសផ្សេងគ្នា បានប្រកាន់យកការប្រព្រឹត្តបែបបទស្លៀកដណ្តប់, ការសូធ្យធម៌, ការនិយម មិនត្រូវគ្នាខ្លះៗដែរ ។ លោកសង្ឃ

ឆាន់បារីនៅប្រទេសកម្ពុជា ទោះនៅទីណា ឬនៅពេលណាក៏គ្មានទោស, គ្មានការរិះគន់ដែរ, ប៉ុន្តែនៅប្រទេសខ្លះវិញ ដូចជាប្រទេសស្រីលង្កា ជាដើម លោកសង្ឃឆាន់បារី គឺជាកំហុសដ៏ធ្ងន់ធ្ងរ ទោះនៅពេលណាក៏ដោយ ។ នៅប្រទេសកម្ពុជា ការប្រព្រឹត្តផ្សេងគ្នាខ្លះៗ រវាងលោកសង្ឃខាងគណៈនេះ និងលោកសង្ឃខាងគណៈនោះ ក៏នៅតែជាបញ្ហារិះគន់គ្នាទៅវិញទៅមក ពុំចេះចប់ពុំចេះហើយ ។ ការចង្អុលខ្លួនឯងថា ប្រព្រឹត្តយ៉ាងនេះទើបត្រឹមត្រូវបរិសុទ្ធ ហើយចង្អុលទៅអ្នកដទៃថា ប្រព្រឹត្តយ៉ាងនោះខុសឆ្គង ពុំបរិសុទ្ធ ពុំត្រឹមត្រូវតាមពុទ្ធបញ្ញត្តិ ។ អាកប្បកិរិយាបែបនេះ គឺជាអកុសលកម្ម, ជាអំពើនាំអោយមានផលវិបាកជាអវិជ្ជមាន ច្រើនប្រការ ។ យោងតាមទ្រឹស្តីនៃពុទ្ធសាសនា, សេចក្តីបរិសុទ្ធ ឬមិនបរិសុទ្ធ គឺបុគ្គលខ្លួនឯងម្នាក់ៗផ្ទាល់ជាអ្នកបង្កើតឡើង ។ គ្មាននរណា ធ្វើអោយនរណាបរិសុទ្ធ ឬមិនបរិសុទ្ធនោះទេ ។

*៣. ការអភិវឌ្ឍន៍ជាប្រវត្តិសាស្ត្រ :*

ការអភិវឌ្ឍន៍ជាប្រវត្តិសាស្ត្រខាងការអប់រំរបស់ពុទ្ធសាសនា ត្រូវបានកំណត់ឡើងយ៉ាងប្រុងប្រយ័ត្ន និងម៉ត់ចត់ ដោយសារទីតាំងដែលព្រះពុទ្ធសាសនាក្តាប់បាននៅក្នុងសង្គមនោះៗ ។ ទីកន្លែងណាមានប្រព័ន្ធសាសនា និងទស្សនវិជ្ជា ជាបដិបក្ខតាំងនៅយ៉ាងរឹងមាំហើយ ភិក្ខុសង្ឃពុទ្ធសាសនិក ត្រូវមានភាពឆ្លាតវាងវៃក្នុងការពន្យល់ និងការពារទ្រឹស្តីរបស់ខ្លួន ដើម្បីរក្សា និងបង្កើនចំនួនបរិស័ទអោយបានច្រើន ។ នោះមុខព្រួញនៃការហ្វឹកហ្វឺនរបស់វត្តអារាម ត្រូវតម្រង់ឆ្ពោះទៅរកការដេញដោល, ការពិភាក្សា, ការវែកញែកដ៏សមហេតុផល ( ឡូស៊ិក ) និងការនិយាយការពារទ្រឹស្តីសាសនារបស់ខ្លួន ។ ប៉ុន្តែ នៅទីកន្លែងណាដែលពុទ្ធសាសនា គ្មានសាសនាណាប្រកួតប្រជែងទេ ហើយទទួលបានការរាប់អានពីប្រជាជន ឬការឧបត្ថម្ភរបស់រដ្ឋ, នោះការយកចិត្តទុកដាក់ ត្រូវផ្តោតទៅលើការថែរក្សាពុទ្ធវចនៈតាមរយៈ

បែបបទផ្សព្វផ្សាយគួរជាទីទុកចិត្ត ដោយមានការយកចិត្តទុកដាក់ជាពិសេសដល់ការពន្យល់ ឬការបកស្រាយគម្ពីរដោយស្មារតីរិះគន់ ( exegesis ) ។ នៅក្នុងឧទាហរណ៍ទាំងពីរនោះ ការអប់រំខាងគ្រហស្ថ ក៏ត្រូវបន្តអនុវត្តតាមមធ្យោបាយទេសនាមិនរៀបរយ ( informal sermons ), ដែលគួបផ្សំការពន្យល់បកស្រាយទ្រឹស្តីជាមួយនឹងការនិទានរឿងបញ្ជាក់ជាឧទាហរណ៍ ។ វិជ្ជាផ្តល់ដល់សហគមន៍ ដោយប្រការដូច្នេះ ត្រូវបានជួយពង្រឹងបន្ថែម តាមរយៈជំនួយចក្ខុទស្សន៍ ក្នុងរូបភាពគំនូរពណ៌ និងចម្លាក់នៅក្នុងព្រះវិហារ ។ នៅលើជញ្ជាំងព្រះវិហារនៃវត្តអារាមក្នុងប្រទេសកម្ពុជាទូទៅ, គេឃើញមានរូបគំនូរពណ៌ដ៏ស្រស់ល្អ ស្តីពីពុទ្ធប្រវត្តិ ឬពីរឿងទសជាតក ជាដើម ។ រូបគំនូរទាំងអស់នោះ កផ្តិបានជាជំនួយចក្ខុទស្សន៍យ៉ាងប្រសើរសំរាប់ជួយពុទ្ធសាសនិកជនអោយយល់ព្រះធម៌ផង និងជួយលើកតម្លៃសិល្បៈគំនូររបស់ខ្មែរផងដែរ ។

*៣.១. ការអប់រំពុទ្ធសាសនាក្នុងប្រទេសឥណ្ឌា :*

នៅក្នុងប្រទេសឥណ្ឌាខ្លួនឯង ពុទ្ធសាសនាបានជួបនឹងការប្រឆាំងមិនមែនមកតែពីលទ្ធិព្រាហ្មណ៍ គម្ពីរវេទប៉ុណ្ណោះទេ ប៉ុន្តែ ក៏មកពីប្រព័ន្ធសាសនា និងទស្សនវិជ្ជាឯទៀតៗដែរ ដែលគួរអោយកត់សម្គាល់នោះ គឺសាសនាជេន និងនិកាយភ្លាស៊ីកនៃទស្សនវិជ្ជាហិណ្ឌូ ។ នៅក្នុងដំណើរប្រព្រឹត្តទៅនៃវិធីសាស្ត្រ " ពន្យល់ និងការពារ " ពុទ្ធសាសនាខ្លួនឯង បានទទួលរងនូវការផ្លាស់ប្តូរប្រែប្រួលយ៉ាងធំ, ជាហេតុនាំអោយកើតមាននិកាយមហាយានឡើង ។ និកាយមហាយាន មានកំណើនប្រជាប្រិយភាពជាសារវន្ត ។ ការជជែកដេញដោល និងការពិភាក្សា ត្រូវបានប្រព្រឹត្តទៅទាំងជាមួយអ្នកគាំទ្រពុទ្ធសាសនា ជាប្រពៃណី, ទាំងជាមួយអ្នកឯទៀត ។ ឋិតក្រោមឥទ្ធិពលនៃសេចក្តីត្រូវការថ្មីនេះ, ការអប់រំពុទ្ធសាសនា បានប្រមូលផ្តុំលើ

ការហ្វឹកហ្វឺនអ្នកជជែកតវ៉ាជាបីផ្នែក តាមមុខវិជ្ជាជំនាញ ដូចខាងក្រោម ៖

ក/ កម្មវិធីសិក្សា ត្រូវបានរៀបចំឡើងយ៉ាងឆាប់ ដោយមានមុខវិជ្ជាផ្សេងៗ រួមមានវិជ្ជាផ្លូវលោក ដូចជា វេជ្ជសាស្ត្រ, តារាសាស្ត្រ, គណិតសាស្ត្របញ្ចូលផង, ពីព្រោះ បេសកជនដ៏ជោគជ័យ ត្រូវតែបានទទួលការហ្វឹកហ្វឺនដ៏ល្អ និងជាមនុស្សមានប្រយោជន៍ដល់សង្គម ;

ខ/ វិចារវិទ្យា, តក្កវិជ្ជា និងវិជ្ជាសិក្សា[១] ( Epistemology ) បានទទួលការយកចិត្តទុកដាក់យ៉ាងខ្ពស់ ទាំងក្នុងការបង្ហាត់បង្រៀន ទាំងក្នុងការផលិតផ្នែកអក្សរសាស្ត្រសិក្សា ;

គ/ ភាសាសំស្ក្រឹត ដ៏ជាភាសារបស់វរជនបញ្ញវន្ត, ហើយដោយហេតុនេះក៏ជាភាសាយានសម្រាប់និយាយជជែក ដេញដោលគ្នា, នោះក៏ត្រូវបានគេប្រើសម្រាប់បង្ហាត់បង្រៀន និងសម្រាប់សិក្សាអក្សរសាស្ត្រផងដែរ ។

ប្រព័ន្ធអប់រំរបស់វត្តអារាម ពង្រីកទូលំទូលាយបែបនេះ បានអនុគ្រោះដល់ស្ថាប័នសិក្សាធំៗ អោយក្លាយទៅជាទីជួបជុំ ជាទីស្ថានបន្តការសិក្សា និងស្រាវជ្រាវរបស់អ្នកប្រាជ្ញទាំងឡាយ មកពីតំបន់នានានៃប្រទេសឥណ្ឌា ក៏ដូចជាមកពីប្រទេសជិតខាងដែរ ។ ប៊ូជនីយេសក៏ចិនបីរូប, ដែលបានមកមើលស្ថាប័នសិក្សាមួយចំនួន ក្នុងបណ្តាស្ថាប័នទាំងនោះ នៅចន្លោះសតវត្សទីប្រាំ និងទីប្រាំពីរនៃគ្រិស្ត-សករាជ បានរៀបរាប់ពីស្ថាប័នសិក្សាទាំងនោះថា ជាមជ្ឈមណ្ឌលធ្វើសកម្មភាពអប់រំនិងអក្សរសាស្ត្រ, ដែលទ្រទ្រង់ និងឧបត្ថម្ភតាមរយៈព្រះរាជអំណោយ និងវិភាគទានពីសប្បុរសជនជាគ្រហស្ថ ។ *នាលន្ទា* នៅភាគខាងកើត និង *វលភិ* នៅភាគខាងលិចនៃប្រទេសឥណ្ឌា គឺជាមជ្ឈមណ្ឌលដ៏ធំបំផុតក្នុងបណ្តាមជ្ឈមណ្ឌលទាំងនោះ ។

---

(១) វិជ្ជាសិក្សា ៖ គឺទ្រឹស្តី ឬការសិក្សាអំពីកំណើត, ធម្មជាតិ, វិធី និងព្រំដែននៃវិជ្ជា ។

សេចក្ដីរាយការណ៍ស្ដីពីសកលវិទ្យាល័យ *នាលន្ទា* របស់លោក ហៀន ត្សាង ( Hiuen Tsang ) ដែលនៅទីនោះ លោកជានិស្សិតសិក្សាអស់ពេលប្រាំឆ្នាំ បានបង្ហាញអោយឃើញថា *នាលន្ទា* គឺជាសកលវិទ្យាល័យដ៏ពេញលក្ខណៈមួយ ដោយមានផ្នែកសិក្សាវិជ្ជានានា, មានបែបបទអោយចូលរៀន និងបែបបទប្រឡង, មានប្រព័ន្ធចម្រុះគ្រប់គ្រងការសិក្សា និងមានមធ្យោបាយងាយស្រួលចាំបាច់នានា ដូចជា បណ្ណាល័យ និងសាលសបាសិក្សា ។ មានសាស្ត្រាចារ្យ ១.៥០០ នាក់ សម្រាប់បង្ហាត់បង្រៀនដល់និស្សិត ១០.០០០ នាក់[(១)] ( ទាំងអ្នកបួស ទាំងគ្រហស្ថ ទាំងជនជាតិឥណ្ឌា ទាំងជនជាតិបរទេស ) ដែលបានសិក្សាមុខវិជ្ជាមួយផ្សេងៗពីគ្នា រួមទាំងទស្សនវិជ្ជា, វេយ្យាករណ៍, តារាសាស្ត្រ និងវេជ្ជសាស្ត្រ ។ លោក *ហៀន ត្សាង* បានកត់សម្គាល់ថា : " ពេលរៀន និងពេលពិភាក្សា គេឃើញថា ថ្ងៃខ្លីពេក " ( Learning and discussing they find the day too short ) ។ នៅពេលនោះ ប្រសិទ្ធភាពនៃសកលវិទ្យាល័យ នាលន្ទា ត្រូវបានលេចត្រដែតឡើង ដោយសារគុណសម្បត្តិនៃសាស្ត្រាចារ្យ និងនិស្សិត ដែលបានបន្សល់ទុកនូវស្លាកស្នាមដ៏ថិតថេរមួយទៅលើប្រវត្តិពុទ្ធសាសនា តាមរយៈសំនេរ ( writings ) ដ៏ច្រើន និងសកម្មភាពបេសកកម្មរបស់លោក ។ បរិវេណដ៏ទូលំទូលាយ នៃសកល

---

(១) លោក A.L.Basham មានសេចក្ដីសង្ស័យចំពោះតួលេខពិតប្រាកដ ។ លោកនិយាយថា " សំណល់បាក់បែកនៃសកលវិទ្យាល័យនាលន្ទា, ទៅតាមការរាយការណ៍បង្អួសរបស់លោក ហៀន ត្សាង ... នាលន្ទា ពិបាកនឹងផ្ដល់ជម្រកដល់ភិក្ខុសង្ឃ ១០០០ អង្គ អោយមានផាសុកភាព តាមដូចអ្នកដំណើរចិនពិពណ៌នានោះណាស់ " ។ ក្នុងទីនេះ លោក Basham បានដាក់ជាពាក្យសួរទៅលើឯកភាពសម្ភារៈសំណង់ដែលប្រើ, ការប្រែប្រួលនៃស្ថាប័ន រួមទាំងសំណង់សាងឡើងវិញជាង ៦០០ ឆ្នាំ, ទំហំនៃការបំផ្លាញដោយពួកភាតត្បាត, និងលើការជីកកកាយបុរាណវត្ថុ ចប់រួចរាល់សព្វថ្ងៃនេះ ។

វិទ្យាល័យ ដែលត្រូវបានគេជីកកកាយរកឃើញ និងថែរក្សាទុកមក ក៏រឹតតែបញ្ជាក់អោយឃើញមហន្តភាព ( the grandeur ) របស់សកលវិទ្យាល័យនាលន្ទា ថែមទៀត ។

ចំពោះសកលវិទ្យាល័យ *វលភិ* វិញ យើងបានពតិមានពីលោក *អ៊ី ត្សីង* ( I-Tsing ) ដែលបាននិយាយថា, បើប្រៀបពីឋានៈវិញ សកលវិទ្យាល័យ *វលភិ* គឺស្មើនឹងសកលវិទ្យាល័យនាលន្ទា ។ វគ្គសិក្សាមានរយៈពេលពីពីរទៅបីឆ្នាំ ហើយនាមរបស់និស្សិតដ៏ឆ្នើមៗប្រឡងជាប់ ត្រូវបានគេឆ្លាក់នៅលើក្លោងទ្វារ ។ សកលវិទ្យាល័យ បានផ្តល់ការអប់រំក្នុងមុខវិជ្ជាផ្លូវលោកផងដែរ ។ រដ្ឋការនៃរដ្ឋ វលភិ បានស្វែងរកនិស្សិតប្រឡងជាប់ចេញពីសកលវិទ្យាល័យនេះ អោយបំពេញមុខនាទីសំខាន់ៗរបស់រដ្ឋ ។

ឯកសារកត់ត្រារបស់ទីបេត៍ បញ្ជាក់ភស្តុតាងចំពោះភាពល្បីល្បាញ និងកេរ្តិ៍ឈ្មោះរបស់សកលវិទ្យាល័យពុទ្ធសាសនាពីរទៀត មានឈ្មោះ *វិក្រមសីលា* និង *ឱទន្តបុរី* ។ សកលវិទ្យាល័យទាំងពីរនេះរួមគ្នាជាសហគមន៍ ក្រោមអធិបតីភាពលោក *ទីបង្ករស្រីជ្ញានៈ* ដែលគេបានស្គាល់លោកជាទូទៅថា *អតិសៈ* ។ លោកត្រូវបានគេអញ្ជើញនៅក្នុងអំឡុងសតវត្សទីដប់មួយ អោយទៅជួយកសាងពុទ្ធសាសនាឡើងវិញ នៅក្នុងប្រទេសទីបេត៍ ។ លោកជាអ្នកប្រាជ្ញរបស់សកលវិទ្យាល័យឱទន្តបុរី និងជានាយកនៃសកលវិទ្យាល័យវិក្រមសីលា ។ សកលវិទ្យាល័យទាំងពីរនេះ បានដំណើរការទៅអស់ពេលច្រើនសតវត្ស ។ ហើយនៅក្នុងសម័យកាលរបស់លោក អតិសៈ, សកលវិទ្យាល័យទាំងពីរ បានទទួលរាជូបត្ថម្ភពីព្រះរាជវង្សបាលៈ នៃរដ្ឋបេនហ្គាល ។ នៅក្នុងសកលវិទ្យាល័យវិក្រមសីលា, ការអនុញ្ញាតអោយចូលរៀនបានត្រូវឆ្លងកាត់ការបង្ហាញអោយឃើញនូវភាពប៉ិនប្រសប់ក្នុងទឡ្ហីកម្មឡូស៊ីកក្នុងការជជែកដេញដោលជាមួយបណ្ឌិតម្នាក់ ក្នុងបណ្តាទ្វារ-បណ្ឌិតទាំងប្រាំមួយរូប ( gate-scholars ) ។ នៅពេលបានបញ្ចប់ការសិក្សារបស់ខ្លួនហើយ, គេត្រូវបានទទួលរង្វាន់ងារថ្នាក់បណ្ឌិត ។ សកលវិទ្យាល័យឱទន្តបុរី ក៏ត្រូវបានគេនិយាយថា

បានគេយកជាគំរូ សម្រាប់អគារសិក្សាអប់រំរបស់វត្តអារាមជំនាន់ដើម នៅក្នុងប្រទេសទីបេត៍ ។ សកលវិទ្យាល័យ *ជគទ្ទលា,* ស្ថាបនាឡើងដោយព្រះរាជាក្នុងវង្សបាលៈ ព្រះនាមរាមបាលៈ នៅក្នុងអំឡុងចតុត្ថភាគទីមួយ (the first quarter) នៃសតវត្សទី ១២ ។ សកលវិទ្យាល័យនេះ បានប្រព្រឹត្តទៅអស់ពេលដ៏ខ្លី ត្រឹមតែមួយសតវត្សកន្លះប៉ុណ្ណោះ, ប៉ុន្តែបានធ្វើវិភាគទានដ៏សំខាន់ដល់ការសិក្សារៀនសូត្រពុទ្ធសាសនា ។

ទោះបីជាមិនបានស្គាល់ និងមិនបានគេសរសេរជាឯកសារអោយបានទូលំទូលាយក្តី ក៏គង់មានវត្តអារាមជាច្រើន នៅក្នុងឧបទ្វីបឥណ្ឌា ដែលត្រូវបានគេពិពណ៌នាយ៉ាងត្រឹមត្រូវ ទុកដូចជាសកលវិទ្យាល័យទាំងឡាយនោះ វាអាចមាន *តក្សិលៈ* ( Taxila ) និង *កាញ្ចិ* ( Kãñchi ) ដែលត្រូវបានគេប្រើជាមជ្ឈមណ្ឌលសិក្សា តាំងតែពីសម័យមុនពុទ្ធកាលម្ល៉េះ ។

*៣.២ ការអប់រំរបស់ពុទ្ធសាសនា នៅក្នុងប្រទេសកាន់ពុទ្ធសាសនាថេរវាទ :*

នៅក្នុងប្រទេសស្រីលង្កា ដែលព្រះពុទ្ធសាសនាថេរវាទ បានចំរុងចំរើនដោយមានប្រវត្តិជាប់មិនដាច់តាំងតែពីសតវត្សទីបី មុនគ្រីស្តសករាជ, ដោយគ្មានសត្រូវធំដុំ ចេញមកពីសាសនាឯទៀត ឬពីប្រព័ន្ធទស្សនវិជ្ជាឯទៀតផងទេ ។ ការអប់រំនៅតាមវត្តអារាម បានប្រមូលផ្តុំទៅលើការបន្តផ្សព្វផ្សាយព្រះធម៌ និងការពន្យល់ព្រះធម៌ ដោយសង្កត់ធ្ងន់លើការរក្សាពុទ្ធវចនៈ អោយបានត្រឹមត្រូវនៅក្នុងភាសាដែលព្រះអង្គបានប្រើសម្រាប់សំដែងធម៌ ។ ពុទ្ធសាសនបញ្ញត្តិ ដែលបេសក-ជនទាំងឡាយរបស់ព្រះបាទ អសោក បាននាំយកមកកាន់ប្រទេសស្រីលង្កានោះ គឺជាភាសាបាលិ - ប្រហែលជាការបកប្រែត្រឹមត្រូវ ពីគ្រាមភាសានៃរដ្ឋមគធៈ ជាតំបន់

ដែលព្រះពុទ្ធបានបំពេញបេសកកម្មយ៉ាងសកម្ម ។ មុនពេលដែលពុទ្ធសាសនបញ្ញត្តិត្រូវបានគេកត់ត្រាជាសំនេរអក្សរនោះ, គោលដៅដ៏សំខាន់នៃការអប់រំរបស់វត្តអារាម ត្រូវបានបន្តផ្សព្វផ្សាយដោយផ្ទាល់មាត់នូវសាសនបញ្ញត្តិទាំងឡាយ តាមរយៈការរៀនចាំមាត់ និងការសូត្យឡើងវិញតាមពេលទៀងទាត់ ។ នៅពេលដែលអត្ថបទសាសនបញ្ញត្តិ ត្រូវបានគេរក្សាទុកជាភាសាបាលិ, មិនទាន់មានការបកប្រែជាភាសាជាតិណាមួយនោះ, អដ្ឋកថា និងស្នាដៃពន្យល់បកស្រាយគម្ពីរបាលី ត្រូវបានគេសរសេរទៅជាភាសាសីហឡៈ គឺជាភាសាជាតិស្រីលង្កា ។ អក្សរសាស្ត្រ អត្ថាធិប្បាយដ៏ធំទូលាយនេះ ក៏ត្រូវបានគេបកប្រែនៅក្នុងសតវត្សទីប្រាំ នៃគ្រឹស្តសករាជទៅជាភាសាបាលិវិញ ។ ជាមួយនឹងចលនានេះ ភាសាបាលិបាន ដណ្តើមយកកន្លែងភាសាសីហឡៈ ជាភាសាអធិប្បាយអក្សរសាស្ត្រ ហើយក៏អាចជាយានសិក្សាអប់រំរបស់ពុទ្ធសាសនាផងដែរ ។

បន្តិចម្តងៗ និកាយមហាយានដោយមានភាសាសំស្ក្រឹតជាយានទេសនាផ្សព្វផ្សាយ កាន់តែដណ្តើមបានប្រជាប្រិយភាព នៅក្នុងប្រទេសស្រីលង្កា ។ ភាសាសំស្ក្រឹតបានបើកទ្វារអោយអក្សរសាស្ត្រផ្លូវលោករីកចំរើនយ៉ាងឆាប់ ចាប់តាំងពីអត្ថបទកំណាព្យ និងរឿងវិនាដកម្មប្រកបដោយពាក្យពេចន៍ខ្ពស់ៗ រហូតដល់អត្ថបទក្បួន ស្តីពីវេជ្ជសាស្ត្រ, តារាសាស្ត្រ, គណិតសាស្ត្រ, និងស្ថាបត្យកម្ម ។ ការអប់រំប្រព្រឹត្តទៅនៅក្នុងវត្តអារាម ។ វត្តអារាមខ្លះ ដូចជាមហាវិហារ នៅអនុរាធបុរៈ និងអាឡាហាណៈបិរិវេណ នៅបុឡុន្នរុវៈ បានក្លាយទៅជាសាកលវិទ្យាល័យដ៏ពិតប្រាកដបានពង្រីកវង្វង់សកម្មភាពរបស់ខ្លួន ពីការហ្វឹកហ្វឺនជាប្រពៃណី ក្នុងវត្តអារាមសម្រាប់ភិក្ខុ និងភិក្ខុនី រហូតដល់បញ្ចូលអោយមានការសិក្សាយ៉ាងទូលំទូលាយអំពីភាសាសាស្ត្រ, អក្សរសាស្ត្រ និងវិជ្ជាផ្លូវលោកដទៃទៀត ។ ក្នុងបណ្តាមុខវិជ្ជាផ្លូវលោកទាំងមូល មានការសិក្សាដ៏សំខាន់បំផុតមួយ គឺការសិក្សាប្រវត្តិសាស្ត្រ ដែល

បាននាំអោយកើតមានអក្សរសាស្ត្រ ខាងកាលប្បវត្តិយ៉ាងសម្បូរ ។ ការអប់រំនៅក្នុងវត្តអារាមនោះៗ មិនមែនកំណត់អោយរៀន សម្រាប់តែការអប់រំភិក្ខុ និងភិក្ខុនីប៉ុណ្ណោះទេ ។ វត្តអារាមទាំងនោះ បានផ្តល់ការអប់រំសម្រាប់គ្រហស្ថដែរ ហើយចំនួនអ្នកប្រាជ្ញខាងពុទ្ធសាសនាដ៏ល្បីៗ របស់ប្រទេសស្រីលង្កា គឺច្រើនតែជាគ្រហស្ថ ( ឧទាហរណ៍ លោក គុរុឡុគោមិ, និងវិទ្យាចក្រវត្តិ និងព្រះរាជាកស្សបៈទីប្រាំ ប្រវាក្រមពាហុទីពីរ ) ។

នៅដំណាក់កាលខ្លះ មានការព្រួយបារម្ភ ស្តែងឡើងពីការចេះតែកើនឡើងនៃមុខវិជ្ជាផ្លូវលោក នៅក្នុងការអប់រំរបស់វត្តអារាម ។ មានព្រះរាជក្រឹត្យមួយក្នុងសតវត្សទីដប់ពីរ បានលុបចោលការសិក្សា ក៏ដូចជាការបង្រៀន " កំណាព្យ, រឿងវិនាដកម្ម និងមុខវិជ្ជាសៅហ្មងដទៃទៀត " ។ ទោះបីមានការព្រួយបារម្ភនេះក្តី ស្ថាប័នអប់រំនៅក្នុងវត្ត ដែលត្រូវបានគេស្គាល់ថាជា *បិរិវេណ* ហើយនោះ នៅតែបន្តផ្តល់ការអប់រំដ៏ពេញលេញ ដូចដែលបានគិតគូរនៅពេលនោះ ។ សេចក្តីរាយការណ៍សហសម័យជាច្រើនរបស់បិរិវេណ នាសតវត្សទីដប់ប្រាំ អះអាងអោយដឹងថា កម្មវិធីសិក្សា រួមមាន ភាសា និងអក្សរសាស្ត្រ សិហឡៈ បាលិ សំស្រ្កឹត ប្រាក្រឹត និងតមិល ។ ការសិក្សាខាងពុទ្ធសាសនា មានតាំងពីគម្ពីរជាភាសាបាលីដល់អត្ថបទមហាយាន, ទស្សនវិជ្ជាឥណ្ឌា, គណិតសាស្ត្រ, ស្ថាបត្យកម្ម, តារាសាស្ត្រ, វេជ្ជសាស្ត្រ និងហោរាសាស្ត្រ ។

នៅពេលដែលពុទ្ធសាសនាថេរវាទ បានផ្សព្វផ្សាយចូលដល់ប្រទេសម្យ៉ានម៉ា ( ភូមា ), ថៃឡង់, កម្ពុជា, និងលាវ គំរូអប់រំពុទ្ធសាសនា តាមបែបស្រីលង្កា ក៏បានតាមជាប់ជាមួយពុទ្ធសាសនាដែរ ។ ការរៀនភាសាបាលី ( ដោយយកចិត្តទុកដាក់ជាពិសេស លើវេយ្យាករណ៍ ) ដែលទុកដូចជាជំហ៊ានដំបូងដ៏ចាំបាច់ សម្រាប់សិក្សាគម្ពីរពុទ្ធសាសនា, បានក្លាយទៅជាបែបបទរៀនមួយដ៏ទូលំទូលាយ រហូតដល់

មានប្រវត្តិរបស់ពុទ្ធសាសនា ដែលគេសរសេរនៅក្នុងប្រទេសម្យ៉ានម៉ា ( ភូមា ) ក្នុងសតវត្សទី ១៣ និយាយថា វេយ្យាករណ៍ គឺជាចំណោះប្រជាប្រិយ សូម្បីនៅក្នុងចំណោមស្ត្រី និងយុវតីទាំងឡាយ ក៏ចេះវេយ្យាករណ៍ដែរ ។ កាលប្បវត្តិសហសម័យផ្សេងទៀត មាននិយាយពីព្រះរាជា ព្រះនាមក្យស្វះ ( Kyaswa ) ថា " បានអាននិងបានក្លាយជាគ្រូនៃគម្ពីរទាំងអស់ បានចាត់តាំងការជជែកដេញដោលជាសាធារណៈ និងបានចាត់តាំងបង្រៀនដល់ស្ត្រីមេផ្ទះរបស់ព្រះអង្គ ប្រាំពីរដង ក្នុងមួយថ្ងៃ " ។

ភាសាជាតិ បានទទួលការយកចិត្តទុកដាក់ស្មើគ្នា ទោះបីភាសាបាលី ដែលទុកជាភាសាសាសនារួម របស់ប្រទេសកាន់ពុទ្ធសាសនាថេរវាទទាំងអស់ ក៏ត្រូវបានគេប្រើសម្រាប់បង្កើតជាក្បួនច្បាប់ សម្រាប់ពួកអ្នកចេះដឹង ។ គេបាន ជំរុញសិល្បៈនៃការសរសេរ ហើយតួអក្សរទាំងឡាយ ក៏ត្រូវបានវិវត្តប្រសើរឡើងដោយព្រះរាជាទាំងឡាយបានចូលរួមផ្តើមគំនិត គឺដូចជានៅក្នុងប្រទេសថៃឡង់ ព្រះបាទរាមាកំហែង បានច្នៃបង្កើតតួអក្សរថៃ ( Thai script ) នៅក្នុងឆ្នាំ ១២៨៣ ។ វត្តអារាមទាំងឡាយ បានទាក់ទាញនិស្សិតពីទីជិត - ទីឆ្ងាយ ហើយបានចូលប្រឡូកក្នុងជួរអក្សរសាស្ត្រ និងការស្រាវជ្រាវដ៏ទូលំទូលាយ ។ វត្តអារាមទាំងនោះ បានតាំងនៅជិត ឬក្នុងទីក្រុងធំៗទាំងអស់ នៃភូមិភាគ ។ បែបបទប្រហាក់ប្រហែលគ្នា នៃការរៀនសូត្យពុទ្ធសាសនា ក៏បានឃើញលេចធ្លោ នៅក្នុងប្រទេសធ្លាប់កាន់ពុទ្ធ-សាសនា ពីមុន ដូចជា ម៉ាឡេស៊ី, ឥណ្ឌូនេស៊ី និងកោះម៉ាល់ឌីវ ។

ការធ្វើអោយមាន នវកម្ម ( ការប្រែប្រួលថ្មី ) ដ៏សំខាន់ក្រៃលែងមួយនៅក្នុងម្យ៉ាន់ម៉ា ( ភូមា ), ថៃឡង់, កម្ពុជា និងលាវ គឺការបួសមួយរយៈកាល ។ ការបួសមួយរយៈកាលនេះ បានលើកទឹកចិត្តអោយយុវជនចំណាយពេលយ៉ាងហោចណាស់ ក៏ចំនួនពីរបីខែ ជាបព្វជិតនៅក្នុងវត្តអារាមណាមួយ ។ ការប្រតិបត្តិ

បែបនេះ សព្វថ្ងៃ នៅតែបន្តឋិតនៅជាស្ថាប័នសង្គម . សាសនា ដ៏សំខាន់មួយ ដើម្បី ផានាថា យ៉ាងហោចណាស់ ក៏ប្រជាជនភេទប្រុស បានចំណាយពេលមួយរយៈកាល ណានោះ ដើម្បីសិក្សាពុទ្ធសាសនាតាមបែបរៀបរយដែរ ។

*៣.៣. ពុទ្ធិកសិក្សានៅក្នុងប្រទេសកាន់ពុទ្ធសាសនាមហាយាន :*

នៅពេលពុទ្ធសាសនាមហាយាន បានផ្សព្វផ្សាយតាមរយៈអាស៊ីភាគ កណ្តាល ទៅកាន់ប្រទេសចិន, ទីបេត៍, ម៉ុងហ្គោលី, កូរ៉េ និង ជប៉ុន, ពុទ្ធសាសនា មហាយាននេះ បានជួបប្រទះនឹងការប្រឆាំងពីជំនឿប្រជាប្រិយ៍, ក៏ដូចជាពីប្រព័ន្ធ សាសនា និងទស្សនវិជ្ជាទាំងឡាយ ដែលធ្លាប់មានរួចហើយ នៅក្នុងប្រទេស នោះៗ ។ ប្រតិកម្មជាមួយលទ្ធិកុងហ្វឺយស៊ុស និងលទ្ធិតាវ បាននាំអោយគេយកចិត្ត ទុកដាក់ ជាពិសេស ហ្វឹកហ្វឺនអ្នកជជែកពិភាក្សា ។ ដើម្បីទទួលបានការគាំទ្រពី ប្រជាជន គេបានខិតខំពង្រឹងតម្លៃចរិយាធម៌ និងសីលធម៌នេះម្យ៉ាង, និងម្យ៉ាងទៀត គេបានយកចិត្តទុកដាក់បំរើសាធារណប្រយោជន៍ រួមមានទាំងការអប់រំគ្រហស្ថផង ។ ឡូស៊ីកហ្វ័រម៉ែល ( Formal logic ) បានគ្របដណ្តប់មកលើកម្មវិធីសិក្សា ហើយ ការសិក្សាបានប្រព្រឹត្តទៅដោយគ្រូ ហើយនិងសិស្សចូលរួមក្នុងការជជែកដេញ ដោលគ្នា ដែលនៅក្នុងការជជែកនេះ គេអនុវត្តយ៉ាងម៉ត់ចត់នូវបែបបទតក្កវិជ្ជា ( logic ) ដើម្បីសំរេចអោយបានសេចក្តីសន្និដ្ឋានមួយគ្មានការតវ៉ាបាន ។ អក្សរ- សាស្ត្រដ៏ទូលំទូលាយ សម្រាប់ការពារពុទ្ធសាសនា ទល់នឹងការប្រឆាំងរបស់លទ្ធិ កុងហ្វឺយស៊ុស និងលទ្ធិតាវ ជាភស្តុតាងគ្រប់គ្រាន់ បញ្ជាក់ពីទិដ្ឋភាពនៃការអប់រំរបស់ ពុទ្ធសាសនា ។ ដើម្បីយល់បានពីជីវភាពរបស់បណ្ឌិតពុទ្ធសាសនា នៅក្នុងវត្តអារាម នីមួយៗ គេគប្បីពិនិត្យមើលរូបលើជញ្ជាំងវិហារទុងហ្វាង ( Tung Huang ) ។ នៅលើជញ្ជាំង ទាំងនោះ គេបានពិពណ៌នាពីភិក្ខុសង្ឃ ដែលកំពុងជាប់ដៃអានគម្ពីរ,

សរសេរ និងចម្លងគម្ពីរ ។

នៅពេលដែលសាលារៀនថ្មីៗ បានកើតមានឡើង ជាពិសេស សាលារៀនដែលខិតខំធ្វើពុទ្ធសាសនាអោយទៅជារបស់ចិន និងជប៉ុន ( ចិន-ឧបនីយកម្ម និងជប៉ុន-ឧបនីយកម្ម ) វិធីសាស្ត្របង្រៀនថ្មីៗ ប្លែកៗ ត្រូវបានគេយកមកប្រើ ។ ជាពិសេស នៅក្នុងសាលាសមាធិរបស់ចាន់ ( Ch'an ) ឬហ្សៀន ( Zen ) ការគ្រប់គ្រងចិត្ត និងកាយ ត្រូវបានបង្រៀន មិនគ្រាន់តែធ្វើតាមការប្រតិបត្តិខាងផ្លូវសមាធិស្ងប់ស្ងាត់ប៉ុណ្ណោះទេ, ប៉ុន្តែ ត្រូវធ្វើ ( ដូចនៅក្នុងសាលាលីនជី រិនហ្សៃ = Linchi Rinzai ជាពិសេស ) តាមរយៈការគោះសង្វាក់ដដែលៗ និងការពោលពាក្យបរមតិ ( verbal parpdoxes ) ។ នៅក្នុងប្រទេសជប៉ុន វិធីអប់រំរបស់សាសនាហ្សៀន ( Zen ) បានជះឥទ្ធិពលលើការហ្វឹកហ្វឺនពួកសាមូរ៉ៃ ( គឺរដ្ឋបុរសអ្នកចម្បាំង ) ។

ប្រព័ន្ធអប់រំរបស់វត្តបានបន្ថែមពីលើការអប់រំបែបគ្រហស្ថ ឧបត្ថម្ភដោយរដ្ឋ ក្នុងផ្លូវពីរយ៉ាងដ៏សំខាន់ ។ ទីមួយ, ប្រព័ន្ធអប់រំនេះ បានផ្តល់ការអប់រំដំបូងដល់ប្រជាជនភាគច្រើន គឺដល់កុមារ ហើយជាពិសេស សម្រាប់មនុស្សសាមញ្ញ និងប្រជាជនក្រីក្រ ដែលសាលារដ្ឋមិនអាចផ្តល់អោយបាន ។ សាលារៀនទាំងឡាយដែលភ្ជាប់ខ្លួនទៅនឹងវិហារ ( ឧទាហរណ៍ សាលារៀន តេរ៉ាកូយ៉ា នៅក្នុងប្រទេសជប៉ុន ) បានផ្តល់ដល់មនុស្សទាំងនោះ នូវចំណេះដឹងជាមូលដ្ឋាន ក្នុងការអាន, សរសេរ និងគណិតវិជ្ជា ។ ទីពីរ, ប្រព័ន្ធអប់រំរបស់វត្ត បានស្ថាបនាសាលារៀនជំនាញសម្រាប់អោយនិស្សិតសេរីទាំងឡាយ បានចូលសិក្សា និងបានចេះដឹងកិច្ចការជំនួញដូចនៅក្នុងសាលារៀន ស៊ូយួន (Shuyuan) ក្នុងប្រទេសចិន ។ ការខិតខំក្នុងការអប់រំបែបគ្រហស្ថនេះ បានជំរុញដល់ការចេះបោះពុម្ពអក្សរ ។ នៅក្នុងប្រទេសទាំងអស់នេះ អត្ថបទពុទ្ធសាសនា ត្រូវបានគេចេះបោះពុម្ពមុនគេ ។ នៅក្នុងប្រទេស

កូរ៉េ គម្ពីរមួយ ក្នុងបណ្តាគម្ពីរពីរ ដែលស្តេចសេជន ( Sejorn ) បានប្រើប្រាស់ដើម្បីបង្រៀនអក្សរដល់បរិវាររបស់ព្រះអង្គអោយចេះតួអក្សរថ្មី ដែលព្រះអង្គបានបង្កើតឡើងនោះ គឺ គម្ពីរស្តីពីព្រះជីវប្រវត្តិរបស់ព្រះពុទ្ធ ។

*៣.៤. ការស្រុតចុះ និងដំណើរដុះដាលឡើងវិញ :*

ជាមួយនឹងការរាតឥទ្ធិពលនៃសាសនាឥស្លាមនៅក្នុងទ្វីបអាស៊ី នាអំឡុងសតវត្សទី ១២ ដល់សតវត្សទី ១៥, ពុទ្ធិកសិក្សាជាមួយនឹងពុទ្ធសាសនាខ្លួនឯងផ្ទាល់បានស្រុតចុះនៅក្នុងឧបទ្វីបឥណ្ឌា ក៏ដូចជានៅក្នុងប្រទេសម៉ាឡេស៊ី, ឥណ្ឌូណេស៊ី និងកោះម៉ាល់ឌីវដែរ ។ នៅក្នុងទឹកដីទៃទៀត ពុទ្ធិកសិក្សាបានត្រដរស់នៅក្នុងកិរិតឋាមពល និងប្រសិទ្ធភាពផ្សេងៗពីគ្នា រហូតដល់ពេលកើតមានការអប់រំតាមបែបសម័យថ្មី, ទោះបីជាតាមរយៈនយោបាយអាណានិគម ឬនយោបាយជាតិ ។

នៅក្នុងប្រទេសខ្លះ នយោបាយអាណានិគម បានជំរុញអោយបេសកជនសាសនាគ្រីស្ត គ្រប់គ្រងសិក្សាធិការសាធារណៈ នេះម្យ៉ាង, ហើយម្យ៉ាងទៀត គេផ្តល់វិធានការទាក់ទាញចិត្តអោយពលរដ្ឋអាណានិគមខិតខំរៀនភាសារបស់រដ្ឋអំណាចអាណាព្យាបាល, ដោយប្រការនេះ ផ្តាច់ជើងស្ថាប័នអប់រំ របស់វត្តអារាមមិនអោយមានការចូលរួម និងការគាំទ្ររបស់ពួកគ្រហស្ថឡើយ ។ ដូចគ្នានេះដែរ, ក្រោមអានុភាពនៃការធ្វើអោយទាន់សម័យ, ប្រព័ន្ធសិក្សាខាងសាលារៀនផ្លូវលោកបានរីកដុះដាលយ៉ាងខ្លាំងនៅក្នុងប្រទេសចិន, ជប៉ុន, កូរ៉េ, និងថៃឡង់ ។ ប៉ុន្តែ ផ្ទុយទៅនឹងមតិធម្មតានេះ, នៅក្នុងប្រទេស ដូចបានរៀបរាប់ខាងលើស្ទើរតែទាំងអស់ គឺវត្តអារាមពុទ្ធសាសនាទេ ដែលបានជួយអោយប្រព័ន្ធអប់រំសម័យថ្មី បានរីកដុះដាលនោះ ។ សាលារៀនសម័យថ្មី បានកើតឡើងព្រោងព្រាត សូម្បីនៅក្នុងតំបន់ជនបទដាច់ស្រយាល ក៏ដោយសារភិក្ខុសង្ឃពុទ្ធសាសនា បានបង្កលក្ខណៈសម្បត្តិអោយ

មានមូលដ្ឋានជាដំបូងរួចទៅហើយ ។ សាលារៀនជប៉ុន តេរ៉ាកូយ៉ា បានកែទម្រង់ខ្លួនឯង ក្នុងយុគសម័យម៉ីហ្ស៊ី ក្នុងឆ្នាំ ១៨៧៣ ទៅជាមូលដ្ឋានមួយ សម្រាប់ធ្វើអោយបឋមសិក្សាបានកើតមានជាទូទៅ ហើយលក្ខណៈសិក្សាតាមបែបពុទ្ធសាសនាបានរលុបបាត់ទៅ ទើបតែនៅពេលដែលផែនការអប់រំឆ្នាំ ១៨៨៦ ត្រូវបានអនុវត្តប៉ុណ្ណោះ ។ នៅក្នុងប្រទេស មយ៉ាន់ម៉ា ( ភូមា ) នយោបាយអាណានិគមអង់គ្លេសដើម្បីពង្រីកបឋមសិក្សាតាមបែបផ្លូវលោក ត្រូវបានគេធ្វើអោយសម្រេចឡើងនៅក្នុងអំឡុងឆ្នាំ ១៨៦៨-៧០ តាមរយៈការផ្ដល់អោយសៀវភៅសម័យថ្មី នៃមុខវិជ្ជានីមួយៗ និងចាត់តាំងគ្រូល្អៗ អោយចុះទៅបង្រៀននៅក្នុងសាលារៀនវត្ត ដែលមានស្រាប់ចំនួន ៣.៩០០ សាលា ។ នៅក្នុងប្រទេសថៃឡង់ ៧១,៣% នៃសាលារៀនទាំងអស់ និង ៨៥,៦% នៃសាលារៀនបឋមសិក្សាក្នុងឆ្នាំ ១៩៣១ បានតាំងនៅនិងប្រព្រឹត្តទៅក្នុងវត្ត, ហើយប្រមាណជាមួយភាគបី នៃសាលារៀនក្នុងព្រះរាជាណាចក្រថៃ កំពុងឋិតនៅក្នុងដីវត្តនៅឡើយ ។ ស្ថានភាពបែបនេះ មានដូចគ្នានៅក្នុងប្រទេសស្រីលង្កាដែរ, ទោះបីសាលារៀនវត្តតាមប្រពៃណីនេះ ត្រូវបានទទួលបញ្ជាអោយបិទក្នុងឆ្នាំ ១៨៦៥ ក៏ដោយ ។

ប៉ុន្តែ ប្រព័ន្ធសិក្សាទាំងពីរបែបនេះ ( ប្រព័ន្ធសិក្សាសម័យថ្មី និងប្រព័ន្ធសិក្សាសាលាវត្ត ) មិនរលាយចូលគ្នាទេ សូម្បីប្រព័ន្ធទាំងពីរនេះ ឋិតនៅជាមួយគ្នាក្នុងអគារតែមួយក៏ដោយ ។ ហេតុនេះ បើត្រឡប់ទៅពិនិត្យមើលតួនាទីវត្តអារាមអោយបានម៉ត់ចត់, នោះការអប់រំរបស់ពុទ្ធសាសនា នៅក្នុងបែបបទរៀបរយរបស់ខ្លួន គឺពិបាកនឹងឋិតថេរនៅបានណាស់ ។ ប៉ុន្តែ បើពិនិត្យមើលមុខងារមិនរៀបរយ, មុខងារសង្គម, មុខងារអប់រំរបស់វត្តអារាមពុទ្ធសាសនាវិញ, នោះមុខងារទាំងនេះមិនមានអ្វីប៉ះពាល់ទេ ។

នៅកន្លែងណា ដែលព្រះពុទ្ធសាសនាឋិតនៅជាសាសនាប្រជាប្រិយ៍,

យុទ្ធសាស្ត្រមួយផ្នែក សម្រាប់ធ្វើអោយគំនិតជាតិនិយមរស់ឡើងវិញ ឬសម្រាប់ប្រយុទ្ធទាមទារឯករាជ្យនោះ គឺការលើកស្ទួយដំណើរល្អតលាស់ឡើងវិញ នៃការអប់រំខាងផ្នែកពុទ្ធសាសនា ។ ការធ្វើអោយរស់ឡើងវិញ និងការធ្វើអោយទំនើប ( នូវបនិយកម្ម ) គឺជាចរិតលក្ខណៈនៃការខិតខំទាំងនេះ ដែលមានពីរយ៉ាងគឺ :

ក/ សម្រួលការអប់រំសាលាវត្ត តាមរយៈការកែទម្រង់កម្មវិធីសិក្សា ដើម្បីបញ្ចូលមិនត្រឹមតែចំណេះវិជ្ជាជឿនលឿនទូទៅប៉ុណ្ណោះទេ, ប៉ុន្តែបញ្ចូលទាំងការសិក្សាទូលំទូលាយខាងពុទ្ធសាសនា ដែលការស្រាវជ្រាវរបស់ពិភព-លោក បានធ្វើអោយប្រសើរឡើង ។

ខ/ ធ្វើអោយប្រព័ន្ធសិក្សារបស់សាលាពុទ្ធសាសនា បានរីកចំរើនសម្រាប់កុមារា - កុមារី ដែលផ្អែកលើគំរូរបស់សាលារៀននៃពួកបេសកជនគ្រីស្ត, ប៉ុន្តែយកចិត្តទុកដាក់យ៉ាងសមស្របដល់ការរៀនសូត្រ និងការប្រតិបត្តិពុទ្ធសាសនា ។ មានស្ថាប័នអប់រំរបស់ពុទ្ធសាសនាបែបថ្មីជាច្រើន បានកើតមានឡើងនៅក្នុងអំឡុងមួយរយឆ្នាំចុងក្រោយនេះ ។

ប្រទេសស្រីលង្កា បានឃើញនូវការរស់ឡើងវិញ នៃ *បិរិវេណ* ( គឺជាស្ថាប័នអប់រំនៅក្នុងវត្តអារាម ) ដែលផ្តល់ការអប់រំដល់ភិក្ខុសង្ឃ និងនិស្សិតជាគ្រហស្ថ ។ *វិទ្យោទ័យ* និង *វិទ្យាលង្ការ បិរិវេណ* ត្រូវបានកសាងឡើងក្នុងឆ្នាំ ១៨៧៣ និងនៅឆ្នាំ ១៨៧៥ ដោយព្រះហិក្កដុវេស្រីសុភមង្គលៈ នាយកៈមហាថេរ និងព្រះរត្មលនេ ស្រីធម្មារាមៈ នាយកៈមហាថេរ តាមលំដាប់លំដោយ ។ ប្រព័ន្ធសិក្សារបស់ បិរិវេណ ដែលបានធ្វើអោយរស់ឡើងវិញ ដោយប្រការដូច្នេះ បានផ្តល់ជាលទ្ធផលនាំអោយកើតមានស្ថាប័នសិក្សា ជិត ២០០ កន្លែង សម្រាប់ផ្តល់ការសិក្សាដល់និស្សិតជាង ១០.០០០ នាក់ ។ *ពុទ្ធស្រាវកៈធម៌បិឋយៈ* ជាសាកលវិទ្យាល័យមួយសម្រាប់ភិក្ខុសង្ឃ ត្រូវបានស្ថាបនាឡើងក្នុង ឆ្នាំ ១៩៦៦, ហើយសាកល-

វិទ្យាល័យពុទ្ធសាសនា និងបាលីមួយ ប្រព្រឹត្តទៅតាមរយៈ *បរិវេណ* ជាប្រពៃណី ក្នុងឋានៈជាមហាវិទ្យាល័យបតិដ្ឋាភាគ ( constituent college ) ពោលគឺជាមហាវិទ្យាល័យឧបសម្ពន្ធ ក៏បានចាប់បដិសន្ធិក្នុងឆ្នាំ ១៩៨១ ដែរ ។ ប្រទេស ម្យ៉ាន់ម៉ា ( ភូមា ) និងថៃឡង់ បានបង្កើនច្រើនឡើងនូវចំនួនសាលាបាលី ។

នៅក្នុងប្រទេសថៃ, ការដុះដាលប្រព័ន្ធសិក្សាអប់រំវត្តអារាម ជាប្រពៃណី បានចាប់ផ្ដើមក្រោមរជ្ជកាលព្រះបាទមង្គុត ( រាមា IV ) ។ បុត្ររបស់ព្រះអង្គ គឺព្រះអង្គម្ចាស់វជិរញ្ញាណវរោរស បានស្ថាបនាក្នុងឆ្នាំ ១៨៩៣ នូវមហាកុដិរាជ-វិទ្យាល័យ ។ ក្នុងឆ្នាំ ១៩៤៦ វិទ្យាល័យនេះ ត្រូវបានដំឡើងថ្នាក់ជាសាកលវិទ្យាល័យមួយ ។ សាកលវិទ្យាល័យនេះ និងមហាចូឡាឡុងកនរាជវិទ្យាល័យ ចាប់ពីឆ្នាំ ១៩៤៧ មក គឺជាសាកលវិទ្យាល័យមួយ ដែលជាអគារសិក្សាក្នុងវត្តដំបូងគេនៅក្នុងប្រទេស ។

ប្រទេសជប៉ុន ចិន និង កូរ៉េ ក៏បានកសាងពុទ្ធិកវិទ្យាល័យរបស់ខ្លួនដែរ ។ នៅក្នុងប្រទេសជប៉ុន ពុទ្ធសាសនិកជនបានប្រតិបត្តិតាមការដឹកនាំលោក អេនរ្យោ អ៊ីនូយ៉េ ( Enryo Inouye ) ។ ក្រោពីបានសរសេរសៀវភៅ ដ៏មានឥទ្ធិពលខ្លាំង មានចំណងជើងថា បុកក្យូកាត់ស៊ូ-រោន ( Bukkyo Katsu-ron ) នៅក្នុងឆ្នាំ ១៨៩០ មក, លោកបានស្ថាបនាវិទ្យាល័យពុទ្ធិកទស្សនវិជ្ជាផ្ទាល់ខ្លួនរបស់លោកមួយ ។ វិទ្យាល័យត្រូវបានប្រើជាគំរូ ក្នុងការចាត់តាំងឡើងវិញ នូវសាលាពុទ្ធិកសិក្សា និងពុទ្ធិកវិទ្យាល័យនានា ។ ក្នុងបណ្ដាស្ថាប័នសិក្សាទាំងនេះ មានមួយចំនួនបានដំឡើងថ្នាក់ទៅជាមហាវិទ្យាល័យ និងបានផ្ដល់អោយភិក្ខុសង្ឃនូវភាពងាយស្រួលសម្រាប់សិក្សាថ្នាក់ខ្ពស់ ក្នុងមុខវិជ្ជាដ៏ទូលំទូលាយ ។ គោលបំណងធំរបស់មហាវិទ្យាល័យទាំងនោះ គឺហ្វឹកហ្វឺនសង្ឃពុទ្ធសាសនិក សម្រាប់បំពេញមុខងារជាបេសកជន ជាបណ្ឌិត និងជាអ្នកបំរើសង្គម និងដើម្បីជួយសម្រួលអ្នកប្រាជ្ញអោយ

បន្តកិច្ចការ ស្រាវជ្រាវទស្សនវិជ្ជាអក្សរសាស្ត្រ និងអរិយធម៌របស់ពុទ្ធសាសនា ។

សាលារៀន និងវិទ្យាល័យទាំងឡាយ ដែលពុទ្ធសាសនិកជនបានកសាងឡើងសម្រាប់កុមារា - កុមារី ជាទូទៅ បានផ្តល់ការអប់រំវិជ្ជាផ្លូវលោក សមស្របតាមនយោបាយជាតិ របស់ប្រទេសនីមួយៗ ។ នៅដំណាក់កាលដំបូងរបស់ចលនាជាតិ សម្រាប់កំណត់អត្តសញ្ញាណវប្បធម៌ និងឯករាជ្យវប្បធម៌ ស្ថាប័នសិក្សាទាំងនោះ បានដើរតួមួយយ៉ាងសំខាន់ ។ ប៉ុន្តែ ស្ថាប័នសិក្សាទាំងនោះ ត្រូវបានស្របយកបន្តិចម្តងៗ នូវវត្ថុបំណង, អត្ថន័យ និងវិធីសាស្ត្រ ( ដោយមិនរាប់ការគ្រប់គ្រងផងទេ ) ចូលទៅក្នុងប្រព័ន្ធសិក្សា នៃសាលារៀនជាតិ ដែលកាន់តែកើនឡើង ហើយដែលភាគច្រើន បានប្រកាន់យកតាមមុខងារវប្បធម៌របស់សាលារៀនពុទ្ធសាសនា ។ ឥទ្ធិពលនៃអន្តរាគមន៍របស់ពុទ្ធសាសនា ទៅក្នុងការអប់រំផ្លូវលោក នៅក្នុងប្រទេសអាស៊ីមួយចំនួន, ត្រូវបានគេសង្កេតឃើញថា បានសង្កត់ធ្ងន់លើការផ្តល់សារសំខាន់ទៅលើភាសា, ប្រវត្តិសាស្ត្រ, និងអរិយធម៌ជាតិមួយចំណែក និងមួយចំណែកទៀតដែលប្រកបដោយអត្ថប្រយោជន៍សំខាន់ផង, គឺបានសង្កត់ធ្ងន់ទៅលើកសិកម្ម, សិប្បកម្មប្រពៃណី, និងការអប់រំវិជ្ជាជីវៈ ។ ដោយប្រការយ៉ាងនេះ, ឥទ្ធិពលនេះបានត្រួសត្រាយផ្លូវ សម្រាប់ឆ្លងកាត់ពីប្រព័ន្ធសាលារៀនតម្រង់ទិស ដើម្បីធ្វើមន្ត្រីស៊ីវិល ដ៏មានក្របខ័ណ្ឌតូចចង្អៀត ទៅកាន់ប្រព័ន្ធសាលារៀន ដែលឆ្លុះបញ្ចាំងសេចក្តីត្រូវការធំទូលាយរបស់ជាតិ ។ ការអប់រំតាមបែបសាសនា សម្រាប់ពុទ្ធសាសនិកជនជាគ្រហស្ថ ត្រូវបានធ្វើឡើង តាមរយៈសាលារៀនថ្ងៃអាទិត្យ ដែលនៅក្នុងប្រទេសស្រីលង្កា ក៏ដូចនៅក្នុងប្រទេសថៃ សុទ្ធតែបានទទួលការឧបត្ថម្ភ និងការគាំទ្រអំពីរដ្ឋ ។

នៅព្រះរាជាណាចក្រកម្ពុជា, មុនពេលអាណានិគមបារាំងចូលមករាតត្បាតដាក់នឹមត្រួតត្រាក្នុងឆ្នាំ ១៨៦៣, ការរៀន និងការបង្រៀន បានប្រព្រឹត្តទៅតែ

នៅក្នុងវត្តអារាមប៉ុណ្ណោះ ។ អស់កាលជាច្រើនសតវត្សហើយ វាជាទម្លាប់របស់ឪពុកម្ដាយ ដែលគេត្រូវបញ្ជូនបុត្ររបស់ខ្លួនអោយទៅនៅវត្ត ដើម្បីរៀនសូត្រចំនួនបី-បួនឆ្នាំ ។ នៅទីនោះ ព្រះសង្ឃតែងបង្រៀនគេអោយចេះអក្សរ អោយចេះសរសេរ អោយអានសាស្ត្រា ចាប់តាំងពីសាស្ត្រាល្បែង ល្បើក រហូតដល់សាស្ត្រាទេសន៍ ដែលសរសេរ-ចារនៅលើស្លឹករឹត ។ នៅពេលដែលភិក្ខុសង្ឃកសាងព្រះវិហារ ឬសាលាឆាន់ ឬកុដិ លោកតែងកសាងដោយកំឡាំងរបស់លោកផ្ទាល់ ។ ឆ្លៀតពេលនោះ លោកតែងតែបង្រៀនជំនាញខ្លះៗ ដល់យុវជនទាំងនោះ ដូចជាជំនាញឈើ, ចម្លាក់, សំណង់, គំនូរ ជាដើម ។

សាលារៀនវត្ត គឺជាប្រពៃណីដ៏យូរលង់ហើយ នៅប្រទេសកម្ពុជា ។ តាមឯកសាររបស់លោក ជូ តាក្វាន ( Chu Takvan ) អ្នកការទូតចិន និយាយពីកម្ពុជា ថាសាលារៀនវត្តកើតមានតាំងពីដើមសតវត្សទី ១៣ ម្ល៉េះ ។ ព្រះសង្ឃពុទ្ធសាសនិកខ្មែរ មានទម្លាប់បង្រៀនចំណេះដឹងដល់កុមារទាំងឡាយបន្ថែមទៅលើការគោរពប្រតិបត្តិកាតព្វកិច្ចសាសនារបស់លោកផ្ទាល់ ។

ប៉ុន្តែដោយហេតុមានវិបត្តិ និងសង្គ្រាមស៊ីវិលឥតលោះខាន ដែលបែងចែកប្រទេសកម្ពុជា ជាបក្ស ជាពួក ទើបរាជធានីអង្គរ ត្រូវបានសត្រូវវាយលុក ហើយត្រូវបានបោះបង់ចោលក្នុងឆ្នាំ ១៤៣២ នៃគ្រិស្តសករាជ ។ វិបត្តិ និងសង្គ្រាមស៊ីវិលដ៏ញឹកញយនោះ បានបណ្ដាលអោយប្រទេសកម្ពុជាធ្លាក់ចុះដុនដាប ដែលជាហេតុនាំមកនូវទុក្ខវេទនាដល់ប្រជាជន និងភាពអភ័ព្វដល់វត្តអារាម ។ ចំណេះដឹងរបស់ភិក្ខុសង្ឃពុទ្ធសាសនិក ត្រូវបានធ្លាក់ចុះទ្រុឌទ្រោមដល់កំរិតទាបបំផុត រហូតដល់ភិក្ខុសង្ឃទាំងនោះ ដែលជាអ្នកបង្រៀន គ្មានបានចេះដឹងអ្វីក្រៅតែពីសីល ឬវិន័យសាសនា ដែលបន្សល់ទុកជាកេរមកពីប្រទេសឥណ្ឌាប៉ុណ្ណោះទេ ។ ដោយហេតុនេះភាពល្ងង់ខ្លៅរបស់ប្រជាពលរដ្ឋយើង គេអាចកាត់ស្មានយល់បានថា មានទំហំប៉ុណ្ណា

ហើយ !

បើទោះជាមានបាតុភូតដូច្នេះក្តី ក៏ភាគច្រើននៃយុវកុលបុត្រខ្មែរ នៅតែបន្តការរៀនសូត្រនៅសាលាវត្ត ដែលជាប្រភេទសាលារៀនសមស្របជាមួយទឹកចិត្ត (The mentality) របស់ប្រទេស ជាងសាលារៀនរបស់រដ្ឋ ពីព្រោះអី ប្រជាពល-រដ្ឋខ្មែរនៅតែមានស្វាមីភ័ក្តិចំពោះសាសនារបស់ខ្លួនជានិច្ច ។ ប្រជាពលរដ្ឋយើង បានប្រកាន់ខ្ជាប់នូវទស្សនៈមួយថា « គោលបំណងធំនៃការសិក្សា គឺដើម្បីក្តាប់ជាប់ និងប្រតិបត្តិត្រឹមត្រូវតាមព្រះធម៌របស់ព្រះពុទ្ធ, ដោយហេតុនេះ គឺចំណុចនេះហើយដែលគេសន្សំបាននូវ " កុសល " ដែលនឹងទទួលបានផលនៃកុសលនោះក្នុងជាតិក្រោយ » ។ នៅក្នុងសាលារៀនវត្ត សិក្ខាបទសាសនាត្រូវបានគេបង្រៀន ប៉ុន្តែមិនត្រូវបានបង្រៀននៅក្នុងសាលារៀនរដ្ឋទេ ហើយយុវជនខ្មែរ ក៏ពុំជាប់ចិត្តរៀននៅក្នុងសាលារៀនរបស់រដ្ឋដែរ ។

អាណានិគមបារាំង បានប្រឈមមុខដោះស្រាយបញ្ហាអប់រំ ដ៏ស្មុគស្មាញមួយនៅកម្ពុជា គឺបញ្ហាផ្តល់នូវប្រព័ន្ធអប់រំមួយសមស្របដល់ប្រទេសមួយ ដែលធ្លាប់តែមានអារ្យធម៌មួយចាស់ទុំ និងរុងរឿង ប៉ុន្តែ ត្រូវបានធ្លាក់ចុះខ្សោយអស់កាលដ៏យូរ ។ ប្រព័ន្ធសិក្សាអប់រំនោះ ត្រូវតែមានលក្ខណៈសម្បត្តិ អាចធ្វើអោយប្រទេសនេះ រីកចំរើនបានឆាប់ តាមលំអានប្រពៃណីរបស់ខ្លួនផង, ប៉ុន្តែជាមួយគ្នានេះ អាចធ្វើអោយប្រព័ន្ធអប់រំនេះ បានសមស្របទៅនឹងសំណូមពរទាមទារនៃជីវភាពប្រចាំថ្ងៃបច្ចុប្បន្នរបស់ប្រជាជននៃប្រទេសនេះផង ។

ដោយហេតុនេះ ក្រសួងអប់រំ បានពិចារណារិះរកលទ្ធភាពប្រែក្លាយ សា-លារៀនវត្ត អោយទៅជាសាលារៀនរដ្ឋវិញ ។ ដំណោះស្រាយដ៏ប្រសើរជាបណ្តោះអាសន្ន ចំពោះបញ្ហាអប់រំនេះ គឺការធ្វើនវូបនីយកម្មសាលារៀនវត្ត ( Ecole de pagode rénovée ) ដោយរដ្ឋអំណាចអាណានិគម បន្តប្រើលោកសង្ឃធ្វើ

ជាគ្រូបណ្ដើរ១សិន ទន្ទឹមនឹងការអប់រំគ្រូជាសង្ឃបណ្ដើរ១ ហើយបន្តប្រើប្រាស់សាលារៀនរបស់វត្ត ( ដែលជាកុដិ ឬជាសាលាឆាន់ ... ) បណ្ដោះអាសន្ន ទំរាំមានសាលារៀនមានបន្ទប់រៀនត្រឹមត្រូវតាមក្បួនខ្នាតគរុកោសល្យ ។ លើសនេះទៅទៀត, ប្រភេទសាលារៀនកែសម្រួលថ្មីនេះ អាចដោះស្រាយបញ្ហាចិត្តសាស្ត្ររបស់ប្រទេស និងប្រជារាស្ត្រ ដែលចូលចិត្តសាលារៀនវត្តជាជាងសាលារៀនរដ្ឋបានយ៉ាងមានប្រសិទ្ធភាព ។

ចំពោះពុទ្ធិកសិក្សា ដ៏ជាការសិក្សាចាំបាច់បំផុត សម្រាប់ព្រះសង្ឃ នៅសម័យមុនរាជធានីឧត្តុង្គ, យើងពុំមានឯកសារសេសសល់បញ្ជាក់បានអំពីដំណើរប្រព្រឹត្តទៅនៃការសិក្សានោះទេ ។ យើងដឹងពីការចាត់តាំងអោយមានពុទ្ធិកសិក្សាតែត្រឹមរាជ្យព្រះបាទអង្គឌួងប៉ុណ្ណោះ ។ ព្រះអង្គជាកវីជាតិមួយអង្គ និងជាពុទ្ធសាសនូបត្ថម្ភក៏ដ៏មោះមុតបំផុត ដែលបានចាត់តាំងការរៀនសូធ្យព្រះត្រៃបិដក នៅក្នុងវត្តអារាមជាច្រើន ដែលទ្រង់បានកសាងឡើង នៅទីក្រុងឧត្តុង្គ ។ ព្រះអង្គឯងផ្ទាល់បានបង្រៀនភាសាបាលីដល់ព្រះសង្ឃ នៅពេលរដូវចូលវស្សា ។ ការបង្រៀន បានប្រព្រឹត្តទៅតាមការបកប្រែបាលីទៅជាខ្មែរដោយផ្ទាល់មាត់ រហូតមកដល់ដើមសតវត្សទី ២០ នៃ គ.ស ។ យូរ១ម្ដង ការប្រឡងបកប្រែភាសាបាលី ត្រូវបានគេរៀបចំ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាជាអម្ចាស់ យោងតាមសេចក្ដីស្នើសុំរបស់ព្រះសង្ឃនាយក ឬព្រះសង្ឃរាជ ។ ការប្រឡង រួមមានតែការល្បងបកប្រែផ្ទាល់មាត់ ពីបាលីទៅជាខ្មែរ ។

ក្រោមនឹមអាណានិគមបារាំង ( ដែលចាត់តាំងឡើងដោយសន្ធិសញ្ញា ថ្ងៃទី ១១ ខែសីហា ឆ្នាំ ១៨៦៣ ) និងស្របតាមទិសដែលចាត់តាំងអោយមានសាលារៀនបារាំង-ខ្មែរ ជាលើកដំបូងនោះ, ពុទ្ធិកសិក្សាក៏ត្រូវបានចាត់ទុកជាអង្គការមុខព្រួញជាផ្លូវការមួយដែរ ។ នៅក្នុងឆ្នាំ ១៩១៤ សាលាបាលីត្រូវបានគេបង្កើតឡើង

នៅក្រុងភ្នំពេញ ក្រោយមកសាលាបាលីនេះ ត្រូវបានគេអោយឈ្មោះថា " សាលាបាលីជាន់ខ្ពស់ " វិញ, ហើយបន្ទាប់មកទៀត នៅក្នុងឆ្នាំ ១៩៣៣ " សាលាបាលីរង " ក៏ត្រូវបានគេបង្កើតអោយមាននៅក្នុងបណ្ដាវត្តទូទាំងប្រទេសដែរ ។

ចាប់តាំងពីប្រទេសកម្ពុជា បានទទួលឯករាជ្យពេញលេញ ក្នុងឆ្នាំ ១៩៥៣ មក ពុទ្ធិកសិក្សាបានទទួលការកែទម្រង់យ៉ាងសំខាន់ យោងទៅតាមព្រះរាជតម្រិះរបស់ព្រះករុណាព្រះបាទនរោត្តមសីហនុវរ្ម័ន ។ ពុទ្ធិកសិក្សានោះ មានបីភូមិសិក្សា : បឋមសិក្សា, មធ្យមសិក្សា, និងឧត្ដមសិក្សា ។ នៅក្នុងក្របខ័ណ្ឌនេះ

- ពុទ្ធិកសាកលវិទ្យាល័យ ព្រះសីហនុរាជ ត្រូវបានគេបង្កើតឡើង ក្នុងឆ្នាំ ១៩៥៩ ។

- ក្រសួងអធិការកិច្ច និងត្រួតពិនិត្យសាលាពុទ្ធិកសិក្សា ក៏ត្រូវបានចាត់តាំងឡើង ;

- កម្មវិធីសិក្សា សម្រាប់សាលាបាលីជាន់ខ្ពស់ និងសាលាបាលីរង ត្រូវបានគេរៀបចំជាថ្មី ដើម្បីសម្រួលការចាប់យកចំណេះបានល្អប្រសើរ ហើយអស់ពេលខ្លី ។

- សាលាបាលីជាន់ខ្ពស់ ត្រូវបានគេប្ដូរឈ្មោះទៅជា ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ក្នុងឆ្នាំ ១៩៥៥ ហើយសាលាបាលីរង ទៅជាសាលាពុទ្ធិកបឋមសិក្សាវិញ នៅក្នុងឆ្នាំ ១៩៥៧ ។

សាលាពុទ្ធិកបឋមសិក្សា មានរយៈពេលសិក្សាចំនួនបីឆ្នាំ សម្រាប់សិស្សជាភិក្ខុសាមណេរ ឬគ្រហស្ថ ។ នៅដំណាច់ឆ្នាំទីបី, សិស្សត្រូវប្រឡងបញ្ចប់ការសិក្សា ។ ក្នុងករណីជោគជ័យ, សិស្សនោះទទួលបានវិញ្ញាបនប័ត្រមួយ ដែលមានឈ្មោះថា " វិញ្ញាបនប័ត្រពុទ្ធិកបឋមសិក្សា " ឬ ( វិញ្ញាបនប័ត្រសាលាបាលីរង ) ។ បានសញ្ញាប័ត្រនេះហើយ បើសិស្សនោះមានបំណងបន្តការសិក្សានៅថ្នាក់មធ្យម

សិក្សាទៀត គេត្រូវដាក់ពាក្យសុំប្រឡងប្រជែងចូលរៀននៅពុទ្ធិកវិទ្យាល័យ ដែលមានពីរកន្លែង គឺពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រឹត នៅភ្នំពេញ និងពុទ្ធិកវិទ្យាល័យ *អ៊ុង ធួង* នៅក្នុងវត្តពោធិ៍វាល ខេត្តបាត់ដំបង ។ ការប្រឡងប្រជែងយកកន្លែងចូលរៀននៅក្នុងវិទ្យាល័យទាំងពីរ មានលក្ខណៈតឹងតែងណាស់ ដោយសារចំនួនសិស្សអោយចូលរៀនមានកំណត់ ។

ការសិក្សានៅក្នុងសាលាមធ្យមសិក្សាទាំងពីរវៀបរាប់ខាងលើ មានរយៈពេលសិក្សាកំណត់បួនឆ្នាំ ។ នៅដំណាច់ឆ្នាំសិក្សាទីបួន សិស្សទាំងអស់ត្រូវបានទទួលការប្រឡងចេញ ដែលជាវិធីត្រួតមើល និងវាយតម្លៃលើចំណេះដឹងរបស់សិស្សចំពោះមុខវិជ្ជាសំខាន់ៗ ដែលបានសិក្សាហើយអស់រយៈពេលបួនឆ្នាំ ។ ក្នុងករណីជោគជ័យ សិស្សនឹងបានទទួលរង្វាន់ជាសញ្ញាប័ត្របញ្ជាក់ការសិក្សា ដែលមានឈ្មោះថា " សញ្ញាប័ត្រពុទ្ធិកមធ្យមសិក្សា " ។ សិស្សដែលបានប្រឡងជាប់ហើយ អាចដាក់ពាក្យសុំប្រឡងចូលរៀននៅក្នុងពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ នៅភ្នំពេញ តទៅទៀតបាន បើសិនជាសិស្សនោះមានបំណងបន្តការសិក្សានៅថ្នាក់ខ្ពស់តទៅទៀត ។

ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ មានកំណត់ពេលសិក្សាចំនួនដប់ឆ្នាំ ដែលបានចែកជាបីភូមិសិក្សា គឺ :

ក/ *បឋមភូមិ* មានរយៈពេលសិក្សាបីឆ្នាំ ដែលមានកិរិតចេះដឹងប្រហាក់ប្រហែលកិរិតសញ្ញាប័ត្រមធ្យមសិក្សា ភាគទី ២ ឬក៏ Bacc II ( Baccalauréat de 2ème partie ),

ខ/ *ទុតិយភូមិ* មានរយៈពេលសិក្សាបួនឆ្នាំ ដែលមានកិរិតចេះដឹងប្រហាក់ប្រហែលកិរិតបរិញ្ញាប័ត្រ ឬក៏ Licence Es Lettres ។

គ/ *តតិយភូមិ* មានរយៈពេលសិក្សា ស្រាវជ្រាវ ចងក្រងជានិក្ខេបបទ

ចំនួនបីឆ្នាំ ។ ក្នុងករណីដែលនិក្ខេបបទទទួលស្គាល់ថា មានលក្ខណៈត្រឹមត្រូវ ពីគណៈមេប្រយោគហើយ ចំណេះដឹងរបស់សិស្សជាម្ចាស់និក្ខេបបទនោះ ត្រូវបានប្រកាសថា មានកិរិតចេះដឹងថ្នាក់បណ្ឌិត គឺប្រហាក់ប្រហែលនឹង Ph.D ( Docter of Philosophy ) ឬ Docteur Es Lettres របស់ប្រព័ន្ធសិក្សានៃលោកខាងលិច ។ ប៉ុន្តែ គួរកត់សម្គាល់ថា កិរិតថ្នាក់បណ្ឌិតនៅពុទ្ធិកសាកលវិទ្យាល័យនេះ មិនធ្លាប់មាន និងមិនធ្លាប់ដែលបានបើកបង្រៀនទេ ពីមុនមក ។

នាឆ្នាំសិក្សា ១៩៦៩ - ១៩៧០ ជាឆ្នាំមុនសង្គ្រាមហែកហួរជាតិផ្ទុះឡើង ចំនួនសមណសិស្សរៀននៅសាលាពុទ្ធិកបឋមសិក្សាមាន ២៧.០០០ រូប, ចំនួនសមណសិស្ស ១.៣២៨ រូប រៀននៅពុទ្ធិកវិទ្យាល័យទាំងពីរ, និងមានសមណនិស្សិត ១៧៦ រូប រៀននៅពុទ្ធិកសាកលវិទ្យាល័យក្នុងថ្នាក់បឋមភូមិ និងទុតិយភូមិ ។ វាជាគ្រោះចង្រៃរបស់ប្រទេសជាតិ ការរីកដុះដាលទាំងប៉ុន្មាន ក្នុងវិស័យពុទ្ធិកសិក្សាមានមកពីមុនទាំងប៉ុន្មាន ត្រូវបានដួលរលំរលាយគ្មានសេសសល់ នៅក្នុងខែមេសា ឆ្នាំ ១៩៧៥ ។ មកដល់ខែកញ្ញា ១៩៧៩ ពុទ្ធសាសនានៅកម្ពុជា បានចាប់កំណើតមានជីវិតរស់ត្រដាបត្រដួសឡើងវិញ ហើយបន្តដំណើរការអភិវឌ្ឍន៍ទៅតាមបែបបទមួយថ្មីក្រោមរបបគ្រប់គ្រងនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ( ១៩៧៩ - ១៩៨៨ ), និងក្រោមរបបគ្រប់គ្រងជាបន្តនៃរដ្ឋកម្ពុជា ( ១៩៨៩ - ១៩៩៣ ) ។ ចំណែកឯពុទ្ធិក-សិក្សា ក៏ត្រូវចាប់កំណើតជាថ្មី ហើយប្រកាសបើកជាផ្លូវការក្នុងឆ្នាំ១៩៨៩ ដោយ *សម្តេច ជា ស៊ីម* កាលនោះជាប្រធានរដ្ឋសភា នៃរដ្ឋកម្ពុជា និងជាប្រធានក្រុមប្រឹក្សាទូទាំងប្រទេស រណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា ចាប់ពីពេលនោះមក ។ បច្ចុប្បន្ននេះ ពុទ្ធិកបឋមសិក្សា កំពុងតែដំណើរការសិក្សា នៅក្នុងវត្តអារាមសំខាន់ៗ ស្ទើរតែទាំងអស់នៅក្នុងខេត្ត - ក្រុងនានា ។ ការរៀបចំគ្រប់គ្រង និងឧបត្ថម្ភ សាលាពុទ្ធិកបឋមសិក្សា គឺជាបន្ទុករបស់ចៅអធិការវត្ត និងពុទ្ធបរិស័ទ

ចំណុះវត្ត រហូតដល់ផ្តល់ប្រាក់និច្ចភត្ត ( Remuneration ) សម្រាប់អាចារ្យបង្រៀនផង ។ ទើបតែនៅក្នុងឆ្នាំសិក្សា ១៩៩៤ - ១៩៩៥ នេះទេ ដែលក្រសួងធម្មការ បានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាលអោយធ្វើការប្រឡងជ្រើសរើសយកគ្រូក្របខ័ណ្ឌពុទ្ធិកសិក្សា ចំនួន សាបសិបប្រាំនាក់ ដើម្បីអោយទៅបង្រៀននៅសាលាពុទ្ធិកបឋមសិក្សាមួយចំនួននៅតាមខេត្ត ដោយរាជរដ្ឋាភិបាលផ្តល់ប្រាក់ខែឧបត្ថម្ភ ។ គ្រូបង្រៀនដែលសេសសល់ក្រៅពីនេះ គឺបំពេញការងារលើមូលដ្ឋានស្មគ្រចិត្ត និងទទួលប្រាក់កំរៃខ្លះ ពីវត្តប៉ុណ្ណោះ ។ ពុទ្ធិកបឋមសិក្សា គឺជាគ្រឹះនៃពុទ្ធិកមធ្យមសិក្សា ។ មុខវិជ្ជាដែលត្រូវបង្រៀននៅក្នុងភូមិសិក្សាដំបូងនេះ មានជាអាទិ៍ ភាសាបាលី, វិន័យ, ពុទ្ធប្បវត្តិ, ភាសាខ្មែរ, និងមុខវិជ្ជាខាងផ្លូវលោកឯទៀតដូចមាននៅក្នុងកម្មវិធីសិក្សា សាលាសាធារណៈ ថ្នាក់ប្រហាក់ប្រហែលគ្នាដែរ ។

រីឯពុទ្ធិកមធ្យមសិក្សាវិញ ទើបតែបានចាប់ផ្តើមបើកទ្វារសិក្សានៅក្នុងឆ្នាំ ១៩៩៣ នេះទេ ។ ទីតាំងគ្រឹះស្ថានសិក្សារបស់ខ្លួនពីមុន គឺ " ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត " នៅក្នុងក្រុងភ្នំពេញ ត្រូវបានក្រសួងការបរទេសកំពុងប្រើប្រាស់ ចាប់តាំងពីឆ្នាំ ១៩៧៩ មក ។ ទីតាំងបច្ចុប្បន្ននៃពុទ្ធិកវិទ្យាល័យ គឺមិតនៅក្នុងបរិវេណមួយរបស់សាកលវិទ្យាល័យព្រះសីហនុរាជពីមុន ដែលសព្វថ្ងៃនេះ ត្រូវបានបើកជាក្រសួងធម្មការផង ជាសាលាពុទ្ធិកវិទ្យាល័យផង និងជាសេវាកម្មផ្សេងទៀតផង ។ គួរកត់សម្គាល់ថា អគារទាំងអស់នៅក្នុងបរិវេណ " ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ" ក៏ទើបតែបានទទួលពីក្រសួងការបរទេស ប្រគល់អោយក្រសួងធម្មការ ប្រើប្រាស់ក្នុងខែសីហា ១៩៩៣ ដែរ ។ មកដល់ឆ្នាំសិក្សា ១៩៩៥-១៩៩៦ មានសមណសិស្ស ចំនួនបីរយរូបហើយ ។ នៅឆ្នាំសិក្សា ១៩៩៦-១៩៩៧ សមណសិស្សដំបូងគេប្រមាណមួយរយរូប នឹងត្រូវទទួលធ្វើការប្រឡងចេញ ។ ការប្រឡង គឺជាវិធីត្រួតពិនិត្យលើចំណេះដឹង លើវិជ្ជាសំខាន់ៗ ដែលបានកំណត់ក្នុងកម្មវិធីសិក្សា ដូចជា

ភាសាបាលី, សំស្ក្រឹត, ខ្មែរ, អង់គ្លេស, អត្ថាធិប្បាយលើគោលធម៌ណាមួយ និង វិទ្យាសាស្ត្រផ្លូវលោក ដូចជា គណិតសាស្ត្រ គីមី រូបវិទ្យា ជាដើម ។

គួរកត់សម្គាល់ថា ពុទ្ធិកសិក្សាទាំងបឋម ទាំងមធ្យម និងទាំងឧត្តមសិក្សា នៅក្នុងបរិបទនៃស្ថានភាពប្រទេសយើង ដែលត្រូវអន្តរាយរលំរលាយបាត់បង់អ្វីៗ ស្ទើរតែទាំងអស់ និងអស់កាលដ៏យូរជាងពីរទសវត្សផងនោះ, ការកសាងពុទ្ធិក-សិក្សាឡើងវិញ តាំងពីក្រោមដល់កំពូល គឺជាកាតព្វកិច្ចចម្បង ដែលទាក់ទងនឹងវិធីសាស្ត្របង្រៀន ការរៀបចំកម្មវិធីសិក្សា ដោយមានការកំណត់ច្បាស់លាស់ជាសត្យានុម័តិ នូវគោលដៅដែលសង្គមបច្ចុប្បន្ននេះត្រូវការផង ។ ការរៀបចំការសិក្សា ដោយគ្រាន់តែរំលឹកឡើងវិញ នូវទម្លាប់រៀនសូត្រពីមុន ហើយបន្តអនុវត្តដោយពុំបានគិតដល់កាលៈទេសៈ មុខវិជ្ជាសិក្សា បច្ចេកទេស វិទ្យាសាស្ត្រ សតិ-អារម្មណ៍សង្គម ដែលវិវត្តប្រែប្រួលទៅតាមក្រឹត្យក្រមពិភពលោកនោះ គឺជាការវិនិយោគទុនផ្សងព្រេងមួយ ។ សេចក្ដីរៀបរាប់ពីការអប់រំរបស់ពុទ្ធសាសនានៅកម្ពុជា ដោយសង្ខេបប៉ុណ្ណោះ គឺដើម្បីបញ្ជាក់នូវការវិវត្តិន៍នៃការអប់រំនេះ សម្រាប់ជាមូលដ្ឋាន រៀបចំការអប់រំរបស់ពុទ្ធសាសនាបន្តទៀត ដើម្បីការរីកចំរើន ។

*៤. លក្ខណៈច្បាស់លាស់ និងការកំណត់ដោយឡែកនៃកម្មវិធីសិក្សាសម្រាប់ការអប់រំរបស់ពុទ្ធសាសនានោះ :*

បើពិនិត្យមើលគំនិត បែបបទ វិធីសាស្ត្រ និងរបៀបដោះស្រាយជាក់ស្តែង នៅក្នុងពុទ្ធិកសិក្សា តាមដូចដែលគេបានដឹងក្នុងឯកសារប្រវត្តិសាស្ត្រ និងស្ថាប័នសិក្សា នៅក្នុងទ្វីបអាស៊ីសព្វថ្ងៃ គេអាចកំណត់បញ្ជាក់នូវលក្ខណៈច្បាស់លាស់ និងភាពដោយឡែកនៃកម្មវិធីសិក្សាមួយចំនួន ដូចតទៅ :

*៤.១. គោលដៅ និងវត្ថុបំណង :*

វត្ថុបំណងចុងក្រោយនៃពុទ្ធិកសិក្សា និងដំណើរប្រព្រឹត្តទៅ ដើម្បីអភិវឌ្ឍន៍ខាងបញ្ញាស្មារតី គឺការរំដោះបុគ្គលម្នាក់ៗ អោយផុតពីចំណងគ្រប់យ៉ាង ។ ការរំដោះ ត្រូវធ្វើអោយសម្រេចបានដោយបុគ្គលម្នាក់ៗ តាមល្បឿនផ្ទាល់របស់គេ និងតាមគំនិតផ្តើមផ្ទាល់ខ្លួន ។ គ្រូអាចារ្យ គឺជាអ្នកជួយសម្រួល ជួយណែនាំ ហើយជាងនេះទៀត គឺជាគំរូដ៏ជំនាញមួយ ដែលគេត្រូវយកតម្រាប់តាម ។ គឺឧទាហរណ៍ល្អជាងការប្រៀនប្រដៅ ដែលត្រូវបានគេចាត់ទុកថា ជាមធ្យោបាយទាក់ទងគ្នារវាងគ្រូ និងសិស្ស ។ គ្រូស្រង់កត់ទុកនូវភាពផ្សេងៗ គ្នា របស់បុគ្គលម្នាក់ៗ ក្នុងចំណោមសិស្សទាំងអស់ ហើយរៀបចំវគ្គហ្វឹកហ្វឺន សម្រាប់បុគ្គលម្នាក់ៗ ( ជាពិសេស មុខវិជ្ជារៀនសមាធិ ) អោយស្របទៅនឹងចរិតលក្ខណៈរបស់គេ ។ ការរៀនសូត្យគឺពុំមែនបញ្ចប់នៅត្រឹមហ្នឹងទេ, ប៉ុន្តែ គ្រាន់តែជាដំណើរមួយ នាំទៅកាន់ការធ្វើអោយបានសំរេចដោយខ្លួនឯង ដែលនៅក្នុងពុទ្ធសាសនា មានន័យស្មើនឹងការរំដោះខ្លួនដ៏ជាគោលដៅចុងក្រោយនៃជីវិតរបស់សាសនា ។ អ្វីដែលនាំបុគ្គលណាមួយ ទៅកាន់ការធ្វើអោយសម្រេចជោគជ័យដោយខ្លួនឯង គឺជាបទពិសោធន៍ផ្ទាល់ខ្លួនដ៏តឹងរ៉ឹងមួយចំនួន ដែលមិនអាចបង្កើតឡើងបានដោយថៃដន្យ សម្រាប់យកទៅអនុវត្តចំពោះបុគ្គលផ្សេងទៀតបានឡើយ ។ ពេលវេលាចំណាយសម្រាប់ដំណើរការពិសោធន៍ គឺប្រែប្រួល បីដូចជាបច្ចេកទេស ក៏ត្រូវប្រែប្រួលដូច្នេះដែរ ។

គោលការណ៍ដូចគ្នានេះ ដែលត្រូវបានគេយកទៅប្រើសម្រាប់ហ្វឹកហ្វឺនខាងផ្លូវស្មារតី ( ចិត្ត ) ក៏បានត្រូវគេយកទៅអនុវត្តចំពោះការពិសោធន៍រៀនសូត្យទាំងអស់ នៅក្នុងប្រព័ន្ធសិក្សាវត្តអារាមពុទ្ធសាសនា ។ នៅក្នុងលទ្ធិពុទ្ធសាសនាពុំមានសៀវភៅ ឬពុំមានគម្ពីរអក្សរសាស្ត្រមួយចំនួនណា សម្រាប់យកមកសិក្សា ឬសម្រាប់យកមករៀនអោយចេះចាំមាត់ ឬសម្រាប់ទុកជាសំអាងនោះឡើយ ។

ការចេះដឹងល្អមតែតម្កល់ខ្លួនបានតាមមាគ៌ាហ្វឹកហ្វឺនស្មារតី ( ចិត្ត ) ត្រូវបានចាត់ទុកថាជាវត្ថុបំណងទីមួយ ។ នេះគឺមានន័យថា ចំណេះដឹងផ្ទាល់ មិនមែនជាវត្ថុបំណងនៃការរៀនសូត្រទេ ។ ព្រះពុទ្ធធ្លាប់បានបន្ទោសជាញឹកញយ ចំពោះអ្នកទាំងឡាយដែលចង់តាំងខ្លួន " ជាម្ចាស់នៃគម្ពីរ ( សៀវភៅ ) " ។ ទទ្ទឹមនឹងការទទួលស្គាល់សារសំខាន់នៃសមិទ្ធផលសិក្សា និងផ្តល់រង្វាន់ដល់ការសិក្សាទាំងជាកិត្តិយស ទាំងជាអត្ថប្រយោជន៍ខាងសម្ភារៈ ប្រព័ន្ធសិក្សាវត្តតែងបានរក្សាទស្សនៈរបស់ខ្លួនថា ការសិក្សាត្រូវតែភ្ជាប់ជាមួយនឹងមនោសញ្ចេតនា ចរិយាធម៌ ហើយនិងគោលការណ៍សីលធម៌ ។ ការសិក្សានឹងមានតម្លៃ តែនៅចំណុចណាដែលការសិក្សានេះ បានធ្វើអោយបុគ្គលក្លាយជាបុគ្គលម្នាក់ប្រសើរ ទាំងខាងសីលធម៌ ទាំងខាងស្មារតី ( ចិត្ត ) ។

*៤.២. ការសិក្សាជុំវិញបុគ្គលខ្លួនឯង :* ( Individual centered learning )

នៅក្នុងប្រព័ន្ធសិក្សារបស់វត្ត, ដែលថ្នាក់រៀនមួយ ត្រូវបានបង្រៀនជាសមូហភាពដល់សិស្សច្រើនរូបដោយគ្រូម្នាក់, គឺទើបតែជាការរីកចំរើនថ្មីៗ នេះទេ ។ តាមធម្មតា, គ្រូម្នាក់ត្រូវជួបជាមួយសិស្សម្នាក់ៗ ជាបុគ្គលដើម្បីបញ្ជាក់ច្បាស់ថាតើកិច្ចការដែលបានប្រគល់អោយធ្វើ បានបំពេញដោយត្រឹមត្រូវហើយឬនៅ, ហើយដើម្បីដាក់កិច្ចការថ្មីអោយបំពេញបន្តទៀត ។ ការបង្រៀនក្នុងន័យនិយាយពន្យល់មេរៀនមួយដល់សិស្សមួយក្រុម ពុំសូវមានធ្វើទេ ហើយប្រើតែក្នុងករិតមួយយ៉ាងប្រយ័ត្នប្រយែងបំផុត សម្រាប់ពន្យល់បំភ្លឺបញ្ហាទាំងឡាយណា ដែលសិស្សទាំងឡាយបានយល់ច្រឡំ ឬមួយក្តាប់ខ្លឹមសារពុំបាន ។

សិស្សបានចំណាយពេលរបស់ខ្លួនស្ទើរតែទាំងអស់ ក្នុងការរៀនដោយ

ខ្លួនឯង ដោយប្រើប្រាស់អដ្ឋកថា, អដ្ឋកថារង, សទ្ទានុក្រម, តារាងអក្សររៀងឈ្មោះសៀវភៅ, វចនានុក្រម ។ អក្សរសាស្ត្រពុទ្ធសាសនា នៅក្នុងភាសានានាជាច្រើន ជាអក្សរសាស្ត្រពោរពេញទៅដោយអត្ថបទស្វ័យសិក្សា ។ វិធីសាស្ត្រសម្រាប់វាយតម្លៃលទ្ធផលនៃការសិក្សា មានពីរយ៉ាង ៖ សិក្សាត្រូវបានគេសួរដេញដោល ទីមួយអោយបង្ហាញសមត្ថភាពរបស់ខ្លួន ដោយទាញយកសេចក្តីសន្និដ្ឋានពីគម្ពីរ ឬសៀវភៅសិក្សាដោយខ្លួនឯង ហើយបង្ហាញអត្ថាធិប្បាយផ្ទាល់របស់ខ្លួន ឬការពន្យល់អំពីអត្ថបទណាមួយជាកំណត់ ; ទីពីរ អោយចូលរួមក្នុងការជជែកដេញដោលជាមួយគ្រូរបស់ខ្លួន ឬជាមួយមនុស្សមានអាយុ ឬឋានៈប្រហាក់ប្រហែលគ្នា ហើយត្រូវនិយាយការពារចំណុចទស្សនៈពិសេសណាមួយ ។ អត្ថបទនិពន្ធដើមរបស់សិស្សតាមធម្មតា ត្រូវបានគេដាក់ពិន្ទុសំគាល់ចំណុចខ្ពស់បំផុតនៃការសិក្សា ។

*៤.៣. ទិដ្ឋភាពណែនាំបង្កបង្កើតគំនិត ៖*

វិធីចោទសំណួរ និងណែនាំសិស្សអោយចេះរកចម្លើយ ឬសេចក្តីសន្និដ្ឋានដោយខ្លួនឯង ( The maieutic method of questioning ) បានផ្តល់វិភាគទានដល់ការវិវត្តន៍ នៃប្រព័ន្ធតក្កវិជ្ជា ( ឡូស៊ីក ) របស់ពុទ្ធសាសនាមួយដោយឡែកផង និងការផ្តល់វិភាគទានធ្វើអោយទំនើបនូវការរីកដុះដាលទ្រឹស្តីនៃវិជ្ជាសិក្សា ( the theory of epistemology ) របស់ឥណ្ឌាតាមរយៈប្រតិកម្មផង ។ នៅក្នុងអភិក្រមនេះ ពុទ្ធសាសនិកជនបានដើរតួនាំមុខគេក្នុងការកកាយរកយន្តការបង្កបង្កើតគំនិត ( the concept formation ) ។ ការសិក្សាស៊ីជម្រៅរបស់ពុទ្ធសាសនាក្នុងផ្នែកនេះ ត្រូវបានអធិប្បាយយ៉ាងល្អិតល្អន់ នៅក្នុង *អភិធម្ម-បិដក* ដ៏ជាសេចក្តីអធិប្បាយ និងជាក្បួនច្បាប់នាពេលក្រោយមក ហើយគម្ពីរភាពសិក្សារបស់ពុទ្ធសាសនា ដោយឡែកនេះ ( The Buddhist scholarship ) ក៏

បានងាកចេញពីទ្រឹស្តី អភិញ្ញាណ និងមនសិការសុទ្ធសាធ ( A pure theory of cognition and consciousness ) មករកទិដ្ឋភាពជាក់ស្តែង ដែលចំណេរកាលក្រោយមក ត្រូវបានចងក្រងទុកជាវិធីហ្វឹកហ្វឺន សម្រាប់ធ្វើសមាធិរបស់ពុទ្ធសាសនាហ្សេន ( Zen Buddhism ) ជាពិសេស ។

*៤.៤. ការកជនដែលចេះសម្របសម្រួល* : ( Committed Change Agents ) :

ការហ្វឹកហ្វឺនសង្ឃ អោយទៅជាក្រុមមួយនៃការកជន ដែលចេះធ្វើអោយថ្មីជានិច្ចដោយខ្លួនឯង គឺជាលក្ខណៈដ៏សំខាន់មួយ របស់ការអប់រំពុទ្ធសាសនា ។ ការកម្ពុំកើតបានជាសង្ឃ ទុកដូចជាអង្គការចាត់តាំងប្រជាធិបតេយ្យមិនប្រមូលផ្តុំអំណាចមួយនៃអ្នកមានវ័យប្រហាក់ប្រហែលគ្នា បានធ្វើអោយសង្ឃមានលទ្ធភាពវិវត្តទៅសមស្របនឹងចំណូលចិត្ត និងសេចក្តីត្រូវការរបស់មនុស្សនៅទីកន្លែង និងពេលវេលាខុសៗគ្នា ។ ហេតុផលដែលនាំអោយមានការសម្របសម្រួលនេះ ចេញមកពីឧត្តមគតិ ដែលផ្អែកលើអត្តប្រយោជន៍ផ្ទាល់ខ្លួនផង ( ផលប្រយោជន៍របស់អ្នកដទៃផង ) ជាដំណាលគ្នា ។ ភិក្ខុពុទ្ធសាសនិកពីដំបូងៗ បានលះបង់ជីវភាពជាគ្រហាវាស ដើម្បីឆ្ពោះទៅរកការជឿនលឿន ខាងបញ្ញាស្មារតីផ្ទាល់ខ្លួន និងការបានរំដោះផុតទុក្ខ ។ ប៉ុន្តែថា លោកកំពុងឋិតនៅក្នុងការធ្វើសកម្មភាព សំដៅធ្វើអោយអង្គការចាត់តាំងសង្ឃឋិតថេរយូរអង្វែង និងសំដៅសងជាសេវាកម្ម ( ជាការបំរើ ) ដល់អ្នកទាំងឡាយ ដែលបានគាំទ្រអង្គការចាត់តាំងសង្ឃនេះវិញ ។ ក្នុងឋានៈជាអង្គការចាត់តាំងមួយ ក្នុងបណ្តាអង្គការចាត់តាំងដ៏សកម្មបំផុត ប្រកបដោយសមត្ថភាពចាស់ទុំ ដើម្បីធ្វើអោយមានការដុះដាលជាថ្មី ដោយខ្លួនឯង, ព្រះសង្ឃធ្លាប់បានជាការកជន ចេះសម្របសម្រួលខ្លួនបានយ៉ាងមានប្រសិទ្ធភាព មិនគ្រាន់តែ

សម្របសម្រួលក្នុងការទេសនាប៉ុណ្ណោះទេ ប៉ុន្តែចេះសម្របខ្លួនទៅនឹងការប្រែប្រួលទេសនានេះ ទៀតផង ។

*៤.៥. ការទាក់ទងគ្រូ - សិស្ស :*

ទស្សនៈ ( Concept ) ស្ដីពីគ្រូរបស់ពុទ្ធសាសនា គឺជាទស្សនៈមួយទូលំទូលាយណាស់ ៖ បុគ្គលណាមួយបានបង្រៀនអ្វីមួយដល់បុគ្គលណាម្នាក់ សូម្បីតែអក្សរមួយតួ ក៏ចាត់ទុកជាគ្រូរបស់អ្នករៀននោះដែរ ។ ឪពុកម្ដាយត្រូវបានគេចាត់ទុកជាគ្រូមុនគេ ដែលលោកហៅថា " បុព្វាចារ្យ " ។ ការអប់រំរបស់ពុទ្ធសាសនា បានលើកស្ទួយអោយមានការរីកចំរើនខាងចំណងសញ្ចេតនា និងសីលធម៌ រវាងអ្នកបង្រៀន និងអ្នករៀន ។ នៅពេលមិនទាន់មានកាតព្វកិច្ចណាមួយ ត្រូវបានគេកំណត់ទៅលើសិស្ស ដើម្បីទទួលយល់ព្រមជាមួយគ្រូ ឬដើម្បីសម្គាល់ទុកលោកជាអ្នកតំណាងអាជ្ញាមួយនៅឡើយទេ, ប្រពៃណីរបស់ពុទ្ធសាសនា បានទាមទារអោយគ្រូមានឋានៈជាបុគ្គល ដែលត្រូវបានគេគោរព ។

ដោយពុំបានគិតដល់វិរិយ នៃភាគីដែលទាក់ទងផងទេ ទំនាក់ទំនងដែលបណ្ដាលអោយមានឡើង គឺជាទំនាក់ទំនងដែលទុកដូចជារវាងឪពុកម្ដាយ និងកូន ។ ក្នុងឋានៈនេះ គ្រូមិនត្រឹមតែត្រូវបានគេតម្រូវអោយការពារសិស្សអំពីអន្តរាយគ្រប់យ៉ាងប៉ុណ្ណោះទេ, ប៉ុន្តែ តម្រូវអោយចេះបង្ហាញសិស្សដល់មិត្តភ័ក្តិទាំងឡាយ និងជួយផ្សាយកិត្តិស័ព្ទរបស់សិស្សទៀតផង ។ ផលវិបាកដ៏សំខាន់ចេញមកពីមតិនេះ គឺថា គ្រូមិនត្រូវតាំងខ្លួនជាសត្រូវរបស់សិស្សឡើយ ។ ជាជំនួសវិញ, សមិទ្ធផល និងជោគជ័យរបស់សិស្ស ជួយបន្ថែមអោយកេរ្តិ៍ឈ្មោះរបស់គ្រូកាន់តែលេចឮរន្ទឺឡើង ។ ប៉ុន្តែ វាជាទម្រង់រូបភាពដ៏អាក្រក់មួយចំពោះសិស្សណា ដែលបានតាំងខ្លួនជាអ្នកប្រណាំងប្រជែងជាមួយគ្រូរបស់ឯង ។ ទំនាក់ទំនងរវាងបុគ្គល និងបុគ្គល

សម្រាប់លើកស្ទួយមេត្រីភាពរវាងគ្រូ និងសិស្ស ដូចពោលខាងលើនេះ បានបង្ក បង្កើតអោយមានបរិយាកាសដ៏ល្អប្រសើរសម្រាប់ការសិក្សា និងការស្រាវជ្រាវ ចំណេះដឹង ។ លក្ខណះដ៏លេចធ្លោមួយនៃការងារអប់រំរបស់ពុទ្ធសាសនានោះ គឺការ សិក្សាត្រូវបានធ្វើឡើងដោយគ្មានការតឹងតែង ឬបង្ខិតបង្ខំ ។

*៤.៦. មធ្យោបាយនៃពាក្យនិយាយ :* ( Medium of spoken word )

ពាក្យនិយាយ គឺជាមធ្យោបាយតែមួយគត់ដែលព្រះពុទ្ធ ហើយនិងសាវ័ក ពីដំបូងៗ របស់ព្រះអង្គបានប្រើ ។ ការប្រើប្រាស់នៃពាក្យនិយាយ ជាមធ្យោបាយ បង្រៀននៅក្នុងការអប់រំរៀបរយរបស់វត្តអារាម គឺមានព្រំដែនកំណត់ ។ ប៉ុន្តែ នៅក្នុងការអប់រំមិនរៀបរយនៃមហាជនវិញ ព្រះសង្ឃពុទ្ធសាសនិក អស់កាលជា ច្រើនសតវត្សហើយ បានបង្កើតអោយមានអ្នកប្រើប្រាស់យ៉ាងប៉ិនប្រសប់នូវស្នេហ៍ ដ៏ពិរោះ, នូវអានុភាពបញ្ចុះបញ្ចូល, និងសាកលភាពនៃពាក្យនិយាយ ។

គំរូជាប្រពៃណីនៃធម៌ទេសនា បានបន្តមកពីព្រះពុទ្ធអង្គផ្ទាល់ ។ ដូច្នេះ លក្ខណះពិសេស ដែលពិពណ៌នាទាក់ទងនឹងព្រះធម៌ទេសនារបស់ព្រះពុទ្ធ ក៏ត្រូវបាន គេយកមកអនុវត្ត នៅក្នុងធម៌ទេសនាភាគច្រើន សូម្បីសព្វថ្ងៃនេះក៏ដោយ ។ ប៉ុន្តែ ដំណើរប្រែប្រួលដែលបានកើតមានហើយនេះ បញ្ជាក់អោយឃើញនូវសមត្ថភាពដ៏ អស្ចារ្យ ដើម្បីធ្វើអោយមានការបញ្ចូលបែបបទថ្មីៗ ទៀត អោយបានសមស្របនឹង ចំណង់ចំណូលចិត្ត ឬការនិយមរបស់ជាតិនីមួយៗ ។

" ទេសនាត្រៃពីរ " គឺជារូបភាពថ្មីមួយ ។ ជាជំនួសលោកសង្ឃមួយអង្គ សំដែងធម៌ទេសនា គេបាននិមន្តលោកសង្ឃពីរអង្គទេសនាវិញ ។ គេបានអនុវត្តតាម វិធីច្រើនយ៉ាង ។ ព្រះសង្ឃមួយអង្គ សូធ្យអត្ថបទដកស្រង់ចេញមកពីព្រះសូត្រ ព្រះ

សង្ឃមួយអង្គទៀត ពន្យល់អត្ថបទដកស្រង់នោះ ដោយមានពតិមានជាមូលដ្ឋាន និងមានរឿងនិទានសំរាប់គាំទ្រផង ។ សវនិកជន ( ជនអ្នកស្តាប់ ) កាន់តែមានចិត្តជាប់ជំពាក់ខ្លាំងទៀត នៅក្នុងឱកាសទេសនាគ្រែពីរ ដែលមួយអង្គដើរតួជាមហាថេរជាអ្នកចោទសំណួរ ឬក៏ទាំងពីរអង្គនេះ ចាត់តាំងការពិភាក្សា ដេញដោលគ្នា ដោយឥតបានព្រាងទុកមុនទេ ។ នៅក្នុងបែបបទផ្សេងមួយទៀត ព្រះសង្ឃទីពីរ គឺព្រះសង្ឃដែលដើរតួជាអនុថេរ ត្រូវបានជំនួសដោយគ្រហស្ថម្នាក់វិញ ដែលបានដើរតួជាស្តេចក្រិកព្រះនាម មេនន្ទេរ ( Menander ) ។ បន្ទាប់មក ព្រះសង្ឃទីមួយ ដែលដើរតួជាមហាថេរនោះ ត្រូវទទួលមុខងារជាព្រះនាគសេនវិញ ហើយការជជែកដេញដោលដ៏ល្បីល្បាញ រវាងបុគ្គលទាំងពីររូបស្តីពីពុទ្ធសាសនា កាលពីជំនាន់ដើមនោះ ក៏ត្រូវបានគេលើកយកមករៀបរាប់ឡើងវិញ ។ លទ្ធភាពធ្វើអោយរំភើបចិត្តខ្លាំង គឺនៅក្នុងឧទាហរណ៍ខ្លះៗ ដែលគេលើកមកសំដែងនូវជាតកទាំងម្ភៃបួនរបស់ព្រះពុទ្ធ នៅពេលដែលព្រះអង្គបានជួបពុទ្ធបុរសនីមួយៗ ក្នុងបណ្តាពុទ្ធបុរសទាំងម្ភៃបួនរបស់ព្រះអង្គ ហើយគេបានអះអាងថា ព្រះអង្គនឹងបានក្លាយទៅជាព្រះពុទ្ធមួយអង្គ ។ ទាំងនេះ គ្រាន់តែជាការបញ្ចូលរបៀបថ្មី ( Innovations ) មួយចំនួនប៉ុណ្ណោះ នៃធម៌ទេសនា ដែលគេធ្លាប់បានធ្វើជាញឹកញយនៅប្រទេសស្រីលង្កា រហូតមកដល់ពេលពីរ - បី ទសវត្សកន្លងមកហើយ ។ ដោយបណ្តាលមកពីការរីកដុះដាលនៃល្បែងកំសាន្តសម័យថ្មី បែបបទទេសនាទាំងប៉ុន្មាននេះ ត្រូវបានបាត់មុខស្ទើរអស់ទៅហើយ ។ នៅក្នុងប្រទេសកាន់ពុទ្ធសាសនាខ្លះទៀត ក៏មានការបញ្ចូលរបៀបថ្មីប្រហាក់ប្រហែលគ្នាកើតមានឡើងដែរ ។

ពុទ្ធសាសនិកជន ធ្លាប់បានប្រើប្រាស់រឿងល្ខោនកំសត់ ព្រាត់ប្រាស់ ( drama ) ក្នុងចំណោមរឿងបុរាណបំផុត ជាមធ្យោបាយផ្សព្វផ្សាយសាសនា ។ រឿងកំសត់ព្រាត់ប្រាស់ ដ៏ជារឿងចាស់ទុំបំផុតរបស់ឥណ្ឌា ដែលមានទាំងប៉ុន្មាន ចាប់

ពីពេលនោះមក គឺជាប្រធានបទដ៏សំខាន់មួយរបស់ពុទ្ធសាសនា ។ រឿងវិនាដកម្ម ( រឿងកំសត់ ព្រាត់ប្រាស់ កំប្លែង = drama ) មានលក្ខណៈសាសនា និងក្រុមល្ខោនវិនាដកម្មគោចរនៅក្នុងប្រទេសកាន់ពុទ្ធសាសនាទាំងអស់ បានរក្សាប្រពៃណីដ៏ចាស់ទុំនេះរៀងៗ ខ្លួន ។ ក្រុមរបាំគោចរនៅក្នុងប្រទេសម្យ៉ាន់ម៉ា ( ភូមា ) និងក្នុងប្រទេសទីបេត៍ គឺជាក្រុមសំខាន់របស់ប្រទេសដែលគេបានប្រើទុកជាមធ្យោបាយអប់រំមហាជន ពីចរិយាធម៌របស់ពុទ្ធសាសនា និងអំពីប្រវត្តិវត្តអារាមរបស់សាសនា ។

នៅក្នុងប្រទេសកម្ពុជាយើងវិញ មធ្យោបាយប្រើពាក្យពោលដើម្បីផ្សព្វផ្សាយទ្រឹស្តីពុទ្ធសាសនា និងការអប់រំ ត្រូវបានគេអនុវត្តយ៉ាងទូលំទូលាយ អស់កាលជាច្រើនសតវត្សមកហើយ ។ នៅស្ទើរគ្រប់បុណ្យទានធំ - តូច គេតែងនិមន្តព្រះសង្ឃទៅជាអធិបតីក្នុងពិធី ។ នៅក្នុងពិធីទាំងនោះ បើទោះជាគេពុំបាននិមន្តភិក្ខុមួយអង្គ ឬពីរអង្គ ឬក៏បីអង្គ សំដែងធម៌ទេសនាក៏ដោយ យ៉ាងហោចណាស់ ក៏គេបាននិមន្តព្រះសង្ឃសូធ្យសត្តបរិត្ត ឬសត្តប្បករណាភិធម្ម ដ៏ជាធម៌មានឥទ្ធិពលនាំទៅរកការធ្វើចិត្តអោយស្ងប់ បន្សាត់បង់បណ្តើរៗ នូវអកុសលចិត្តទាំងពួង ។

បែបបទសំដែងធម៌ទេសនានៅប្រទេសកម្ពុជា ក៏មានច្រើនបែបដែរ គឺការសំដែងធម៌ដោយភិក្ខុមួយអង្គ ដែលពាក្យសាមញ្ញ ហៅថា " ទេសនាគ្រែមួយ " ការសំដែងធម៌ទេសនា ដោយភិក្ខុពីរអង្គចោទ - ឆ្លើយ អំពីគោលធម៌ខ្លីៗ ដែលគេហៅថា " ទេសនាគ្រែពីរ " និងមានការសំដែងធម៌ទេសនា ដោយភិក្ខុច្រើនអង្គរហូតដល់គ្រែបីក៏មាន ដោយយោងទៅតាមសារសំខាន់នៃបុណ្យទាននោះៗ និងយោងទៅតាមចំណូលចិត្តរបស់ម្ចាស់ទាន ដែលគេចង់ប្រដូចការរៀបចំទេសនារបស់គេនោះ ទៅនឹងការធ្វើសង្គាយនាផ្ទៀងផ្ទាត់ធម៌ - វិន័យ ។

ក្រុមល្ខោន ក្រុមរបាំគោចរ មានជាអាទិ៍ ល្ខោនបាសាក់ យីកេ អាប៉េច្រើនតែបានលើកយករឿងពុទ្ធនិយម ដ៏ជារឿងប្រជាប្រិយ៍មកសំដែង ដូចជារឿង

វេស្សន្តរ រឿងព្រះល័ក្ខជិនវង្ស រឿងសង្ខសិល្បជ័យ រឿងវរវង្សសូរ្យវង្ស -ល- ក្រៅពីនេះ ក៏នៅមានទម្រង់អប់រំពុទ្ធនិយមមួយបែបទៀត ដោយប្រើពាក្យសំដី គឺអ្នកចម្រៀងចាប៉ី ។ ប្រធានបទរបស់អ្នកចម្រៀងចាប៉ីនេះ ក៏ផ្អែកទៅលើរឿងនានាជាតក រឿងប្រឌិតបែបពុទ្ធនិយម លាយឡំដោយពាក្យបំផ្លើស លែបខាយ កំប្លែងនាំអោយជក់ចិត្តយ៉ាងខ្លាំង ។

ប៉ុន្តែ ដោយសារបច្ចេកទេសវិទ្យាសាស្ត្រ បានរីកចំរើនខ្លាំង ក្រុមល្ខោនយីកេ អាប៉េ ជាដើម កាន់តែលិបបាត់មុខពីលើឆាក ហើយភាពយន្ត ខ្សែវីដេអូបានដើរតួជំនួសវិញ ។ ខ្សែអាត់ថតសំឡេង ថតរូបផ្សាយតាមវិទ្យុ ទូរទស្សន៍ ឬម៉ាញ៉េតូហ្វូន បានដើរតួជំនួសល្ខោនបាសាក់ យីកេ អាប៉េ ចម្រៀងចាប៉ីផងដែរ ។ ដោយសារឥទ្ធិពលនៃការអប់រំរបស់ពុទ្ធសាសនា តាមរយៈបែបបទផ្សព្វផ្សាយគោលការណ៍សីលធម៌ និងចរិយាធម៌ នៅក្នុងប្រទេសអស់កាលជាច្រើនសតវត្ស ជាបន្តបន្ទាប់មិនដាច់ដូចនោះហើយ ទើបគេឃើញមានស្នាដៃជាកុសលយ៉ាងច្រើនសម្រាប់សង្គម ដូចជា ៖ វិទ្យាល័យ អនុវិទ្យាល័យ សាលារៀន មន្ទីរពេទ្យផ្ទះសំណាក់ ស្រះ អណ្តូង ... ដែលសប្បុរសជនក្នុងប្រទេសបានកសាងឡើង តាមគំរូកសាងទានបារមី របស់ព្រះបាទស្រីវេស្សន្តរ ជាដើម ។

*៤.៧. មធ្យោបាយនៃពាក្យសរសេរ ៖*

ផ្តើមចេញពីសិលាចារឹករបស់ព្រះបាទអសោក ដែលនៅក្នុងសិលាចារឹកនោះ ស្មារតីនៃពុទ្ធសាសនា ត្រូវបានតម្រង់ឆ្ពោះទៅរកប្រជានុរាស្ត្រ នៅក្នុងព្រះរាជាណាចក្រមោរ្យៈ ( the Maurya empire ) ដ៏ទូលំទូលាយ នាសតវត្សទី ៣ មុនគ្រឹស្តសករាជ, ពុទ្ធសាសនិកជនបានខិតខំច្នៃពាក្យនិយាយអោយទៅជាពាក្យសរសេរ សម្រាប់បំរើសង្គមអោយបានច្រើនបែប ។ តាំងពីសតវត្សទីមួយ មុនគ្រឹស្ត

សករាជ នៅពេលដែលគម្ពីរត្រូវបានគេសរសេរកត់ត្រាហើយ, ប្រព័ន្ធអប់រំរបស់វត្ត អារាម បានពឹងផ្អែកទាំងស្រុងលើសាស្ត្រា ឬសៀវភៅ ទុកជាឧបករណ៍ដំបូង សម្រាប់ស្វ័យសិក្សា ។

ពាក្យសរសេរ បានក្លាយតាំងតែពីដើមទីទៅ ជាមធ្យោបាយដ៏សំខាន់ សម្រាប់ការអប់រំមិនរៀបរយរបស់ពុទ្ធសាសនា ។ សាស្ត្រា ឬគម្ពីរពីដំបូងៗ បាន ត្រាប់តាមស្ទីល ( style ) របស់ធម្មកថិក ( the praechers ) ហើយផលិត បាននូវសាស្ត្រា ឬសៀវភៅ ដែលគេហៅថា ធម៌ទេសនាសរសេរ ។ ការអានអោយ អ្នកភូមិស្តាប់ ត្រូវបានថិតថេរ រហូតមកដល់ពេលថ្មីៗ នេះ ។ អ្នកភូមិជនបទ បានចាត់ ទុកការស្តាប់នេះជាពេលសម្រាកលំហែទាំងនៅក្នុងវត្ត ទាំងនៅក្នុងផ្ទះរបស់គេ ។

នៅប្រទេសកម្ពុជា រូបភាពមើល ( អាន ) សាស្ត្រាទេសន៍ ឬសាស្ត្រា ច្បាប់ ឬក៏សាស្ត្រាល្បែងនៅក្នុងវត្ត ឬនៅតាមផ្ទះសម្បែងក្នុងភូមិ ត្រូវបានគេអនុវត្ត ចាប់តាំងពីច្រើនសតវត្សហើយ ទើបតែផុតរលត់ទៅពេលថ្មីៗនេះទេ ។ រូបភាព មើលសាស្ត្រាទេសន៍ ឬសាស្ត្រាផ្សេងៗទៀត ត្រូវបានអ្នកភូមិសំដែងស្វាគមន៍ ណាស់ ពីព្រោះសាស្ត្រា ក្បួនច្បាប់មានតិច អ្នកចេះអានអក្សរ ក៏មានចំនួនតិចតួច ហើយពិសេសជាងនេះទៀត ការស្តាប់គេអានសាស្ត្រា គឺជាការសម្រាកលំហែ ស្តាប់ផង និងជាកុសលផង ( កិច្ចំ ធម្មស្សវនំ ) ។ វិទ្យុ ទូរទស្សន៍ ម៉ាញ៉េតូហ្វូន សម្រាប់កំដរអារម្មណ៍ ឬផ្តល់ពតិមានដល់អ្នកភូមិ ជនបទ ទើបតែមានថ្មីៗ នេះទេ ។

នៅក្នុងប្រទេសម្យ៉ាន់ម៉ា ( ភូមា ) មានកន្លែងពីរ ក្នុងទីក្រុងមណ្ឌលេ ( Mandalay ) មានផ្ទាំងថ្មកែវ ( Marble ) រាប់រយ ។ នៅលើផ្ទាំងសិលាទាំង នោះ គេបានចារឹកយ៉ាងស្អាត នូវបាលីព្រះត្រៃបិដកទាំងមូល ។ នេះគឺជា " បណ្ណា-ល័យ " កណ្តាលវាល ដែលជាការអញ្ជើញប្រជានុរាស្ត្រ អោយចូលចិត្តអាន ។

ការតាំងបង្ហាញសំនៅសាសនានៅលើទង់ អក្សរសរសេរលើក្រដាសព្យួរ

នៅជញ្ជាំង ដូចនៅប្រទេសជប៉ុន កូរ៉េ ម៉ុងហ្គោលី និងទីបេត៍ ក៏សម្រាប់បំរើគោលបំណងដូចគ្នា ។ គ្រាន់តែប្រធានក្បាច់ ( ចម្លាក់ ឬគំនូរ ) សាសនាសុទ្ធសាធ ( a purely religious motive ) ក៏អាចជួយបំរើបន្ថែមទៅលើអក្សរសាស្ត្រពុទ្ធសាសនាប្រជាប្រិយ៍បានដែរ ។ ទាំងសៀវភៅសរសេរសាសនាដោយដៃ ទាំងសៀវភៅសាសនាបោះពុម្ព ត្រូវបានគេចាត់ទុកជាទ្រង់ទ្រាយមួយនៃធម្មទាន ( អំណោយព្រះធម៌ ) ហើយមានពុទ្ធភាសិតមួយឃ្លាបានចែងថា ធម្មទាន ( ការអោយព្រះធម៌ ) គឺជាទានប្រសើរជាងទានទាំងអស់ ( សព្វទានំ ធម្មទានំ ជិនាតិ ) ។

*៤.៨. ជំនួយចក្ខុទស្សន៍ :*

ហួសពីការបង្ហាញហេតុ - ផល សោភណភាពទៅទៀត ពុទ្ធសាសនិកជនបានប្រើចម្លាក់ និងគំនូរលាបពណ៌ ជាមធ្យោបាយសម្រាប់ទាក់ទងគ្នាទៅវិញទៅមក ។ ជញ្ជាំងព្រះវិហារ បានវិវត្តទៅជាមធ្យោបាយមួយផ្សេងសម្រាប់ការអប់រំមិនរៀបរយ ។ ប្រធានបទនៃគំនូរ និងចម្លាក់ ត្រូវបានដកស្រង់ចេញមកពីក្នុងអក្សរ-សាស្ត្រ នូវរឿងនិទានទាំងស្រុង ដែលរួមមានទាំងរឿងអតីតជាតិ និងបច្ចុប្បន្ន-ជាតិនៃព្រះពុទ្ធ, ជីវប្បវត្តិនានារបស់សាវ័កសំខាន់ៗ របស់ព្រះអង្គ និងប្រវត្តិនៃពុទ្ធ-សាសនា ព្រមទាំងសេចក្ដីរៀបរាប់ដោយរូបគំនូរមើលស្គាល់ថាជាឋាននរក ឬឋានសួគ៌ ។ ជាញឹកញយដែរ ការធ្វើបូជនីយសក៏ ក៏ជាដំណើរទស្សនកិច្ចម្យ៉ាងដើម្បីពិនិត្យមើលវិហារទាំងឡាយដែលល្បីល្បាញ ខាងរូបគំនូរពណ៌ និងរូបចម្លាក់ ។

*៤.៩. វិធីសិក្សារៀបរយ :*

ដើម្បីហ្វឹកហ្វឺនបណ្ឌិត ( អ្នកប្រាជ្ញ ) និងអ្នកឯកទេស, ហ្វឹកហ្វឺនអ្នកនិពន្ធ

និងធម្មកថិក ( អ្នកសម្តែងធម៌ ), និងហ្វឹកហ្វឺនអ្នករៀបចំអង្គការចាត់តាំង និងអ្នករដ្ឋបាល, ពុទ្ធសាសនិកជន បានអភិវឌ្ឍ និងបានទ្រទ្រង់ប្រព័ន្ធអប់រំរៀបរយមួយ ដោយសង្កត់ធ្ងន់លើចំណុចបីយ៉ាង ៖ ជាអាទិ៍ ការរៀនអោយចេះចាំមាត់, ការរៀនសរសេរអក្សរអោយស្អាត ( Calligraphy ), និងការអានពាក្យពេចន៍ច្បាស់ឥតអោយភ្លាត់ ។

ការរៀនអោយចេះចាំមាត់ ( Memorization ) នូវអត្ថបទដើម និងអត្ថបទអត្ថាធិប្បាយនៃសៀវភៅក្រាស់ៗ ត្រូវបានគេចាត់ទុកជាគុណសម្បត្តិមួយសម្រាប់ហ្វឹកហ្វឺន និងហាត់ពត់បញ្ញាស្មារតី ។ ដោយមានទំនុកទុកចិត្តលើគម្ពីរ លើការកសាងអោយមានបណ្ណាល័យនៅគ្រប់ទិសទី និងលើការហាត់ចម្លងអក្សរសរសេរដៃជាទៀងទាត់ ដូចនៅក្នុងប្រទេស កូរ៉េ ជប៉ុន ទីបេត៍ និងកន្លែងឯទៀត ការរៀនអោយចេះចាំមាត់ គឺពុំមែនជាការខិតខំស្តុកពតិមាន ( ចំណេះដឹង ) នៅក្នុងខួរក្បាលរបស់គេនោះឡើយ ។ សមត្ថភាពអាចសូធ្យឡើងវិញ នូវអត្ថបទវែងៗ តាមការចងចាំក្នុងស្មារតី អាចត្រូវបានគេកោតសរសើរថាជាជោគជ័យមួយ ប៉ុន្តែការចេះចាំក្នុងស្មារតីខ្លួនឯង មិនត្រូវបានគេទទួលស្គាល់ថាជាសញ្ញានៃការចេះដឹងនោះទេ ។ ការចេះដឹង ត្រូវបានគេអោយតម្លៃទៅលើការវៃឆ្លាត ចេះប្រទាក់ប្រទង និងចេះធ្វើសំយោគ នូវអ្វីដែលចេះចាំតាមរយៈមធ្យោបាយផ្សេងៗ ។ គ្មានអ្នកអប់រំពុទ្ធសាសនិកណាមួយ អាចនឹងលើកតម្កើងការរៀនចេះចាំមាត់ ដោយមិនយល់ន័យនេះទេ ( rotelearning ) ប៉ុន្តែ គេតវ៉ាការពារបែបបទរៀននេះ សម្រាប់ជាគុណប្រយោជន៍ដល់របបរៀនដ៏ម៉ត់ចត់ខាងហ្វឹកហ្វឺនស្មារតី ។

អក្សរសសេរដៃដ៏ស្អាត (good handwriting) ត្រូវបានគេចាត់ទុកថាជាសម្បត្តិមួយដ៏មានតម្លៃ ។ នៅក្នុងប្រព័ន្ធអប់រំរបស់វត្តអារាម អក្សរសរសេរស្អាត គឺជាសញ្ញានៃបណ្ឌិតភាព ។ ដោយហេតុនេះ សិស្សបានចំណាយពេលច្រើន

ណាស់ ដើម្បីហ្វឹកហ្វឺនសរសេរអក្សរ ។ នៅក្នុងវត្តអារាមប្រទេសទីបេតវិញ ការហាត់សរសេរអក្សរអោយស្អាត គឺជាសកម្មភាពដ៏សំខាន់មួយ ពីព្រោះការហ្វឹកហ្វឺនស្មារតី ត្រូវភ្ជាប់ជាមួយនឹងការសរសេរ ហើយសិស្សផលិតបាន " សៀវភៅចម្លង " ច្រើនច្បាប់ ទុកជាភស្តុតាងនៃការសិក្សា ។ ជាមួយនឹងសារសំខាន់ភ្ជាប់ទៅនឹងវោហារ និយាយឆ្លើយឆ្លង សិស្សត្រូវមានសមត្ថភាពវៃឆ្លាត ចេះអាន ចេះនិយាយបានល្អ និងត្រឹមត្រូវដោយបន្លឺព្យាង្គនីមួយៗ ច្បាស់ៗ ។ នេះជាការហ្វឹកហ្វឺនដ៏ចាំបាច់បំផុត សម្រាប់ក្រុមសូធ្យធម៌ ( ទាំងសម្រាប់ថ្វាយបង្គំនៅក្នុងវត្ត ទាំងសម្រាប់ពិធីបុណ្យ របស់គ្រហស្ថ ) និងសម្រាប់ការសំដែងធម៌ទេសនា ។ អត្ថបទទាំងឡាយដែលត្រូវរៀនសូធ្យសម្រាប់កិច្ចការនេះ ត្រូវមានកំរិតជាថ្នាក់ៗ ចាប់ផ្តើមពីពាក្យទោលងាយ ៗ ហើយឈានឡើងយ៉ាងម៉ត់ចត់ ទៅរៀនអានពាក្យពិបាកៗ ស្មុគស្មាញ ។ នេះជាវិធីដែលគេប្រើសម្រាប់អោយចេះអាន និយាយអោយបានច្បាស់ និងត្រឹមត្រូវ ។

ហេតុនេះ ស្មារតីល្អបរិសុទ្ធ និងផ្លូវផង់ សរសេរអក្សរល្អស្អាត ហើយនិងសំដីនិយាយច្បាស់លាស់ ត្រូវតែភ្ជាប់គ្នាជាមួយនឹងចំណេះដឹង ។ ការហ្វឹកហាត់ដោយមានវិន័យ ដើម្បីសំរេចអោយបាននូវគុណសម្បត្តិទាំងបីខាងលើនេះ ត្រូវប្រព្រឹត្តទៅអស់ពេលរាប់ឆ្នាំ ។ ការហ្វឹកហាត់ដោយមានវិន័យនេះ ត្រូវបានចាត់ទុកថាជាតម្លៃដែលអ្នកប្រាជ្ញទាំងឡាយលោកតែងលើកសរសើរយ៉ាងខ្លាំងថាជាស្នូលសារវន្តបំផុតនៃចំណេះដឹង ។

*៤.១០. បទពិសោធន៍ការងារ :*

ក្នុងការអប់រំរបស់វត្តអារាមពុទ្ធសាសនា ការសិក្សាមិនអាចផ្តាច់ចេញបានពីការងារពលកម្មបានទេ ។ សិស្ស ទោះបីជាអ្នកបួស ឬគ្រហស្ថ ត្រូវបំពេញការងារ

ផ្សេងៗ ដែលទាក់ទងនឹងការថែរក្សាបោសសំអាតវត្តអារាម ។ បុណ្យទានជាញឹកញយនៅក្នុងវត្ត ទាមទារអោយបំពេញកិច្ចការច្រើនបែប ។ សិស្សត្រូវចេះ ហើយរួមចំណែកធ្វើការងារមួយចំនួន ដូចជា ជំនាងឈើ ជំនាងកំបោរ . បាយអរ ជំនាងដែក ។ នេះក៏ជាចំណែក ដើម្បីធ្វើខ្លួនអោយមានប្រយោជន៍ដល់ឱកាសបុណ្យទាន ។ ជំនាញ ឬការប៉ិនប្រសប់ឯទៀតៗ ទាក់ទងនឹងការគូរ ការបត់ក្រដាស និងការឆ្លាក់ ហើយនិងនិម្មិតកម្មសិល្បៈ ( artistic creations ) ផ្សេងទៀត ត្រូវឆ្លៀតឱកាសរៀនអោយរីកចំរើនដែរ ។ អ្នកប្រាជ្ញ ឬអ្នកបណ្ឌិតធុនមធ្យម ដែលទទួលការអប់រំតាមប្រព័ន្ធសិក្សានៅក្នុងវត្តអារាម គឺជាពលករម្នាក់មានចំណេះច្រើនមុខ រាប់តាំងពីជំនាញ ( skills ) ដោយដៃ និងបច្ចេកទេស ។ នៅក្នុងប្រព័ន្ធអប់រំប្រទេសទីបេតវិញ ភិក្ខុសង្ឃត្រូវតែរៀនអោយចេះពិតប្រាកដខាងជាងឈើ ជាងកំបោរ អារ ឈូស និងឆ្លាក់ តែងលំអ ក្រៅពីមុខវិជ្ជាឯទៀត ដែលត្រូវរៀន ហើយប្រឡងថែមទៀត ។

### *៤.១១. សេវាកម្មសង្គម ( ការបំរើសង្គម ) :*

វត្តអារាមនីមួយៗ មានកាតព្វកិច្ចជាច្រើន ដើម្បីបំពេញតបគុណ ចំពោះពួកពុទ្ធបរិស័ទជាគ្រហស្ថរបស់ខ្លួនវិញ នៅក្នុងសហគមន៍ ។ ភិក្ខុជាសិស្សមួយរូបជាធម្មតា ត្រូវចូលរួមក្នុងពិធីបុណ្យចាត់ចែងនៅផ្ទះគ្រហស្ថ ។ កិច្ចការនេះ បាននាំអោយគេបានជួបប្រាស្រ័យទាក់ទងជាមួយនឹងជីវភាពសហគមន៍ ។

ការងារជាធម្មតាមួយ គឺការបង្រៀនក្មេងៗ ។ ដូចជាមានធ្វើក្នុងប្រទេសកាន់ពុទ្ធសាសនាជាច្រើនដែរ ។ ឪពុកម្ដាយទាំងឡាយ នៅតែខិតខំបន្ថែមការអប់រំនៅតាមសាលារបស់កូនចៅខ្លួន ដោយអោយមកទទួលការប្រៀនប្រដៅពីវត្តអារាម, អោយចេះអានអក្សរតាមប្រពៃណី និងទទួលការហ្វឹកហ្វឺនអក្សរសាស្ត្រពីវត្ត ។

សមណសិស្សទាំងឡាយ ត្រូវចូលរួមក្នុងសកម្មភាពសង្គម ទោះបីជាសកម្មភាពនោះធ្វើដើម្បីអោយមានការអភិវឌ្ឍន៍ ឬធ្វើសម្រាប់ជំនួយសង្គ្រោះ និងសម្រាប់នីតិ-សម្បទា ( ការធ្វើអ្វីមួយអោយមានលក្ខណៈដូចដើមវិញ ឬការធ្វើអោយអ្នកណាមួយមានស្ថានភាពដើមឡើងវិញ ) ។ តាមធម្មតា កម្មវិធីសិក្សារបស់វត្តអារាម ពុំមានរចនាសម្ពន្ធរៀបរយទេ ដោយពុំតម្រូវអោយអនុវត្តតាមពេលវេលាជាប់លាប់ដូចជាពេលប្រឡង ឬការឡើងថ្នាក់ទេ, ដោយហេតុនេះ សមណសិស្សអាចបញ្ចូលការសិក្សា ការពិសោធន៍ការងារ និងការបំរើសង្គមជាមួយគ្នា ហើយពន្យារពេលសិក្សាបន្តទៅទៀតបាន តាមតែកាលៈទេសៈអនុញ្ញាត ។

*៤.១២. ការលើកស្ទួយសិល្បៈ និងសិប្បកម្ម :*

សិល្បៈប្រជាប្រិយ និងសិប្បកម្ម ហើយនិងភ្លេង គឺជាផ្នែកមិនរៀបរយនៃការអប់រំរបស់ពុទ្ធសាសនា, ដោយសារមានបុណ្យទានញឹកញយ និងមិនបានគ្រោងរៀបចំមុន ។ ដូចជានៅក្នុងការងារបំរើសង្គម ការចូលរួមរបស់សិស្សត្រូវបានលើកទឹកចិត្ត ដោយពុំមានកាលវិភាគរៀនសូត្យតឹងតែង ឬការប្រឡងចាប់បង្ខំនោះទេ ។

*៥. សេចក្តីសន្និដ្ឋាន :* សេចក្តីត្រូវការសម្រាប់ការស្រាវជ្រាវ :

ដូចនៅក្នុងប្រការនេះ បានចង្អុលប្រាប់ហើយថា ពតិមានដែលប្រមែប្រមូលបាន ស្តីពីការអប់រំពុទ្ធសាសនាតាំងពីអតីតកកាល និងបច្ចុប្បន្ននេះ គឺមានកំរិតស្តួចស្តើងណាស់ ។ ការព្យាយាមស្រាវជ្រាវ ត្រូវបានធ្វើឡើងដើម្បីធ្វើអោយទស្សនវិជ្ជាពុទ្ធសាសនា ស្តីពីការអប់រំ បានលេចច្បាស់ឡើង, ប៉ុន្តែ យើងទទួលបានលទ្ធផលតែបន្តិចបន្តួចប៉ុណ្ណោះ ពីព្រោះការធ្វើវិភាគដ៏ល្អិតល្អន់ អំពីអក្សរសាស្ត្រ

នៅមិនទាន់បានចាប់ផ្តើមនៅឡើយ ។ ប្រវត្តិនៃការអប់រំពុទ្ធសាសនា បានរៀបរាប់ត្រឹមតែការសរសេររៀបរាប់ខ្លីៗ ស្តីពីការអប់រំរបស់ឥណ្ឌា ដូចមាននិទាននៅក្នុងរឿងពុទ្ធសាសនា ឬនៅក្នុងរបាយការណ៍ ស្តីពីស្ថាប័នសិក្សា ដែលបូជនិយេសក៏ចិនបានឃើញ ហើយសរសេររៀបរាប់ ។ ទិដ្ឋភាពខាងក្រៅនៃសាលារៀនរបស់វត្ត, ការព្យាយាមធ្វើអោយការអប់រំរបស់ពុទ្ធសាសនារស់រានឡើងវិញ, និងឥទ្ធិពលសង្គម . វប្បធម៌នៃការរីកចំរើនទាំងអស់នេះ នៅក្នុងប្រទេសកាន់ពុទ្ធសាសនានីមួយៗ នៃទ្វីបអាស៊ី ក៏ស្ថិតនៅតែជាកិច្ចការដែលត្រូវចងក្រងជាឯកសារ ហើយពិនិត្យសិក្សាដោយស្មារតីរិះគន់បំផុត ។ ក៏មានសារសំខាន់ដូចគ្នាដែរនោះ គឺការពិនិត្យពិចារណា ថាតើគំនិត, បែបបទការងារ ( Modalities ), វិធីសាស្ត្រ ( methods ), និងវិធីអនុវត្តជាក់ស្តែង ( practical approaches ) ដែលប្រព័ន្ធអប់រំរបស់ពុទ្ធសាសនា បានអភិវឌ្ឍន៍កន្លងមកហើយនេះ អាចមានលក្ខណ-សម្បត្តិល្អ ដើម្បីជាគុណប្រយោជន៍ដល់កំឡាំងខិតខំបច្ចុប្បន្ននេះ ក្នុងការអភិវឌ្ឍន៍កិច្ចការអប់រំបានដោយប្រការណាមួយដែរឬទេ ?

---

# នរនាម និង ឋានន្តរនាម

## តាមសិលាចារឹកកម្ពុជា សម័យមុនអង្គរ

## ( សតវត្សទី VI ដល់ VIII )

Les noms de titres et les anthroponymes d'après

les inscriptions du Cambodge ( VIe - VIIIe siècles )

នរនាម និងឋានន្តរនាម គឺជាមុខវិជ្ជាដ៏សំខាន់នៅក្នុងភាសាវិទ្យា នៅក្នុងជាតិពន្ធុវិទ្យា ។ នៅក្នុងប្រទេសកម្ពុជាយើង គេពុំទាន់ឃើញមាននូវការស្រាវជ្រាវដែលទាក់ទងទៅនឹងឋានន្តរនាម ឬនរនាម ហើយដែលការសិក្សាស្រាវជ្រាវនោះមានលក្ខណៈជានិក្ខេបបទនៅឡើយ ។ ការសិក្សានូវវិជ្ជាទាំងពីរនេះ មិនគ្រាន់តែផ្តល់ចំណេះដឹងខាងភាសាវិទ្យា ឬខាងសង្គមវិទ្យាប៉ុណ្ណោះទេ ប៉ុន្តែគឺជាមុខវិជ្ជា ឬការស្រាវជ្រាវដែលអាចអោយយើងដឹងនូវព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ នៅក្នុងបុព្វកាលថែមទៀតផង ។ សិលាចារឹកប្រទេសកម្ពុជា ពីសតវត្សទី ៦ ដល់ ១៤ គឺជាឯកសារដ៏សំខាន់ខាងឋានន្តរនាម និងនរនាម ព្រមទាំងស្ថាននាម ។ មិនតែប៉ុណ្ណោះ នៅក្នុងសិលាចារឹកទាំងនេះ គេប្រទះឃើញមានទាំងឈ្មោះអាទិទេពដ៏សំខាន់ៗ នៅក្នុងព្រហ្មញ្ញសាសនា ឈ្មោះទេវៈ ( ទេវនាម ) ដែលជានាមរបស់មហាក្សត្រនានា របស់ឥស្សរជនជាន់ខ្ពស់ទាំងឡាយ បន្ទាប់ពីមរណកាលទៅ ។

នរនាម ឬនាមឈ្មោះ ដែលមាននៅក្នុងសិលាចារឹកកម្ពុជា មានចំនួនច្រើន គឺប្រហែលពី ៥.០០០ ឡើងទៅ ហើយអាចចែកចេញជាពីរក្រុមធំៗ ទៅតាមឋានៈរបស់មនុស្សក្នុងសង្គម ។

ក្រុមទី១ ៖ គឺជានរនាមរបស់មនុស្ស ដែលស្ថិតនៅក្នុងស្រទាប់លើនៃសង្គម (Catégorie Social Supérieur) « CSS » មានជាអាទិ៍ រាជវង្សានុវង្ស ព្រាហ្មណ៍ បុរោហិត រាជក្ដូល មហាមន្ត្រី រាជគ្រូ ( ព្រះគុរុ ) ឥស្សរជនជាន់ខ្ពស់ មន្ត្រីសង្ឃជាន់ខ្ពស់ ពួកអភិជន ( aristocrates ) ពួកកុដុម្ពីក៍ ( ពួកអ្នកមានដីច្រើន ) រាជការ ( អ្នកបំរើការរបស់រាជ្យព្រះមហាក្សត្រ ) សេនាបតី កីឡាករប្រដាល់ ។ ល ។ គឺជាឈ្មោះមនុស្សដែលស្ថិតនៅក្នុងស្រទាប់លើនៃសង្គម ។

ក្រុមទី២ ៖ គឺជាឈ្មោះមនុស្សដែលស្ថិតនៅក្នុងស្រទាប់ធម្មតា ឬស្រទាប់ក្រោមនៃសង្គម ( Catégorie Sociale Inférieur ) « CSI » គឺជាឈ្មោះអ្នកបំរើ ឬពួកក្ញុំ មានអ្នកបំរើនៅក្នុងប្រាសាទ នៅវត្តអារាម អ្នកធ្វើស្រែ ធ្វើចំការ ដែលស្ថិតនៅក្រោមរបបគ្រប់គ្រងរបស់វត្តអារាម អ្នកដាំដំណាំនៅសួនឧទ្យាន អ្នកគង្វាលសត្វពាហនៈ ឆ្មាំនានា មានឆ្មាំវិហារ ឆ្មាំច្បារ ឆ្មាំសាលា ឆ្មាំមាស ឆ្មាំប្រាក់ អ្នកតម្បាញ អ្នករវៃអំបោះ ( រង្វៃ ) អ្នកចម្លាក់ សិល្បករ តូរ្យតន្ត្រីករ អ្នកចំរៀង នាដ្យករ របាំ អ្នកដណ្ដាំស្ល អ្នកផលិតគ្រឿងក្រអូប ( pamas danhum ) អ្នកធ្វើអង្ករ ( rmmes ranko ) ។

ឈ្មោះរបស់ក្ញុំបំរើនៅវត្តអារាមទាំងនេះ មានអត្ថប្រយោជន៍គួរកត់សំគាល់ ដោយហេតុថា នៅក្នុងប្រព័ន្ធនៃនរនាមខ្មែរ ឈ្មោះទាំងនេះ ឬមួយមានដើមកំណើតពីពាក្យខ្មែរ ឬមួយពីពាក្យសំស្ក្រឹត ឬមួយពីពាក្យដែលមានប្រើនៅក្នុងភាសាមនបុរាណ ។

ឈ្មោះមនុស្ស គឺនរនាមនៅក្នុងសិលាចារឹកមានរាប់ពាន់ ហើយគ្រាន់តែនៅក្នុងសិលាចារឹកសម័យមុនអង្គរ មានចំនួនប្រហែល ៣.០០០ ។ ដូចយើងអធិប្បាយខ្លះមកហើយថា នរនាមបានកើតចេញមកពីនាមសព្ទធម្មតានៅក្នុងភាសាដែលសំគាល់នូវបញ្ញត្តិ ឬមតិគំនិតណាមួយ របស់ណាមួយច្បាស់លាស់ ។ ដូច្នេះ

នរនាមមានសារសំខាន់សំរាប់សិក្សា និងចងក្រងអត្ថន័យរបស់ពាក្យ បង្កើតជាវចនានុក្រមនៃភាសាខ្មែរបុរាណ ។ នៅលើទស្សនៈ នៃការសិក្សាប្រវត្តិសាស្ត្រ ពាក្យបុរាណនិមួយៗ ដែលគេរកឃើញនៅតាមសិលាចារឹក គឺជាពាក្យដែលមានការវិវត្តន៍ការល្អួតលាស់ គឺជាពាក្យដែលមានប្រវត្តិផ្ទាល់របស់ខ្លួន ។ មុននឹងឆ្លងទៅធ្វើការវិភាគលើលក្ខណៈនៃរចនាសម្ព័ន្ធ និងអត្ថន័យនៃនរនាមនៅក្នុងភាសាខ្មែរបុរាណ យើងគួរសិក្សាអំពីប្រព័ន្ធនៃឋានន្តរនាម នាសម័យនោះដែរ ដោយហេតុថា នរនាមក៏មិនខុសពីស័ព្ទធម្មតា នៅក្នុងភាសានិយាយ ក៏ដូចជាក្នុងភាសាសរសេរ ប៉ុន្តែ គេអាចសំគាល់បាននូវនរនាម មិនមែនដោយសារការប្រើតួអក្សរតូច ឬធំ នោះទេ គឺគេអាចសំគាល់បានដោយសារការប្រើឋានន្តរនាម ។

នរនាមភាគច្រើន កើតឡើងពីវចនស័ព្ទធម្មតា គឺកើតពីនាម និងនាមគុណនាម កិរិយាស័ព្ទ សំខ្យាស័ព្ទ ( លេខ ) ។

នរនាមដែលជានាមឈ្មោះរបស់អ្នកបំរើនៅក្នុងវត្តអារាម ព្រមទាំងទេវ-នាម គឺជានាមរបស់ទេវៈ និងទេវតារក្សាគ្រប់បែបយ៉ាងនាសម័យនោះ គឺសម័យអង្គរ និងមុនអង្គរ ជាឈ្មោះដែលមានសារសំខាន់សំរាប់ការសិក្សាផ្នែកខាងប្រវត្តិ-សាស្ត្រ និងសង្គមវិទ្យា ដោយហេតុថា នាមឈ្មោះនីមួយៗ ទាក់ទងទៅនឹងពាក្យធម្មតានៅក្នុងភាសា ទាក់ទងទៅនឹងវត្ថុដែលមាននៅក្នុងសម័យនោះ ទាក់ទងទៅនឹងមុខងារ ឬវិជ្ជាជីវៈ ហើយជាពិសេសទៅនឹងជំនឿ ឬសាសនា ដែលអ្នកស្រុកជំនាន់នោះប្រកាន់យក ។

នាមឈ្មោះមនុស្សសម័យនោះ បានកត់ត្រាឡើងនៅក្នុងបញ្ជីជាសិលាចារឹក ដោយមានប្រើពាក្យជាភាសាខ្មែរសុទ្ធ ជាភាសាសំស្ក្រឹត ឬក៏ជាភាសាខ្មែរលាយជាមួយភាសាសំស្ក្រឹត ។

ជាធម្មតា មុននឹងរៀបរាប់អំពីនរនាម គឺរាប់នាមឈ្មោះមនុស្ស ឬនាម

ឈ្មោះអ្នកបំរើទៅតាមមុខងាររបស់ខ្លួន នៅតាមវត្តអារាម គេតែងប្រទះឃើញការប្រើពាក្យឈ្មោះ « ក្ញុំ » ។

ពាក្យទាំង ២ ម៉ាត់នេះ អាចចាត់ទុកជាពាក្យដែលមានលក្ខណៈប្រវត្តិ-សាស្ត្រ ប្រសិនបើគេអាចបំបែកន័យរបស់ពាក្យទាំង ២ នេះ ជ្មះ ឡ្យ; ឡ្មះ: ជ្មោះ ជាពាក្យ កើតចេញមកពីកិរិយាស័ព្ទ « ជោះ » + បទជ្រែក « ម » ហើយពាក្យ « ជោះ » ទាក់ទងទៅនឹងពាក្យ « ចុះ » ( ឈ្មោះ ) ក្នុងបញ្ជីជាក្ញុំបំរើរបស់ព្រះឬមួយរបស់ ព្រះវិហារ ។

ពាក្យថា « ក្ញុំ » អាចចេញពីពាក្យ « ភិបកុ » នៅក្នុងភាសាមនបុរាណ ប្រែថា « អ្នកផ្គត់ផ្គង់ » ឬ « អ្នកបំរើសេចក្តីត្រូវការរបស់លោកសង្ឃនៅក្នុងវត្តអារាម » ។ ដូច្នេះ ពាក្យនេះក៏មានន័យមិនខុសប៉ុន្មានពីពាក្យខ្មែរសម័យថា «ញោម» ដែលមានន័យថា « ពុទ្ធបរិស័ទជើងវត្ត » ហើយជាអ្នកផ្គត់ផ្គង់វត្តអារាម ។

នៅតាមសិលាចារឹកសម័យអង្គរ និងមុនអង្គរ គឺស្ទើងគ្រប់សិលាចារឹកទាំងអស់ជាភាសាខ្មែរ រមែងមានការរៀបរាប់ឈ្មោះឋានន្តរសក្តិនៅពីមុខ ហើយឈ្មោះមនុស្សទាំងនោះមាននៅតាមសិលាចារឹកចំនួនរហូតដល់ ៥.០០០ ឬ ៦.០០០ ។ ឈ្មោះមនុស្សជាភាសាសំស្ក្រឹត ក៏មានប្រយោជន៍ដូចជាឈ្មោះមនុស្សក្នុងភាសាខ្មែរសុទ្ធ ដោយហេតុថា ក្នុងការសិក្សានិរុត្តិវិទ្យា ដើម្បីចងក្រងជាវចនានុក្រម គេអាចដកស្រង់យកអត្ថន័យ ដ៏សុទ្ធសាធរបស់ពាក្យនីមួយៗដែលមាននៅក្នុងនរនាមទាំងនោះ ។ តទៅនេះ យើងនឹងសិក្សាអំពីប្រព័ន្ធ និងទំរង់នៃឋានន្តរនាមសម័យមុនអង្គរ និងសម័យអង្គរ ដែលយើងអាចធ្វើការចាត់ថ្នាក់ ដូចតទៅ ៖

សតវត្សទី VI - VIII



## SIGNES CONSONNES

| | | | | |
|---|---|---|---|---|
| ក ka | ខ kha | គ ga | ឃ gha | ង ṅa |
| ច ca | ឆ cha | ជ ja | ឈ jha | ញ ña |
| ដ ṭa | ឋ ṭha | ឌ ḍa | ឍ ḍha | ណ ṇa |
| ត ta | ថ tha | ទ da | ធ dha | ន na |
| ប pa | ផ pha | ព ba | ភ bha | ម ma |
| យ ya | រ ra | ល la | វ va | ស sa |
| ឝ śa | ឞ ṣa | ហ ha | ឡ ḷa | អ a |

## SIGNES VOYELLES

| | | | | | |
|---|---|---|---|---|---|
| អ a | ា a | ិ i | ី ī | ឹ i | ឺ ī |
| ុ u | ូ ū | ួ uo (w) | ើ oe | ឿ ioe | ៀ ie |
| េ e | ែ ae | ៃ ai | ោ o | ៅ au | |
| ំ ṃ | ះ ḥ | | | | |

## SIGNES DIACRITIQUES

៉ = " ម៉ = ma ់ = ' សក់ sak .១ ២ក្មេង = kmen២

៊ = ^ ប៊ = p̂a ័ = ˘ ជ័រ jar

៏ = ˝ ក៏ = ka ៌ = r ធម៌ dharm

៑ = virama សញ្ញានេះ បញ្ជាក់ថា ស្រះកប់ត្លួចុងព្យាង្គមិនអាន

 po

 po cas

ពោចស់អញ po cas añ

ពោយាង po yāṅ

ពោញ poñ

ក្ពោញ kpoñ

ក្ពោញ កម្រតាងអញ kpoñ kaṃmratāṅ añ

តាង tāṅ

តាងអញ tāṅ añ

ម្រតាង mratāṅ

ម្រតាងកុរុង mratāṅ kuruṅ

ម្រតាងក្លោញ mratāṅ kloñ

កម្រតាង kaṃmratāṅ

កម្រតាងអញ kaṃmratāṅ añ

វ្រះ កម្រតាងអញ vraḥ kaṃmratāṅ añ

អំពីទំរង់អត្ថន័យនៃឋានន្តរនាមសម័យមុនអង្គរ សតវត្ស VI - VIII

*I. ក្នុងបណ្តាពាក្យសំគាល់ខាងឋានន្តរនាម ខាងលើនេះ CSS យើង អាចពន្យល់អត្ថន័យ ដូចតទៅ :*

១. តាង tāṅ : គឺជាឋានន្តរនាមរបស់មន្ត្រីធម្មតានៅតាមខេត្ត ឬស្រុក Ex : លោកតាងកន្មេងម្រសិរ ( tāṅ kanmeṅ mrasir ) ពាក្យ « » មានន័យថា : តំណាង តំណាងអាជ្ញាព្រះមហាក្សត្រ ។

២. តាង អញ tāṅ añ : ជាគោរម្យងារនៃមន្ត្រីនៅបរមរាជវាំង ឬនៅតាមខេត្តធំៗ ផ្សេងៗ ។

Ex : តាងអញក្លោញរង្គោ tāṅ añ kloñ raṅko

ក្នុងសិលាចារឹកអង្គរបុរីមួយ មានគេប្រទះឃើញពាក្យ « តាងអាជ្ញាវ្រះកំម្រតាងអញ » ( តាងមន្ត្រី ពោញ ភគិល ) ជាមន្ត្រីតំណាងនូវព្រះរាជ-បញ្ជារបស់ព្រះមហាក្សត្រ ។

៣. ម្រតាញ mratāṅ : ជាឋាននូវនាមរបស់មន្ត្រី ឬព្រះសង្ឃដែលមានឋានៈខ្ពស់ជាង tāṅ añ

ពាក្យ mratāṅ ចេញមកពីពាក្យ mra ( ប្រែថាមនុស្ស ) ពាក្យ មនខ្មែរ + កិរិយាស័ព្ទ តាង tāṅ ( តាងអំណាច, តាងអាជ្ញា )

៤. ម្រតាញ ក្លោញ mratāṅ kloñ : ជាឋាននូវនាមរបស់អភិបាលខេត្ត ក្រុង រាជធានី ឬមួយក៏ជាសង្ឃរាជខាងព្រហ្មញ្ញសាសនា ដែលគង់នៅទីរួមខេត្ត Ex : ម្រតាញក្លោញវ្យាធបុរ អភិបាលនៃរាជធានីនគរភ្នំវ្យាធបុរ

ជាពាក្យសមាសកើតមកពីពាក្យ

ម្រតាង + ក្លោញ ( មេជាអធិបតី )

៥. ម្រតាញ កុរុង mratāṅ kuruṅ : ជាគោរម្យងារនៃអភិបាលខេត្ត ឬក៏ជាគោរម្យងាររបស់ស្តេចត្រាញ់ ដែលជាស្តេចសាមន្តរាជឬសមន្តរដ្ឋ ( Principauté ) ។

ម្រតាញកុរុង ជាពាក្យសមាសចេញមកពីពាក្យ : ម្រតាង + កុរុង

( កុ + រុង : រុងរឿង, រុង = ធំ . ឧត្តម . ជ្រៅ )

នៅក្នុងភាសាខ្មែរប្រែថាស្តេច ឯក្នុងភាសាមនប្រែថា « ទន្លេ » បើភាសាខ្មែរសម័យថា « ក្រុងកម្ពុជាធិបតី » ។

៦. កម្រតាញ kamṃratāṅ : ជាឋាននូវនាមរបស់អភិជន ឬរបស់ព្រះសង្ឃ ដែលមានឋានៈខ្ពស់បំផុតនៅក្នុងសង្គម ។ ពាក្យនេះចេញមកពីពាក្យ ម្រតាង + បុព្វបទ កំ បានសេចក្តីថា គឺពាក្យកំម្រតាងកើតឡើងដោយ

បុព្វបទ ២ ជាន់ កំ និង ម្រ ។

គេសង្កេតឃើញថា កាលណាពាក្យកម្លាយមានបុព្វបទតែមួយជាន់ ពាក្យនោះមានកិរិតនៃឧត្តមភាពខ្ពស់ជាងពាក្យសាមញ្ញ ធម្មតា ហើយកាលណា ពាក្យកម្លាយណាមានបុព្វបទ ២ ជាន់ ពាក្យនោះមានកិរិតឧត្តមភាពខ្ពស់ជាងគេបំផុត ។ ឧទាហរណ៍ខាងលើ បញ្ជាក់នូវទស្សនៈបែបនេះក្នុងភាសាខ្មែរបុរាណ ។

៧.  kaṃmratāṅ añ : ជាឋានន្តរនាមមានឧត្តមភាពខ្ពស់ជាងឋានន្តរនាម កំម្រតាង ។ នៅក្នុងសិលាចារឹកសម័យមុនអង្គរមានការប្រើប្រាស់ពាក្យនេះសំរាប់សំគាល់ព្រះសង្ឃជាន់ខ្ពស់ ឬក៏សម្តេចសង្ឃខាងព្រហ្មញ្ញសាសនា ហើយពាក្យនេះមានឧត្តមភាពប្រហាក់ប្រហែលគ្នានឹងពាក្យ :

 po cas añ ( Mon seigneur ) ។

៨.  vraḥ kaṃmratāṅ añ : គឺជាគោរម្យងារដែលមានឧត្តមភាពខ្លាំងជាងគោរម្យងារ កំម្រតាង គឺជាគោរម្យងារសំរាប់សំគាល់អាទិទេពនៅក្នុងព្រហ្មញ្ញ សាសនា ដូចជាព្រះសិវៈ ព្រះវិស្ណុ សំរាប់សំគាល់ព្រះសម្មាសម្ពុទ្ធ ឬព្រះពោធិសត្វ មានព្រះពោធិសត្វលោកេស្វរៈ នៅក្នុងពុទ្ធ-សាសនាមហាយាន ។ ពាក្យនេះ ត្រូវប្រើប្រាស់សំរាប់សំគាល់ព្រះមហាក្សត្រផងដែរ ព្រោះថា ព្រះមហាក្សត្រ ជាតំណាងអាទិទេពនៅលើផែនដី :

 ព្រះមហាក្សត្រ



៩.  yaṅ / yāṅ : ជាពាក្យសំរាប់សំគាល់នូវអាទិ-ទេពរបស់ជនជាតិ អូស្ត្រូ អាស៊ីយ៉ាទិក និងជនជាតិ អូស្ត្រូនេស្យាង មានជនជាតិ មន ខ្មែរ ចាម ឥណ្ឌូនេស៊ី ជ្វា ជាដើម ។ ពាក្យនេះមានប្រើជាញឹកញាប់ នៅក្នុងសិលាចារឹក ចាម ឬជ្វាទៀតផង ។

១០. ប្ុ - ពៅ pu / po : មានន័យថា «ម្ចាស់ ឬព្រះជាម្ចាស់» ឬជាពាក្យសំរាប់សំគាល់មនុស្សដែលគេគោរពនៅសម័យមុនអង្គរ ជាពាក្យមានដើមកំណើតពីពាក្យរបស់ជនជាតិ អូស្ត្រូ អាស៊ីយ៉ាទិក Austro Asiatique ។

១១. ចស៑-ចាស៑cas / cās : នៅក្នុងភាសាខ្មែរបុរាណ ( សម័យមុនអង្គរ មានន័យថា « បូរាណ, មានវ័យចំណាស់ ហើយមានន័យស្របគ្នា នឹងពាក្យសំស្ក្រឹត «ព្រឹទ្ធ» ។ គឺជាពាក្យត្រូវគេប្រើប្រាស់ក្នុងការបង្កើតឋានន្តរនាមព្រះសង្ឃជាន់ខ្ពស់ ជាដើម ។

*II. នៅក្នុងក្រុមនៃវណ្ណៈថ្នាក់ក្រោម CSI តាមសិលាចារឹកសម័យអង្គរ មានប្រើពាក្យ ដូចតទៅ :*

១ / វ- វា va , vā : ពាក្យនេះ ( វ . វា ) មានន័យថា មនុស្សប្រុស ដែលគេប្រើពាក្យដូចតទៅ នាមឈ្មោះមនុស្សជាអ្នកបំរើនៅវត្តអារាម ជាអ្នកធ្វើស្រែចំការ ។ បានសេចក្តីថា ពាក្យ « វ » ត្រូវបានប្រើសំរាប់សំគាល់មនុស្សប្រុសធម្មតា នៅក្នុងសិលាចារឹកសតវត្សទី៦ , ទី៧ នៅក្នុងសិលាចារឹកណាដែលមានប្រើពាក្យ « វា » ពីមុខឈ្មោះមនុស្ស គេសន្និដ្ឋានថា សិលាចារឹកទាំងនោះ មានកាលបរិច្ឆេទ រវាងសតវត្សទី៦ និងទី៧ ។ នៅក្នុងសិលាចារឹកណាដែលមានប្រើពាក្យ « វ » មុខនាមឈ្មោះមនុស្សប្រុស គេអាចសន្និដ្ឋានបានថា សិលាចារឹកនោះមានកាលបរិច្ឆេទនៅសតវត្សទី៧ ទី៨ ។

បានសេចក្តីថា អក្ខរាវិរុទ្ធិ « វ » មានលក្ខណៈបរមបុរាណជាងអក្ខរាវិរុទ្ធិសរសេរដោយ « វា » ។ នៅក្នុងភាសាខ្មែរសម័យបច្ចុប្បន្នពាក្យ « វា » បានបាត់បង់អត្ថន័យដើមរបស់ខ្លួន ( មនុស្សប្រុស ) ហើយពាក្យ « វា » បានប្រែក្លាយទៅជាបុរិសសព្វនាមមួយដ៏សំខាន់សំរាប់សំគាល់មនុស្សផង សត្វផង របស់ឥតវិញ្ញាណផង ព្រមទាំងមតិអវូបិយថែមទៀត ។ ពាក្យនេះមានប្រើនៅក្នុងពាក្យមួយទៀត ដូច

ជាពាក្យ « អាវ៉ា » ។

យោងទៅលើអត្ថន័យដើមរបស់ពាក្យ « វ៉ា » នៅក្នុងប្រវត្តិនៃពាក្យនេះ ពាក្យ « វ៉ា » បានទៅជាពាក្យមួយសំខាន់ សំរាប់សំគាល់ជនជាតិមន - ខ្មែរ ពីរ បី ក្រុម គឺជនជាតិ « va, wa : វ៉ា » ជនជាតិ លវ៉ា lava ជនជាតិ កវ៉ា ka-wa ។ ជនជាតិទាំងនេះរស់នៅភាគខាងជើង និងខាងលិចនៃឧបទ្វីបឥណ្ឌូចិន មាន នៅប្រទេសថៃ និងចិន ។

២ /  ku : នៅសម័យមុនអង្គរ ពាក្យ ku ឬ កូ មានន័យថា « មនុស្សស្រី » ជាពាក្យដែលគេប្រើនៅមុខឈ្មោះមនុស្សស្រី ។ នៅក្នុងភាសាខ្មែរ បច្ចុប្បន្ន គេបានភ្លេចពាក្យ ku ដោយហេតុថាមានពាក្យសំស្ក្រឹត ( ស្ត្រី ) បានមក ជំនួសពាក្យ « កុ » ក៏ប៉ុន្តែ គេអាចសន្និដ្ឋានថា ពាក្យនេះនៅរស់ក្នុងភាសាជិតខាង នៃប្រទេសខ្មែរ គឺវៀតណាម នេះគ្រាន់តែជាការសន្និដ្ឋាន ប៉ុន្តែពុំទាន់មានភស្តុតាង ច្បាស់លាស់ ។

៣ / ជាមួយនឹងពាក្យ  ដែលសំគាល់នូវមនុស្សពេញវ័យ តាម សិលាចារឹកគេឃើញមានការប្រើពាក្យ  kon ( កូន ) នៅពីមុខពាក្យ កុ ឬ វ៉ា

-  : ជាពាក្យសំគាល់នូវកូនស្រី ហើយពាក្យនេះបានត្រូវ គេប្រើពីមុំខនរនាម

-  konva, konvā : ជាពាក្យសំគាល់ក្មេងប្រុស ហើយដែលត្រូវបានគេប្រើពីមុខនរនាម ក្នុងសិលាចារឹកសម័យមុនអង្គរ ។ នៅក្នុង សិលាចារឹកខ្លះគេបានប្រទះឃើញការប្រើពាក្យ :

-  ame ku ម្ដាយរបស់នារី
-  atā ku ឪពុករបស់នារី

ពាក្យ ame, atā ( ម្ដាយ, ឪពុក ) ពាក្យទាំងពីរនេះ ក៏ត្រូវបានគេប្រើនៅមុខនរនាមដទៃទៀតដែរ ។

នៅក្នុងសិលាចារឹកទាំងឡាយសម័យមុនអង្គរ ច្រើនមានរៀបរាប់អំពីនាមឈ្មោះអាទិទេព ព្រះមហាក្សត្រ ព្រះសង្ឃ មន្ត្រី ព្រមទាំងជនសាមញ្ញធម្មតា ដែលស្ថិតនៅក្នុងស្រទាប់នៃពួកខ្ញុំ ហើយសុំកុំច្រឡំន័យរបស់ពាក្យនេះ និងន័យរបស់ពាក្យ « ខ្ញុំ » ( បុរសទី១ ) អោយសោះ ។

ចំណេះដឹងអំពីប្រព័ន្ធ នៃឋានន្តរនាម និងនរនាមសម័យមុនអង្គរ ព្រមទាំងការយល់ដឹងនូវអត្ថាវិវុទ្ធិផ្សេងៗ របស់ពាក្យទាំងនេះ គឺជាការសំរួលមួយដ៏សំខាន់ក្នុងការអាន និងការយល់ដឹងនៃសិលាចារឹក ។

បណ្ឌិត **ឡុង សៀម**
សាស្ត្រាចារ្យសិលាចារឹក និងអក្សរសាស្ត្រ
នៅសាកលវិទ្យាល័យភូមិន្ទ ភ្នំពេញ
ព្រឹទ្ធសហការីវិទ្យាសាស្ត្រ
បណ្ឌិត្យសភាវិទ្យាសាស្ត្រ សហព័ន្ធរុស្ស៊ី

# បញ្ហានៃសិលាចារឹកពីរ សម័យមុនអង្គរ ទើបរកឃើញនៅវត្តព្រៃវែង រាជធានីភ្នំពេញ និងលក្ខណៈប្រវត្តិសាស្ត្រ

ដោយ : លោក វង់ សុធារ៉ា
លោក ឡឹក សាវណ្ណ
កញ្ញា អ៊ួន ភតិនី
ដឹកនាំដោយ សាស្ត្រាចារ្យបណ្ឌិត ឡុង សៀម
ខែ សីហា ១៩៩៦

ប្រវត្តិនៃសិលាចារឹកព្រៃវែង :

តាមសេចក្តីរាយការណ៍របស់និស្សិតឈ្មោះ ជា រស្មី អំពីបញ្ហាសិលាចារឹក នៅវត្តព្រៃវែង ឃុំព្រៃវែង ស្រុកដង្កោ រាជធានីភ្នំពេញ កាលពីដើមខែកុម្ភៈ ឆ្នាំ១៩៩៥ លោកបណ្ឌិតសាស្ត្រាចារ្យ ឡុង សៀម ដែលជាគ្រូបង្រៀនផ្នែកសិលាចារឹកវិទ្យា និងលោកបណ្ឌិត អ៊ីវ ច័ន្ទ ជាសាស្ត្រាចារ្យផ្នែកវិធីសាស្ត្រស្រាវជ្រាវ បានដឹកនាំនិស្សិតមួយក្រុមនៅមហាវិទ្យាល័យប្រវត្តិវិទ្យា ជំនាន់ទី ១៣ ចុះទៅធ្វើការស្រាវជ្រាវដល់ទីកន្លែង ។

ចៅអធិការវត្តព្រះនាម ឈុំ ឈុន គឺជាអ្នកថែរក្សា ការពារផ្ទាំងសិលាចារឹកនេះ បានមានពុទ្ធដីការៀបរាប់អំពីសាវតាររបស់វា និងវត្ថុអារ៉ាម ព្រមទាំងបុរាណវត្ថុផ្សេងៗទៀត ដែលលោកមាន ។ ពោរពេញដោយមនសិការស្រឡាញ់កេរមតិកវប្បធម៌ជាតិ លោកបានខិតខំប្រមែប្រមូលវត្ថុទាំងនោះមករក្សាទុកក្នុងកុដិ

ដែលពីមុនត្រូវបានគេទុកចោលរាយប៉ាយនៅលើដី ឬកប់ក្នុងដី និងក្លាយជាថ្មសំលៀងទៅហើយនោះ ។

ព្រះអង្គបានឱ្យដឹងថា ពីមុនវត្តព្រៃវែងមានឈ្មោះថា « វត្តអង្គចក » ដែលមានទីតាំងវិហារនៅទល់មុខឈៀងពាយ័ព្យ នៃវត្តបច្ចុប្បន្ន ពោលគឺស្ថិតនៅមាត់ស្រះ « អង្គ » ផ្នែកខាងលិច ។ ប៉ុន្តែដីទួលអាវាសវត្តអង្គចកសព្វថ្ងៃត្រូវបានអ្នកស្រុកឈ្វៀសឆាយពង្រាបធ្វើវាលស្រែអស់ហើយ ។

ចំណែកទីតាំងនៃព្រះវិហារសព្វថ្ងៃ ទើបតែស្ថាបនាឡើងនៅឆ្នាំ ១៩៥៩ នៅលើខឿន នៃប្រាសាទចាស់ ដែលសព្វថ្ងៃមានសំណល់ថ្មបាយក្រៀមជាច្រើន ។

ក្រៅពីនោះទឹកដីជាទ្រព្យសម្បត្តិរបស់វត្តអារ៉ាមដែលគេហៅថា « ស្រែគរុភ័ណ្ឌ » នៅមាននៅឡើយរហូតមកដល់ទសវត្សឆ្នាំ ១៩៦០ ។

ទាក់ទងនឹងសិលាចារឹក លោកមានពុទ្ធដីកាថា អ្នកស្រាវជ្រាវបារាំងធ្លាប់មកសុំយកពីព្រះចៅអធិការមុនៗ នោះដែរ តែព្រះអង្គមិនព្រមឱ្យទោះបីជាអ្នកស្រាវជ្រាវទាំងនោះសន្យាថានឹងសាងសង់ព្រះវិហារឱ្យយ៉ាងណាក៏ដោយ ។ ម្យ៉ាងទៀតសិលាចារឹកនៅក្នុងវត្តនេះមានចំនួន ៤ ផ្ទាំងសុទ្ធសឹងជាអក្សរមុនសម័យអង្គរ ប៉ុន្តែនៅសម័យកាលសង្គ្រាមធ្វើឱ្យបាត់ផ្ទាំងធំមួយដែលចារជាកំណាព្យសំស្ក្រឹត ហើយលោកមានពុទ្ធដីកាថា សម្តេចសង្ឃរាជ ជួន ណាត ធ្លាប់បានអានអត្ថបទនោះ ក្នុងឱកាសបុណ្យបញ្ចុះសីមា ។

ហេតុនេះហើយទើបសព្វថ្ងៃ គេឃើញសល់តែសិលាចារឹកចំនួន ៣ ផ្ទាំងដែលមាន ៤ អត្ថបទ ។ ផ្ទាំងនិមួយៗ ត្រូវបានចារឡើងក្នុងសម័យកាលខុសៗគ្នា ។

ព្រះចៅអធិការវត្តបានអនុញ្ញាតឱ្យក្រុមនិស្សិតថត និងផ្តិតយកមកសិក្សានៅមហាវិទ្យាល័យ ។

ក្រោយមកលោកសាស្ត្រាចារ្យ ឡុង សៀម បានដាក់ប្រធានបទសិក្សា

អំពីសិលាចារឹកវត្តព្រៃវែង សំរាប់និស្សិតទូទាំងថ្នាក់ ។

ដោយសារចំណេះដឹងផ្នែកនេះនៅមានកំរិត គ្មាននិស្សិតណាម្នាក់អាចបកប្រែអត្ថបទជាភាសាខ្មែរបានឡើយ ការសិក្សាត្រូវបរាជ័យ ។

ដោយយល់ឃើញនូវសារសំខាន់នៃសិលាចារឹកនេះ យើងខ្ញុំក៏សំរេចចិត្តថា និងធ្វើការសាកល្បងសិក្សាបកប្រែលើអត្ថបទនេះម្តងទៀត ដើម្បីយកស្នាដៃនេះ ទៅចូលរួមក្នុងសន្និសីទអន្តរជាតិស្តីអំពីខេមរវិទ្យា ( International Conference on Khmer Studies ) ពីថ្ងៃទី ២៦ ដល់ ៣០ សីហា ១៩៩៦ ។

ក្រោយមកនៅថ្ងៃ ០៧ សីហា ១៩៩៦ យើងខ្ញុំបានទៅធ្វើការសំភាសន៍ជាមួយព្រះចៅអធិការវត្ត និងសុំអនុញ្ញាតផ្តិតសិលាចារឹកនោះម្តងទៀត ។

យើងខ្ញុំក៏បានធ្វើការសិក្សាវិភាគ ក្រោយពីបានបកប្រែអត្ថបទពីរជាភាសាខ្មែរ ។ ចំណែកអត្ថបទជាភាសាសំស្ក្រឹតយើងមិនមានសមត្ថភាពបកប្រែ សូមរក្សាទុកសិន ។

សូមបញ្ជាក់ថា សិលាចារឹកទាំង ៣ ផ្ទាំងនេះ មានពីរផ្ទាំងជាសិលាចារឹកថ្មីមិនទាន់ត្រូវបានអ្នកស្រាវជ្រាវណារកឃើញលើកយកទៅសិក្សាបោះពុម្ពផ្សាយនៅឡើយ ។ លើកលែងតែសិលាចារឹកដែលសព្វថ្ងៃគេចាត់ទុក ជារូបអ្នកតានៅភាគខាងកើតនៃអាវាសវត្តព្រៃវែងសព្វថ្ងៃ ទើបត្រូវបានលោក G. Cœdès ចុះក្នុងបញ្ជី K ៨០ ផ្សាយក្នុងសៀវភៅ IC. G. C. VI, ៣ អត្ថបទមានសេចក្តីជាអាទិ៍ថា : « អត្ថបទសំស្ក្រឹតចារបន្ទាប់ពីសេចក្តីបួងសួងមួយនៅសម្ភុ ។ ព្រះមហាក្សត្រព្រះនាម ឥសានវរ្ម័ន ជាអ្នកត្រួតត្រាលើនគរបី ( Possesseur de trois villes ) មានមូលនិធិ ( le fondations ) របស់ វិទ្យាទេវ ដែលជាអ្នកមានដីសំបើមម្នាក់បានឱ្យដល់អាស្រមនូវមុខជំនូននិមួយ១ គឺក្ញុំបំរើ ( esclaves ) សត្វពាហនៈ ( bétail ) និងទឹកដីច្បារដំណាំ ។

អត្ថបទជាភាសាខ្មែរនិយាយពិស្តារនូវអំណោយតាមរិទ្យាទេវ ដែលឱ្យក្ញុំប្រុស ( វា ) រស់នៅក្នុងអាវាសនៃអាស្រម ក្ញុំបំរើដទៃទៀតមានក្ញុំស្រី ( កុ ) ពី ៨ ទៅ ៩ នាក់ និងក្ញុំប្រុសម្នាក់ មានគោសំរាប់ទឹម ដើមស្លា និងស្រែមួយ ។

ចុងអត្ថបទមានឈ្មោះប្រមាណ មហាត្មទ ដែលមានន័យថា « ភូមិភាគមហាត្មទ ( le territoire de Mahātmad ) ។ »

កំណត់សំគាល់ទីតាំងភូមិសាស្ត្រ និងភិនភាគសិលាចារឹក

វត្តព្រៃវែងនៅក្នុងភូមិព្រៃវែង ឃុំព្រៃវែង ស្រុកដង្កោ រាជធានីភ្នំពេញ មានចំងាយ ១៧ គ.ម ពីផ្សារពោធិចិនតុង តាំងនៅភាគខាងកើតនៃផ្លូវជាតិលេខ ៣ ។ ផ្លូវទៅកាន់វត្តនេះ នៅពេលយើងធ្វើដំណើរតាមផ្លូវជាតិលេខ ៣ ទៅដល់វត្តស្លែង ត្រូវបត់ចូលតាមផ្លូវលំមួយខាងឆ្វេងដៃ ( ទិសចេញពីភ្នំពេញ ) ប្រមាណ ១៨០០ ម ។ វត្តមួយនៅខាងស្តាំដៃមានដើមអំពិលចាស់ដ៏ធំមួយនៅខាងមុខ និងព្រះវិហារដ៏ខ្ពស់នោះ គឺជាវត្តព្រៃវែង ដែលពីអតីតកាលគេហៅថា វត្តអង្គចក ។

សិលាចារឹក ដែលមាននៅទីនោះសព្វថ្ងៃមានចំនួន ៣ ផ្ទាំង ជាភាសាខ្មែរមានពីរអត្ថបទជាភាសាសំស្ក្រឹតពីរអត្ថបទ ក្រោមការគ្រប់គ្រងថែរក្សារបស់ព្រះចៅអធិការវត្តព្រះនាម ឈុំ ឈុន ។ ប៉ុន្តែសិលាចារឹកដែលថ្មីស្រឡាងនោះ មាន ២ ផ្ទាំង ។

+ ផ្ទាំងទី ១ : ចារលើសិលាស្តម្ភ ( stèle ) ទំហំ : កំពស់ ០,៨៧ ម បណ្តោយ ០,៣៤ ម កំរាស់ ០,០៧៥ ម ។ ផ្ទាំងនេះចារឹកអក្សរទាំងសងខាងផ្ទៃកខាងមុខភាសាសំស្ក្រឹតមានអក្សរ ១២ បន្ទាត់ ផ្ទៃកខាងក្រោយភាសាខ្មែរ មានអក្សរ ២០ បន្ទាត់ ផ្នែកនៃផ្ទៃខាងលើអត្ថបទសំស្ក្រឹត មានគំនូរត្របកផ្កាឈូកបើកស្រទាប់ទ្រកងចក្ររាងពងក្រពើ ។ ផ្ទាំងសិលាចារឹកបែកជាពីរចំរៀកដាច់ពីគ្នា ចំរៀកធំត្រូវបាក់ជាពីរកំណាត់ៗ ខាងក្រោមត្រូវបាត់ នៅសល់កំណាត់ខាងលើ ដែលត្រូវលប់

អក្សរសំស្ក្រឹតមួយចំនួនដោយសារគេយកកាំបិទទៅសំលៀង ព្រោះវាជាប្រភេទថ្មភក់សំរាប់សំលៀងស្រាប់ ។

+ ផ្ទាំងទី ២ :ចារលើសិលាស្ដម្ភ ( stèle ) ដែរ មានទំហំ : កំពស់ 0,៨៦ ម បណ្ដោយ 0,៥៣ ម កំរាស់ 0,0៩៥ ម អត្ថបទចារឹកជាភាសាខ្មែរមាន ១៦ បន្ទាត់ លើថ្មភក់ខ្ចីមពណ៌ស្លែចាស់ ។ ផ្ទាំងចារឹក បាក់ជាពីរកំណាត់ដាច់ពីរគ្នា ដែលជាហេតុធ្វើឱ្យបាត់បង់អក្សរមួយចំនួននៅបន្ទាត់ទី ១២ , ១៣ , ១៤ , ១៥ ។

## អត្ថបទសិលាចារឹកវត្តព្រៃវែង

## Text in latin translitterations

### Text I

1 - .... [ bhamasarvva ta gui vraḥ kamratāṅ añ ]
2 - ..................... gui kāla tāṅ añ
3 - ...........pratiṣṭha vraḥ kamratāṅ añ çrī caṇḍa
4 - kātyāyinī droṅ vraḥ mahāgaṇapatī saṃ paribhoga-dro-
5 - ṅ vraḥ kamratāṅ añ çrī aṃvrātakeçvara
6 - [ bakha ] hver aṃnoy tāṅ añ ai ta vraḥ çrī
7 - caṇḍakātyāyinī kantai tāṅ añ devī añ
8 - *gui ta yajaman ta vraḥ taṅai vraḥ vaṅe jnau da*
9 - nhuṃ pañjut cuḥ saṃvaḥ vraḥ kū panlāṅ tel
10 - oy ta vraḥ kñuṃ aṃnoy ai ta vraḥ vā kandā
11 - s vā tvaḥ .vā vaṅāmansot .vā vaṅā añ kā
12 - la asanna .vā kanseṅ vā kanto ...
13 - ñcoṅ .ku dmoc ko [ n ] ...............
14 - tmī .ku seṅ nā-a-ai ......................
15 - vinās panhem . [ ku ] .................
16 - ku plas guṇe . [ ku ] ....................

17 - ku paliha̤ṭṭa . [ ku ] ....................
18 - ku arasa kon 2 ku ........................
19 - vā tmul ....................................
20 - [ tmur ] ..................................

Text ( II )

1 - ...... çaka ājñā vraḥ kaṃmratāṅ añ ...
2 - vraḥ kaṃmratāṅ añ çrī tila keçvara punya mrat [āñ]
3 - kumārasvāmi doṅ vraḥ kaṃmratāṅ añ Çrī rudrama hālaya
4 - puṇya tāṅ rudradāsa doṅ gi vnok phoṅ ṭa nu poñ çratakirtti
5 - ta amā mahāvikrāntakesarī nu paṃre muh han gi tel prasāda
6 - aṃvi kanloṅṅ ta mahāvikrāntakesarī nu paṃre ta gi maddhyama pa-
7 - ricāraka gi srepiṅ aṃ lac le lon vrañai vnur pumaṅ stuk
8 - kanleṅ prasān sre cdiṅ piṅ poñ vrau sre vaḥ vuṇ
9 - sre trey vrai krāy stuk slāṅ sre vraḥ suvarṇṇa liṅga-pu
10 - ṇya tāṅ içvara sre kandac tel poñ çāp tve sre
11 - sre jeṅ toc sre piṅ taṃ paḥ stuk kracap sre cdiṅ maṃsār ra-
12 - hvat man vraḥ kaṃmratāṅ añ ta dau çivapura pra-sāda ta ge gi
13 - rudradāsa ta aji mahāvikrāntakesarī gi tel dhūli jeṅ vraḥ kaṃ
14 - martāṅ añ prasāda ta mahāvikrāntakesarī nu-paṃre ta gi man
15 - paricāraka ge ta dap gi ge ta sak gi ge ta pre roḥ

gi ge cok
16 - ājñā vraḥ kaṃmratāṅ añ ge tel oy daṇḍya //

អត្ថបទសិលាចារឹកវត្តព្រៃវែង ជាអក្សរខ្មែរសម័យថ្មី

អត្ថបទ I

១ . . [ ភ ម ស វ្វ ត គុ វ្រះកម្រតាង៑អញ ]-
២ . . . . . . . . គុ៑កាលតាង៑អញ-
៣ . . . . . . . ប្រតិមួ វ្រះកម្រតាង៑ អញ ត្រីចណ្ឌ
៤ . កាត្យាយិនី ទ្រោង៑ វ្រះ មហាគណបតី សំបរិភោគ ទ្រោ
៥ . ង៑ វ្រះកម្រតាង៑ អញ ត្រី អំវ្រាតកេត្វរ
៦ . [ ព ខ ] ហ្វេរ៑ អំនោយ៑ តាង៑ អញ ព្វតវ្រះ ត្រី
៧ . ចណ្ឌកាត្យាយិនី កន្តែ តាង៑ អញ ទេវី អញ
៨ . គុ៑ ត យជមាន តវ្រះ តង៉ៃ វ្រះ វង៉ៃ ជ្មោ ទ
៩ . ន្លុំ បញ្ចុត៑ ចុះសំវះ វ្រះ កុ បន្លាង៑ តេលិ
១០ . ឱយ៑ តវ្រះក្នុំ អំនោយ៑ ព្វ តវ្រះ វា កន្ត
១១ . ស៑ វា ត្វះ . វាវង៉ាមន្ស្យោត៑ . វាវង៉ា អញ កា
១២ . ល អសន្ន . វាកន្សេង៑ វា កន្តោ . . . .
១៣ . ញោង៑ . កុ ទ្មោច៑ កោ [ និ ] . . . . .
១៤ . ត្មី . កុសេង៑នាអៃ . . . . . . . . . .
១៥ . វិនាស៑ បន្ទ្មែ . [ កុ ] . . . . . . . . .
១៦ . កុ ប្លស៑ គុណោ. [ កុ ] . . . . . . . .
១៧ . កុ បលិហាដ្ត . [ កុ ] . . . . . . .
១៨ . កុ អរស កោនិ ២ កុ . . . . . . . .

១៩ . វា ត្មលិ - - - - - - - - - - - - - - - -
២០ . - - - [ ត្មរិៈ ] - - - - - - - - - - -

## អត្ថបទជាភាសាខ្មែរសម័យថ្មី

### អត្ថបទ II

១ . ៚ក អាជ្ញា វ្រះកំម្រតាង៑ អញ ..
២ . វ្រះកំម្រតាង៑ អញ ក្រិតិលកេក្ស បុន្យ ម្រតា [ ញ ]
៣ . កុមារស្វាមិ ទោង៑ វ្រះកំម្រតាង៑ អញ ក្សុំទ្រមហាលយ
៤ . បុណ្យតាង៑ វុទ្រទាស ទោង៑គិ ឝ្មោក៑ ផោង្គ នុបោញ ក្រតកីត្តិ
៥ . ត រ្យា មហាវិក្រាន្តកេសរី នុ បំរេ មុហ្វូនិ គិ តេលិ ប្រសាទ
៦ . អរិកន្លោង្វ ត មហាវិក្រាន្តកេសរី នុ បំរេ ត គិ មឡ្យម ប
៧ . វិចារក គិ ស្រេ បិង៑ អំលចិ លេ លោនិវ្រញៃ វ្នុំ បុមង៑ ស្តុក៑
៨ . កន្លេង៑ប្រសានិ ស្រេ ច្ចិង៑ បិង៑ បោញ វ្រៅ ស្រេ វះវុណិ
៩ . ស្រេ ត្រេយ៑វ្រៃក្រាយ៑ ស្តុក៑ស្លាង៑ ស្រេវ្រះសុវណ្ណលិង្គ បុ
១០ . ណ្យ តាង៑ ឥក្ស ស្រេ កន្ទិចិ តេលិ បោញ ករុបិ ត្វេ ស្រេ
១១ . ស្រេ ជេង្គោចិ ស្រេ បិង៑តំបះ ស្តុក៑ ក្រចបិ ស្រេច្ចិង៑មំសារិ រ
១២ . ហ្វតិ មនិ វ្រះកំម្រតាង៑ អញ តទៅអំរបុរ ប្រសាទ ត [ គេ គិ ]
១៣ . វុទ្រ ទាស តអជិ មហាវិក្រាន្តកេសរីតិ តេលិ ធ្វលិ ៖ [ជង៑វ្រះកំ]
១៤ . ម្រតាង៑ អញប្រសាទ ត មហាវិក្រាន្តកេសរី នុ បំរេ តគិ ម [និ]
១៥ . បរិចារក គេតទបិ គិគេ តសក៑ គិគេតប្រេរោះ គិគេ ចោក៑
១៦ . អាជ្ញា វ្រះកំម្រតាង៑ អញ គេ តេលិ ឱយ៑ ទណ្ឌ ។

## អត្ថបទដើមទី ១



អត្ថបទដើមទី ២

[illegible]

បកប្រែសេចក្ដីនៃអត្ថបទទី ១

[ ...... សព្វដល់ទីនេះ វ្រះ កំម្រតាងអញ .... ]

....... នេះ កាលតាងអញ-

..... ( ប្រតិស្ឋ ) ធ្វើអធិស្ឋានព្រះកម្រតាង អញ ( ព្រះទេវី ) ស្រីចណ្ឌ

កាត្យាយិនី ព្រមទាំង ព្រះមហាគណបតី បន្សំម្ហូលនិធិព្រមទាំង

ព្រះអាទិទេពក្រី អំវ្រាតកេត្វ

... ប្រគេនអំណោយតាងអញ ឮដ៏ព្រះទេវី

ចណ្ឌកាត្យាយិនី ស្ត្រីកុំបំរើរបស់តាងអញទេវីអញ

នេះគឺ បូជាដល់ព្រះនៅថ្ងៃព្រះនូវផ្កាជ្មៅក្រអូប

ចង្ហាន់ ( ម្ហូបអាហារ ) ចុះសំពះព្រះ ( វ្រះ ) កុ បន្លាងដែល

បានឱ្យដល់ព្រះ កុំបំរើដទៃទៀតជាអំណោយឮដ៏ព្រះ

វា កន្ទាស . វាត្វះ . វា វងាមនេ្យាត . វា វងារអញកាល-

អសន្ទ . វា កន្សៀង . វា កន្ដោ ...

ញោង . កុ ទ្មោចកោន ...

ត្មី . កុ សេង នាអៃ ...

វិនាសបន្ទើ . កុ ...

កុប្លស គុណោ . កុ ...

កុ បលិ ហដ្ឋ . កុ ...

កុ អរស កោន កុ ... ២

វា ត្មល ...

.... [ ត្មរ ] ....

## បកប្រែសេចក្ដីនៃអត្ថបទទី ២

... គក អាជ្ញាព្រះមហាក្សត្រ

ព្រះអាទិទេព ត្រី តិលកេត្វរជាអំណោយម្រតាញ

កុមារស្វាមិ និង ( ព្រមទាំង ) ព្រះវិហារត្រីរុទ្រមហាលយ

អំណោយ តាងរុទ្រទាស អស់ពួកក្ញុំបំរើទាំងនេះផង

បោញក្រឝគីត្តិ ជាមាមហារិក្រាន្តកេសរីន្ធវក្ញុំបំរើទល់នឹងមុខនេះ ដែលជាព្រះរាជទានអំពីព្រះមាតាដល់មហារិក្រាន្តកេសរី ហើយអ្នកបំរើនៅទីនេះជាមធ្យមឧបការី ( ជំនួយការកណ្ដាល ) នៅទីនេះ ស្រែបិងអំលេចលេ លោនវ្រញ្ញៃ ផ្ទរ បុមង ស្ដុក កន្លេងប្រសាន ស្រែ ស្ទឹង បឹងបោញ ជ្រៅ ស្រែ វះរុណ ស្រែត្រើយព្រៃក្រាយ ស្ដុក ស្លែង ស្រែ ព្រះសុវណ្ណលិង្គ

អំណោយតាង ឥត្វរ ស្រែកន្ទេច ដែលបោញ គាបធ្វើស្រែ

ស្រែជើងតោច ស្រែ បឹង តំបះ ស្ដុកក្រចាប់ ស្រែស្ទឹងមំសារ

រហូតដល់មាន ព្រះមហាក្សត្រយាងទៅកាន់ឝិវបុរ ព្រះរាជទានដល់ពួកគេទាំងនេះជាក្ញុំបំរើព្រះរុទ្រ គឺអធិមហារិក្រាន្តកេសរីនេះ ដែលព្រះមហាមហាក្សត្រិយានីព្រះរាជទាន ដែលមហារិក្រាន្តកេសរីនិងអ្នកបំរើនៅទីនេះមានឧបការី ( ឬឆ្នាំ ) ពួកគេដែលរារាំងនេះ, ពួកគេដែលលួចនេះ ពួកគេដែលកំពុងបំរើនេះ ពួកគេត្រូវផ្ដន្ទាទោស ( ដោយ ) អាជ្ញាព្រះមហាក្សត្រ ពួកគេដែលត្រូវឱ្យជាប់ទោស ។

( *នៅមាន ត* )

# ល្បងពិចារណា
# អំពី
# សិទ្ធិមនុស្ស និង ពុទ្ធសាសនា

( ត-ចប់ )

រៀបរៀងដោយ **ឈន អៀម**

នៅក្នុងទំនាក់ទំនងទៅវិញទៅមករវាងមនុស្ស និងមនុស្សវិញ, ពុទ្ធ-សាសនា បានដើរហួសឆ្ងាយពី « ស្មារតី នៃភាតរភាព » - ដ៏ជាទស្សនៈមូលដ្ឋាននៅក្នុងមាត្រាទី១ នេះ នៃសេចក្តីប្រកាសជាសកល -ទៅដល់អាណាចក្រ នៃ *មេត្តា* ឬ មេត្រី ពោលគឺ មិត្តភាពជាសកល ឬមេត្តាករុណា ( Loving kindness ) ។ អត្ថ-ន័យ «មេត្តា» ឬ « មេត្តាករុណា » ឱបក្រសោប និងគ្របដណ្តប់លើគ្រប់រូបភាពនៃសព្វសត្វមានជីវិត, ហើយប្រាកដជាមានវិសាលភាពទូលំទូលាយជាងទស្សនាទាន នៃ « ភាតរភាព » នៅក្នុងមាត្រា ១ នៃសេចក្តីប្រកាសនេះផង ។ ជាងនេះទៀត, ស័ព្ទ « ភាតរភាព » នេះ ពិតជាសំដៅទៅរកការទទួលស្គាល់ថាមាន *មាតុភាព ឬ បិតុភាព* ( ភាពមានឪពុក - ម្តាយ ) រួមគ្នាហើយ, ដោយហេតុនេះ ស័ព្ទនេះចង្អុលន័យនៅតែក្នុងរង្វង់ណាមួយនៃផ្នែកមនុស្សជាតិប៉ុណ្ណោះ, ដែលតាមពិតទៅ នេះពុំមែនជាបំណងប្រាថ្នានៅក្នុងមាត្រានេះទេ, ប៉ុន្តែ នេះជាមតិយោបល់ដែលពុំសមស្របនឹងទស្សនៈទូលំទូលាយរបស់ពុទ្ធសាសនា ហើយពុទ្ធសាសនា ពុំអាចទទួល

យកអត្ថន័យក្នុងវង្វង់នេះបានឡើយ ។ « ទស្សនៈរបស់ពុទ្ធសាសនាទាំងនៅក្នុងក្របខណ្ឌសាសនា ក៏ដូចជានៅក្នុងក្របខណ្ឌទស្សនវិជ្ជា, ចាប់ផ្ដើមពីឫសគល់យល់ដឹងដ៏ជ្រាលជ្រៅថា ជីវិតទាំងអស់ សុទ្ធតែមានចំណង់ដើម្បីរក្សាការពារអត្ថិភាពរបស់ខ្លួនអោយបានឋិតថេរ ហើយធ្វើអោយអត្ថិភាពនេះបានទទួលផាសុកភាព និងមានសុភមង្គល ។ នៅក្នុងជីវភាពសាសនារបស់ព្រះពុទ្ធ, ទស្សនវិជ្ជាស្ដីពី *មេត្រី* និង *អហិង្សា,* ដ៏ជាសេចក្ដីស្រឡាញ់សកល និងជាការមិនរំលោភបំពាន, មានសុពលភាពរបស់ខ្លួនហូរចេញមកពីជំហរនេះ ។ ដោយហេតុនេះ, សូម្បីនៅត្រឹមថ្នាក់សង្គមក៏ដោយ, ក៏វាជាការទទួលខុសត្រូវរបស់សមាជិកសង្គមគ្រប់រូបដែរ ចាប់តាំងពីប្រមុខរដ្ឋចុះមក ដើម្បីជួយបំពេញភារកិច្ចដោយឥតគិតការនឿយហត់ សំដៅសំរេចគោលការណ៍ដ៏ប្រសើរនេះ ពោលគឺ ធ្វើអោយសមាជិកសង្គមទាំងអស់ មានសុខុមាលភាព និង សុភមង្គល ។

ប៉ុន្តែ ចំពោះសមភាព ( equality ) វិញ, គេគប្បីយល់ថា សមភាពនៅក្នុងការអនុវត្តជាក់ស្ដែងក្នុងពេលកន្លងមកហើយ ក៏ដូចជាក្នុងពេលបច្ចុប្បន្ន គឺឋិតនៅក្នុងកំរិតក្របខណ្ឌមួយ ។ ការប្រកាសថា មនុស្សទាំងអស់មានភាពស្មើគ្នា គឺមានភាពប្រាកដប្រជានៅក្នុងច្បាប់ ឬលើក្រដាសច្រើនជាងការអនុវត្តជាក់ស្ដែង ។ តាមពិតទៅ វាមានន័យថា នៅក្នុងទិដ្ឋភាពផ្សេងៗជាច្រើន គេពុំគប្បីធ្វើការបែងចែកអោយមានសភាពខុសគ្នាណាមួយចំពោះមនុស្សទាំងអស់ទេ បើយោងតាមអត្ថបទពុទ្ធសាសនា ដូចជា *បុគ្គលវេមត្តតា* ជាដើម ។ តែថា សមភាព វាអាស្រ័យលើគុណសម្បត្តិ និងលើកាលៈទេសៈក្នុងការរស់នៅនៃមនុស្សផងដែរ ។

នៅពេលទទួលស្គាល់ថា សមភាពមានកំរិតក្របខណ្ឌដូចនេះ, ពុទ្ធសាសនា បានកំណត់អោយមានសមភាពជាគ្រឹះមួយ រវាងមនុស្សទាំងអស់ ដោយយោងទៅតាមធម្មជាតិជាសារវន្តរបស់មនុស្ស, ហើយដោយហេតុនេះ ពុទ្ធសាសនា

មើលឃើញមនុស្សទាំងអស់ *ជាមនុស្សមានភាពស្មើគ្នានៅក្នុងសេចក្តីថ្លៃថ្នូរ និងក្នុងសិទ្ធិទាំងឡាយ* ។ សមភាពជាគ្រឹះទាក់ទងនឹងធម្មជាតិជាសារវន្តរបស់មនុស្សនេះ,តាមទស្សនៈពុទ្ធសាសនា-ថាបានផុះចេញមកអំពីកត្តាមួយចំនួន ។ ក្នុងបណ្តាកត្តាទាំងអស់នោះ កត្តាសំខាន់ជាងគេបំផុត គឺកត្តាជីវសាស្ត្រ និងកត្តានរវិទ្យា ( Biological and anthropological factors ) ។ កត្តាជីវសាស្ត្រ គឺជាទឡ្ហីករណ៍ដែលអះអាងថា មនុស្សជាតិ ( Homo sapiens ) កកើតឡើងជាប្រភេទតែមួយគត់ ដែលខុសប្លែកពីប្រភេទរបស់ពពួកសត្វ និងពពួកបុប្ផជាតិផ្សេងៗ ។ តាមសេចក្តីសន្និដ្ឋាន ដែលបានមកពីការសង្កេតស្រាវជ្រាវ ឬពីបច្ចេកទេស-វិទ្យាសាស្ត្រនៅក្នុងមន្ទីរពិសោធន៍, គេបានអះអាងថា សេចក្តីសន្និដ្ឋាននោះ ស្របទៅនឹងទស្សនៈជីវសាស្ត្រសម័យថ្មី ដែលបង្កើតជាទស្សនៈស្តីពីសមភាពជាមូលដ្ឋាននៃមនុស្ស ។ និយាយអំពីភាពផ្សេងគ្នារវាង « មនុស្ស » និង « មនុស្ស », គម្ពីរសុត្តនិបាត និយាយថា, គឺនិយាយជាពាក្យសំដីប្រជាប្រិយទេ «*វោហារញ្ច មនុស្សេសុ សមញ្ញាយ បវុច្ចតិ* » ។ ទឡ្ហីករណ៍នរវិទ្យា ត្រូវបាន*អគ្គញ្ញសូត្រ* នៃគម្ពីរទីឃនិកាយ លើកយកមកអធិប្បាយយ៉ាងល្អិតល្អន់ ដោយបាននិយាយថា កាលពីដើមទី មនុស្សទាំងអស់ «ដូចៗគ្នា ហើយគ្មានខុសគ្នាទេ» *(អញ្ញេសំ សទិសានញ្ញេវ នោ អសទិសានំ)* ។ ព្រះសូត្រនេះ បានបន្ថែមទៀតថា នេះគឺជាក្រឹត្យក្រមសកល, ហើយគ្មានអ្វីផ្ទុយទៅនឹងក្រឹត្យក្រមនេះឡើយ ។ ព្រះសូត្របានអធិប្បាយបន្តទៀតថា « ការផ្សេងគ្នាខាងសង្គម បានកើតមានឡើងនៅក្នុងសង្គម ដែលមានការចាត់តាំងតាមរយៈការបែងចែកពលកម្ម ដ៏ជាលក្ខខណ្ឌចាំបាច់សម្រាប់ការរស់រានរបស់សង្គមខ្លួនឯងផ្ទាល់ រហូតដល់បង្កើតទៅជាកិច្ចសន្យាសង្គម និងកិច្ចសន្យារដ្ឋាភិបាល ដែលផ្អែកលើមតិប្រជាធិបតេយ្យ ។ មតិប្រជាធិបតេយ្យនេះ ឆ្លុះបញ្ចាំងចេញជាន័យនៃសមភាព ដែលគប្បីឋិតថេរនៅក្នុងចំណោមមនុស្ស ។ តាមពិតទៅ, ពុទ្ធសាសនាប្រហែលជាសាសនា

ដំបូងគេបំផុត ក្នុងចំណោមសាសនាទាំងឡាយក្នុងពិភពលោក ដែលបានទទួលស្គាល់សមភាពជាមូលដ្ឋាននៃមនុស្សគ្រប់រូប, បើទោះបីមនុស្សទាំងនោះឋិតនៅក្នុងសហៈគមន៍ណាមួយក៏ដោយ ។ ការទទួលស្គាល់សមភាពមនុស្សគ្រប់រូបនេះ គឺនៅក្នុងន័យដែលថាធម្មជាតិជាសារវន្តរបស់មនុស្ស គឺដដែលដូចគ្នា ទោះបីជាមានភាពផ្សេងៗគ្នាទៅតាមបុគ្គលម្នាក់ៗក៏ដោយ, ដូចជាបុគ្គលខ្លះមានតំណពូជផ្សេង, មានបរិដ្ឋានដោយឡែក និងមានកត្តាដទៃទៀត ខុសៗគ្នា - ល - ។

ន័យនៃសមភាពនេះ ត្រូវបានពង្រឹងថែមទៀតដោយទស្សនៈពុទ្ធសាសនាដែលប្រកាន់ថា មនុស្សគ្រប់រូប នៅទីបំផុតទៅ ត្រូវប្រឈមមុខនឹងបាតុភូតជាមូលៈដ្ឋានដូចគ្នា គឺបាតុភូត ជាតិ ( កំណើត ), ជរា និងការរលាយរលត់រូប ដែលលោកអោយឈ្មោះថាជាអរិយសច្ចៈទីមួយ ។ នៅពេលជាមួយគ្នានេះ មនុស្សគ្រប់រូប ត្រូវឋិតក្នុងជំហរមួយ ដើម្បីជំនះបញ្ហាទាំងអស់នេះ ដោយខិតខំព្យាយាមធ្វើអោយសំរេចនូវគុណធម៌ក៏រិតខ្ពស់បំផុត ខាងសីលធម៌ និងខាងបញ្ញាស្មារតី តាមរយៈការធ្វើអភិវឌ្ឍសក្តានុភាពរបស់មនុស្ស ។ ជីវិតរស់នៅរបស់មនុស្ស ត្រូវបានតាំងនៅក្នុងសង្សារចក្រ នៃការកើត-ស្លាប់ ហើយក៏មានតែមនុស្សទេ ដែលមានភ័ព្វសំណាងអាចឆ្លងផុតពីភាពសោកសៅនៃជីវិត ទៅកាន់ព្រះនិព្វានបាន - ដ៏ជាបរមសុខ ដ៏ក្រៃលែងនោះ ។ មនុស្សមានភាពស្មើគ្នា ( សមភាព ) នៅក្នុងន័យដែលថា មនុស្សត្រូវប្រឈមមុខចំពោះបញ្ហាជាមូលដ្ឋានដូចគ្នា ហើយមានសិទ្ធិរួមគ្នាតែមួយ គឺមានសក្តាៈនុភាពដើម្បីសំរេចបាននូវគុណធម៌ដ៏ខ្ពស់បំផុត គឺព្រះនិព្វាន ។

មាត្រាទី ២ - មនុស្សម្នាក់ៗ មានសិទ្ធិ និងសេរីភាព ដូចបានចែងនៅក្នុងសេចក្តីប្រកាសនេះ, ដោយពុំមានការរើសអើងអ្វីឡើយ, ដូចជាពូជជាតិ, ពណ៌ស្បែក, ភេទ, ភាសា, សាសនា, មតិនយោបាយ ឬមតិផ្សេងទៀត, ដើមកំណើតឬសង្គមដើម, កម្មសិទ្ធិ, កំណើតឬស្ថានភាពផ្សេងទៀត ។

ជាងនេះទៀត, គ្មានការប្លែកគ្នាណាមួយអាចត្រូវបានគេបង្កបង្កើតឡើង នៅលើមូលដ្ឋាន នៃស្ថានភាពនយោបាយ, យុត្តាធិការ ឬអន្តរជាតិ របស់ប្រទេស ឬដែនដីរបស់បុគ្គលនោះទេ, ទោះបីប្រទេស ឬដែនដីនោះមានឯករាជ្យ, ជាសមាគតរដ្ឋ, ជារដ្ឋគ្មានស្វ័យភាព ឬជារដ្ឋនៅក្រោមក្របខណ្ឌអធិបតេយ្យបែបណាមួយ ក៏ដោយ ។

មាត្រាទី ២ ហូរចេញមកពីគោលការណ៍ដូចបានចែងនៅក្នុងមាត្រាទី១, ហើយក៏ជាគ្រឹះមូលដ្ឋានសម្រាប់មាត្រាដទៃទៀតទាំងអស់ ។ មាត្រាទី២ ក៏ជាគ្រឹះរបស់សេចក្តីប្រកាស ( the Declaration ), ចាត់ទុកស្មើនឹងកថាមុខរបស់សេចក្តីប្រកាសនោះ ។ កថាមុខបានបញ្ចូលវិវិធភាព ( ភាពផ្សេងៗគ្នា ) នៅក្នុងស្ថាន-ភាពរបស់មនុស្ស, ដែលនៅក្នុងវិវិធភាពនេះ សិទ្ធិមនុស្សទាំងអស់ ត្រូវបានគេតម្រូវអោយមានការគោរព និងទទួលស្គាល់ ។ ចំពោះពុទ្ធសាសនិកជនវិញ, វិវិធភាព ឬភាពផ្សេងៗគ្នា គឺជាផ្នែកនៃការវិវត្តន៍របស់ធម្មជាតិ ហើយក៏មិនត្រូវសំគាល់ភាពផ្សេងៗគ្នានេះថា ជាបញ្ហាដែរ ។ មនុស្ស, ទុកដូចជា « វិស្វករម្នាក់ » នៅក្នុងធម្មជាតិ ។ មនុស្សនេះ, ត្រូវបានគេជឿទុកចិត្តថា ចេះធ្វើការរំដោះខ្លួនដោយខ្លួនឯង នៅក្នុងរង្វង់ និងតាមរយៈវិវិធភាព ឬភាពផ្សេងៗគ្នានេះ ។ ដូចបានបញ្ជាក់ខាងដើមហើយ, ក្នុងឋានៈជាសាសនា និងជាទស្សនវិជ្ជាមួយ យកចិត្តគិតគូរដល់ « សព្វសត្វ » *( សព្វេ សត្តា)*, ពុទ្ធសាសនាមិនបានទទួលស្គាល់នូវភាពផ្សេងៗគ្នា ដែលមានចែងនៅក្នុងមាត្រានេះទេ ។

នៅក្នុងការសង្កេតលើមាត្រាទី ១, យើងបាននិយាយហើយថា តើនៅលើមូលដ្ឋានណា និងរបៀបយ៉ាងណា ដែលពុទ្ធសាសនាចាត់ទុកមនុស្សទាំងអស់ថាមានភាពស្មើគ្នា ។ គេអាចបន្ថែមក្នុងទីនេះទៀតថា សមភាពនេះ ក៏ត្រូវបានគេពោលថា ជាសមភាព «សមស្របជាមួយ» ព្រះ*ធម៌* ក្នុងន័យជា «ក្រឹត្យក្រមសកល»,

« ហើយមិនផ្ទុយទៅនឹងក្រឹត្យក្រមនេះ » ( *ធម្មេនេវ នោ អធម្មេន* )។ នេះមានន័យវែងឆ្ងាយទៀតថា សមភាពដែលនិយាយដល់នេះ គឺជាគ្រឹះ, ជាឫសគល់ និងជាធម្មជាតិ ។ ទស្សនាមាននៃសមភាពបែបនេះ ទាមទារថា សិទ្ធិ និងសេរីភាពទាំងឡាយត្រូវតែឋិតនៅអោយផុតស្រឡះពីចំណង ពីឧបសគ្គ ពីច្រវាក់ខ្នោះឃ្នាងទាំងអស់ ដូចជា ហេតុផលខាងពូជជាតិ, ពណ៌សម្បុរស្បែក, ភេទស្រី-ប្រុស ជាដើម ។

តាមការយល់របស់ពុទ្ធសាសនា ចំពោះបញ្ហានេះ, អភិក្រមជីវិតរបស់មនុស្ស តែងប្រព្រឹត្តទៅតាម « ទ្វារបី » គឺកាយ, វាចា, និងចិត្ត ។ សកម្មភាពរបស់មនុស្ស ( ទោះបីលក្ខណៈសីលធម៌របស់អំពើនោះជាអ្វីក៏ដោយ ) តែងមានប្រភពចេញមកពីចិត្ត ហើយស្ដែងចេញមកខាងក្រៅតាមផ្លូវកាយ ឬ ផ្លូវវាចា ។ ដូចនេះ, តាមដូចព្រះពុទ្ធបានទេសនាប្រាប់ ហើយដូចជានៅក្នុង *វសលៈ* និង *មធុរៈ* ថា, មនុស្សម្នាក់ៗ គឺជា « ទាយាទ » ( អ្នកទទួលមរតក ) ចំពោះអំពើរបស់ខ្លួន *(ធម្ម-ទាយាទោ)* ដោយមិនគិតដល់កត្តានានា ដូចយ៉ាងពូជជាតិ, សម្បុរស្បែក, ប្រភពសញ្ជាតិ ឬប្រភពសង្គម, ទ្រព្យសម្បត្តិ, ជាតិ ( កំណើត ) ឬស្ថានភាពដទៃទៀតឡើយ ។ ព្រោះហេតុនេះ, កត្តាទាំងអស់នេះ មិនត្រូវបានព្រះពុទ្ធសាសនា យកចិត្តគិតគូរដោយប្រការណាមួយទេ ។ សិទ្ធិ និងសេរីភាពទាំងឡាយ ត្រូវតែបានអនុវត្តទៅតាមរយៈសកម្មភាពសមស្រប ( Appropriate action ) ពោលគឺ តាមរយៈសម្មាកម្មន្តៈ ។ នេះ គឺជាគោលការណ៍ខាងសង្គមកិច្ចរបស់ពុទ្ធសាសនា ។

គោលការណ៍នេះ ក៏ទាក់ទងដល់ភេទ និងភាសាផងដែរ ។ ចំពោះសម-ភាពជាឫសគល់ ដែលបានផ្ដល់ដល់មនុស្សទាំងអស់, គេនឹងពុំមានប្រយោជន៍អ្វីដើម្បីលើកយកមកពិចារណានូវភាពផ្សេងគ្នារវាងភេទទេ ។ ស្ត្រីក៏មានសក្ដានុភាពដូចបុរសមានសក្ដានុភាពរបស់ផងខ្លួនដូច្នោះដែរ ។ មានមនុស្សខ្លះយល់ច្រឡំ ដោយអោយតម្លៃលើ *បេត្តេយ្យកា* ( ទស្សនៈអោយតម្លៃបិតា ខ្ពស់ជាងមាតា ) ក្នុងការ

ប្រព្រឹត្តចំពោះ « ភេទទន់ខ្សោយ » បណ្ដាលមកពីវិន័យរបស់វត្តអារ៉ាមពុទ្ធសាសនាខ្លះ ទាក់ទងនឹងការគ្រប់គ្រង(១) ភិក្ខុនី (ឬ សាមណេរី) ។ រីឯលទ្ធិពុទ្ធសាសនាដំបូងទីក៏បានពេញចិត្តអោយមានបរិយាកាសមួយ ដែលមានផលប៉ះពាល់ដល់ប្រយោជន៍របស់ស្ត្រី ផងដែរ ។ ប៉ុន្តែ ពុទ្ធសាសនានា ពេលខាងក្រោយមកមើលឃើញថា ពុំមានហេតុផលណាមួយនាំបង្កើតអោយមានការរើសអើងចំពោះស្ត្រី ជាពិសេស ក្នុងកិច្ចការលើកស្ទួយតម្លៃសីលធម៌ និងតម្លៃបញ្ញាស្មារតីនោះទេ ។ ដោយផ្អែកលើទស្សនៈនេះ ព្រះពុទ្ធទ្រង់បានអះអាងថា ស្ត្រីអាចមានលទ្ធភាពធ្វើបានប្រសើរលើសបុរសផង ។ នៅក្នុងព្រះតម្រិះរបស់ព្រះពុទ្ធ, « ហាក់ដូចជាពុំមានសេចក្ដីសង្ស័យអ្វីមួយទេ ... ចំពោះសមភាពខាងអំណាចរបស់បុរស និងស្ត្រី ។ ពុទ្ធសាសនាបានដាក់បុរស និងស្ត្រី អោយមានសមភាពដូចគ្នា ។ នៅក្នុង *ថេរីគាថា,* ស្ត្រីបានទទួលសេរីភាពសំរេចបានគុណធម៌ខ្ពស់ក្នុងពុទ្ធសាសនា ដូចជាបុរសដែរ ។

ព្រះពុទ្ធបានទទួលស្គាល់សិទ្ធិ និងសេរីភាពរបស់បុគ្គលក្នុងការស្វែងរកសុខុមាលភាពជាសម្ភារៈ ( អត្ថ ) និងជាស្មារតី ( ធម្ម ) ។ ពិនិត្យមើលបញ្ហានេះតាមទស្សនៈនៃភាសាប្រើជាយានសម្រាប់សិក្សាវិញ, ព្រះពុទ្ធបានបញ្ញត្តថា, បុគ្គលគប្បីរៀនពាក្យប្រៀនប្រដៅ ( ព្រះធម៌ ) របស់តថាគត នៅក្នុងភាសារបស់ខ្លួនផ្ទាល់

---

(១) តាមធម្មតា, វិន័យបានទទួលស្គាល់ ភាពទន់ខ្សោយរបស់ស្ត្រីភេទ ។ ហេតុនេះ មានការទាមទារថា អ្វីដែលបានសំរេចហើយ ដោយភិក្ខុនី ( ឬ សាមណេរី ) ស្ដីពីជីវភាពជាអ្នកបួសនោះ, ឥឡូវនេះ ត្រូវការអោយមានសច្ចានុម័តិ ពោលគឺ អោយមានការយល់ព្រមត្រឹមត្រូវដែលអាចអនុវត្តបាន អំពីភិក្ខុសង្ឃ ។

( សកាយ និរុត្តិយ ) [(១)], ហើយទ្រង់បានហាមប្រាមសាវ័កទាំងឡាយរបស់ព្រះអង្គ មិនអោយសំដែងធម៌របស់ព្រះអង្គ តាមរយៈភាសាយានរបស់ពួកអភិជន [(២)] នាសម័យកាលនោះទេ ។

ក្នុងឋានៈជាសាសានាមួយ, ពុទ្ធសាសនាបានផ្ដល់អោយដល់អ្នកជឿសាសនាឯទៀត ទាំងអស់ នូវសិទ្ធិ និងសេរីភាព ដែលពុទ្ធសាសនិកជនទាំងឡាយធ្លាប់តែបានប្រកាសថាជារបស់ខ្លួនដោយស្របច្បាប់ ។ នៅក្នុងទីនេះ, ក៏ដូចនៅក្នុងទិដ្ឋភាពផ្សេងទៀតដែរ ពុទ្ធសាសនា បានជឿជាក់ថា បុគ្គលម្នាក់ៗ ត្រូវចាត់ទុកបុគ្គលឯទៀតដោយប្រដូចបុគ្គលឯទៀតមកខ្លួនឯងផ្ទាល់ : « *អត្តានំ ឧបមំ កត្វា* » ។ គោលការណ៍នេះ ត្រូវបានរៀបរាប់យ៉ាងក្បោះក្បាយនៅក្នុង*អត្តុបនាយិកធម្ម-បរិយាយ* ដែលមានចែងនៅក្នុង*វេឡុទ្វារេយ្យសូត្រ* នៃសំយុត្តនិកាយ ។ នៅក្នុងចរិយាធម៌របស់ពុទ្ធសាសនា, ការខ្វល់ខ្វាយរបស់បុគ្គលម្នាក់ៗ ចំពោះសិទ្ធិ និងសន្តិសុខរបស់អ្នកឯទៀត គឺជាអត្ថប្រយោជន៍មុនគេបំផុត ។ ដោយហេតុនេះ ការអនុវត្តន៍សិទ្ធិ និង សេរីភាព ដោយបុគ្គលម្នាក់ៗ ត្រូវចំណុះក្រោមការទទួលស្គាល់ នូវសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ ។

---

(១) មានសេចក្ដីចែងក្នុងចុល្លវគ្គថា, អនុជានាមិ ភិក្ខវេ សកាយ និរុត្តិយា ពុទ្ធវចនំ បរិយា-បុណិតុំ, ពិនិត្យជារួមចំពោះអាកប្បកិរិយារបស់ព្រះពុទ្ធចំពោះភាសា ដែលមាននៅក្នុងទីឯទៀត ( ឧ. អរណាវិភង្គសូត្រ នៃមជ្ឈិមនិកាយ ) ក៏ព្រះអង្គបានបញ្ជាក់ច្បាស់ថា សកាយ និរុត្តិយា គប្បីយោងដល់ភាសារបស់ខ្លួនផ្ទាល់, ហើយមិនមែនយោងទៅរកភាសាមគធៈ ដូចអដ្ឋកថាចារ្យយល់នោះទេ ។ គេគប្បីយល់ទៀតថា សក និរុត្តិ អាចយល់បានថា មានន័យជាភាសាធម្មតា ដែលព្រះពុទ្ធបានប្រើ សម្រាប់សំដែងធម៌ ។

(២) និយាយយោងដល់ ភាសាវេទ, ដែលជាភាសាប្រើប្រាស់ដោយពួកអភិជន នាសម័យនោះ នៅក្នុងភាគឧត្តរ នៃ ប្រទេសឥណ្ឌា ។ ភាសាវេទ គឺប្រើភាសា សំស្ក្រឹត ។

នៅទីអវសាន, ដោយយោងដល់កថាខណ្ឌទីមួយនៃមាត្រានេះ គេបានថែងជាទស្សនៈនយោបាយ ឬទស្សនៈផ្សេងទៀតរបស់បុគ្គលម្នាក់ៗ ដើម្បីវិនិច្ឆ័យលើពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ដូចជាកាលាមសូត្រ គឺគ្មានការហាមឃាត់ណាមួយមិនអោយក្រេបរសជាតិសិទ្ធិមនុស្ស និងសេរីភាពនោះទេ ។ ទាក់ទងនឹងមតិនយោបាយ គេគប្បីយល់អោយច្បាស់ថា អក្សរសាស្ត្រពុទ្ធសាសនាជំនាន់ដើមមិនបានបង្ហាញនូវការពេញចិត្តចំពោះទម្រង់នយោបាយណាមួយ ទៅលើទម្រង់នយោបាយមួយទៀតទេ ។ ប៉ុន្តែ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ បានអោយតម្លៃខ្ពស់ចំពោះគំនិតប្រជាធិបតេយ្យ ។ ព្រះពុទ្ធសាសនា បានជ្រើសយកទម្រង់នយោ-បាយ ដែលនៅក្នុងគ្រប់កាលៈទេសៈ បានផ្តល់លទ្ធភាពអោយការប្រតិបត្តិសីលធម៌សង្គមប្រព្រឹត្តទៅបាន ។ លក្ខខណ្ឌដំបូង មិនសង្កត់ធ្ងន់លើក្របខណ្ឌនយោបាយ និងសេដ្ឋកិច្ចទេ, ប៉ុន្តែសង្កត់ធ្ងន់លើការប្រតិបត្តិជាក់ស្តែង នូវសីលធម៌សង្គម ( The social ethic ) ដែលត្រូវតែធ្វើអោយមានប្រសិទ្ធភាព តាមរយៈកិច្ចការនយោបាយ និងសេដ្ឋកិច្ចរបស់ប្រជាជាតិណាមួយ ។

កថាខណ្ឌទីពីរ នៃមាត្រានេះ ត្រូវបានភ្ជាប់ដោយមិនអាចផ្តាច់បាន ជាមួយនឹងបញ្ហាដែលសួរថា តើអធិបតេយ្យចុងក្រោយបំផុត នៅក្នុងទស្សនៈពុទ្ធសាសនាឋិតនៅក្នុងទីណា ? ទន្ទឹមនឹងពុទ្ធសាសនា ទាមទារអោយមានការវាយតម្លៃមួយជាក់លាក់អំពីស្ថានភាពមនុស្ស ហើយធ្លាប់បានទទួលស្គាល់នូវភាពភ្លាំងភ្លាត់របស់មនុស្សក្នុងឋានៈជាមនុស្ស, ពុទ្ធសាសនា តែងវាស់កិច្ចការរបស់មនុស្ស ទៅតាមក្រឹត្យក្រមសកល ( ព្រះធម៌ ) ឬទៅតាមគោលការណ៍ នៃភាពត្រឹមត្រូវដែលនិយាយយោងខាងលើ ។ ទស្សនាទានស្តីពីក្រឹត្យក្រមសកលនេះ មានន័យថា នៅក្នុងទស្សនៈពុទ្ធ-សាសនា អធិបតេយ្យចុងក្រោយបំផុតឋិតនៅ, មិនមែនក្នុងកណ្តាប់ដៃអ្នកដឹកនាំណាម្នាក់ ទោះជាមនុស្សក្តី ជាទេវតាក្តី នោះទេ, ទាំងមិននៅក្នុងកណ្តាប់ដៃអង្គការ

ណាមួយកំពុងគ្រប់គ្រងរដ្ឋនោះទេ, ទាំងមិននៅក្នុងរដ្ឋខ្លួនឯងនោះ ក៏ទេដែរ, ប៉ុន្តែ នៅក្នុង *ព្រះធម៌,* ដ៏ជាគោលការណ៍ជានិរន្តរ៍នៃភាពត្រឹមត្រូវ ( Righteousness ) ។ នៅក្នុងបរិបទនេះ, គេមិនគប្បីយល់ព្រះធម៌ទុកដូចជាមានន័យថា : « ជាសភាវៈអាថ៌កំបាំងម្យ៉ាងនោះទេ, » ប៉ុន្តែ គេគប្បីយល់ថា បើរដ្ឋទាំងឡាយ ប្រព្រឹត្តតាមព្រះធម៌ដល់កំរិតណាមួយ នៅក្នុងនយោបាយផ្ទៃក្នុង និងនយោបាយបរទេសរបស់ខ្លួន, មនុស្សជាតិអាចធ្វើអោយសម្រេចបាននូវចំណង់ដ៏ត្រឹមត្រូវរបស់ខ្លួន ដើម្បីសន្តិភាព, ភាពសម្បូរសប្បាយ និងសុភមង្គល ជាប្រាកដ ។

ដោយហេតុថា, ពុទ្ធសាសនា មានទំនុកចិត្តក្នុងបុគ្គលភាពរបស់មនុស្ស ប្រកបដោយកិត្តិយស និងភាពទទួលខុសត្រូវខាងសីលធម៌នោះ, ទើបពុទ្ធសាសនាបានទុកមនុស្សជាតិ ជាសត្វមានគុណសម្បត្តិប្រកបដោយអធិបតេយ្យបង្កប់នៅក្នុង *ព្រះធម៌,* នៅក្នុងការគ្រប់គ្រងកិច្ចការរបស់មនុស្ស ។ ពុទ្ធសាសនាបានអះអាង, ហើយក៏ដូចលោក ហ្សង់ហ្សាក់ រូស្សូ ( Jean Jacques Rousseau ) បានអះអាងនៅកាលជាខាងក្រោយយូរលង់មកថា សារជាតិនៃសេចក្តីថ្លៃថ្នូររបស់មនុស្សឋិតនៅក្នុងការប៉ានទទួលខុសត្រូវចំពោះការប្រព្រឹត្តរបស់ខ្លួនផ្ទាល់ ។ ដោយហេតុនេះ, ទោះបីជាទម្រង់នយោបាយបែបណាមួយក៏ដោយ ដែលមនុស្សអាចប្រកាន់យក, តាមទស្សនៈពុទ្ធសាសនា, *សម្រាប់គោលដៅជាក់ស្តែងទាំងអស់,* គឺនៅក្នុងមនុស្សនេះឯង ដែលអធិតេយ្យបង្កប់នៅក្នុង *ព្រះធម៌* តែងឋិតនៅ ។ ដូច្នេះ, ការពិនិត្យអោយឃើញប្លែកគ្នានៅក្នុងការសិក្សា បែងចែកមនុស្សនៅក្រោមទម្រង់នយោបាយផ្សេងៗ ពុំមានន័យអ្វីទេ ហើយអាចមានផលអាក្រក់ និងបង្កអោយមានការធុញទ្រាន់ទៀតផង ចំពោះទស្សនៈពុទ្ធសាសនា ។

មាត្រា ៦ - *មនុស្សម្នាក់ៗ មានសិទ្ធិអោយគេទទួលស្គាល់នៅគ្រប់ទីកន្លែងថាជាមនុស្សម្នាក់ នៅចំពោះមុខច្បាប់ ។*

មាត្រា ៦ អះអាងនូវតម្លៃ ឬសេចក្ដីថ្លៃថ្នូររបស់បុគ្គល ដោយមិនគិតពីកាលៈទេសៈនៃការរស់នៅក្នុងទីណានោះទេ ។ មាត្រានេះ មានន័យត្រឹមត្រូវល្អណាស់តាមទស្សនៈសីលធម៌របស់ពុទ្ធសាសនា និងសញ្ញាណស្ដីពីយុត្តិធម៌ក្នុងពុទ្ធ-សាសនា ។

ជាបឋម មាត្រា ៦ នេះ តម្រូវអោយមានការទទួលស្គាល់តម្លៃគុណធម៌របស់បុគ្គលថាជាមនុស្សមានជីវិតម្នាក់ ហើយក្នុងឋានៈនេះ, ទើបអះអាងយ៉ាងរឹងមាំនូវសិទ្ធិរបស់បុគ្គល ដើម្បីអោយមានការទទួលថាជាមនុស្សនៅចំពោះមុខច្បាប់ ។

ពាក្យមួយម៉ាត់នេះ ចាំបាច់ណាស់ ស្ដីពីទស្សនៈអំពីច្បាប់របស់ពុទ្ធ-សាសនា និងវិធីដោះស្រាយរបស់ច្បាប់ ។ បីដូចជាមាគ៌ានាំទៅកាន់ព្រះនិព្វាន មិនមែនសុទ្ធតែត្រូវឆ្លងកាត់ព្រៃស្ងាត់ឈឹងប៉ុណ្ណោះទេ, ប៉ុន្តែ ត្រូវឆ្លងកាត់តាមមហាវិថីនៃជីវិតផងដែរ, ច្បាប់នៅក្នុងទស្សនៈពុទ្ធសាសនា កើតមានឡើងដើម្បីជាអត្ថ-ប្រយោជន៍សម្រាប់ជីវិត និងសម្រាប់អ្វីៗ ដែលទ្រទ្រង់ជីវិត ។ ច្បាប់គឺមនុស្សបង្កើតឡើង, ហើយនៅក្នុងពុទ្ធសាសនា ច្បាប់គឺជាកំឡាំងចងភ្ជាប់ ពីព្រោះប្រភពដើមនៃច្បាប់ គឺ *ព្រះធម៌* ឬក្រឹត្យក្រមសច្ចៈ សាកលលោកធាតុ ស្វ័យវិវត្តអចិន្ត្រៃយ៍ ( The eternal, self operative, Cosmic principle of Righteousness ) ប្រសើរលើស និងមានមុនអ្វីៗទាំងអស់ ទោះជាមានជីវិតក្ដី ឥតជីវិតក្ដី ដែលអាចកើតមាន ។

វិធីដោះស្រាយរបស់ពុទ្ធសាសនាចំពោះច្បាប់ គឺទាមទារអោយច្បាប់ ត្រូវបានគេយកមកពិចារណានៅក្នុងទំនាក់ទំនងជាមួយសីលធម៌ពុទ្ធសាសនា និងទស្សន-វិជ្ជាសង្គម របស់ពុទ្ធសាសនា ។ បើទោះជាពួកវិជ្ជមាននិយម ( Positivists ) ចូលចិត្តបាមឃាត់នូវការពិចារណាគោលការណ៍ច្បាប់ខាងក្រៅដូចនេះក្ដី ក៏គេត្រូវតែយល់ អោយច្បាស់ថា ច្បាប់ក្លាយទៅជាមានន័យបានតែលើមូលដ្ឋានឧត្តមគតិ ចរិយា

ធម៌ប៉ុណ្ណោះ ។ ពុទ្ធសាសនា បានចាត់ទុកច្បាប់ « ដូចជាឧបករណ៍សម្រាប់សំរេចគោលដៅមួយចំនួន ដែលមានប្រយោជន៍ដល់សង្គម ។ តើគោលដៅទាំងនោះជាអ្វី ឬនឹងអាចជាអ្វីនោះ នេះគឺជាខ្លឹមសារសម្រាប់ចរិយាធម៌ ។ ចរិយាធម៌ពុទ្ធសាសនាមានមូលដ្ឋានលើទស្សនះពុទ្ធសាសនា ស្តីពីតថភាព ( Reality ) ដែលមានមូលដ្ឋានគ្រឹះរបស់ខ្លួនរឹងមាំ ចេញមកពីទ្រឹស្តីពុទ្ធសាសនា ស្តីពី វិជ្ជា ( Knowledge ), ទស្សនាទាននៃច្បាប់នៅក្នុងពុទ្ធសាសនា អាចអោយគេនិយាយបានថា គឺជាទស្សនា-ទាន មានគ្រឹះមូលដ្ឋានលើការប្រៀនប្រដៅអំពីវិជ្ជាវិទ្យា ( epistemology ) របស់ពុទ្ធសាសនា ។

សម្រាប់គោលបំណងបច្ចុប្បន្ន, វាជាការគ្រប់គ្រាន់ណាស់ទៅហើយ ដើម្បីសន្និដ្ឋានថា អាកប្បកិរិយារបស់ពុទ្ធសាសនាចំពោះច្បាប់ (law) ជាទូទៅ និងចំពោះនីតិវិធីសន្តោស ឬលើកលែងទោសជាពិសេស គឺមានប្រភព ឬដើមទងចេញមកពីទស្សនាទានពីរយ៉ាង : (១) ទស្សនាទានស្តីពីការគ្រប់គ្រងប្រកបដោយធម៌ ( Rule of Righteousness ) ដែលមានចែងនៅក្នុងនិមិត្តរូបសញ្ញា នៃ « ធម្ម-ចក្ក ឬចក្រនៃព្រះធម៌ » ពីព្រោះ អាជ្ញារបស់ស្តេច នៅក្នុងបរិបទពុទ្ធសាសនា ត្រូវបានតាងដោយ « ចក្រ » ដែលជានិមិត្តរូបនៃការប្រព្រឹត្តទៅ និងដំណើររីករាលដាលនៃច្បាប់ និងយុត្តិធម៌ នៅក្នុងពិភពលោក, ហើយ (២) ទស្សនាទាននៃ « សុភ-មង្គល និងសុខុមាលភាព សម្រាប់មនុស្សជាតិ » *(ពហុជនហិតៈ, ពហុជនសុខៈ)* គឺជាទស្សនៈឯក ឬទស្សនៈតែមួយគត់ តាមការយល់ឃើញរបស់ពុទ្ធសាសនា ។

ការប្រៀនប្រដៅរបស់ពុទ្ធសាសនាពីដំបូងទី ដែលទាក់ទងនឹងសង្គម បានគាំទ្រគំនិតនៃអ្នកគ្រប់គ្រង « ធម្មចក្រ », ជាអ្នកគ្រប់គ្រងពិភពលោក ឬស្តេចចក្រ-ព័ត្តិ, ជាព្រះធម្មិករាជ ដែលគ្រប់គ្រងប្រកបដោយធម៌ ( law ) ហើយក្នុងចំណោមភារកិច្ចរបស់ព្រះអង្គ គឺមានភារកិច្ចផ្តល់នូវការថែទាំ និងកិច្ចការពារប្រកបដោយធម៌

ឬដោយយុត្តិធម៌ មិនមែនសម្រាប់តែមនុស្ស ដោយមិនគិតពីជាន់ថ្នាក់របស់គេ នៅក្នុងសង្គមប៉ុណ្ណោះទេ, ប៉ុន្តែ ដូចដែលបានកត់សម្គាល់ពីខាងដើមរួចហើយ សូម្បីតែសត្វធាតុ និងបក្សាបក្សីក៏ត្រូវតែបានទទួលការថែទាំ និងកិច្ចការពារផងដែរ, ដោយហេតុនេះ ផ្តល់អានុភាពពេញលេញដល់ការគ្រប់គ្រងប្រកបដោយធម៌ ។ ទស្សនៈនេះ, កាលណាបូកបន្ថែមដោយទស្សនាទានទី២ ខាងលើ, បានចេញជាលទ្ធផលនៅក្នុងមតិ ស្តីពី « សុភមង្គលរួមរបស់មនុស្សជាតិទាំងអស់ » - ជាគំនិតមួយកើតមានឡើង ជាលើកដំបូងនៅក្នុងការត្រិះរិះរបស់មនុស្ស ។ ជាបន្តមក គំនិតស្តីពី « សុភមង្គលរួម » ត្រូវតែជាប់ទាក់ទិនយ៉ាងចាំបាច់ជាមួយនឹងការទទួលស្គាល់សិទ្ធិរបស់មនុស្សគ្រប់រូប នៅគ្រប់ទីកន្លែង ក្នុងឋានៈជាមនុស្សម្នាក់នៅចំពោះមុខច្បាប់ ដោយគ្មានការបែងចែកបែបណាមួយឡើយ ។ តាមទស្សនៈច្បាប់ គំនិតនេះ គឺជាឧត្តមគតិដែលគួរតែសំរេចអោយបាន ។ ដោយហេតុនេះ « ការគ្រប់គ្រងប្រកបដោយធម៌ » និង « សុខុមាលភាព និងសុភមង្គលរបស់មនុស្សជាតិ » គឺជាគំនិតគន្លឹះនៅក្នុងបរិបទបច្ចុប្បន្ននេះ ។ តែថា, ប្រសិនបើក្នុងការអនុវត្តជាក់ស្តែង វាកើតមានករណីខ្លះ ដែលយុត្តិធម៌មិនអាចត្រូវបានគេផ្តល់អោយដោយសមស្របទេ, យុត្តិធម៌ ក៏នៅតែត្រូវបានគេសង្ឃឹមទុកថា បានទទួលក្នុងជាតិខាងមុខ ( Conditionality ) ឬ បានទទួលតាមច្បាប់កម្ម - ផល ដូចដែលព្រះពុទ្ធបានរកឃើញ ។

ការប្រៀនប្រដៅរបស់ពុទ្ធសាសនា តែងតែឲិតលើតម្លៃ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ។ នៅក្នុងបណ្តាជីវិត ក្នុងរូបភពទាំងពីរ គឺជីវិតជាមនុស្ស និងជីវិតជាទេព្តា, ក្នុងជីវិតណាមួយក៏ដោយ បុគ្គលអាចធ្វើការកសាងអំពើល្អ ឆ្ពោះទៅរកការរំដោះខ្លួនបាន, ។ តាមទស្សនៈរបស់ពុទ្ធសាសនា ជីវិតជាមនុស្សមានគុណសម្បត្តិប្រសើរជាង ហើយជាជីវិតដែលកើតបានមកដោយលំបាក និងកម្រ ។ ដូចយើងបានបញ្ជាក់នៅក្នុងការសង្កេតរបស់យើងលើមាត្រា ១ រួចហើយថា មនុស្សដែលបាន

កើតឡើងនៅក្នុងលោកនេះ មានភ័ព្វសំណាងប្រសើរណាស់ ដើម្បីកសាងខ្លួនអោយចេញផុតពីជីវិតប្រកបដោយទុក្ខទោមនស្ស ឆ្ពោះទៅកាន់និព្វាន ដ៏ជាសុភមង្គលប្រសើរបំផុត ។ ជីវិតក្នុងលោកិយនេះ គឺជាជីវិតដ៏ប្រសើរជាងជីវិតក្នុងទេវលោក ពីព្រោះលោកិយនេះបានផ្តល់ឱកាសដ៏ប្រសើរអោយបុគ្គលមើលឃើញ និងយល់ដឹងសច្ចធម៌ ដែលជាធម៌មានសារសំខាន់គឺ *ទុក្ខៈ* ។ លើសពីនេះទៀត ការប្រព្រឹត្តកាន់ព្រហ្មចរិយធម៌នៅក្នុងជីវិតបច្ចុប្បន្ននេះ ក៏អាចនាំបុគ្គលអ្នកប្រព្រឹត្តអោយចេញផុត, រំដោះខ្លួនផុតពីវដ្តសង្សារនៅក្នុងជាតិនេះតែម្តង, ដោយមិនចាំបាច់ទៅកាន់ឋានសួគ៌នោះទេ ។ ដូច្នេះ គេបានផ្តល់តម្លៃថា នៅក្នុងបរិបទពុទ្ធសាសនា បុគ្គលម្នាក់ៗ ចាំបាច់ត្រូវតែបានគេទទួលស្គាល់យ៉ាងសមស្រប ទុកដូចជាមនុស្សម្នាក់នៅចំពោះមុខច្បាប់, ពីព្រោះ អ្វីៗទាំងអស់ នៅក្នុងលោកិយខ្លួនឯងនេះ ចាំបាច់ត្រូវមានការវាយតម្លៃ ដែលទុកដូចជាមធ្យោបាយមួយឆ្ពោះទៅរកគោលដៅ ។

ដូច្នេះ, តម្លៃរបស់បុគ្គលឆ្លុះបញ្ចាំងតាមទស្សនាទានស្តីពី *ការគ្រប់គ្រងប្រកបដោយធម៌* ឬការគ្រប់គ្រងប្រកបដោយយុត្តិធម៌ និងមតិស្តីពី *សុភមង្គលរួមរបស់មនុស្សជាតិ* បានទាមទារអោយមានការខិតខំដោះស្រាយបញ្ហាមនុស្សទន់ខ្សោយ, មនុស្សត្រូវគេជិះជាន់, មនុស្សស្លូតត្រង់, មនុស្សក្រីក្រ និងមនុស្សអនាថាខ្វះមធ្យោបាយរស់នៅក្នុងសង្គម ។ មនុស្សទាំងនេះ ក៏ចង់បានការថែទាំ, និងការយកចិត្តទុកដាក់អំពីច្បាប់ ដូចដែលច្បាប់នេះត្រូវបានគេយកទៅអនុវត្តចំពោះស្រទាប់មនុស្សដទៃទៀត នៅក្នុងសង្គមដែរ ។ ប្រសិនបើបទបញ្ញត្តិ និងអាជ្ញានៃច្បាប់ ត្រូវបានគេយកទៅឆ្លុះបញ្ចាំងនូវដំណើរប្រព្រឹត្តទៅនៃធម្មចក្រ ( ធម្មចក្កប្បវត្តនៈ ), ការទទួលស្គាល់បុគ្គលភាពនៅចំពោះមុខច្បាប់ គឺជាសិទ្ធិមូលដ្ឋានរបស់មនុស្ស, បើទោះជាកាលៈទេសៈនៃអ្នករងគ្រោះអំពីការរើសអើងកើតមាន យ៉ាងដូចម្តេចក្តី ។

មាត្រា ២៣ :

១ . មនុស្សម្នាក់មានសិទ្ធិមានការងារធ្វើ, មានសិទ្ធិជ្រើសរើសដោយសេរីនូវមុខរបរ, មានសិទ្ធិធ្វើការងារក្នុងលក្ខខណ្ឌត្រឹមត្រូវ និងសមស្រប និងមានសិទ្ធិទទួលកិច្ចការពារទល់នឹងការខ្វះការងារធ្វើ ។

២ . មនុស្សម្នាក់ៗ មានសិទ្ធិទទួលប្រាក់ឈ្នួលស្មើគ្នា ចំពោះការងារស្មើគ្នា ដោយគ្មានការរើសអើងណាមួយ ។

៣ . មនុស្សម្នាក់ៗដែលធ្វើការ មានសិទ្ធិទទួលប្រាក់បំណាច់ត្រឹមត្រូវ និងសមស្រប ដើម្បីចិញ្ចឹមជីវិតខ្លួន និងគ្រួសារអោយបានសក្តិសមនឹងសេចក្តីថ្លៃថ្នូរជាមនុស្ស, ហើយប្រសិនជាចាំបាច់, ត្រូវការទទួលប្រាក់បន្ថែម ដោយមធ្យោបាយផ្សេងអំពីកិច្ចការពាររបស់សង្គម ។

៤ . មនុស្សម្នាក់ៗ មានសិទ្ធិបង្កើត ឬចូលរួមអង្គការសហជីព ដើម្បីការពារអត្ថប្រយោជន៍របស់ខ្លួន ។

នៅក្នុងសម័យពុទ្ធកាល ប្រជាជនភាគច្រើនបំពេញមុខរបរដោយខ្លួនឯង, ម្នាក់ៗ បំពេញសកម្មភាពតាមការកំណត់របស់វណ្ណៈខ្លួន, ដោយហេតុនេះ គេចូលរួមអង្គការសេដ្ឋកិច្ចបែបណាមួយរបស់សង្គម ហើយគេបានទទួលការផ្គត់ផ្គង់សម្រាប់ខ្លួនឯង ក៏ដូចជាធ្វើវិភាគទានដល់សុខុមាលភាពរបស់សហគមន៍ដូចោ្នះ ។ គម្ពីរពុទ្ធ-សាសនា បង្ហាញថា សម័យពុទ្ធកាល គឺជាសម័យកាលនៃការពង្រីកទីក្រុង នៅក្នុងជ្រលង ទន្លេគង្គា ជាមួយនឹងការវិវត្តរីកចំរើនវណ្ណៈឈ្មួញ ( វៃស្យៈ ) ដែលមានមូល-ដ្ឋាននៅទីក្រុង និងដែលផ្តល់ឱកាសអោយកើតមានមុខរបរផ្សេងៗ ផង ។

ចំពោះប្រព័ន្ធវណ្ណៈនៅក្នុងសម័យនោះ គេបានដឹងច្បាស់ណាស់ថា ព្រះពុទ្ធជំទាស់នឹងប្រព័ន្ធវណ្ណៈនោះយ៉ាងណាហើយ ។ តាមការពិតជាក់ស្តែង, ប្រព័ន្ធវណ្ណៈបានផ្ទុយទៅនឹងគោលការណ៍មូលដ្ឋានរបស់ពុទ្ធសាសនា ដែលចែងថាមនុស្ស

ទាំងអស់បានកើតមកមានសេរីភាព និងសមភាពរស់នៅក្នុងសេចក្ដីថ្លៃថ្នូរ ហើយមានសិទ្ធិទាំងឡាយដូចគ្នា ដោយគ្មានការលើកលែងណាមួយឡើយ, ហើយខិតខំព្យាយាមប្រតិបត្តិតាមគន្លងអដ្ឋង្គិកមគ្គ ឆ្ពោះទៅសំរេចគោលដៅចុងក្រោយបង្អស់គឺនិព្វាន។

ភាគរួមផ្សំនៃអដ្ឋង្គិកមគ្គ(១) ក្រៅពីខ្លឹមសារដ៏មានអត្ថន័យជ្រាលជ្រៅខាងស្មារតីជាអមតៈរបស់ខ្លួនចេញ, ក៏គង់មានខ្លឹមសារខាងផ្លូវលោក ដែលគេអាចយកមកអធិប្បាយសេចក្ដីអោយស្របនឹងស្ថានភាពប្រែប្រួល ដែលឋិតនៅក្នុងរង្វង់នៃអត្ថន័យខាងស្មារតីរបស់អដ្ឋង្គិកមគ្គដែរ ។ តាមពិត ប្រការទាំងប្រាំខាងដើមនៃមាគ៌ា (ផ្លូវ) ទាំងប្រាំបីនេះ ត្រូវគេចាត់ទុកថាមានអត្ថន័យពិសេសសម្រាប់គ្រហស្ថ, ហើយមានប្រការពីរក្នុងប្រការទាំងប្រាំ មានទំនាក់ទំនងពិសេសជាមួយសិទ្ធិមនុស្ស ដែលបានចែងនៅក្នុងមាត្រានេះ ។ ប្រការទាំងពីរនេះ គឺ *សម្មាកម្មន្តៈ* និង*សម្មាអាជីវៈ* ។ សម្មាកម្មន្តៈទាក់ទងនឹងការវៀរចាកការបង្កអោយមានការឈឺចាប់ ឬសម្លាប់សត្វមានជីវិត ( មនុស្ស និងសត្វ ), វៀរចាកការលួច ការប្រព្រឹត្តខុសផ្លូវភេទ, និងការកុហក បោកប្រាស ។ ចំណែកអត្ថន័យ នៃសម្មាអាជីវៈ គឺសំដៅដល់ការចិញ្ចឹមជីវិតរបស់បុគ្គលម្នាក់ៗ ទៅតាមបែបបទមួយ មិនមានផលប៉ះពាល់ ឬនាំអោយខូចខាតផលប្រយោជន៍របស់មនុស្សដទៃ ។ សម្មាអាជីវៈ ទាក់ទងផងដែរដល់សេដ្ឋកិច្ចពុទ្ធសាសនា ក្នុងន័យដែលថា បុគ្គលម្នាក់ៗ ត្រូវការចិញ្ចឹមជីវិត ហើយដោយហេតុនេះ បុគ្គលម្នាក់ៗ ត្រូវមានកាតព្វកិច្ច ក៏ដូចជា « សិទ្ធិ » ដើម្បីធ្វើការងារ ។ នៅក្នុងបរិបទបច្ចុប្បន្ននេះ ដោយមានការកើនឡើងនៃរដ្ឋអំណាច ហើយដោយហេតុនេះ ក៏

(១) អដ្ឋង្គិកមគ្គៈ ប្រែថា « ផ្លូវមានអង្គប្រាំបី ឬ ផ្លូវប្រាំបីយ៉ាង » គឺ ៖ ១. សម្មាទិដ្ឋិ សេចក្ដីយល់ឃើញត្រូវ, ២. សម្មាសង្កប្បៈ សេចក្ដីត្រិះរិះត្រូវ ឬតម្រិះត្រូវ, ៣. សម្មាវាចា សំដីត្រូវ, ៤. សម្មាកម្មន្តៈ ការងារត្រូវ, ៥. សម្មាអាជីវៈ ការចិញ្ចឹមជីវិតត្រូវ, ៦. សម្មាវាយាមៈ ព្យាយាមត្រូវ, ៧. សម្មាសតិ ស្មារតីត្រូវ, ការរលឹកត្រូវ, ៨. សម្មាសមាធិ សមាធិត្រូវ ។

មានការកើនឡើងនៃការទទួលខុសត្រូវរបស់រដ្ឋអំណាចចំពោះប្រជាពលរដ្ឋ, ស្ថាន-ភាពបែបនេះ ត្រូវជាប់ទាក់ទិននឹងសិទ្ធិ « ដើម្បីការពារប្រឆាំងនឹងការខ្វះការងារធ្វើ » ។ គោលការណ៍របស់ សម្មាកម្មន្តៈ . មានទាក់ទងដល់និយោជក ( employers ) ទោះជាបុគ្គលក្ដី សាជីវកម្មក្ដី ឬជារដ្ឋក្ដី . តម្រូវអោយមានការទទួលស្គាល់ថា និយោជិត . និយោជិតា ( employees ) មិនត្រូវបាននិយោជកដាក់អោយធ្វើការ ឬតម្រូវអោយធ្វើការក្នុងស្ថានភាពដែលមានផលប៉ះពាល់ដល់សុខុមាលភាពខាងផ្លូវកាយក្ដី ខាងផ្លូវស្មារតីក្ដីរបស់ខ្លួនឡើយ, និងតម្រូវអោយមានការទទួលស្គាល់ថា និយោជិត . និយោជិតាទាំងនោះ មិនត្រូវគេដកហូត ឬលួចយកនូវប្រាក់បំណាច់ដ៏ត្រឹមត្រូវ និងសមស្របរបស់គេទេ ។ ត្រូវអនុញ្ញាតអោយពលករទាំងនោះ និងគ្រួសាររបស់គេ អាចរស់នៅបានដោយសារប្រាក់បំណាច់នោះ ក្នុងស្ថានភាពមួយសមរម្យ និងសេចក្ដីថ្លៃថ្នូរជាមនុស្ស ។ តាមការជាក់ស្ដែង, សព្វថ្ងៃនេះ មានច្បាប់ការងារដ៏ទាន់សម័យ កំពុងត្រូវបានប្រើប្រាស់នៅក្នុងប្រទេសនីមួយៗ ដែលបាននាំយកមកអនុវត្តនូវគោលការណ៍សំខាន់ៗ នៃសន្និសញ្ញាជាច្រើនរបស់អង្គការពលកម្មអន្តរជាតិ ។ ច្បាប់ការងារនេះ ត្រូវបានគេធ្វើអោយចំរើនល្អឡើង ដោយផ្អែកលើការអនុវត្តតាមអត្ថន័យខាងស្មារតី នៃអដ្ឋង្គិកមគ្គ ដែលអនុវត្តចំពោះស្ថានភាពផ្លូវលោក ទាក់ទងនឹងសិទ្ធិការងារ ។

យើងមានឱកាសជាច្រើនសម្រាប់បង្ហាញថា នៅក្នុងបរិបទពុទ្ធសាសនាតើសិទ្ធិទាំងឡាយ ត្រូវបានគេធានារ៉ាប់រងយ៉ាងម៉េច តាមរយៈការបំពេញកាតព្វកិច្ច និងករណីយកិច្ច ។ គេជឿថា លក្ខខណ្ឌការងារដ៏ត្រឹមត្រូវ និងសមស្រប និងប្រាក់បំណាច់ត្រឹមត្រូវ និងសមស្រប សម្រាប់ពលករ ត្រូវបានធានាតាមរយៈការបំពេញករណីយកិច្ចមូលដ្ឋានទាំងប្រាំយ៉ាងនេះ ចំពោះការងារ ៖

ក. ការចែកការងារអោយស្រុបទៅតាមជំនាញ និងទៅតាមកំឡាំងរបស់

និយោជិត ( *យថាពលំ កម្មន្តសំវិធាន* )។ នេះ គឺបានន័យថា ការងាររបស់អ្នកមាន វ័យក្មេង មិនគប្បីតម្រូវទៅអោយមនុស្សចាស់ធ្វើទេ ហើយការងាររបស់មនុស្ស ចាស់ ក៏ពុំត្រូវផ្តល់ទៅអោយអ្នកមានវ័យក្មេងធ្វើដែរ ។ ឬក៏ការងារសម្រាប់មនុស្ស ប្រុស ក៏ពុំត្រូវចែកអោយមនុស្សស្រីធ្វើ ឬផ្ទុយទៅវិញដែរ « *ទហរេហិ កាតព្វំ មហល្លកេហិ, មហល្លកេហិ កាតព្វំ ទហរេហិ, ឥត្ថីហិ កាតព្វំ បុរិសេហិ, បុរិសេហិ កាតព្វំ ឥត្ថីហិ អការេត្វា* » (ទីឃនិកាយ អដ្ឋកថា សុមង្គលវិលាសនី) ។ សេចក្តីនេះ បញ្ជាក់នូវការធានាលក្ខខណ្ឌត្រឹមត្រូវ និងសមស្របនៃការងារ, និងផ្តល់ ការទទួលស្គាល់នូវសមត្ថភាព និងជំរើស ( ចំណូលចិត្ត ) របស់បុគ្គលផងដែរ ។ អត្ថន័យនេះ ក៏បង្ហាញផងទៀត នូវកង្វល់ចំពោះភាពសមស្របរបស់និយោជិត (the fitness of the worker) ការគោរពចំពោះវ័យ និងភេទ និងការមិនកេងប្រវ័ញ្ច លើពលកម្ម របស់ស្ត្រីភេទ ។ គេត្រូវតែលុបបំបាត់ពលកម្មពេលយប់ ( Night shifts ) សម្រាប់ស្ត្រី ហើយពលកម្ម . កុមារ ក៏មិនត្រូវអោយមានដែរ ។

ខ/ ការចែកចំណីអាហារ និងការផ្តល់ប្រាក់ឈ្នួលពលកម្ម « *ភត្ត - វេតនានុប្បទានេន* » (ទីឃនិកាយ) ។ ពុទ្ធសាសនា បានប្រកាសគោលនយោបាយ ប្រាក់ឈ្នួលតែមួយ ។ ក្នុងការពន្យល់កាតព្វកិច្ចរបស់និយោជក ចំពោះការផ្តល់ « អាហារ និងប្រាក់ឈ្នួល », អដ្ឋកថាចារ្យបាននិយាយថា កាលៈទេសៈរបស់មនុស្សម្នាក់ៗ ត្រូវតែបានយកមកពិនិត្យ ពិចារណា ដោយឡែកៗពីគ្នា ហើយប្រាក់ឈ្នួល ក៏គួរ កំណត់ទៅតាមចំនួនបន្ទុក ( dependants ) ក្នុងគ្រួសារដែរ (ទីឃនិកាយ . អដ្ឋកថា) ។ តួយ៉ាង មនុស្សមានគូស្រករហើយ មានកូនក្នុងបន្ទុក (ខុទ្ទកបុត្តោ) គប្បី ទទួលប្រាក់ឈ្នួលបានលើសអ្នកនៅលីវ « ឯកវិហារិ » (ទីឃនិកាយ . អដ្ឋកថា) ។ គោលទស្សនៈបែបនេះ សមស្របទៅនឹងមាត្រា ២៣. ចំណុច ៣ ដោយពិតប្រាកដ ហើយធានាចំពោះពលករ នូវ « ប្រាក់ឈ្នួលត្រឹមត្រូវ និងសមស្រប » ដើម្បីអោយ

ពលករ និងគ្រួសាររបស់គេ អាចរស់នៅ « មានជីវិតថ្លៃថ្នូរ សមនឹងកិត្តិយសជាមនុស្ស » ។ អដ្ឋកថាក៏បានចែងផងដែរថា ពលកម្មធ្ងន់ធ្ងរចំពោះពលករ គប្បីចៀសវៀង ហើយគេមិនគប្បីប្រើពលករធ្វើការដោយឥតប្រាក់ឈ្នួលឡើយ ។

គ/ ធានាការពារសុខភាពរបស់និយោជិត . និយោជិតា «គិលានុបដ្ឋាក» ( ទីឃនិកាយ ) ។ ចំពោះវិស័យនេះ ពុទ្ធសាសនាបានគិតគូរមកអស់ច្រើនសតវត្សហើយ ។ ធម្មនុញ្ញអន្តរជាតិ ទើបតែចាប់ផ្តើមគិតគូរកាលពីអឌ្ឍភាគទីមួយនៃទសវត្សនេះប៉ុណ្ណោះ នូវការថែទាំសុខភាពពលករ និងការពារពលករ ទល់នឹងគ្រោះថ្នាក់ដល់សុខភាព ក្នុងពេលកំពុងធ្វើការងារ ។ អដ្ឋកថាចារ្យបាននិយាយថា ក្នុងករណីមានជំងឺ, និយោជិត-និយោជិតា ត្រូវបានសម្រាកពីការងារ ដោយមានការថែទាំសុខភាព និងអាហារ . ចំណីចាំបាច់ « *គិលានុប្បដ្ឋានេនាទិ អផាសុកកាលេ កម្មំ អការេត្វា សប្បាយភេសជ្ជាទីនិ ទត្វា បដិជគ្គនេន* » ( ទីឃនិកាយ . អដ្ឋកថា ) ។ សព្វថ្ងៃ ទស្សនៈនេះត្រូវបានបញ្ចូលទៅក្នុងការធានារ៉ាប់រង (insurance) ទល់នឹងជំងឺតម្កាត់ និងគ្រោះថ្នាក់ពលកម្មផ្សេងៗ ទៀត ។

ឃ/ បង្កើតទំនាក់ទំនងជិតស្និទ្ធជាមួយនិយោជិត . និយោជិតា « *អច្ឆរិយានំ រសានំ សំវិភាគេ* » ( ទីឃនិកាយ ) ។ តាមន័យត្រង់នៃពាក្យ វាមានន័យថា «ដោយការចែករំលែកភាពទន់ភ្លន់ ល្អក់ល្អឺន មិនធម្មតា » ជាមួយនិយោជិត ។ អាកប្បកិរិយានេះ ប្រាកដជាអាចជំរុញស្មារតីមិត្តភាពឡើងខ្ពស់ដល់កំពូល, ម្ល៉ោះហើយតែងនាំមកនូវលទ្ធផល គឺទំនាក់ទំនងស្និទ្ធស្នាលក្នុងពលកម្ម រវាងនិយោជក និងនិយោជិត ហើយនិងស្មារតីស្រឡាញ់មនុស្សជាតិជាទូទៅ ។

ង/ ការទទួលស្គាល់សិទ្ធិរបស់និយោជិត . និយោជិតា ក្នុងការបានសម្រាកលំហែ « *សមយេ វោសគ្គៈ* » ( ទីឃនិកាយ ) ។ នេះមានន័យសំដៅថា ធ្វើការមានកំណត់ពេលម៉ោង ។ ការសម្រាកលំហែ ត្រូវបានគេពន្យល់ថា មានពីរ

យ៉ាង ១.សម្រាកពីកិច្ចការ ឬពីការងារតាមពេលវេលាកំណត់ ក្នុងអំឡុងម៉ោងធ្វើការ « *និច្ចសមយេ វោសជ្ជនៈ* » ( ទីឃនិកាយ . អដ្ឋកថា ) ។ ២. ការសម្រាកតាមរដូវកាល ដែលគេអនុញ្ញាតអោយសម្រាប់ថ្ងៃបុណ្យជាតិជាដើម « *កាលសមយេ វោសជ្ជនៈ* » ។

កថាខណ្ឌ ២ នៃមាត្រា ២៣ បានចែងពីសិទ្ធិរបស់បុគ្គលម្នាក់ៗ « ដោយគ្មានការរើសអើង .... ចំពោះប្រាក់ឈ្នួលស្មើគ្នា សម្រាប់ការងារស្មើគ្នា » ។ សេចក្ដីប្រកាសអំពីសិទ្ធិនេះ ត្រូវបានគេលើកឡើងដើម្បីលុបបំបាត់គំនិតរើសអើង អោយតម្លៃលើសញ្ជាតិ, ពូជជាតិ, សម្បុរស្បែក ឬភេទ ដែលគេបានលុបបំបាត់មកយូរហើយ, ប៉ុន្តែ នៅក្នុងប្រទេសខ្លះ កំពុងតែប្រកាន់គំនិតរើសអើងនេះនៅឡើយ ដើម្បីកំណត់ប្រាក់ឈ្នួលពលកម្ម ។ អត្ថន័យសំដៅដល់ត្រង់ចំណុចនេះ គឺលក្ខណៈវិនិច្ឆ័យតែមួយគត់ (the only criteria) សម្រាប់កំណត់ប្រាក់ឈ្នួល អាចជាប្រភេទពលកម្ម, តម្លៃ (value) ពលកម្ម ចំពោះសហគមន៍, ជំនាញរបស់ពលករ, និងគុណសម្បត្តិនៃពលកម្ម ។ បើទោះជាសិទ្ធិ មិនត្រូវបានចែងជាពាក្យពេចន៍ដូចនេះ នៅក្នុងអត្ថបទឯណានីមួយរបស់ពុទ្ធសាសនាក៏ដោយ, ក៏វានៅតែមានន័យច្បាស់លាស់ណាស់ថា ពុទ្ធសាសនា បានផ្ដល់ទម្ងន់ទៅលើហេតុការណ៍ ដែលថាមនុស្សទាំងអស់ កើតមកមានសេរីភាព និងមានសមត្ថភាពរស់នៅក្នុងសេចក្ដីថ្លៃថ្នូរ និងក្នុងសិទ្ធិទាំងឡាយ ។ ជាមួយនឹងទម្ងន់នៃទស្សនៈនេះ ពុទ្ធសាសនាបានប្រឆាំងយ៉ាងដាច់ខាត ចំពោះទម្រង់ឯណានីមួយនៃការរើសអើងមកពីខាងក្រៅ នៅក្នុងរចនាសម្ពន្ធប្រាក់ឈ្នួល ។

ចំពោះសិទ្ធិ ( ដែលបានបញ្ជាក់ក្នុងកថាខណ្ឌ ៤ ) ដើម្បីបង្កើត និងចូលរួមក្នុងសហជីព, វាជាការជាក់ស្ដែងហើយដែលថា នៅក្នុងសម័យកាលនៃព្រះពុទ្ធ, សិទ្ធិបែបនេះមិនទាន់កើតមានទេ ។ ចាប់ពីត្រឹមសម័យពុទ្ធកាល រហូតដល់សម័យ

រង្វង់ឆ្នាំ ៥០០ នៃគ្រឹស្តសករាជ ( ដែលនៅក្នុងសម័យកាលនេះ ប្រពៃណីពុទ្ធសាសនាបានអភិវឌ្ឍ, បានចងជាប្រព័ន្ធរឹងមាំ និងបានឆ្លាក់ជាប់ឫសផ្ដៃក្នុងរបស់ខ្លួន នូវទស្សនៈ ( concepts ) និងតម្លៃ ( values ) ដែលទាក់ទងនឹងការសង្កេតនេះ ), សង្គមមនុស្សមិនទាន់កើតមានការជិះជាន់នៅឡើយទេ, មនុស្សនៅបែងចែកផលិតផលបានមកពីពលកម្មនៅឡើយ ។ ទ្រឹស្តី នៃ « ការកេងប្រវ័ញ្ច » និង « តម្លៃលើស » ( surplus valus ) ក៏នៅមិនទាន់គេស្គាល់ដែរនៅពេលនោះ ។ ជាងនេះទៀត, ពលករ ដែលជាអ្នកធ្វើការបំរើខ្លួនឯង, ជាពិសេស ជាសិប្បករ តែងមានក្រុម ឬសមាគមរបស់ខ្លួន ដើម្បីការពារអត្ថប្រយោជន៍ពិសេសរបស់ខ្លួនដែរ ។ មានភស្តុតាងជាអត្ថបទយ៉ាងទូលំទូលាយផងដែរ ដើម្បីបង្ហាញថា ពុទ្ធសាសនា ដែលជាលទ្ធិមានលក្ខណៈប្រជាធិបតេយ្យក្នុងទស្សនៈវិស័យ បានទទួលស្គាល់ «សិទ្ធិមានសេរីភាពក្នុងការប្រជុំ និងក្នុងការបង្កើតជាសមាគមដោយសន្តិភាព » ដូចដែលមានចែងនៅក្នុងសេចក្ដីប្រកាសត្រង់មាត្រា ២០ ដែលចែងថា ៖ ១. មនុស្សម្នាក់ៗ មានសិទ្ធិប្រជុំ និងបង្កើតសមាគមដោយសេរី, ២. គ្មាននរណាម្នាក់ ត្រូវបានគេបង្ខំអោយចូលក្នុងសមាគមណាមួយដែលខ្លួនមិនស្ម័គ្រចិត្តនោះឡើយ ។ សិទ្ធិនេះ ត្រូវគ្នានឹងប្រការទាំងប្រាំខាងដើមនៃអដ្ឋង្គិកមគ្គ ដែលបានរៀបរាប់ខាងលើ, ទាក់ទងនឹងលក្ខខណ្ឌពលកម្ម ហើយនិងទំនាក់ទំនងនិយោជក . និយោជិត ។ សិទ្ធិនេះនឹងបង្ហាញអោយឃើញថា នៅក្នុងស្ថានភាពសព្វថ្ងៃ, ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធអាចផ្ដល់ការគាំទ្រយ៉ាងពិតប្រាកដដល់មនុស្សគ្រប់រូបអោយមានសិទ្ធិ « បង្កើត និងចូលរួមសហជីព ដើម្បីការពារអត្ថប្រយោជន៍របស់ខ្លួន » ។

នៅក្នុងចំណុចនេះ គេអាចនិយាយថា ពុទ្ធសាសនាយល់ស្របទាំងស្រុងជាមួយនឹងសិទ្ធិទាំងឡាយ ដែលមាននៅក្នុងមាត្រា ២៣ ហើយការមិនប្រតិបត្តិតាមសិទ្ធិ ទាំងនោះអាចជាការរំលោភបំពានលើគោលការណ៍សំខាន់ៗ របស់ពុទ្ធសាសនា ។

គឺចាប់ផ្តើមពីចំណុចទស្សនៈនៃគោលដៅរបស់ខ្លួននេះហើយ ដែលពុទ្ធ-សាសនា បានធ្វើការពិចារណាវាយតម្លៃលើសកម្មភាព ( អំពើ ) ទាំងអស់ ។ ដូច្នេះទស្សនៈយល់ដឹងរបស់ពុទ្ធសាសនា បានត្រូវគ្នា ហើយស្របស្រួលគ្នាជាមួយមាត្រាទាំងឡាយ ដែលមានចែងនៅក្នុងសេចក្តីប្រកាសសកល ស្តីពីសិទ្ធិមនុស្ស រហូតដល់កំរិតដែលសិទ្ធិទាំងឡាយនោះ បានជួយសម្រួលដំណើរប្រព្រឹត្តទៅមុខរបស់មនុស្សឆ្ពោះទៅរកគោលដៅពុទ្ធសាសនា , ហើយដើម្បីទៅដល់គោលដៅនេះ ពុទ្ធសាសនាមិនដែលបង្ខិតបង្ខំអ្នកណាសោះឡើយ ។

សិទ្ធិដូចដែលគេបានយល់សព្វថ្ងៃ គឺជាអត្ថប្រយោជន៍ដែលបានច្បាប់ការពារ ។ ហើយសិទ្ធិទាំងឡាយរបស់មនុស្ស នៅក្នុងទស្សនៈរបស់ពុទ្ធសាសនា គឺជាអត្ថប្រយោជន៍ទាំងឡាយ ដែលនាំទៅរកសុខុមាលភាពរបស់មនុស្សជាតិ *(ពហុជន-ហិតៈ - ពហុជនសុខៈ)* - ទៅរកអត្ថប្រយោជន៍ ដែលកើតចេញមកពីសំណូមពរទាំងឡាយផ្ទាល់របស់បុគ្គល ( អត្តហិតៈ ), និងដែលកើតចេញមកពី « ស្មារតីបំពេញករណីយកិច្ច និងកាតព្វកិច្ចចំពោះសព្វសត្វ » ( បរហិតៈ ) ។ សំណូមពរទាំងនេះត្រូវបានចាត់ទុកជាសំណូមពរត្រឹមត្រូវ ដរាបណា អត្ថប្រយោជន៍ទាំងនោះ មិនផ្អែកលើលោភៈ ទោសៈ និងមោហៈ ដែលជាបាបធម៌បីដ៏ចម្បង, ជាមេនាំបង្កអោយកើតមានអំពើអាក្រក់ជាច្រើនប្រការនោះទេ ។

គន្ថនិទ្ទេស :

- Encyclopedia of Buddhism
  Vol V Fasciele 3 ( p.p 487 - 496 )
  Human Rights by L.P.N Perera
- Documents on Human Rights by
  Cambodian Institute of Human Rights
- វចនានុក្រមខ្មែរ - ជ. ណាត
- សេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស បោះពុម្ពដោយ ADHOC

# ប្រវត្តិខ្លែងឮង ឬ ខ្លែងអែក និងប្រពៃណីបង្ហើរខ្លែង

តាំងពីយូរយាណាស់មកហើយ ប្រទេសកម្ពុជា និងប្រទេសមួយចំនួនក្នុងពិភពលោកនេះ តែងតែមានប្រពៃណីបង្ហើរខ្លែង ប៉ុន្តែមានពិធីធ្វើខុសប្លែកគ្នា ពីប្រទេសមួយទៅប្រទេសមួយ ត្រង់រដូវកាលនៃការបង្ហើរ និងរូបភាពនៃខ្លែង និងពិធីបង្ហើរ ដែលធ្វើជាពិសេសទៅតាមប្រពៃណី និងជំនឿរបស់ជាតិ សាសន៍នីមួយៗ ។

ជាប្រការគួរឱ្យស្តាយបំផុត ពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៥ ពិធីបង្ហើរខ្លែងនៅក្នុងប្រទេសត្រូវបានផ្អាកសកម្មភាព ដោយប្រទេសយើងមានអសន្តិសុខ ហើយចាប់តាំងពីឆ្នាំ ១៩៧៥ រហូតដល់ឆ្នាំ ១៩៧៩ សូម្បីតែខ្លែងមួយធ្វើអំពីក្រដាស ឬពីស្លឹកប៉ប្រកស្ងួត ក៏គេពុំឃើញមានបង្ហើរនៅលើដែនអាកាសខ្មែរដែរ ព្រោះនៅសម័យនោះ វប្បធម៌ ប្រពៃណីខ្មែរ ត្រូវបានហាមឃាត់យ៉ាងតឹងរ៉ឹងបំផុត ។ ក្រោយឆ្នាំ ១៩៧៩ គេឃើញ មានក្មេងៗ បានផ្តើមបង្ហើរខ្លែងខ្លះៗវិញ ។

នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានចាត់ចែងរៀបចំធ្វើពិធីបង្ហើរខ្លែងនេះឡើងវិញ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស ក្នុងគោលបំណងស្តារ និងថែរក្សាប្រពៃណី ទំនៀមទម្លាប់ជាតិខ្មែរយើងឱ្យគង់វង្ស ជាពិសេសចង់ដាស់ស្មារតីកូនចៅខ្មែរជំនាក់នេះ និងជំនាន់ក្រោយៗ ទៀតឱ្យដឹងថាបុព្វបុរស ជាដូនតារបស់ខ្លួន បានបន្សល់ទុកនូវប្រពៃណី ទំនៀមទម្លាប់មួយពិសេសសំរាប់ជាតិសាសន៍របស់ខ្លួន ។

នៅថ្ងៃទី ២៥-២៦ ខែធ្នូ ឆ្នាំ១៩៩៦ នេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានប្រារព្ធពិធីបង្ហើរខ្លែងនេះ ជាលើកទីពីរ ដើម្បីអបអរសាទរដល់ចលនាបង្រួប

បង្រួមជាតិ ក៏ដូចជាទទួលស្វាគមន៍ចំពោះសន្តិភាពនៅព្រះរាជាណាចក្រ កម្ពុជា ។

តទៅនេះ យើងនឹងសិក្សាអំពីប្រពៃណីនៃការបង្ហើរខ្លែងខ្មែរ ដែលមានពីសម័យមុន ហើយដែលយើងអាចរៀបរាប់ ដូចតទៅ ៖

របៀបរបបបង្ហើរខ្លែង បានឆ្លុះបញ្ចាំងនូវចរិតរបស់សង្គមខ្មែរ ដែលរស់នៅផ្សារភ្ជាប់នឹងធម្មជាតិ ទទួលឥទ្ធិពលពីធម្មជាតិ និងប្រើប្រាស់ថាមពលធម្មជាតិសម្រាប់បំរើការរស់នៅ និងការកំសាន្ត ។

ម្យ៉ាងទៀត ប្រពៃណីនៃការបង្ហើរខ្លែង មិនគ្រាន់តែជាពិធីមួយធ្វើឡើងសំរាប់ជាការកំសាន្តប៉ុណ្ណោះទេ ប៉ុន្តែ ក៏ជាពិធីមួយសំរាប់គោរពបូជាដល់សាសនាសំខាន់ទាំងពីរផងដែរ ដែលប្រជាជនខ្មែរធ្លាប់ជឿ និងគោរពតាំងពីដើមរៀងមក គឺ ៖ ព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា ។

## I. ប្រភពកំណើត និងពិធីបង្ហើរខ្លែងខ្មែរ

### *១ . ប្រវត្តិខ្លែងឰង ៖*

មានរឿងព្រេងនិទានជាច្រើន ដែលទាក់ទងទៅនឹងដើមកំណើតខ្លែង និងការបង្ហើរខ្លែង ។ នៅក្នុងសៀវភៅរឿង « ធនញ្ជ័យ » ក៏បាននិយាយដល់ការបង្ហើរខ្លែង គឺនៅពេលដែលធនញ្ជ័យជាប់គុកសិរីទ្ធិនៅប្រទេសចិន ។ ដោយសារការបកស្រាយសំឡេងអែក (១) ដែលភ្ជាប់នឹងក្បាលខ្លែង ធនញ្ជ័យត្រូវបានរួចពីការឃុំឃាំង ហើយមានសេរីភាពឡើងវិញ ។

ឯកសារមួយទាក់ទងទៅនឹងប្រវត្តិខ្លែងឰង មានដំណាលថា ៖ « កាល

---

(១) អែកនៃខ្លែងធនញ្ជ័យ បន្លឺសំឡេងថា « ចង់ស៊ី ! ចង់ស៊ី ! ចង់ស៊ី ! » គឺចង់ស៊ីស្តេចស្រុកចិន ។ ហោរាទាយថា ទាល់តែដោះលែងធនញ្ជ័យជាអ្នកប្រាជ្ញស្រុកខ្មែរ ទើបសត្វនេះឈប់ស្រែកថា ចង់ស៊ី !

នោះ មានព្រះរាជាមួយអង្គ ទ្រង់បានចេញព្រះរាជបញ្ជាឱ្យគេយកទង់ព្រលើងមកធ្វើជាខ្លែងបង្ហើរ ដើម្បីឱ្យប្រជារាស្ត្រដឹងថា ជាព្រលឹងព្រះរៀមរបស់ព្រះអង្គ ដែលហោះអណ្តែតទៅកាន់ឋានលើ » ។ ចំពោះសំឡេងអែក ពិរោះគួរឱ្យស្រណោះស្រណោកនោះ គឺជាទំនួញសោយសោកអាឡោះអាល័យរបស់ព្រះរាជវង្សានុវង្ស និងប្រជារាស្ត្រ ចំពោះម្ចាស់ដែនដីរបស់ខ្លួនដែលបានសោយទីវង្គតទៅ ។ លុះដល់តំណក្រោយៗមក ពាក្យថា «ខ្លែងព្រលើង» នេះ ក៏នាំគ្នាហៅក្លាយមកថា «ខ្លែងឰង» ទៅវិញ ។

អ្នកស្រី ពេជ . សល់ សមាជិកក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៃពុទ្ធសាសនបណ្ឌិត្យ បានឱ្យយោបល់ថា ៖ ពាក្យ « ខ្លែងឰង » នេះ ដោយផ្អែកទៅលើកំណត់ហេតុរបស់ជូតាក្វាន់ បេសកជនចិន ដែលបានមកទស្សនាប្រទេសកម្ពុជា ក្នុងរវាង គ.ស. ១២៩៦ បានឱ្យដឹងថា ៖ នគរខ្មែរយើងពីដើម ឈ្មោះ « នគរភ្នំ » ឬ « នគរវ្នំ » ។ ចិនហៅពាក្យនេះ មិនត្រូវតាមសូរសៀងដើម គឺហៅបានត្រឹម « វណាន ឬហ្វូណាន » ។ ដូច្នេះ អ្នកស្រី ពេជ . សល់ ក៏សន្និដ្ឋានថា ៖ ប្រហែលជាខ្លែងឰងនេះក្លាយមកពីពាក្យ « ខ្លែងភ្នំ ឬខ្លែងអ្នកនគរភ្នំ » ហើយក្រោយមក ក៏ហៅក្លាយជា « ខ្លែងឰង » តែម្តងទៅ ។ តែអ្នកស្រី ក៏នៅមានការសង្ស័យម្យ៉ាងទៀតដែរថា ប្រហែលជាខ្លែងរបស់ជនជាតិព្នងទេដឹង ? ។

មានរឿងព្រេងនិទានមួយទៀត របស់ជនជាតិភាគតិច នៅខេត្តរតនគិរី ដែលពាក់ព័ន្ធដល់ដើមកំណើតនៃខ្លែងឰងនេះ បាននិណាលមកថា ៖ អស់កាលជាយូរលង់ណាស់មកហើយ មានកសិករជនជាតិតំបន់ភ្នំពីរនាក់ប្តីប្រពន្ធ មានកូនប្រុសម្នាក់ អាយុ ១៣ ឆ្នាំ ឈ្មោះ « រំផ្លង់ » ដែលមានប្រាជ្ញាវាងវៃខុសប្លែកពីក្មេងឯទៀតនៅក្នុងភូមិ ។ ថ្ងៃមួយ នៅពេលដែលវាត្រឡប់មកពីចំការវិញ កុមាររំផ្លង់បានឆ្មៀងចូលទៅអង្គុយលេងនៅលើផ្ទាំងថ្មរាបស្មើមួយ មើលទឹកជ្រោះដ៏ថ្លាឆ្វង់

ហូរកាត់ភ្នំ តាមចន្លោះដុំថ្មនាចង្កេះភ្នំ ។ ពេលនោះ កុមារបានឃើញស្លឹកឈើទុំមួយធំ ធ្លាក់ពីលើមកសន្សឹមៗ រេចុះឡើង មុននឹងធ្លាក់ដល់ដី ។ រំផ្លង់ចាប់អារម្មណ៍យ៉ាងខ្លាំង ហើយក៏រត់ទៅរើសយកមកចងខ្សែបង្ហើរលេងយ៉ាងសប្បាយតែម្នាក់ឯង ។ ឯកុមារដទៃទៀត ដែលរស់នៅក្នុងភូមិជាមួយ ក៏នាំគ្នាយកស្លឹកឈើប្រភេទនោះ មកចងខ្សែបង្ហើរលេងតាមកុមាររំផ្លង់ដែរ ។ ថ្ងៃមួយ ស្លឹកឈើរបស់កុមាររំផ្លង់ក៏ស្វិតស្រពោនរេចរិល ធ្លុះធ្លាយជាច្រើនអន្លើ ហើយក៏លែងហោះហើរបានដូចមុនទៀត ។ កុមារកំសត់ ដោយពុំបានលេងកំសាន្តសប្បាយដូចមុន ក៏អង្គុយយំសោកស្តាយដោយក្តីអស់សង្ឃឹម ។ ឃើញដូច្នោះ តាចាស់ម្នាក់ឈ្មោះ « កាលែងពោនង » មានចិត្តអាណិតកុមារពន់ពេក ក៏យកក្រណាត់មួយផ្ទាំងធំ មកច្នៃឱ្យហោះហើរបាន ហើយប្រគល់ទៅឱ្យកុមាររំផ្លង់ចងបង្ហើរលេង ។ កុមារមានការរីករាយឡើងវិញ ។ ដោយក្រណាត់ដែលតាចាស់យកមកឱ្យរំផ្លង់នោះ មានឈ្មោះពិបាកហៅពេក ក្រោយមក គេក៏នាំគ្នាហៅឈ្មោះលោកតានោះជាជំនួសវិញ គឺ « កាលែងពោនង » ។ លុះហៅយូរៗ ក៏ចេះតែក្លាយរូបកាន់តែខ្លី គឺ :

កាលែង > ខ្លែង ; ពោនង > ឰង

ដូច្នេះ ពាក្យថា « ខ្លែងឰង » នេះ ពីមុនគឺជាឈ្មោះដើមរបស់លោកតា « កាលែងពោនង » ដែលជាឈ្មោះរបស់ជនជាតិ តំបន់ព្រៃភ្នំ ម្នាក់នោះឯង ។ ឯទីវាលមួយ នៅខេត្តរតនគិរី ដែលកុមាររំផ្លង់ តែងបង្ហើរខ្លែងលេងនោះ មានឈ្មោះថាវាល « រំផ្លង់ » រហូតមកទល់សព្វថ្ងៃ ។

មានរឿងមួយទៀត ទាក់ទងនឹងប្រវត្តិខ្លែងនេះដែរ បាននិទានថា : កាលនោះ មានព្រានប្រមាញ់ម្នាក់ឈ្មោះ លុន ពណិ រស់នៅជាមួយនឹងកូនកម្លោះពីរនាក់, ប្រកបរបរបាញ់សត្វព្រៃ និងដាំដំណាំសំរាប់ជាមធ្យោបាយចិញ្ចឹមជីវិត ។ ក្នុងពេលទៅបរបាញ់សត្វ យុវជនទាំងពីរ ចាប់បានខ្លែងពណិមាសមួយគូ ដែលមានពណ៌ល្អ

ប្លែកលើសខ្លែងដទៃ ។ កាលណា គេទៅលក់ផលិតផលប្រមាញ់របស់គេនៅឯផ្សារ គេក៏បានយកខ្លែងពណិមាសទាំងគូរបស់គេទៅជាមួយផងដែរ ។ ថ្ងៃមួយ មានរាជ-បុត្រីពីរអង្គយាងមកក្រសាលនៅទីផ្សារដែរ ។ ពេលបានឃើញខ្លែងពណិមាស របស់អ្នកប្រមាញ់កម្លោះល្អប្លែកដូច្នេះ ព្រះនាងក៏ចាប់ចិត្តស្រឡាញ់ខ្លែងនេះពន់ពេក ហើយក៏និយាយសុំទិញពីបុរសទាំងពីរនាក់ ដើម្បីយកទៅបង្ហើរលេងនៅឯរាជវាំង ។ តែយុវជនទាំងពីរនាក់ ដោយខ្លួនក៏ស្រឡាញ់ខ្លែងនេះខ្លាំងណាស់ដែរនោះ ក៏ទូលថា : « ទូលបង្គំមិនលក់ទេ » ។ ដើម្បីបានលេងសប្បាយ រាជបុត្រីក៏និយាយសុំខ្ចីខ្លែងនេះលេងរួមជាមួយនឹងម្ចាស់ខ្លែងផង នៅទីវាលមួយក្បែរនគរ «គុជ្ជោរសិលា» ។ យុវជនយុវតីទាំងបួន យកខ្សែវែងមកចងជើងខ្លែង ហើយព្រលែងឱ្យវាហើរទៅលើអាកាស ។ គេទាំងអស់សប្បាយនឹងល្បែងនេះពន់ពេកណាស់ ។ ដោយសារបានរស់នៅជិតស្និទ្ធនឹងគ្នារៀងរាល់ថ្ងៃ មិនយូរប៉ុន្មាន កម្លោះក្រមុំទាំងពីរគូ ក៏ចាប់ចិត្តស្រឡាញ់គ្នាកាន់តែខ្លាំងឡើងៗ ។ ឯសត្វខ្លែងពណិមាសវិញ ដោយត្រូវទទួលការលំបាកហេវហត់បាក់កម្លាំងពីការបង្ហោះបង្ហើរឥតស្រាកស្រាន្តជារៀងរាល់ថ្ងៃដូច្នេះ ថ្ងៃមួយក៏ចាប់មានជំងឺជាទម្ងន់ ។ ទោះជាមានការព្យាបាលបែបណាពីយុវជនទាំងនោះ ក៏នៅទីបំផុតខ្លែងនោះស្លាប់ទាល់តែបាន ។ រីឯកម្លោះក្រមុំទាំងបួននាក់ ក៏បានសម្រេចចិត្តរៀបការជាប្តីប្រពន្ធ នៅពេលនោះទៅ ។

ដើម្បីរំលឹកនូវកម្រងអនុស្សាវរីយ៍ នៃសេចក្តីស្នេហារបស់ខ្លួន អ្នកទាំងបួន បានយកក្រណាត់មកធ្វើជាខ្លែងបង្ហើរយ៉ាងសប្បាយជំនួសខ្លែងបក្សីវិញ ។ រីឯអ្នកស្រុក អ្នកភូមិ ពិសេសក្រមុំកម្លោះដែលស្រឡាញ់គ្នាក្នុងរដូវរំហើយ ហើយចង់បានគ្នាជាប្តីប្រពន្ធ នាំគ្នាយកតម្រាប់តាមកម្លោះក្រមុំទាំងពីរគូ ហើយក៏នាំគ្នាបង្ហើរខ្លែងលេងដោយសប្បាយរីករាយ ។

នេះជាប្រភពកំណើតនៃការបង្ហើរខ្លែងរបស់ខ្មែរយើង ។

## ២ . ប្រវត្តិព្រះរាជពិធីបង្ហើរខ្លែង

ព្រះរាជពិធីបង្ហើរខ្លែងនេះ មានជាតំណតាំងពីយូរអង្វែងមកហើយ ។ លោក ហ៊្សេក សឺដែស អ្នកប្រាជ្ញបុរាណវិទូ នៃសាលាបារាំងចុងបូព៌ាប្រទេស បានរកឃើញសិលាចារឹកមួយក្នុងចុងចុល្លសករាជ ៨៩៤ ត្រូវនឹង គ.ស. ៩៧២ ។ អត្ថន័យនៃសិលាចារឹកនោះបានបញ្ជាក់អំពីការរៀបចំព្រះរាជពិធីបង្ហើរខ្លែង និងតង្វាយជាច្រើនមុខ ដូចជា : មាស ប្រាក់ សំរិទ្ធិ ភ្លុក លង្ហិន ពាន គ្រឿងភ្លេង លំពែង និងខ្លែង ៥ ទៀតផង ។ លោក ហ៊្សេក សឺដែស មិននឹកស្មានថា មានខ្លែង ៥ នៅក្នុងតង្វាយឯទៀតៗ ដែលសុទ្ធសឹងជាវត្ថុមានតម្លៃនោះសោះឡើយ ។ ប្រការដែលគួរឱ្យស្ដាយនោះគឺ : សិលាចារឹកពុំបានប្រាប់ឱ្យដឹងថា តើខ្លែងដែលមានចំណែកនៅក្នុងរណ្ដាប់តង្វាយនោះ គេប្រើប្រាស់សំរាប់ធ្វើអ្វីនោះឡើយ ។

នៅ គ.ស ១៥៩០ លោក កេរ៉្សូហ្សា ដឺសង់ អង់តូនីញ៉ូ ( Quiroza de San Antonio ) ជនជាតិពកទុយហ្គាល់ ដែលបានធ្វើដំណើរមកកម្ពុជា បានសរសេរទុកថា : ប្រជាជនខ្មែរបានចាត់ចែងធ្វើពិធីបង្ហើរខ្លែងដែលធ្វើពីក្រដាស និងដើមបបុស ។ ខ្លែងនោះមានចងខ្សែវែង ហើយអាចហោះហើរឡើងទៅលើអាកាសបាន កាលណាត្រូវខ្យល់បក់មក ។ ខ្លែងនោះមានបន្លឺស្នូរសំឡេងអ្វីមួយពិរោះគួរឱ្យចង់ស្ដាប់ ។ តាមឯកសាររបស់វិជ្ជាស្ថានលំនៅខ្មែរ បានបញ្ជាក់ថា : ការបង្ហើរខ្លែងគឺជាព្រះរាជពិធីមួយសំរាប់គោរពបូជាដល់ព្រះចូឡាមណីចេតិយ ដែលប្រតិស្ឋាននៅវិមានត្រៃត្រឹង្ស ។ ពិធីនេះត្រូវបានប្រារព្ធធ្វើឡើងចាប់ពីថ្ងៃទី ១២ រោច ដល់ថ្ងៃ ១៥ កើត ខែមិគសិរ ។ គេបានរៀបចំធ្វើរោងពិធីនៅគ្រប់ទិសទាំងបួន និងរោងធំមួយនៅចំកណ្ដាល ។ ព្រះសង្ឃជារាជាគណៈក្នុងព្រះនគរ ត្រូវបាននិមន្តមកចំរើនព្រះបរិត្តនៅគ្រប់រោងទាំងប្រាំ ដែលមានអុជគោមបំភ្លឺនៅតាមរោងនីមួយៗ ព្រមទាំងមានយកខ្លែងប្រាំ ទៅដាក់តាំងនៅទីនោះផងដែរ ។ ពិធីនេះបានធ្វើឡើងនៅក្នុង

រជ្ជកាលព្រះបាទ ស្រីសុរិយោពណ៌ ដែលគង់នៅព្រះបរមរាជវាំង ឧត្តុង្គមានជ័យ ។

ក្រោយតមកទៀត ក្នុងរជ្ជកាលព្រះបាទសម្តេចព្រះអង្គដួង ព្រះរាជកិច្ចប្រារព្ធពិធីបង្ហើរខ្លែងនេះក៏ត្រូវបានចាប់ផ្តើមធ្វើម្តងទៀត តាមលំនាំប្រពៃណីព្រះពុទ្ធសាសនា ។ រជ្ជកាលក្រោយៗ មកទៀត បន្ទាប់ពី គ.ស. ១៨៥៩ គេពុំឃើញមានការប្រារព្ធពិធីបង្ហើរខ្លែងនេះទៀតឡើយ ។ ប៉ុន្តែ ទោះបីយ៉ាងនេះក្តី ក៏ប្រជារាស្ត្រនៅគ្រប់ទិសទី នៃព្រះរាជាណាចក្រកម្ពុជា កាលណារដូវរំហើយចូលមកដល់ គឺខ្យល់បក់មកពីទិសខាងជើង[១] គេនាំគ្នាបង្ហើរខ្លែងលេងកំសាន្ត ទាំងចាស់ ទាំងក្មេង ក្រោយពីបានប្រមូលផលស្រូវរួចហើយ ។ ខ្លែងដែលប្រជាជនលេងនៅតាមនិគមជនបទផ្សេងៗ ទូទាំងប្រទេសនោះ ចែកជាពីរផ្នែក :

- ចាស់ៗ និយមបង្ហើរខ្លែងឡូង ឬខ្លែងអែក
- ក្មេងៗ លេងខ្លែងតូចៗ ដូចជា ខ្លែងកណ្តូង ខ្លែងបោពៅ ឬប្រពៅ ខ្លែងផ្កាយ ខ្លែងគោម ខ្លែងប៉ោត ។ ល ។

## II. ការចាត់ចែងរៀបចំពិធីបង្ហើរខ្លែង

*១ . ការសង់រោងពិធី*

តាមទម្លាប់ពីមុនរៀងមក គេត្រូវសង់រោងពិធីចំនួនប្រាំ គឺ :

- រោងតូចៗ នៅតាមទិសធំទាំង ៤ គឺខាងកើត ខាងជើង ខាងត្បូង និងខាងលិច ។
- នៅចំកណ្តាលរោងតូចទាំង ៤ គេសង់រោងធំមួយ មានទំហំ ១០ម x ៧ម ។ គឺនៅក្នុងរោងធំនេះហើយ ដែលជាវេទិកាកិត្តិយសសំរាប់ព្រះករុណា ជា

(១) ពិសេសគឺនៅខែ មិគសិរ

ម្ចាស់ជីវិតតម្កល់លើត្បូង ទ្រង់យាងមកជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់ ឬព្រះរាជតំណាង ជាកន្លែងសំរាប់ព្រះសង្ឃគង់ និងជាទីសំរាប់សំដែងនៃក្រុមរបាំ និងវង់តន្ត្រី មកប្រគំកំដរពិធីនេះផង ។ នៅក្នុងរោងធំនេះដែរ គេបានតាំងរូបសំណាកជាតំណាង ព្រះអា-ទិទេព ( ព្រះពាយ ) ដែលគង់លើអាសនៈសំរាប់ជាទីគោរពសក្ការៈ ក្នុងពិធីនេះ ។

នៅពេលព្រលប់នៃរាត្រីទីមួយ ក្រុមបារគូត្រូវដើរអុជភ្លើងគោម ដែលគេព្យួរនៅទីនោះឱ្យភ្លឺព្រោងព្រាត ។ គោមនេះ ត្រូវបានគេពន្លត់នៅពេលព្រលឹមស្រាងៗ នៃថ្ងៃបន្ទាប់ ។

នៅពេលព្រលប់នៃថ្ងៃទីពីរ មុនព្រះមហាក្សត្រ ឬព្រះរាជតំណាងយាងមកដល់ គេអុជភ្លើងគោមជាថ្មីម្តងទៀត ។ ព្រមពេលជាមួយនោះ អស់នាម៉ឺនសព្វមុខមន្ត្រី ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ និងប្រជារាស្ត្រដែលបានចូលរួម ក៏បានដុតទៀន ធូប ធ្វើពិធីបួងសួង បន់ស្រន់ សុំឱ្យបានសុខសប្បាយ សិរីសួស្តី សុភមង្គល នៅចំពោះរូបតំណាងព្រះអាទិទេព ( ព្រះពាយ ) ផងដែរ ។

### ២ . អំពីតង្វាយផ្សេងៗ

ក – តង្វាយភ្លេង

ពិធីដង្ហែខ្លែងត្រូវប្រារព្ធឡើងក្នុងបរិយាកាសយ៉ាងអឺកធឹក ដោយមានភ្ញៀវធំ តូច និងមហាជនចូលរួម ។ ដោយឡែកទៀត ដើម្បីញ៉ាំងឱ្យពិធីបុណ្យប្រកបដោយភាពមនោរម្យថែមទៀតនោះ ក្រុមតន្ត្រីពិណពាទ្យបានប្រគំបទភ្លេងដ៏ពិរោះរងំគួរជាទីរីករាយ ។ បទដែលតែងតែធ្លាប់ប្រគំក្នុងពិធីនេះមានជាអាទិ៍ ៖ បទក្រាណៃ បទដើត បទតង្វាយព្រះពាយ បទតង្វាយព្រះពិស្ណុការ បទអុំទូក ។ ល ។ បន្ទាប់មកព្រះសង្ឃ ៧ អង្គ និមន្តមកពិរត្ត ៧ ស្វាធ្យាយធមិជយន្តោ ចំរើនសិរីសួស្តីជ័យមង្គលដល់អ្នកដែលបានចូលរួមក្នុងពិធីនេះ ។

១ - តង្វាយរបាំ

បន្ទាប់ពីព្រះសង្ឃបានស្វាយធ្យាយព្រះសត្តប្បករណាភិធម្មរួចហើយ ក្រុមសិល្បៈចាប់សំដែងរបាំថ្វាយព្រះពិស្ណុការ របាំបាច់ផ្កា របាំទេពមនោរម្យ និងរបាំនាងមេខលាជាដើម ដើម្បីឧទ្ទិសថ្វាយចំពោះព្រះអាទិទេពទាំងឡាយក្នុងព្រហ្មញ្ញ - សាសនា មានព្រះសិវៈ ព្រះវិស្ណុ ព្រះព្រហ្ម ព្រះឥន្ទ ព្រះច័ន្ទ ព្រះអាទិត្យ ព្រះពាយ ។ ល ។

គ - គ្រឿងតង្វាយក្នុងរោងធំ

រោងធំដែលជារោងពិសេសចម្បង មានរៀបចំគ្រឿងតង្វាយសំខាន់ៗមួយចំនួន ដូចតទៅ :

- បាយសី ៣ ថ្នាក់ ១ គូ
- បាយសី ៥ ថ្នាក់ ១ គូ
- បាយសី ៧ ថ្នាក់ ១ គូ
- បាយសី ៩ ថ្នាក់ ១ គូ
- ដាវជ័យ ១, កាំបិតមាស ១, កាំបិតប្រាក់ ១, លំពែងពេជ្រ ១, ខ្លែងចំនួន ៥ ។ ក្រៅពីនេះ គេមានរៀបចំសំណែនជាម្ហូបចំណី និងគ្រឿងសក្ការៈផ្សេងៗរួមមាន :
- ចំអាប ១ ថាស បង្អែម ១ ថាស នំអន្សម នំគម នំបត់ គ្រឿងស្រ-វឹង ទៀនធូប ផ្កាភ្ញី ជាដើម ។

ឃ - គ្រឿងតង្វាយក្នុងរោងតូចៗ ទាំង ៤

ក្នុងរោងពិធីតូចៗ សង់នៅតាមទិសធំទាំងបួននោះ មានរៀបរណ្ដាប់ដូចគ្នាគ្រប់រោង ដូចជា : ផ្លែឈើគ្រប់មុខពីរថាស, ចំអាបពីរថាស ស្រា ទៀន ធូប ផ្កាកែវទឹក ជាដើម ។

៣ – ក្បួនដង្ហែខ្លែង

លុះក្រុមសិល្បៈរបាំសំដែងចប់សព្វគ្រប់ហើយ អាចារ្យបារគូបាននាំអ្នកបង្ហើរខ្លែងទាំងអស់កាន់ខ្លែងរៀងៗខ្លួន រួចធ្វើពិធីគោរពចំពោះព្រះអាទិទេព ព្រះពាយ ( ខ្យល់ ) នៅក្នុងរោងពិធីទាំងរោងតូចទាំងរោងធំ ។ បន្ទាប់មក គេនាំគ្នាដើរដង្ហែប្រទក្សិណជុំវិញទីលានបង្ហោះខ្លែងមួយជុំ ដោយមានក្រុមឆៃយ៉ាំប្រគំនាំមុខក្បួនផង ។ ក្បួនដង្ហែនេះក៏មានភ្ញៀវ និងមហាជនច្រើនកុះករចូលរួមយ៉ាងអឺកធឹកផងដែរ ។

កាលណាក្បួនដង្ហែបានប្រព្រឹត្តទៅបានមួយជុំហើយ អាចារ្យ បារគូក៏ចាប់ផ្តើមពិធីបង្ហោះខ្លែង តាមលំដាប់លំដោយតទៅ ។

## III . ប្រភេទខ្លែងខ្មែរ :

ប្រជាជនខ្មែរ បានច្នៃប្រឌិតខ្លែងជាច្រើនប្រភេទ ដែលមានទ្រង់ទ្រាយប្រហាក់ប្រហែលនឹងសត្វខ្លះ ឬដូចវត្ថុដែលគេប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃខ្លះ ។ គេឱ្យឈ្មោះប្លែកៗគ្នា ទៅតាមទ្រង់ទ្រាយនៃខ្លែងនោះ ដូចខាងក្រោម :

១ . ខ្លែងឪ្នង
២ . ខ្លែងកន្ទោង
៣ . ខ្លែងកណ្តុង
៤ . ខ្លែងខ្លោះ
៥ . ខ្លែងកូនមាន់
៦ . ខ្លែងបៅ ឬប្រប៉ៅ
៧ . ខ្លែងប្រមង់
៨ . ខ្លែងសាក់ ឬ ខ្លែងចាក់
៩ . ខ្លែងគោម
១៣ . ខ្លែងហោប៉ៅ
១៤ . ខ្លែងព្រះខែ
១៥ . ខ្លែងបណ្តើរកូន
១៦ . ខ្លែងប៉ោត
១៧ . ខ្លែងផ្កាយ
១៨ . ខ្លែងផ្កា
១៩ . ខ្លែងពស់
២០ . ខ្លែងនាគ
២១ . ខ្លែងកង្កែប

១០. ខ្លែងមេអំពៅ ២២ . ខ្លែងប្រជៀវ

១១. ខ្លែងស្វាប្រសាក់ ឬ ស្វាប្រចាក់ ២៣ . ខ្លែងប្រយុទ្ធ

១២. ខ្លែងយក្ស ២៤ . ខ្លែងឃ្លោក ឬខ្លែងក្អម

## IV . របៀបធ្វើខ្លែងញួន ឬ ខ្លែងអែក

មុននឹងធ្វើខ្លែង ចាំបាច់គេត្រូវជ្រើសរើសរកសម្ភារៈដែលជាគ្រឿងផ្សំផ្គុំនោះឱ្យមានគុណភាពល្អ និងគ្រប់មុខតាមសេចក្ដីត្រូវការ ។ របស់ផ្សេងៗ ដែលគេតែងត្រៀមទុកសំរាប់ធ្វើខ្លែងនោះ មាន :

១ . ឫស្សី [(១)] សំរាប់ធ្វើជាគ្រោងឆ្អឹងខ្លែង ឬដងអែក,

២ . ផ្ដៅ [(២)] សំរាប់ធ្វើអណ្ដាតអែក,

៣ . ក្រមួនសំរាប់បិតចុងអណ្ដាតអែកទាំងសងខាង,

៤ . ស្លឹកត្នោត ស្លឹកទ្រាំង ឬស្លឹកដូង សំរាប់ធ្វើកន្ទុយខ្លែង,

៥ . ជ័រពៅ្ន ឬបាយម៉ាន ឬជ័រកាវ សំរាប់បិទក្រដាសខ្លែង,

៦ . ក្រណាត់ទេសឯក ឬសូត្រ ឬក្រដាសយៃ សំរាប់ពាស ឬដាសតួខ្លែង និងផ្នែកបន្ទាប់បន្សំផ្សេងៗទៀតនៃខ្លែង ។

លុះប្រមែប្រមូលគ្រឿងសម្ភារៈ បានគ្រប់មុខអស់ហើយ ដំបូងឡើង គេត្រូវយកឫស្សីមកកាត់ទៅតាមខ្នាតដែលគេចង់បាន រួចហើយពុះច្រៀកបិតធ្វើជាដងអែកខ្លះ ធ្វើជាផ្នែកផ្សេងៗ នៃគ្រោងឆ្អឹងខ្លែងខ្លះ តូច . ធំ មូល ឬសំប៉ែត វែងខ្លីទៅតាមផ្នែករបស់វា ។

---

(១) ច្រើនយកឫស្សីស្រុកពេញចំណាស់ ដើម្បីប្រើជាប់បានយូរ ។ ជួនកាលបើគ្មានឫស្សីស្រុក គេក៏យកឫស្សីពីងពង់មកជំនួសក៏បានដែរ ។

(២) គេអាចប្រើស្លឹកត្នោត ឬ ស្លឹកទ្រាំងធ្វើអណ្ដាតអែកក៏បានដែរ ។

ក -ការធ្វើអែក ៖ គេយកឫស្សីដែលពុះច្រៀករួចហើយនោះយកមកបិតឱ្យស្អាតនឹងកាំបិតបន្ទះយ៉ាងមុត ។ ដងអែកដែលវែងបំផុតមិនសូវលើសពី ពីរម៉ែត្រឡើយ ។ គេធ្វើអែកវែង ឬខ្លី ទៅតាមទំហំខ្លែងធំ ឬតូច[1] ។ ជាធម្មតា ដងអែកច្រើនតែធំហើយក្រាស់នៅផ្នែកកណ្ដាល ហើយរាងរៀវបន្តិចនៅចុងទាំងសងខាងដែលគេតែងតែឆ្លាក់ធ្វើជាក្បាច់គន្លាក់ និងធ្វើជាចំពាមសំរាប់ទ្រខ្សែអែកឱ្យនៅចំត្រង់កណ្ដាលចំពាម ។ ដើម្បីឱ្យដងអែករឹងមាំនៅផ្នែកកណ្ដាលនោះ គេត្រូវយកបន្ទះឫស្សីមួយកំណាត់ទៀតមកចងអបស្របជាមួយនឹងដងអែក ដោយទុកចន្លោះប្រហោងល្មមតែអាចស៊កក្បាលខ្លែងបានជាប់រឹងល្អមិនឱ្យងាករេបាន ។

បន្ទាប់ពីធ្វើដងរួចហើយ គេក៏យកផ្ដៅចាស់មានដើមត្រង់ហើយស្មើល្អមកពុះច្រៀកបិតយ៉ាងផ្ចិតផ្ចង់ឱ្យសំប៉ែតស្ដើងស្មើសាច់ ហើយមានបន្ទារប៉ុនគ្នាពីចុងម្ខាងទៅចុងម្ខាង ។ នៅចុងអណ្ដាតអែកទាំងសងខាង គេលាក់ត្រង់កអណ្ដាតបន្តិចសំរាប់ចងខ្សែ[2] ភ្ជាប់ទៅនឹងចុងដងអែកទាំងសងខាង ។ ត្រង់កន្លែងមានគន្លាក់សំរាប់ចងខ្សែនោះ គេចោះប្រហោងតូចល្មមប៉ុនជើងធូបសំរាប់ស៊កខ្សែសាយអែក ។ ហើយ គឺនៅត្រង់កន្លែងនោះដែរ ដែលគេបិទក្រមួនឃ្មុំសំរាប់ធ្វើជាប៉ោលជួយឱ្យមានទម្ងន់យោលបង្វិលអណ្ដាតអែកទៅតាមកម្លាំងខ្យល់បក់ ។ មុនស៊កអែកទៅនឹងឆ្អឹងក្បាលខ្លែង គេត្រូវដំឡើងខ្សែសាយឱ្យតឹងល្មម ដែលធ្វើឱ្យដងអែករាងពត់វង់កោងបន្តិច ដូចទម្រង់ដងធ្នូដែលមិនទាន់យិតដូច្នោះឯង ។ ប៉ុន្តែតាមបទពិសោធន៍របស់អ្នកលេងខ្លែង មុនដាក់អែកបង្ហោះភ្ជាប់ជាមួយខ្លែង គេតែងចងខ្សែគ្រវីស្ដាប់សំឡេងអែកសាកមើលសិន ដើម្បីឱ្យដឹងថា តើសំឡេង

(១) បើខ្លែងតូច អែកធំនោះ វាមិនគ្រាន់តែគ្មានសមាមាត្រប៉ុណ្ណោះទេ ប៉ុន្តែ ខ្លែងយោងមិនរួច មិនអាចហោះហើរទៅលើអាកាសបាន ។ (២) ខ្សែនេះ គេហៅថា សាយអែក ច្រើនធ្វើពីសរសៃសូត្រ ទើបជាប់ល្អ ហើយងាយរំញ័រ តាមកម្លាំងខ្យល់បក់ ។

អែកឆ្លើយគ្នាល្អ ឬទេ ? ពីរោះឬទេ ? សំឡេងអែកឮ ចេញមកប៉ុន្មានសូរ ? ( notes ) ។ បើឮឆ្លើយគ្នាបានបួន ឬប្រាំសំឡេង ( notes ) នេះគេសន្និដ្ឋានថា ល្អណាស់ ! ពិរោះណាស់ ! អាចដាក់ភ្ជាប់ជាមួយខ្លែងបង្ហើរបាន ។ ផ្ទុយទៅវិញ បើកាលណាសំឡេងអែកឮតែបីសំឡេង ហើយមិនឆ្លើយគ្នារណ្ដំរងំទេនោះ អ្នកធ្វើអែកត្រូវមានវិធានការរិះរកវិធីកែសម្រួល ដោយបិតអណ្ដាតឱ្យកាន់តែស្ដើង ឬបិតសម្រួលឱ្យស្មើល្អ ឬក៏បន្ថែមបន្ថយក្រមួនដែលបិតនៅចុងអណ្ដាតធ្វើយ៉ាងណាទាល់តែសំឡេងអែកឆ្លើយឆ្លងបានពីរោះ ។ សូមជំរាបថា ពេលគ្រវីសាក គេយកមេដៃ និងចង្អុលដៃឈ្លេញបង្វិលសាយអែកឱ្យវិល រួចទើបគ្រវីឱ្យជក់ ។ ទាល់តែធ្វើយ៉ាងនេះ ទើបអណ្ដាតអែកវិល ហើយបន្លឺសំឡេងចេញមកបាន ។

២ - របៀបធ្វើតួខ្លែង

គេយកឫស្សីមកពុះជ្រៀកធ្វើឆ្អឹងទ្រូងដែលធំ ហើយរឹងមាំជាងឆ្អឹងផ្នែកដទៃទៀត ។ គេបិតឆ្អឹងទ្រូងនេះឱ្យរាងមូលសំប៉ែតបន្តិច ដែលត្រូវដាក់ចំកណ្ដាលតួខ្លែង តាំងពីក្បាលលើរហូតដល់គុម្ពកន្ទុយខ្លែង ។ ឆ្អឹងទ្រូងនេះ ជាផ្នែកសំខាន់ជាងគេ ជាមេមាំរឹង និងជាស្នូលកណ្ដាលនៃគ្រោងឆ្អឹងទាំងអស់ ។ នៅផ្នែកចុងខាងលើត្រង់ក្បាលខ្លែង គេបិតឆ្អឹងនេះឱ្យស្រួចបន្តិច ។ គឺត្រង់នេះហើយដែលជាកន្លែងសម្រាប់ស៊កអែកភ្ជាប់មកនឹងតួខ្លែង ។ បន្ទាប់មក គេបិតឫស្សីឱ្យមានសណ្ឋានរាងមូល សំរាប់ធ្វើជាតួសំខាន់នៃខ្លួនខ្លែង ។ ឆ្អឹងតួនេះមានពីរ គឺផ្នែកខាងលើ និងផ្នែកខាងក្រោម ដែលគេត្រូវចងផ្ដោបភ្ជាប់គ្នានៅខាងចុងស្លាបខ្លែងទាំងសងខាងឱ្យមានរាងបែបវៀវបន្តិចនៅខាងចុង ។ ទៅតាមចំណូលចិត្តរបស់អ្នកលេងខ្លែង ខ្លះគេច្នៃធ្វើចុងស្លាបនេះពត់ឱ្យង ក្រងក់ទៅខាងលើ ។ ឯអ្នកខ្លះទៀត មិនធ្វើក្បាច់ក្បូរអ្វីច្រើនទេ គឺគ្រាន់តែយកឆ្អឹងតួខាងលើ និងខាងក្រោមមកចងភ្ជាប់គ្នាជារង្វង់កោងនោះជាការស្រេច ។ ធ្វើយ៉ាងនេះ ខ្លែងមានរាងពងក្រពើបែបសំប៉ែតបន្តិច ។ លុះ

ចងឆ្អឹងតួលើក្រោមទាំងពីរភ្ជាប់គ្នាហើយ គេក៏បិតឫស្សីធ្វើផ្នែកខាងក្រោម[១] នៃតួសំខាន់របស់ខ្លែង គឺចង្កេះខ្លែងដែលភ្ជាប់ចុះមកក្រោម ប្រមាណជាបីដេស៊ីម៉ែត្រ ។ នៅខាងក្រោមចង្កេះខ្លែង គេធ្វើតួកូនខ្លែង ដោយពត់ចេញជារាង មានទម្រង់ជាក្បាច់ដូចរាងបេះដូងបន្តិច ដូចឃ្លោកសាយដៀវបន្តិច ។ បន្ទាប់ពីធ្វើរាងចង្កេះមក គេក៏ចាប់ធ្វើកន្ទុយរារបស់ខ្លែង ដោយយកខ្សែពីរចងតភ្ជាប់ពីផ្នែកខាងឆ្វេង និងខាងស្តាំចុះត្រង់មកខាងក្រោម ប្រមាណជាប្រាំបីដេស៊ីម៉ែត្រ អមអែបសងខាងឆ្អឹងទ្រូង ដែលលយវែងធ្លាក់ចុះមកដល់ផ្នែកនេះ ។ កាលណាសង់បានជារាងខ្លែងសព្វគ្រប់ផ្នែកទាំងអស់ហើយ គេក៏យកក្រណាត់ ឬក្រដាសយៃ យកមកពាសតាមគ្រោងឆ្អឹងខ្លែង ។ នៅត្រង់ជាយគ្រែងខាង១ គេបិតឱ្យត្រូវតាមគ្រោងឆ្អឹង ដោយប្រើជ័រល្មៅ[២] ឬបាយម៉ាន ឬកាវ ។ ក្រោយពីបានបិតក្រដាស ឬក្រណាត់តាមទម្រង់រាងខ្លែងបានល្អត្រឹមត្រូវហើយ គេក៏យកស្លឹកត្នោត, ស្លឹកទ្រាំង ឬស្លឹកចាកមកចាក់គួចតគ្នាធ្វើជាកន្ទុយខ្លែង ដែលតាមធម្មតាតែងតែមានពីរជាដរាប ។ បើខ្លែងមានទំហំកាន់តែធំ នោះគេត្រូវធ្វើកន្ទុយខ្លែងកាន់តែវែង ដើម្បីឱ្យមានសមាមាត្រផង និងមានលំនឹងល្អ ក្នុងការហោះហើររបស់ខ្លែងផង ។ ពេលចាក់កន្ទុយខ្លែងបានហើយ គេយកមកចងភ្ជាប់ទៅនឹងឈើទទឹងត្រង់ផ្នែកខាងក្រោមនៃកន្ទុយរា ។ ក្នុងការបង្ហោះខ្លែងសាកល្បងនោះ គេត្រូវពិនិត្យមើល បើកាលណាខ្លែងចេះតែវេ គ្រវីក្បាលហើយដាំទីងក្បាលចុះនោះ គេដឹងថាខ្លែងនោះស្រាលកន្ទុយ គេត្រូវបន្តថែមឱ្យវែងបន្តិចទៀត ។ ម្យ៉ាងទៀត គេត្រូវពិនិត្យ និងសម្រួលខ្សែទ្រូងផងដែរ[៣] ។

---

(១) ត្រង់នេះហៅថា ចង្កេះខ្លែង ។

(២) នៅស្រុកស្រែ គេនិយមប្រើតែជ័រល្មៅ ឬបាយម៉ានប៉ុណ្ណោះ ។

(៣) ខ្សែទ្រូង គឺខ្សែដែលចងត្រង់ប្រជុំឆ្អឹងទ្រូង និងឆ្អឹងស្លាបលើ ភ្ជាប់មកប្រជុំឆ្អឹងទ្រូង និងឆ្អឹងស្លាបក្រោម លៃអោយខ្លី ខេចខាងលើបន្តិច ។

## V . របៀបលេងខ្លែង

១ - តើគេបង្ហោះ [១] ខ្លែងនៅពេលណា ?

តាមទំនៀមទម្លាប់ខ្មែរយើងតាំងពីបុរមបុរាណមក គេតែងតែចាត់ចែងធ្វើពិធីបង្ហើរខ្លែង នៅថ្ងៃពេញបូរមី ខែមិគសិរ ។ នេះគឺជាកាលបរិច្ឆេទផ្លូវការដែលបានឯកភាពគ្នាទូទាំងប្រទេស ។ ប៉ុន្តែ ចំពោះប្រជាជនចាស់ ក្មេង នៅគ្រប់ទីតំបន់ជនបទ ស្រែចំការទូទាំងប្រទេសវិញ គេមិនកំណត់នៅថ្ងៃណានោះឡើយ ។ តែកាលណា គេទំនេរដៃពីការងារច្រូតកាត់ បោកបែន ប្រមូលផលដាក់ជង្រុកហើយនោះ គេនាំគ្នាចាប់បង្ហោះខ្លែងលេងយ៉ាងសស្រាក់សស្រាំ ។ យើងមិនពិបាកយល់អំពីបញ្ហាជ្រើសរើសពេលវេលា ដើម្បីលេងខ្លែងនោះទេ យើងគ្រាន់តែសង្កេតចំណាំមើលទៅក៏អាចដឹងថា នៅខែដែលមានខ្យល់រដូវ ( មុស្សុង ) បក់មកពីទិសខាងជើងជាប់មិនដាច់រយៈ នាំយកទាំងធាតុអាកាសត្រជាក់មកជាមួយផងនោះ គឺចំណុចនេះហើយជាលក្ខណសម្បត្តិដ៏ល្អ [២] សម្រាប់ការបង្ហើរខ្លែង ។ សូមជំរាបថា ភោគផលផ្សេងៗ ដែលតែងមកដល់ជាមួយនឹងការបង្ហើរខ្លែងនេះ គឺរដូវដាល់អំបុកដែលបរិបូរដោយផលានុផលផ្សេងៗ មានក្រូច អំពៅ ដូង ចេក ល្មុត ។ ល ។ ហើយទន្ទឹមនេះដែរ គឺរដូវសម្បូរត្រីកំពិស ដែលគេធ្វើប្រហុក ផ្អកទុកបរិភោគនៅរដូវដកស្ទូងខាងមុខ ។ ពេលនោះ នៅតំបន់ជនបទ គេឃើញក្មេងៗ ឬចាស់ៗ បង្ហើរខ្លែងមុនថ្ងៃពេញបូរមី ខែមិគសិរក៏មាន, ដោយឆ្លៀតពេលដែលមានខ្យល់ពីទិសខាងជើងបក់មកត្រង់ល្អ ។

---

(១) ពាក្យទាំងពីរ គឺបង្ហោះ និងបង្ហើរនេះ ខ្មែរធ្លាប់ប្រើក្នុងន័យដូចគ្នា : ហោះហើរ; ជួនកាលគេហៅបង្ហោះ ជួនកាលគេហៅបង្ហើរ; បង្ហោះ, បង្ហើរ ធ្វើឱ្យហើរ ។

(២) ក/ ខ្យល់រដូវបក់ជាប់ជាទៀងទាត់មកពីទិសខាងជើង ឬពីឦសាន,
ខ/ ទំនេរដៃពីការងារច្រូតកាត់ប្រមូលផល,

*២ . ទីកន្លែងសំរាប់បង្ហោះខ្លែង*

ការបង្ហោះខ្លែងមិនមែនអាចធ្វើបាននៅគ្រប់តែទីកន្លែងនោះឡើយ ។ ជាពិសេស ក្នុងការបង្ហោះខ្លែងឰង ( ខ្លែងធំ ) ឬ ខ្លែងអែក គេត្រូវរកកន្លែងណាដែលមានវាលធំ ស្រឡះល្អ [១] ពុំមានដើមឈើខ្ពស់ៗ ជាឧបស័គ្គ ។ តំបន់ជនបទរបស់ខ្មែរយើង ជាទីលានដ៏សមស្របបំផុតសំរាប់បង្ហើរខ្លែង ។ ម្យ៉ាងទៀត ទីវាល ជាកន្លែងដែលខ្យល់បក់បានជាប់ជាប្រចាំ ដោយពុំមានអ្វីមកបាំងរាំងស្ទះខ្យល់ឱ្យអាក់នោះឡើយ ។ នៅកន្លែងនោះ គេអាចមានទីវែងសំរាប់រត់លឿន ឱ្យខ្លែងហោះឡើង ។ គេមិនបារម្ភខ្លាចខ្លែងទើ ជាប់នៅលើមែកឈើឡើយ ។ ដូច្នេះ ខ្លែងអាចហោះបានខ្ពស់ល្អជាងទីណាៗ ទាំងអស់ ។ ហើយ បើកាលណាខ្លែងហោះបានកាន់តែខ្ពស់ នោះសំឡេងអែកក៏លាន់ឮសាយទៅបានកាន់តែឆ្ងាយ ។ នេះក៏ជាការបង្កួតស្នាដៃគ្នារវាងភូមិមួយ និងភូមិមួយទៀត តាមរយៈការបង្ហោះខ្លែង មានទ្រង់ទ្រាយធំ ខ្លែងហោះបានខ្ពស់ និងសំឡេងអែកឮយ៉ាងពិរោះ ។

*៣ . របៀបស្ទង់ខ្យល់មុនបង្ហោះខ្លែង*

ដើម្បីឱ្យខ្លែងហោះហើរបានល្អ អ្នកលេងខ្លែងត្រូវចេះពិនិត្យខ្យល់ :

ក / ខ្យល់តិច ឬខ្លាំង ខ្យល់ជាប់ ឬខ្យល់ដាច់,

ខ / ខ្យល់ក្រោម ឬខ្យល់លើ,

. ខ្យល់ខ្លាំងពេក : ខ្លែងអាចរេខ្លាំង ឬទីងក្បាលចុះ,

. ខ្យល់ដាច់ ខ្យល់មិនជាប់ : ខ្លែងហោះហើយអាចធ្លាក់ចុះមកវិញ [២]

. ខ្យល់តិច : ខ្លែងឡើងមិនរួច

. មានតែខ្យល់ក្រោម = ខ្លែងឡើងបានក្នុងកំពស់យ៉ាងទាប រួចក៏ធ្លាក់មកវិញ,

---

(១) វាលស្រែធំល្វឹងល្វើយ ដែលបានចតរួចហើយ ។ (២) សូមរំលឹកដល់ពាក្យខ្មែរបុរាណថា : ខ្លែងឡើង ដ្បិតខ្យល់ ...

- មានទាំងខ្យល់ក្រោម ទាំងខ្យល់លើ : ខ្លែងហើរបានជាប់នៅបានយូរលើអាកាស [១] ។ តាមចំណាំ ខ្លែងអែកខ្មែរយើង, អាចបោះបានកំពស់ ៣០០ ម ទៅ ៤០០ ម ។

*៤ - ការបង្ហោះខ្លែង :*

ដូចបានជម្រាបខាងលើរួចហើយថា ការបង្ហោះខ្លែងទាមទារទីវាលធំបង្គួរសំរាប់រត់បង្ហើរខ្លែង ។ កាលបើចង់បង្ហោះខ្លែង គេត្រូវការមនុស្សពីរនាក់ ជាចាំបាច់គឺ :

- អ្នករត់ខ្លែង
- អ្នកកាន់ខ្លែងបង្ហោះ

មុនបង្ហោះ គេត្រូវលាខ្សែខ្លែងឱ្យវែងប្រមាណពី ៥០ ទៅ ១០០ ម ។ អ្នករត់និងអ្នកបង្ហោះ អាចនិយាយឆ្លើយឆ្លងគ្នាទៅវិញទៅមក អំពីសកម្មភាពដែលត្រូវធ្វើ ។ លុះខ្យល់បក់មកល្អហើយ អ្នករត់ខ្លែងស្រែកប្រាប់មកអ្នកបង្ហោះថា : « ប្រុង » « ត្របាញ់ខ្សែសាយអែក ! » អ្នកបង្ហោះធ្វើតាម ហើយស្រែកប្រាប់ទៅវិញថា « ហ៊ឺ ! រត់ឱ្យលឿន ! » ។ អ្នករត់ ចេះតែរត់បណ្ដើរ លាខ្សែខ្លែងបណ្ដើរ ងាកមើលខ្លែងបណ្ដើរ ដរាបទាល់តែអស់ខ្សែ ។ កាលបើឃើញថា ខ្លែងបានបោះជាប់នៅស្រទាប់ខ្យល់លើល្អហើយ គេក៏យកខ្សែខ្លែងទៅចងភ្ជាប់នឹងដើមឈើណាមួយ ហើយអង្គុយសម្លឹងមើលខ្លែងរេរាំចុះឡើងតាមចរន្តខ្យល់ ដោយបន្លឺសំឡេងអែកដ៏ពិរោះរងំគួរឱ្យស្រណោះ ។ ម្ចាស់ខ្លែងសប្បាយរីករាយនឹងមើលទស្សនីយ-ភាពដែលធ្វើឱ្យអារម្មណ៍គេរំភើបរីករាយនេះពន់ពេកណាស់ ។ ចំពោះខ្លែងតូចតាចដែលក្មេងៗទៅលេងកំសាន្តវិញនោះ ជួនកាលវាអាចបង្ហោះបានតែម្នាក់ឯង ដោយពុំចាំបាច់មានអ្នកជំនួយឡើយ ។

---

(១) គេអាចបង្ហោះខ្លែង ចងវាទុករហូត ១ ថ្ងៃ ១ យប់ ទៀតផង ។

## VI . ជំនឿរបស់ប្រជាជនទៅលើការបង្ហោះខ្លែង

ទាំងព្រះមហាក្សត្រ ទាំងប្រជារាស្ត្រខ្មែរ តែងតែមានជំនឿតៗគ្នាថា : ការបង្ហោះខ្លែងធ្វើឡើងដើម្បីគោរពបូជាដល់ព្រហ្មញ្ញសាសនាផង និងព្រះពុទ្ធ-សាសនាផង ។

*១ . បង្ហោះខ្លែងបូជាព្រហ្មញ្ញសាសនា :*

ក្នុងលទ្ធិព្រហ្មញ្ញសាសនា គេគោរពព្រះអាទិទេពជាច្រើន ដូចជា : ព្រះសិវៈ ព្រះវិស្ណុ ព្រះព្រហ្ម ។ល។ ក្រៅពីនេះ នៅមានព្រះអាទិទេពបន្ទាប់បន្សំផ្សេងៗទៀត ដូចជាព្រះអាទិត្យ ព្រះច័ន្ទ ព្រះពាយ [(១)] ព្រះភិរុណ ព្រះធរណី ព្រះអគ្គី ។ ពិធីបង្ហើរខ្លែងនេះ ជាកិច្ចគោរពដឹងគុណព្រះពាយ ( ខ្យល់ ) ដែលផ្តល់នូវខ្យល់ឱ្យយើងដកដង្ហើម បានរស់ជីវិតគ្រប់ៗគ្នា ដែលគេនិយមហៅថា ដង្ហើមរស់ ។

*២ . បង្ហោះខ្លែងបូជាព្រះពុទ្ធសាសនា :*

ម្យ៉ាងទៀត ផ្អែកទៅតាមជំនឿខាងព្រះពុទ្ធសាសនា ពិធីបង្ហោះខ្លែងនេះគឺជាពិធីមួយសំរាប់គោរពបូជាដល់ព្រះចូឡាមណីចេតិយ [(២)] ដែលប្រតិស្ឋាននៅវិមានត្រៃត្រឹង្ស ។

*៣ . អំពីខ្លែងធ្លាក់លើផ្ទះ :*

តាមជំនឿរបស់ខ្មែរយើង បើកាលណាខ្លែង [(៣)] ធ្លាក់លើដំបូលផ្ទះអ្នកណាមួយនោះ គេចាត់ទុកថាជាការចង្រៃ [(៤)] ពន់ពេកណាស់ ។ ម្ចាស់ផ្ទះទាមទារឱ្យម្ចាស់ខ្លែង ធ្វើពិធីបង្កក់ប្រសិទ្ធិ លើករាសីឱ្យគេ នោះទើបគេសុខចិត្ត ។ បើពុំនោះទេនឹងកើតមានការវិវាទប្តឹងផ្តល់គ្នាជាប្រាកដ ។

---

(១) ព្រះពាយ ឬ វាយុ ។ (២) ព្រះចេតិយតម្កល់ព្រះអដ្ឋិធាតុបរមគ្រូនៃយើង នៅស្ថានត្រៃ-ត្រឹង្ស ។ (៣) និយាយចំពោះតែខ្លែងពួង ឬ ខ្លែងអែកំធៗប៉ុណ្ណោះ ។ (៤) នាំមកនូវគ្រោះកាចផ្សេងៗ ដល់ម្ចាស់ផ្ទះនោះ ។

## VII. សេចក្តីសន្និដ្ឋាន

ការបង្ហោះខ្លែង គឺជាទំនៀមទម្លាប់ប្រពៃណីរបស់សង្គមខ្មែរយើងតាំងបុរមបុរាណមកម្ល៉េះ ។ សព្វថ្ងៃនេះ ជំនាន់យើងនៅតែបន្តធ្វើតាមដំណែលនៃដូនតាយើង ដែលបញ្ជាក់អំពីក្រឹត្យក្រមមួយដែលថា ជីវិតតែងផ្សារភ្ជាប់ទៅនឹងធម្មជាតិ ។

ដើម្បីគោរពនឹកគុណដល់ធាតុទាំងបួន ដែលទ្រទ្រង់នូវលោកគឺ ធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ ដែលផ្តល់នូវជីវិត នូវធម្មជាតិផ្សេងៗ សំរាប់កំដរជីវិតយើងក៏នាំគ្នាធ្វើពិធីនេះឡើង នៅពេលដែលខ្មែរបានរីករាយក្នុងអារម្មណ៍ដោយបានទទួលផលពីរបរកសិកម្ម ។ ទោះបីបានពិនិត្យឃើញថា នៅសម័យនេះ ការបង្ហោះខ្លែងមិនសូវមានសកម្មភាពខ្លាំងក្លាយ៉ាងណាក្តី ក៏គេនៅតែឃើញមានការបង្ហោះខ្លែងនៅក្នុងប្រទេសយើងជាដរាប ។

**មៀច ប៉ុណ្ណ**

ប្រធានការិយាល័យ ទំនៀមទម្លាប់ខ្មែរ

នៅពុទ្ធសាសនបណ្ឌិត្យ

ដកស្រង់យកអត្ថន័យខ្លះពីឯកសាររបស់លោក សុខ ធូក

និងបន្ថែមអត្ថន័យមួយចំនួនទៀត តាមការពិសោធន៍ដោយផ្ទាល់

# បទ ន មោ

## វាចារំព្រក

កាលក្នុងអំឡុងពាក់កណ្ដាលទសវត្ស ៦០ ខ្ញុំបានអានសៀវភៅរបស់លោកគ្រូ អៀង សាយ ដែលមានឈ្មោះថា « មេកាព្យ » ។ ក្រៅពីបទដែលយើងធ្លាប់រៀនជាធម្មតា ដូចជាបទកាកគតិ បទព្រហ្មគីតិ បទពំនោល បទភុជង្គលីលា បទបន្ទោកាក បទពាក្យ ៧ បទពាក្យ ៨ បទពាក្យ ៩ ។ ល ។ លោកបានចងក្រងកំណាព្យទៅតាមបទជាច្រើនទៀត ដែលអ្នកប្រាជ្ញកំណាព្យខ្មែរយើង បានបែងចែកទៅតាមការចាប់ចុងចួន លាយឡំនឹងការរណ្ដំ ណែងណងនៃស្វរស័ព្ទសំឡេងរបស់ពាក្យពេចន៍ខ្មែរ ។ លោកច្រើនយកបទពាក្យ ៧ មករចនាចងក្រង ។ បទមុនគេ គឺបទ « ន មោ » ។

ការអានកំណាព្យបទ ន មោ ធ្វើឱ្យខ្ញុំនឹកដល់អនុស្សាវរីយ៍នៃការចាប់ផ្ដើមរៀនអាន រៀនសរសេរភាសាខ្មែរជាដំបូង នៅតាមសាលារៀន ហើយជាពិសេស នៅតាមវត្តអារាម ។ ជាទម្លាប់ ពីសម័យដើមមុននេះ ខ្មែរយើងតែងតែយកកូនឱ្យទៅនៅវត្ត ដើម្បីឱ្យកូននោះរៀនសរសេរ រៀនអាន ក្នុងសំណាក់ព្រះសង្ឃ ។ ការរៀនសរសេរ និងរៀនអានជាដំបូងនោះ គឺជាការត្រៀមសម្រាប់ចូលរៀននៅសាលាធម្មតា ។ ជាធម្មតា មុននឹងរៀនថ្នាក់ដំបូង គឺថ្នាក់ទី១ នៃសាលាបឋមសិក្សាបច្ចុប្បន្ននេះ ដែលកាលនោះគេហៅថា ថ្នាក់កុមារដ្ឋាន ( Cours en fantin ) លោកតម្រូវឱ្យក្មេងៗចេះ «រាប់» ឬស្គាល់ស្រៈពេញតួសិន ទើបចាប់រៀន «រាប់» និងរៀនសរសេរព្យញ្ជនៈ និងស្រៈនិស្ស័យ ។ ជួនកាល នៅពេលចូលរៀនថ្នាក់កុមារ-ដ្ឋាន ក្មេងៗច្រើនតែចេះរហូតដល់បំបែកតួអក្សរ ឬខ្លះទៀត ចេះប្រកប ចេះអានបានខ្លះផង ។ នេះជាជំនួយមួយយ៉ាងធំដល់គ្រូបង្រៀនថ្នាក់ដំបូង ។

កាលបើគេចង់និយាយពីកូនទៅរៀន ព្រោះដល់អាយុ ខ្មែរយើងតែងសួរគ្នាថា ៖

« កូនអ្នកឯងចេះ ន មោ ហើយឬនៅ ? » ឬ

« កូនអ្នកឯងចេះរាប់ ន មោ ឬនៅ ? »

« កូនអ្នកឯងរៀន ន មោ ក ខ ចប់ ឬនៅ ? » ។ ល ។

ការសួរគ្នាថា « ចេះ ន មោ ហើយឬនៅ ? » នេះ គឺលោកសំដៅត្រង់ចង់ដឹងថា កូននោះចេះរាប់ស្រះពេញតួហើយឬនៅ ។ បានជាសួរគ្នាដូច្នេះ ពីព្រោះលោកឱ្យរៀនរាប់ស្រះពេញតួ ដោយចាប់ផ្ដើមឱ្យរំឭកដល់ព្រះពុទ្ធគុណ ពោលគឺសូត្រឱ្យចាំមាត់នូវឃ្លាបាលីដ៏ខ្លីថា ន មោ ពុ ទ្ធា យ សិទ្ធំ រួចទើបបន្តដោយ អ អា ឥ ឦ ។ ល ។ ប៉ុន្តែ ដោយហេតុថា ក្មេងទើបនឹងចាប់ផ្ដើមរៀន វាមិនស្គាល់ថា ឃ្លាបាលីនេះជាអ្វីទេ ទើបលោកមិនទម្លាប់ឱ្យក្មេងអានតាមបាលី តែលោកឱ្យអានតាមសរសេរទៅតាមបែបភាសាខ្មែរវិញ ជា ៖

[ ន - មោ - ពុត - ធា - យ - សិត - ធំ ] ទើបបន្តរាប់ស្រះពេញតួតទៅ ទាល់តែចប់ ។

នៅក្នុងឆ្នាំ ១៩៧៩ បន្ទាប់ពីខ្មែរក្រហមត្រូវបណ្ដេញចេញពីអំណាច ខ្ញុំក៏បានចូលមកបំរើការនៅក្រសួងការបរទេស ក្នុងទីក្រុងភ្នំពេញ ។

នៅក្នុងបណ្ណាល័យ នៃពុទ្ធសាសនបណ្ឌិត្យ ខ្ញុំបានឃើញសៀវភៅចាស់ថ្មី សៀវភៅជំនាន់ដើម ដែលសរសេរដោយដៃ សាស្ត្រាស្លឹករឹតដ៏ល្អៗប្រណីត ក្រាស់ស្តើង រៀបនៅលើទូថ្នាក់ខ្លះ គរគ្នានៅលើការ៉ូខ្លះ គរគ្នានៅក្រោមបន្ទប់ខ្លះ ដោយឥតសណ្ដាប់ធ្នាប់ឡើយ ។ ខ្ញុំបានប្រឹងជញ្ជូនចូលរៀបចំទុកដាក់វិញតែម្នាក់ឯង សឹងតែរាល់ពេលណាដែលខ្ញុំទំនេរ តែមិនឈ្នះនឹងប្រជាជនរើកកាយឡើយ ។ ខ្ញុំនឹកសង្ឃឹមទាំង «ខុស» ថា «វត្ថុទាំងនេះជាសម្បត្តិវប្បធម៌ ដ៏មានតម្លៃកាត់ថ្លៃមិនបាន .... ។

បន្ថិចទៀត ក្រសួងអប់រំ ឬក្រសួងវប្បធម៌ណាមួយ នឹងយកសម្បត្តិទាំងនេះទៅរៀបចំទុកដាក់ជាមិនខាន .... » ។ ខ្ញុំដាក់ចិត្តរើសយកតែសៀវភៅបោះពុម្ពមួយមុខៗមួយក្បាល ឬពីរក្បាលប៉ុណ្ណោះ ក្នុងនោះមានសៀវភៅប្រវត្តិរបស់ព្រះមហាសុមេធាធិបតី ជួន ណាត និងសៀវភៅរឿងព្រេងបុរាណខ្មែរខ្លះ ជាភាសាបារាំង និងអង់គ្លេស ។ សៀវភៅទាំងនេះ រួមទាំងសៀវភៅខ្មែរខ្លះទៀត ខ្ញុំបានប្រគល់ជូនឯកឧត្តម ឈន អៀម អនុរដ្ឋលេខាធិការក្រសួងធម្មការ ដើម្បីឱ្យចាត់ការបោះពុម្ពឡើងវិញហើយ កាលពីខែ មីនា និងខែ ឧសភា ឆ្នាំ ១៩៩៦ ។

នៅពេលនោះ និងរហូតមកដល់ពេលនេះ ខ្ញុំខំព្យាយាមរកសៀវភៅ « **មេកាព្យ** » របស់លោកគ្រូ អៀង សាយ ដែរ ប៉ុន្តែរកមិនឃើញមានសោះ ហើយក៏មិនដឹងជាអស់លោក - អ្នកណា មានវាសនានឹងបានសៀវភៅនេះធ្វើជាកម្ម-សិទ្ធិរបស់ខ្លួនដែរឬទេ ។

កាលខ្ញុំមានសៀវភៅ មេកាព្យ នោះ នៅពេលទំនេរ ខ្ញុំតែងតែអានកំសាន្តលេងនូវកំណាព្យរបស់លោកគ្រូ អៀង សាយ រហូតដល់មានបទខ្លះ ខ្ញុំបានចាំមាត់ស្ទាត់រហូតដល់ពេលនេះ ។

ខ្ញុំសូមចម្លងកំណាព្យនេះចេញពីការចេះចាំរបស់ខ្ញុំ ដើម្បីគ្រាន់ជាការផ្សព្វផ្សាយ និងជាការរក្សាទុកនូវស្នាដៃដ៏ប្រពៃនៃបុព្វបុរសយើងឱ្យបាននៅគង់វង្សខ្លះ កុំឱ្យវាបាត់បង់អស់ទាំងស្រុងពេក ។

លោកគ្រូ អៀង សាយ ជាវរជនខ្មែរមួយរូបដ៏កម្ររកបាន ។ លោកមានទេពកោសល្យជាច្រើន ៖ លោកជាជាងគំនូរ ជាសិល្បករផ្នែករហាសកម្ម ផ្នែកថ្មីនភ្នែក ( ឬ ប៉ាហ៊ុ ) ជាកវីនិពន្ធ ជាគ្រូបង្ហាត់វិជ្ជាខាងលើនេះ ជាអ្នកនិពន្ធរឿងកំប្លែងជាអ្នកនិពន្ធ ឬលើកប្រស្នាផ្សេងៗ ។

បទ ន.មោ ជាកំណាព្យបទពាក្យ ៧ ដែលឃ្លានីមួយៗ ត្រូវចាប់ផ្ដើម

ដោយ « ព្យាង្គ » នីមួយៗ នៃស្រះពេញតួ គឺ ន នៅឃ្លាទី ១ មោ នៅឃ្លាទី ២ ពុ នៅឃ្លាទី ៣ ធា នៅឃ្លាទី ៤ នៃវគ្គទី ១ ហើយយ៉ាងដូច្នេះជាបន្តទៅ ។

សូមឧទ្ទិសបុញ្ញកុសលជូនចំពោះវិញ្ញាណក្ខន្ធរបស់លោកគ្រូ អៀង សាយ ដោយលោកបានចងក្រងបទ ន មោ នេះឡើងទុកជាគំរូនៃក្បួនតែងបទកំណាព្យខ្មែរ ដោយសេចក្ដីគោរព និងដឹងគុណដ៏ជ្រាលជ្រៅបំផុត ។

ថ្ងៃទី ៣០ តុលា ១៩៩៦ **ធន់ ហ៊ិន**

## បទ **ន មោ** ( ទី១ )

**ន** អ្នកណាចង់ចេះចងកាព្យ
**មោ** មោះមិនដាបដោយរវល់
**ពុ** ពង្សវង្សប្រាជ្ញអាចឈ្វេងយល់
**ធា** ធាតុជួបជល់ជាក់ជាចេះ ។
**យ** យកច្បាប់មកមើលពិនិត្យ
**សិ** សិក្សាគិតជាចំណេះ
**ធំ** ធេងលេងល្បងកុំខ្លាចល្បេះ
**អ** ឱនអង្គអេះក្បាលចំណាំ ។
**អា** អានពាក្យពោលយោលតាមច្បាប់
**ឥ** ឥតគេប្រាប់កុំប្រឹងចាំ
**ឦ** ឥឡូវត្រូវប្រុងចំណាំ
**ឧ** ឧស្សាហ៍ចាំចាប់ពាក្យជូន ។
ឱ្យអានអស់ពាក្យទាក់ទង

ឫ រកទំនងចងជាក្បួន

ឬ រើសពាក្យពោលរកគោលស្ទួន

ឭ ឮ ឡើងចួនជាប់ដោយយ៉ាង ។

ឯ អស់មេកាព្យឈ្មោះផ្សេងគ្នា

ឰ ឯបមានឃ្លាជាសំអាង

ឱ អើត្រូសាយមានភស្តុតាង

ឳ អួតអង្គអាងតែងទុកឱ្យ ។

អុំ ឪពុកគាត់ស្ទាត់ចំណាប់

អំ អំពីច្បាប់មិនខ្សត់ខ្សោយ

អាំ អាំងតែងតាំងទុកទៅក្រោយ

អះ អួតអង្គឱ្យមានពូជ ត ។

ដោយ អៀង សាយ

## បទ ឆ មោ ( ទី២ )

ឆ នៃនាងនោះកូនអ្នកណា

មោ មើលមុខថ្លាសល្អល្អះ

ពុ ពជ្សវង្សាមិនស្គាល់ច្បាស់

ឆ្នា ធនធានក្រាស់ក្រៃលគ្រាន់បើ ។

យ យល់យប់នេះរិះចង់ដឹង

សិ សួរដំណឹងតាមដំណើរ

ឋំ ធាត់កត់ឈ្មោះពិគ្រោះស្មើ
អ អស់អ្នកដើរដេកនៅជិត ។
អា អញស្រឡាញ់នាងនេះណាស់
ឥ ឥតមានផ្លាស់ប្រែគំនិត
ឦ អីភ្លេចអស់មិនមានគិត
ឧ អុកឡុករីតរិលរវល់ចិត្ត ។
ឩ អើបើទៅស្ដីដណ្ដឹង
ឫ រាងនាងហ្នឹងគួរស្នេហ៍ស្និទ្ធ
ឬ រើសរកញាតិសន្ដានមិត្ត
ឭ លមើលចិត្តឱ្យដឹងសិន ។
ឮ លោជាព្រមល្មមទទួល
ឯ ឯងក៏ស្រួលនឹងសង្កិន
ឰ ឯបឱ្យជាប់ជួយចងក្បិន
ឱ ឱនក្រាបមិនឱ្យមានហ្មង ។
ឳ ឱ្យឪពុកក្មេកពេញចិត្ត
អុំ អូនអាណិតដ្បិតទាក់ទង
អំ អាំ ចាំមើលមានទំនង
អះ អង្អែលខ្នងម្ដងសិមការ ។

ដោយ អៀង សាយ

# ផ្សាំ

( បទគោលព្ទស្ទីង )



- កាត់ព្រៃឲ្យរៃកណ្តីងយំ យំផ្ទួររងំរណ្តំចិត្ត
ចិត្តអើយអាណោចអនេកពិត ពិតក្នុងជីវិតសង្រេងក្រៃ ។
- ក្រៃណារំជួលអស់អង់ប្រាណ ប្រាណអើយព្រោះបានជួបប្រាណថ្លៃ
ថ្លៃលើសអប្បរស្ទូគាល័យ លៃប៉ាន់តម្លៃគ្មានអ្វីស្មើ ។
- ស្មើនឹងជីវិតនេត្រទាំងគូ គូនឹងក្បាច់ក្បូរគួរសរសើរ
សើរាក់លោក់ជ្រៅដាច់បន្ទើ ថើថៃមដំណើរថើល្ងួតល្ងន់ ។
- ល្ងន់ល្ងួតទតសព្វសពាង្គកាយ កាយគន់មិនណាយចង់គយគន់
គន់ព្រោះផ្សារស់ស្រោលស្រទន់ ទន់ព្រោះផ្ទូន់មិនស្រើបស្រោល ។

- ស្រាលចិត្តព្រោះដ្បិតស្មានមិនដល់ ដល់តែឃើញផ្ទាល់ភាពត្រកាល
កាលបង្ហំចិត្តត្រេកត្រអាល អាលអុជដុតដាលចិត្តវេទនា ។
- នាពេលនេះសូមបង្គំថ្វាយ ថ្វាយចិត្តថ្វាយកាយក្រាបវន្ទា
ទាសុំស្មាដៃទុកពណ៌នា នាកេរវាលគ្មាជាសក្ការ ។
- ការដែលលង់ស្លុងនឹងថ្មរស់ រស់ដូចមនុស្សរស់គ្មានទុក្ខា
ខាឃាំងខ្លួនក្នុងភាពអស្ចារ្យ ចារអប្សរាសិលារាំ ។
- រាំចេញមួយៗរញ្ជួយថ្ម ថ្មប្រាសាទល្អមិនខ្មៅចខ្ចាំ
ខ្ចាំខ្ចរដូចភ្លេងលេងរណ្តំ ដំគោះប្រគំសព្ទវាយោ ។
- យោយោលស្លឹកឈើលើវេហាស៍ ហាហាក់បាចផ្កាតាមជំនោរ
នោរអើយបាចផ្កាភ្លេងអើយរោទិ៍ រោទិ៍អើយនាំសួរសូមបូជា ។
- ជាហេតុនាំអោយតួប្រាសាទ សាធសុទ្ធល្អស្អាតរាល់ទិវា
វៀរចាកក្តីស្លាប់គ្រប់វេលា លាជីពជីពលាពត់ពេនពង់ ។
- ពង្សពូជសាវតារដូនតាខ្មែរ ខ្មែររស់ខ្មែរថែខ្មែរគង់វង្ស
វង្សរិលតកេរ្តិ៍មិនលិចលង់ លង់លក់លះបង់សាវតារខ្មែរ ។

**ខៀវ បញ្ញាឧត្តម**
អនុប្រធានការិយាល័យស្រាវជ្រាវ
ផ្នែកចក្ខុ - សោតទស្សន៍
នៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ទស្សនៈជីវិតតាមបែបពុទ្ធចក្រ

# សើចតិចជាងយំ

( បទកាកគតិ )

មិនគួរច្រឡំ រឿងសើចរឿងយំ ថារឿងធម្មតា
រឿងសើចមានតិច រឿងយំសោតណា យំពេញលោកា
យំមួយជីវិត ។

រឿងសើចមានមែន តែសើចមែនទែន មិនមែនរឿងពិត
សើចលាយសោកសៅ សើចក្រៅក្រមក្រិត្យ សើចគួរអាណិត
សើចដើម្បីយំ ។

គឺសើចតែក្រៅ សើចអ្វីខ្លះទៅ ដែលគេសើចសម
គេសើចនឹងទ្រព្យ សម្បត្តិស្តុកស្តម្ភ ជីវិតមនោរម
សម្បូរក្រាស់ក្រៃ ។

សើចព្រោះសោយសុខ កាយចិត្តស្រណុក មានភ័ព្វនិស្ស័យ
មានចិត្តមូលមីរ ពឹងពាក់អាស្រ័យ សប្បាយពេកក្រៃ
ក្អាកក្អាយភ្លេចភ្លាំង ។

សប្បាយនឹងយស មុខមាត់ខ្ពង់ខ្ពស់ ឥតគូប្រណាំង
កេរ្តិ៍ឈ្មោះរន្ទឺ ពន្លឺចែងចាំង អំណាចក្លាខ្លាំង
គួរអោយខ្លបខ្លាច ។

សប្បាយនឹងសុខ គិតថាអស់ទុក្ខ អស់មានគ្រោះកាច
សាច់ធាត់ទ្រលុក មុខមាត់អង់អាច ខ្មោចព្រាយបិសាច

ខ្លាចខ្លួបចេស្តា ។

បើបានសើចហើយ អស់លោកអ្នកអើយ គួរគិតអនិច្ចា
កុំអោយសើចខុស សើចភ្លេចសោកា យកទឹកនេត្រា
ជាការសប្បាយ ។

យើងសើចច្រឡំ ភ្លេចគិតរឿងយំ គិតតែសប្បាយ
សព្វសត្វនិករ រស់នៅរាយមាយ ជីវិតសម្ពាយ
ជាជីវិតទុក្ខ ។

សច្ចធម៌ពិត ពេលពីជីវិត ពិតជាមិនសុខ
ពេលបានសុខហើយ សុខលាយដោយទុក្ខ មិនរាប់ថាសុខ
ព្រោះសុខក្លែងក្លាយ ។

ជីវិតគឺយំ ជាភពយោបំ យំព្រោះសោកស្តាយ
យំព្រោះកិលេស រុំរឹតចិត្តកាយ លង់លក់សប្បាយ
ក្លាយឃ្លាតកុសល ។

ដូច្នេះគួរគិត កែច្នៃជីវិត ចេញចាកកង្វល់
ខិតខំកសាង សន្សំកុសល តម្កើងតម្កល់
ចិត្តឧបេក្ខា ។

កុំស្អប់ទុក្ខពេក ហើយក៏កុំត្រេក នឹងក្តីសុខា
ដែលនាំអោយបាត់ លំនឹងចិន្តា នាំអោយអាត្មា
វិលវល់រឹងស៊ុង ។

ដោយ **មៀច ប៉ុណ្ណ**
ពុទ្ធសាសនបណ្ឌិត្យ

# ពួកជនពាល ព្រខាលភ្លើងកាច

បទពាក្យ ប្រាំបួន ( រលកខ្ទប់ច្រាំង )

- បុគ្គលពាល  រាលដាលដាប  ឆាបឆេះក្តៅ
ដុំផ្សែងខ្មៅ  ឆ្អៅប៉ផ្លុង  ក្នុងខ្លួនប្រាណ
ហុយរងាល  រាលឥតឈប់  ទប់មិនបាន
ប៉ានរាប់អាន  បានទុក្ខសោក  ថោកសិរី ។
- គ្រោះអាសន្ន  អន្តរាយ  សាយឆាបរាល
មកពីពាល  រាលដាលគ្រប់  ភពលោកិយ
ឈាមពេញអូរ  ហូរលើសលន់  ជន់លិចដី
ពាលអប្រិយ  ខ្ចីគំនិត  គិតចាក់កាប់ ។
- ជាតិបណ្ឌិត  គិតឥតឈប់  ទប់ពាលខ្មៅ
លួងប្រដៅ  ហៅសាសង  ប្រងប្រាប់ច្បាប់
ប្រាកដច្បាស់  ដាស់បំពេ  គេពុំស្តាប់
ពាលចាក់កាប់  អាប់សោកម៉ោក  ថោកពុំយល់ ។
- កសង្គ្រាម  ឈាមជោរជន់  ពន់ប្រមាណ
ខកខានបាន  ក្សាន្តផុតភ័យ  ជ័យមង្គល
ប្រជាជន  ទន់ខ្សូរមុខ  ទុក្ខវិលវល់
កើតអំពល់  យល់មិនដល់  កលពាលខ្មៅ ។
- ជនឯណា  សាវ៉ាសេព  អែបនែបជិត
កើយក្បៀកកិត  ស្និទ្ធពាលរឹង  នឹងឆេះក្តៅ

| | | |
|---|---|---|
| កើតក្តុលក្តុក | ចុករួលណែន | សែនសោកសៅ |
| ចិត្តប្រែខ្មៅ | ខ្លៅដាមដិត | ស្អិតកាយា ។ |
| - ក្រណាត់អប់ [១] | ខ្ចប់ប្រហុក | ទុកនៅងំ |
| ស្អុយរហុំ | ពុំរលាយ | ងាយឡើយណា |
| ទោះបោកគក់ | ទក់ទាំងសាច់ | ដាច់ម្តេចម្តា |
| គង់ក្លិនសា | ខាររងំឡប់ | ហាប់រហុំ ។ |
| - ពាលតែងប៉ង | ចងជាបរឹង | នឹងក្រុមវា |
| ពេលបានគ្នា | ជាបក្ខពួក | ស្មគ្រស្មោគម |
| កបំពក់ | ភ្នក់ភ្លើងក្តៅ | ឆ្អៅឆ្អិនងំ |
| ផ្សែងជិតជុំ | ហុំគ្រប់ទី | វិភាយសាយ ។ |
| - ផ្ទះកន្តាំង | បាំងកន្តឹប | ផ្អឹបប្រក់ស្លឹក |
| ខែកត្តិក | ក្អឹកវាយោ | ជោរផាត់ផាយ |
| គួចភ្លើងដក់ | ឆក់ឆេះដាប | ឆាបដាលឆ្ងាយ |
| អន្តរាយ | សាយពាល់ប៉ះ | ផ្ទះធំឆ្អៅ ។ |
| - ចូរជនិរះ | នេះពាក្យប្រៀប | ធៀបប្រឌិត |
| ថាពាលពិត | គិតបំពក់ | ភ្នក់ភ្លើងក្តៅ |
| អោយរាលដាល | ច្រាលឆក់ឆាប | ដាបដល់ក្រៅ |
| អោយសោកសៅ | ក្តៅឆួលងំ | ហុំខ្ពលខ្ចាញ់ ។ |
| - សង្គ្រាមលោក | ខ្លោកផ្ទុះឡើង | ប៉ើងភ្លើងក្តៅ |
| ព្រោះពាលខ្មៅ | ខ្លៅប្រាជ្ញា | ថាអញ្ចេញ |
| កែនរេហ៍ពល | យល់ខ្លួនធំ | ពុំចុះចាញ់ |

(១) ដាក់ទឹកអប់ ឬអ្វីៗដែលក្រអូប ។

| | | |
|---|---|---|
| វត់ចូលខ្មាញ់ | បាញ់សម្លាប់ | កាប់ចាក់គ្នា ។ |
| - សម្លាប់វាល | វាលសល់រ៉ល់ | ដល់ជនជាតិ |
| វាលពិឃាត | លាតល្វើយល្វឹង | ស្ទើងហូរជា |
| ទឹកលោហិត | ស្អិតហូររ៉ | ចរតាមធារ |
| គ្រប់ប្រជា | គ្រាសង្គ្រាម | ឈាមជោកដី ។ |
| - ពាលអាងច្បាំង | ខ្លាំងជាងខ្លា | សាវ៉ាពិត |
| ខ្វីគំនិត | គិតតែខឹង | ប្រឹងខាងវ៉ី[១] |
| បង្កគ្រោះ | ឈ្មោះឥតអាក់ | រាក់សេចក្តី |
| ត្បិតគិតខ្វី | ខ្វីប្រាជ្ញា | ខ្លាអប្រិយ ។ |
| - គប់ពាលខ្លៅ | ក្តៅឆេះខ្លួន | ខ្លួនខ្ជាប់នៅ |
| ហុយសន្ធៅ | ទៅជាធំ | ពុំបាត់អី |
| ចូរប្រយ័ត្ន | ខាត់ដុះចិត្ត | ស្និទ្ធមេត្រី |
| នឹងករី | ប្រើជាខ្ពស់ | យសថ្លៃថ្លា ។ |
| - ពាលខ្លៅខូច | ដូចខ្លាធំ | ពុំគួរស្និទ្ធ |
| មុខកំបុត | ចិត្តកំប៉ោង | កោងវាចា |
| សាមាន្យក្រៃ | ដៃយោលយោង | ឃ្លោងដូចខ្លា |
| ចិត្តឫស្យា | ប្រាជ្ញាធំ | ពុំដែលជា ។ |
| - ពាលតែងប៉ង | ចងទាញទាក់ | ផ្ទាក់ជិតកិត |
| អោយក្បៀកស្អិត | ស្និទ្ធរម៉ក្សរ | ស្មគ្រនឹងវា |
| ដូចភក់ល្អក់ | ឆក់លុកលូក | ឈូកគន្ធា |
| បទុមា | ជាជាតិនឹង | រឹងឥតប្រែ ។ |

(១) វ៉ី = វាយ ។

| | | |
|---|---|---|
| - ដុះនឹងភក់ | រកវិលវល់ | គល់ជាប់ល្បប់ |
| ភក់ហ៊ុំហប់ | ថប់ឥតលស់ | នោះគួរតែ |
| ក្លាយកខ្វក់ | ល្អក់អសោចិ៍ | ដូចភក់ដែរ |
| តែឥតបែរ | ប្រែក្លាយធាតុ | ឃ្លាតពីផៅ ។ |
| - ជាតិបណ្ឌិត | ពិតនឹងធឹង | រឹងមាំណាស់ |
| ពុំក្រឡាស់ | ផ្លាស់ប្រែធាតុ | ជាតិឆ្អិនឆ្អៅ |
| ដូចបទុម | ពុំក្រឡាស់ | ផ្លាស់ហ្មងសៅ |
| មើមក្រឱ | ម្សៅផ្លែវា | ជាចំណី ។ |
| - សូមជាតិជន | គន់គួរលេខ | ដេកដើរគិត |
| ផ្ចង់គំនិត | រឹតចំណង | ចងស្មារតី |
| កុំបណ្តោយ | អោយខកខ្លួន | កូនប្រុសស្រី |
| ពន្លកខ្ចី | ខ្ចីគំនិត | គិតខុសច្បាប់ ។ |
| - ស៊ុកគ្រលុក | ទុកបណ្តោយ | អោយបុត្រា |
| ភ្លេចសិក្សា | អាវ៉ាសៃ | ខ្មែរនឹងអាប់ |
| ដល់វាទ្រើស | ល្មើសឥតរៀន | ប្រៀនលែងស្តាប់ |
| ប៊ានសម្លាប់ | កាប់ឥតគិត | ឃើតឱឯង ។ |
| - ខ្ញុំកវី | ស្តីប៉ុណ្ណោះ | ស្នេះវាចា |
| អស់ខ្លឹមសារ | ថាមិនសព្វ | ចប់ឈប់ថ្លែង |
| ល្បងកលកិច្ច | ល្បិចល្បែងល្បាក់ | ធ្លាក់ពាក់តែង |
| ឈប់សំដែង | ល្បែងកវី | ខ្លីប៉ុណ្ណោះ ។ |

នូច ជឹម
ប្រធានការិយាល័យគរុកោសល្យ ( ក្រសួងធម្មការ និងសាសនា )

# ឆ្នាំងដីកំសត់

( បទពាក្យ ប្រាំបួន )

ឆ្នាំងដីកេរ ដែលខ្មោចម៉ែ បន្សល់មក
ខំតែរក បែរជាជ្រក ក្រោមទ្រូងមាន់
មើលអាគក ដើរទៅមក យកជើងជាន់
បងឃើញទាន់ កុំអីមាន់ ជុះអាចម៍ដាក់ ។
ប្អូនគិតមើល អាយុកាល ច្រើនតំណ
ឆ្នាំងនៅល្អ ប្រើបន្ត ដោយថ្នមថ្នាក់
ឬផុតក្រ ឆ្នាំងមិនស ខ្លាចប្រឡាក់
ឱ ! វរលក្ខណ៍ អាចយកដាក់ ក្នុងបន្ទប់ ។
ចងជរហួល មនុស្សចេញចូល ឃើញឆ្នាំងចាស់
ប្រាកដណាស់ សាវតារព្រាស់ ទាំងថ្ងៃយប់
ប្រាប់ប្រវត្តិ ប្រាប់រឿងព្រាត់ ប្រាប់សព្វគ្រប់
មិនត្រូវលុប រឿងសំណាប់ បាត់បំណង ។
ឆ្នាំងមានមាត់ ឆ្នាំងប្រាកដ ចេះនិយាយ
រាយប្រាប់ប្រាយ វែងអន្ឆាយ ឆ្ងាយកន្លង
ជីវិតម៉ែ រស់ថ្នមថៃ ប្អូននិងបង
នឹកម្តង១ លើកដៃផ្សង ជួបម៉ែទៀត ។
កាលពុករស់ មុនទៅបួស គាត់ជាងឆ្នាំង
ទឹកដៃខ្លាំង ពុកធ្វើឆ្នាំង ខ្លាំងលើសញាតិ

ជាងពុកច្បាស់ សាច់ឆ្នាំងក្រាស់ សមណាស់ទៀត
ពុកមានស្នៀត ធ្វើអោយញាតិ កោតសរសើរ ។
មុនពុកស្លាប់ ហៅម៉ែប្រាប់ អោយថែទុក
របរសុខ រស់ស្រណុក គ្មានអ្វីស្មើ
ទៅលក់ឆ្នាំង បុកក្រសាំង អាំងត្រីឆ្អើរ
មិនមែនថ្មើរ ធ្វើដំណើរ ដោយរទេះ ។
ភូមិនាងសុខ ចៅតាម៉ុក ធ្វើតែគ្រប
ទៅដាក់លប ចូលខ្ទិចប នាងសែនចេះ
ហុចចបថ្មម មុខក្រហម បងដើរវេះ
ព្រោះក្បៀរនេះ តាម៉ុកចេះ តែដៀងភ្នែក ។
ចាស់ៗដឹង រឿងទាំងហ្នឹង លាក់មិនជិត
ថ្ងៃមួយពិត គាត់ជីវិត សួរបងប្លែក
ស្រឡាញ់ហ្នឹង ចូលដណ្តឹង នៅថ្ងៃស្អែក
ទ្រូងចម្លែក អរខ្លាំងពេក ងក់តែក្បាល ។
ឥឡូវម៉ែ លែងនៅថៃ យើងទៀតហើយ
ឱ ! ប្អូនអើយ កុំកន្តើយ ផ្លូវកណ្តាល
រក្សាកេរ មិនច្នេះទេ ត្រូវបាត់ថ្កាល
បាត់កេរកាល បាត់ពូជនាឡិ បាត់សាវតារ ។

ខៀវ បញ្ញាវុឌ្ឍ

# វគ្គបណ្តុះបណ្តាលចំណេះដឹងគ្រប់គ្រងបណ្ណាល័យ នៅពុទ្ធសាសនបណ្ឌិត្យ, ក្រុងភ្នំពេញ

ព្រះសង្ឃ និងមន្ត្រីនៃមន្ទីរធម្មការ និងសាសនា ខេត្ត-ក្រុងនានា ចំនួន ៣៦ រូប ត្រូវបាននិមន្ត និងអញ្ជើញទៅទទួលការបណ្តុះបណ្តាលចំណេះដឹងគ្រប់គ្រងបណ្ណាល័យ នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ចំនួន ២ សប្តាហ៍ ចាប់ពីថ្ងៃទី ១៨ ដល់ ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៦ ។ វគ្គនេះ បានប្រព្រឹត្តទៅក្រោមការដឹកនាំរបស់លោកបណ្ឌិត ពៅ ធនវឌ្ឍ អ្នកជំនាញការខាងការរៀបចំបណ្ណាល័យ ជាអ្នកបង្ហាត់បង្រៀន ។



លោកបណ្ឌិត ពៅ ធនវឌ្ឍ កំពុងអធិប្បាយសិក្ខាកាម អំពីមុខងារ និងសារសំខាន់ និងពីរបៀបរបបធ្វើការងារ របស់បណ្ណារក្សនៅបណ្ណាល័យ ពិសេស បណ្ណាល័យនៅមូលដ្ឋាន

រីឯចំណេះដឹងដែលបានផ្ដល់ជូនសិក្ខាកាម នៅក្នុងវគ្គនេះ មានជាអាទិ៍ :

ក) តួនាទីរបស់ពុទ្ធសាសនបណ្ឌិត្យ ក្នុងអតីតកាល និងបច្ចុប្បន្នកាល,

ខ) តួនាទី និង មុខងាររបស់បណ្ណាល័យ,

គ) របៀបរបបធ្វើការងាររបស់បណ្ណារក្ស :

- ចុះបញ្ជីសៀវភៅ តាមអក្ខរានុក្រម : អ្នកនិពន្ធ, ចំណងជើង, អ្នកបោះពុម្ពផ្សាយ,
- ចុះបញ្ជីសៀវភៅ តាមប្រភេទប្រធានបទ : ក្រុម, ជំពូក, ផ្នែក,
- ចុះបញ្ជីសៀវភៅពិសេស សំរាប់វចនានុក្រម, គម្ពីរព្រះត្រៃបិដក, សៀវភៅសំរាប់រៀនភាសាបរទេស,
- ឯកសារសមោធាន និងការដកស្រង់អត្ថបទ : អត្ថបទសំខាន់ៗ នៃទស្សនាវដ្ដី, ...

ឃ) ពីអត្ថប្រយោជន៍ និងសារសំខាន់នៃសាស្ត្រាស្លឹករឹត ។

នៅក្នុងរយៈពេលសិក្សានេះដែរ សិក្ខាកាមទាំងអស់ ក៏ត្រូវបានបង្កលក្ខណៈអោយចុះទៅធ្វើទស្សនកិច្ចសិក្សា នៅតាមបណ្ណាល័យនានា ក្នុងក្រុងភ្នំពេញ មានបណ្ណាល័យជាតិ, បណ្ណាល័យសកលវិទ្យាល័យ ភ្នំពេញ, បណ្ណាល័យសារមន្ទីរជាតិ, បណ្ណាល័យតម្កល់សាស្ត្រាស្លឹករឹត នៅវត្តសារាវ័ន ជាដើម ដែលជាប្រការមួយជួយលើកកំពស់ការសិក្សារបស់សិក្ខាកាម អោយមានពន្លឺ និងមើលឃើញទូលំទូលាយ នូវតួនាទីរបស់បណ្ណាល័យ ពិសេស សាខាបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ នៅតាមខេត្ត-ក្រុង ក្នុងការផ្សព្វផ្សាយវប្បធម៌ និងចំណេះដឹងទូទៅក្នុងសាធារណជន សំដៅលើកស្ទួយសីលធម៌រស់នៅក្នុងសង្គម អោយបានល្អឡើងវិញ ។